United Nations
Educational, Scientific and
Cultural Organization

KH/EDU/2002/RP/2
Phnom Penh, May 2008
Original: French

# ចន្លោះខ្លា និង ក្រពើ

ចុះទឹកក្រពើ ឡើងលើខ្លា

# Between a Tiger and a Crocodile

ការសិក្សាបែបនរវិទ្យាស្តីអំពី
ការអនុវត្តន៍តាមបែបប្រពៃណីនិងបែបថ្មី
ក្នុងការបង្ការនិងការដោះស្រាយទំនាស់នៅកម្ពុជា



ហ្វាប៊ីយែន លុយកូ

ភ្នំពេញ, ខែកញ្ញា ឆ្នាំ២០០២

អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ

# កម្មវិធី
# វប្បធម៌សន្តិភាព

# *ការសិក្សាបែបនរវិទ្យាស្តីអំពីការអនុវត្តន៍ តាមបែបប្រពៃណីនិងបែបថ្មីចំពោះ ការបង្ការ និងការដោះស្រាយជម្លោះនៅកម្ពុជា*

ដោយសហការជាមួយ ផ្នែកទស្សនវិជ្ជា និងមនុស្សសាស្ត្រ (SHS/FPH/PHS)
និងការិយាល័យអង្គការយូណេស្កូនៅភ្នំពេញ

*ភ្នំពេញ, កម្ពុជា*
*ខែកញ្ញា ឆ្នាំ២០០២*

*បកប្រែពីភាសាបារាំងមកភាសាខ្មែរដោយៈ* ***កុយ នាម***

*ទស្សនៈដែលលើកឡើងនៅក្នុងរបាយការណ៍នេះ គឺជាយោបល់ផ្ទាល់របស់អ្នកនិពន្ធ មិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការយូណេស្កូឡើយ ។*

*ការជ្រើសរើសទីកន្លែង និងសំភារៈដែលបង្ហាញនៅក្នុងរបាយការណ៍នេះ មិនមែនជាការឆ្លុះបញ្ចាំងនូវទស្សនៈរបស់អង្គការយូណេស្កូ ដែលទាក់ទងនឹងស្ថានភាពច្បាប់នៃប្រទេសណាមួយ, ដែនដី, ទីក្រុង រឺដែនសមត្ថកិច្ច រឺជាការកំណត់ព្រំដែន រឺព្រំប្រទល់ឡើយ ។*

# សេចក្តីថ្លែងអំណរគុណ

*សូមថ្លែងអំណរគុណពិសេសចំពោះលោកស្រី* Moufida Goucha *ប្រធានផ្នែកទស្សនវិជ្ជា និងមនុស្សសាស្ត្រ* ( SHS/FPH/PHS ) *ការិយាល័យយូណេស្កូនៅទីក្រុងប៉ារីស ដែលបានផ្តួចផ្តើមគំរោងនេះ ហើយដែលបានផ្តល់ការទុកចិត្តមកលើរូបខ្ញុំដើម្បីដឹកនាំការសិក្សានេះ ។*

*សូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ចំពោះលោក* Etienne Clément *នាយកការិយាល័យយូណេស្កូនៅភ្នំពេញ ព្រមទាំងបុគ្គលិកការិយាល័យទាំងអស់ ដែលបានទទួលស្វាគមន៍ និងបានជួយខ្ញុំនៅក្នុងកិច្ចការនេះ ។ ខ្ញុំសូមថ្លែងអំណរគុណ ជាពិសេសចំពោះលោកស្រី តី សំបូរណ៌ លោក សម រិទ្ធី លោក ណាំង រាវុធ និង លោក អ៊ឹម សំអុល ដែលបានជួយខ្ញុំក្នុងការបញ្ជាក់ពី ចំណុចវប្បធម៌ និងភាសាខ្លះៗ ។*

*ខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះអ្នកជំនួយការទាំងអស់ អ្នកបកប្រែ ដែលបានជួយខ្ញុំនៅតាមទីកន្លែង ម្តងម្នាក់ៗ អាស្រ័យទៅតាមពេលវេលាអនុគ្រោះ : លោក ជួន ប៉ុក និង លោក សុន ណាវុធ តឹក ។*

*សូមថ្លែងអំណរគុណផងដែរចំពោះលោក* Bolin Davit *។*

*ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក* Bruno Carette, *លោកស្រី* Christine Chanmeau, Marie-Halgand, Luc Iniesta *និង* Nicolas Mouy *ចំពោះការ លើកទឹកចិត្ត និង ការផ្តល់ការណែនាំដល់រូបខ្ញុំ ។*

*សូមថ្លែងអំណរគុណចំពោះលោក សួស្តី ច័ន្ទធុល និង លោក* Fabrice Cerezales *ដែលបានជួយខ្ញុំលើផ្នែកបច្ចេកទេស ។*

*ជាទីបញ្ចប់ទោះបីជាការថ្លែងអំណរគុណនៅមិនទាន់គ្រប់គ្រាន់ក៏ដោយ ក៏ខ្ញុំសូមឧទ្ទិសការសិក្សានេះចំពោះអស់លោក លោកស្រី ដែលបានផ្តល់ពត៌មានអំពីប្រវត្តិរបស់អស់លោក លោកស្រី ហើយដែលពេលខ្លះអស់លោក លោកស្រីត្រូវប្រឈមនិងអារម្មណ៍តឹងតែងយ៉ាងខ្លាំងក្នុងពេលរំលឹកពីអតីតកាល ។*

# សេចក្តីសង្ខេប


សេចក្តីផ្តើម..........................................................................................................១០

១. គោលបំណង..........................................................................................................១០

២. វិធីសាស្ត្រ ..........................................................................................................១២

៣. ព្រំដែននៃការសិក្សា ..........................................................................................................១៨

៤. ការបង្ហាញនិងវិធីសាស្ត្រដោះស្រាយ..........................................................................................................១៩


<u>ជំពូក</u> I

## <u>មរតកពីអតីតកាល</u>


I. ក្របខ័ណ្ឌវប្បធម៌: និរន្តរភាពនៃប្រពៃណី ..........................................................................................................២២

១. រចនាសម្ព័ន្ធទៅតាមទីកន្លែង: សង្គមនៅជនបទតាមបែបប្រពៃណី ..........................................................................................................២២

១.១. ការរស់នៅខ័ណ្ឌដាច់ពីគ្នា និងមនោសញ្ចេតនាអសន្តិសុខ

១.២. សហពន្ធ័ជុំវិញអំណាចកណ្តាល

២. រចនាសម្ព័ន្ធសង្គម: គំរូបែបគ្រួសារ ..........................................................................................................២៦

៣. រចនាសម្ព័ន្ធអំណាច: បណ្តាញផ្លូវការនិងក្រៅផ្លូវការ ..........................................................................................................២៩

៣.១. អំណាចផ្លូវការ

៣.២. បណ្តាញអំណាចក្រៅផ្លូវការ

៤. ការអប់រំ-ក្រមសីលធម៌: ទំងន់វប្បធម៌ ..........................................................................................................៣២

៤.១. ការអប់រំ

៤.២. ក្រមសីលធម៌

៥. តួនាទីរបស់សាសនា ..........................................................................................................៣៧

ព្រះពុទ្ធសាសនា និងការបូជាចំពោះទេវតាម្ចាស់ទឹកម្ចាស់ដី

*សំយោគ* ..........................................................................................................៤៣

II. ក្របខ័ណ្ឌប្រវត្តិសាស្ត្រ: មរតកនៃប្រវត្តិសាស្ត្រពេលថ្មីៗនេះនៅក្នុងការដោះស្រាយទំនាស់នៅមូលដ្ឋាន ........................................................................................................៤៥

១. ប្រពៃណី: សម័យមុនឆ្នាំ ១៩៧០ .................................................................................. ៤៧

១.១. ប្រភពលាយលក្ខ័អក្សរ ........................................................................................៤៧

១.២. ការចងចាំព្រឹត្តិការណ៍ដោយអ្នកនៅរស់និងដោយការនិទាន : ទសវត្សឆ្នាំ ៥០ និង ៦០....................................................................................................... ៤៩

១.២. ក. ទំនាស់ ............................................................................................ ៥១

១.២. ខ. ការដោះស្រាយទំនាស់...................................................................... ៥៣

១.២.គ. ការបង្កាទំនាស់................................ ...............................៧១

*សំយោគ* ....................................................................................................................៨១

២. ការឈានចូលភាពអន្ទការ: ១៩៧០- ១៩៧៥.....................................................................៨៣

២.១. តំបន់ត្រួតត្រាដោយកងទ័ពលោក លន់ នល់ .........................................៨៥

២.២. តំបន់ត្រួតត្រាដោយចលនាតស៊ូ...............................................................................៨៦

*សំយោគ* .................................................................................................................១០៧

៣. ឆ្នាំដែលមានការភ័យខ្លាចខ្លាំង: ១៩៧៥-១៩៧៩ ............................................. ១០៩

៣.១. ការបង្កើតរបៀបរបបថ្មី ...........................................................................១១០

៣.២. ប្រពន្ធ័មួយមានការបង្ខិតបង្ខំដើម្បីត្រួតត្រាប្រជាជន...........................១១៣

- ការតាមដានរក"កំហុស"
- ការរាយការណ៍ និងស្វ័យទិទាន
- ការបែងចែកប្រជាជនតាមប្រភេទ
- ការពង្រឹងប្រព័ន្ធចាប់តាំងពីឆ្នាំ១៩៧៧

*សំយោគ* ............................................................................................................... ១៣១

៤. ការកសាងឡើងវិញដ៏លំបាក: ១៩៧៩-១៩៩៣ ............................................ ១៣៣

៤.១. ការកសាងក្របខ័ណ្ឌជីវភាពឡើងវិញ ........................................................ ១៣៥

- ការវិលត្រឡប់ទៅភូមិកំណើតវិញ
- ការកសាងរចនាសម្ព័ន្ធរដ្ឋបាលឡើងវិញ

- ក្រុមសាមគ្គី និងបញ្ហាដីធ្លី
៤.២. ការដោះស្រាយ និងការបង្កាទំនាស់ប្រចាំថ្ងៃ នៅក្នុងតំបន់ត្រួតត្រាដោយរដ្ឋាភិបាល ........................................................................................១៤៦
- ការវិលត្រឡប់ទៅរកការអនុវត្តន៍តាមប្រពៃណីនៅក្នុងបរិបទផ្សេង
- ការវិលត្រឡប់ទៅរកការអនុវត្តន៍ផ្នែកសាសនាវិញ
៤.៣. ការដោះស្រាយ និងការទប់ស្កាត់ទំនាស់ប្រចាំថ្ងៃ នៅក្នុងតំបន់ត្រួតត្រាដោយចលនាតស៊ូខ្មែរក្រហម................................................................ ១៥២
- ការត្រឡប់ទៅចូលពួកខ្មែរក្រហមវិញ
- និរន្តរភាពនិងការវិវត្តន៍នៃការអនុវត្តន៍របស់ពួកខ្មែរក្រហម
- បញ្ហារួមរស់ជាមួយអតីតខ្មែរក្រហមនៅក្នុងភូមិ
៤.៤. រដ្ឋកម្ពុជាៈ (១៩៨៩-១៩៩៣) ......................................................១៦៦
*សំយោគ* ..................................................................................................១៦៨

## ជំពូក II

## ការដោះស្រាយទំនាស់នៅមូលដ្ឋានៈ សភាពការណ៍បច្ចុប្បន្ននេះ

*១៩៩៣-២០០១*

*(ការរៀបចំឱ្យមានសន្តិភាពនិងការបើកចំហទៅកាន់ពិភពលោកខាងក្រៅ)*

I. ជម្លោះ....... .....................................................................................១៧៣
១. ជម្លោះដីធ្លី ........................................................................................ ១៧៣
១.១. ជម្លោះដីធ្លីនៅស្រុកស្រែ ........................................................ ១៧៣
១.២. ជម្លោះទាក់ទងនឹងការសាងសង់នៅទីក្រុង........................................ ១៧៥
២. ជម្លោះប្តីប្រពន្ធ.................................................................................... ១៧៦
២.១. ហេតុផលដែលលើកឡើង
២.២. ករណីនានា
៣. ជម្លោះជាមួយអ្នកជិតខាង........................................................................ ១៨១
៤. ជម្លោះជាមួយមនុស្សមកពីក្រៅ.................................................................. ១៨២

II. ការដោះស្រាយជម្លោះ ....... ១៨៣
១. ការដោះស្រាយបញ្ហាដោយខ្លួនឯង ....... ១៨៤
១.១. ការជៀសវាង ....... ១៨៤
១.២. ការបំបាត់បញ្ហា ....... ១៨៦
- ការផាត់ចេញពីសង្គម
- ការបំបាត់រូបកាយ
១.៣. ការសន្ទនាជាមួយភាគីម្ខាងទៀត ....... ១៨៩
១.៤.ការឈ្លោះគ្នាជាចំហ ....... ១៩១
២. ការរកជំនួយពីជនទីបី ....... ១៩១
២.១. នីតិវិធី ....... ១៩២
២.២. អ្នកសំរុះសំរួល ....... ១៩៣
- អ្នកសំរុះសំរួលក្រៅផ្លូវការ
- អ្នកសំរុះសំរួលផ្លូវការៈ អាជ្ញាធររដ្ឋបាល
២.៣. ការប្រើប្រាស់ការសំរុះសំរួល ....... ២០១
២.៤. របៀបធ្វើការសំរុះសំរួល ....... ២០៣
- អំណាចនិយម និងបិតុនិយម
- ការបណ្តេញចេញ ការផាត់ចេញ
- ការបំបិទបញ្ហា
- ការព្រមព្រៀងជាមិត្តភាព
- អនុគ្រោះនិយម
- ការដកខ្លួនថយរបស់អ្នកសំរបសំរួល
- ការបញ្ជូនដំណឹងទៅថ្នាក់លើតាមឋានានុក្រម
- ការរត់រកថ្នាក់លើ
- ការធ្វើការសំរុសំរួលនៅតុលាការ
- ការនាំបញ្ចូលគោលការណ៍ថ្មី-សិទ្ធិមនុស្ស
III. ការបង្កា ....... ២៨១

IV. ការកត់សំគាល់លើស្ថានការណ៍បច្ចុប្បន្ន ៖ការបារម្ភពីការផ្លាស់ប្តូរ ............................... ២៨៥

*សំយោគ* ...........................................................................................................៣០១

សេចក្តីសន្និដ្ឋាន...................................................................................................... ៣០៣

អនុសាសន៏.......................................................................................................... ៣០៧

ឧបសម្ពន្ធ ........................................................................................................... ៣១៤

មគ្គុទ្ទេសក៏នៃការជួបសន្ទនា....................................................................................៣១៦

គន្ថនិទ្ទេស.............................................................................................................៣២៥

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. គោលបំណង

ការសិក្សាអំពីសង្គមក្នុងទិដ្ឋភាពជាគុណភាពនេះ គឺសំដៅលើកឡើងពីទំនាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងភូមិនានានៅជនបទ និងនៅទីក្រុង ដើម្បីបានយល់អំពីការអនុវត្តន៍ពីអតីតកាល និងបច្ចុប្បន្ន ក្នុងការទប់ស្កាត់ និងការដោះស្រាយទំនាស់ទាំងនោះ ចាប់តាំងពីសម័យកាលរបស់ជីដូនជីតារហូតដល់សព្វថ្ងៃនេះ ។

### ១.១ និយមន័យនៃពាក្យ

ពាក្យថា "ទំនាស់" ដែលប្រើនៅក្នុងការអង្កេតនេះគឺមានន័យថា "ផលប្រយោជន៍របស់មនុស្សម្នាក់ៗ ឬក្រុមមួយចំនួនដែលហាក់ដូចជាមានលក្ខណៈផ្ទុយទៅនឹងផលប្រយោជន៍របស់មនុស្សម្នាក់ៗ ឬមនុស្ស ឬក្រុមណាមួយផ្សេងទៀត"[១] ។

នៅកម្ពុជា ជនទាំងឡាយណាដែលមានទំនាស់ជាមួយជនដទៃម្នាក់ទៀត ឬក្រុមជនមួយក្រុម ឬក្រុមផ្សេងទៀតបាននិយាយថា ពួកគាត់មានរឿង មានបញ្ហា ឬមានទំនាស់ ។

ទំនាស់នៅទីនេះ ត្រូវបានចាត់ទុកជាបញ្ហា ហើយជាជំលោះដែលកើតមានជារៀងរាល់ថ្ងៃរវាងជនទាំងឡាយ ហើយដែលនាំទៅដល់ការប្រជុំគ្នាមួយដោយការព្រមព្រៀងគ្នាជាមួយភាគីក្នុងជំលោះ និងអ្នកសំរុះសំរួល ដើម្បីស្វែងរកដំណោះស្រាយ ។

ករណីព្រហ្មទ័ណ្ឌដែលបង្ហាញអំពីនិតិវិធីតុលាការ ហើយដែលនាំឱ្យមានការវិនិច្ឆ័យនៅសាលាជំរះក្តី និងមិនត្រូវបានយកមកពិចារណានៅក្នុងការសិក្សានេះទេ ។

អ្វីដែលគេហៅថាការអនុវត្តន៍ជាប្រពៃណីៈ រយៈពេលដែលប្រជាពលរដ្ឋខ្មែរចាត់ទុកជាប្រពៃណី នោះគឺជារយៈពេលនៅមុនពេលសង្គ្រាមមុនឆ្នាំ១៩៧០ ។ ក៏ប៉ុន្តែ ដោយសារការចងចាំនិងការសរសេរមានការខ្វះខាតទិន្នន័យដែលយើងបានទទួលមួយចំនួនកម្រនិយាយដល់សភាពការណ៍មុនទសវត្ស១៩៥០ ណាស់ ។ តាមធម្មតា ការអនុវត្តន៍បែបប្រពៃណីដែលបានទទួលយកមកប្រើនៅកម្ពុជា នៅក្នុងក្របខ័ណ្ឌការស្វែងរកដំណោះស្រាយជំលោះក្រៅផ្លូវការ ហៅថាការសំរុះសំរួល ។ គេក៏ប្រើពាក្យដំណោះស្រាយដែរ ។

---

[1] ជំរើសផ្សេងៗនៃការដោះស្រាយជំលោះ (Janet king, Mathew Rendall) មជ្ឈមណ្ឌលអប់រំផ្នែកច្បាប់របស់សមាគមសកលវិទ្យាល័យ San Francisco of law ៖ គំរោងច្បាប់ខ្មែរនិងប្រជាធិបតេយ្យឆ្នាំ ២០០០ ។ អគ្គបទច្បាប់ខ្មែរ

យើងនឹងបកស្រាយពាក្យសំរុះសំរួលដោយប្រើពាក្យថា ផ្សះផ្សា[2]។ គេនឹងឈានទៅដល់ការសំរបសំរួល មួយរវាងភាគីនានានៅក្នុងជំលោះ ហើយដែលនៅក្នុងការសំរបសំរួលនោះ ភាគីនីមួយៗសាកល្បងរកផល ចំណេញអ្វីមួយ ដោយធ្វើការជជែកគ្នាអំពីការធ្វើសម្បទានទៅឱ្យភាគីម្ខាងទៀត ក្នុងគោលបំណងបញ្ចប់ បញ្ហា និងបំពេញ ចិត្តយ៉ាងសមហេតុផលដល់ភាគីទាំងពីរ។ គឺពុំមានអ្នកឈ្នះ ពុំមានអ្នកចាញ់ទេ។ តាមទ្រឹស្តីភាគីនីមួយៗអាច ឬ ពុំអាចទទួលយកលទ្ធផលនៃការផ្សះផ្សានេះ។

មនុស្សទី៣ដែលភាគីក្នុងទំនាស់បានទទួលស្គាល់ ត្រូវបានកោះហៅឱ្យមកស្តាប់ដើម្បីផ្តល់ការណែនាំ និង ធ្វើសំណូមពរផ្សេងៗ នៅពេលធ្វើការប្រជុំសំរុះសំរួល ដើម្បីធ្វើការដោះស្រាយបញ្ហាឬ រឿងណាមួយ។

ការអនុវត្តន៍បែបថ្មី: ឆ្នាំ១៩៧០បានបង្ហាញពីការបញ្ចប់ការអនុវត្តន៍បែបប្រពៃណី ការធ្លាក់ទៅក្នុង សង្គ្រាម និងការដាក់ឱ្យអនុវត្តន៍បែបបង្ខិតបង្ខំ ហើយមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើងៗ នៅក្នុងតំបន់ត្រួត ត្រាដោយពួកខ្មែរក្រហម។ ពួកខ្មែរក្រហមបានបង្កើតរបបផ្តាច់ការ ដោយបដិសេធទាំងស្រុងពីរបៀបបែប ប្រពៃណី ហើយប្រើរបបដាច់ខាតក្នុងការទប់ស្កាត់ និងដោះស្រាយទំនាស់របស់ប្រជាជន។ ចាប់តាំងពី ឆ្នាំ១៩៧៩ ការអនុវត្តន៍ការផ្សះផ្សាតាមបែប ប្រពៃណីត្រូវបានយកមកប្រតិបត្តិវិញនៅក្នុងតំបន់ដែលបាន រំដោះពីពួកខ្មែរក្រហម ក៏ប៉ុន្តែមានការប្រតិបត្តិក្នុងបរិបទបែបនយោបាយច្រើនជាងកាលពីមុន។ សភាព-ការណ៍បានវិវឌ្ឍន៍ថែមទៀតចាប់តាំងពីឆ្នាំ១៩៩២ ដោយមានជំនួយអន្តរជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ និង ការបើកចំហរឱ្យមានទស្សនៈពីក្រៅប្រទេសស្តីអំពីសិទ្ធិមនុស្ស។

## ១.២ រឿងរ៉ាវដែលជាបញ្ហា

យើងនឹងមើលឃើញថា តើកម្ពុជាបច្ចុប្បន្ននេះត្រូវសាកល្បងធ្វើការសំរបសំរួលបែបណារវាងប្រពៃណី និង បទពិសោធន៍កុម្មុយនីស្តដ៏ឈឺចាប់ជាមួយនឹងសម័យកាលបច្ចុប្បន្ន ដែលគោលការណ៍សិទ្ធិមនុស្សត្រូវបាន បង្ហាត់បង្រៀនដោយអង្គការអន្តជាតិនោះ។

---

[2] "ការសំរុះសំរួល គឺជាដំណើរការនៃការដោះស្រាយជំលោះដែលអាចត្រូវបានប្រើជាជំរើសមួយជំនួសការចាប់ផ្តើមរឿងក្តី ឬជាមធ្យោបាយ មួយដើម្បីធ្វើឱ្យគេចផុតពីរឿងក្តីទោះបីរឿងក្តីបានចាប់ដំណើរការទៅហើយក្តី។ ការសំរុះសំរួលដែលមានដំណើរការនៅសហគមន៍ ត្រូវបាន អនុវត្តន៍ ជាធម្មតានៅថ្នាក់មូលដ្ឋាន និងដឹកនាំដោយមេភូមិ ឬមេឃុំ ឬព្រះសង្ឃ ឬមនុស្សនៅមូលដ្ឋានដែលគេគោរព។ ការសំរុះសំរួលដែល ផ្អែកទៅលើសហគមន៍ តាមធម្មតាមានលក្ខណៈខុសពីប្រពន្ធ័យុត្តិធម៌។ ការសំរុះសំរួលដែលមានដំណើរការនៅសហគមន៍ បានបើកផ្លូវឱ្យមានការ ដោះស្រាយជំលោះបានយ៉ាងឆាប់រហ័ស និងពុំមានលក្ខណៈជាផ្លូវការនៅឡើយក្នុងរឿងក្តី។ តាមប្រពៃណី បញ្ហាជាមួយអ្នកជិតខាង និងអ្នកភូមិ ក៏ដូចជាបញ្ហាគ្រួសារ ការលះលែងគ្នា ការនិយាយកាន់ជើងកូន ឬអំពើហឹង្សាក្នុងគ្រួសារត្រូវបានដោះស្រាយតាមរយៈការសំរុះសំរួល។ ការសំរុះ សំរួលត្រូវផ្អែកលើផលប្រយោជន៍នៃការសំរុះសំរួលនៃភាគីទាំងពីរ និងដោយការរក្សាទំនាក់ទំនងល្អរវាងភាគីទាំងនោះជាមួយសហគមន៍។ វិធីដោះ ស្រាយជំលោះតាមប្រពៃណីនៅតែផ្តល់ក្របខ័ណ្ឌវប្បធម៌យ៉ាងសំខាន់របស់សហគមន៍ សំរាប់ជំរើសដំណោះស្រាយជំលោះនៅកម្ពុជាសព្វថ្ងៃ នេះ "
( ជំរើសផ្សេងៗនៃដំណោះស្រាយជំលោះ Janet king , Matthew Rendall *ទំព័រ* ៤៤ )

នៅក្រោយពេលមានកោលាហល  តើសង្គមកម្ពុជាបច្ចុប្បន្នមានមធ្យោបាយអ្វីខ្លះដើម្បីទប់ស្កាត់និងដោះ-ស្រាយទំនាស់ប្រចាំថ្ងៃ? តើអ្វីខ្លះជាការអនុវត្តន៍បែបប្រពៃណីនៅក្នុងរយៈពេលមុនសង្គ្រាម ហើយតើសព្វថ្ងៃមាននៅសល់អ្វីខ្លះ? បន្ទាប់មក តើអ្វីខ្លះជាការអនុវត្តន៍ដែលដាក់បង្ខំដោយរបបអាជ្ញានិយម ដោយផ្អែកទៅលើគំរូមកពីបរទេស?

តើសង្គមបច្ចុប្បន្នត្រូវដោះស្រាយដូចម្តេច ដើម្បីសំរួលគ្នារវាងប្រពៃណី បទពិសោធន៍ជ្រុលនិយមក្នុងសង្គមបិទជិត ហើយបន្ទាប់មកបច្ចុប្បន្នទៀត  គឺមានការបើកចំហរយ៉ាងលឿនឆ្ពោះទៅរកពិភពបែបសេរីនិយមនោះ?

# ២. វិធីសាស្ត្រ

## ២.១ ការរៀបចំការអង្កេត

### ក. ការស្រាវជ្រាវផ្អែកឯកសារ

ធនធានជាឯកសារសំរាប់ការស្រាវជ្រាវនៅកម្ពុជាមានកំរិតស្តួចស្តើងណាស់។  ឯកសារតិចតួចណាស់ដែលមានកាលពីជំនាន់ដ៏យូរលង់  ហើយត្រូវបានរក្សាទុករហូតដល់សព្វថ្ងៃនេះ។  គេពុំបានឃើញមានឯកសារបែបប្រពៃណីជាលាយល័ក្ខអក្សរពិតប្រាដកទេ។  អក្សរចារឹកខ្លះៗក្នុងសម័យមុនអង្គរ  និងក្នុងសម័យអង្គរបានបង្ហាញអំពីភាពរុងរឿងរបស់ព្រះមហាក្សត្រ   និងព្រះអាទិទេព។   អក្សរចារឹកទាំងនេះបានបង្ហាញតិចតួចអំពីជីវភាពរបស់ប្រជាពលរដ្ឋ។   អត្ថបទដែលបានសរសេរនៅលើសំភារៈនានា   ដែលអាចរិចរិលខូចខាតបានដូចជាស្លឹករឹត   ឬស្បែកសត្វពុំអាចទប់ទល់នឹងធាតុអាកាសនិងសត្វល្អិតបានទេ។  អត្ថបទដែលបានសរសេរនៅលើស្លឹករឹតដែលមាននៅសល់ក្នុងពេលបច្ចុប្បន្ននេះ   ពុំបានសរសេរឡើងវិញពីសម័យកាលមុនសតវត្សទី២០ ទេ។ អត្ថបទទាំងនេះ បានលើកឡើងពីសាសនាដែលព្រះសង្ឃបានចំលងឡើងវិញ។ បន្ថែមពីលើនេះទៀត   គឺមានការបំផ្លិចបំផ្លាញវត្ថុវប្បធម៌ដោយពួកខ្មែរក្រហម   ដោយពុំបានគិតអំពីការសន្សំសំចៃសៀវភៅដែលបានបោះពុម្ពរួចហើយ   និងសៀវភៅផ្សេងៗទៀតដែលបានសរសេរដោយដៃក្នុងផ្នែកពុទ្ធសាសនាទេ។

ទិន្នន័យស្តីអំពីប្រធានបទដែលមានសារៈសំខាន់ដល់យើងគ្រប់គ្នាពុំសូវសំបូរទេ[៣] ។

យើងបែងចែកឯកសារសរសេរជាភាសាបារាំង  និងអង់គ្លេសជាពីរប្រភេទដែលស្របទៅនឹងសម័យកាលពីរនៃប្រវត្តិសាស្ត្រកម្ពុជា :

[3] យើងបានធ្វើការស្រាវជ្រាវសៀវភៅនៅបណ្ណាល័យនានានិងមជ្ឈមណ្ឌលឯកសារនៅទីក្រុង ភ្នំពេញ:

បណ្ណាល័យជាតិ បណ្ណាល័យនៃសារមន្ទីរជាតិ មជ្ឈមណ្ឌលវប្បធម៌បារាំង មូលនិធិសាលាបារាំងចុងបូព៌ា (EFEO) វិទ្យាស្ថានធនធាន អភិវឌ្ឍន៍កម្ពុជា CDRI ក៏ដូចជាប្រភពផ្ទាល់ខ្លួនផ្សេងៗ (ជាភាសាបារាំងនិងអង់គ្លេស)។

- ឯកសារដែលអាចហៅថា "ចាស់"នោះ គឺជាឯកសារដែលមានមុនឆ្នាំ១៩៧០ ជាកាលបរិច្ឆេទដែលកម្ពុជាបានធ្លាក់ក្នុងសង្គ្រាម។ ឯកសារភាគច្រើនស្តីអំពីកម្ពុជាដែលបានបោះពុម្ពហើយ គឺសរសេរដោយជនបរទេស។ ថ្វីបើប្រវត្តិសាស្ត្រ ចារឹកសាស្ត្រ ស្ថាបត្យកម្ម...ត្រូវបានគេបង្ហាញឱ្យបានសមល្មមនោះ (ជាពិសេសដោយសារការងាររបស់អ្នកស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ា[៤]) ទិន្នន័យដែលទាក់ទងទៅនឹងការអនុវត្តន៍នៅក្នុងសង្គមតាមបែបប្រពៃណី គឺពុំសូវសំខាន់ប៉ុន្មានទេ។ យើងគ្រាន់តែអាចស្រង់ទិន្នន័យខ្លះៗដែលមានដោយកម្រហើយ ដែលលើកអំពីទំនាស់ព្រមទាំង របៀបដោះស្រាយប៉ុណ្ណោះ។
- ឯកសារប្រភេទទីពីរ គឺទាក់ទងទៅនិងសម័យកាលថ្មីៗនេះ។ ក្រោយពីរយៈពេលបាត់សម្លេងមួយដែលបានចាប់ផ្តើមពីឆ្នាំ៧០ ដល់ឆ្នាំ៨០(សម័យខ្មែរក្រហម) និងបន្តដោយរបបដែលហាក់ដូចជាបិទជិតឈឹងគឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា[៥] បន្ទាប់មកគឺរដ្ឋកម្ពុជា[៦] សៀវភៅនានាដែលបានបោះពុម្ពស្តីអំពីកម្ពុជា គឺភាគច្រើនសរសេរអំពីឥទ្ធិពលនៃសង្គ្រាម ហើយជាពិសេសសរសេរអំពីរបបខ្មែរក្រហម។ ចាប់តាំងពីឆ្នាំ ១៩៩២-១៩៩៣ (បេសកកម្មរបស់អ៊ុនតាក់[៧] និងការមកដល់ដ៏សន្ធឹកសន្ធាប់នៃអង្គការមនុស្សធម៌) ការអង្កេតខ្លះៗ នៅតាមទីកន្លែងផ្សេងៗបានចាប់ផ្តើមឡើង។ នៅក្នុងបរិបទនៃការបញ្ចប់ជំលោះដោយអាវុធ និងការរុះរើរចនាសម្ព័ន្ធសង្គមយ៉ាងជ្រៅ អង្គការក្រៅរដ្ឋាភិបាល[៨] មួយចំនួនបានធ្វើសកម្មភាពយ៉ាងខ្លាំងក្លានៅក្នុងផ្នែកសិទ្ធិមនុស្ស និងវប្បធម៌សន្តិភាព។ ការបណ្តុះបណ្តាលយ៉ាងច្រើនស្តីអំពីគោលការណ៍សិទ្ធិមនុស្សត្រូវបានធ្វើ ឡើងនៅនឹងទីកន្លែងឬតាមវិទ្យុ។ នៅទីនេះទៀត យើងសង្កេតឃើញមានការខ្វះខាតការសិក្សាឱ្យបានស៊ីជំរៅទៅលើប្រធានបទ។ បែបនេះយើងក៏លើកអំពីការងារដែលមានការទាក់ទងទៅនឹងអំពើហឹង្សាក្នុងគ្រួសារ ការដោះស្រាយទំនាស់ និងតួនាទីនៃអាជ្ញាធរតុលាការឬរដ្ឋបាល ការអនុវត្តន៍បែបចៅហ្វាយនិងកូនចៅ និងការអភិវឌ្ឍន៍សហគមន៍ ព្រមទាំងឯកសារស្តីអំពីទំនាស់ដីធ្លី និងការដោះស្រាយតាមផ្លូវតុលាការ។

សារពត៌មានជាតិ បានផ្តល់ជាប្រភពពត៌មានដ៏មានសារៈ សំខាន់ស្តីពីទំនាស់និងរបៀបដែលសង្គម និងអាជ្ញាធរមូលដ្ឋាន ឬថ្នាក់ជាតិ[៩] បានដោះស្រាយ។

---

4 . សាលាបារាំងចុងបូព៌ា

5 . សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)

6 . រដ្ឋកម្ពុជា (១៩៨៩-១៩៩៣)

7 . អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (១៩៩២-១៩៩៣)

8 . អង្គការក្រៅរដ្ឋាភិបាល

9 . យើងបានធ្វើការផ្ទៀងផ្ទាត់ពត៌មាននៅក្នុងកាសែតជាភាសាបរទេស(Phnom Penh Post)(Cambodia Daily)និង(Cambodge Soir)។ យើងពុំបានមើល កាសែតខ្មែរទេដោយសារពុំមានពេលវេលានិងពុំមានចំណេះដឹងគ្រប់គ្រាន់ផ្នែកភាសាសរសេរ។

## ខ.ការសន្ទនាជាមួយជនដែលបានចូលរួមនៅក្នុងវិស័យវប្បធម៌សន្តិភាព

យើងបានធ្វើការសន្ទនាជាសាច់រឿង ជាមួយអ្នកទទួលខុសត្រូវនៃអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស វិជ្ជាស្ថានស្រាវជ្រាវការលើកស្ទួយវប្បធម៌សន្តិភាព និងការអភិវឌ្ឍន៍ [១០] ។

## ២.២ ការអង្កេតនៅទីកន្លែង

ការសិក្សានេះ ដែលពិនិត្យអំពីប្រធានបទដ៏វែងនិងលំបាកយល់ គឺពុំអាចចាត់ទុកថាលំអិតសព្វជ្រុងជ្រោយអំពីការពិតជាក់ស្តែងប្រចាំថ្ងៃនៅកម្ពុជាទាំងមូលបានទេ។ ការសិក្សានេះ គឺគ្រាន់តែជាការចងក្រងសក្ខីកម្មខ្លះៗដែលអាចផ្តល់ធាតុសំរាប់ការយល់ដឹងជាជំហានដំបូងមានលក្ខណៈជាតំណាង បើគិតតាមបែបពាក្យខាងស្ថិតិចំពោះអ្វីដែលកើតមាននៅក្នុងប្រទេសទាំងមូលប៉ុណ្ណោះ។

ការងារនេះដែលអាចត្រូវបានគេហៅថា "ការសិក្សាបែបនរវិទ្យា" តំរូវឱ្យមានការងារជាបន្ត និងមានលក្ខណៈទូលំទូលាយទៅគ្រប់ទិដ្ឋភាពនៃប្រធានបទដែលយើងគ្រាន់តែបានធ្វើដោយសើរៗ ឬក៏បំភ្លេចចោល ដោយការមិនបានដឹងពីសភាពការណ៍ទូទៅ និងករណីនានាដែលទាក់ទងទៅនឹងទីកន្លែង ឬពេលវេលាជាក់ លាក់នៃ ប្រវត្តិសាស្ត្រកម្ពុជា។

ការសិក្សានេះ(ការរៀបចំ ការសន្ទនា ការវិភាគនិងការសរសេរ) ត្រូវបានធ្វើចាប់ពីខែមករា ដល់ខែតុលា ២០០១។

## ក. កម្រងសំនួរណែនាំការសម្ភាសន៍

ក្រោយពីពេលមានការពិគ្រោះយោបល់គ្នាជាមួយអ្នកដែលធ្វើការនៅក្នុងវិស័យតុលាការ និងសិទ្ធិមនុស្សនៅកម្ពុជា និងបានអានបឋកថានានាមក យើងបានរៀបចំជាកម្រងសំនួរណែនាំការសម្ភាសន៍ដែលមានលក្ខណៈប្លែកៗគ្នាទៅតាមប្រភេទនៃមនុស្សដែលត្រូវបានសាកសួរ។

ការជួបសម្ភាសន៍ទាំងឡាយត្រូវបានធ្វើឡើងក្នុងលក្ខណៈក្រៅផ្លូវការនៅក្នុងក្របខ័ណ្ឌនៃជីវភាព ឬការងារប្រចាំថ្ងៃ ជួនកាលមានលក្ខណៈជាបុគ្គលផ្ទាល់ខ្លួន ជួនកាលមានលក្ខណៈជាក្រុមពិភាក្សាពិសេស។

---

[10] . ដំណើរការនៃការជួបសន្ទនា :

- ការបង្ហាញគំរោងសិក្សា
- ការពិភាក្សាដោយចំហរ : ទំនាស់នៅកម្ពុជា ដំណោះស្រាយទំនាស់កាលពីអតីតកាល និងបច្ចុប្បន្ននេះ។
- សភាពនៃទីកន្លែង : ជាអចិន្ត្រៃយ៍និងមានការផ្លាស់ប្តូរ។ ហេតុផលដែលបានលើក ឡើង។
- សំណើ : តើកម្មវិធីដែលកំពុងប្រព្រឹត្តទៅមានអ្វីខ្លះ? និងតើការណែនាំសំរាប់ពេល អនាគតមានអ្វីខ្លះ ?

ការជួបពិភាក្សាជាសាច់រឿងចំនួន១២៦លើក ត្រូវបានធ្វើនៅក្នុងខេត្តចំនួនប្រាំនៅកម្ពុជាក្នុងរយៈពេលពីរខែ។ រយៈពេលនៃការជួបសន្ទនានីមួយៗពុំមានកំណត់ទៀងទាត់ទេ គឺអាចមានរយៈពេលពីមួយម៉ោងទៅបីម៉ោងដោយយោងទៅលើដៃគូសន្ទនា។ ការជួបសន្ទនាទាំងនោះ ត្រូវបានដឹកនាំដោយនរវិទូបរទេសមួយរូបដែលនិយាយភាសាខ្មែរ និងមានអ្នកបកប្រែភាសាខ្មែរម្នាក់ជាជំនួយការ។ វិធីនៃការជួបសម្ភាសន៍ជាសាច់រឿងនោះ ត្រូវបានផ្តល់ឯកសិទ្ធិដោយទុកពេលឱ្យជនដែលត្រូវសាកសួរនោះបញ្ចេញវាចាប្រកបដោយវិចារណញ្ញាណ។

ការជួបសន្ទនាត្រូវបានធ្វើទៅតាមកំរងសំនួរណែនាំ ដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ជាមុន។ ការជួបសម្ភាសន៍ត្រូវបានចំលងឡើងវិញដោយផ្ទាល់ជាភាសាបារាំង ក្រោយពីការបកប្រែភាសាដោយផ្ទាល់មាត់នៃអ្នកបកប្រែ និងមាននរវិទូមួយរូបជាអ្នកត្រួតពិនិត្យ។

## ខ. ការជ្រើសរើសអ្នកដែលត្រូវធ្វើការសាកសួរ

ការជ្រើសរើសមនុស្សដើម្បីធ្វើការសាកសួរ ត្រូវធ្វើដោយសមស្របទៅតាមគោលបំណងនៃការសិក្សា។ ប្រភេទជាចំបងពីរត្រូវបានកំណត់គឺ អ្នកណាដែលចូលធ្វើអន្តរាគមន៍នៅក្នុងការផ្សះផ្សាទំនាស់ និងអ្នកដែលពាក់ព័ន្ធក្នុងទំនាស់។ កំរងសំនួរណែនាំមួយប្រើសំរាប់តែជនក្នុងប្រភេទមួយ។

### ***អ្នកចូលធ្វើអន្តរាគមន៍ក្នុងការសំរុះសំរួលទំនាស់ :***

- អាជ្ញាធររដ្ឋបាលដែលចូលរួមនៅក្នុងការដោះស្រាយទំនាស់ នៅមូលដ្ឋាននៅគ្រប់ជាន់ថ្នាក់គឺៈ មេក្រុម មេភូមិ អនុប្រធានភូមិទទួលបន្ទុកសន្តិសុខ មេឃុំ ឬប្រធានសង្កាត់ នរគបាលស្រុក អភិបាលខេត្តរងទទួលបន្ទុកបញ្ហា ដីធ្លី ក្រឡាបញ្ជី ចៅក្រមនៅតុលាការខេត្ត ព្រមទាំងអតីតកម្មាភិបាលខ្មែរក្រហម។
- អ្នកដែលមានឥទ្ធិពល ឬត្រូវគេគោរពៈ អាចារ្យ, អ្នកចាស់ទុំ, ចៅអធិការវត្ត, អ្នកជំនួញ, យោធា, តំណាង គណបក្សនយោបាយ។

ការជួបសម្ភាសន៍បានប្រព្រឹត្តទៅតាមការរៀបចំនៅក្នុងកំរងសំនួរណែនាំ។ ក្រោយពីការធ្វើសំនួរដំបូងផ្នែកស្ថិតិ និងសង្គមដែលទាក់ទងទៅនឹងទីកន្លែងមក យើងបានលើកយកប្រធានបទស្តីពីទំនាស់នៅមូលដ្ឋាន និងការដោះស្រាយទំនាស់ដោយពិនិត្យទៅតាមសម័យកាលខុសៗគ្នានៃប្រវត្តិសាស្ត្រកម្ពុជា ក្នុងពេលកន្លងទៅថ្មីៗនេះ ដែលគូសន្ទនាបានរស់នៅ។ បន្ទាប់មកទៀតការសំខាន់គឺត្រូវនិយាយសង្កត់ទៅលើរឿងរ៉ាវផ្ទាល់ខ្លួនស្តីអំពីការដោះស្រាយទំនាស់នៃគូសន្ទនាតាមរយៈនៃការសិក្សាអំពីករណីនីមួយៗ។

ចំណុចចុងក្រោយនេះ អាចនាំឱ្យស្គាល់អ្នកដែលមានការពាក់ពន្ធ័នៅក្នុងទំនាស់ ហើយយើងអាចជួបជាមួយជនទាំងនោះដោយផ្ទាល់នៅពេលក្រោយ ក្នុងគោលបំណងប្រមូលយកការបកស្រាយពីជននោះស្តីអំពី

ទំនាស់ និងការផ្សះផ្សាគ្នា។ បន្ទាប់មក យើងអាចទាញយកចំនុចនានាមកពីធ្វើការប្រៀបធៀបរួមជាមួយ និងទស្សនៈរបស់អាជ្ញាធរដែលបានដឹកនាំធ្វើការផ្សះផ្សា ដើម្បីឱ្យបានយល់កាន់តែច្បាស់អំពីដំណើរការ និងធ្វើការវាយតំលៃអំពី ប្រសិទ្ធភាពនៃការផ្សះផ្សា។

***អ្នកជាប់ពាក់ពន្ធ័នៅក្នុងទំនាស់ ឬដែលបានឃើញទំនាស់កើតមាន :***

- អ្នកនៅក្នុងភូមិ ឬនៅទីក្រុងដែលត្រូវបានស្គាល់ថាជាអ្នកបានជួយដោះស្រាយទំនាស់។
- អ្នកនៅក្នុងភូមិ ឬនៅទីក្រុងដែលត្រូវបានជ្រើសរើសដោយមិនចំពោះ។

កំរងសំណួរណែនាំបានធ្វើឱ្យគូរសន្ទនានិយាយរៀបរាប់អំពីទំនាស់ និងការសំរុះសំរួល (ការប្រព្រឹត្តិទៅការវាយតំលៃពីលទ្ធផល) ។

នៅក្នុងករណីដែលអាចធ្វើទៅបាន យើងបានធ្វើឱ្យមានការជួបសន្ទនាទល់មុខគ្នា។ ដូចនេះយើងបានស្តាប់ទស្សនៈប្លែកៗ ដើម្បីប្រមូលយោបល់ទាំងពីរខាងដែលកើតចេញមកពីការពិតតែមួយ។

ឧទាហរណ៍ៈ តំណាងរដ្ឋាភិបាលមូលដ្ឋាន កសិករក្រីក្រ សមាជិកនៃគណបក្សនយោបាយប្រឆាំង។

ឧទាហរណ៍ៈ ជននៅក្នុងទីក្រុង និងជននៅក្នុងភូមិ ដែលបានទទួលរងគ្រោះដោយពួកខ្មែរក្រហមហៅថា "ប្រជាជនថ្មី"។ ជនដែលបានរស់នៅជាមួយពួកខ្មែរក្រហមហៅថា "ប្រជាជនចាស់" ហើយជនដែលបានចូលរួមក្នុងរបបខ្មែរក្រហម (កម្មាភិបាលយោធា) ។

ឧទាហរណ៍ : អ្នកប្តឹង និងភាគីត្រូវបានចោទប្រកាន់នៅក្នុងទំនាស់

**គ. ការជ្រើសរើសទីកន្លែងអង្កេត :**

ការសិក្សាបានចាប់ផ្តើមធ្វើនៅទីក្រុងភ្នំពេញ។ សំនួរលើកដំបូងជាច្រើនបានតំរង់មគ្គុទេសក៍ជួបសន្ទនារកការពិតជាក់ស្តែងនៅនឹងទីកន្លែង(ការជ្រើសរើសរឿងដែលត្រូវលើកឡើងនិងជនដែលត្រូវសាកសួរ)។ ការសិក្សា ក៏ត្រូវធ្វើបន្តនៅក្នុងតំបន់ជនបទនៅក្នុងភូមិជាច្រើននៅក្នុងខេត្តកំពង់ស្ពឺ កណ្តាល កំពត សៀមរាប ស្វាយរៀង និងទីកដីក្រុងកែប។

យើងបានធ្វើការងារយ៉ាងស៊ីជំរៅបំផុតនៅក្នុងមណ្ឌលកែប ខេត្តកំពត។ នៅទីនោះយើងបានធ្វើការសិក្សាមួយយ៉ាងពិសេសពោរពេញទៅដោយទិន្នន័យផ្នែកសង្គម ប្រវត្តិសាស្ត្រ និងសេដ្ឋកិច្ច។ នៅទីនោះភារកិច្ចរបស់យើងមានភាពងាយស្រួលយ៉ាងធំធេង ដោយសារអង្គការយូណេស្កូបានធ្វើការនៅក្នុងតំបន់នោះតាំង

តែពីឆ្នាំ១៩៩៨ ក្នុងក្របខ័ណ្ឌនៃកម្មវិធីអក្ខរកម្មសំរាប់ស្ត្រីនិងយុវនារី (គំរោង "ការអប់រំដើម្បីសន្តិភាព និងការអភិវឌ្ឍន៍មនុស្ស" ដែលដឹកនាំដោយលោកស្រី តឺ សំបូរណ៍) ។

យើងបានជ្រើសរើសសភាពការណ៍ខុសគ្នាចំនួនពីរៈ ភូមិចាស់ចំនួនបួនស្ថិតនៅតំបន់នៅវាលរាបៈកោះសោម អំពែង ព្រៃតាកុយ ភ្នំលាវ និងភូមិធំថ្មីមួយគឺ ចំការបី (មានភូមិបី ) ដែលស្ថិតនៅក្បែរជើងភ្នំ។ ភូមិទាំងបី(កោះសោម អំពែង ព្រៃតាកុយ) ឋិតនៅក្នុងឃុំអង្គោល។ ភូមិលាវ និងចំការបីឋិតនៅក្នុងឃុំពងទឹក។

ដើម្បីរក្សារកុំឱ្យគេដឹងឈ្មោះមេប្រធានភូមិទាំងនោះយើងពុំបានរៀបរាប់ឈ្មោះភូមិទាំងនោះទេ។ ផ្ទុយទៅវិញ នៅពេលដែលយើងលើកអំពីភូមិពិសេសដោយឡែកណាមួយដូចជាចំការបី យើងបានបញ្ជាក់ថាមានភូមិថ្មីមួយ។

ឆ្នាំ១៩៧០ ចង្អុលបង្ហាញពីការចាប់ផ្តើមនៃសង្គ្រាម។ ប្រជាពលរដ្ឋមួយភាគដែលរស់នៅក្នុងភូមិចាស់ទាំងនោះក៏ដូចជាប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំក្បែរៗនោះ បានចូលរួមនៅក្នុងការតស៊ូប្រដាប់អាវុធនៅក្នុងព្រៃលើភ្នំ ដោយមានឈ្មោះថាខ្មែរក្រហម។ អស់រយៈពេលជាងពីរទសវត្ស អ្នកដែលរស់នៅលើភ្នំត្រូវប្រឈមមុខគ្នាធ្វើការងាររួមគ្នា ឬសហការគ្នាជាមួយអ្នកនៅវាលរាបអស់រយៈពេលជាច្រើនឆ្នាំនៃប្រវត្តិ-សាស្ត្រមិនទៀងទាត់នេះ។

នៅឆ្នាំ១៩៩៤ យុទ្ធជននៅក្នុងព្រៃបានប្រគល់អាវុធដើម្បីធ្វើការចុះចូល។ យុទ្ធជនខ្លះបានវិលត្រលប់ទៅភូមិកំណើតរបស់ខ្លួននៅតំបន់វាលរាប ហើយភាគច្រើនបានតាំងទីលំនៅៗលើដីដែលគេបានកាប់ឆ្ការហើយដែលរដ្ឋាភិបាលបានប្រគល់ឱ្យ។ យុទ្ធជនទាំងនោះបានបង្កើតភូមិថ្មីមួយឈ្មោះចំការបី ដែលឋិតនៅជើងភ្នំ។ ការបែងចែកដីធ្លីឱ្យកាប់ឆ្ការដែលអាជ្ញាធរមូលដ្ឋានបានប្រគល់ឱ្យ បានទាក់ទាញប្រជាពលរដ្ឋដែលមកពីភូមិចាស់ក្បែរៗនេះ ប្រជាជនមកពីបណ្តាខេត្តផ្សេងៗ និងការស្រេកឃ្លានរបស់មន្ត្រីជាន់ខ្ពស់ និងយោធានៅក្នុងខេត្តកំពត និងមកពីទីក្រុងភ្នំពេញ។ ទំនាស់ដីធ្លីមានលក្ខណៈស្រួចស្រាវណាស់។ ការដោះស្រាយទំនាស់បើកឱកាសឱ្យមានកម្មភាព ខុសៗគ្នាដែលចាប់ផ្តើមពីការសំរុះសំរួលនៅថ្នាក់ភូមិរហូតដល់ស្ថាប័នខ្ពស់បំផុតរបស់ប្រទេស និងអង្គការសិទ្ធិមនុស្សនានា។

យើងក៏បានធ្វើការនៅក្នុងភូមិថ្មីៗដែលឋិតនៅឃុំត្រពាំងភ្លាំង និងតាកែននៅក្នុងស្រុកឈូកដែរ។ ភូមិទាំងនោះត្រូវបានបង្កើតនៅឆ្នាំ១៩៩៦ ដើម្បីឱ្យប្រជាពលរដ្ឋអតីតខ្មែរក្រហម ដែលចុះចូលបានតាំងទីលំនៅ។ នៅពេល ក្រោយមកទៀតប្រជាពលរដ្ឋផ្សេងទៀតដែលពុំមានដីធ្លីក៏បានមកតាំងទីលំនៅដែរ។

ដូចនេះ វត្ថុធាតុសំខាន់ៗដោយឡែកនៃប្រវត្តិសាស្ត្រកម្ពុជាក្នុងរយៈពេលថ្មីៗកន្លងមកនេះ និងបញ្ហាសព្វថ្ងៃនេះគឺបានប្រមូលផ្តុំគ្នានៅក្នុងតំបន់នេះ ។

ប្រជាពលរដ្ឋទាំងពីរក្រុមនេះដែលបច្ចុប្បន្នកំពុងរស់នៅរួមគ្នាមាន វប្បធម៌ និងសង្គមដូចគ្នា ក៏ប៉ុន្តែកាលពីមុនបានរស់តាមរបៀបខុសគ្នានៅក្នុងប្រវត្តិសាស្ត្រកន្លងមកថ្មីៗនេះ (ខ្មែរក្រហមនិងប្រជាពលរដ្ឋកសិករបែបប្រពៃណី ) ។

នៅក្នុងខេត្តស្វាយរៀង និងជាពិសេសនៅខេត្តសៀមរាប ការសិក្សាមានលក្ខណៈងាយស្រួលយ៉ាងច្រើន ដោយហេតុថាអ្នកស្រាវជ្រាវធ្លាប់បានស្នាក់នៅក្នុងខេត្តទាំងពីរនេះ ។

## ៣.ព្រំដែននៃការសិក្សា

### ប្រវត្តិសាស្ត្រស៊ីជំរៅមានតិចតួច

ភាពខ្វះខាតនៃឯកសារសរសេរ និងប្រវត្តិសាស្ត្រប្រពៃណីដែលមានលក្ខណៈស៊ីជំរៅ និងដែលបាននិយាយតៗគ្នា ឬតាមការចងចាំបានធ្វើឱ្យមានការលំបាកដល់ការប្រៀបធៀបទៅនឹងសម័យអតីតកាល ។ លើសពីនេះទៀត គេត្រូវតែបញ្ជាក់ថា សក្ខីកម្មជាច្រើនត្រូវបានជីតដាមដោយការឃោសនានៅពេលដែលគេរំលឹកពីអនុស្សាវរីយ៍ពីអតីតកាល ។

ពត៌មានដែលទាក់ទងទៅនឹងសម័យមុនឆ្នាំ១៩៧០ ពុំមានលក្ខណៈច្បាស់លាស់ទេ គឺច្រើនលើកឡើងពីភាពចំរុងចំរាញ់នៃសម័យកាលប្រកបដោយសុភមង្គលនៅមុនពេលសង្គ្រាម ។ ជាបន្ថែមទៀតគឺជាការលំបាកណាស់ក្នុងការជួបជាមួយមនុស្សចាស់ៗដែលនឹកឃើញភាពលំអិតនៃសម័យកាលនោះ ។
ដោយសារសង្គ្រាម និងលក្ខណៈសុខាភិបាលមិនល្អ អាយុកាលមធ្យមបានធ្លាក់ចុះយ៉ាងខ្លាំងគឺ ធ្លាក់មកដល់អាយុ ៤៥ ឆ្នាំ ។

### ការស្រាវជ្រាវតាមឯកសារនៅមានកំរិត

ពេលវេលាកំណត់សំរាប់ការស្រាវជ្រាវតាមឯកសារ គ្រាន់តែផ្តល់ឱ្យយើងនូវវិធីសាស្ត្រមួយស្តីអំពីប្រធានបទមួយដ៏ទូលំទូលាយហើយដែលទាមទារឱ្យមានការស្រាវជ្រាវយ៉ាងជ្រាលជ្រៅបំផុត ។ ដូចនេះ អត្ថបទច្បាប់ចាស់និងថ្មី រឿងនិទាន របាយការណ៍អង្កេតរបស់តុលាការនិងប៉ុស្តិ៍នគរបាល ឯកសារនៅឯនាយសមុទ្រ នៅអិចអង់ប្រូវ៉ង់ **(Aix en Provence)** ដែលមានប្រយោជន៍ខ្លាំងសំរាប់ការយល់ដឹងពីវិស័យមួយដែលគេបានធ្វើការ សិក្សា មិនបានលើកយកមកពិគ្រោះទូលំទូលាយទេ ។

### ភាពស្មុគស្មាញនៃសភាពការណ៍នៅទីកន្លែង

ការងារនៅទីកន្លែង បាននាំឱ្យយើងរកឃើញប្រធានបទធំៗដែលមានៈ ដើមកំណើត និងប្រភេទនៃទំនាស់ (បញ្ហាដីធ្លី ជំលោះក្នុងគ្រួសារនិងជាមួយអ្នកជិតខាង បំណុល...) ព្រមទាំងការអនុវត្តន៍តាមបែបប្រពៃណីនៃការសំរុះសំរួល។ ថ្វីបើគំរោងទូទៅត្រូវបានរៀបចំរួចហើយ លក្ខណៈពិសេសនៃទីកន្លែងនីមួយៗក៏នឹងបង្ហាញពីភាពស្មុគ្រស្មាញយ៉ាងខ្លាំងនៃសភាពការណ៍កម្ពុជាបច្ចុប្បន្ននេះ ហើយដែលគួរកុំសុំអាងទៅលើនឹងទិន្នន័យដែលមានខ្លាំងពេក។ ដូចនេះបញ្ហាដីធ្លីពុំមានលក្ខណៈដូចគ្នាទេ ប្រសិនបើគេនិយាយអំពីសង្កាត់មួយនៅទីក្រុង (បញ្ហាសំណង់ដែលមានសិទ្ធិពាក់កណ្តាលម្នាក់) នៅភូមិចាស់មួយ (ដីពីដូនតា ច្បាប់ប្រពៃណី), នៅភូមិថ្មីមួយ (ដីដែលបានចែកនៅឆ្នាំ១៩៧៩ ច្បាប់ដីធ្លីផ្លូវការ) នៅភូមិចាស់មួយដែលដីត្រូវបានគេចែករួចហើយ (ទំនាស់រវាងច្បាប់ប្រពៃណី និងច្បាប់ដីធ្លីផ្លូវការ) នៅភូមិមួយដែលមានប្រជាជនចាស់ និងប្រជាជនថ្មីរស់នៅក្នុងភូមិមួយដែលរហូតមកដល់ ពេលថ្មីនេះឋិតនៅក្រោមការគ្រប់គ្រងរបស់អ្នកតស៊ូប្រដាប់អាវុធ និងនៅភូមិមួយដែលមានសន្តិភាពតាំងពីឆ្នាំ១៩៧៩ ។ ម្យ៉ាងវិញទៀត នៅក្នុងប្រទេសមួយដែលមានអស្ថេរភាពយ៉ាងខ្លាំងបំផុតដោយសារតែសង្គ្រាមជាច្រើនឆ្នាំ គេសង្កេតឃើញថាវិធីនៃការសម្រុះសម្រួល និងការដោះស្រាយទំនាស់ មានការប្រែប្រួលយ៉ាងខ្លាំង ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត (ភាពនៅឆ្ងាយ ឬនៅជិតមជ្ឈមណ្ឌលរដ្ឋបាលខេត្ត បុគ្គលិកលក្ខណៈរបស់ប្រធានភូមិ កំរិតនៃការអប់រំរបស់ប្រធានភូមិ...) ។ ដូចយើងបង្ហាញអំពីការផ្សាំដោយជោគជ័យតិចឬច្រើនរវាង ធាតុផ្សេងៗនៃវប្បធម៌ប្រពៃណីដែលមានការរេចរិលយ៉ាងខ្លាំង រួមជាមួយនិងចំនួនតិចតួចនៃច្បាប់ថ្មីៗ និងគោលការណ៍សិទ្ធិមនុស្សដែលមានការយល់ដឹងតិចឬច្រើន។

ការនេះក៏ត្រូវគិតអំពីការបន្ថែមភាពស្មុគស្មាញនៃប្រព័ន្ធមិនផ្លូវការទៀតផង។ ដូចនេះ នៅពីខាងក្រោយរចនាសម្ព័ន្ធរដ្ឋបាលផ្លូវការ គឺមានបណ្តាញអំណាចគ្រួសារ សេដ្ឋកិច្ច និង នយោបាយ... ដែលមានអានុភាពយ៉ាងទូលំទូលាយនៅក្នុងការសំរុះសំរួល។ បណ្តាញអំណាចទាំងនោះមានការលំបាកយល់ណាស់នៅពេលដែលការស្នាក់នៅទីកន្លែងមួយមានរយៈ ពេលខ្លី។

គឺដោយសារតែការសិក្សាស៊ីជំរៅនៃករណីដូចនេះ និងដោយបានទទួលការទុកចិត្តពីជនដែលត្រូវបានសាកសួរដែលរឿងរ៉ាវទាំងឡាយអាចចាប់ផ្តើមប្រមូលផ្តុំបានយ៉ាងល្អ។

## ៤. ការបង្ហាញនិងវិធីសាស្ត្រដោះស្រាយ

ប្រធានបទត្រូវបានដាក់នៅក្នុងបរិបទសង្គម វប្បធម៌ និងប្រវត្តិសាស្ត្រ។ ភាគទីមួយលើកឡើងអំពីក្របខ័ណ្ឌសង្គម-វប្បធម៌ ហើយសាកល្បងលើកឡើងអំពីតួនាទីចំបងនៃវប្បធម៌ នៅក្នុងការបណ្តុះបណ្តាលអាកប្បកិរិយា។ នៅក្នុងភាគបន្តបន្ទាប់មកទៀត យើងរកប្រធានបទនៃទំនាស់ និងប្រភេទផ្សេងៗក្នុងការ

ដាក់ឈ្មោះទំនាស់ និងការដោះស្រាយទំនាស់ទាំងនោះ នៅក្នុងសម័យកាលដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជាដែលកន្លងមកថ្មីៗនេះ។

ដូចនេះ គឺជាការសំខាន់ជាទីបំផុតក្នុងការដាក់ប្រធានបទជាថ្មីនៅក្នុងក្របខ័ណ្ឌវប្បធម៌ និងបរិបទប្រវត្តិ-សាស្ត្រកន្លងមកថ្មីៗនេះ ដើម្បីអាចធ្វើឱ្យយើងយល់យ៉ាងងាយស្រួលអំពីសភាពការណ៍បច្ចុប្បន្ននេះ។ ដើម្បីឱ្យបានយល់កាន់តែច្បាស់អំពីការពិតនៅនិងទីកន្លែង យើងបានឱ្យតំលៃមុនគេចំពោះពាក្យសម្ដីរបស់ជនដែលយើងបានជួបប្រទះ។ ការសិក្សានេះបានរក្សាទុកពេលមួយភាគធំសំរាប់ការរៀបរាប់ផ្ទាល់មាត់។ ការជួបសន្ទនាត្រូវបានធ្វើឡើងជាភាគ១។ ត្រូវតែផ្ដល់ឱកាសឱ្យអតីតខ្មែរក្រហមនិយាយ ដើម្បីរកការបំភ្លឺពីក្នុងសម័យកាលវឹកវររបស់ពួកគេ (ការលើកអំពីអតីតខ្មែរក្រហមនៅក្នុងអត្ថបទនេះគឺសំដៅជាពិសេសទៅលើអតីតកម្មាភិបាលខ្មែរក្រហម)។

ដើម្បីធានាភាពសំងាត់នៃជនទាំងឡាយដែលបានជួបសន្ទនាឈ្មោះជនទាំងនោះ យើងបានប្ដូរឈ្មោះជនទាំងនេះ ហើយឈ្មោះភូមិក៏ពុំមានដែរ។

ជំពូក១

# មរតកពីអតីតកាល

# I. ក្របខ័ណ្ឌវប្បធម៌

## និរន្តភាពនៃវប្បធម៌

### ១. រចនាសម្ព័ន្ធទៅតាមទីកន្លែង: សង្គមជនបទមួយតាមបែបប្រពៃណី

នៅពីខាងក្រោយអាការៈនៃភាពទំនើបនៅរាជធានី សង្គមកម្ពុជានៅតែមានលក្ខណៈបែបនៅជនបទ និង តាមបែបប្រពៃណីយ៉ាងជ្រាលជ្រៅ។ ទោះបីមានការរេចរិលយ៉ាងខ្លាំងក៏ដោយ ក៏អត្តសញ្ញាណនៃវប្បធម៌ចាស់ នៅតែចាក់ឫសយ៉ាងរឹងមាំដដែល។ លោក Jacques Nepote[១១] បានសរសេរអំពីប្រជាជនមួយដែលមាន លក្ខណៈចាស់បំផុតៈ "ខ្មែរគឺជាប្រជាជនតែមួយគត់នៃប្រវត្តិសាស្ត្រឥណ្ឌូចិន ដែលបានរស់នៅរបៀបបែប នោះ"។

៨៥%នៃប្រជាពលរដ្ឋបានរស់នៅក្នុងតំបន់ស្រុកស្រែចំការ។ អ្នកខ្លះរស់នៅក្នុងតំបន់ដាច់ស្រយាលតែឯង។ ក្រុមអ្នករស់នៅក្នុងតំបន់នោះហាក់ដូចជាមានស្វ័យភាព ភាពមិនប្រែប្រួលចំពោះការផ្លាស់ប្តូរ និងមាន មនោសញ្ចេតនាមិនទុកចិត្ត និងអសន្តិសុខចំពោះប្រជាពលរដ្ឋដែលចូលមកពីក្រៅក្រុម។

មនោសញ្ចេតនាដែលដាក់ខ្លួនជាសមាជិកនៃប្រជាជាតិរួមមួយ គឺនៅទាប។ ប្រសិនបើយោងទៅលើពាក្យ ថា"យើង"ដែលសំដៅថា"ខ្មែរយើង"ការយោងនេះហាក់ដូចជាមានន័យថាការដកចេញច្រើនជាងគឺជនទាំង ឡាយណាដែលមិនដូចយើង) ការដាក់បញ្ចូល (យើងទាំងអស់គ្នា)។ ដូចនេះនៅកំរិតថ្នាក់ជាតិ គេសង្កេត ឃើញមានការផ្តុំគ្នានៅជុំវិញមនុស្សម្នាក់ដែលមានអំណាចគឺ ព្រះមហាក្សត្រ ឥស្សរជននយោបាយ ឬ អង្គការមួយ។

### ១.១ ការរស់នៅខ័ណ្ឌដាច់ពីគ្នា និងមនោសញ្ចេតនាអសន្តិសុខ

ការរស់នៅខ័ណ្ឌដាច់ពីគ្នា និងមនោសញ្ចេតនាអសន្តិសុខនេះអាចពន្យល់បានខ្លះនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ពីអតីតកាលនិងក្នុងពេលកន្លងមកថ្មីៗនេះ។ គឺវាកើតមកអំពីការធ្វើសង្គ្រាមដ៏យូរអង្វែង ការបាក់បែកផ្ទៃ ក្នុង ការចែកបក្សពួក ការបះបោរ ការបែងចែកទឹកដី ការដាក់ប្រទេសឱ្យនៅក្រោមអាណាព្យាបាលរបស់ បរទេស។ បច្ចុប្បន្ននេះទៀត កម្ពុជាទើបតែងើបពីសង្គ្រាមដែលមានរយៈពេលជិត៣០ឆ្នាំ និងអំពើហិង្សា ដ៏ធ្ងន់ធ្ងរបំផុត។

នៅក្នុងសង្គមដែលមានការបែងចែកជាផ្នែកតូចៗនេះ សេចក្តីត្រូវការផ្នែកសន្តិសុខផ្ទាល់ខ្លួន និងការខ្លាច ក្រែងធ្វើឱ្យមានការរំខានដល់សណ្តាប់ធ្នាប់មានកំរិតធំធេងណាស់។ មនុស្សម្នាក់ៗចូលចិត្តរស់នៅក្នុងផ្ទះ

[11]. Nepote Jacques ញាតិនិងអង្គការសង្គមកម្ពុជាថ្មី–ការសិក្សាផ្នែកបូព៌ា Olizane 1992 *ទំព័រ* ១៩១

របស់ខ្លួន និងសំអាងតែទៅលើកំលាំងរបស់ខ្លួនផ្ទាល់។ គេមិនសូវហ៊ានធ្វើដំណើរទៅណាឆ្ងាយទេ។ នៅក្រៅទីកដីនៅជនបទ ផលប្រយោជន៍ចំបងគឺទីផ្សារនៅទីក្រុង។ គេកាត់បន្ថយឱ្យបានជាអប្បបរិមាពីការជួបទាក់ទងជាមួយរាជការ។

គេសង្កេតឃើញមានភាពខុសគ្នាខ្លាំងរវាងប្រជាពលរដ្ឋដែលរស់នៅស្រុកស្រែចំការ( អ្នកស្រែចំការ) និងប្រជាពលរដ្ឋដែលរស់នៅទីក្រុង (រាជធានី និងទីប្រជុំជននៅខេត្ត) អ្នកផ្សារ (ជនលក់ដូរនៅផ្សារ)។ ប្រជាពលរដ្ឋ នៅទីក្រុងដែលភាគច្រើនជាកូនកាត់ចិនមានសកម្មភាពយ៉ាងសកម្មនៅក្នុងផ្នែកពាណិជ្ជកម្ម និងរាជការ។ ពួកខ្មែរ ក្រហមបានធ្វើឱ្យភាពខុសគ្នានេះមានលក្ខណៈលេចធ្លោឡើង។

ដោយសារតែការរស់នៅរាយប៉ាយនៅលើទឹកដីមួយធំទូលំទូលាយឬ ដោយសារការប្រមូលផ្តុំជាភូមិតូចៗ គ្រួសារជាច្រើនបានប្រមូលផ្តុំគ្នារស់នៅក្រោមពាក្យ រដ្ឋបាលដែនដីរួមគឺ ភូមិ ភូមិរួមគ្នាច្រើនបានជាឃុំ។ ឃុំរួមគ្នាបង្កើតបានជាស្រុកដែលឋិតនៅក្រោមអាជ្ញាធររបស់ខេត្តផ្ទាល់ ហើយដែលពុំបានមើលឃើញការពិតជាក់ស្តែងរបស់សង្គមជានិច្ចបានទេ។

សញ្ញាណចាស់នៃពាក្យស្រុក និងភូមិ ទោះបីគេបានយកមកប្រើប្រាស់ឡើងវិញជាពាក្យរដ្ឋបាលក្តី ស្រុក និងភូមិគឺសំគាល់អំពីទីកន្លែងរស់នៅនៅក្នុងពេលវេលាណាមួយ។ ស្រុកនិងភូមិពុំមានគំនូសព្រំដែនច្បាស់-លាស់ទេហើយអាចផ្លាស់ប្តូរឈ្មោះ និងទំរង់ឬទីកន្លែងបានយ៉ាងងាយទៀតផង[១២]។ ដូចនេះ ស្រុក និងភូមិបង្កើតបានជា រចនាសម្ព័ន្ធ "យើង" ដែលជារចនាសម្ព័ន្ធមានន័យត្រឹមទប់ទល់នឹងអ្វីៗមកពីខាងក្រៅច្រើនជាងរចនាសម្ព័ន្ធដែលមានន័យជាសហគមន៍តែមួយនិងរួបរួមគ្នា[១៣]។ នៅក្នុងផ្ទៃក្នុងនៃក្រុមលំនៅដ្ឋានទាំងនោះ ចង្កោមក្រុមគ្រួសារតូចៗ បានរស់នៅជាមួយគ្នាក្នុងលក្ខណៈបែបឯករាជ្យម្ចាស់ការ។

តាមនិយមន័យចាស់ ស្រុកគឺ ជាតំបន់សក្តិភូមិមួយដែលដឹកនាំដោយនាហ្មឺនមួយរូបឬដែលត្រូវប្រគល់ឱ្យដាច់មុខទៅគ្រួសារស្តេចមួយអង្គ។ បច្ចុប្បន្ននេះ គេនៅតែប្រកាន់យកការយល់តាមបែបប្រពៃណីចំពោះអត្តសញ្ញាណសង្គមសាស្ត្រនិងភូមិសាស្ត្រមិនច្បាស់លាស់ ហើយនៅក្នុងរយៈពេលនោះមានការផ្តល់អត្ថន័យតិចតួចពេកសំរាប់ការបកប្រែថា "ស្រុក"។ ដោយពុំធ្វើការវិលត្រលប់ទៅរកភូមិសាស្ត្រពិតប្រាកដ ស្រុកគឺសំគាល់ទីកដី មួយតាមខ្នាតនៃភូមិ គឺជាទីកដីប្រជុំភូមិច្រើនឬ ឃុំមួយ។

"ស្រុក" របស់ខ្មែរហាក់ដូចជាមានលក្ខណៈបិទជិតដោយខ្លួនឯង។ ស្រុកពុំទទួលយកជនណាមកពីខាងក្រៅដោយងាយៗទេ។ "គេពុំស្គាល់ដើមកំណើតនៃជនទាំងនោះ គេពុំស្គាល់ចិត្តរបស់អ្នកទាំងអស់នោះទេ"។

---

12 . ប្រជាជនបានធ្វើការផ្លាស់ប្តូរទីកន្លែង និងបានផ្តល់ឈ្មោះទីកន្លែងចាស់ នៅពេលបានទៅដល់ទីកន្លែងថ្មី។

13. នៅទសវត្សឆ្នាំ៦០នរវិទូម្នាក់ឈ្មោះ May Hebihara បានស្នាក់នៅអស់រយៈពេលជាច្រើនខែនៅក្នុងភូមិខ្មែរមួយ។ គាត់បានសរសេរពីរចនាសម្ព័ន្ធនៃ ប្រព័ន្ធធូររលុងមួយ ប៉ុន្តែបានធ្វើការកត់សំគាល់ថាអត្ថន័យនៃពាក្យសហគមន៍បានកើតមានហើយ។

ប្រសិនបើបុរសម្នាក់ដែលមកពីខាងក្រៅហើយបានរៀបអាពាហ៍ពិពាហ៍ជាមួយនារីម្នាក់ បានបង្ហាញអាកប្បកិរិយាសមរម្យដូចអ្នកស្រុកក្នុងភូមិ បុរសនោះអាចរាប់បញ្ចូលជាមួយគេបាននៅក្នុងពេលនោះ។ ចំពោះករណីមនុស្សចម្លែកដែលពុំមានអ្វីជាប់ទាក់ទងនឹងទឹកដីនោះ មនុស្សគេគិតជាអ្នកផ្សេង។ ជននោះតែងបានទទួលការមន្ទិលសង្ស័យដោយសារតែមានអតីតកាលមិនច្បាស់លាស់ ហើយមានការលំបាកណាស់ដើម្បីធ្វើឱ្យគេយល់ព្រមទទួលយកមកនៅក្នុងស្រុកភូមិ[១៤] ។

ដើម្បីបានកន្លែងរស់នៅក្នុងស្រុក ជននោះត្រូវគោរពរបៀបរបបដែលមានស្រាប់ឬតំលៃសំខាន់ៗដោយពុំធ្វើឱ្យមានការកត់សំគាល់ មិនរស់នៅឃ្លាតឆ្ងាយពីគេ ឬពុំបង្កើតបញ្ហាអ្វីឡើយ ។

ជនមួយរូបដែលមានលក្ខណៈខុសប្លែកពីអ្នកដទៃ ដោយសារតែអាកប្បកិរិយាដោយឡែកណាមួយនឹងត្រូវដាក់ឱ្យនៅក្រៅសៃវៀន។ ដំណោះស្រាយសំរាប់ជននោះគឺ ត្រូវបញ្ចូលខ្លួនទៅតាមពុម្ភរបស់សង្គម ហើយនឹងត្រូវបានទទួលការគ្រាប្រណី ឬក៏ត្រូវផ្តន្ទាទោសដោយការបណ្តេញចេញពីសង្គម[១៥] ឬត្រូវចាកចេញពីភូមិ ស្រុក (ប្តូរស្រុក ចូលកងទ័ព ចូលបួសធ្វើជាសង្ឃ)។ នៅក្នុងករណីមានកំហុសធ្ងន់ធ្ងរ ជននោះអាចត្រូវប្រជាជនសំលាប់ចោលដោយចោទប្រកាន់ថា ជននោះជាគ្រូធ្មប់។ ដូចនេះ មនុស្សដែលគេចាត់ថា"ខុសគេ" ជននោះត្រូវគេសង្ស័យថា ចេះប្រើមន្តអាគមគាថា ឬខ្មោចបីសាច។

លោក A Forest[១៦] បានសង្កត់ធ្ងន់ទៅលើរបៀបរបបនៃការរៀបចំសង្គមខ្មែរជាក្រុមតូចៗ និងការរស់ខ័ណ្ឌដាច់ពីគ្នាក្នុងទំនាក់ទំនងសង្គម ដែលមិនអនុញ្ញាតឱ្យបុគ្គលម្នាក់បញ្ចេញមតិដោយផ្ទាល់។ "ខ្ញុំគិតថាគេបានលើកស្ទួយឱ្យមានការបង្កើតស្រុកថ្មីជាច្រើន ដោយសារតែបញ្ហាចាំបាច់ខាងសេដ្ឋកិច្ច ក៏ដូចជាបញ្ហាជាក់ស្តែងដែលកើតឡើងរវាងអ្នករុករានដីធ្លីនិងប្រជាពលរដ្ឋចាស់ដែលរស់នៅក្នុងស្រុក។ ដូចគ្នានេះដែរ ការផ្ទុះអំពើឃោរឃៅ បែបឆ្កួតលីលាប្រៀបបានទៅនឹងអាម៉ុកនៅប្រទេសម៉ាឡេស៊ី ដែលនាំឱ្យមានប្រតិកម្មខ្លះៗតាមបែបជាបុគ្គល ឬជាសមូហភាព ហើយបើខ្ញុំមើលទៅឃើញហាក់ដូចជាការសំដែងភាពចលាចលរបស់បុគ្គលទាំងនោះ ហើយរបៀបរបបមូលដ្ឋានដែលបង្កើតឡើងដោយសារតែទំនាក់ទំនងរវាងបុគ្គល និងបុគ្គលសុទ្ធសាទត្រូវមានជំរើសពីរគឺ ជនណាម្នាក់ត្រូវចូលជាធ្លុងមួយជាមួយគេ ឬជននោះត្រូវបដិសេធចេញ"។

---

14 . នេះគឺជាករណីរបស់ជនទាំងឡាយដែលបានធ្វើមាតុភូមិនិវត្តន៍នៅឆ្នាំ ១៩៩៣ ហើយដែលបានតាំងទីលំនៅនៅក្នុងភុមិចាស់។

15 . ការហ៊ុំពទ្ធ័ដោយស្ងៀមស្ងាត់របស់ប្រជាជនមូលដ្ឋានប្រឆាំងនឹងជនមួយរូបដែលសង្គមបានចាត់ទុកថាដូចជាស្លាប់ទៅហើយ។

16 . Forest Alain : អ្នកតា " នៅកម្ពុជា L harmattan ១៩៩២ *ទំព័រ* ៩១។

គេក៏លើកឡើងអំពីការលំបាករស់នៅដោយសារតែការសង់ផ្ទះជិតគ្នាពេក។ នៅក្នុងការអភិប្រាយពីរបៀបសង់ផ្ទះដែលរៀបចំនិងបោះពុម្ពផ្សាយដោយ Madeleine Giteau គេឃើញថាគឺជាការប្រាកដណាស់ដែលគេណែនាំឱ្យសង់ផ្ទះឆ្ងាយពីអ្នកជិតខាង។ ការសង់ផ្ទះជិតគ្នាពេកគឺជាប្រភពជំលោះ[១៧]។

## ១.២ សហព័ន្ធជុំវិញអំណាចកណ្ដាល

ការបង្កើតភូមិតូចៗដោយឥតរបៀបរៀបរយ ដូចផ្កាយនៅជុំវិញអំណាចមួយដែលនៅឆ្ងាយ (ព្រះមហាក្សត្រ ឬអ្នកនយោបាយដែលមានឥទ្ធិពល) មិនអាចប្រព្រឹត្តទៅបានល្អទេ បើពុំត្រឡប់ទៅរករចនាសម្ពន្ធ័ចាស់ទេ។ ចំពោះរឿងនេះ Tambiah[១៨] បានប្រៀបធៀបសង្គមខ្មែរទៅនិងកញ្ចុមផ្កាយមួយ។

តាមរបៀបចាស់ ព្រះមហាក្សត្រគង់នៅកណ្ដាលក្រុមនាហ្មឺនឬក្រុមព្រះអង្គម្ចាស់។ កិច្ចសន្យាដែលផ្អែកលើទំនាក់ទំនងគ្រួសារត្រូវបានបង្កើតឡើងរវាងអ្នកទាំងអស់នោះ: ឪពុក កូន ចៅ[១៩] ។ ព្រះមហាក្សត្រធានាកិច្ចការពារ (ប្រយុទ្ធជាមួយសត្រូវ រកយុត្តិធម៌ ធានាវិបុលភាពរបស់ប្រទេសដោយអំណាចនៃព្រះអាទិទេព) ទាមទារភក្ដីភាពជាថ្នូរ (ដង្វាយ សួយសារអាករ កំណែន ការជ្រើសរើសពលទាហានក្នុងពេលមានសង្គ្រាម)។ សម្ពន្ធ័ភាព នេះគឺធ្វើទៅតាមកាលៈទេសៈ និងមានលក្ខណៈទន់ភ្លន់។

ដើម្បីបានទទួលរូបភាពជានិមិត្តរូបរបស់កម្ពុជាឡើងវិញ ព្រះមហាក្សត្រទ្រង់គង់នៅចំកណ្ដាលលើភ្នំ ហើយពិនិត្យមើលទៅលើក្រុមផ្ទះតូចៗរបស់ប្រជាពលរដ្ឋដែលមានដីស្រែលិចទឹកឬ ព្រៃឈើពទ្ធ័ជុំវិញ។ តាមប្រពៃណីរបស់ប្រជាពលរដ្ឋ ព្រះមហាក្សត្រ គឺជាតំណាងព្រះអាទិទេពនៅលើទឹកដី។ ព្រះមហាក្សត្រជាអ្នកផ្ដល់កំលាំងធម្មជាតិ[២០] ។ ព្រះមហាក្សត្រជាម្ចាស់ទឹកម្ចាស់ដី។ តាមច្បាប់ប្រពៃណី ទឹកដីជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រ ហើយអ្នកធ្វើស្រែចំការដែលដាំដុះដីនោះជាអ្នកទទួលផលពីដីនោះ។

នៅពេលបច្ចុប្បន្ននេះ នៅពីខាងក្រោយអង្គការរដ្ឋបាលផ្លូវការ និងការលើកបញ្ហាឆ្លងកាត់អាជ្ញាធរមូលដ្ឋាន នៅពេលដែលបញ្ហានោះត្រូវបានចាត់ទុកថាមានសារៈសំខាន់នោះ រចនាសម្ពន្ធនេះនៅតែឋិតនៅឯថ្នាក់

---

[17] . Giteau Madeleine "ក្បួនស្ថាបត្យកម្មខ្លីមួយរបស់ខ្មែរក្នុងសម័យទំនើប" សិល្បអាស៊ី លេខ ២៤ "ស្ដីអំពីសំណង់អាគារធំៗ" សិល្បៈអាស៊ី២៤ .១៩៧១។

[18] . TAMBIAH S.J "អ្នកឈ្នះនិងអ្នកចាញ់ក្នុងពិភពលោក": ការសិក្សាអំពីព្រះពុទ្ធ សាសនានិងនយោបាយនៅប្រទេសថៃប្រឆាំងនិងប្រវត្តិសាវតារ . Cambridge សារពតិមានរបស់សកលវិទ្យាល័យ Cambridge ១៩៧៦ ។

[19] . ព្រះមហាក្សត្រមានព្រះបរមនាមថា សម្ដេចឪ ហើយនៅក្នុងសុន្ទរកថា ព្រះមហាក្សត្រហៅ ប្រជាជនថាកូនចៅ។

[20]. តាមប្រពៃណីរបស់ប្រទេសដែលគេធ្វើដំណាំស្រូវឡើងទឹក ព្រះមហាក្សត្រត្រូវបាននិយាយ ថាជាអ្នកបញ្ជោទឹក។ នៅពេលរៀបចំពិធីបុណ្យអុំទូកនៅទីក្រុង ភ្នំពេញគឺព្រះមហាក្សត្រជានិមិត្តរូបនៃការបើកទឹកឱ្យហូរចេញពីទន្លេសាបនិងហូរត្រឡប់ទៅទន្លេមេគង្គវិញ។ ព្រះមហាក្សត្រក៏រៀបចំ ពិធីច្រត់ព្រះនង្គ័លដែរ។ព្រះអង្គភ្ជួរព្រះស្រែជារៀងរាល់ឆ្នាំដើម្បីជាការចាប់ផ្ដើមរដូវភ្ជួររាស់។ (ប៉ុន្តែសព្វថ្ងៃនេះគេសង្កេតឃើញថាកសិករពុំបាន គោរពកាលបរិច្ឆេទនៃការរៀប ចំពិធីនេះទេ ហើយបានចាប់ផ្ដើមធ្វើការភ្ជួររាស់កាលណាគេមើលទៅឃើញថាមានលក្ខណៈល្អហើយ)។

ក្រោមជានិច្ច។ ការប្រមូលផ្ទះជាក្រុមតូចឬធំ គឺដើម្បីធ្វើការប្រុងប្រយ័ត្នក្នុងការរក្សាឯករាជភាពចំពោះមុខរដ្ឋអំណាចសាធារណៈមូលដ្ឋាន ប៉ុន្តែនៅតែទទួលស្គាល់អាជ្ញាធរថ្នាក់ជាតិដដែល។ ដូចនេះ នៅពេលមានបញ្ហាសំខាន់មួយដែលពុំអាចដោះស្រាយបាននៅក្នុងមូលដ្ឋាន ប្រជាពលរដ្ឋជាអ្នកភូមិបាននាំគ្នាធ្វើដំណើរទៅរាជធានី ដើម្បីធ្វើការតវ៉ាអំពីរឿងហេតុរបស់គាត់ដល់ព្រះមហាក្សត្រ ឬក៏ដូចជាការអនុវត្តន៍សព្វថ្ងៃនេះ គឺទៅប្តឹងរដ្ឋសភា។

តាមការយល់របស់លោក Jean Delvert លក្ខណៈបែបសិប្បនិម្មិតនៃការបែងចែករដ្ឋបាលទាំងនោះពុំបានទទួលជោគជ័យពិតប្រាកដនៅក្នុងការបញ្ជា"មហាជនកសិករ ដែលពុំមានសណ្តាប់ធ្នាប់ និងពុំមានរចនាសម្ពន្ធ័នោះឡើយ"។ ភាពជិតស្និទ្ធិផ្នែកសង្គមសាស្ត្រមានកំរិតដ៏ទាបបំផុត: "ផ្ទះគឺជាអង្គធាតុសំខាន់ណាស់នៅទីនោះ[២១]"។

## ២.រចនាសម្ព័ន្ធសង្គម: គំរូគ្រួសារ

ឯកតាសង្គមដែលបានលើកឡើងនេះគឺគ្រួសារដែលមានតែ: ឪពុកម្តាយនិងកូនដែលរស់នៅក្រោមដំបូលផ្ទះតែមួយ។ ចំណងទាក់ទងជាមួយគ្រួសារផ្សេងទៀតមានលក្ខណៈទូលំទូលាយសមគួរ ទោះបីមានជាប់សាច់ឈាមឬមិនជាប់សាច់ឈាមជាមួយគ្នាក៏ដោយ។ ក្រោយពីពេលរៀបអាពាហ៍ពិពាហ៍កូនជាមួយជនមកពីក្រៅគ្រួសារជាស្ទួលរួចហើយគូស្រករថ្មីនេះស្វែងរកការតាំងទីលំនៅក្នុងផ្ទះថ្មីមួយ ។ "គេពុំធ្វើឱ្យមានការលាយឡំគ្នានៅក្នុងលំនៅដ្ឋានទេ" ។ ប្រសិនបើដីធ្លីរបស់ឪពុកម្តាយមានទំហំធំល្មមអាចឱ្យគូថ្មីនេះបានគូស្រករថ្មីនេះនឹងតាំងទីលំនៅនៅក្បែរផ្ទះរបស់ឪពុកម្តាយ។ ភូមិបែបប្រពៃណីបង្កើតឡើងដោយការបំបែកជាគ្រួសារថ្មីក្រោយពេលរៀបការកូន។ គ្រួសារថ្មីនីមួយៗនេះតែងយកគំរូតាមមាតាបិតា។ ក្រោយពីកូនបានចាកចេញពីលំនៅដ្ឋានគ្រួសារមកចំណងទាក់ទងកាន់តែរយាល ជាពិសេសករណីដូចជាកូនប្រុសដែលចាកចេញទៅរស់នៅភូមិខាងភរិយារបស់ខ្លួន[២២]។ ទំនាស់រវាងឪពុកម្តាយនិងកូនមានមិនតិចទេសព្វថ្ងៃនេះ។ ប្រសិនបើពុំមានដីធ្លីគ្រាប់គ្រាន់សំរាប់ចិញ្ចឹមគ្រួសារទាំងមូល ឬប្រសិនបើទំនាស់កើតមានជាញឹកញាប់ គ្រួសារមួយអាចចាកចេញទៅទីកន្លែងផ្សេងទៀតដើម្បី រុករានដីធ្លីនិងបង្កើតក្រុមផ្ទះមួយថ្មីទៀត។ កំណើនប្រជាពលរដ្ឋក្នុងពេលកន្លងមកថ្មីៗនេះ បានបង្កើតឱ្យមានបញ្ហានៃការរស់នៅច្របល់ចូលគ្នា[២៣]។ នៅទីក្រុងភ្នំពេញ សភាពការណ៍មានការលំបាកខ្លាំងណាស់។ ផ្ទះសំបែងមានតំលៃខ្ពស់ណាស់ និងពុំអាចឱ្យគូស្រករថ្មីៗអាចជួលឬទិញបានទេ។

---

[21] . DELVERT Jean កសិករខ្មែរ L Harmattan read ១៩៩៤ . ២០២ . ២០៤.

[22] . ទីកន្លែងថ្មី (ប្តីប្រពន្ធបានសង់ផ្ទះរបស់ខ្លួនដាច់ដោយឡែកពីផ្ទះមាតាបិតា) ដោយមាននិន្នាការទៅរកភូមិខាងម្តាយ( ប្តីប្រពន្ធរស់នៅក្នុងភូមិរបស់ប្រពន្ធ ប៉ុន្តែពុំមែន នៅក្នុងផ្ទះនៃគ្រួសាររបស់ប្រពន្ធឡើយ )និយមន័យរបស់ May Ebihera *ទំព័រ* ១០៩។

[23] . កំណើនប្រជាជននៅក្រោយសម័យរបបខ្មែរក្រហម ១៩៧៩

ក្រុមគ្រួសារជាច្រើនត្រូវរស់នៅជាមួយគ្នានៅក្នុងចន្លោះមួយចង្អៀត ហើយភាគច្រើនគ្មានការបិទបាំង។ នៅក្នុងសង្គមតូចនេះ ការគ្រប់គ្រងទីធ្លារួមនេះមានការលំបាកណាស់។

កង្វល់ចង់បានឯករាជភាពបានដក់ជាប់នៅក្នុងអារម្មណ៍របស់មនុស្សចាស់ៗ។ គាត់បានសំរេចថាត្រូវតែរស់នៅឱ្យឆ្ងាយពីផ្ទះគ្រួសារធំ[២៤] និងដើម្បីដកខ្លួនថយទៅនៅខ្ទមតូចនៅក្បែរនោះឬទៅនៅវត្ត ដើម្បីរៀបចំខ្លួនសំរាប់ការចាប់ជាតិក្រោយទៀត។
ជាញឹកញាប់ គេមិនអាចចងចាំពង្សាវលីលើសពីជីដូនជីតាទេ។ បណ្តាញជួយគ្នាទៅវិញទៅមកក្នុងគ្រួសារនៅមាន ប៉ុន្តែបណ្តាញនោះមានលក្ខណៈរយាលបន្តិច។ ជារឿយៗការរស់នៅជិតខាងគ្នាប្រសើរជាងទំនាក់ទំនងជាញាតិសន្តាន។

គ្រួសារដែលមានដើមកំណើតចិន បានរក្សាឱ្យមានចំណងទាក់ទងក្នុងគ្រួសារ និងសាមគ្គីភាពយ៉ាងទូលំទូលាយ។ ករណីនេះមានជាប់ពាក់ពន្ធ័ភាគច្រើនជាមួយប្រជាពលរដ្ឋដែលរស់នៅទីក្រុង។

ដូចនេះ គ្រួសារនីមួយៗបានស្វែងរកវិធានការតាមលទ្ធភាពដែលអាចធ្វើទៅបានដោយខ្លួនឯងផ្ទាល់ ។ បណ្តាញសាមគ្គីភាព និងការជួយគ្នាទៅវិញទៅមកមានលក្ខណៈថយចុះ។ ដូចនេះ Ovesen , Trankell និង Ojendal បានធ្វើការសន្និដ្ឋានថា "ផ្ទះនីមួយៗ គឺជាកោះមួយ[២៥]"។

ប្រព័ន្ធដែលខ័ណ្ឌជាកង់ៗនិងចង្អៀតនេះនៅតែដាក់ឱ្យប្រើរបៀបរបបបែបបង្ខិតបង្ខំ និងតាមលំដាប់ឋានានុក្រមហើយដែលនាទី សិទ្ធិ និងករណីយកិច្ចរបស់ជនម្នាក់ៗត្រូវបានកំណត់តាមអាយុ ភេទ ឋានៈ និងទ្រព្យសម្បត្តិ។ គេយល់ព្រមទទួលយកតួនាទីនិងសភាពរបស់គេទៅតាមប្រពៃណីដោយមិនឆ្ងល់ ឬតវ៉ាអ្វីទាំងអស់។

របៀបរបបនេះដែលមានលំនាំដូចៗគ្នានៅគ្រប់ជាន់ថ្នាក់នៃសង្គមខ្មែរ មានដំណើរការតាមគំរូបែបគ្រួសារ។ វិន័យដែលដាក់ឱ្យប្រតិបត្តិនិងការប្រុងប្រយ័ត្នចំពោះមាតា បិតា និងកូនច្បង ក៏កើតចេញមកពីរបៀបរបបនោះដែរ។

គេបានរំលឹកឱ្យមនុស្សម្នាក់ៗប្រព្រឹត្តទៅតាមតួនាទីរបស់ខ្លួន ហើយកុំធ្វើឱ្យមានការរំខានដល់របៀបរបបនេះបើពុំនោះសោតទេនឹងទទួលការដាក់ទណ្ឌកម្ម[២៦]។

---

24 . កូនដែលកាន់កាប់ផ្ទះសំបែង ជាទូទៅគឺកូនស្រីពៅបានបន្តធានាសន្តិសុខនិងត្រូវការស្បៀងអាហារដល់មាតាបិតាចាស់ជរា។

25 . OVESEN J.TRANKELL Ing Britt , OJENDAL Jaokin "នាំពេលដែលផ្ទះសំបែងនីមួយៗជាទីពុំនឹង"។ អង្គការសង្គម និងរចនាសម្ព័ន្ធអំណាចនៅក្នុងបរិបទនៃប្រទេសកម្ពុជារបាយការណ៍ស្រាវជ្រាវUppasala នៅក្នុងផ្នែកនរវិទ្យាវប្បធម៌លេខ ១៥ . ១៩៩៦។

ទោះបីជាប្រពៃណីចាត់ទុកថាមិនល្អក្តី ការលះលែងគ្នានៅអាចប្រព្រឹត្តទៅបាន។ គេបានដាក់ទោសទៅលើប្រពន្ធក្នុងករណីដែលមូលហេតុនៃការលះលែងគ្នានោះត្រូវបានទំលាក់ទោសទៅលើប្រពន្ធ ដោយចាត់ទុកថា "ប្រពន្ធមានអត្តចរឹកមិនល្អ"។

នៅក្នុងប្រពន្ធ័ដែលមានរបាំង និងការយកគំរូបែបគ្រួសារធ្វើជាមូលដ្ឋានសំរាប់ការរស់នៅដូច្នេះ តើសង្គមស៊ីវិលរបៀបនៃការជួយគ្នា និងសាមគ្គីភាពមានលក្ខណៈដូចម្តេចដែរ ?

តាមប្រពៃណីខ្មែរ ក្នុងពេលថ្មីៗកន្លងមកនេះ គេពុំបានសង្កេតឃើញ ឬ បានសង្កេតឃើញតិចតួច ពីទំរង់សមាគម ស្ថាប័នសង្គម ឬក្រុមមនុស្សដែលរួបរួមគ្នាដើម្បីការពារផលប្រយោជន៏រួម។ ប្រសិនបើរូបភាពបែបនេះមានធ្វើកាលពីអតីតកាល គេអាចនិយាយបានថា គេបានបង្កើតដោយសារតែការភ័យខ្លាច ជាជាងអ្វីដែលគេបានជ្រើសរើសដោយមានការព្រមព្រៀងគ្នា[២៧]។ បច្ចុប្បន្ននេះ អង្គការមនុស្សធមិជាច្រើនបានសាកល្បងដោយលំបាកក្នុងការបង្កើតប្រព័ន្ធ "អភិវឌ្ឍន៏សហគមន៏" និងសមាគម។

នៅមុនឆ្នាំ១៩៧០ គេបានសង្កេតឃើញមានសមាគមជាច្រើនដែលមានគោលបំណងជាសារវ័ន្តដើម្បីជួយគ្រួសារដូចជាការជួយចាត់ចែងក្នុងពិធីបុណ្យខ្មោច។ គឺមានសមាគមមរណៈសង្គ្រោះជាច្រើន។ គេក៏សង្កេតឃើញមានសមាគមចានដែលអាចឱ្យសមាជិករបស់ខ្លួនប្រើប្រាស់សំភារៈចាំបាច់នានា នៅក្នុងពេលមានពិធីបុណ្យមួយ (ចាន កំរាល កែវ...)។ ដូចនេះគេអាចសង្កេតឃើញថា ជាទូទៅគឺមានសមាគមជាច្រើនត្រូវបានបង្កើតឡើងដោយ គ្រួសារដែលមានដើមកំណើតចិន។

តាមរយៈលោក Jacque Nepote[២៨] សាមគ្គីភាពកើតមានទៅតាមតែ "កាលៈទេសៈតាមបែបស្ម័គ្រចិត្ត និងដោយជាប់កិច្ចសន្យា" នៅពេលដែលអ្វីៗបានប្រព្រឹត្តទៅបានល្អ ទៅតាមគោលដៅសមាគមនឹងផ្តល់អត្ថប្រយោជន៏ជូនសមាជិកគ្រប់ៗរូប។ នៅពេលណាមានកើតវិបត្តិអ្វីមួយ គេដកខ្លួនឱ្យឆ្ងាយពីអ្នកដែលជួបការលំបាក។ គេអាចមើលឃើញថាជាការធ្វើទោសមួយតាមបែបកម្មផល ឬជាទណ្ឌកម្មរបស់ទេវតា។ ការខិតចូលទៅជិតជនទាំងឡាយដែលមានការលំបាកខ្លាំងពេក ហើយដែលនៅក្រៅបណ្តាញគ្រួសារអាចនាំឱ្យមានទុកលំបាក ដល់ខ្លួនឯង។

---

[26]. Pou saveros កំរងច្បាប់ ច្បាប់ហៃមហាជនបទ ៣៨-៣៩ (វំលោភមានកិត្តិយស បុណ្យខ្ពង់ខ្ពស់ធំទូលាយ អ្នកតូចកុំមើលងាយ កុំធ្មឹមកាយនឹងលោកឡើយ។ បើស្តីឱ្យមានក្រែង កុំជល់ជែងពាក្យលោកឡើយ តតបថែមរឿយៗ មានទោសហើយខ្លួនអាស្រូវ ។)៖ "តួអង្គ សំខាន់ៗដែលមានឋានន្តរស័ក្តិ និង កិត្តិយសឋានន្តរស័ក្តិខ្ពស់ និងមានអានុភាពប្រជាជនតូចតាម មិនត្រូវមើលងាយមិនត្រូវសាកល្បងធ្វើការប្រៀបធៀបជាមួយអ្នកមានបុណ្យស័ក្តិខ្ពស់ឡើយ "។ "គេត្រូវតែនិយាយដោយការប្រុងប្រយត្ន័ជាមួយជនទាំងនោះ គេមិនជជែកពិភាក្សាអំពីគោលបំណង ឬការសំរេចរបស់គាត់ឡើយ និងមិនចចេសឆ្លើយតប ជាមួយជនទាំងនោះឡើយ ពីព្រោះនឹងបានរងទណ្ឌកម្មនិងបាត់បង់កិត្តិយស "។

[27] . របបសហគមន៏ជ្រុលនៃកម្ពុជាប្រជាធិតេយ្យរបស់ពួកខ្មែរក្រហម និងក្រុមសាមគ្គីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

[28] . NEPOTE 1992 *ទំព័រ* ១៨-២០។

ប៉ុន្តែសាមគ្គីភាព ត្រូវបានគេសង្កេតឃើញនៅក្នុងករណីមានទុក្ខភ័យរួមគ្នា។ នៅឆ្នាំ១៩៧៩ ក្រោយពីរបបខ្មែរក្រហម ប្រជាពលរដ្ឋបានវិលត្រលប់ទៅផ្ទះសំបែងនៅភូមិកំណើតរបស់ខ្លួន។ អ្វីៗទាំង អស់ត្រូវកសាងឡើងវិញ។ នៅតាមទីកន្លែងផ្សេងៗ មនុស្សជាច្រើនដែលបានសាកសួរបានបង្ហាញអំពីសាមគ្គីភាពដ៏ធំធេងនៅក្នុងរយៈពេលមួយឆ្នាំដំបូង។ បន្ទាប់មក គ្រួសារនីមួយៗបានខិតខំប្រឹងប្រែងដើម្បីការរស់រានមានជីវិតតាមមធ្យោបាយរបស់ខ្លួនផ្ទាល់ដូចករណីសព្វថ្ងៃនេះដែរ។ គ្រួសារនីមួយៗទទួលបន្ទុកតែវាសនារបស់ខ្លួនផ្ទាល់តែប៉ុណ្ណោះ[២៩]។

ស្របទៅតាមការរៀបចំសង្គមនិងអំណាចនេះ ដោយយកគំរូតាមបែបគ្រួសារដែលមានសមាជិកតិច ប្រព័ន្ធរដ្ឋបាលបានខំប្រឹងប្រែងរកតួនាទីរបស់ខ្លួនដោយប្រឈមមុខទល់និងបណ្តាញនៃអំណាចក្រៅផ្លូវការ។

## ៣. រចនាសម្ព័ន្ធអំណាចៈ បណ្តាញផ្លូវការនិងក្រៅផ្លូវការ

### ៣.១. អំណាចផ្លូវការៈ ការរៀបចំរដ្ឋបាលដំបូង

ប្រព័ន្ធរដ្ឋបាលបែបសាជីជ្រុងដែលមានច្រើនជាន់ថ្នាក់ ហើយដែលបានដាក់ឱ្យប្រើដោយអាណានិគមបារាំងនិង ដែលកម្ពុជាបានទទួលមកវិញបន្ទាប់ពីបានឯករាជ្យថ្មីៗ ហើយបន្ទាប់មកអនុវត្តន៏ដោយរបបកុម្មុយនីស្តបានបង្កើតជាផ្នែកធំជាច្រើនបន្តបន្ទាប់គ្នា និងផ្នែកតូចៗជាច្រើនទៀតរវាងប្រជាពលរដ្ឋ អ្នកភូមិ និងព្រះហាក្សត្រៈ ក្រុម ភូមិ ឃុំ ស្រុក និងខេត្ត។ ជាទូទៅ ប្រជាកសិករហាក់ដូចជាមានការទីទើរចំពោះប្រព័ន្ធនេះ ដែលពុំមានតួនាទីអ្វីនៅក្នុងក្របខ័ណ្ឌប្រពៃណី ហើយដែលជាប្រព័ន្ធដែលដាក់បង្គាប់ដោយប្រភពខាងក្រៅ[៣០]។

ប៉ុន្តែនៅមុនឆ្នាំ១៩៧០ សភាពការណ៏ហាក់ដូចជាមានភាពច្បាស់លាស់ណាស់។ ផ្នែករដ្ឋបាល និងយុត្តិធម៌មានគេគោរពខ្លះ។ ចាប់តាំងពីមានសង្គ្រាមមក ការមិនទុកចិត្តចំពោះអាជ្ញាធរនិងគំនិតយករស់តែខ្លួនឯងបានបំផ្លាញមូលដ្ឋានដ៏ផុយស្រួយទាំងនោះ ។ អ្វីៗដែលចេញមកពីផ្នែករដ្ឋបាល គឺហាក់ដូចជាការគំរាមកំហែងមកលើស្នេហភាពគ្រួសារទៅវិញ។

អាជ្ញាធររដ្ឋបាលមាននៅគ្រប់ផ្នែករដ្ឋបាលនីមួយៗ ។ នៅថ្នាក់មូលដ្ឋាន អ្នកដែលត្រូវទាក់ទងទីមួយគឺមេក្រុម[៣១] (មេក្រុមគ្រប់គ្រងមនុស្សចំនួនដប់គ្រួសារ) បន្ទាប់មក គឺមេភូមិ (គ្រប់គ្រងពី ១០០ ទៅ ២០០

[29] អាកប្បកិរិយានេះត្រូវបានកើតឡើងនិងចាត់ទុកជាកំហុសនៅក្នុងក្បួនសីលធម៌ៈ Pou Saveros កំរងច្បាប់ "ច្បាប់ពាក្យចាស់បទទី២" (ចូលព្រៃសត្វសាហាវរកអំពាវគ្នាមកជុំ ដល់បានស្តុះទឹកឃ្មុំពួនសំងំឆីម្នាក់ឯង)។

[30]. នៅក្នុងរបបចាស់ អ្នកឧកញ៉ាដែលតែងតាំងដោយព្រះមហាក្សត្រគឺជាចំណងទាក់ទងតែមួយ ដ៏សំខាន់បំផុតរវាងព្រះមហាក្សត្រនិងប្រជាជន។

[31]. គ្រួសារមួយមានសមាជិកជាមធ្យមប្រាំពីរនាក់គឺមាតាបិតានិងកូនប្រាំនាក់។

គ្រួសារ) មេឃុំ[៣២] (គ្រប់គ្រង ៤ ទៅ ៧ ភូមិ) មេស្រុក (គ្រប់គ្រង ៣ ទៅ ៤ ឃុំ) និងអភិបាលខេត្ត។ ទោះបីនៅកំរិតថ្នាក់មូលដ្ឋានក្តី ប្រជាពលរដ្ឋនៅក្នុងភូមិកម្រធ្វើការងារអ្វីៗហួសពីថ្នាក់ឃុំដែរ។ ស្រុកគឺជាកំរិតរដ្ឋបាលថ្នាក់ខ្ពស់ បំផុតរបស់ពួកគាត់។ ស្រុកអនុវត្តអំណាចនីតិប្រតិបត្តិ (នគរបាល)។ ទីប្រជុំជន ខេត្តនីមួយៗ មានតុលាការមួយ និងពន្ធនាគារមួយ។

ផ្នែករដ្ឋបាលតូចបំផុត[៣៣] គឺភូមិដែលរហូតមកដល់ឆ្នាំ១៩៧៥ ហាក់បីដូចជាមានភាពស្វ័យយ័តពីអាជ្ញាធរខេត្ត។ កាលពីមុន មេភូមិបំពេញភារកិច្ចទាំងឡាយនៅក្នុងភូមិមានៈ រៀបចំពិធីបុណ្យនានាប្រមូលប្រជា-ជនដើម្បីធ្វើការរួម(ធ្វើផ្លូវ លើកទំនប់)។ នៅឆ្នាំ១៩៧៩ រចនាសម្ពន្ធ័ថ្មីដែលបានដាក់ឱ្យអនុវត្តមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងរចនាសម្ពន្ធ័ចាស់ពីមុន។ ប៉ុន្តែតាមរូបភាពជាក់ស្តែង មុខងារមានលក្ខណៈជានយោបាយ ហើយអាជ្ញាធរថ្នាក់ខ្ពស់មានវត្តមានច្រើនពេលណាស់។ ដូចនេះ មេភូមិត្រូវបានជ្រើសរើសដោយអ្នកភូមិ តាមសំណើរបស់អាជ្ញាធរឃុំសំរាប់អាណត្តិមិនកំនត់។ មេភូមិជាច្រើនបានធ្វើការតាំងតែពីឆ្នាំ ១៩៧៩ ។ មេភូមិណាដែលចង់ចាកចេញពីមុខងារនេះក៏ពុំហ៊ានដែរ ដោយហេតុថា គាត់ត្រូវប្រឈមមុខនឹងចៅហ្វាយនាយរបស់ខ្លួន។ មុខងាររបស់មេភូមិពុំមែនជាឧបនិស្ស័យទេ។ នៅក្នុងការប្រតិបត្តិជារឿយៗ មេភូមិមានភារកិច្ចត្រួតពិនិត្យការងារអ្វីមួយ។ គាត់ជាអ្នកនាំយកបទបញ្ជាមកពីថ្នាក់លើៈ (ការប្រជុំ ការធ្វើជំរឿន ពតិមាន...) និងធ្វើការគ្រប់បែបយ៉ាងឱ្យបានល្អ ដើម្បីកុំឱ្យអាជ្ញាធរថ្នាក់លើមានការពុំសប្បាយចិត្ត។ ការផ្លាស់ប្តូរដ៏សំខាន់មួយទៀតគឺមុខងារបែបនយោបាយ។ មេភូមិគឺជាអ្នកតំណាងគណបក្សនយោបាយដែលមានឥទ្ធិពលនៅមូលដ្ឋាន។ ការធ្វើរបៀបនេះ បានបង្កើតឱ្យមានការបាក់បែកគ្នានឹងមានការមិនទុកចិត្តគ្នានៅក្នុងភូមិ។ ជនទាំងឡាយណាដែលជ្រើសរើសយកគណបក្សប្រឆាំងណាមួយនឹងអនុវត្តតាមឱវាទរបស់មេភូមិដោយស្ទាក់ស្ទើរ។ ជនទាំងឡាយណាដែលនៅខាងគណបក្សរបស់មេភូមិនឹងបានទទួលភាពអនុគ្រោះជាច្រើន។ ជាទូទៅ គេមានការទុកចិត្តតិចណាស់ទៅលើប្រធានភូមិ ប្រសិនបើគេពុំបាន នៅក្នុងបណ្តាញនៃអំណាចរបស់មេភូមិ។

មេភូមិដែលមានដើមកំណើតនៅក្នុងភូមិ បានទទួលការគោរពយ៉ាងច្រើនដោយសារតែបុគ្គលិកលក្ខណៈផ្ទាល់របស់គាត់ ច្រើនជាជាងដោយសារមុខងាររបស់គាត់។ មេភូមិណាដែលពុំសូវមានអំណោយទាន ឬដែលមកពីស្រុកមួយផ្សេងទៀតនឹងត្រូវបានគេចាត់ទុកជាដំបូងថា ជាអ្នករាជការតែពុំសូវបានទទួលការគោរពប៉ុន្មានទេ។

---

32 . នៅទីក្រុងគឺមេសង្កាត់ឬ ចៅសង្កាត់ ប្រធានសង្កាត់

33 . ក្រុមនានាដែលបានបង្កើតនៅឆ្នាំ ១៩៧៩ ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃការកសាង ប្រទេសឡើងវិញ ពុំមានដំណើរការទេនៅពេលបច្ចុប្បន្នកាលនេះ (ក្រុមសាមគ្គី)។ ក្រុមទាំង នោះបានបំរើដល់ការផ្តល់ពតិមាន (កោះហៅធ្វើការប្រជុំ ផ្សព្វផ្សាយក្រុមនយោបាយមួយ)។

មេឃុំគឺជាអាជ្ញាធរមូលដ្ឋានដែលមានសារៈសំខាន់ជាង។ ជារឿយៗ គេខ្លាចមេឃុំ។ គេរកជួបមេឃុំ ដោយសារតែគេមានបញ្ហាសំខាន់ៗ។ ចៅហ្វាយស្រុកគឺជាអាជ្ញាធរដែលនៅឆ្ងាយ ភាគច្រើនមកពីទីកន្លែងផ្សេង ហើយដែលចាត់តាំងដោយខេត្ត។ ចៅហ្វាយស្រុកនៅឃ្លាតឆ្ងាយពីខ្សែរយៈនៃទំនាក់ទំនងគ្រួសារ និងមិត្តភក្តិ។

## ៣.២. បណ្តាញអំណាចក្រៅផ្លូវការ

នៅពីក្រោយរូបភាពផ្នែករដ្ឋបាលដែលគេដាក់ឱ្យប្រតិបត្តិដោយបង្ខំ មានលេចចេញជាមានបណ្តាញអំណាចយ៉ាងរស់រវើក។

ថ្វីបើគេចូលចិត្តឯករាជភាព គ្រួសារខ្មែរជាច្រើនត្រូវការអំពាវនាវឱ្យមានអ្នកការពារមកពីខាងក្រៅនៅពេលមានការរំជើបរំជួលដល់សណ្តាប់ធ្នាប់ (បញ្ហាសេដ្ឋកិច្ច យុត្តិធម៌ វេជ្ជវិទ្យា ទំនាស់ដែលតំរូវឱ្យមានការសំរុះសំរួល...)។ ជានិច្ចកាល គ្រួសារទាំងនោះតែងខិតខំដើម្បីបង្កើតបណ្តាញអំណាចផ្ទាល់របស់ខ្លួននៅអមជនទាំងឡាយដែលប្រត្តិបត្តិការនៅក្នុងវិស័យផ្សេងៗនៃសង្គម សេដ្ឋកិច្ច និងនយោបាយ (មានខ្នងៈ មានទំនាក់ទំនង)។

រូបភាពនៃទំនាក់ទំនងទាំងនោះគឺ ផ្អែកទៅលើគំរូជាប្រពៃណីនៃគ្រួសារដែលមានតែឪពុក ម្តាយ និងកូន។ នៅពេលមានការជួបសន្ទនារវាងជនពីររូប គេត្រូវកំណត់ថាអ្នកណាជាបងហើយអ្នកណាជាប្អូន និងបង្ហាញអំពីទំនាក់ទំនងតាមឋានានុក្រមដែលបងត្រូវធ្វើអន្តរាគមន៍ទៅលើប្អូន។

ប្រសិនបើមានភាពខុសគ្នារវាងជន ទាំងពីររូប ទំហំពាក្យពេចន៍ដែលត្រូវប្រើក៏មានទំងន់ទៅតាមនោះដែរ។ គេនិងហៅថា ពូ អ៊ុំ មីង រឺ អ៊ុំ តា...។ ដូចនេះ សង្គមខ្មែរទាំងមូលត្រូវបានរៀបចំតាមបែបគ្រួសារ និងមានឋានានុក្រមដោយឥតគិតអំពី ចំណងសាច់ឈាមពិសេសនោះឡើយ។ ជនទាំងឡាយណាដែលគេទទួលស្គាល់ថាជាបងនោះ គឺដោយសារអាយុរបស់គាត់ ដោយសារបទពិសោធន៍ ទ្រព្យសម្បត្តិ និងតួនាទីក្នុងសង្គមនិងឋានានុក្រមរបស់គាត់។ របៀបរបបនេះមានរហូតសូម្បីតែក្នុងទំនាក់ទំនងរវាងប្តី និងប្រពន្ធ បងប្រុសនិងប្អូនស្រី កសិករ និងអ្នកតំណាងផ្នែករដ្ឋបាល នាយទាហានរហូតដល់ពលទាហាន គ្រូនិងសិស្ស/ព្រះសង្ឃ និងលោកនេន ថ្នាក់លើ និងថ្នាក់ក្រោម...។

គឺជារបៀបមួយសំរាប់ប្អូនដើម្បីធ្វើការជ្រើសរើសបងមួយរូប និងធ្វើឱ្យគាត់យល់ព្រមទទួលធ្វើជាបង។ ផ្ទុយទៅវិញ បងក៏អាចធ្វើការបង្ខិតបង្ខំដោយកំលាំង ហើយទាមទារឱ្យប្អូនឋិតនៅក្រោមបង្គាប់របស់ខ្លួន។ ឧទាហរណ៍ នៅក្នុងក្របខ័ណ្ឌនយោបាយ ឬយោធា។

នៅពេលដែលទំនាក់ទំនងត្រូវបានបង្កើត គឺបងជាអ្នកធានារ៉ាប់រងកិច្ចការពារផ្នែករូបរាងកាយ និងសេដ្ឋកិច្ចចំពោះប្អូន។ តួនាទីរបស់ប្អូនគឺត្រូវមានភក្តីភាពផ្នែកនយោបាយ? ទទួលស្គាល់ស្ថានភាពរបស់ខ្លួនដដែល និងសុំបំរើបងនៅពេលដែលត្រូវការ។ ការគោរពបងបានប្រព្រឹត្តទៅស្របគ្នាជាមួយនឹងការខ្លាច (គោរពខ្លាច)។ នៅក្នុងច្បាប់សុជីវធម៌ ទំនាក់ទំនង "ធំ និង តូច" ប្រៀបបានទៅនឹងទំនាក់ទំនងដែលពុំអាចកាត់ផ្តាច់បានដូចជាទំនាក់ ទំនងរវាងដើមឈើនិងវល្លិ[៣៤]។

ការផ្លាស់ប្តូររវាងអ្នកការពារគេ និងអ្នកត្រូវបានគេការពារបានប្រព្រឹត្តទៅតាមកាលៈទេសៈដោយយោលទៅលើសេចក្តីត្រូវការរវាងអ្នកទាំងសងគ្នា។ អ្នកទាំងពីរមានលក្ខណៈងាយប្រែប្រួល និងងាយផ្លាស់ប្តូរណាស់។ ប្រសិនបើអ្នកការពារគេបាត់បង់អំណាច ប្អូនអាចរត់ទៅរកអ្នកផ្សេងម្នាក់ទៀតដើម្បីឱ្យជួយ។ ដូចនេះ គេអាចដូរពីជំនឿនយោបាយមួយទៅជំនឿនយោបាយមួយផ្សេងទៀតដោយពុំមានបញ្ហាអ្វីទាំងអស់[៣៥]។ ការរស់ឡើងវិញនៃសេដ្ឋកិច្ចនៃគ្រួសារដែលមានតែឪពុកម្តាយនិងកូន មានអាទិភាពលើកត្តាមនោសញ្ចេតនា ឬ នយោបាយ។

## ៤. ការអប់រំ-ក្រមសីលធម៌: ទំងន់វប្បធម៌

### ៤.១. ការអប់រំ

មាតា ជាអ្នកធានាដល់ការអប់រំកុមារដោយមានការជួយពីកូនបង១ពីបិតានិងជីដូនជីតាប្រសិនបើគាត់រស់នៅជាមួយគ្នា។

ការផ្តល់ឱវាទដែលទាក់ទងទៅនឹងការអប់រំ ឬការព្រមានរបស់គ្រួសារមួយទៅលើកូនក្មេងដែលពុំមែនជាកូនរបស់ខ្លួនគឺគេពុំអាចទទួលយល់ព្រមបានទេ។ ប្រសិនបើករណីនេះកើតមានមែន ទំនាស់រវាងគ្រួសារទាំងពីរ និងផ្ទុះឡើងជាញឹកញយ (សូមមើលជំពូក II)។

តាមយោបល់របស់លោក Chantal Nodier នៅក្នុងប្រពន្ធ័សង្គមមួយដែលពុំបង្ហាញអំពីចំណងសាមគ្គីភាព និងការជួយទៅវិញទៅមកដោយពិតប្រាកដ "កូនជាអ្នកជួយតែមួយគត់ដែលឪពុកម្តាយអាចពឹងពាក់បាន"។ កុមារនៅស្រុកស្រែចំការបានចូលរួមក្នុងការធ្វើសេដ្ឋកិច្ចគ្រួសារតាំងតែពីក្មេង។ ឪពុកម្តាយ បាន

---

34 . Pou Saveros កំរងច្បាប់ "ច្បាប់ហែមហាជន" បទ ៦៥ ៦៦ ៦៨ ៦៨ ៧០ (យកលោកជា ទីពឹង លើពំនឹងលោកជាធំ គួរគិតឱ្យគួរសម ទោះដេកដើរអង្គុយក្តី។ ឱ្យមានទីប្រតិបត្តិ គួរប្រយ័ត្នប្រុងស្មារតី ទោះទ្រព្យលោកថោកថ្លៃ គន់រំពៃមើលរក្សា។ ប្រៀបដូចដើមឈើធំ វល្លិដុះរុំព័ទ្ធពីក្រៅ វល្លិសូមសំណាក់នៅ ដើមឈើនោះដុះខ្ពស់ផង។ វល្លិខ្ពស់ព្រោះគុណឈើ វល្លិព័ទ្ធលើនោះឯងហោង វល្លិវារព័ទ្ធទាក់ទង មានផ្លែផ្កាច្រើនក្រាស់ក្រៃ។ ឈើដូចលោកមានបុណ្យ វល្លិដុះព័ទ្ធពាក់ប្រស្រ័យ ដូចអ្នកតូចនោះនៃ គួរគិតកុំភ្លេចគុណឡើយ។)

35 . នៅពេលដែលទ័ពពួកខ្មែរក្រហមបានចុះចូល គេបានឃើញពួកអតីតខ្មែរក្រហមស្លៀកពាក់ ខោអាវរដ្ឋាភិបាល ហើយវិលត្រឡប់ទៅវាយប្រហារបង ប្អូនខ្លួនពីថ្ងៃមុនភ្លាម។

លើកឡើងជារឿយៗអំពីការលំបាកដែលគាត់ជួបប្រទះក្នុងការអប់រំកូន និងបណ្តុះគំនិតកូនឱ្យទទួលស្គាល់អ្នកបង្កើត។ មែនទែនទៅ គេនៅចាំថាកូននឹងទទួលបន្ទុកទាំងអស់នៅពេលដែលឪពុកម្តាយរបស់ខ្លួនមានភាពចាស់ជរា។

ប៉ុន្តែនៅទីក្រុងនិងនៅស្រុកស្រែចំការបច្ចុប្បន្ននេះ គេជឿទុកចិត្តតិចណាស់ទៅលើកូនដែលជាអ្នកធានាឪពុក ម្តាយចាស់ជរាឱ្យមានជីវភាពសុខសប្បាយ។

> "ឥឡូវនេះ កូនខ្ញុំគិតតែពីសប្បាយពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំសង្ស័យថាវាមិនអាចជួយខ្ញុំនៅពេលដែលខ្ញុំចាស់ទៅ" ។
> (លោកជួន អាយុ ៤៩ ឆ្នាំ រស់នៅទីក្រុងភ្នំពេញ)

ក្នុងករណីមានបញ្ហាធ្ងន់ធ្ងរ ប្រសិនបើការប្រព្រឹត្តិរបស់កូនបានធ្វើឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះឪពុកម្តាយ ឪពុក ម្តាយអាចផ្តាច់ទំនាក់ទំនងជាមួយកូន ហើយអាចចុះផ្សាយសកម្មភាព ឬអំពើនេះនៅក្នុងសារពតិមាន។ (សូមមើលជំពូក II) ។

ទំនាក់ទំនងរវាងមាតាបិតានឹងកូនកាន់តែថយចុះបន្តិចម្តងៗ កូនត្រូវរៀនសូត្របទបញ្ជាដំបូងៗនៃបែបបទរបស់សង្គម។ បែបបទនេះគឺកូនត្រូវនៅស្ងៀម។ ការចង់ដឹងក៏ដូចជាគំនិតទិតៀន និងការធ្វើវិភាគគឺពុំត្រូវបានលើកទឹកចិត្តទេ។ ការរៀនសូត្រ គឺគេឱ្យកូនស្តាប់គ្រាប់ធ្វើតាមកាយវិការ និងពាក្យសំដីរបស់បងៗដោយពុំចាំបាច់សួរអ្វីច្រើនឡើយ។

តាមយោបល់របស់លោក Jacques Népote គឺពុំមានបទបញ្ជាដែលទាក់ទងទៅនឹងការប្រព្រឹត្តរបស់គ្រួសារឱ្យមានលក្ខណៈមាំទាំនោះទេ។ "ការប្រព្រឹត្តិទាំងនោះគឺជាផ្លែផ្កានៃឆន្ទៈរបស់បុគ្គលម្នាក់ៗ ឬក៏ជាជំរើស ដែលមានយុទ្ធវិធីរបស់បណ្តាញឪពុកម្តាយដែលបានបង្កើតឡើងដោយចៃដន្យ នៅក្នុងប្រវត្តិសាស្ត្រសេដ្ឋកិច្ច និង សង្គមរបស់ក្រុមដែលមានការពាក់ព័ន្ធ[៣៦]" ។

ដើម្បីឆ្លុះបញ្ចាំងពីអំពើនឹងការប្រព្រឹត្តិទាំងនោះ ការនិយាយយោងទៅប្រពៃណីកើតមានជារឿយៗ ចំពោះមនុស្សចាស់ ដូចជាពាក្យថា "គេធ្វើរបៀបនេះព្រោះវាជាប្រពៃណី"។ ប៉ុន្តែគឺជាការលំបាកណាស់ក្នុងការឃើញហេតុផលណាមួយដែលគាំទ្រការបញ្ចេញអាកប្បកិរិយាគ្រាប់តាមគ្នានេះ។

គំរូនៃការប្រព្រឹត្តិទាំងឡាយរបស់សង្គមដែលពេញលេញ និងក្បួនខ្នាតនៃការរស់នៅជាសង្គមហើយដែលមាននៅក្នុងសង្គមស្រាប់បង្កើតបានជាអត្ថបទជាលាយល័ក្ខអក្សរ ឬអត្ថបទនិយាយមាត់ទទេៈ រឿងនិទាន

36 . NEPOTE : ១៩៩២ *ទំព័រ* ១៣៣

ច្បាប់ សុជីវធម៌ សុភាសិត[៣៧]។ ចំពោះអត្ថបទទាំងនោះត្រូវបានគេនិយាយតៗគ្នា ឬបង្រៀននៅសាលារហូតដល់ ពេលចាប់ផ្តើមមានសង្គ្រាមនៅឆ្នាំ១៩៧០ បច្ចុប្បន្ននេះ យុវជនជំនាន់ក្រោយពុំសូវបានស្គាល់ទេ។ ប៉ុន្តែគេបានបង្ហាញថា អត្ថបទទាំងអស់នោះនៅតែត្រូវគេចាត់ទុកដូចជាពុម្ពវប្បធម៌ចំពោះរបៀបនៃការប្រព្រឹត្តិរវាងឪពុក ម្តាយនិងកូន ប្តីនិងប្រពន្ធ មន្ត្រីថ្នាក់លើនិងថ្នាក់ក្រោម។

## ៤. ២ ក្រមសីលធម៌

អត្ថបទច្បាប់នានាគឺជាអត្ថបទទូន្មានផ្សេងៗដែលមាតាបិតាប្រៀនប្រដៅកូន ឬដូចជាជនមានកិត្តនាមម្នាក់ទូន្មានសិស្សជាសាវ័ករបស់ខ្លួនឬអនាគតមន្ត្រីមួយរូប។ ច្បាប់ទាំងនោះរួមបញ្ចូលគ្នារវាងប្រពៃណីប្រជាប្រិយនិងពុទ្ធសាសនា[៣៨]។ ក្បួនច្បាប់ដែលដាក់ឱ្យអនុវត្តទាំងនោះបានដាក់ឱ្យប្រតិបត្តិជាប្រចាំដើម្បីប្រឆាំងនឹងការប្រព្រឹត្តខុសឆ្គង និងការសេពគប់របស់ជនមួយចំនួន ហើយធ្វើការចងក្រងទុកចំពោះឥរិយាបថណាដែលអាចធ្វើជាគួរប្រកាន់យក។

ដើម្បីឱ្យបានទៅដល់គោលដៅដែលពុំមានការរងទុក្ខវេទនាគឺ សន្តិភាព នឹងកាទទួលស្គាល់សង្គមផ្ទាល់ខ្លួន គេបានណែនាំឱ្យអនុវត្តគុណធម៌ និងការធ្វើទាន ព្រមទាំងការជៀសវាងអាកប្បកិរិយាមិនល្អ។

គុណធម៌ ឬឥរិយាបថសង្គមដែលមានតម្លៃគឺ ការបន្ទន់ខ្លួន[៣៩] ស្គាល់តួនាទីរបស់ខ្លួន ការគោរពឪពុកម្តាយនិងប្តី(ក្នុងករណីស្ត្រី) ការប្រព្រឹត្តិសមរម្យ និងដែលចេះលាក់អាថិកំបាំង កុំធ្វើឱ្យគេកត់សំគាល់បាន[៤០] គិតមុននឹងធ្វើអ្វីមួយ[៤១] កុំយកត្រចៀកស្តាប់ពាក្យចចាមអារាមហើយកុំនិយាយបន្តទៅទៀត[៤២] បណ្តុះចំណេះដឹងរបស់ខ្លួន និងត្រូវទទួលខុសចំពោះអំពើខ្លួនឯង។

ឋិតនៅឆ្ងាយពីឧត្តមគតិបែបទស្សនវិទ្យា ការឱ្យអ្វីមួយទៅអ្នកដទៃ គឺទុកដូចជាការផ្តល់រង្វាន់ដើម្បីបានផ្នូរមកវិញ។

---

[37] . រៀងរាល់ថ្ងៃ ការនិយាយយោងទៅសុភាសិតមានជារឿយៗ។ ពេលវេលានៃការស្រាវជ្រាវនេះមានកំរិតនេះពុំអាចឱ្យយើងដកស្រង់សុភាសិតដែលសំដៅការដោះស្រាយទំនាស់ទាំងអស់នោះបានឡើយ។ គឺនៅមានការងារត្រូវធ្វើច្រើនទៀត។

[38] . អត្ថបទជាច្រើនគឺព្រះសង្ឃជាអ្នកបានសរសេរ។

[39] . Pou Saaveros កំរងច្បាប់ ច្បាប់បណ្តាំបិតា បទ៣( ឪកូនកំសត់ រៀនឱនរៀនអត់ រៀនគិតក្នុងក្រៅ រៀនឱនលំទោន កុំឱ្យហួងសៅ ដល់ខ្លួនកូនពៅ កើ្តដល់ឪពុក )។

[40] . Pou Saveros កំរងច្បាប់ "ច្បាប់សុភាសិត"

[41] . Pou Saveros កំរងច្បាប់ "ច្បាប់បណ្តាំបិតា" ( ហាឡើងមិនធ្យាន ស្តីមិនប្រមាណ នឹងប្រាណអាត្មា សូវអោនកុំងើប សូវស្ងៀមកុំថា សូវវាយកុំប្រហារ សូវកាប់កុំជេះ។ )

[42] . Pou Saveros កំរងច្បាប់ ច្បាប់អរិយសត្ថា ( កុំធ្វើមាក់ងាយ នឹងគ្រូបាធ្យាយ រៀនចិត្តឱ្យល្អ ទោះអ្នកឯណា ណែផ្លូវអក្សរ អ្នកនោះឯងអរឱ្យចិត្តមេត្រី។ - Pou Saveros កំរងច្បាប់ "ក្នុងករណីមានការមិនចុះសំរុងជាមួយអ្នកដទៃ សូមកុំនិយាយពាក្យអាក្រក់ជាមួយអ្នកទាំងនោះ។ ការនេះ អាចបណ្តាលឱ្យមាន ជំលោះដ៏ធ្ងន់ធ្ងរ "។

នេះគឺជារបៀបដែលគេធ្វើដើម្បីបានយល់ព្រមពីសំណាក់អ្នកធំនិងអ្នកតូច[៤៣] ដើម្បីចូលរួមជាមួយប្រព័ន្ធអ្នកមានអំណាច ឬបង្កើតប្រព័ន្ធអំណាចថ្មី ឬដើម្បីឱ្យជាតិក្រោយបានកាន់តែល្អជាងនេះ។

ដូច្នេះវាជាច្បាប់ទៅហើយ ដែលថាគេមិនចូលចិត្តអត្តចរិតទាំងឡាយដែលគំរាមកំហែងដល់ភាពសុខដុមរបស់សង្គមដែលផ្អែកលើឯករាជ្យភាពនិងការគោរពចំពោះស្ថានភាពរបស់មនុស្ស ម្នាក់ៗនិងឯករាជភាព។ នៅក្នុងច្បាប់ចងក្រងដោយអ្នកប្រាជ្ញកវីផ្សេងៗ មានការគូសបញ្ជាក់ពីការខូចខាតដែលកើតឡើងដោយសារពាក្យសំដី។

មនុស្សគ្រប់រូបត្រូវបានលើកទឹកចិត្តឱ្យធ្វើមិនដឹងមិនឮចំពោះពាក្យសំដីដែលបង្កការមិនចុះសម្រុងគ្នា ហើយដែលពាក្យសំដីទាំងនោះដកមកវិញមិនបាន[៤៤]។

គេតិះដៀលអ្នកដែលយកប្រពន្ធគេ អ្នកធំ អ្នកលេងល្បែង អ្នកប្រើពាក្យអសុរស អ្នកចិត្តច្រើនឆាប់ខឹង អ្នកលេងសើច អ្នកល្ងង់។ គេបានណែនាំឱ្យរស់នៅឃ្លាតឆ្ងាយពីមនុស្សអាក្រក់ ពីព្រោះមនុស្សអាក្រក់ពុំអាចកែ ប្រែបានទេ[៤៥] ហើយត្រូវស្វែងរកការរាប់អាននឹងការគាំទ្រពីអ្នកធំ។

ជនទាំងឡាយណាដែលពុំគោរពតាមក្បួនច្បាប់ទាំងនេះ នឹងត្រូវទទួលការខាតបង់ទ្រព្យសម្បត្តិនឹងបាត់បង់ស្ថានភាពរបស់ខ្លួន ព្រមទាំងទទួលអំពើបាបតាមផ្លូវសាសនាទៀតផង។

អត្ថបទទាំងអស់នោះត្រូវបានសរសេរនៅក្នុងសម័យកាលចាស់។ គឺក្នុងសម័យដែលសង្គមត្រូវបានបែងចែកជាវណ្ណៈ។ នៅខាងលើបំផុតមានព្រះមហាក្សត្រនិងក្រុមព្រះអង្គម្ចាស់។ បន្ទាប់មកគឺជនដែលមានបណ្តាសក្តិខ្ពស់ បន្ទាប់មកទៀតគឺជនតូចតាច។ មនុស្សអាចឡើងចុះឋានៈយ៉ាងងាយ ក្នុងបណ្តាឋានៈទាំងពីរខាងក្រោយនេះ។ ក្បួនច្បាប់ទាំងអស់ទូន្មានជនគ្រប់រូបអំពីមាគ៌ាដែលត្រូវដើរ ដើម្បីឈោងទៅថ្នាក់ខ្ពស់មួយទៀត។ "អ្នកធំ និងអ្នកតូច" បានរួបរួមគ្នាជាក្រុមដោយសារករណីយកិច្ចនិងកាតព្វកិច្ចដែលមានចំពោះគ្នាទៅវិញទៅមក។ ករណីយកិច្ច និងកាតព្វកិច្ចទាំងនេះបង្កើតបានជាមូលដ្ឋានសង្គម និងសីលធម៌នៃព្រះរាជាណាចក្រ។

---

[43] . Pou Saveros កំរងច្បាប់ ច្បាប់ធម្មបាលបទ ១១៩

[44] . Pou Saveros កំរងច្បាប់ "ច្បាប់បណ្តាំបិតា" បទ ២៤( ទូកហួសកំពង់ រាថែវបង្អង់ ថយមកចូលចាប់ ពាក្យលឿនហួសខ្នាត ហៅឥតគំនាប់ ថយមករកគាប់ ពុំបានឡើយណា។ )

[45] . Pou Saveros កំរងច្បាប់ "ច្បាប់វិធុរបណ្ឌិត" បទ ៣៤ ៣៥ ៣៦ ( ដូចពុតពាលពុំជា កុំផ្តន្ទាទោសទណ្ឌផង ផងតប់ដាល់វាយចង ពុំចេះចោលពុត បាត់បង់។ ដូចខ្សៀនកន្ទុយឆ្កែ ទោះនូវប្រែពត់មិនត្រង់ យកប្រេងទួនរឹតទង់ រោលភ្លើងពត់ពុំត្រង់បាន។ ដូចពុតពាលសក់ឡក់ចិត្តអាក្រក់ធ្វើលឹកលាន យកធមិដំបូន្មាន ចិត្តពុំចូលពុំចង់ស្តាប់។ )

ទោះបីជាយើងបានឃើញការប្រែប្រួលនៅក្នុងសង្គមពីមុនក៏ដោយ ការប្រតិបត្តិតាមប្រព័ន្ធចាស់នេះក៏នៅតែមានតទៅទៀតនៅក្នុងសង្គមបច្ចុប្បន្ននេះតាមបែបក្រៅផ្លូវការ។

អត្ថបទទាំងឡាយស្តីអំពីទំនាក់ទំនងប្រុសស្រីនៅ តែឋិតនៅក្នុងការយកចិត្តទុកដាក់។ គឺមានក្បួនច្បាប់សំរាប់ស្រី "ច្បាប់ស្រី" ដែលត្រូវបានលើកឡើងជារឿយៗនៅក្នុងពេលជួបសន្ទនា។

គឺជាការទូន្មានរបស់ម្តាយចំពោះកូនស្រីគាត់ ដែលទាក់ទងទៅនឹងករណីយកិច្ចរបស់ប្រពន្ធដែលធ្វើចំពោះប្តី។ ប្រពន្ធត្រូវទទួលភារកិច្ចពិនិត្យមើលភ្នក់ភ្លើងទាំងបីគឺ មាតាបិតា ( ជាពិសេស មាតា ) និងប្តី។ ប្រពន្ធត្រូវតែ ប្រុងប្រយ័ត្នជានិច្ចចំពោះវិបត្តិភ័យដែលអាចកើតចេញពីអកប្បកិរិយាខុសឆ្គងទៅលើប្តី។ ចរិយាក្រអឺតក្រទម ត្រូវបានទទួលការស្តីបន្ទោស ហើយឥរិយាបថចេះអត់ធ្មត់, ការដាក់ខ្លួនឱ្យទាប និងការអត់ទ្រាំ[៤៦] ត្រូវបានគេឱ្យតម្លៃខ្ពស់។ ប្រពន្ធត្រូវតែដាក់ខ្លួនឱ្យទាបជាងប្តី ទោះបីខ្លួនមានអាយុច្រើនជាងប្តី[៤៧] ក៏ដោយ។ ប្រពន្ធតែងហៅប្តីថា "បង" ហើយប្តីហៅប្រពន្ធថា "អូន"។ ក្នុងករណីមានទំនាស់ក្នុងគ្រួសារ គេណែនាំឱ្យប្រពន្ធបង្ហាញអត្តចរិតចុះ ចាញ់ប្តីរបស់ខ្លួន ទោះប្តីមានឥរិយាបថអាក្រក់ក៏ដោយ[៤៨]។ តាមក្បួន ច្បាប់ ការប្រតិបត្តិតាមគោលការណ៍ទាំង នោះបានល្អនឹងនាំឱ្យកើតជាតិថ្មីបានល្អ។

នៅក្នុងទីនេះទៀត គេក៏បានណែនាំមិនឱ្យយករឿងគ្រួសាររបស់ខ្លួនឯងទៅប្រាប់អ្នកដទៃឡើយ មានមាតាបិតា[៤៩] ឬអ្នកជិតខាង[៥០] ជាដើមព្រោះខ្លាចនាំឱ្យមានទំនាស់។ គេណែនាំឱ្យពឹងផ្អែកលើខ្លួនឯង ហើយរក្សាបញ្ហាទាំងនេះឱ្យនៅតែក្នុងផ្ទះ គឺមិនឱ្យលេចចេញទៅក្រៅឡើយ ។ គេត្រូវលាក់រឿងទុកនៅក្នុងបេះដូងក៏ដូចជានៅក្នុងផ្ទះដែរ ពីព្រោះអ្នកក្រៅមានលក្ខណៈមិនល្អទេ[៥១]។

---

46 . Pou Saveros កំរងច្បាប់ ច្បាប់ស្រី បទ៧៦ ( មិនស្រួលទទួលបាត់មាត់ ម្នះម្នេញក្នុងចិត្ត ឱ្យ បានប្តីចាញ់ )

47 . Pou Saveros កំរងច្បាប់ ច្បាប់ស្រី ( អត់អោនក្លាយខ្លួនជាស្រី កុំឱ្យស្រដី ទុកគេជាស្មើ។ )

48 . Pou Saveros កំរងច្បាប់ ច្បាប់ស្រី បទ ៥២( ទោះបីបើប្តីនាងជេរ នាងចូលទៅឯ ដំណេកគិតសិន។ ចេញមកនាងយកពាក្យទន់ ស្រដីឱ្យអន់ ស្រាយទោសនោះទៅ។ ព្រោះឯងមិនក្រែងមិនស្តាប់ ពាក្យគេបង្គាប់ បង្កើតតែឈ្លោះ។ ឥតសុខអាក្រក់តែឈ្មោះ ឮគេប្រឈ្លោះ មិនចេះហៅល្វែ។ នេះពុំរាប់ជាស្រីទេ ជាអ្នកប៉ោឡែ ចិត្តចោរដកទង។ )

49 . Pou Saveros កំរងច្បាប់ ច្បាប់ស្រី បទ៥៤ ៥៥ ៥៦ ៥៧ ៥៨ ៥៩ ៦០ ( ទោះប្តីស្រដីពុំគាប់ ពុំគួរឱ្យប្រាប់ បានដឹងដល់ម្តាយ។ កើតខឹងវៃងរឹងខូរខ្វាយ ឮពាក្យពីម្តាយ ខ្សឹបខ្សៀវប្រាប់ប្តី។ មិនក្សាន្តបែងបានពីរបី កើតជាសំដីសួរចុះសួរឡើង។ ពុំស្វាត់ស្មៀមមាត់ចចើង ជជែកនាំឡើង ចចើងមិនបាត់។ តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀមឱ្យបាត់ ឱ្យបានទីសុខ។ ជជែកស្មើរ បែកទាំងស្រុក មិនមានហៅសុខយូរលង់ឡើងនេះ។ នេះហើយភ្នក់ភ្លើងទាំងបី ម្តាយផ្តាំកូនស្រី ឱ្យខំរក្សា។

50 . Pou Saveros កំរងច្បាប់ ច្បាប់ស្រី បទ ៣៩ ៤៩ ៤១ ( ភ្លើងក្រៅកុំនាំទៅក្នុង ឱ្យឆេះបំផ្លុង រីងផ្លុំបង្កាត់។ ភ្លើងក្នុងមិនប្រុងប្រយ័ត្ន នាំមកបង្កាត់ ឱ្យឆេះឯក្រៅ។ អុជអាលបណ្តាលឱ្យក្តៅ ដាលដល់កូនចៅអសោចិ៍អប្រិយ។ )

51 . Pou Saveros កំរងច្បាប់ ច្បាប់ស្រី បទ ១០៤ ១០៥ ១០៦ ( ចង្រៃមួយនៃរាល់គ្នា ចេញចូលមាត់ទ្វារ ពុំបានបិទបាំង។ ធ្វេសប្រាណខុសខានមិនរាំង មិនរុញបំបាំង មើលយល់ សាយសុស។ ទុកស្មើគេអុជចន្លុះ ឱ្យចោរចូលចុះ យកទ្រព្យទាំងឡាយ។ )

ទោះបីជាអត្ថបទទាំងនេះពុំត្រូវបានដឹងដោយលំអិតក៏ដោយ គំនិតនេះនៅតែដក់ជាប់ជានិច្ចនៅក្នុងទំនាក់ទំនងប្ដី-ប្រពន្ធ នៅពេលសព្វថ្ងៃនេះ។ ដូចនេះ នៅពេលមានទំនាស់ប្ដី-ប្រពន្ធ គេបានទូន្មានប្រពន្ធដែលត្រូវគេវាយតប់កុំឱ្យធ្វើការប្ដឹងផ្ដល់ ហើយឱ្យទ្រាំអត់ធ្មត់ទៅតាមព្រេងវាសនាដោយសារតែប្រពៃណី។

យើងនឹងជួបប្រទះរឿង បែបនេះនៅខាងមុខទៀតទាក់ទងទៅនឹងជំពូកស្ដីអំពីយុត្តិធម៌និងការផ្សះផ្សាទំនាស់ មានតួអង្គមួយនៅក្នុងរឿងនិទានដែលជនគ្រប់រូបបានស្គាល់គឺ "សុភាទន្សាយ[៥២]"។ ដោយមានសុភវិនិច្ឆ័យ មានគំនិតប៉ិនប្រសប់ដោះកុន ហើយជារឿយៗមានភាពឆ្លាតទៀតនោះ សុភាទន្សាយដោះស្រាយបញ្ហាស្មុគស្មាញជាច្រើនដែលគេបានប្ដឹងទៅតុលាការ ឬប្ដឹងព្រះមហាក្សត្រ។ ជារៀងរាល់ថ្ងៃនៅក្នុងព្រៃ ទន្សាយលេងសើច សប្បាយដោយចំអកទៅសត្វនានាជាសត្រូវ ហើយជួយសត្វជាមិត្ត។ សត្រូវទាំងនោះ គឺសត្វទាំងឡាយដែលទន្សាយបានលេងជាមួយដោយប្រើល្បិចនឹងដើម្បីសងសឹក។ ទន្សាយបានរួចផុតពីការ ធ្វើទោសទាំងអស់ ពីព្រោះទន្សាយជាសត្វឆ្លាត និងមានឧបាយកលច្រើនណាស់។ តាមរយៈនៃអ្នកនិពន្ធ អារម្ភកថាដែលបោះពុម្ពផ្សាយនៅ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត "រឿងសុភាទន្សាយគ្រាន់តែជារឿងសើចលេងសប្បាយប៉ុណ្ណោះ ក្រៅពីកង្វល់សីលធម៌ ឬក៏សង្គមទាំងអស់"។ ក៏ប៉ុន្តែរឿងសុភាទន្សាយបានផ្ដល់ជាគំរូដល់សង្គម ដោយបង្ហាត់បង្រៀនឱ្យចេះដោះស្រាយដោយខ្លួនឯង ដោយប្រើសុភវិនិច្ឆ័យនិងភាព ឆ្លាតវាងវៃដើម្បីដោះស្រាយបញ្ហា។

## ៥. តួនាទីរបស់សាសនា

សាសនាចូលរួមមួយផ្នែកធំដល់ការបង្កើតរចនាសម្ព័ន្ធដែលទាក់ទងទៅនឹងការប្រព្រឹត្តិផ្សេងៗ ដោយមានការបង្ហាញអំពីក្របខ័ណ្ឌនៃការគិតគូរ និងក្បួនច្បាប់នានាដែលត្រូវបានផ្សព្វផ្សាយឱ្យដឹងអំពីអ្វីដែលត្រូវធ្វើ ឬមិន ត្រូវធ្វើដើម្បីថែរក្សារបៀបរៀបរយ និងដើម្បីជៀសវាងការដាក់ទោសផ្សេងៗ។

សាសនានៅកម្ពុជាគឺជាការប្រជុំផ្សំគ្នារវាងការគោរពបូជាប្រជាប្រិយ សាសនាឥណ្ឌូនិងព្រះពុទ្ធសាសនា។ ការគោរពព្រលឹងបានកើតឡើងនៅលើទឹកដីកម្ពុជាតាំងពីយូរយារណាស់មកហើយ។ ក្រោយមកទៀតចាប់តាំងពីសតវត្សទី១នៃគ្រឹស្តសករាជ សាសនាផ្សេងៗដែលចេញមកពីប្រទេសឥណ្ឌាបានមកដក់ជាប់នៅក្នុងគំនិតប្រកាន់សាសនារបស់ប្រជាជនកម្ពុជា (ព្រហ្មញ្ញសាសនា សាសនាឥណ្ឌូ ព្រះពុទ្ធសាសនា) ហើយរួមរស់ជាមួយគ្នាជាមួយនឹងការគោរពបូជាបែបប្រជាប្រិយ។ ចាប់តាំងពីសតវត្សទី១៣មក ព្រះពុទ្ធសាសនាថេរវាទ[៥៣] បានត្រូវ គេប្រតិបត្តិនៅកម្ពុជា។

[52] . MONOD G.H. រឿងព្រេងខ្មែរ Cedorek 1985 រឿងសុភាទន្សាយ ប្រជុំរឿងព្រេងខ្មែរ : ភាគបួន វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត ១៩៧០

[53] . ព្រះពុទ្ធសាសនាហីនយានដែលមានប្រទេសឡាវ ថៃ ភូមា និងសេរីលង្កា ប្រតិបត្តិ ប្រទេសវៀតណាមនិងចិនប្រតិបត្តិព្រះពុទ្ធសាសនាមហាយាន។

ការគោរពអ្នកតា[៥៤] ការគោរពព្រះពុទ្ធសាសនាព្រមទាំងការអនុវត្តនានាដោយផ្អែកទៅលើប្រព័ន្ធមួយដែលគិតគូរអំពីថ្ងៃមានឬក និងថ្ងៃគ្មានឬកបានផ្តល់ជាលក្ខខ័ណ្ឌមួយសំរាប់ការធ្វើអ្វីៗទាំងអស់[៥៥] នៅគ្រប់ឥរិយាបថនៃការរស់នៅ។ គឺពុំមានអ្វីកើតឡើងដោយចៃដន្យទេ។ គ្រប់អំពើទាំងអស់នឹងផ្តល់លទ្ធផលជានិច្ច ជួនកាលផ្តល់លទ្ធផលនៅពេលបច្ចុប្បន្ន ជួនកាលផ្តល់លទ្ធផលនៅជាតិក្រោយទៀត។ ព្រះពុទ្ធសាសនាច្រើនសំដៅទៅរកអនាគតកាល និងការរៀបចំខ្លួនសំរាប់ការចាប់ជាតិក្រោយទៀត។ ការគោរពតាមប្រពៃណីឆ្លើយតបយ៉ាងច្រើនទៅនឹងសេចក្តីត្រូវការសំរាប់កិច្ចការការពារប្រចាំថ្ងៃ និង វិបុលភាព។

ជាទូទៅ កាលណាកើតមានបញ្ហាអ្វីមួយ[៥៦] គេកំណត់បញ្ហានោះថាជាទណ្ឌកម្ម ឬជារង្វាន់នៃអំណាចអភិធម្មជាតិ[៥៧]។

ប្រសិនបើមូលហេតុនៃបញ្ហាមានទាក់ទងទៅនឹងកម្មផល[៥៨] គេអាចមានលទ្ធភាពតិចតួចណាស់ក្នុងការធ្វើសកម្មភាពអ្វីមួយក្រៅពីការព្រមទទួលយកព្រេងវាសនាដែលគេចាត់ទុកថា ដូចជាលទ្ធផលនៃអំពើមកពីអតីតកាល។ មានតែការធ្វើអំពើល្អនៅពេលបច្ចុប្បន្នទេដែលអាចរៀបចំខ្លួនសំរាប់ពេលអនាគត[៥៩]។

---

54 . អ្នកតាគឺជាបុព្វបុរស អ្នករុករានដីស្រែចំការនៅទីកន្លែងមួយហើយដែលនៅក្រោយពេល ដែលគាត់ស្លាប់គេបានកសាងជាទីកន្លែងសំរាប់បូជា។ បុព្វបុរសបានទៅនៅបន្តការពារ "កូនចៅរបស់គាត់" ប្រឆាំងនឹងអានុភាពអាក្រក់មកពីខាងក្រៅហើយបានដាក់ទោសដល់ជនណាដែលប្រព្រឹត្តល្មើសបទបញ្ជា។ អ្នកតាត្រួតត្រាទឹកដីមួយកន្លែងសំខាន់ដែរ។ អ្នកតាអាចមានរូបសំណាក ដើមឈើ ថ្ម ជានិម្មិតរូប។ នៅពេលមានបញ្ហានៅក្នុងភូមិ ឬនៅក្នុងគ្រួសារ (ជំងឺក្ស័យ ធន ការមានទុក្ខ ការមានជំងឺរាតត្បាត...) គេធ្វើការចូលរូបអារក្ស (នៅកំពង់ឃ្លាំងគេ ហៅថាមេមត់) ដែលមានព្រលឹងអ្នកតាមកសណ្ឋិត។ គេបាននិយាយជាមួយអ្នកតាពីមូលហេតុនៃជំងឺ។ នៅពេលដែលគេដឹងពីប្រភពជំងឺហើយពិធីសែនព្រេនបានធ្វើឱ្យធូរស្រាលដល់ព្រលឹងដែលមានការខឹងសម្បារ។

55 . យើងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃប្រផ្នូល "ការទាយ" ។ គំរោងការមួយអាចត្រូវ គាំងដោយសារប្រផ្នូលមិនល្អ ការជ្រើសរើសទីតាំងមិនល្អ ពេលវេលាមិនល្អ។ ប៉ុន្តែគេអាចធ្វើ ឱ្យបានល្អវិញដោយសារការរៀបចំពិធីពិសេសៗ។

56 . ជំងឺ ការមានទុក្ខព្រួយដដែលៗ ការលួច...

57 . Pou Saveros ច្បាប់សុភាសិត បទ២

58 . ការយល់ដឹងបីបែបអនុលោមទៅតាមឥរិយាបទរបស់ព្រះពុទ្ធសាសនារបស់ប្រជាពលរដ្ឋខ្មែរ គឺកុសល កម្មផល និងវដ្តសង្សារ។ កុសលគឺជាអំពើល្អ ដែលបានប្រព្រឹត្តនៅពេលបច្ចុប្បន្នកាល និងដែលបូករួមជាមួយនឹងការរស់នៅសព្វថ្ងៃដើម្បីសំរាប់ជាតិខាងមុខទៀត។ សេចក្តីសប្បុរសគឺជាមធ្យោបាយមួយ នៅក្នុងចំណោមមធ្យោបាយសំខាន់ៗដើម្បីនាំមកនូវកុសល។ ការអនុវត្តន៏តាមផ្លូវ សាសនាត្រូវបានគេរៀបចំឡើងដើម្បីអាចឱ្យមនុស្សម្នាក់ៗ សន្សំកុសល របស់ខ្លួន : ការប្រតិបត្តិ តាមបញ្ញត្តិសាសនានៅថ្ងៃសីល ការសូត្រធម៌ ការធ្វើអំណោយដល់វត្តអារាម។

អំពើអាក្រក់ គឺបាបក៏ដូចគ្នាដែរគឺត្រូវបានកត់ត្រាទុកនិងអនុភាពអវិជ្ជមាននៃអំពើទាំងនោះនឹងកើត មាននៅជាតិខាងមុខទៀត។ ទស្សនៈវិស័យ ទីពីរ កើតចេញមកពីទីមួយ វដ្តសង្សារបានផ្សាភ្ជាប់ទស្សនៈវិស័យទាំងពីរនេះ។ សេចក្តីស្លាប់ពុំមែនជាការបញ្ចប់ជីវិតទេ ប៉ុន្តែជាការឈាន ចូលទៅក្នុងជីវិតមួយទៀត។

**កម្មផល** : គំនិតដែលថាអំពើល្អឬ អំពើអាក្រក់ត្រូវបានចងចាំគឺដោយសារអំពើនោះនាំមកនូវ វិធានការជាក់ស្តែងដែលគេបានប្រព្រឹត្តអំពើល្អ ឬនិងអំពើអាក្រក់ ។ គំនិតនេះបានដក់ជាប់យ៉ាង ជ្រៅនៅក្នុងចិត្តរបស់ប្រជាជនអាស៊ី។ មនុស្សម្នាក់ៗបានយល់ស្របទៅតាមព្រេងវាសនា របស់ ខ្លួន សព្វថ្ងៃដែលទុកជារង្វាន់នៃអំពើរបស់ខ្លួនពីអតីតកាល។ នេះគឺពុំមែនជាការអត់ធ្មត់ទេ ប៉ុន្តែគឺជាការយល់ព្រមទៅសភាវៈមួយ។ គេមាន បុណ្យឬមានបាប។ ដូចនេះមនុស្សម្នាក់ៗជាអ្នកតាក់ តែងអនាគតរបស់ខ្លួន។

ប្រសិនបើមូលហេតុនៃបញ្ហាកើតដោយសារមន្តអាគម (ព្រលឹង អ្នកតា គ្រូធ្មប់) ការលុបលាងកំហុសអាចធ្វើបានជានិច្ច (សែនតាមពិធីក្នុងសាសនា ការរៀបចំកិច្ចការពារតាមមន្តអាគម, ការកំចាត់មនុស្សដែលគេសន្មត់ថាជាគ្រូធ្មប់ ) ។

ក្នុងជីវិតប្រចាំថ្ងៃ លំនាំបែបនេះត្រូវសំដែងឡើងដោយការភ័យខ្លាចមានការប៉ះពាលដល់របៀបរបបមួយដែលចាក់គ្រឹះដោយសារអំណាចអភិធម្មជាតិ និងទុរជនទាំងអស់។ ការភ័យខ្លាចអំពើអ្វីមួយដែលអាចធ្វើឱ្យបញ្ហាកាន់តែរីករាលដាលបានជំរុញមនុស្សម្នាក់ៗឱ្យនៅស្ងៀមជាជាងធ្វើសកម្មភាព។ ឧទាហរណ៍ដូចជា នៅក្នុងករណីអ្នកជិតខាងធ្វើអ្វីមួយរំខានដល់ខ្លួន ឥរិយាបថទីមួយគឺត្រូវនៅស្ងៀមកុំនិយាយអ្វីទាំងអស់ ដើម្បីកុំឱ្យតើតមាន បញ្ហាធ្ងន់ធ្ងរទៅថ្ងៃក្រោយ។

ដោយសារអាកប្បកិរិយាពិសេសណាមួយ មនុស្សម្នាក់អាចមានគេសង្ស័យថាចេះមន្តអាគម ហើយមនុស្សនោះអាចដាក់ឱ្យនៅឯកកោគ្មានគេរាប់រក ឬជួនកាលត្រូវកំចាត់រូបរាងកាយចោលក៏មាន។

លោក A Forest បានធ្វើការកត់សំគាល់ថា គេត្រូវនៅស្ងៀមស្ងាត់"ដើម្បីជាផ្នូរកុំឱ្យគេបំបិទបុគ្គលិកលក្ខណៈ និងជាការផ្តួចផ្តើមគំនិតណាមួយ[៦០]"។

នៅក្នុងពេលធ្វើដំណើរទៅស្រុកស្រែចំការកម្ពុជា Emile Senart បានធ្វើការកត់សំគាល់ថានៅគ្រប់ទីកន្លែង "គ្មាននរណាម្នាក់ខ្វល់នឹងធ្វើឱ្យប៉ះពាល់ដល់ទម្លាប់របស់អ្នកដ៏ទៃសូម្បីតែបន្តិចឡើយ"។

បុគ្គលម្នាក់ៗបានដក់ជាប់នូវទស្សនៈព្រះពុទ្ធសាសនាៈ ភាពមិនទៀងទាត់នៃសត្វលោក (មនុស្ស) និងវត្ថុផ្សេងៗការទទួលស្គាល់ទុក្ខថាជាវាសនាដូចៗគ្នារបស់មនុស្សជាតិ ហើយសេចក្តីស្លាប់គឺជារឿងដែលពុំអាចជៀសផុតបានទេ។ ផលនៃអំពើល្អគឺបុណ្យ ឯផលនៃអំពើអាក្រក់គឺបាប សំរាប់ជាតិក្រោយ (បានដកស្រង់យ៉ាងទូលំទូលាយចេញពីក្បួនច្បាប់សីលធមិដែលបានពិពណ៌នាពីមុនមក)។

តាមមតិរបស់លោក Francois Ponchand, គំនិតទាំងអស់នេះបានយកទម្រង់តាមបែបបុគ្គលនិយមហើយនឹងការផ្តាច់ខ្លួនចេញពីកិច្ចការពិភពលោក[៦១]។ "ព្រះពុទ្ធសាសនាបានផ្តល់ភាពអនុគ្រោះបែបបុគ្គល

---

[59] . Ros Chantrabot សាធារណរដ្ឋខ្មែរៈ ១៩៧០-១៩៧៥ L Harmattan ១៩៩៣ *ទំព័រ* ១៥១។ "ការបកស្រាយពីគោលការណ៍ព្រះពុទ្ធសាសនាទាំងអស់ ដែលគេបានជួបប្រទះនៅក្នុងចំណោមប្រជាពលរដ្ឋខ្មែរបានវិលនៅជុំវិញស្នូលពីរគឺ ជាតិមុននិងការចាប់កំណើតនៅជាតិក្រោយ។ ឥឡូវនេះពុំមានទេ ឬគ្រាន់ តែជាផលវិបាកនៃជាតិមុននិងជាការរៀបចំខ្លួនរបស់មនុស្សម្នាក់ៗសំរាប់ជាតិខាងមុខ។ គឺត្រូវតែទទួលស្គាល់កម្មផលរបស់ខ្លួន។ គេបាននិយាយថា កម្ពុជាទាំង មូលបានសងកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តក្នុងសម័យអង្គរប្រឈមមុខទល់នឹងគំនិតនៃការអត់ធ្មត់នេះ និងការជឿទៅលើកម្មវាសនាដែលព្រះពុទ្ធសាសនា បានដឹកនាំយើងទាំងអស់គ្នា។ យើងត្រូវតែរៀនសូត្រនិងស្នើឱ្យ មានការបកស្រាយជាច្រើនទៀតអំពី សីលធមិព្រះពុទ្ធសាសនារបស់ខ្លួន "។

[60] . Forest 1992 *ទំព័រ* ៩១។

និយម របស់ប្រជាកសិករខ្មែរដោយបង្ហាត់បង្រៀនថា "ខ្លួនទីពឹងខ្លួន" "គ្មាននរណាម្នាក់អាចជួយអ្នកដទៃឱ្យរួចផុតពីអំពើបាបឡើយ"។ ការប្រាថ្នាចង់បានពិភពលោកមួយដែលយុត្តិធម៌និងមានសាមគ្គីភាព ហាក់ដូចជាធ្លាក់ទៅជួរទីពីរ វិញគឺនៅបន្ទាប់ពីការទទួលកុសលផ្ទាល់ខ្លួនសំរាប់បើកផ្លូវទៅរកជីវិតដ៏ប្រសើរនៅពេលអនាគត...។ ពិភពលោក ផ្តល់ផលប្រយោជន៏តិចតួចណាស់ ពីព្រោះពិភពលោកគ្រាន់តែជាអាការៈខាងក្រៅបណ្តោះអាសន្នប៉ុណ្ណោះ។ គេបំភ្លេចអំពើអាក្រក់ដែលអ្នកដទៃបានប្រព្រឹត្តមកលើខ្លួន ដោយពុំបាច់អត់ទោសឱ្យអ្នកនោះផង ត្បិតពលរដ្ឋខ្មែរម្នាក់មិនអាចអត់អោនទោសឱ្យអ្នកណាទៀតបានទេ ដោយហេតុថាកុសលនិងអកុសលនៅអន្ទោលតាមអ្នក ប្រព្រឹត្តរៀងរហូតដូចស្រមោលអន្ទោលតាមប្រាណរបស់ខ្លួនដែរ"។ ដើម្បីឱ្យបានរួចផុតអំពីទុក្ខវេទនាទាំងអស់នេះ គេបានលើកទឹកចិត្តឱ្យត្រឡប់ទៅរកការអនុវត្តន៏តាមបែបគុណធម៌[៦២] ការគោរពក្បួនច្បាប់នឹងធ្វើអំពើល្អដោយការធ្វើទាន[៦៣]។

ទោះបីអ្នកភូមិមានការយល់ដឹងតិចតួចអំពីអត្ថបទព្រះពុទ្ធសាសនាក្តី[៦៤] តែសិក្ខាបទទាំងប្រាំជាមូលដ្ឋានត្រូវបានដឹងទាំងអស់គឺៈ មិនឱ្យសម្លាប់ជីវិតគេ មិនឱ្យភូតកុហកគេ មិនឱ្យសេពសុរា មិនឱ្យលួចប្រពន្ធគេ និងមិន ឱ្យលួចរបស់គេ ។

នៅពេលមានធម្មទេសនា ព្រះសង្ឃមើលសាស្ត្រាដែលសំដែងពីរឿងនិទាននៃជីវិតជាតិមុនៗរបស់ព្រះពុទ្ធៈ គឺរឿងជាតក។ រឿងនិទានមួយក្នុងចំណោមរឿងនិទានជាច្រើនរបស់ព្រះពុទ្ធដែលគេបានស្គាល់ជាងគេគឺរឿងព្រះវេស្សន្តរ។ រឿងព្រះវេស្សន្តរបានឱ្យតម្លៃទៅលើការធ្វើទាន។ ព្រះវេស្សន្តរបានធ្វើការបរិច្ចាគទានដោយប្រគល់ប្រពន្ធនិងកូនទៅឱ្យតាចាស់ម្នាក់ដែលគាត់បានសុំពីព្រះវេស្សន្តរ ។

គេសង្កេតឃើញថានៅក្នុងការអនុវត្តន៏គំនិតនៃសេចក្តីសប្បុរស ឬការធ្វើទាន ភាគច្រើនដោយលុយកាក់គឺសំដៅទៅរកវត្តអារាម។ ព្រះសង្ឃជាអ្នកពង្រឹងប្រសិទ្ធភាពនៃការធ្វើទាននៅតាមវត្តអារាម និងជាអ្នកនៅកណ្តាលរវាងពុទ្ធសាសនិកនិងព្រះពុទ្ធ។ បច្ច័យត្រូវបានបង្ហាញជាសាធារណៈ ហើយសង្គមបានប្រកាសទទួលស្គាល់ការដឹងគុណចំពោះម្ចាស់អំណោយ។ ម្ចាស់អំណោយនឹងបានទទួលកុសលផលបុណ្យរៀងៗខ្លួននៅជាតិក្រោយ។

---

61 . Ponchaud Francois in dessier pour un debat លេខ ៤ *ទំព័រ* ១៤៣-១៥១ . *ទំព័រ* ១៤៨

62 . Pou Saveros កំរងច្បាប់ ច្បាប់ទូន្មានខ្លួន បទ ២២ ២៣ (គួរតែសាងសីលទាន នោះនឹងបានបុណ្យលាងបាប រក្សាសីលដរាប នោះប្រសើរពេកកូនអើយ។ អស់ទ្រព្យសម្បត្តិ នៅមិនបានទៅតាមខ្លួនឡើយ មានតែសីលទានហើយទៅកំដរបរលោកនាយ។)

63 . ដែលនឹងត្រូវត្រឡប់ទៅវត្តអារាមវិញ។

64 . នៅមុនឆ្នាំ ១៩៧០ ប្រពៃណីចង់ឱ្យមនុស្សប្រុសចូលបួសជាសង្ឃរយៈពេលខ្លីឬវែង។ ការអនុវត្តន៏បែបនេះពុំសូវមានទេនៅពេលបច្ចុប្បន្នកាលនេះ។

ចំពោះជនទាំងឡាយណាដែលប្រឆាំងនឹងក្បួនច្បាប់នេះ គេទាយថានឹងចាប់កំណើតយ៉ាងអាក្រក់នៅជាតិមុខ ក្រោយពីការឆ្លងកាត់ឋាននរកតាមបែបព្រះពុទ្ធសាសនា[៦៥] ។

មរណភ័យនៅឋាននរក តាមផ្នែកព្រះពុទ្ធសាសនា ត្រូវបានសរសេរនឹងគូរនៅលើជញ្ជាំងព្រះវិហារក្នុងលក្ខណៈដើម្បីបំបាក់ស្មារតីឱ្យបានខ្លាំងក្លា[៦៦] ។ អំពើអាក្រក់នីមួយៗត្រូវទទួលទណ្ឌកម្មដោយឡែកៗ។ គេបានមើលឃើញរូបភាពមនុស្សម្នាក់ដែលត្រូវគេយកដង្កាប់ទៅកាត់អណ្តាតគាត់ ដោយសារគាត់បាននិយាយពាក្យអាក្រក់...។ ផ្ទុយទៅវិញ ជនទាំងឡាយណាដែលធ្វើតាមក្បួនច្បាប់ទាំងអស់នោះនឹងត្រូវបានធានាថា ចាប់ជាតិឡើងវិញយ៉ាងសុខសប្បាយ[៦៧] ។

គេក៏ទទួលស្គាល់ផងដែរអំពីអ្នកតា ឬព្រលឹងខ្មោចមាតាបិតាដែលមានតួនាទីទប់ទល់នឹងអំពើអាក្រក់។ ព្រលឹងទាំងនោះបានដាក់ទណ្ឌកម្មជនទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងរបៀបរបបដែលមានមកដោយការនិយាយច្រើនហួសហេតុពេក ដោយការចំអកឡកឡឺយ ដេរប្រមាថច្រើនដើរឬបន្ទោរបង់ដាក់កន្លែងអ្នកតា[៦៨] ។

តាមមតិរបស់លោក Forest[៦៩] គេស្រណុកនិយាយជាមួយអ្នកតា ហើយអ្នកតាងាយបន្ទន់ចិត្តជាងព្រះពុទ្ធ។ មានតែអ្នកតាទេដែលប្រជាពលរដ្ឋទៅបន់ដើម្បីជួយដោះបញ្ហាប្រចាំថ្ងៃ។

ក្នុងខណៈដែលព្រះពុទ្ធសាសនានិយាយអំពីកម្មផលដែលជាការកត់ត្រាឥតខ្ចោះពីអំពើល្អនិងកំហុស ហើយដាក់ចុះនូវរង្វាន់ ឬការដាក់ទណ្ឌកម្មទៅតាមអំពើរបស់មនុស្ស ជំនឿលើអ្នកតាផ្តល់ច្រកមួយសំរាប់ឱ្យអ្នកជឿពឹង ផ្អែកថែមទាំងញុំាងមិនឱ្យពឹងផ្អែកទៅលើផលកម្មទាំងស្រុងផង។ ថ្វីបើកម្មគឺជាគោលការណ៍ទណ្ឌកម្មមួយមានលក្ខណៈបែបត្រជាក់ គេឃើញដូនតាដែលស្គាល់សារជាតិរបស់មនុស្សមិនអាចបណ្តោយឱ្យគេពត់បានទេ ដូច្នេះអ្នកតាតឹងតែងណាស់។ អ្នកតាពូកែ តែអ្នកតាចេះអត់អោន លុបបំបាត់កំហុសទាំងឡាយ

---

65 . Pou Saveros កំរងច្បាប់ ច្បាប់ទូន្មានខ្លួន បទ ១៨ ១៩ ២០ (បើខ្លួនមានស័ក្តិបុណ្យ បានទ្រព្យធនខ្ញុំពលរេហ៍ ធ្វើចិត្តឱ្យត្រង់ត្រៃជាតិទៅមុខនឹងបាន ទៀត។ ស៊ីបានៗនឹងខំ លោភវាយដំគេបៀនបៀត បំបាត់ទ្រព្យគេឆ្លៀត ខុសច្បាប់ផងមិនទេឡើយ។ ល្អតែនៅលោកិយ លុះដល់ក្ស័យជីវិតហើយ ទល់ទុក្ខពុំដែលស្បើយ រូបវែងរងកម្មវេទនា។)

66 . Pou Saveros កំរងច្បាប់ ច្បាប់ទូន្មានខ្លួន បទ ១៨ ១៩ ២០ (មានខ្លួននោះដាចដាច់ អស់ទាំងសាច់ឈឺខ្លោចផ្សាវាត្រូវនឹងបន្លាសឹងដែកដាមុតធ្លាយធ្លុះ។ ហើយធ្លាក់ពីបន្លា ដើមរកាដែកធំនោះ ធ្លាក់ចុះក្នុងទឹកខ្ទុះ ប្រែផ្សាក្តៅឥតសម្រាន្ត។ ហើយហែលក្នុងទឹកនោះ ស្លាប់ហើយរស់ លំបាកប្រាណ ពីរពាន់ឆ្នាំទើប បានរួចមកកើតជាមនុស្សា។)

67 . Pou Saveros កំរងច្បាប់ ច្បាប់ទូន្មានខ្លួន បទ ៥១ ៥២ (កើតកបទ្រព្យរបស់ ខ្ញុំស្រីប្រុសគោក្របី មាសប្រាក់ឥតខ្វះអ្វីមានទូកក្តាច្រវ៉ារហោង។ មានកើ្ត កោះស្រែស្រូវ ចេកអំពៅដូងស្លាផង នោះច្រើនៗពេកហោង សឹងលើសលន់ប៉ុនប្រមាណ។)

68 . គេមានការភ័យខ្លាចក្នុងការដើរកាត់កន្លែងដែលគេមិនដែលស្គាល់ ឬ ដែលមិនមានអ្វីចំណាំ ព្រោះគេខ្លាចរំខានអ្នកថែរក្សាទឹកដីទីនោះ ហើយខ្លាចទទួល ទណ្ឌកម្ម។

69 . ( FOREST 1992 ) *ទំព័រ* ៨៣

ដែលគេបានធ្វើនៅលើទីកន្លែងរបស់គាត់យ៉ាងឆាប់រហ័ស និងជាបន្ទាន់ នៅពេលណាអ្នកប្រព្រឹត្តបានកែខ្លួនសារភាពចំពោះគាត់ ឬសែនអ្វីដល់គាត់។ ឧទាហរណ៍ នៅពេលមានជម្ងឺ ឬមានការជ្រួលច្របល់ដោយការភ័យខ្លាច/ក្នុងករណីមានការគំរាមកំហែងដោយសង្គ្រាម ប្រជាកសិករនៅតែមានសេចក្តីសង្ឃឹមលាក់កំបាំងមួយគឺថា អ្នកតាត្រូវដាក់ទណ្ឌកម្មទៅ អ្នកធ្វើសង្គ្រាមនោះដោយសារទោសកំហុសដែលគេបានធ្វើទៅលើអ្នកតា។ អំពើនេះ សឱ្យឃើញពីការស្រវាស្រទេញរបស់ប្រជាកសិករក្នុងការទៅរកអ្នកតា និងសឱ្យឃើញអំពីកម្លាំងផ្សារភ្ជាប់របស់អ្នកតាជាមួយប្រជាកសិករទាំងនោះ។ បើគេជឿថា អ្នកតាអាចដាក់ទណ្ឌកម្មដល់គេ គេក៏មានសង្ឃឹមថាអ្នកតាអាចអត់អោនជួយធ្វើឱ្យជាសះស្បើយ និងធ្វើឱ្យបាត់ការភ័យខ្លាចដែរ។

លោក A.Forest[៧០] បានបង្ហាញថាមូលហេតុដំបូងបង្អស់នៃទំនាស់រវាងប្រជាពលរដ្ឋគឺ ការប្រើពាក្យសំដីមិនស្គាល់កាលៈទេសៈ។ អាកប្បកិរិយាបែបនេះត្រូវបានអ្នកតាដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត :

- "អ្នកតាដាក់ទណ្ឌកម្មជនទាំងឡាយដែលនិយាយពាក្យមិនគិតនឹងបំផ្លើស ជាអ្នកអួតអាង សើចច្រើនហួស ជេរប្រមាថគ្នាទៅវិញទៅមកឬប្រើពាក្យអាសគ្រាម។ អ្នកណានិយាយច្រើនពេកគេឱ្យឈ្មោះថាមាត់អាក្រក់"។
- "ភាពតឹងរឹងរបស់អ្នកតានៅទីកន្លែងដែលមានអ្នកនិយាយអាក្រក់ ដោយឥតមានការពិចារណាពីព្រោះថា ពាក្យសំដីអាក្រក់ទាំងនេះគឺជាប្រភពទីមួយនៃទំនាស់រវាងប្រជាជន ហើយសំដីទាំងនោះហាក់ដូចជាការបញ្ជាក់ពីការឃ្លាតចាកពីក្រឹតក្រមសង្គមក្នុងបំណងចង់ត្រួតត្រាលើអ្នកដទៃ។

  ការនិយាយព្នៗកាលពីមុន មានន័យថាជាការ "អួតអាង" ល្មើសលើក្បួនច្បាប់ឯកឆន្ទនិយម និង "សមភាពនិយម" ដែលគ្របដណ្តប់នៅក្នុងទំនាក់ទំនងសង្គម។ និយាយដោយខ្ជីគឺបំបែកសភាពស្ងប់ស្ងាត់និងសុខសាន្តដែលជាឧត្តមគតិរបស់ស្រុក"។

ក្បួនច្បាប់សំខាន់ៗ ដែលទាក់ទងទៅនឹងការប្រព្រឹត្តិនៅក្នុងសង្គមជំរុញឱ្យគេជៀសវាងការប្រឈមមុខដាក់គ្នា និងឱ្យចេះអត់ទ្រាំទៅតាមព្រេងវាសនារបស់ខ្លួន។ ការភ័យខ្លាចរំខានវត្ថុសក្តិសិទ្ធិ បានជួយដល់ការទប់ទល់កុំឱ្យមានទំនាស់ ក៏ប៉ុន្តែ ក៏នាំឱ្យមានការចងគំនុំក្នុងចិត្តចំពោះបញ្ហាមួយដែលពុំបានដោះស្រាយដែរ។ ជាញឹកញាប់ណាស់ នៅពេលដែលអនីតិជនប៉ះទង្គិចគ្នា អំពើហឹង្សាដែលកើតដោយការឆ្លើយតបដោយពាក្យសំដី ឬដោយការប៉ះពាល់លើរូបរាងកាយ គឺជាវិធានការនៃការគុំនៅក្នុងចិត្តតាំងពីយូរមកហើយ។

70 . ( FOREST 1992 ) *ទំព័រ* ៤៩-៥០

# សំយោគជំពូក ១
# មរតកពីអតីតកាលៈ
# ក្របខ័ណ្ឌវប្បធម៌

*សង្គមខ្មែរគឺជាសង្គមបែបជនបទនឹងមានលក្ខណៈអភិរក្សខ្លាំង ។ សង្គមខ្មែរនៅតែផ្សារភ្ជាប់ទៅនឹងគ្រឹះប្រពៃណីដែលត្រូវរិចរិលយ៉ាងខ្លាំងដោយសារសង្គ្រាមរាប់សតវត្សជាមួយប្រទេសជិតខាង ។ ដោយសារការរស់នៅជាក្រុមតូចៗពីក្រុមមួយទៅមួយក្រុមទៀត ក្រុមគ្រួសារទាំងនោះរស់នៅដោយមានការភ័យខ្លាចការប៉ះទង្គិចទៅ លើវត្ថុសក្តិសិទ្ធិ ឬខ្លាចរំខានដល់មន្ត្រីរដ្ឋបាលស៊ីវិល ។*

*ក៏ប៉ុន្តែ ការខ្វល់ចង់បានកិច្ចការពារខ្លួន បានញ៉ាំងឱ្យគេខិតខំស្វែងរកការជួយគាំពារដែលឋិតនៅខាងក្រៅរង្វង់គ្រួសារតូច ។ សមាគមក្រៅផ្លូវការតូចធំជាច្រើន ( មនុស្សម្នាក់ឬបណ្តាញនយោបាយ) ត្រូវបានបង្កើតឡើង ដោយផ្អែកទៅលើទំនាក់ទំនង គ្រួសារបង/ប្អូន អ្នកការពារ/អ្នកបានទទួលការការពារ ។ ទំនាក់ទំនងទាំងនេះងាយប្រែប្រួលណាស់ ។ ទំនាក់ទំនងនេះអាចមានឬដាច់ទៅវិញយ៉ាងងាយបំផុត ដោយយោលទៅលើភាពមិនទៀងទាត់នៃប្រវត្តិសាស្ត្រ និងយោលទៅតាមកាលៈទេសៈ ។ ប្រសិនបើមេបាត់បង់ អំណាច ។ អ្នកទាំងឡាយដែលទទួល កិច្ចគេការពារនឹងទៅរកអ្នកការពារម្នាក់ផ្សេងទៀត[៧១] ។*

*ស្របជាមួយគ្នានេះ ប្រព័ន្ធរដ្ឋបាលរឹងកំព្រឹសដែលដាក់បង្ខំដោយអាណានិគមបារាំង និងត្រូវពង្រឹងដោយរបបកុម្មុយនីស្តពុំបានទទួលការយល់ព្រមឱ្យបានត្រឹមត្រូវទេ ។*

*គឺមានក្បួនច្បាប់តិចតួចណាស់សំរាប់ការរស់នៅជាសង្គម ដែលមានការរៀបចំយ៉ាងរឹងមាំ ។ នៅក្នុងស្រុក, ក្បួនច្បាប់ជាទូទៅគឺជាក្បួនច្បាប់ដែលមិនធ្វើឱ្យប៉ះពាល់ដល់ភាពស្ងប់ស្ងាត់ ។ ក្បួនច្បាប់ដែលស្តីអំពីអាកប្បកិរិយា ក្នុងសង្គមត្រូវបានយកមកបង្រៀនដែលនៅក្នុងនោះមានសុភាសិតរឿងប្រឌិត ក្រមសីលធម៌/គួបផ្សំជាមួយគោលការណ៍ព្រះពុទ្ធសាសនា ។ ក្បួនច្បាប់ទាំងនោះគឺដើម្បីថែរក្សាអ្វីខ្មែរលោក* Vighen *ហៅថា "យុទ្ធសាស្ត្រដើម្បីស្វែងរកមតិរួម" ។ ឥរិយាបថដែលមានតម្លៃគឺជាឥរិយាបថដែលពុំធ្វើឱ្យគេមានការចាប់អារម្មណ៍ ស្គាល់ឋានៈខ្លួនឯង និងកុំបញ្ចេញមនោសញ្ចេតនារបស់ខ្លួនឱ្យគេដឹង ។ នៅពេលមានទំនាស់ ការបំបិទមនោសញ្ចេតនាផ្ទាល់ខ្លួន ត្រូវបានទាមទារដើម្បីជៀសវាងការបាត់សណ្តាប់ធ្នាប់ ។ ភាពតានតឹង នៅក្នុងចិត្តបានលិចបាត់ទៅក្នុងអសម្បជញ្ញាការវប្បធម៌ ។*

---

[71] . ដូចនេះគេអាចលើកឡើងអំពីការចាកចេញយ៉ាងច្រើនរបស់ក្រុមនយោបាយមួយ ដើម្បីទៅចូលជាមួយក្រុមមួយទៀតដែលហាក់ដូចជាកង្វល់ដ៏ធំមួយនៅក្នុងការការពារគ្រួសារមួយដែលមានតែប្តីប្រពន្ធនិងកូន ។

ជាទូទៅ គោលការណ៍តាមបែបព្រះពុទ្ធសាសនាក៏ដូចជាជំនឿរបស់ប្រជាពលរដ្ឋដែលទាក់ទងទៅនឹងការជឿទៅលើព្រលឹងនឹងអ្នកតាក្នុងការបង្កាការទាស់ទែងគ្នា និងបង្កាទំនាស់ ។ ក៏ប៉ុន្តែ គោលការណ៍និងជំនឿទាំងនោះផ្តែកលើរង្វាន់/ទណ្ឌកម្មផ្ទាល់ខ្លួនច្រើនជាងការទទួលខុសត្រូវរួម ។

ក្រមព្រះពុទ្ធសាសនាដែលនាំចូលមកពីប្រទេសសេរីលង្កា មានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងអត្ថបទនានា ។ ក្បួនច្បាប់នៃការរស់នៅក្នុងបរិវេណវត្តអារាម មានថែងអំពីឥរិយាបថថ្លៃថ្នូរ និងក្បួនច្បាប់សំរាប់ការដាក់ទណ្ឌកម្ម ។ ចូរយើងកត់សម្គាល់ថា ក្បួនច្បាប់នោះមានជាប់ទាក់ទងជាពិសេសទៅនឹងការប្រព្រឹត្តិរបស់ព្រះសង្ឃនៅក្នុងវត្តអារាម ហើយពុំអនុវត្តទៅលើគ្រហស្ថទេ ។

ដូចនេះ គ្រឹះវេចវិលនៃប្រពៃណីដ៏ចាស់ក៏នៅតែមានទម្ងន់យ៉ាងខ្លាំងមកលើការប្រព្រឹត្តរបស់សង្គមសព្វថ្ងៃនេះដែរ ។

កាលពីជំនាន់ដើម ក្បួនច្បាប់សីលធម៌និងសាសនាទាំងនេះអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាករចំនួនតូច និងនៅដាច់ៗពីគ្នា ។ ប្រទេសដែលមានប្រពៃណីចាស់នេះ បានបើកចំហយ៉ាងឆាប់រហ័សឆ្ពោះទៅរកភាពប្រាកដនិយមនៃពិភពលោកខាងក្រៅថ្មីមួយ ។ ចំនួនប្រជាពលរដ្ឋបានកើនឡើង ហើយសេចក្តីត្រូវការផ្នែកសេដ្ឋកិច្ចនិងការវិវត្តន៍របស់សង្គម ដែលជំរុញដោយមធ្យោបាយគមនាគមន៍ទំនើបកំពុងបោះពួយទៅ ។

នៅក្នុងវប្បធម៌ប្រពៃណីខ្មែរ មធ្យោបាយតិចតួចណាស់ដែលសំរាប់បំរើតម្រូវការរបស់បុគ្គល ដើម្បីដោះស្រាយសភាពការណ៍ពិភពថ្មីមួយនៅចំពេលដែលមនុស្សត្រូវរស់នៅលាយឡំគ្នាកាន់តែខ្លាំងឡើង ហើយទំនាក់ទំនងរវាងបុគ្គលនិងបុគ្គលគឺ មាននិន្នាការទៅរកភាពស្មើគ្នា[៧២] ។

[72] . ភាគច្រើននៅក្រោយការគាបសង្កត់របស់អង្គការអន្តរជាតិនិងអង្គការក្រៅរដ្ឋាភិបាល

# II. ក្របខ័ណ្ឌប្រវត្តិសាស្ត្រ

## មរតកនៃប្រវត្តិសាស្ត្រពេលថ្មីៗនេះនៅក្នុងការដោះស្រាយទំនាស់នៅមូលដ្ឋាន

ក្នុងរយៈពេលបីទសវត្សនៃសង្គ្រាមនិងរបបបង្ខិតបង្ខំចុងក្រោយនេះ មូលដ្ឋានគ្រឹះប្រពៃណីរបស់សង្គមខ្មែរមានការភាន់ប្រែយ៉ាងខ្លាំង ។

នៅចុងទសវត្សទី៦០ ព្រះរាជាណាចក្រកម្ពុជាបានរស់នៅយ៉ាងសុខសាន្តបំផុត។ ប្រជាកសិករបានរៀបចំការរស់នៅទៅតាមទំនៀមទម្លាប់របស់ខ្លួន។ នៅឆ្នាំ១៩៧០ ព្រះអង្គម្ចាស់សិរិមតៈ និងលោកឧត្តមសេនីយ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចសីហនុ ហើយបានធ្វើឱ្យប្រទេសដ៏តូចនេះប្រែក្រឡាស់ធ្លាក់ទៅក្នុងសង្គ្រាមឥណ្ឌូចិនជាលើកទី២។ ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងការបំផ្លិចបំផ្លាញនិងភាពអន្ធការ។

ការទម្លាក់គ្រាប់បែករបស់អាមេរិកនៅលើទឹកដីខ្មែរជាដំបូងនៅតាមបណ្តោយព្រំដែនវៀតណាម[៧៣] បន្ទាប់មកទម្លាក់នៅក្នុងប្រទេសខ្មែរកាន់តែមានសភាពខ្លាំងក្លា ហើយបានធ្វើឱ្យប្រជាពលរដ្ឋដែលខ្វះស្បៀងអាហារ នាំគ្នារត់ចូលមកទីក្រុង។ នៅចំពោះមុខការអាប់អោននៃរបបមួយដោយសារអំពើពុករលួយ ពួកដែលហៅថា"ខ្មែរក្រហម" ដណ្តើមបានទឹកដីជាច្រើននៅស្រុកស្រែចំការ ហើយបានចាប់ផ្តើមនយោបាយសហគមន៍របស់ខ្លួនជាបណ្តើរៗ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានធ្វើជាម្ចាស់លើប្រទេសទាំងមូល និងដេញប្រជាពលរដ្ឋទាំងអស់ឱ្យចេញពីទីក្រុង។ សង្គ្រាមបានបញ្ចប់ ក៏ប៉ុន្តែកំរិតនៃការបំផ្លិចបំផ្លាញមានកំរិតខ្ពស់បំផុត ហើយសេចក្តីភ័យរន្ធត់បានមកដល់។ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រជាពលរដ្ឋត្រូវបានគេជម្លៀសនៅពេញទូទាំងប្រទេស។ សាសនាក៏ដូចជាតម្លៃនៃសង្គមទាំងមូលកាលមុន ឆ្នាំ១៩៧០ ត្រូវបានបំផ្លាញចោលអស់។ ក្រុមប្រជាជននិងសមាជិកនៃគ្រួសារដែលពីមុនបានរួមប្រជុំជា មួយគ្នាបានក្លាយទៅជាសត្រូវដាក់គ្នាដោយសារតែសេចក្តីសំរេចរបស់មេដឹកនាំ (ប្រជាពលរដ្ឋនៅខាងខ្មែរ ក្រហមនឹងប្រជាពលរដ្ឋនៅក្នុងរបប លន់ នល់ ប្រជាពលរដ្ឋដែលរស់នៅទីក្រុងនិងប្រជាពលរដ្ឋនៅស្រុក ស្រែចំការ បញ្ញាជននិងអ្នកល្ងង់ខ្លៅ ឪពុកម្តាយនិងកូន...)។ គ្រោះទុរភិក្ស ការបាក់កម្លាំង និងការសម្លាប់ មនុស្សបានធ្វើឱ្យមនុស្ស ស្លាប់ជាច្រើន[៧៤] ។

---

73 . ផ្លូវលំ "ហូជីមិញ " ដែលអាចធ្វើការផ្គត់ផ្គង់ដល់ពួកយៀកកុងពីភាគខាងជើងទៅភាគខាងត្បូងប្រទេសវៀតណាមបានឆ្លងកាត់តាមប្រទេសកម្ពុជា។

74 . តាមការវាយតំលៃរបស់អ្នកស្រាវជ្រាវប្រជាពលរដ្ឋខ្មែរពី ១,៣ ទៅ ១,៨ លាននាក់បាន ស្លាប់នៅក្នុងរបបខ្មែរក្រហម។ នៅក្នុងរឿងនេះដែរគេត្រូវបន្ថែមពីការចុះថយអាត្រាកំណើត យ៉ាងច្រើនទៀតផង។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានមករំដោះកម្ពុជា បន្ទាប់មកបានកាន់កាប់ប្រទេសនេះអស់រយៈពេលដប់ឆ្នាំ។ នៅក្នុងប្រទេសមួយដែលត្រូវបំផ្លិចបំផ្លាញទាំងស្រុង កងទ័ពវៀតណាមបានចាត់តាំងរដ្ឋបាលកុម្មុយនិស្តមួយដោយផ្អែកទៅលើប្រព័ន្ធគ្រប់គ្រងប្រជាពលរដ្ឋមួយ ដែលមានលក្ខណៈយ៉ាងតឹងរឹង។ នៅក្នុងព្រៃពួកអ្នកតស៊ូខ្មែរក្រហមបានរៀបចំអង្គការចាត់តាំងឡើងវិញ។ ដោយសារមានជំនួយពីមហាអំណាចបរទេស ខ្មែរក្រហមបានរៀបចំកងទ័ពនិងកាន់អាវុធឡើងវិញ។ រហូតដល់ចុងទសវត្សទី៩០ ពួកខ្មែរក្រហមបានកាន់កាប់ទឹកដីឡើងវិញ បានចំនួនមួយភាគធំនៅតំបន់ខាងជើងនិងខាងលិចនៃប្រទេស។ បន្ទាប់មកដោយពុំមានការគាំទ្រពីបរទេស ដែលជាចៅហ្វាយ មេដឹកនាំខ្មែរក្រហមជាច្រើនបានចុះចូលជាមួយរដ្ឋាភិបាល ឬត្រូវចាប់ខ្លួន។ បច្ចុប្បន្ននេះ ដោយយោលទៅលើសំណើរបស់មេដឹកនាំជាច្រើននិងក្នុងនាមនៃការផ្សះផ្សាជាតិ បងប្អូនកាលពីមុនសង្គ្រាម តែជាសត្រូវនឹងគ្នានៅពេលបន្ទាប់មកទៀតបានរស់នៅជាថ្មី ជាមួយគ្នាជាបងប្អូនឡើងវិញ។

ជាមួយគ្នានេះដែរ ចលនាបើកទូលាយ និងការអភិវឌ្ឍន៍បានចាប់ផ្តើមចាប់តាំងពីឆ្នាំ១៩៩៣ ដោយអ៊ុនតាក់[៧៥] បានមកដល់និងមានការរៀបចំការបោះឆ្នោតដោយសេរី។ គោលការណ៍ថ្មីៗជាច្រើន ដូចជាគោលការណ៍សិទ្ធិមនុស្សត្រូវបានផ្សព្វផ្សាយដោយអង្គការអន្តរជាតិ។ គោលការណ៍ថ្មីៗទាំងនោះបានមកបន្ថែមពីលើគ្រឹះប្រពៃណីខ្មែរដែលបានរេចរឹលយ៉ាងខ្លាំងទៅហើយ។

តាមរយៈការជួបសន្ទនាជាច្រើន យើងបានរកឃើញបញ្ហានៃការដោះស្រាយបញ្ហានិងការទប់ស្កាត់ទំនាស់នៅក្នុងសម័យកាលខុសៗគ្នា កាលពីអតីតកាលថ្មីៗនេះនៅកម្ពុជា។ មរតកក្នុងរយៈពេលសាមសិបឆ្នាំនៃសង្គ្រាមមានលក្ខណៈធ្ងន់ធ្ងរពិបាកក្នុងការដោះស្រាយណាស់។ នៅចន្លោះរវាងប្រពៃណីដែលនៅសេសសល់បន្តិចបន្តួច បទពិសោធន៍បែបកុម្មុយនិស្តជ្រុលនិយម និងការបើកទូលាយទៅពិភពលោកខាងក្រៅឆាប់ពេក សង្គមខ្មែរសព្វថ្ងៃ កំពុងសាកល្បងប្រមូលផ្តុំគ្នាឡើងវិញ និងសម្របសម្រួលទៅតាមតម្រូវការនៃសហសវត្សថ្មីមួយ ក៏ប៉ុន្តែនៅមានការលំបាកខ្លាំងណាស់។

យើងបានសាកសួរជនទាំងឡាយដែលយើងបានជួបប្រទះ ដើម្បីឱ្យគេនិយាយអំពីហេតុការណ៍ពីអតីតកាលនឹងសុំឱ្យគេនិយាយអំពីអ្វីដែលគេហៅថាទំនាស់ តើគេត្រូវគិតគូររស់នៅទប់ស្កាត់ និងដោះស្រាយតាមរបៀបបែបណានៅក្នុងសម័យកាលខុសៗគ្នាទាំងនោះ។

---

[75] . អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា។

# ១. ប្រពៃណី: សម័យមុនឆ្នាំ១៩៧០

## ១.១. ប្រភពលាយល័ក្ខអក្សរ:

តាមទិន្នន័យជាលាយល័ក្ខអក្សរ ឬតាមទិន្នន័យដែលបង្ហាញពីប្រពៃណីដោយផ្ទាល់មាត់ ការនិយាយយោងទៅលើទំនាស់ និងការដោះស្រាយទំនាស់នៅក្នុងសម័យកាលកន្លងមកមានចំនួនតិចតួចណាស់។ ឯកសារខ្លះដែលអធិប្បាយអំពីការរស់នៅប្រចាំថ្ងៃនៅកម្ពុជា ត្រូវបានសរសេរដោយការសង្កេតរបស់ជនបរទេសដែលបានធ្វើដំណើរមកកម្ពុជាក្នុងបេសកកម្មការទូត ការរុករក ឬការស្រាវជ្រាវផ្សេងៗ។ ក្នុងចំណោមកម្រងសៀវភៅជាច្រើនដែលយើងបានធ្វើការសិក្សា យើងអាចធ្វើការកត់ត្រាទុកបានចំនួនតិចតួចណាស់អំពីការពិពណ៌នាជាក់ស្តែង។ សៀវភៅដែលចាស់ជាងគេ គឺនៅសម័យអង្គរដែលជាស្នាដៃរបស់ជនជាតិចិនម្នាក់ឈ្មោះ ជាវ តាខ្វាន់ " Tcheou Ta Kouan [៧៦]"។ ក្រោយមក បន្ទាប់ពីការបាត់បង់អង្គរ ព្រៃឈើនិងការបំភ្លេចអង្គរបានធ្វើឱ្យប្រាសាទធំៗដែល សង់អំពីថ្មបានទទួលរងការវិនាសហិនហោចជាច្រើន។ យើងពុំមានទិន្នន័យពិតប្រាកដទេ។ ការស្រាវជ្រាវស៊ីជំរៅ ទៅលើអត្ថបទជាភាសាខ្មែរខ្លះ និងសេចក្តីរៀបរាប់របស់បេសកម្មបរទេស អាចផ្តល់ពន្លឺដ៏មានប្រយោជន៍បំផុត សំរាប់ការយល់ដឹងអំពីការប្រតិបត្តិបច្ចុប្បនេះ។ កិច្ចការនេះមានកំរិតហួសពីក្របខ័ណ្ឌការងារនេះ ប៉ុន្តែកិច្ចការនេះបានទាមទារឱ្យមានការស្រាវជ្រាវ។

---

[76] . PELLIO P ការចងក្រងស្តីអំពីទំនៀមទំលាប់ខ្មែររបស់លោក ជាវតាក្វាន់ ប៉ារីស Adrien Maison neuve 1951 ។

"ជាវតាក្វាន់" អ្នកការទូតចិនដែលបំពេញបេកសកម្មបានទៅដល់អង្គរនិងបានសរសេរអំពីអ្វីដែលគាត់បានរកឃើញ។ នៅក្នុងរឿងនិទានរបស់គាត់ៗ បានទុកមួយកថាខ័ណ្ឌសំរាប់រៀបរាប់អំពីការកាត់សេចក្តីនិងការដាក់ទោស។ គាត់បានលើកឡើងអំពីតួនាទីរបស់ព្រះមហាក្សត្រនិងអាទិទេពនៅក្នុងការវិនិច្ឆ័យរឿងនានា: "ការទាស់ទែងគ្នារបស់ប្រជាពលរដ្ឋ ទោះបីមានខ្លះឥតមានន័យអ្វីក៏ដោយ ក៏បានបញ្ជូនរហូតដល់ព្រះមហាក្សត្រដែរ។ គេពុំដែលឃើញការដាក់ទោសដោយការវាយនឹងដំបងឬស្សីស្រាល ឬធ្ងន់ទាល់តែសោះ គេផ្តន្ទាទោសដោយឱ្យបង់ប្រាក់តែប៉ុណ្ណោះ។ ក្នុងករណីមានការទាស់ទែង គ្នាគេបាននាំគ្នាគិតទៅតាមវិធីបែបអរូបិយឬការកាត់សេចក្តីដោយអាទិទេព។ អ្នកបង្ករឿងទាំងពីរនាក់បានយកដៃជ្រលក់ទៅក្នុងប្រេងកំពុងពុះ។

មានតែអ្នកប្រព្រឹត្តខុសទេដែលត្រូវឆេះដៃ។ នៅក្នុងករណីមួយទៀតអ្នកទាំងពីរនាក់ត្រូវបានយក ទៅដាក់នៅក្នុងប៉ម (tour)ម្នាក់ម្តងៗ អ្នកណា ប្រព្រឹត្តខុសនឹងមានជំងឺ។

- ការដាក់ទោសបានធ្វើឱ្យអ្នកដំណើរមានការយកចិត្តទុកដាក់។ នៅក្នុងករណីធ្ងន់ធ្ងរបំផុត ការដាក់ទោសប្រហារជីវិតត្រូវបានអនុវត្តន៏ : "នៅខាង ក្រៅទ្វារទិសខាងលិចគេជីករណ្តៅសំរាប់កប់ឧក្រិដ្ឋជន។ គេបានចាក់ដីបំពេញរណ្តៅ ពួនបង្ហាប់ជាការស្រេច"។ ក្នុងករណីស្រាលៗ គេអនុវត្តន៏ការកាត់ ម្រាមដៃម្រាមជើងនិងការកាត់ច្រមុះ។ ជាវតាក្វាន់ពុំបានដឹងច្បាស់ពីប្រភេទនៃទំនាស់ឬបទល្មើសទេ។ គាត់លើកតែឧទាហរណ៏មួយប៉ុណ្ណោះ គឺការផិតក្បត់ប្តីប្រពន្ធ។ ប្តីដែលមានការយល់ច្រលំបានរឹតជើងរបស់គូរសង្សារនៅក្នុងព្រួល។ អ្នកមានកំហុសត្រូវតែ ប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ទៅ ឱ្យប្តី។

អត្ថបទនានារបស់អ្នកស្រាវជ្រាវ និងអ្នករុករកសម័យចុងសតវត្សទី១៩ និងនៅដើមសម័យពាក់កណ្តាលសតវត្សទី២០ អាចរកបាន។ យើងបានយកស្នាដៃរបស់លោក A. Ledere ស្តីអំពីក្រមច្បាប់ ខ្មែរ[៧៧], Etienne Aymonier[៧៨] និង Evelyne Poree Maspero[៧៩] ។

នៅដើមទសវត្សទី៦០ លោកស្រី Gabrielle Martal ជាតិពិន្ទុវិទូរបារាំងម្នាក់បានធ្វើការពិពណ៌នាអំពីជាតិពិន្ទុនៅភូមិមួយដែលឋិតនៅជិតអង្គរ។ គាត់បានសរសេរអំពីការរស់នៅដ៏សុខសាន្ត ដែលទំនាក់ទំនងសង្គមមានលក្ខណៈងាយប្រែប្រួល ហើយដែលកម្រមានអំពើហឹង្សា[៨០] ។
លោកស្រី May Ebihara[៨១] នរៈវិទូសញ្ជាតិអាមេរិកម្នាក់បានបង្ហាញថា ពុំមានក្បួនច្បាប់ដែលមានលក្ខណៈជាកាតព្វកិច្ច និងកំណត់តឹងរឹងទៅលើការប្រព្រឹត្តរវាងបុគ្គលនិងបុគ្គលនោះឡើយ។

---

[77] . LECLERE ADHELMARD ក្រមកម្ពុជា ក្រមកម្ពុជា ប៉ារីស LEROU ១៨៩៨

[78] . AYMONIER ETIENNE កម្ពុជា ប៉ារីស LEROUX ៣ភាគ ១៩០០ ១៩០៤

[79] . POREE MASPERO EVELYNE ការសិក្សាអំពីពិធីនានានៃកសិករខ្មែរ ៣ភាគ Mouton et cie lahaye Paris ភាគ I ១៩៥២ ភាគ ២ ១៩៦៤ ភាគបី ១៩៦៩

[80] .ជីវភាពនៅក្នុងភូមិមានលក្ខណៈសុខសាន្តណាស់។ ការឈ្លោះទាស់ទែងគ្នា នៅក្នុងភូមិមានលក្ខណៈពិសេសណាស់ ។ ភាពស្ងប់ស្ងៀមនៃពិភពលោកនេះ។ ភាពស្លូតបូតគឺហាក់ដូចជា ផ្នែកមួយនៃសីលធម៌នៅ "កន្លែងនីមួយៗ" ។ ការទាស់គ្នា ការបង្ហាញអំពីអំពើហឹង្សា ហាក់ដូចជាធ្វើឱ្យប៉ះពាល់ដល់ក្បួនច្បាប់ នៃសុជីវធម៌របស់អ្នកភូមិ។ ហេតុដូចនេះហើយបានជាអាកប្បកិរិយានានា ពុំមានលក្ខណៈឃោរឃៅទេ ប៉ុន្តែមានលក្ខណៈអវិជ្ជមាន : ប្រសិនបើ មនុស្សពុំ មានសមានចិត្តទេ ឬប្រសិនបើមនុស្សចិញ្ចឹមកំហឹងតទល់គ្នា ជននោះចូលចិត្តធ្វើមិនដឹងខ្លួន "Martel ទំព័រ២០០។ ក្នុងរយៈពេលមួយឆ្នាំនៃការរស់នៅក្នុងភូមិ គាត់បានសង្កេត ឃើញមានជំលោះបីបែបៈ តាមលក្ខណៈទូទៅបរិយាកាសនៃការ រស់នៅក្នុងគ្រួសារមានលក្ខណៈសុខសាន្តណាស់សមាជិកម្នាក់ៗបានធ្វើការ កិច្ចការរបស់ខ្លួនដោយផ្ចិតផ្ចង់ និងក្នុងភាពស្ងាត់ស្ងៀម។ ជំលោះឬការ តបតគ្នាដោយពាក្យសំដីខ្លាំងៗ មានលក្ខណៈខុសពីធម្មតាណាស់ ហើយជួនកាលនៅពេលដែលពួកគេបានបង្កើតជំលោះទាំង នោះគេបានធ្វើយ៉ាងជាក់ស្តែងណាស់។ ក្នុងរយៈពេលមួយឆ្នាំនៃការស្នាក់នៅជំលោះដែល កើតមានឡើងនៅខាង ក្រៅនិងមានលក្ខណៈសំបើមអស្ចារ្យមានចំនួនបីបែប។ ជំលោះដ៏ខ្លាំងក្លាមួយបានកើតឡើងរវាងបងប្អូនពីរនាក់ដែលរស់នៅជាមួយគ្នា ហើយដែលកិច្ចការធ្វើស្រែរួមគ្នាហាក់ដូចជាមានលក្ខណៈមិនល្អសោះ។ បងប្អូន ម្នាក់បានចាក់ស្រូវចោលទៅលើកំទេចអស់មួយល្អី។ អ្នកជិតខាងជាច្រើនបានប្រឹងប្រែងសំរុះសំរួល ដើម្បីធ្វើឱ្យមានភាពស្ងប់ស្ងាត់វិញ។ អំពើទាំង នេះហាក់ដូចជាធ្វើឱ្យអ្នកទាំងពីរប៉ះទង្គិចគ្នាគឺដូចជាកំហុសមួយប្រឆាំងនឹង " ស្លាកស្នាម" គឺជាអំពើមួយដែល មិនគួរសចំពោះផ្នែកអ្នកទាំងពីរ។ ការទាស់ទែងពីរផ្សេងទៀតមានលក្ខណៈខុសៗគ្នាៈ ការទាស់ទែងបែបសាធារណៈនិងខ្លាំងក្លានៃអាជ្ញាធរដែលមានការ ទទួលស្គាល់ហើយគ្មាន ជនណាម្នាក់ចូលធ្វើអន្តរាគមន៍។ ប៉ុន្តែភាគីទាំងពីរពុំចុះសំរុងគ្នាឡើយនៅក្នុងពិភពដែលតាមធម្មតា មានសភាពយ៉ាងស្ងប់ស្ងៀមណាស់។ បងស្រីម្នាក់ដែលមានអាយុ២០ឆ្នាំបានវាយប្អូនប្រុសអាយុ ១៥ឆ្នាំ យ៉ាងខ្លាំង។ ប្អូនប្រុសដែលបានដេកនៅលើដីបានទទួលការវាយដំដោយពុំមានការតបតឡើយ។ ឪពុកបានវាយកូនស្រីអាយុ ៨ ឆ្នាំយ៉ាងខ្លាំង។ កូនស្រីបានលត់ជង្គង់សុំទោស និងសុំអង្វរសេចក្តីប្រោសប្រណី។ គឺត្រូវតែមានកំហុស ធ្ងន់ធ្ងរមួយព្រោះថាការវាយដំណើររូបរាងកាយរបស់កូនមានលក្ខណៈកម្រណាស់។ ជាថ្មីម្តងទៀតនេះ គឺជាហេតុការណ៍មួយដែលមានលក្ខណៈ ពិសេសណាស់ " Martel *ទំព័រ* ២០២

[81] . EBIHARA MAY ភូមិថ្មីមួយនៅកម្ពុជា និក្ខេបទថ្នាក់បណ្ឌិតសកលវិទ្យាល័យកូឡុំប៊ីយ៉ា ១៩៦៨ ( អាចធ្វើការពិគ្រោះនៅ CDRI )

### ១.២. ការចងចាំព្រឹត្តិការណ៍ដោយអ្នកនៅរស់និងដោយការនិទានៈ ទសវត្សឆ្នាំ ៥០ និង ៦០

ការវិលត្រឡប់ទៅរកហេតុការណ៍ជាច្រើនដែលបានកើតឡើង បានបង្ហាញឱ្យឃើញថាមានការលំបាកច្រើន។ នៅមុនជំនាន់របស់ជីដូនជីតា បញ្ជីរាយនាមរបស់ជីដូនជីតាទាំងអស់នោះបានបាត់បង់អស់ទៅហើយ។ ព្រឹត្តិការណ៍ចងចាំទាំងអស់នោះបានរលាយអស់នៅក្នុងពេលនោះដែរ។ គេបានចងចាំកាលបរិច្ឆេទនៃព្រឹត្តិការណ៍ធំៗ ប៉ុន្តែអនុស្សាវរីយ៍ខ្លះៗច្រឡំជាមួយជំនាន់ផ្សេងៗ។ ដូចនេះ ពាក្យទាំងឡាយសំរាប់និយាយអំពីការបែងចែងរដ្ឋបាល បានធ្វើឱ្យមានការច្រលំគ្នាជាមួយពាក្យនៅក្នុងរបបផ្សេងៗទៀត[៨២]។ ឈ្មោះមនុស្សបានផ្លាស់ប្តូរ។ ជាបន្ថែមទៀត ដៃគូសន្ទនាដែលមានវ័យចំណាស់មានតិចតួច។ សង្គ្រាមនិងលក្ខខ័ណ្ឌជីវភាពលំបាកលំបិនបាន ធ្វើឱ្យមនុស្សគ្រប់វ័យស្លាប់ជាច្រើន។ ដូចនេះ មនុស្សម្នាក់ដែលមានអាយុ៥០ឆ្នាំ អាចចាត់ទុកជា "មនុស្សចាស់" បាន។

សម័យសង្គមចាស់ គឺសំដៅសម័យមុនឆ្នាំ១៩៧០ ដែលកត់សម្គាល់អំពីការធ្លាក់ទៅក្នុងភ្នក់ភ្លើងសង្គ្រាម។ ការហៅថា "ការអនុវត្តន៏បែបប្រពៃណី" គឺជាការអនុវត្តន៏ដែលបានធ្វើឡើងនៅក្នុងទសវត្សឆ្នាំ ៥០ និង ៦០ ដែលជាការបញ្ចប់របបអាណាព្យាបាលបារាំង និងជាយុគសម័យនៃរបបសង្គមរាស្ត្រនិយមរបស់សម្តេចព្រះនរោត្តមសីហនុ។

### ការនិយាយយោងទៅលើការរស់នៅដ៏សុខសាន្ត

នៅទូទាំងប្រទេស ការនិយាយយោងទៅរកការរស់នៅដ៏សុខសាន្តនិងដោយសុខដុមគឺនៅពេលដែលស្ថាប័ននានាត្រូវបានគោរព ហើយជនគ្រប់រូបមានសាមគ្គីគ្នា។ សភាពការណ៍នេះបានកើតមាននៅក្នុងទសវត្សឆ្នាំ ៥០ និង៦០។ តើនេះជាទស្សនៈកើតឡើងដោយការស្រឡាញ់? ឬដោយការពិតជាក់ស្តែង? ទិន្នន័យជាក់ស្តែងនៅសម័យនោះមានពុំគ្រប់គ្រាន់ ហើយមានពុំអាចធ្វើការប្រៀបធៀបឱ្យបានត្រឹមត្រូវជាមួយសម័យបច្ចុប្បន្នបានទេ។ ប៉ុន្តែគេអាចធ្វើការកត់សម្គាល់ថាសង្គមសម័យនោះ មានលក្ខណៈប្រពៃណីណាស់ហើយពុំសូវបានរៀបចំខ្លួនសំរាប់ការបើកទូលាយទៅរកពិភពលោកខាងក្រៅទេ។

កង្វល់ជាសារវន្តរបស់ប្រជាកសិករនៃប្រទេសនេះ គឺការធ្វើស្រែតូចៗដែលពឹងផ្អែកទៅលើទឹកភ្លៀងដោយសន្តិភាព និងដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការផ្នែកសេដ្ឋកិច្ចដល់គ្រួសារដែលមានតែឪពុកម្តាយនិងកូន និងដើម្បីជៀសវាងការរំខានសណ្តាប់ធ្នាប់រឹងកំព្រឹស។

> "គេបានរស់នៅយ៉ាងសុខស្រួល។ មនុស្សមានសាមគ្គីភាពជាមួយគ្នាទៅវិញទៅមក។ មនុស្សមានការទាស់ទែងគ្នាតិចតួចបំផុត "។ (លោក ហៀង អាយុ ៦៧ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

---

[82] . គេបានឮការរំលឹករបស់មេក្រុមជាញឹកញាប់នៅក្នុងសម័យសង្គមរាស្ត្រនិយម ។ ប៉ុន្តែអង្គភាព រដ្ឋាភិបាលកើតមានឡើងវិញនៅឆ្នាំ ១៩៧៩។

"ពុំមានបញ្ហាអ្វីធំដុំទេ ។ មនុស្សស្រឡាញ់គ្នាណាស់។ គេមានសាមគ្គីភាពជាមួយគ្នាណាស់ " ។
(លោក សាត អាយុ៧១ឆ្នាំ ទីក្រុងភ្នំពេញ)

ការចងចាំមិនភ្លេចពីពេលមានសន្តិភាពនេះហើយ ដែលនៅពេលនោះ ទំនាស់បានកើតមានតិចតួចបំផុត។ សភាពស្ងប់ស្ងាត់នេះអាចពន្យល់បានគឺដោយសារលំនៅដ្ឋានត្រូវបានសង់ដាច់ឆ្ងាយពីគ្នាកំណើនប្រជាពលរដ្ឋមានតិច ការគោរពលាយឡំនិងការភ័យខ្លាចចំពោះរដ្ឋបាល ហើយនិងវត្តសក្តិសិទ្ធិបានជួយទប់ស្កាត់ទំនាស់ជាច្រើន។

ដែលហៅថាភូមិ គឺជាទីកន្លែងមួយដែលមានទំហំដីទូលំទូលាយ ហើយដែលមានប្រជាពលរដ្ឋរស់នៅបែកខ្ញែកគ្នា។ មានភូមិជាច្រើនទៀតដែលមានប្រជាពលរដ្ឋរស់នៅជាក្រុមនៅតាមបណ្តោយផ្លូវ ដែលអាចប្រើធ្វើជាទំនប់បានផង។ សភាពការណ៍បែបនេះគឺកើតមកពីឆន្ទៈរបស់រដ្ឋាភិបាលតែងតាំងពីសតវត្សទី៤០ ដើម្បីឃ្លាំមើលក៏ ដូចជាការពារប្រជាពលរដ្ឋនៅក្នុងពេលមានអសន្តិសុខ[៨៣] ។ ប៉ុន្តែ ទោះបីជាមានការរស់នៅជាក្រុមៗក៏ដោយ មានគ្រួសារជាច្រើននៅតែប្រកាន់ការថែរក្សាឯករាជភាពរបស់ខ្លួន និងរក្សាទុកដីចន្លោះពីផ្ទះមួយទៅផ្ទះមួយទៀត[៨៤] ។ ដូចនេះ ការរស់នៅឆ្ងាយពីគ្នាពីផ្ទះមួយទៅផ្ទះមួយទៀតនៅក្នុងសង្គមមួយដែលគ្រប់គ្រងដោយគ្រួសារដែលមានតែមាតាបិតានិងកូន បានបន្ថយប្រភពទំនាស់យ៉ាងច្រើន។ ជាបន្ថែមទៀត ដីធ្លីទំនេរដ៏ធំធេងនៅកម្ពុជាអាចឱ្យ ប្រជាពលរដ្ឋកសិករមានលទ្ធភាពរកដីដើម្បីដាំដំណាំយ៉ាងងាយស្រួល។ មានប្រជាពលរដ្ឋមួយភាគតិចទេដែល មានបំណងចង់ធ្វើការផ្លាស់ប្តូរទីកន្លែងនិងរស់នៅតាមព្រៃភ្នំ។

"កាលខ្ញុំនៅពីតូច នៅទីនេះមានផ្ទះតែ៥០ទេ។ បច្ចុប្បន្ននេះមានផ្ទះចំនួន២០០។ កាលពីមុនមានមនុស្សតិចទេ និងមានបញ្ហាធំៗតិចតួចទេ គឺមានតែការទាស់ទែងគ្នាម្តងម្កាល" ។
(លោកញ៉ុល អាយុ ៦៩ឆ្នាំ ឃុំស្វាយជ្រុំ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

សភាពសេដ្ឋកិច្ចរបស់អ្នកភូមិមានភាពប្រហាក់ប្រហែលគ្នា។ សាមគ្គីភាព ការប្តូរកម្លាំងពលកម្មគ្នាមានច្រើនជាងការដោះដូរជាលុយកាក់។

"កាលពីដើមមានសាមគ្គីភាពខ្លាំងក្លាណាស់។ ប្រជាពលរដ្ឋក្រីក្រណាស់ហើយច្រើនពឹងផ្អែកទៅលើអ្នកជិតខាង។ នៅពេលដែលក៏រិតជីវភាពនៅទាប ហើយប្រជាជនមានក៏រិតសេដ្ឋកិច្ចស្មើៗគ្នា ទំនាក់ទំនងរវាងមនុស្ស គ្រប់រូបមានលក្ខណៈស្និទ្ធស្នាលណាស់។ ពេលណាគេនិយាយអំពីលុយ

---

83 . ក្រុមឧទ្ទាមខ្មែរឥស្សរៈបានធ្វើការវាយប្រហារដើម្បីរំដោះប្រទេសពីអាណានិគមបារាំង។

84 . បច្ចុប្បន្ននេះទៀត គេបានសង្កេតឃើញថាពុំមានទីកន្លែងសាធារណៈទេនៅក្នុងភូមិ។ ប្រជាពលរដ្ឋ ចូលចិត្តទៅជួបជុំគ្នានៅទីកន្លែងសាធារណៈ។ ពុំមានមជ្ឈមណ្ឌលភូមិទេ។ ប្រជាពលរដ្ឋឋិតនៅក្នុង លំនៅដ្ឋានរបស់ខ្លួន។

កាក់ គឺនាំឱ្យមានការបែកបាក់គ្នាជាពុំខាន។ មានបញ្ហាកើតឡើងតិចតួចណាស់ពីព្រោះប្រជាពលរដ្ឋរស់នៅឆ្ងាយពីគ្នា។ ការឈ្លោះទាស់ទែងគ្នាពុំសូវកើត មានញឹកញាប់ទេ"។
(លោក វ៉ើត អាយុ ៥៧ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅមុនឆ្នាំ១៩៧០ នៅទីនេះប្រជាពលរដ្ឋបានរស់នៅសុខស្រួលណាស់។ ពីផ្ទះមួយទៅផ្ទះមួយទៀតមានទីធ្លាធំ។ គេពុំមានបញ្ហាដីធ្លីច្រើនទេ ពីព្រោះកាលពីមុនដីពុំថ្លៃទេ។ ប្រសិនបើគេពុំមានដីធ្លីទេ គេអាចស្នើសុំដីមេភូមិមួយកន្លែងដើម្បីធ្វើការកាប់ឆ្ការ"។
(លោកព្រុំ អាយុ ៥៩ឆ្នាំ មេឃុំ នគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

**ក. ទំនាស់:**

ទំនាស់ខ្លះៗ ដែលកើតមានឡើងច្រើនមានការពាក់ព័ន្ធទៅនឹងការឈ្លោះទាស់ទែងជាមួយអ្នកជិតខាង (ព្រំដី សត្វដែលស៊ីដំណាំ ពាក្យសំដីអាក្រក់ កូនក្មេងឈ្លោះគ្នា ហើយមាតាបិតាជាអ្នកតបតវិញ) គ្រួសារ (ការឈ្លោះ ទាស់ទែងប្តីប្រពន្ធ មរតក លែងលះគ្នា) យុវជន (វាយគ្នា) ឬបញ្ហាដីធ្លី (ព្រំដី ការបង្ហូរទឹកភ្លៀង កម្មសិទ្ធិ)។

"នៅក្នុងសម័យសង្គមរាស្ត្រនិយម ទំនាស់នៅក្នុងភូមិមានទាក់ទងទៅនឹងបញ្ហាភ្លឺស្រែ[៨៥] ដើមឈើដែលដុះនៅលើព្រំដី ហើយបានធ្វើឱ្យខូចស្រូវនៅពេលមែកវាបាក់ធ្លាក់មក សត្វស៊ីដំណាំ ឬមួយ ជម្លោះក្នុងគ្រួសារ"។
(លោក ខៅ, អាយុ ៤៦ឆ្នាំ ប្រធានភូមិ ឃុំចេក ស្រុកស្វាយជ្រំ ខេត្ត ស្វាយរៀង)

"កាលពីមុន មានបញ្ហាចំនួនបីបែបគឺៈ ជម្លោះក្នុងគ្រួសារ ជម្លោះរវាងអ្នកភូមិ និងជម្លោះដីធ្លី។ ជម្លោះទីមួយ គឺកើតមាននៅពេលប្តីដើរលេងញឹកញាប់ពេក។ នៅពេលប្តីវិលត្រឡប់មកផ្ទះវិញ ប្រពន្ធមានការប្រច័ណ្ឌ ហើយនិយាយខ្លាំងៗទៅកាន់ប្តី ហើយការទាស់ទែងគ្នាបានក្លាយទៅជាអំពើហឹង្សា។ ប្រពន្ធត្រូវប្តីវាយតប់។ បញ្ហាទីពីរ គឺជម្លោះរវាងអ្នកភូមិគ្នាឯង ហើយជាញឹកញាប់កើតឡើងដោយសារ គោ ក្របី និង ជ្រូក ដែលពុំបាន ចងខ្សែឬដាក់ទ្រុងហើយទៅស៊ីដំណាំគេ។ ជនទាំងនេះបាននិយាយពាក្យសំដីអាក្រក់ដាក់គ្នាទៅវិញទៅមក ហើយពាក្យសំដីអាក្រក់ទាំងនោះបានធ្វើឱ្យភាគីទាំងសងខាងមានការខឹងសម្បានឹងគ្នា។ បញ្ហាមួយទៀតគឺ បញ្ហាព្រំដី។ មានជនជាច្រើនបានពង្រីកព្រំដីស្រែចំការ ឬដីភូមិរបស់ខ្លួនទៅលើដីអ្នកជិតខាង។
(លោកស្រី សេង អាយុ ៤៧ឆ្នាំ (អតីត ខ្មែរក្រហម) ឃុំពងទឹក សង្កាត់ដំណាក់ចង្អើរ ក្រុងកែប)

[85]. ភ្លឺស្រែតូចៗដែលបែងចែកដីស្រែ

"កាលពីមុនមានបញ្ហាដីធ្លីខ្លះៗ ប៉ុន្តែជានិច្ចកាលគេតែងតែរកដំណោះស្រាយឃើញ។ នៅសម័យនោះ មានព្រៃជាច្រើននៅជុំវិញភូមិ ហើយអ្នកភូមិទាំងអស់ជាម្ចាស់កម្មសិទ្ធិលើដើមឈើទាំងនោះ។ មានរឿងអំពីមនុស្ស ម្នាក់ដែលបានទៅយកជ័រឬកាប់ដើមឈើដែលពុំមែនជារបស់ខ្លួន។ នៅពេលដែលគេបានជួបប្រទះចោរដែលលួចយកជ័រ គេបានប្រាប់ជននោះកុំឱ្យលួចជ័រតទៅទៀត។ ចំពោះបញ្ហាដីស្រែចំការគេបានពន្យល់គ្នា។ អ្នកភូមិពុំដូច សព្វថ្ងៃនេះទេ។ ខ្ញុំពុំយល់ថាតើហេតុដូចម្តេចបានជាក្លាយទៅដូច្នេះវិញ។ កាលពីជំនាន់មុន អ្នកភូមិមានភាព ក្រីក្រណាស់ ប៉ុន្តែគេចេះជួយគ្នាទៅវិញទៅមក។ គេពុំបានបង្កើតឱ្យមានបញ្ហាច្រើនទេ។ ឥឡូវនេះ មានបញ្ហាច្រើនណាស់ដោយសារតែមូលហេតុលុយកាក់។ កាលពីមុនមានម៉ូតូ តែមួយគត់ គឺជារបស់ឪពុកខ្ញុំ"។

(លោកប៉ែត អាយុ៧១ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅក្នុងសម័យសង្គមរាស្ត្រនិយមមានការទាស់ទែងគ្នាតិចជាងក្នុងពេលសព្វថ្ងៃនេះ។ ទំនាស់ដែលកើតមានច្រើនជាងគេគឺ រឿងក្មេងៗនៅលីវ ។ ពួកយុវជនទាំងនោះបាននាំគ្នាផឹកស្រា ហើយឈ្លោះប្រកែកគ្នារហូតដល់វាយតប់គ្នា។ អ្នកខ្លះមានរបស់សក្តិសិទ្ធិសំរាប់ការពារខ្លួន (សាក់នៅលើខ្លួនប្រាណ និងមានកន្សែងយ័ន្ត)។ ពួកគេវាយតប់គ្នាដើម្បីដណ្តើមស្រី ដើម្បីបង្ហាញថាពួកខ្លួនជាអ្នកខ្លាំងនិងមានវត្ថុសក្តិសិទ្ធដ៏អស្ចារ្យសំរាប់ការពារ។ ពួកគេវាយតប់គ្នាដោយប្រើកាំបិត និងដំបង។ ជាទូទៅ ពួកគេមានតែត្រូវរបួសទេ និងពុំមានអ្នកណាស្លាប់ទេ។ នៅក្នុងករណីទាំងអស់នេះ មេភូមិបានហៅទៅមេប៉ុស្តិនគរបាល[៨៦]"។

(លោក វ៉េត អាយុ៥៧ឆ្នាំ ឃុំនគរធំ, ស្រុកសៀមរាប ខេត្តសៀមរាប)

នៅពេលកើតមានទំនាស់រវាងអ្នកដែលរស់នៅក្នុងភូមិជាមួយនិងអ្នកដែលមកពីខាងក្រៅ ការមន្ទិលសង្ស័យបានសំដៅភាគច្រើនទៅលើអ្នកទីពីរ។ គេនិយាយថាអ្នកបង្កើតឱ្យមានចលាចលគឺអ្នកមកពីក្រៅភូមិ។

"មានបញ្ហាដីធ្លីជាច្រើនបានកើតមានឡើងៈ រវាងសមាជិកនៅក្នុងគ្រួសារមួយ និងអ្នកជិតខាង។ នៅពេលមានការបែងចែកមរតក ឪពុកម្តាយអាចចែកឱ្យកូនខ្លះច្រើន កូនខ្លះតិច។ កូនដែលបានចំណែកតិចមានការខឹងសម្បានឹងមាតាបិតា។ នៅមានបញ្ហាភ្លឺស្រែទៀតដែលអ្នកជិតខាងបានធ្វើឱ្យខូច។ ក៏ប៉ុន្តែករណីនេះពុំសូវកើតមានញឹកញាប់ទេ។ ទាក់ទងទៅនឹងការលះលែងប្តីប្រពន្ធករណីនេះច្រើនកើតមានចំពោះអ្នកមកពីភូមិខាងក្រៅដែល បានរៀបអាពាហ៍ពិពាហ៍ជាមួយជន

[86] ពាក្យបារាំងដែលបន្សល់ពីអាណានិគមៈ ប៉ុស្តិ៍នគរបាល

ដែលរស់នៅក្នុងភូមិ។ គេគោរពចំពោះអ្នកដែលមានដើមកំណើតក្នុងភូមិខ្លាំងជាង។ គេមានការទុកចិត្តជាង។ ជនដែលមកពីខាងក្រៅមានប្រតិកម្មផ្សេង ហើយជួនកាលគេពុំយល់អំពីអ្នកទាំងនេះផង"។

(លោក ជួប អាយុ៧០ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ទំនាស់ក៏មានចំពោះអ្នកកាន់ព្រះពុទ្ធសាសនាដែរ។ បញ្ហាសិទ្ធិឆ្លងកាត់បានចោទទាំងនៅក្នុងភូមិក៏ដូចជានៅតាមវត្តអារាមដែរ។

"ខ្ញុំនឹកឃើញទំនាស់មួយដែលកើតមានរវាងវត្តពីរនៅខាងជើងនិងខាងត្បូងអង្គរវត្ត។ ព្រះសង្ឃបានវាយតប់គ្នាដើម្បីបានសិទ្ធិអាចនិមន្តឆ្លងកាត់ប្រាសាទអង្គរវត្តបាន។ ប្រាសាទឋិតនៅចន្លោះវត្តទាំងពីរ ហើយព្រះសង្ឃទាំងពីរវត្តនេះចង់បានថា មានតែព្រះសង្ឃវត្តមួយទេដែលអាចឆ្លងកាត់តាមប្រាសាទ។ គឺមានតែព្រះចៅអធិការ វត្តទាំងពីរទេដែលអាចសម្រុះសម្រួលកិច្ចការបាន "។

(លោក វ៉េត អាយុ ៥៧ឆ្នាំ ឃុំ នគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## ខ. ការដោះស្រាយទំនាស់

### ការខ្ចប់កុំឱ្យមានបញ្ហា

នៅពេលមានកើតទំនាស់ម្តងៗ កង្វល់ទី១គឺត្រូវរកគ្រប់វិធីដើម្បីជៀសវាងកុំឱ្យទំនាស់រីកធំឡើង។ តាមក្បួនច្បាប់គឺត្រូវថែរក្សាភាពស្ងៀមស្ងាត់ សូម្បីតែត្រូវអត់ទ្រាំនឹងសភាពការណ៍ដែលខ្លួនមិនពេញចិត្តក្តី។ ត្រូវធ្វើជាអ្នកស្លូត មិនបង្កើតបញ្ហា ទាំងនេះជាតម្លៃរបស់នេះ។

"ប្រសិនបើជាបញ្ហាតូចតាច ឬប្រសិនបើបញ្ហានោះអាចបង្កើតឱ្យមានភាពស្មុគស្មាញ, គឺត្រូវឋិតនៅស្ងៀមជាការប្រសើរ"។

(លោក ឈន អាយុ ៥០ឆ្នាំ សង្កាត់ដំណាក់ចង្អើរ ក្រុងកែប ខេត្តកំពត)

"គេអាចធ្វើការសម្រុះសម្រួលបានជានិច្ចប្រសិនបើគេស្គាល់ជនណាម្នាក់។ ប៉ុន្តែ ប្រសិនបើគេពុំស្គាល់ជន នោះទេគេពុំដឹងថា តើជនម្នាក់ទៀតនឹងអាចធ្វើអ្វីដែរ។ ការនេះអាចបង្កើតបញ្ហាច្រើន។ ប្រសិនបើជាបញ្ហាតូច តាចដែលអាចទ្រាំទ្របានគឺគួរតែកុំរវីរវល់ជាការប្រសើរ"។

(លោក វ៉ង់ អាយុ ៤៥ឆ្នាំ ឃុំសំបូរ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

### ការរកអ្នកទីបីជាជំនួយ

ជានិច្ចកាល គេតែងតែមានបំណងបំបិទបញ្ហា។ ប៉ុន្តែប្រសិនបើគូជម្លោះណាមួយមិនសុខចិត្ត អ្នកនោះអាចទៅរកជំនួយដោយទាក់ទងជាមួយជនម្នាក់ដែលជាញាតិសាច់សារលោហិតរបស់ខ្លួន(ឪពុកម្តាយ) ឬអ្នក ជិតខាងដើម្បីធ្វើការពិភាក្សាអំពីបញ្ហានោះ។ ប្រសិនបើបញ្ហានោះមិនស្ងប់ស្ងាត់ទេ គេនឹងទៅរក

ជនអព្យាក្រិត្យម្នាក់ទៀតដើម្បីសាកល្បងធ្វើការសម្រុះសម្រួលរវាងភាគីទាំងពីរដែលមានទំនាស់។ គេបានទាក់ទង ចាស់ទុំម្នាក់ ឬមេភូមិ ឬមេឃុំ ដែលជាអ្នកតំណាងរដ្ឋបាលមូលដ្ឋាន។

- គ្រួសារ (ឪពុកម្តាយ):

ជាទូទៅ ឪពុកម្តាយបានធ្វើអន្តរាគមន៍នៅក្នុងករណីដែលប្តីប្រពន្ធ ជាកូនរបស់គាត់មានការមិនចុះសម្រុងគ្នា។ ជានិច្ចកាលអាពាហ៍ពិពាហ៍ត្រូវបានរៀបចំដោយឪពុកម្តាយ ហើយគូស្រករថ្មីៗមិនមែនសុទ្ធតែយល់ព្រមជានិច្ចទេ។ ឪពុកម្តាយបានធ្វើអន្តរាគមន៍ដើម្បីធ្វើការគាបសង្កត់ទៅលើកូនរបស់ខ្លួន ក្នុងបំណងឱ្យកូនរបស់ខ្លួនរួមរស់នៅជាមួយគ្នា។ ក្នុងករណីមានការមិនចុះសម្រុងគ្នាយ៉ាងធ្ងន់ធ្ងររវាងប្តីប្រពន្ធជាកូន ឪពុកម្តាយទាំងសងខាង និយាយកាន់ជើងកូនរៀងៗខ្លួន ហើយបន្ទុះបង្អាប់គ្រួសារខាងដន្លង។ បញ្ហាទាំងនេះមិនបានធ្វើឱ្យលេចឮទៅខាង ក្រៅទេ ដរាបណាការពិភាក្សានៅតែអាចធ្វើទៅកើតរវាងគ្រួសារទាំងពីរ។

អ្នកចាស់ទុំ:

ពាក្យ "**ចាស់ទុំ**[៨៧]" ពុំសំដៅទៅលើជនដែលមានអាយុច្រើនទាំងអស់នោះទេ ប៉ុន្តែពាក្យចាស់ទុំគ្រាន់តែសំដៅជនទាំងឡាយណាដែលគេទទួលស្គាល់ថាមានសីលធម៌ល្អ មានកេរ្តិ៍ការអប់រំសមល្មម មានចំណេះដឹងអំពីក្បួនច្បាប់ព្រះពុទ្ធសាសនា។ មន្ត្រីចាស់ៗត្រូវបានទទួលការគោរព ជាពិសេសមន្ត្រីចាស់ៗទាំងនោះ បានផ្តល់ឱវាទស្តីអំពីបណ្តាញរដ្ឋបាលនៅទីក្រុងនៅពេលត្រូវការចាំបាច់ ហើយគាត់មានទំនាក់ទំនងជាមួយមិត្តភក្តិនៅទីក្រុង។

> "ចាស់ទុំគឺជាជនទាំងឡាយដែលមានកេរ្តិ៍ឈ្មោះដោយសារសីលធម៌របស់គាត់។ ពេលណាគាត់និយាយ គេនាំគ្នាស្តាប់គាត់។ គាត់បានទទួលការគោរព ពីព្រោះគាត់ជាមនុស្សមានលក្ខណៈសម្បត្តិល្អ។ ចាស់ទុំ គឺអាចជាមន្ត្រីចាស់ដែលមានចំណេះដឹង និង ដែលអាចផ្តល់ឱវាទជាច្រើនដល់(អ្នកផងទាំងពួង)"។
>
> (លោក អ៊ួន អាយុ៥០ឆ្នាំ អ្នកទទួលខុសត្រូវនៅការិយាល័យនៃអង្គការសិទ្ធិមនុស្ស. ក្រុងកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

> "នៅសម័យសម្តេចសីហនុ មនុស្សគ្រប់រូបគោរពចាស់ទុំណាស់។ គេទៅជួបចាស់ទុំដើម្បីឱ្យគាត់ផ្តល់ដំបូន្មាន ឬស្តីប្រដៅជនទាំងឡាយណាដែលបានបង្កើតបញ្ហា។ ចាស់ទុំពុំធ្វើការវិនិច្ឆ័យទេ តួនាទីរបស់គាត់ គឺធ្វើឱ្យជនគ្រប់រូបស្ងប់ចិត្តដោយណែនាំផ្តល់ដំបូន្មាន។ ប្រសិនបើពាក្យសំដីរបស់ចាស់ទុំពុំទាន់មាន លក្ខណៈគ្រប់គ្រាន់ទេ គេត្រូវទៅជួបមេភូមិទៀត"។
>
> (លោក វ៉ាយ អាយុ៨៦ឆ្នាំ មេភូមិ ឃុំពងទឹក ស្រុកស្វាយទាប ខេត្តស្វាយរៀង)

---

[87] ... ចាស់ទុំ

ចាស់ទុំដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសាកល្បងធ្វើការសម្រុះសម្រួលប្តីប្រពន្ធដែលមានទំនាស់។ គាត់បានបញ្ចុះបញ្ចូលចិត្តអ្នកទាំងពីរ គឺប្តីនិងប្រពន្ធឱ្យរក្សាភាពស្ងៀមស្ងាត់ គាត់ពុំញញើតទេក្នុងការស្តីបន្ទោសអ្នកទាំងពីរដើម្បីឱ្យគេរស់នៅជាមួយគ្នាតទៅទៀត។

នៅក្នុងករណីផ្សេងទៀត ដូចជាបញ្ហាដីធ្លីចាស់ទុំអាចធ្វើការប្រជុំអ្នកទាំងពីររូបដើម្បីធ្វើការសម្រុះសម្រួល ឬគាត់អាចនិយាយដោយឡែកពីគ្នាក៏មាន។ ចាស់ទុំបានផ្តល់ឱវាទ ឬធ្វើការស្តីប្រដៅដោយយោលទៅតាមបទពិសោធន៍ផ្ទាល់ខ្លួន ការយល់ដឹង និងការបកស្រាយតាមបែបប្រពៃណីរបស់គាត់។

ភារកិច្ចនៃការសម្រុះសម្រួលត្រូវបានគេទទួលស្គាល់នៅថ្នាក់មេភូមិ។ ចាស់ទុំក៏ចាត់ធ្វើការសម្រុះសម្រួលដែរ តែជាទូទៅគេបានធ្វើការពិគ្រោះជាមួយគាត់ចំពោះសកម្មភាពដែលគាត់បានអនុវត្តកាលពីអតីតកាល (ការលក់ដូរដីធ្លី ការបែងចែកមរតក...) និងការយល់ដឹងរបស់គាត់ដែលមានទាក់ទងទៅនឹងគោលការណ៍ជាប្រពៃណីដែលគេនិយមប្រើនិងតាមរបបព្រះពុទ្ធសាសនា។ ចាស់ទុំគឺជាអ្នកចងចាំព្រឹត្តិការណ៍នៅក្នុងភូមិ។ តួនាទីរបស់គាត់គឺរ៉ាយរ៉ាប់អំពីព្រឹត្តិការណ៍ផ្សេងៗនិងគាំទ្រពាក្យប្រដៅរបស់មេភូមិ។ ជាគោល-ការណ៍ ចាស់ទុំបានចូលធ្វើអន្តរាគមន៍ដោយផ្ទាល់នៅក្នុងរឿងទំនាស់ប្តីប្រពន្ធ។ នៅក្នុងរឿងដែលមានលក្ខណៈសំខាន់ៗដូចជាទំនាស់ដីធ្លីជាដើម ចាស់ទុំបានផ្តល់ពតិមាន តែពុំដោះស្រាយទេ។

> "មានចាស់ទុំជាច្រើន ប៉ុន្តែគាត់ពុំមានអំណាចដើម្បីធ្វើការសម្រុះសម្រួលទេ។ គេចាត់ទុកគាត់ដូចជាសាក្សី"
>
> (លោក ចាង អាយុ៥៦ឆ្នាំ មេភូមិ, សង្កាត់អង្កាល់, ក្រុងកែប)
>
> "កាលពីមុន ជាដំបូងគេរត់ទៅរកជួបចាស់ទុំ។ គេចាត់ទុកគាត់ដូចជាសាក្សី ជាទូទៅនៅក្នុងរឿងដីធ្លី, ព្រំដីស្រែចំការ ទោះបីជាគាត់ជាសមាជិកគ្រួសារឬពុំមែនក៏ដោយ។ ប្រសិនបើប្តីឬប្រពន្ធចង់ស្នើសុំធ្វើការលះ លែងគ្នាហើយភាគីម្ខាងពុំសុខចិត្ត អ្នកដែលពុំសុខចិត្តធ្វើការលះលែងគ្នាបានទៅស្នើសុំចាស់ទុំដើម្បីឱ្យផ្តល់ឱវាទដល់ភាគីម្ខាងទៀត ។ ចាស់ទុំបានរារាំងពុំឱ្យមានការលះលែងគ្នាទេ។ នេះគឺជាប្រពៃណី "។
>
> (លោកស្រី ហែម អាយុ៧៧ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប)
>
> "ប្រសិនបើមានការតវ៉ាស្តីពីព្រំដីដែលឪពុកម្តាយបានចែកឱ្យជាមរតកនោះ មេភូមិបានធ្វើការសាកសួរចាស់ទុំថា តើគាត់បានដឹងអំពីការបែងចែកដីនោះក្នុងពេលដែលឪពុកម្តាយរបស់គេនៅរស់ឬទេ"។ (លោក សំអុល អាយុ ៦៤ឆ្នាំ អាចារ្យ[៨៨] សង្កាត់អង្កាល់, ក្រុងកែប)

---

[88] . អាចារ្យ-គ្រហស្ថជាអន្តរការីរវាងអ្នកភូមិ និងព្រះសង្ឃព្រះពុទ្ធសាសនា

"ប្រសិនបើគេចង់លះលែងគ្នា ជាដំបូងគេទៅរកជួបមនុស្សនៅក្នុងគ្រួសារឬអ្នកជិតខាង ជាពិសេសជួបចាស់ទុំនៅជិតខាងប្រសិនបើមាន។ ចាស់ទុំបានផ្តល់ឱវាទយ៉ាងល្អជាច្រើន។ គាត់ពុំមានគំនិតចង់ធ្វើការវិនិច្ឆ័យឡើយ ប៉ុន្តែបានណែនាំភាគីទាំងពីរឱ្យស្រុះស្រួលគ្នា។ លោកអាចារ្យបានបង្រៀនយើងឱ្យយល់ដឹងអំពីក្រមសីល ធម៌ចាស់ៗ"។

(លោក សាន អាយុ៥៧ឆ្នាំ សង្កាត់ពងទឹក, ក្រុងកែប)

"កាលពីមុន នៅពេលមានការសម្រុះសម្រួលបញ្ហាអ្វីមួយជាមួយមេភូមិនិងមេឃុំ គេបានអញ្ជើញចាស់ទុំ ឱ្យចូលរួមក្នុងឋានៈជាសាក្សី ដូចជាភ័ស្តុតាងដែលគេបាននិយាយរួចមកហើយ"។

(លោកស្រី ចំប៉ី អាយុ៧០ឆ្នាំ ក្រុងបន្ទាយស្រី ខេត្តសៀមរាប)

## ការស្វែងរកដំណោះស្រាយរដ្ឋបាល

<u>មេភូមិ</u>

ប្រសិនបើរឿងរ៉ាវត្រូវបានចាត់ទុកថាមានសភាពធ្ងន់ធ្ងរ ប្រសិនបើភាគីមួយមិនទទួលស្គាល់អំណាចរបស់ចាស់ទុំទេ ប្រសិនបើភាគីណាមួយដែលជាគូជម្លោះពុំព្រមបញ្ចប់រឿង ហើយប្រសិនបើគេបានរស់នៅជិតមេភូមិ ឬ គេបានស្គាល់មេភូមិនោះច្បាស់ គឺគេនឹងទៅរកមេភូមិនោះ។

មេភូមិឋិតនៅក្នុងផ្នែកមួយដ៏ទូលំទូលាយមុនដំបូងគេ ដែលអាចចាត់ទុកជាមនុស្សដែលគេចង្អុលឱ្យទៅទាក់ទងក្នុងករណីមានទំនាស់ដែលតម្រូវឱ្យមានអ្នកសម្រុះសម្រួលមួយរូប។ ក្នុងឋានៈជាអ្នកតំណាងរដ្ឋបាលមូលដ្ឋាន ការសម្រុះសម្រួលមនុស្សដែលមានទំនាស់នឹងគ្នាគឺជាភារកិច្ចរបស់មេភូមិ។ លទ្ធផលសំរេចនៃការពិភាក្សាគ្នាត្រូវចាត់ទុកជាលទ្ធផល"ផ្លូវការ"។ ជាពិសេសគឺនឹងឈានទៅសំរេចជាលាយល័ក្ខអក្សរដែលរៀបរាប់អំពីរឿងរ៉ាវ និងអំពីការប្តេជ្ញារបស់ជនទាំងនោះដើម្បីបញ្ចប់ជម្លោះ។ ឯកសារដែលបានសរសេរ និងចុះហត្ថលេខា ញ៉ាំងឱ្យមានការគោរពនិងការខ្លាច។

មេភូមិតែងបានស្នើសុំឱ្យចាស់ទុំចូលរួមធ្វើការសម្រុះសម្រួលជាញឹកញាប់។ ចាស់ទុំមានតួនាទីធ្វើជាកសិណសាក្សីនៅក្នុងរឿងនោះនិងធ្វើជាទីប្រឹក្សារបស់មេភូមិ។

"កាលពីមុន នៅពេលណាមានការឈ្លោះគ្នា គេតែងធ្វើការសាកល្បងជជែកគ្នាដើម្បីស្វែងរកការសម្របសម្រួលគ្នាទៅវិញទៅមក។ ប្រសិនបើគេពុំអាចធ្វើទៅកើតទេ គេបានយករឿងនោះទៅប្តឹងមេភូមិ។ មេភូមិអាចហៅអ្នកចាស់ទុំឱ្យមកចូលរួម ប៉ុន្តែគេមិនឱ្យគាត់ធ្វើអន្តរាគមន៍នៅក្នុងការសម្រុះសម្រួលទេ គេទុកឱ្យគាត់ធ្វើជាសាក្សី។ មេភូមិនិងជនទាំងនោះបានស្គាល់ក្រមសីលធម៌

ហើយក៏ត្រូវប្រព្រឹត្តតាមក្រមសីលធម៌ដែរ។ បច្ចុប្បន្ននេះពុំសូវកើតមានបញ្ហាទេ។ ពួកយុវជនបានស្តាប់ពាក្យសំដីរបស់ចាស់ទុំ។ ពួកគេបានប្រើប្រាស់ក្រមប្រពៃណី។ មេភូមិបានសួរយុវជនទាំងនោះម្តងម្កាលអំពីពតិមានដែលទាក់ទងទៅនឹងទំនាស់នេះ"។

(លោក ទិត អាយុ ៥៤ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប)

គេស្តាប់ចាស់ទុំ ហើយនៅក្នុងករណីខ្លះគេខ្លាចគាត់។ គាត់ជាតំណាងនៃការចេះដឹង និងជាអាជ្ញាធរផ្នែកទំនៀមទម្លាប់និងបទពិសោធន៍។ ដោយសារពាក្យសំដីរបស់គាត់ពីរបីម៉ាត់ គាត់អាចធ្វើឱ្យមនុស្សខ្មាស់គេទាំងភូមិនិងមិនអាចរស់នៅជាមួយគេឯទៀតនៅក្នុងភូមិ។

អំណាចរបស់មេភូមិស្ថិតនៅលើឋានៈរបស់គាត់ជាមន្ត្រីរាជការ។ មេភូមិពុំបានទទួលការស្រឡាញ់ពីអ្នកភូមិជានិច្ចទេ។ ប៉ុន្តែពាក្យសំដីរបស់មេភូមិមិនសូវមានអ្នកណាហ៊ានតវ៉ាទេ។ មេភូមិមានមធ្យោបាយសំរាប់ធ្វើការគាបសង្កត់អ្នកភូមិមិនតិចទេៈ បញ្ជូនរឿងទៅថ្នាក់លើជាហេតុធ្វើឱ្យមានបញ្ហាឱ្យកាន់តែច្រើនដាក់ខ្នោះ[៨៩]...។

ដោយយោលទៅតាមទីកន្លែង គេសង្កេតឃើញមានចាស់ទុំបីឬបួននាក់រហូតដល់១០នាក់ក្នុងមួយភូមិៗ និងមានមេភូមិមួយរូបគត់។ ដូចនេះ គឺជាការងាយស្រួលណាស់ក្នុងការរកជួបចាស់ទុំ។ នៅកន្លែងខ្លះ មេភូមិមានអាយុច្រើននិងមានចំណេះដឹងច្រើន។ គាត់ក៏ជាចាស់ទុំមួយរូបដែរ។ នៅកន្លែងខ្លះទៀតចំណេះដឹងរបស់មេភូមិមានកំរិត ហើយប្រជាជនក៏ងាកទៅពិគ្រោះការងារជាមួយចាស់ទុំ។

"មេភូមិមគ្មានចេះធ្វើអ្វីទេ។ ចាស់ទុំសំខាន់ជាង មានការគោរពច្រើនជាងមេភូមិ។ គាត់មានការប៉ិនប្រសប់ណាស់ក្នុងការនិយាយស្តី។ គាត់ចេះក្បួនច្បាប់ផ្នែកព្រះពុទ្ធសាសនា"។

(លោក ពេន អាយុ ៦៨ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

"កាលពីមុនយើងបានដោះស្រាយរឿងរ៉ាវនានាដោយឆ្លងកាត់តាមរយៈចាស់ទុំ។ យើងពុំមានការទុកចិត្តទៅលើអ្នកធ្វើការរាជការទេ។ ទោះបីជាមេភូមិមានដើមកំណើតនៅក្នុងភូមិក៏ដោយ ក៏គាត់អាចទៅនិយាយនៅខាងក្រៅបានជានិច្ច ឬធ្វើការគាបសង្កត់មកលើយើង។ គឺជាប្រសើរណាស់ដែលយើងត្រូវដោះស្រាយរវាង គ្នាយើង។

(លោក សុត អាយុ៦៤ឆ្នាំ អាចារ្យសង្កាត់អង្គល់ ក្រុងកែប)

---

[89] . ខ្នោះឃ្នាង

ហាក់ដូចជាមានក្បួនច្បាប់ដែលមិនបាននិយាយជាចំហរថា គេត្រូវដោះស្រាយបញ្ហានានាជាដំបូងរវាងគ្នាឯងសិន មុននឹងទៅជួបអាជ្ញាធររដ្ឋបាល។ ក៏ប៉ុន្តែតាមការជាក់ស្តែង ទោះបីមានអ្នកខ្លះមានបំណងចង់ដោះស្រាយកិច្ចការរវាងគ្នាឯងសិន ឬដោះស្រាយបញ្ហានៅក្នុងរង្វង់គ្រួសារ ឬជាមួយអ្នកចាស់ទុំ អ្នកខ្លះទៀតបានទៅដោះ ស្រាយដោយផ្ទាល់ជាមួយមេភូមិ។ នេះអាស្រ័យជាពិសេសលើការរស់នៅជិត ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយប្រធានភូមិ។ នៅក្នុងភូមិមួយដែលអ្នកស្រុករស់នៅឆ្ងាយៗពីគ្នា គេបានជ្រើសយកការដោះស្រាយបញ្ហានានា ជាមួយអ្នកដែលរស់នៅជិតខ្លួន។ ប្រសិនមេភូមិរស់នៅឆ្ងាយ គេអាចធ្វើការទាក់ទងគាត់តែនៅក្នុងករណីដែលដោះស្រាយបញ្ហានៅពេលចុងក្រោយប៉ុណ្ណោះ។ តែផ្ទុយទៅវិញ ប្រសិនបើផ្ទះមេភូមិឋិតនៅជិតវិញ គេនាំគ្នាទៅ ទាក់ទងមេភូមិមុនគេបង្អស់។

"កាលណាគេមានបញ្ហាអ្វីមួយ ដំបូងគេតែងទៅរកជួបគ្រួសារ ប្រសិនបើជាបញ្ហាគ្រួសារ។ គេនាំគ្នាទៅ ជួបមេភូមិតែក្នុងករណីមានបញ្ហាធ្ងន់ធ្ងរដូចជាបញ្ហាដីធ្លី។ មេភូមិអាចធ្វើការអារកាត់យ៉ាងត្រឹមត្រូវជាមួយជនទាំងឡាយដែលមានទំនាស់"។

(លោក សុត អាយុ៦៤ឆ្នាំ អាចារ្យ សង្កាត់អង់កោរ ក្រុងកែប)

"មេភូមិរស់នៅឆ្ងាយ។ គេស្គាល់គាត់តិចណាស់។ គេត្រូវជិះកង់ដើម្បីទៅរកជួបគាត់។ គឺលំបាកណាស់។ គាត់ពុំស្គាល់យើងទាំងអស់គ្នាច្បាស់ទេ។ ដូចនេះដោយសារមេឃុំរស់នៅជិតយើង គឺយើងអាចទៅជួប គាត់បានយ៉ាងងាយពីព្រោះយើងបានស្គាល់គាត់យ៉ាងច្បាស់"។

(លោកតា មឿន អាយុ ៦៣ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"មេឃុំគឺជាមនុស្សខ្លាំង។ គេអាចទៅជួបគាត់ ឬធ្វើការទាក់ទងជាមួយអនុប្រធានណាមួយនៃអនុប្រធានទាំងបីរបស់គាត់នៅពេលណាគេមានបញ្ហាអ្វីមួយ។ គេច្រើនទៅជួបអ្នកណាដែលគេស្គាល់ ឬដែលរស់នៅជិតពួកគេ។ នៅសម័យមុន គេមានតែកង់សំរាប់ជិះហើយគេពុំអាចធ្វើដំណើរទៅណាឆ្ងាយបានទេ។ នៅទីនេះ អនុប្រធានឃុំរស់នៅជិតជាងមេឃុំ ដូចនេះគេឱ្យតម្លៃទៅលើទំនាក់ទំនងជាមួយអនុប្រធានឃុំច្រើនជាង។ ចាប់ពីដើមទសវត្សរ៍ឆ្នាំ៦០ គឺមានការផ្លាស់ប្តូរជាច្រើន។ អនុប្រធានឃុំស្លាប់បាត់ទៅហើយ។ គឺមេឃុំជាមនុស្សខ្លាំងបំផុត"។

(លោក វ៉េត អាយុ ៥៧ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្ត សៀមរាប)

អាស្រ័យទៅតាមបុគ្គលិគ្គលក្ខណៈផ្ទាល់ខ្លួន មេភូមិខ្លះបានទទួលការគោរពគួរសម។ មេភូមិខ្លះចូលចិត្តបំពេញករណីយកិច្ចរដ្ឋបាលរបស់គាត់ដោយមិនសូវរវល់នឹងកិច្ចការផ្ទៃក្នុងរបស់ភូមិ។ ខ្លះទៀតដែលមានបុគ្គលិកលក្ខណៈខ្ពស់ មានអំណោយទាន និងអំណាចខ្លាំងត្រូវបានប្រជាជនគោរពនិងខ្លាច។

"ក្នុងរបបសង្គមរាស្ត្រនិយមក៏មានមេភូមិដែរ ប៉ុន្តែគេមិនរវល់ជាមួយប្រជាជនក្នុងភូមិទេ។ មេភូមិមិនមែនជាអ្នកពិសេសអ្វីទេ។ គាត់ក៏ជាជនធម្មតាដូចយើងដែរ គ្មានសិទ្ធអំណាចអ្វីជាក់លាក់នោះទេ។ គាត់មិនមានប្រាក់ខែទេ។ នៅពេលធ្វើការសម្រុះសម្រួល ប្រសិនបើគាត់ធ្វើមិនកើត គាត់រត់ទៅរកមេឃុំ ដូចជានៅក្នុងករណីមានការវាយតប់គ្នារហូតដល់មានរបួស។ គេគោរពមេភូមិ។ គេតែងតែទៅជួបមេភូមិដើម្បីសុំសំបុត្រអាពាហ៍ ពិពាហ៍ ឬសំបុត្រមរណភាព"។

(លោក សុត អាយុ ៦៤ឆ្នាំ អាចារ្យ សង្កាត់ អង្គោរ ក្រុងកែប)

នៅក្នុងចង្កោមផ្ទះមួយក្រុមតូច គ្រួសារជាច្រើនគឺជាបងប្អូននឹងគ្នា ហើយតួនាទីរបស់មេភូមិមានការច្រឡំគ្នាជាមួយតួនាទីរបស់មេគ្រួសារ។ ទំនាក់ទំនងរវាងមនុស្សមានភាពងាយស្រួលណាស់។ នៅក្នុងទីកន្លែងដែលមានផ្ទះបែកខ្ញែកគ្នាច្រើន ជួនកាលអ្នកភូមិរស់នៅឆ្ងាយពីមេភូមិ ហើយបានធ្វើទំនាក់ទំនងតិចតួចជាមួយមេភូមិ។ អ្នកភូមិចូលចិត្តធ្វើការទាក់ទងជាមួយអ្នកចាស់ទុំ ឬអ្នកជិតខាងដែលរស់នៅក្បែរគ្នា ហើយដែលគាត់បានស្គាល់គ្នាយ៉ាងច្បាស់លាស់។

"យើងមានបញ្ហាតូចតាចនៅក្នុងភូមិ ដូចជាបញ្ហាឈ្លោះទាស់ទែងគ្នានៅក្នុងគ្រួសារប្តីប្រពន្ធ។ ប្តីប្រពន្ធ បានបាក់បែកគ្នាក្រោយមកបានមករួមរស់នៅជាមួយគ្នាវិញ។ គឺមេភូមិជាអ្នកដោះស្រាយទំនាស់ទាំងអស់នោះ។ នៅក្នុងសម័យនេះ អ្នកភូមិទាំងអស់គ្នាសុទ្ធសឹងជាបងប្អូននឹងគ្នា។ ដូចនេះគឺមានការងាយស្រួលណាស់។ មានបទបញ្ជាជាច្រើនដូចជា ហាមមិនឱ្យលេងបៀរ មិនឱ្យបង្កើតជម្លោះ មិនឱ្យលួច មិនឱ្យសេពសុរា។ នៅក្នុងឱកាសមាន បុណ្យនៅក្នុងភូមិ មេភូមិបាននិយាយជាមួយអ្នកភូមិទាំងអស់គ្នា ហើយបានផ្តល់ឱវាទជាច្រើន។ គាត់បានសង្កត់ទៅលើតម្លៃនៃសាមគ្គីភាពនិងកិច្ចការពារភូមិប្រឆាំងនឹងពួកចោរ។ គាត់បាននិយាយថាប្រសិនបើអ្នកភូមិលេងបៀរនោះ នឹងកើតមានចោរ។ អ្នកភូមិបានស្តាប់នឹងធ្វើតាមគាត់ ពីព្រោះគេខ្លាចគាត់"។

(លោក ហួន អាយុ ៥៣ឆ្នាំ អនុប្រធានឃុំ(អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត)

ទោះបីជាមនុស្សភាគច្រើនដែលត្រូវបានធ្វើការសាកសួរ បានចងចាំយ៉ាងច្បាស់អំពីរឿងរ៉ាវនៅក្នុងសម័យនោះ ក៏នៅមានជនខ្លះទៀតដែលបានចូលទៅក្នុងចលនាតស៊ូរបស់ខ្មែរក្រហមនៅដើមទសវត្សឆ្នាំ៧០ បាននិយាយពីការចងចាំរឿងរ៉ាវបានច្រើនថែមទៀត។

"កាលពីមុន បញ្ហាទាំងឡាយត្រូវបានគេដោះស្រាយទៅតាមលំដាប់ថ្នាក់។ គេបញ្ជូនរឿងមួយដែលមានភាពស្មុគស្មាញទៅគ្រប់លំដាប់ថ្នាក់ដើម្បីដោះស្រាយ។ ដំបូងចាប់ផ្តើមពីមេភូមិ បន្ទាប់មកចូលទៅមេឃុំ, ចៅហ្វាយស្រុករហូតដល់ចៅហ្វាយខេត្ត។ មេភូមិ និងមេឃុំជាអ្នកប្រកាន់បក្ស

ពួក។ គាត់ពុំមានយុត្តិធម៌ទេ។ គាត់ជួយតែជនណាដែលមានលុយកាក់។ មានការគាបសង្កត់ច្រើនណាស់។ ជនទាំងឡាយណាដែលមាន លុយ កាក់បានបញ្ជូនរឿងក្តីទៅតុលាការដោយផ្ទាល់តែម្តង ហើយបានសង្ឃឹមថានឹងឈ្នះក្តីទៀត។ យើងជាអ្នកក្រ មិនចង់ខ្វល់ទេ យើងថែមទាំងពុំបានគិតថា ត្រូវទៅតុលាការទេ។ យើងបានទៅជួបចាស់ទុំ។ ចាស់ទុំមានការចេះដឹងមិនចូលចិត្តការយោគយល់អ្នកមានលើអ្នកក្រទេ"។

(លោក ក្រែម អាយុ ៥៤ឆ្នាំ អនុប្រធានភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត)

"នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំបានរស់នៅក្នុងតំបន់ព្រៃភ្នំ (កំពង់ត្រឡាច) គឺនៅឆ្ងាយពីទីក្រុង។ កាលណាកើតមានបញ្ហា យើងបានទៅរកមេភូមិ។ មានបញ្ហាតិចតួចណាស់ដែលបានកើតមានឡើង តែមិនអីទេ។ ខ្ញុំបាននឹកឃើញរឿងមួយដែលបានកើតឡើងនៅឯវត្តរវាងយុវជន និងមនុស្សចាស់។ ខ្ញុំពុំដឹងថាអ្នកណាត្រូវទេ។ មេភូមិបានធ្វើការសម្រុះសម្រួលគ្នា។

យើងពុំមានបញ្ហាដីធ្លីទេ ពីព្រោះដីជាកម្មសិទ្ធិរបស់ពួកចិន១ដែលបានដាំម្រេច។ កាលណាគេមានបញ្ហាជាមួយអ្នកណាម្នាក់ គេបានធ្វើការជជែកគ្នា បន្ទាប់មកប្រសិនបើរឿងរ៉ាវដោះស្រាយមិនបានយើងនាំគ្នាទៅរកមេភូមិ។ មេភូមិមានអំណាចច្រើន។ គាត់ចង់ឱ្យអ្នកទាំងអស់គ្នាធ្វើតាមគំនិតរបស់គាត់។ នៅពេលមានទំនាស់កើតឡើង មេភូមិបានធ្វើសំណើមួយ ហើយភាគីទាំងពីរត្រូវតែយល់ស្របតាមដោយគ្មានការជជែកអ្វីឡើយ។ គេទាំងអស់គ្នាខ្លាចមន្ត្រីរាជការ។ គេមានការភ័យខ្លាចក្នុងការបង់ពន្ធ (ដីស្រែចំការ ដីម្រេច អត្តសញ្ញាណប័ណ្ណ)។ គេពុំចង់ធ្វើអ្វីដែលអាចឱ្យមានការកត់សំគាល់ឡើយ។ គេក៏ពុំចង់ធ្វើការទាក់ទង ជាមួយមេភូមិឱ្យច្រើនហួសពេកដែរ។ អ្នកក្របានជៀសវាងក្នុងការធ្វើទំនាក់ទំនងជាមួយមន្ត្រីរាជការ។

គាត់ចូលចិត្តរក្សាភាពនៅស្ងាត់ស្ងៀម ដោយខ្លាចមានរឿង។ កាលណាគាត់មានរឿងរ៉ាវអ្វីមួយ គាត់ចូលចិត្តធ្វើការទាក់ទងជាមួយជនទាំងឡាយ ដែលមានឋានៈប្រហាក់ប្រហែលគ្នា។ នៅក្នុងភូមិខ្ញុំគេបែងចែកអ្នកភូមិជាពីរប្រភេទគឺ កម្មករចំការម្រេច កសិករអ្នកស្រែ នាយទុន (ម្ចាស់ចំការម្រេច)"។

(លោក សារម្យ អាយុ៦២ឆ្នាំ អាចារ្យសង្កាត់ពងទឹក ក្រុងកែប)

## ការបញ្ជូនរឿងឡើងតាមលំដាប់ថ្នាក់រដ្ឋបាល:

កាលណាការសម្រុះសម្រួលធ្វើពុំបានសំរេចនៅថ្នាក់ភូមិ រឿងរ៉ាវនោះនឹងបញ្ជូនទៅតាមលំដាប់ថ្នាក់ ផ្នែករដ្ឋបាល (ភូមិ - ឃុំ - ស្រុក)។

ទោះបីមានការលាយឡំពាក្យគ្នាញឹកញាប់ក៏ដោយ ចាស់ទុំតែងបានរំឭកឡើងអំពីអង្គការរដ្ឋបាលមូលដ្ឋាន ដែលមានមេឃុំមួយរូប ជំទប់បីរូបជាជំនួយការ និងស្មៀនមួយរូប។

គេនៅចាំថា មេឃុំមានភារកិច្ចប្រមូលប្រាក់ពន្ធ(ដី) អាករ (គោ ក្របី កង់...) ការចុះបញ្ជីដីធ្លីការធ្វើអត្តសញ្ញាណប័ណ្ណ ការជ្រើសរើសមនុស្សឱ្យចូលកំណែនធ្វើការងារសាធារណៈ ការរក្សាសណ្តាប់ធ្នាប់ និងការរៀបចំការសម្រុះសម្រួល។ មេឃុំមានជំទប់បីនាក់ជួយធ្វើការ។ មេភូមិធ្វើការនៅក្នុងភូមិស្រុក។ គាត់ជាអ្នករៀបចំពិធីផ្សេងៗ និងរៀបចំការសម្រុះសម្រួល។ គេពុំសូវនិយាយអំពីសំបុត្រអត្រានុកូលដ្ឋានទេ ព្រោះថាភូមិមិនសូវប្រើប្រាស់ទេ។

ជំទប់ទីមួយទទួលបន្ទុកបញ្ហាសន្តិសុខ។ ក្នុងពេលមានបញ្ហានៅក្នុងភូមិ គេបាននាំគ្នាទៅរកគាត់។

> "កាលពីមុន មានមេឃុំមួយរូបនិងជំទប់បីនាក់: ជំទប់ទីមួយ ជំទប់ទីពីរ ជំទប់ទីបី និងស្មៀនមួយនាក់ ដែលជ្រើសរើសដោយក្រសួងមហាផ្ទៃ។ មានតែភូមិធំៗ ទេដែលមានមេភូមិ។ ភូមិគឺជាទីកន្លែងដែលមានទំហំធំទូលាយ និងមានផ្ទះនៅបែកខ្ញែកគ្នា។ កាលណាមានបញ្ហាអ្វីមួយកើតឡើង ដំបូងគេហៅរកអ្នកចាស់ទុំម្នាក់ ដែលរស់នៅក្បែរគ្នា។ បន្ទាប់មក ប្រសិនបើរឿងរ៉ាវត្រូវបានបញ្ជូនទៅដល់មេភូមិ មេភូមិបានធ្វើការសាកសួរ អ្នកចាស់ទុំឱ្យគាត់និយាយរឿងរ៉ាវប្រាប់ ដើម្បីគាត់អាចធ្វើការវាយតម្លៃត្រឹមត្រូវក្នុងការនិយាយជាមួយជនដែលមានទំនាស់"។
> (លោក វៃ អាយុ៤៦ឆ្នាំ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

> "មេឃុំជាអ្នកប្រមូលប្រាក់ពន្ធលើដីធ្លី។ នៅពេលណាមេឃុំមកដល់ មេភូមិបានរួមដំណើរជាមួយគាត់។ មេភូមិជាអ្នកទទួលបន្ទុកការរៀបចំថ្នាក់សំរាប់អនក្ខរជន។ មេភូមិបានជ្រើសរើសគ្រូដើម្បីបង្រៀនអនក្ខរជន។ មេភូមិក៏ជ្រើសរើសមនុស្សចូលកំណែនពលកម្មដែរ។ នៅពេលខ្លះការងារមានរយៈពេលយូរណាស់។ ចំពោះការកសាងផ្លូវដែក គេបានធ្វើការអស់រយៈពេលពីរសប្តាហ៍នៅកំពង់ត្រាច។ មហាវិទ្យាល័យ[90] ក៏ត្រូវបានសាងសង់ ដោយសារកម្លាំងពលកម្មរបស់ប្រជាកសិករដែរ។ មេភូមិក៏ទទួលបន្ទុកធ្វើការជ្រើសរើសកងសេនាជនដែលត្រូវតែ ទៅការពារព្រំដែនជាមួយវៀតណាម។ មានការផ្លាស់ប្តូរវេនមនុស្សនៅក្នុងភូមិ។ យើងមានការសប្បាយរីករាយណាស់នៅក្នុងការចូលរួមការងារនេះ។ គឺជាករណីយកិច្ច។ យើងមានអារុំធ មានសន្តិសុខ"។
> (លោក សុត អាយុ ៦៤ ឆ្នាំ ឃុំ អង្កាល់ ក្រុងកែប ខេត្ត កំពត)

---

[90] . តាកែវ កំពត

បើតាមមតិរបស់លោក Jean Delvert ឃុំខ្លះមានទំហំធំណាស់ និងពិបាកគ្រប់គ្រងណាស់ៈ "ឃុំភាគច្រើនមានប្រជាពលរដ្ឋច្រើនជាង ៣០០០នាក់។ ដូច្នេះនាំឱ្យមានផលវិបាកធ្ងន់ធ្ងរខាងរដ្ឋបាល។ គេពិបាកគ្រប់គ្រងមនុស្ស៣០០០នាក់ៈ មេឃុំភាគច្រើនដែលពុំចេះអក្សរពុំមានសមត្ថភាពធ្វើការងារបានទេ។ ដោយហេតុនេះគេនឹងពុំមានការងឿងឆ្ងល់អំពីការគ្មានជំរឿន គ្មានសំបុត្រអត្រានុកូលដ្ឋាន គ្មានស្ថិតិឱ្យបានត្រឹមត្រូវនោះទេ[៩១]"។

ថ្វីបើប្រជាពលរដ្ឋពុំបានដឹងពីការបង់ប្រាក់ពន្ធលើដីធ្លីឱ្យបានត្រឹមត្រូវក៏ដោយ តែការចុះបញ្ជីដីធ្លីនៅក្នុងបញ្ជីជាការមានសារៈសំខាន់ណាស់ ដូចជានៅក្នុងករណីមានវិវាទរឿងដីធ្លី។

> "ចំពោះបញ្ហាដីធ្លីតូចតាច ដូចជាបញ្ហាភ្លឺស្រែចំការ ការកាប់ដើមឈើ ការបង្ហូរទឹក គេអាចធ្វើការសម្រុះសម្រួលដោយផ្ទាល់ជាមួយអ្នកជិតខាង។ ប្រសិនបើអ្នកជិតខាងមិនព្រម ឬប្រសិនបើមានកិច្ចការសំខាន់ណាស់គេបានទៅរកជួបមេភូមិ ហើយមេភូមិក៏ធ្វើការទាក់ទងជាមួយមេឃុំ( ប្រសិនបើអ្នកជិតខាងលួចបង្ខិតព្រំដី)។ មេឃុំមានសៀវភៅចុះបញ្ជីដីធ្លី ដូចនេះគាត់បានដឹងអំពីទំហំដីធ្លីទាំងអស់។ គេត្រូវវាស់ដីទាំងពីរដែលមានវិវាទនឹងគ្នាដើម្បីឱ្យដឹងថា តើនរណាបានលួចបង្ខិតព្រំដីអ្នកម្ខាងទៀត"។
>
> (លោក សេង អាយុ ៥៧ឆ្នាំ ឃុំពងទឹក ក្រុងកែប)

> "កាលខ្ញុំនៅពីតូច នៅទីនេះមានផ្ទះតិចតួចណាស់ ពុំសូវមានមនុស្សច្រើនទេ ហើយក៏ពុំសូវកើតមានបញ្ហាច្រើនដែរ។ ទំនាស់ដីធ្លីទាំងឡាយមានលក្ខណៈងាយស្រួលក្នុងការដោះស្រាយណាស់ពីព្រោះមានបង្កាន់ដៃនៃការចុះបញ្ជីដីធ្លីសំរាប់ការបង់ប្រាក់ពន្ធ។ ក្នុងករណីមានទំនាស់ យើងបានទៅរកជួបចាស់ទុំនិងមេភូមិ"។
>
> (លោក ហង់ អាយុ ៥៦ ឆ្នាំ ឃុំពងទឹក ក្រុងកែប )

ប៉ុន្តែគេអាចសួរថា តើមានដីធ្លីដែលពុំបានប្រកាសប្រាប់ក្រសួងពន្ធដារដែរឬទេ?

នៅក្នុងករណីខ្លះ ដូចជាចំពោះអ្នកដែលបានលះលែងគ្នា មេភូមិពុំមាននិតិសម្បទាក្នុងការវិនិច្ឆ័យទេ។ មេភូមិមានតួនាទីត្រឹមតែធ្វើការសម្រុះសម្រួល។ គាត់អាចដោះស្រាយបញ្ហាការលះលែងគ្នាបានតែនៅក្នុងករណីដែលភាគីទាំងពីរបានព្រមព្រៀងគ្នា។ ការលះលែងគ្នាដោយមានការយល់ព្រមទៅវិញទៅមកមានលក្ខណៈងាយស្រួលក្នុងការដោះស្រាយណាស់ ទោះបីការនេះមានលក្ខណៈផ្ទុយទៅនឹងប្រពៃណីក៏ដោយ។ គូស្រករបែកគ្នាខ្លួនឯង។ ការសំរេចរួមរស់ជាមួយគ្នាជាប្តីប្រពន្ធដោយខ្លួនឯងក្រោយពីពេលអាពាហ៍ពិពាហ៍

[91] (DELVERT, 1984) *ទំព័រ*២០០

លើកទីមួយ ឬការរៀបអាពាហ៍ពិពាហ៍ឡើងវិញមានញឹកញាប់ជាង ដែលសីលធម៌បានទទួលស្គាល់ការធ្វើរបៀបនេះដែរ។

ក៏ប៉ុន្តែ ប្រសិនបើប្តីឬប្រពន្ធពុំចង់ធ្វើការលះលែងគ្នាទេ ហើយនៅក្នុងករណីមានបញ្ហានៅក្នុងការបែងចែកទ្រព្យសម្បត្តិ តួនាទីរបស់មេភូមិនិងចាស់ទុំគឺធ្វើការគោបសង្កត់ទៅលើអ្នកទាំងពីរដើម្បីឱ្យសុខចិត្តរួមរស់នៅជាមួយគ្នា។ ប្រសិនបើបញ្ហានៅតែកើតមានដដែល បញ្ហានេះត្រូវតែបញ្ជូនទៅថ្នាក់លើទៀត។

ករណីទំនាស់ដីធ្លី គឺជាបញ្ហាស្រួចស្រាល។ ជួនកាលពុំមានភាគីណាមួយមានបំណងចុះចាញ់ឡើយ ហើយរឿងត្រូវបញ្ជូនឡើងទៅគ្រប់ជាន់ថ្នាក់រដ្ឋបាល។

ប្រសិនបើអាជ្ញាធរភូមិនិងឃុំគឺជាមនុស្សដែលអ្នកភូមិបានស្គាល់ច្បាស់ គេមិនចង់នាំរឿងនោះទៅអាជ្ញាធរស្រុក ខេត្តដែលនៅឆ្ងាយទេ ហើយដែលគេពុំមានការទុកចិត្តនិងពុំចង់ជួបដែរ។ គេពុំបានដឹងថាមានការសម្រុះសម្រួលដោយពិតប្រាកដនៅថ្នាក់ស្រុកទេ។ គេជឿថា អាជ្ញាធរស្រុកនឹងបញ្ជូនរឿងនោះដោយត្រង់ទៅអាជ្ញាធរ តុលាការដើម្បីធ្វើការវិនិច្ឆ័យ ដែលគេហៅថាសាលាដំបូង។

**ដំណើរការសម្រុះសម្រួលៈ**

ផ្អែកទៅលើការសម្ភាសន៍ជាច្រើន យើងឃើញថា ដំណើរការនៃនៃការសម្រុះសម្រួលទាក់ទងយ៉ាងខ្លាំងទៅនឹងបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលមួយរូប ច្រើនជាងចំណេះដឹងដែលមានចែងនៅក្នុងសៀវភៅ។ ចំពោះមេភូមិដែលមានការរៀនសូត្រនឹងមានចំណេះដឹងខ្ពស់ គាត់បានយកគោលការណ៍ដែលមានមកពីប្រពៃណី និងផ្អែក ព្រះពុទ្ធសាសនាមកផ្សំបញ្ចូលគ្នាដើម្បីធ្វើឱ្យភាគីដែលមានទំនាស់រក្សាភាពស្ងប់ស្ងាត់វិញ។ ចំណែកឯអ្នកមិនចេះអក្សរសំអាងតែទៅលើវិចារណញ្ញាណល្អ ឬអាក្រក់របស់គាត់។ នៅក្នុងភូមិដែលអ្នកស្រុកបានស្គាល់គ្នាទាំងអស់ គោលបំណងនៃការសម្រុះសម្រួលគឺ ជាការស្វែងរកការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទជាជាងទៅស្វែងរកយុត្តិធម៌ដែលមានអ្នកចាញ់និងអ្នកឈ្នះ។ អ្នកចាញ់បានបាត់បង់កិត្តិយសហើយអាចដាក់ឱ្យនៅឆ្ងាយពីគេ។ គេខិតខំបញ្ចៀស វិធីរបៀបនេះដែលនឹងនាំឱ្យសង្គមគ្រួសារតូចអាចស្លាប់ដោយយឺត១។ នៅពេលមានការសម្រុះសម្រួល ភាគីនិមួយ១ត្រូវចេះធ្វើសម្បទានបន្តិច គឺផ្តល់ឱ្យគេបន្តិចនិងយកមកវិញបន្តិច ដើម្បីឱ្យបានទៅដល់ការព្រមព្រៀងមួយដែលអាចផ្តល់កិត្តិយសទាំងសងខាង។ ថ្វីបើការអនុវត្តន៍ការសម្រុះសម្រួលមានការផ្លាស់ប្តូរពីមេភូមិមួយទៅមេភូមិម្នាក់ទៀតនោះ តែក្របខ័ណ្ឌជាមូលដ្ឋានមានលក្ខណៈដូចតែគ្នា :

នៅពេលដែលភាគីម្ខាង ឬភាគីទាំងពីរនៅក្នុងទំនាស់បានស្នើសុំឱ្យមានការសម្រុះសម្រួល មេភូមិបានរៀបចំឱ្យមានការប្រជុំមួយ។ គូជម្លោះទាំងពីរ ត្រូវបានអញ្ជើញឱ្យទៅផ្ទះមេភូមិឬទៅកន្លែងដែលមានវិវាទ។

ទៅតាមតែអធ្យាស្រ័យរបស់មេភូមិ ចាស់ទុំនឹងសមាជិករបស់គ្រួសារអាចអនុញ្ញាតឱ្យចូលរួមបាន។ មេភូមិស្នើឱ្យភាគីទាំងពីរនិយាយម្នាក់ម្តង១ និងពន្យល់អំពីសភាពការណ៍។ គាត់ក៏អាចស្នើសុំឱ្យជនផ្សេងទៀតជួយផ្តល់ការបំភ្លឺបញ្ហាទាំងនេះដែរ។ បន្ទាប់មក គាត់ក៏សាកល្បងរំងាប់បញ្ហា។ គាត់បានសុំឱ្យគូជម្លោះទាំងសងខាងដើម្បីរកដំណោះស្រាយមួយដែលធ្វើឱ្យភាគីទាំងពីរមានការពេញចិត្ត ឬមួយគាត់បញ្ចេញទស្សនៈរបស់គាត់ដើម្បីឱ្យភាគីទាំងពីរគោរពតាម។

ប្រធានភូមិដែលចូលចិត្តស្តាប់គេនិយាយ និងមានគំនិតប្រកបដោយសមធម៌ ព្យាយាមថ្លឹងថ្លែងការទាមទាររបស់ភាគីនិមួយ១ទៅវិញទៅមកដើម្បីជៀសវាងកុំឱ្យភាគីណាមួយខូចប្រយោជន៍ ឬធ្វើឱ្យបាត់បង់កិត្តិយ។ ឧទាហរណ៍ នៅក្នុងករណីដែលមានសត្វស៊ីផលដំណាំ ប្រសិនបើមានការខូចខាតតិចតួច មេភូមិបានស្នើសុំឱ្យបំភ្លេចរឿងនោះចោលទៅ ហើយកុំបង្កើតរឿងទៀត។ ប្រសិនបើមានការខូចខាតច្រើន មេភូមិបានស្តាប់ការស្នើសុំឱ្យ មានការសងម្ចាស់ចំការ និងបានធ្វើការវាយតម្លៃអំពីលទ្ធភាពនៃការសងរបស់ម្ចាស់សត្វដែលបានស៊ីដំណាំគេ។ មេភូមិបានរកដំណោះស្រាយកណ្តាលមួយ ដែលភាគីទាំងពីរត្រូវតែធ្វើការប្រឹងប្រែងដើម្បីបង្ហាញពីសាមគ្គីភាពរវាងគ្នានិងគ្នា។

មេភូមិជាច្រើនដែលមិនចេះគួរសម បានស្តីប្រដៅអ្នកទាំងនោះ ហើយបង្គាប់ដាច់ខាតដល់អ្នកទាំងនោះឱ្យបំភ្លេចបញ្ហាតែម្តងនិងស្តីកុំឱ្យបង្កើតរឿងរ៉ាវទៀតប្រយ័ត្នមានទោស។

នៅចន្លោះកិរិយាទាំងពីរនេះ គឺមានឥរិយាបថជាច្រើនទៀតដែលប្រព្រឹត្តទៅតាមលំដាប់ថ្នាក់ គឺពីយុត្តិធម៌បំផុតរហូតដល់ការបង្ខិតបង្ខំបំផុត ដែលអាស្រ័យដោយបុគ្គលិកលក្ខណៈរបស់មេភូមិ។

បើនិយាយឱ្យចំទៅគឺ ពុំមានរបៀបដោះស្រាយទំនាស់ដែលមានចែងនៅក្នុងក្រមឱ្យបានត្រឹមត្រូវនោះទេ។ មនុស្សម្នាក់១បានសម្របសម្រួលវិធីរបស់ខ្លួនទៅនឹងអ្វីដែលគាត់បានយល់ដឹង និងបានរស់នៅ។

> "នៅក្នុងសម័យសង្គមរាស្ត្រនិយម បងរបស់ខ្ញុំឈ្មោះតាអោម បានធ្វើជាមេភូមិអស់រយៈពេលពីរឬបីឆ្នាំ។ គាត់បានជួយប្រជាពលរដ្ឋឱ្យចេះដោះស្រាយបញ្ហារបស់ខ្លួននៅក្នុងថ្នាក់ភូមិ ពីព្រោះគាត់មិនចង់ឱ្យគេចំណាយប្រាក់ច្រើននៅពេលទៅដល់តុលាការទេ។ គាត់បានដោះស្រាយរឿងឈ្លោះគ្នារវាងប្តីនិងប្រពន្ធ រឿងព្រំដីធ្លី។ តាអោមបានស្តាប់ការរឹកញែករបស់ភាគីទាំងពីរ បន្ទាប់មកគាត់បានធ្វើការសំរេច។ គាត់ពុំធ្វើអន្តរាគមន៍ដោយ ផ្ទាល់នៅក្នុងបញ្ហានោះទេ។ គាត់ចាំដល់គេនឹងមករកគាត់ លើកលែងតែក្នុងករណីវាយតប់គ្នានិងបណ្តាលឱ្យមានរបួស។ តាអោមបាននិយាយថា ត្រូវតែមានការអត់អោន និងមិនត្រូវបង្កើតរឿងទេ។ ប្រជាពលរដ្ឋទាំងអស់បានស្តាប់តាមមតិរបស់គាត់។ គាត់ចេះដឹងគោលការណ៍របស់ព្រះពុទ្ធ។ កាលពីមុនគាត់ជាលោកសង្ឃ

បន្ទាប់មកបានរៀបអាពាហ៍ពិពាហ៍ ហើយក្រោយមកទៀតបានធ្វើជាអាចារ្យ។ គាត់មានកេរ្តិ៍ឈ្មោះល្អណាស់ដោយសារតែចំណេះដឹងរបស់គាត់។ នៅក្នុងការប្រតិបត្តិប្រចាំថ្ងៃ គាត់បានផ្សំគោលការណ៍ផ្អែកព្រះពុទ្ធសាសនាជាមួយច្បាប់ អាណាចក្រដែលកើតមានរៀងរាល់ថ្ងៃ។ តាអោមបានរៀនសូត្រច្បាប់អាណាចក្រនៅសាលាដូចមនុស្សគ្រប់រូបដែរ។ គាត់បានរៀនសូត្រអត្ថបទផ្អែកព្រះពុទ្ធសាសនានៅតាមវត្ត។

(លោក ពេន អាយុ៦៨ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

ការស្វែងរកការព្រមព្រៀងគ្នាជាឯកច្ឆ័ន

ទំនាស់ឬបញ្ហាជាច្រើនត្រូវបានដោះស្រាយ ដោយផ្អែកទៅលើអ្វីដែលសហគមន៍បានចាត់ទុកថាត្រឹមត្រូវ ទោះបីនៅក្នុងការពិតគេពុំអាចនិយាយអំពី "យុត្តិធម៌" ពិតប្រាកដបានឡើយក៏ដោយ។ ការរស់នៅក្នុងពុម្ពរបស់សង្គម និងការស្វែងរកការព្រមព្រៀងគ្នាជាឯកច្ឆ័នមានសារសំខាន់ជាងការបង្កើតគំនិតប្លែកៗពីគំនិតអ្នកដទៃ។ ការនេះបានបង្ហាញឱ្យឃើញថា គេបានលំអោនទៅតាមពាក្យសំដីរបស់ជនដែលមានឋានន្តរសក្តិខ្ពស់ តាមរបៀបរៀមច្បង និងតាមតំណាងអ្នករាជការជារៀងរហូត។

"កាលពីមុន ការគោរពគ្រួសារនិងការគោរពឋានៈរបស់មនុស្សម្នាក់ៗ មានសារៈសំខាន់ជាងផលប្រយោជន៍ផ្ទាល់ខ្លួន" ។

(លោក អួន អាយុ៧០ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

តាមមតិលោក Vighen: "ការយល់ស្របគ្នាដែលបានបង្ហាញជាសាធារណៈ មានសារៈសំខាន់ជាងការបង្ហាញអំពីទស្សនៈប្រឆាំង[៩២]" ។

"យើងទាំងអស់គ្នាជាអ្នកស្រែចំការ យើងជាអ្នកក្រីក្រ និងមិនចេះអ្វីទេ។ វត្តគឺជាទីកន្លែងតែមួយគត់ដែលយើងរៀនសូត្រ។ អ្នកចាស់ៗពុំមែនជាអ្នកចេះដឹងជ្រៅជ្រះទេ។ គាត់និយាយតែពីជនណាដែលធ្វើឱ្យគាត់ពេញចិត្ត ហើយអំពើនេះពុំមែនជាការត្រឹមត្រូវជានិច្ចទេ។ ក៏ប៉ុន្តែ គេបានយល់ស្របតាមសេចក្តីសំរេចរបស់អ្នកចាស់ទុំ ពីព្រោះជាបឋមគេត្រូវស្វែងរកការព្រមព្រៀងគ្នាមួយ។ ឥឡូវនេះ គេក៏ស្វែងរកការព្រមព្រៀងគ្នាដែរ ប៉ុន្តែគឺរដ្ឋបាលមូលដ្ឋានទេដែលជាអ្នកមានសារៈសំខាន់បំផុត។ រដ្ឋបាលមូលដ្ឋានធ្វើការដោយផ្អែកទៅលើច្បាប់ ហើយពុំគិតពីមតិផ្ទាល់ខ្លួនរបស់ជន

[92]. VIGHEN ការការពារទំនៀមទំលាប់និងការអភិវឌ្ឍន៍សហគមន៍នៅក្នុងភូមិខ្មែរអ្នកស្រាវជ្រាវ ខ្មែរដើម្បីការអភិវឌ្ឍ-ភ្នំពេញ ១៩៩៦ *ទំព័រ* ១២

ទាំងឡាយនោះឡើយ ។ កាលពីមុន មនុស្សដែលចេះដឹងគឺជាឈ្មួញ ។ គឺជនជាតិចិន ពួកមូលធន ។ ពួកគេជាអ្នកមាន" ។

(លោកស្រី ហៀង អាយុ៧៧ឆ្នាំ សង្កាត់ អង់កោល ក្រុងកែប)

## ការវិនិច្ឆ័យ

នៅក្នុងករណីវិវាទដែលទាមទារឱ្យមានការកាត់សេចក្ដីរវាងជនពីររូបដែលហៅថា "រឹងរូស" ឬ "ក្បាលរឹង" តួនាទីរបស់អ្នកសម្រុះសម្រួលដែលបានរៀបចំធ្វើដោយអាជ្ញាធរមូលដ្ឋាន ហាក់ដូចជាមិនមានដំណើរការទៅមុខទេ ។ តួនាទីដែលចង់បានរបស់អាជ្ញាធរមូលដ្ឋានគឺធ្វើការសម្រុះសម្រួល ។ ការវិនិច្ឆ័យដោយមានអ្នកឈ្នះនិងអ្នកចាញ់ធ្វើបានតែនៅឯតុលាការទេ ។

"គេពុំអាចនិយាយថាអ្នកមួយត្រូវហើយអ្នកម្នាក់ទៀតនោះខុសឡើយ ។ តួនាទីរបស់គាត់ គឺធ្វើការសម្រុះសម្រួលមនុស្សទាំងសងខាង ពុំមែនធ្វើការកាត់សេចក្ដីលើជនទាំងនោះឡើយ" ។

(លោកស្រី សំអុល អាយុ៤៩ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន, ខេត្តកំពង់ស្ពឺ)

ជាទូទៅ អាជ្ញាធរមូលដ្ឋានចង់ធ្វើការដោះស្រាយបញ្ហានានាដោយខ្លួនឯង ហើយមិនលើកទឹកចិត្តឱ្យជនទាំងអស់ធ្វើការប្ដឹងផ្ដល់គ្នារហូតដល់តុលាការទេ ។ ការដោះស្រាយបញ្ហានានាដោយខ្លួនឯង និងការមិនផ្សព្វផ្សាយបញ្ហាឱ្យគេដឹងដោយសារខ្លាចមានកេរ្តិ៍ឈ្មោះអាក្រក់គឺជាអំពើមួយដែលគេចូលចិត្តធ្វើ ។

ដោយចង់បង្ហាញកេរ្តិ៍ ឈ្មោះទៅខាងក្រៅឱ្យឃើញថាភូមិគេជាកន្លែងមួយដែលពុំដែលកើតមានបញ្ហានិងពុំមានចោរ ។ ភូមិមួយដែលមានអាជ្ញាធរនៅនឹងកន្លែងគ្រប់គ្រងបានយ៉ាងល្អត្រឹមត្រូវគឺមានសារៈសំខាន់ណាស់ ។

ការបញ្ជូនទៅតុលាការខេត្ត (សាលាដំបូង) កើតមានជាញឹកញាប់គួរសម ជាពិសេសចំពោះជនទាំងឡាយណាដែលរស់នៅក្នុងភូមិដែលឋិតនៅជិតទីប្រជុំជនខេត្ត ។ ហេតុការណ៍នេះ មានលក្ខណៈផ្ទុយគ្នាស្រឡះចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ហើយដែលបានពឹងផ្អែកជារឿយៗតែទៅលើខ្លួនឯងផ្ទាល់ និងរដ្ឋអំណាចមួយដែលនៅដាច់ស្រយាល ។

ទោះបីជាដំណើរការរបស់តុលាការពុំមានលក្ខណៈត្រឹមត្រូវតតខ្មោះ និងមានការទិតៀនយ៉ាងច្រើនក៏ដោយក៏គេបានចាត់ទុកថាអាចទទួលយកបានត្រឹមត្រូវនិងមានការទុកចិត្ត ។ ចៅក្រមមានប្រាក់ខែយ៉ាងសមរម្យហើយពុំសូវមានចោទអំពីបញ្ហាពុករលួយដូចសម័យឥឡូវនេះទេ ។

"ប្រជាជនមានការភ័យខ្លាចអំពីដីការកោះហៅទៅតុលាការ ប៉ុន្តែពុំខ្លាចការកោះហៅផ្សេងៗទៀតឡើយ ។ គេបានយល់ស្របតាមការវិនិច្ឆ័យរបស់តុលាការ ។ ការវិនិច្ឆ័យគឺជាច្បាប់ ដូចនេះគេបាន

យល់ស្របតាម។ ការទៅតុលាការជាការល្អ តែគេត្រូវចំណាយប្រាក់ច្រើន។ មានសុភាសិតខ្មែរមួយនិយាយថា" ទៅតុលាការ គឺដូច ឋិតនៅក្នុងម៉ាស៊ីនកិនស្រូវដែលកិនខាងលើផងនិងកិនខាងក្រោមផង។ ដូចនេះ ប្រសិនបើមនុស្សពីរនាក់មានទំនាស់ បើអ្នកទីមួយចំណាយប្រាក់អស់១០០០រៀល អ្នកទីពីរក៏ចំណាយប្រាក់អស់១០០០រៀលដែរ។ ម៉ាស៊ីនកិន អ្នកទាំងពីរ"។

(លោក វ៉ាន់ណេត អាយុ ៥២ ឆ្នាំ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល)

"ជនទាំងឡាយមានការភ័យខ្លាចច្បាប់និងតុលាការ។ គេមានការទុកចិត្តទៅលើច្បាប់។ អំពើពុករលួយ ពុំមានលក្ខណៈខ្លាំងក្លាដូចសព្វថ្ងៃនេះទេ ពីព្រោះកាលពេលនោះអ្នកធ្វើការនៅក្នុងផ្នែកតុលាការបានទទួលប្រាក់ បៀវត្សគ្រប់គ្រាន់"។

(លោក សាន អតីតនាយកបឋមសិក្សា ក្រុងស្វាយរៀង, ខេត្តស្វាយរៀង)

នៅពេលបើកសវនាការម្ដងៗ អ្នកភូមិពុំបានការពាររឿងរបស់ខ្លួនឯងផ្ទាល់ទេ។ គេបានប្រគល់រឿងនេះទៅឱ្យអ្នកមានចំណេះដឹងម្នាក់ដែលមានភារកិច្ចធ្វើជាតំណាងរបស់ពួកគេនៅឯតុលាការ។ ប្រព័ន្ធនេះបានទទួលការយល់ព្រមច្រើន។ បើយោលទៅតាមឃុំជាច្រើន បន្ទុកនេះបានធ្លាក់ទៅលើមេឃុំ អនុប្រធានឃុំណាមួយ ឬ លេខាធិការឃុំ។ ពាក្យពេចន៍ដែលគេបានប្រើមានការខុសៗគ្នាអាស្រ័យទៅដោយទីកន្លែងនិងមនុស្ស។

"កាលពីមុនគេពុំមានសិទ្ធិធ្វើការលះលែងប្ដីប្រពន្ធនៅថ្នាក់ភូមិឡើយ។ ប្រសិនបើគេចង់ធ្វើការលះលែងគ្នា គេត្រូវទៅតុលាការ។ ក្នុងសម័យសង្គមរាស្ត្រនិយម មានតុលាការមួយដែលគេឱ្យឈ្មោះថាសាលាដំបូង។ គេអាចទៅប្ដឹងនៅសាលាដំបូងបានយ៉ាងងាយបំផុត។ កាលនោះគេចូលចិត្តតុលាការ។ គេអាចទៅប្ដឹងតុលាការយ៉ាងងាយ។ នៅពេលធ្វើការវិនិច្ឆ័យ គឺយើងពុំមែនជាអ្នកធ្វើការពន្យល់អំពីបញ្ហារបស់យើងទេ។ មានមនុស្សម្នាក់ដែល បានធ្វើការនៅក្នុងឃុំចំនួន៤ គឺមេមណ្ឌល។ គឺមេមណ្ឌលដែលជាអ្នកការពារផលប្រយោជន៍ឱ្យយើង។ "គាត់ជាអ្នកស៊ីលុយកាក់មែន"។ យើងឱ្យលុយកាក់ដើម្បីឱ្យគាត់គិតគូររឿងយើងឱ្យបានល្អ។ ជនគ្រប់រូបបានចូលចិត្តប្រព័ន្ធនេះ"។

(លោក សេង អាយុ ៥៧ឆ្នាំ សង្កាត់ ពងទឹក ក្រុងកែប)

"ប្រជាជនច្រើនបានទៅប្ដឹងតុលាការចំពោះករណីព្រហ្មទណ្ឌ ប៉ុន្តែក៏នៅមានករណីរដ្ឋប្បវេណីដែរដូចជាបញ្ហាដីធ្លី ឬការលះលែងគ្នា។ ចាប់តាំងពីដើមទសវត្សឆ្នាំ៦០ មានប្រជាជនជាច្រើនបានទៅដាក់ពាក្យបណ្ដឹងនៅតុលាការយ៉ាងងាយស្រួល។ ដើម្បីជួយអ្នកភូមិ មានទីប្រឹក្សារដ្ឋបាលពីរឬបីរូបដែលបានធ្វើការទាក់ទងគ្នារវាងយើងនិងតុលាការ។ គាត់បានការពាររឿងក្ដីនោះជំនួសយើង

ពីព្រោះគាត់ចេះនិយាយប្រសើរជាងយើង ហើយគាត់បានយល់អំពីនីតិវិធីច្រើន។ គាត់បានធ្វើការអង្កេតអំពីរឿងដែលបានកើតមាន ហើយបានផ្តល់របាយការណ៍ ជូនទៅចៅក្រមតាមភាសារបស់គាត់។ នៅឆ្នាំ១៩៧០ សង្គ្រាមបានផ្ទុះឡើង តុលាការបានបិទទ្វារ ហើយចាប់តាំង ពីពេលនោះមកគេពុំបានដាក់ក្រុមប្រឹក្សាឱ្យមានដំណើរការឡើយ។ ប៉ុន្តែ ក៏ជាការល្អ១ដែរ"។

(លោក វ៉េត អាយុ ៥៧ឆ្នាំ ឃុំនគរធំ ស្រុក សៀមរាប, ខេត្ត សៀមរាប)

"កាលពីមុន មេឃុំមួយរូបមានអនុប្រធានបីរូប និងលេខាធិការមួយរូបជួយធ្វើការ។ នៅពេលមានរឿងក្តីម្តង១ មានស្មាក្តីមួយរូបជាអ្នកទទួលបន្ទុកជួយការពារអ្នកក្រីក្រក្នុងការបង្ហាញរឿងរបស់ខ្លួន។ ចំពោះរឿងរ៉ាវតូចតាចជាមួយគ្រួសារនិងអ្នកជិតខាង គេពុំបានទៅរកមេភូមិឱ្យជួយដោះស្រាយទេ។ គេបានទៅរកជួបអ្នកចាស់ទុំ ឬមនុស្សនៅក្នុងគ្រួសារ។ នៅក្នុងភូមិ តាគនមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ គាត់មានចំណេះដឹងច្រើន មានកេរ្តិ៍ឈ្មោះល្អនិងមានបទពិសោធន៍ផ្នែករដ្ឋបាល ពីព្រោះគាត់ជាអតីតមន្ត្រីមួយរូប"។

(លោក សាន អាយុ៧០ឆ្នាំ អតីតនាយកសាលាបឋមសិក្សា ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

"តុលាការមានលក្ខណៈល្អ ហើយមានយុត្តិធម៌។ ប្រជាជនទាំងអស់បានគោរពតាមការវិនិច្ឆ័យ។ ជនកាចសាហាវត្រូវបានទទួលការអប់រំយ៉ាងល្អ"។

(លោក ខៅ អាយុ៤៦ឆ្នាំ មេភូមិ ឃុំចេក , ស្រុកស្វាយជ្រំ, ខេត្ត ស្វាយរៀង)

## ផ្លូវដោះស្រាយផ្សេងទៀត

នៅក្នុងករណីព្រហ្មទណ្ឌ នគរបាលបានចូលរួមជានិច្ច។

"កាលណាមានបញ្ហាអ្វីមួយ គេបានទៅរកជួបមេភូមិ។ ប៉ុន្តែប្រសិនបើមានការវាយគ្នានិងមានរបួស គេ បានទៅរកជួបនគរបាលដើម្បីនាំអ្នកទាំងនោះទៅប៉ុស្តិ៍"។

(លោក ចាន់ណា អាយុ៦២ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប)

ទំនាស់ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុតមានទាក់ទងទៅនឹងបញ្ហាទ្រព្យសម្បត្តិជាសម្ភារៈ។ ទំនាស់ដីធ្លីអាចប្តឹងឡើងទៅរហូតដល់តុលាការហើយធ្វើឱ្យភាគីទាំងពីរចំណាយប្រាក់អស់ជាច្រើន។

ការធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយរបស់បុគ្គលត្រូវបានចាត់ទុកថាពុំសូវមានសារៈសំខាន់ទេ។ ករណីវាយតប់គ្នានិងមានរបួស ឬការរំលោភផ្លូវភេទត្រូវបានដោះស្រាយជាញឹកញាប់តាមការស្រុះស្រួលគ្នាជាមិត្ត-ភាព ដោយធ្វើការបង់សំណងជាប្រាក់។ អំពើទាំងអស់នោះកើតឡើងដោយសារការម៉ូម៉ៅខ្លាំងពេក

ដោយសារកំហឹង ឬ ដោយសារឥទ្ធិពលនៃសុរា។ ជនដែលបានប្រព្រឹត្តកំហុសមិនត្រូវបានធ្វើការវិនិច្ឆ័យ ដោយជាក់ស្តែងជាអ្នកទទួល ខុសត្រូវចំពោះអំពើរបស់គេឡើយ ។

អំពើវាយតប់ទៅលើប្រពន្ធ មិនត្រូវបានចាត់ទុកដូចជាបទល្មើសទេ ប៉ុន្តែទុកដូចជាមធ្យោបាយមួយបែប ជ្រុលដៃបន្តិច ដើម្បីថែរក្សាសេចក្តីសុខក្នុងពេលរស់ជាមួយប្តីប្រពន្ធរៀបការ ។ បញ្ហាអំពើហឹង្សាក្នុងគ្រួសារ មិនបានបង្ករឱ្យមានភាពរំជើបរំជួលទេ ដរាបណាមិនមានឈាមហូរ ឬបែកក្បាល ។

"នៅពេលមនុស្សប្រុសម្នាក់ខឹងខ្លាំង ហើយវាយប្រពន្ធខ្លួន មេភូមិនឹងទៅសួរនាំប្តី តែនៅពេល ដែលប្រពន្ធបែកក្បាលហូរឈាម ហើយគឺប្រពន្ធជាអ្នករត់ទៅរកមេភូមិឱ្យជួយធ្វើអន្តរាគមន៍។ និយាយដោយខ្លីគឺ ជារឿងទាក់ទងតែប្តីប្រពន្ធ។ គេមិនចូលចិត្តឱ្យមានការជ្រៀតជ្រែកចូល កិច្ចការអ្នកដទៃទេ" ។

(លោក ឈុប អាយុ ៧០ ឃុំនគរធំ ស្រុក សៀមរាប ខេត្តសៀមរាប)

ព្រះសង្ឃ

នៅពេលជួបសន្ទនា ព្រះសង្ឃពុំដើរតួនាទី ដោយឡែកនៅក្នុងការដោះស្រាយឬការសម្រុះសម្រួលទំនាស់ របស់គ្រហស្ថឡើយ។ តែផ្ទុយទៅវិញ នៅក្នុងបរិវេណទីវត្ត ព្រះសង្ឃមានវិន័យច្បាស់លាស់ណាស់ដើម្បី ដោះស្រាយបញ្ហាគ្រប់បែបយ៉ាងទាំងអស់ ឬទំនាស់មួងម៉ាល់ដែលកើតឡើងដោយព្រះសង្ឃអង្គណាមួយ ។ កម្រងវិន័យ នេះមានច្រើនណាស់បើប្រៀបធៀបទៅនឹងវិន័យតិចតួចផ្នែកគ្រហស្ថក្នុងវិស័យដោះស្រាយ បញ្ហាប្រចាំថ្ងៃ។ វិន័យ នេះកើតចេញមកអំពីប្រពៃណីរបស់ព្រះពុទ្ធសាសនាហីនយានដែលបានចូលមកពី ប្រទេសសីរីលង្កា និងបានផ្សព្វផ្សាយនៅក្នុងប្រទេសជាច្រើននៅអាស៊ីអគ្នេយ៍។ វិន័យបានរៀបរាប់អំពី ករណីនានាយ៉ាងច្បាស់លាស់ណាស់ ហើយនិងទណ្ឌកម្មដែលកើតចេញពីការរំលោភវិន័យទាំងនោះ ។

មានជំនួយផ្នែកសាសនាតែមួយគត់ដែលត្រូវបានគ្រហស្ថស្នើសុំគឺ ពិធីលាងអំពើបាប និងបួងសួងសុំសេចក្តី សុខនិងសុភមង្គល ។

"ព្រះសង្ឃនិងគ្រហស្ថត្រូវបានចែកដាច់ពីគ្នា។ ទំនាស់រវាងគ្រហស្ថនិងគ្រហស្ថ គឺគ្រហស្ថជាអ្នក ដោះស្រាយ ។ ព្រះសង្ឃដោះស្រាយទំនាស់របស់ព្រះអង្គនៅតែក្នុងបរិវេណវត្តអារាមតែប៉ុណ្ណោះ ។ មានការបែងចែកដាច់ពីគ្នារវាងព្រះសង្ឃនិងគ្រហស្ថ" ។

( លោក សាន អាយុ៧០ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង )

"ព្រះសង្ឃពុំអាចធ្វើអន្តរាគមន៍នៅក្នុងរឿងរបស់ភូមិបានឡើយ ។ ព្រះសង្ឃត្រូវបានកាត់ផ្តាច់ពី អ្នកភូមិ" ។ ( លោក ឈុប អាយុ ៧០ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ប៉ុន្តែ គេបានសង្កេតឃើញមានឥទ្ធិពលរបស់ព្រះពុទ្ធសាសនានៅក្នុងផ្នែកអប់រំ។ ដូចនេះ ចំណែកដ៏សំខាន់បំផុតនៃចំណេះដឹងរបស់អ្នកចាស់ទុំនៅក្នុងភូមិគឺបានមកអំពីអត្ថបទនានាផ្នែកព្រះពុទ្ធសាសនា។ ប្រពៃណីចង់ឱ្យមនុស្សចូលបួសធ្វើជាព្រះសង្ឃក្នុងរយៈពេលមួយមិនកំណត់។ នៅវត្តអារាមគេបានទទួលការបង្ហាត់បង្រៀនអំពីគោលការណ៏ព្រះពុទ្ធសាសនា។ ពេលវិលត្រឡប់មករស់នៅជាគ្រហស្ថវិញ គាត់បានសាកល្បងអនុវត្តអ្វីដែលគាត់បានសិក្សា។ ក្មេងៗរៀនអាននិងសរសេរនៅតាមវត្តអារាម បន្ទាប់មករៀនសូត្របន្ថែមទៀតនៅសាលា របស់រដ្ឋដែលឋិតនៅក្នុងបរិវេណវត្តដដែលៈ គឺសាលាវត្តបែបថ្មី"។

អ្នកបានប្រគល់បញ្ហារបស់ខ្លួនទៅឱ្យព្រះសង្ឃ តាមគោលការណ៏គឺជនទាំងនោះមានចំណងទាក់ទងក្នុងគ្រួសារឬបានមិត្តភាពជាមួយព្រះសង្ឃនោះ។

ព្រះសង្ឃខ្លះមានតួនាទីយ៉ាងសកម្មណាស់ជាមួយប្រជាពលរដ្ឋ។ តួនាទីនេះបានបង្ហាញអំពីអត្តចរិតផ្ទាល់របស់ព្រះអង្គច្រើនជាងភារកិច្ចដែលគេបានប្រគេនព្រះអង្គ។

ប៉ុន្តែវត្តអារាមមានតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងសម័យនោះ។ ថ្វីបើគេពុំអាចហៅភូមិថាជាសហគមន៏មួយបានទេនោះ តែគេអាចធ្វើការប្រជុំនៅក្នុងវត្តអារាមបាន។

ហេតុដូច្នេះហើយបានជាលោក Jean Delvert បានកំណត់ថាៈ "កុមារតូចៗបានទៅរៀនវិជ្ជាជាន់ដំបូងនៅតាមវត្តអារាម ហើយកុមារទាំងនោះបានបន្តការសិក្សារបស់ខ្លួននៅតាមសាលាសាធារណៈដែលសង់នៅក្នុងបរិវេណវត្តអារាម។ ចំពោះប្រជាកសិករ វត្តអារាមគឺជាទីកន្លែងស្ងប់ស្ងាត់ ជាកន្លែងស្ញឹងស្ញាធ ជាកន្លែងប្រជុំ គឺជាគេហដ្ឋានពិតប្រាកដរបស់សហគមន៏[៩៣]"។

<u>ព្រះមហាក្សត្រ</u>

នៅក្នុងការធ្វើបណ្តឹងតវ៉ាចុងក្រោយបង្អស់ គឺនៅពេលណាដែលការប៉ុនប៉ងដោះស្រាយទំនាស់ទាំងអស់ បានជួបប្រទះបរាជ័យ គេអាចមានលទ្ធភាពធ្វើដំណើរទៅទីក្រុងភ្នំពេញដើម្បីចូលគាល់ព្រះមហាក្សត្រ។

> "នៅក្នុងសម័យសង្គមរាស្ត្រនិយម ក្នុងឱកាសសមាជជាតិដែលបានប្រព្រឹត្តទៅមួយដងឬពីរដងក្នុងមួយឆ្នាំ ប្រជាជនជាច្រើនរូបដែលបានមកពីទូទាំងប្រទេសបានទៅចូលគាល់ព្រះមហាក្សត្រ ដើម្បីឱ្យព្រះអង្គរកយុត្តិធម៌។ ព្រះមហាក្សត្របានស្តាប់ពាក្យបណ្តឹងហើយបានធ្វើការកាត់សេចក្តី។ ទំនាស់គ្រប់ប្រភេទក្នុងសង្គម ទាំងអស់របស់ប្រជាពលរដ្ឋត្រូវបានធ្វើការជជែកគ្នាដោយចំហរនិង

---

93 . Delvert Jeam *ទំព័រ* ២២០

បានធ្វើការចាក់ផ្សាយផ្ទាល់តាមវិទ្យុ។ បទបញ្ញត្តិនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ តែពុំមានចែងនៅក្នុងច្បាប់ទេ"។

(លោកស្រី សូលីណា អាយុ៤០ឆ្នាំ ចៅក្រមក្រុងភ្នំពេញ)

គេបានរាយការណ៍ឱ្យយើងបានដឹងថា នៅពេលមានកើតវិវាទម្តងៗ អ្នកមានវិវាទត្រូវបានគេនាំឱ្យទៅស្បថនៅមុខរូបសំណាកមនុស្សជិះសេះ គឺរូបសំណាកព្រះមហាក្សត្រព្រះនរោត្តម ដែលលោកណាប៉ូឡេ-អុងទី៣ (Napoléon III) បានសាង ហើយបានដាក់តាំងនៅក្នុងបរិវេណព្រះបរមរាជវាំង។ គេនិយាយថារូបសំណាក នេះមានទេវតាថែរក្សាដ៏មានអនុភាពខ្លាំងបំផុតគង់នៅ។

## គ. ការបង្កាទំនាស់

ការភ័យខ្លាចការបង្ក្រាបដែលអនុវត្តដោយអាជ្ញាធរមូលដ្ឋាន, ការភ័យខ្លាចការសងសឹកផ្ទាល់ខ្លួន ឬការដាក់ទណ្ឌកម្មដោយអំណាចទេវតា អារក្ស អ្នកតា បានចោទជាបញ្ហាដ៏ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋ។ ការភ័យខ្លាចទាំងនោះបានបង្កាទំនាស់ជាច្រើនតាមបែបរៀងៗខ្លួន និងបានរួមចំណែកដល់ការថែរក្សាភាពស្ងប់ស្ងាត់សំបកក្រៅ។

### ការភ័យខ្លាចអាជ្ញាធរមូលដ្ឋាន

ការប្រមូលប្រាក់ពន្ធអាករ ការជំរឿនមនុស្សប្រុសឱ្យចូលកំណែនពលកម្ម បានធ្វើឱ្យអ្នកភូមិប្រកាន់យកការរស់នៅឃ្លាតឆ្ងាយពីមេឃុំនិងមេភូមិ។ អ្នកក្រីក្រដែលពុំមានលទ្ធភាពបង់ប្រាក់ពន្ធ ឬបង់សាហ៊ុយធ្វើអត្តសញ្ញាណប័ណ្ណបានខិតខំលាក់ខ្លួន។ នៅពេលមានបញ្ហាកើតឡើង គាត់ចូលចិត្តលាក់រឿងនោះទុកជាជាងឱ្យអាជ្ញាធរដោះស្រាយ ព្រោះគាត់គិតថាអាជ្ញាធរទាំងនេះនិងពុំដោះស្រាយឱ្យឡើយ។ ការភ័យខ្លាចការដាក់ទណ្ឌកម្មនិងការគោរពថ្នាក់លើបានធ្វើឱ្យប្រជាពលរដ្ឋឋិតនៅក្នុងសភាពស្តាប់បង្គាប់គេរៀងរហូត។

"មេភូមិបានកេណ្ឌប្រជាពលរដ្ឋឱ្យចូលធ្វើកំណែនក្នុងការងារអ្វីមួយ។ ផ្លូវជាតិលេខ១ ត្រូវបានកសាងក្នុងសម័យអាណានិគម។ មនុស្សម្នាក់ៗត្រូវតែចូលរួមការកសាងផ្លូវនេះចំនួនដប់ថ្ងៃ ។ គេពុំបានទទួលកម្រៃអ្វីទេ។ មនុស្សម្នាក់ៗត្រូវតែទៅធ្វើ គេពុំបានត្រិះរិះអ្វីទាំងអស់។ ជនណាដែលពុំបានទៅធ្វើការនោះ ត្រូវបានគេកត់សំគាល់ ហើយមេភូមិក៏បានស្តីប្រដៅជនទាំងនោះដែរ"។

(លោក សាន អាយុ៧០ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

"កាលខ្ញុំនៅតូច ឪពុកខ្ញុំបានធ្វើជាជំទប់។ គាត់ជាអ្នកទទួលបន្ទុកទារប្រាក់ពន្ធនិងអាករ រៀបចំការប្រជុំសំរាប់អ្នកជាប់កំណែនក្នុងការកសាងផ្លូវថ្នល់ឬប្រឡាយទឹក។ គាត់ពុំមានប្រាក់ខែទេ តែបាន

កាត់យកភាគរយ ពីប្រាក់ពន្ធនិងអាករដែលប្រមូលបានមាន ដីស្រែចំការ គោ រទេះ ទោចក្រយាន អត្តសញ្ញាណប័ណ្ណ។ ប្រជាពលរដ្ឋត្រូវតែធ្វើអត្តសញ្ញាណប័ណ្ណថ្មីរៀងរាល់ប្រាំឆ្នាំម្តង ហើយត្រូវដាក់អត្តសញ្ញាណប័ណ្ណនោះតាមខ្លួនជានិច្ច។ ការធ្វើអត្តសញ្ញាណប័ណ្ណនោះត្រូវចំណាយអស់ប្រាក់ច្រើនណាស់។ ជនណាដែលពុំមានអត្តសញ្ញាណប័ណ្ណតែងមានការព្រួយបារម្ភជានិច្ច។ ពួកគេច្រើនតែលាក់ខ្លួន។ ពួកគេមានការភ័យខ្លាចជំទប់និងខ្លាចច្បាប់ណាស់។ ជំទប់កាចណាស់ ហើយគេគោរពគាត់ច្រើន។ ប្រសិនបើជនណាបានប្រព្រឹត្តកំហុសអ្វីមួយ ជននោះត្រូវដាក់ខ្នោះ។ សព្វថ្ងៃនេះ គេលែងគោរពអាជ្ញាធរ លែងគោរពឋានន្តរសក្តិតាមលំដាប់ថ្នាក់របស់មនុស្សទៀតឡើយ។ អំពើនេះមិនល្អសោះ។

កាលពីមុនមានបទបញ្ជាច្បាស់លាស់ ជាមួយនឹងការហាមឃាត់។ ប្រសិនបើគេត្រូវចូលរួមក្នុងកំណែន គេត្រូវតែធ្វើ ពុំនោះសោតទេគេនឹងត្រូវទទួលទណ្ឌកម្មដូចជាត្រូវទៅចូលរួមនៅក្នុងកំណែនមួយផ្សេងទៀត។ គេបានហាមមិនឱ្យធ្វើការនេសាទនៅក្នុងកន្លែងខ្លះ។ កាលណាមានភ្លៀង ប្រជាកសិករបានដាក់នេសាទូបករណ៍ នៅតាមប្រឡាយ។ ការដាក់នេសាទូបករណ៍នេះនៅតាមប្រឡាយទឹកត្រូវបានហាមឃាត់។ គេត្រូវជីកប្រឡាយ ដែលបន្តចេញមកពីព្រែកប្រជាក ហើយដែលបង្ហូរទឹកចូលទៅក្នុងស្រែយើង។ ឥឡូវនេះ មេឃុំគ្មានកម្លាំងទេ គាត់មិនចេះដឹកនាំ "កូនចៅ" របស់គាត់ទេ[៩៤]។ មនុស្សទាំងអស់ពុំខ្លាចមេឃុំទាល់តែសោះ។ ប្រឡាយទឹកពុំអាចប្រើប្រាស់បានទេ ពីព្រោះពុំមាននរណាម្នាក់មាន ឥទ្ធិពលដើម្បីនិយាយទៅកាន់អ្នកភូមិឱ្យធ្វើការជួសជុលប្រឡាយនោះឡើយ។ មេឃុំមិននៅជិតជាមួយប្រជាពលរដ្ឋដូចកាលពីមុនឡើយ។ កាលពីមុនជំទប់បានហៅប្រជាពលរដ្ឋទៅប្រជុំដោយវាយជួងត្រដោក។ គេត្រូវតែទៅប្រជុំ។ កាលណាជនណាម្នាក់ពុំបានទៅប្រជុំ គេសាកសួរអំពីមូលហេតុដែលមិនបានចូលរួមការប្រជុំ។ កាលណាមានចោរលួចគោ គេបានកោះហៅអ្នកភូមិធ្វើការប្រជុំជាប្រញាប់។ ជនណាដែលពុំបានមកប្រជុំត្រូវបានគេសង្ស័យថាគាត់ជាចោរ។

នៅជំនាន់នោះមានបញ្ហាតិចតួចណាស់ ពីព្រោះមនុស្សខ្លាចច្បាប់ និងខ្លាចទណ្ឌកម្ម។ ការជាប់ខ្នោះគឺជាការអាម៉ាស់ណាស់។ ខ្នោះត្រូវបានគេទុកនៅក្រោមផ្ទះជំទប់។ កាលពីខ្ញុំនៅតូច ខ្ញុំនឹកឃើញរឿងមួយ។ កម្លោះនិងក្រមុំពីរនាក់ចង់រៀបការជាមួយគ្នា។ ឪពុកម្តាយអ្នកទាំងពីរមិនចង់ឱ្យរៀបការជាមួយគ្នាទេ។ អ្នកទាំងពីរបានលួចរត់ចេញពីជួរ ហើយបានដេកនៅជាមួយគ្នា។ ឪពុកម្តាយបានរកឃើញអ្នកទាំងពីរ ហើយបានស្នើសុំឱ្យជំទប់ដាក់ខ្នោះអ្នកទាំងពីរ។ អ្នកទាំងពីរពុំមាន

---

94 . កូនចៅ: ពាក្យនៅក្នុងគ្រួសារ ដែលសំដៅអ្នកនៅក្រោមការគ្រប់គ្រង។ មេភូមិមានឋានៈ ជាជីតា

អ្វីបរិភោគទេ ហើយឪពុកម្តាយបានវាយអ្នកទាំងពីរទៀត។ ឪពុកម្តាយបានស្នើឱ្យជំទប់វាយអ្នកទាំងពីរដែរ តែគាត់មិនព្រម។ ទោះបីករណីបែបនេះត្រូវគេស្អប់យ៉ាងខ្លាំងក៏ដោយ ករណីផិតក្បត់ស្វាមីឬភរិយាដែលគេបានដាក់ទោសមានចំនួនតិចតួចទេ។ ជនគ្រប់រូបបានរក្សាការសម្ងាត់។ សេនាជនជើងខ្មៅ (ទាហានជើងខ្មៅ) បានដាក់ខ្នោះចោរ"។

(លោក ប៉ែត អាយុ៧១ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

វិធីរម្ងាប់ជម្លោះឱ្យបានឆាប់រហ័សដើម្បីរក្សាច្បាប់និងទម្លាប់

"នៅពេលណាមានជនណាម្នាក់បានប្រព្រឹត្តកំហុស ជំទប់មានភារកិច្ចធ្វើការអប់រំជនទាំងនោះ។ ឧទាហរណ៍ គាត់បាននិយាយថា គេមិនត្រូវធ្វើការលះលែងគ្នាទេ គេត្រូវគិតទៅដល់កូន គេត្រូវចេះអត់ទ្រាំ គេត្រូវសន្យាថាមិនបង្កើតឱ្យមានការឈ្លោះគ្នាទៀតទេ។ មានម្តងនោះ ឪពុកខ្ញុំបានទទួលបន្ទុកអប់រំមនុស្សប្រុស ម្នាក់ដែលបានវាយប្រពន្ធរបស់ខ្លួន។ ឪពុកខ្ញុំបានវាយក្បាលជននោះវិញរហូតដល់ចេញឈាមដើម្បីកុំឱ្យជននោះ ប្រព្រឹត្តអំពើវាយប្រពន្ធរបស់ខ្លួនឯងជាថ្មីទៀត។ នៅពេលមានទំនាស់ ឪពុកខ្ញុំបានធ្វើការសំរុះសំរួល ហើយបានធ្វើការស្តីប្រដៅអ្នកទាំងពីរ។ គាត់បាននិយាយទៅកាន់អ្នកទាំងពីរថា ប្រសិនបើអ្នកទាំងពីរបន្តបង្កើតបញ្ហាទៀត អ្នកទាំងពីរនឹងត្រូវដាក់ខ្នោះ។ ជាគោលការណ៍ ជនទាំងអស់បានប្រកាន់អាកប្បកិរិយាស្ញៀមស្ងាត់នៅក្រោយពេលសំរុះសំរួល។ មានករណីតិចតួចណាស់ដែលគេដាក់ខ្នោះមនុស្ស គឺគេគ្រាន់តែធ្វើឱ្យមនុស្សខ្លាចតែប៉ុណ្ណោះ។ ចំពោះជនណាដែលត្រូវដាក់ខ្នោះគឺជាការអាម៉ាស់ណាស់។ ជនទាំងនោះត្រូវគេលែងរាប់អាននៅក្នុងភូមិ។ គឺជាការខ្មាស់អៀនណាស់។ ជនទាំងឡាយណាដែលបានប្រព្រឹត្តកំហុសទាំងនោះ គឺជាជនចំឡែក។ គ្មាននរណាទៅជិតអ្នកទាំងនោះឡើយ។ គេពុំចូលចិត្តជនទាំងនោះឡើយ"។

(លោក ប៉ែត អាយុ ៧១ ឆ្នាំ ឃុំនរធំស្រុកសៀមរាបខេត្តសៀមរាប)

"នៅក្នុងទសវត្ស៥០ មនុស្សដែលគេគោរពបំផុតគឺជំទប់។ ជំទប់គឺជាអនុប្រធានទី១របស់មេឃុំ។ គាត់ ឈ្មោះតាដុំ ហើយទទួលបន្ទុកឃុំស្រះស្រង់ខាងជើង ស្រះស្រង់ខាងត្បូង រហាល និងក្រវ៉ាន់។ តាសែមគឺជាមេឃុំ ហើយគាត់រស់នៅឯអំពិល។

ជំទប់ត្រូវបានជ្រើសតាំងដោយអ្នកភូមិ។ មេឃុំជាអ្នករៀបចំការបោះឆ្នោត។ គាត់បានជ្រើសរើសមនុស្សពីរនាក់ហើយបានស្នើឱ្យជនទាំងពីររូបនោះបែរមុខទៅជញ្ជាំង។

អ្នកភូមិត្រូវដាក់គ្រាប់សណ្តែកនៅក្នុង កែវសំរាប់បេក្ខជនណាដែលគាត់ត្រូវជ្រើសរើស។ ជនណាដែលបានទទួលគ្រាប់សណ្តែកច្រើនត្រូវបានជ្រើសតាំង ជាជំទប់ទីមួយ។

កាលណាមានបញ្ហាអ្វីមួយបានកើតឡើង គេចូលចិត្តដោះស្រាយបញ្ហានោះនៅក៏រិតថ្នាក់ជំទប់។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរនៅក្នុងភូមិ អ្នកភូមិបានចាប់អ្នកប្រព្រឹត្តបទល្មើស ហើយយកជននោះទៅដាក់ខ្នោះអស់រយៈពេលជាច្រើនម៉ោង។ គឺជាការខ្មាស់អៀនណាស់ដែលត្រូវគេដាក់ខ្នោះនៅចំពោះមុខមនុស្សទាំងអស់គ្នាដូច្នេះ។
ចំណែកឯជនណាម្នាក់ដែលបានវាយអ្នកដ៏ទៃ ជននោះនឹងត្រូវបានគេដាក់ខ្នោះអស់រយៈពេលមួយម៉ោងឬ ពីរម៉ោង។

គេពុំបានផ្តល់លុយកាក់ឱ្យអាជ្ញាធរមូលដ្ឋានទេនៅសម័យនោះ ពីព្រោះគេពុំមានលុយកាក់ទេ។ គេឱ្យអង្ករឬមាន់។

គេបានធ្វើការទាក់ទងថ្នាក់ស្រុកនៅពេលណាមានបញ្ហាធ្ងន់ធ្ងរបំផុតដូចជាអំពើឃាតកម្ម។ គេត្រូវតែរកនគរបាលស្រុក(...)។ នៅថ្នាក់ភូមិ គេបានធ្វើការទាក់ទងជាមួយអ្នកចាស់ទុំក្នុងក៏រិតតិចតួចណាស់។ គេគោរពជំទប់ ហើយនេះជាការគ្រប់គ្រាន់ទៅហើយ។ តាជុំជាមនុស្សមានឥទ្ធិពល គាត់ពុំបានសួរមតិរបស់ចាស់ទុំទេ។ គាត់អាចធ្វើការសំរេចដោយខ្លួនឯង។ គាត់ពុំបានប្រើប្រាស់ចំណេះដឹងរបស់អ្នកចាស់ទុំទេ។ ការបង្កាទំនាស់មានលក្ខណៈងាយស្រួលណាស់។ គេបាននិយាយទៅកាន់ជនគ្រប់រូបថា: "ប្រសិនបើអ្នកប្រព្រឹត្តអំពើអាក្រក់ អ្នកនឹងត្រូវគេដាក់ខ្នោះ។ មនុស្សទាំងអស់គេនឹងមើល ហើយអ្នកឯងពិតជាខ្មាស់គេ។ តាមពិតការដាក់ខ្នោះនេះបានកើតមានដោយកម្រណាស់ ប៉ុន្តែមនុស្សមានការភ័យខ្លាចណាស់។ តាជុំបានទទួចជាច្រើនដងអំពីការអប់រំកុមារ។ គាត់បាននិយាយថា ការអប់រំដ៏ល្អមួយអាចបញ្ចៀសកុមារពីការប្រព្រឹត្តិកំហុស។ ការអប់រំដ៏ល្អគឺជាការបង្រៀនកុមារឱ្យ យល់ដឹងអំពីអ្វីដែលមិនត្រូវប្រព្រឹត្ត"។ (លោក វ៉ែត អាយុ ៥៧ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## ការភ័យខ្លាចការសងសឹក

ការសំឡុតដែលអាជ្ញាធរបានធ្វើទៅលើប្រជាពលរដ្ឋកើតមានញឹកញាប់ណាស់។ អំពើនេះកើតមានដែររវាងប្រជាពលរដ្ឋគ្នាឯង។ នៅពេលមានទំនាស់ជាមួយមនុស្សដែលមានបុណ្យសក្តិខ្ពស់ឬមានទ្រព្យសម្បត្តិច្រើន គេមានការភ័យខ្លាចពីប្រតិកម្មយ៉ាងខ្លាំងពីជនទាំងនោះ ហើយជារឿយៗគេច្រើនតែបោះបង់រឿងនោះចោល។

ដូចនេះគេអាចបង្ហាញពីកំលាំងរបស់ខ្លួនដើម្បីធ្វើការគាបសង្កត់ទៅលើជនណាម្នាក់។ គោលការណ៍នៃការប្រើកំលាំងហាក់ដូចជាត្រូវបានគេទទួលយក។ គេបានបង្ហាញអំពីបង្អែក(អ្នកគាំទ្រ) ជូនកាលជាមន្ត្រីមាន

ឋានន្តរសក្តិ ជួនកាលជាអ្នកមាន ឬជាមនុស្សមានឥទ្ធិពល។ គោលបំណង គឺធ្វើការសំឡុតភាគីម្ខាងទៀត ដើម្បី បំបិទរឿង ដើម្បីចោទគេថាជាអ្នកមានទោសឬជាអ្នករងគ្រោះ។

"កាលណាគេត្រូវការមនុស្សខ្លាំងម្នាក់ គេនាំគ្នាទៅរកលោក សាខន។ គាត់ជាអ្នកពូកែខាងប្រើកាំបិត។ កាលណាគេចាញ់ល្បែងឬចាញ់ក្នុងការដោះស្រាយទំនាស់ គេតែងនាំគ្នាទៅរកលោក សាខន ដើម្បីធ្វើឱ្យអ្នកដ៏ទៃទៀតខ្លាច ហើយជួនកាលគេអាចសំឡុតយកប្រាក់កាសឬដីបានមកវិញ។ ជនទាំងអស់នោះបានស្តាប់តាមលោក សាខន។ គេទាំងអស់គ្នាមានការភ័យខ្លាចគាត់"។
(លោក រឿង អាយុ ៤៥ឆ្នាំ គ្រូបង្រៀនឃុំចេកស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"ប្រជាជនគោរពកោតខ្លាចអាជ្ញាធរ។ មានការផាកពិន័យចំពោះបញ្ហាតូចតាច និងដាក់ខ្នោះចំពោះអ្នកកាចសាហាវ។ ពួកក្មេងៗច្រើនប្រើកាំបិតនៅពេលមានការវាយតប់គ្នា ប៉ុន្តែក៏មានបទបញ្ជាដែរ។ កាលពីមុនមិនដូចសព្វថ្ងៃនេះទេដែលមនុស្សមិនគោរពអ្វីទាំងអស់។ កាលពីមុន កាលណាគេមានបញ្ហាអ្វីមួយជាមួយជនណាម្នាក់ គេបានទៅរកមិត្តភក្តិម្នាក់ទៀតដែលមានការស្ទាត់ជំនាញក្នុងការប្រើកាំបិតកែ។ មិត្តម្នាក់នោះបានជួយយើងក្នុងការធ្វើឱ្យអ្នកម្នាក់ទៀតមានការភ័យខ្លាច។ ជនណាដែលចេះប្រើកាំបិតគឺមានឥទ្ធិពលណាស់។ ជាការល្អណាស់ ដែលយើងត្រូវតែស្គាល់អ្នកចេះប្រើកាំបិតម្នាក់។ ក្រុមគ្រួសារឬក្រុមជាខ្សែរយៈ តែងបានសាកល្បងដើម្បីធ្វើការអូសទាញអ្នកជំនាញប្រើកាំបិតម្នាក់ឱ្យបានមកនៅខាងបក្សពួករបស់ខ្លួន។ គឺជាការមានប្រយោជន៍ជានិច្ច ដើម្បីធ្វើឱ្យពួកចោរដែលមកពីខាងក្រៅមានការភ័យខ្លាច។ ជួនកាលនៅក្នុងភូមិមានក្រុមជាច្រើនបានប៉ះទង្គិចគ្នា។ ដើម្បីជៀសវាងការចូលវាយទាំងអស់គ្នា មេបក្សបានបញ្ជូនមនុស្សម្នាក់ក្នុងមួយក្រុមដែលជាតំណាង ហើយឱ្យអ្នកតំណាងទាំងនោះវាយគ្នា។ ប្រសិនបើមានបញ្ហានៅក្នុងក្រុម គេបានធ្វើការសំរុះសំរួល ប៉ុន្តែប្រសិនបើជាបញ្ហាជាមួយអ្នកមកពីខាងក្រៅ គេបានធ្វើការគំរាមគំហែងគេបានបង្ហាញកំលាំង។ សព្វថ្ងៃនេះ លែងមានអ្នកជំនាញខាងប្រើកាំបិតទៀតហើយ។ កាលណាគេមានបញ្ហាជាមួយជនណាម្នាក់ គេទៅរកនគរបាល"។
(លោក ខៅ អាយុ ៤៦ ឆ្នាំ មេភូមិឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

ចាស់ទុំម្នាក់មានការសោកស្តាយពេលវេលាដែលគាត់អាចប្រើកំលាំងគួបផ្សំ និងពាក្យសម្តី ដើម្បីធ្វើឱ្យគេគោរពគាត់ និងរក្សាភាពស្ងប់ស្ងាត់។

"កាលពីមុន ក្មេងៗខ្លាចចាស់ទុំណាស់។ នៅសម័យនោះគេក៏ផឹកស្រាដែរ តែគេមិនឱ្យចាស់ទុំឃើញទេ បើពុំដូច្នោះទេគាត់នឹងជេរស្តីជាពុំខាន។ "បើឯងផឹកស្រាស្រវឹង អញវាយឯង"។ កាលណាចាស់ទុំវាយពួកយើង យើងនាំគ្នារត់ទៅពួន។ កាលណាក្មេងៗជួបជុំគ្នា គេខ្លាចចាស់ទុំ។ គាត់មាន

ការសង្ស័យជានិច្ចថា ពួកក្មេងៗបានរៀបចំផែនការអ្វីមួយមិនល្អ។ គាត់ទៅជួបឪពុកម្តាយរបស់យើង ហើយស្តីប្រដៅអំពីការអប់រំរបស់កូន។ ឪពុកម្តាយមិនសប្បាយចិត្តទេ។ គាត់មានការខ្មាស់អៀន។ សព្វថ្ងៃនេះ ពួកក្មេងៗពុំស្តាប់ចាស់ទុំសោះ ហើយថែមទាំងសើចចំអកទៀតផង។ ប្រសិនបើគេវាយក្មេង គេនឹងត្រូវផ្តន្ទាទោសតាមច្បាប់។ ឪពុកម្តាយនឹងប្តឹងមេឃុំ។ ខ្ញុំពុំចង់និយាយអ្វីទាល់តែសោះ។ ពួកក្មេងៗមិនជៀសផ្លូវយើងទេ។ គឺជាកំហុសនៃសង្គ្រាមនិងការវិវឌ្ឍន៍បច្ចុប្បន្ននេះ។ កាលពីដើមគេបាននិយាយថា "ឯងទៅដេកទៅ ឯងស្រវឹងហើយ" ឥឡូវនេះគេនិយាយថា មនុស្សមានសិទ្ធិ...! គេបាននិយាយថា មនុស្សមានសិទ្ធិស្មើៗគ្នា គឺចាស់ទុំមានសិទ្ធិស្មើនឹងយុវជនដែរ! "។

(លោកពឿន អាយុ៦៨ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

## ការភ័យខ្លាចវត្ថុសក្តិសិទ្ធិ

ការភ័យខ្លាចការដាក់ទណ្ឌកម្មបែបអរូបីមានសភាពខ្លាំងក្លាណាស់។ ការប្រព្រឹត្តិអំពើអាក្រក់អាចគេចផុតពីភ្នែករបស់អាជ្ញាធរមូលដ្ឋាន តែពុំអាចគេចផុតពីភ្នែករបស់អាទិទេពរបស់ប្រជាពលរដ្ឋបានឡើយ ដូចជាអ្នកតា មេបា ឬខ្មោច។

ទ្រឹស្តីកម្មផលដែលមកផ្សព្វផ្សាយដោយព្រះពុទ្ធសាសនា មានតួនាទីយ៉ាងសំខាន់ក្នុងការបង្កាទំនាស់។ ការបង្កើតបញ្ហា ឬការប្រកាន់យកអាកប្បកិរិយាអាក្រក់មួយ អាចនាំឱ្យខ្លួនឯងមានកង្វល់នៅជាតិក្រោយទៀត។ គេបានខិតខំដើម្បីបញ្ចៀសបញ្ហាគ្រប់បែបយ៉ាង ហើយគេបានអត់ទ្រាំនឹងភ័ព្វព្រេងវាសនារបស់គេ។

ថ្វីបើតួនាទីរបស់ព្រះសង្ឃនៅក្នុងការសំរុះសំរួលទំនាស់របស់អ្នកភូមិមានបន្តិចបន្តួច តែការអប់រំដែលព្រះសង្ឃបានបង្រៀននៅតាមវត្តអារាមធ្វើឱ្យព្រះសង្ឃមានឋានៈទីមួយក្នុងការអប់រំដើម្បីបង្កាទំនាស់។ នៅពេលមានពិធីធំៗនៅតាមវត្តអារាមដែលមានការរួមប្រជុំមនុស្សជាច្រើន ព្រះសង្ឃបានទេសនាពីធម៌នានាហើយបាន រំឭកគ្រហស្ថអំពីគោលការណ៍ព្រះពុទ្ធសាសនាជាមូលដ្ឋាននិងផលកម្មនៃអំពើទាំងនោះ។

"នៅថ្ងៃសីល ព្រះសង្ឃបានទេសនាដើម្បីបង្រៀនពុទ្ធសាសនិកអំពីគោលការណ៍ព្រះពុទ្ធសាសនា។ ព្រះសង្ឃមានពុទ្ធដីកាថា: "ចូរអ្នកគិតគូរអំពីលទ្ធផលនៃអំពើរបស់អ្នកគឺ កម្មផល" និងបានរៀបរាប់អំពីគោលការណ៍ព្រះពុទ្ធសាសនាស្តីអំពីការហាមឃាត់នានា។ ដូចនេះ ព្រះសង្ឃបានពន្យល់គ្រហស្ថអំពីទោសដែលគ្រហស្ថ បានលួចទៅមានប្រពន្ធចុងនិងទៅសេពកាមជាមួយស្រីពេស្យា"។

(លោក សាន អាយុ ៧០ឆ្នាំក្រុងស្វាយរៀង ខេត្តស្វាយរៀង)

គេក៏មានការភ័យខ្លាចដែរអំពីបណ្តាសាររបស់អាទិទេពដែលប្រជាជននិយម(ជំងឺអពមង្គលមិនចេះចប់)។ មានអ្នកតាជាច្រើននៅតាមភូមិនីមួយៗ នៅតាមវត្តអារាម និងនៅតុលាការនីមួយៗ។ នៅពេលមានទំនាស់កើតឡើងជារឿយៗគេតែងតែឱ្យអ្នកតាជាអ្នកអារកាត់។ ដូចនេះនៅឯតុលាការ មុនបើកសវនាការគូភាគីទាំងពីរដែលមានទំនាស់បានស្បថថានឹងនិយាយការពិតនៅចំពោះមុខទេវតា ហើយក្រឡាបញ្ជីជាអ្នកអានពាក្យស្បថទាំងនោះ។

"នៅក្រសួងយុត្តិធម៌ គេក៏បានឃើញរូបសំណាកទេវតាពីរ។ ទេវតាមួយរាងកាច មួយទៀតល្អ។ នៅក្នុងទសវត្សឆ្នាំ៦០ គឺមានសាលាវិនិច្ឆ័យ។ មុននឹងចូលក្នុងបន្ទប់សវនាការ ភាគីទាំងពីរដែលមានទំនាស់ត្រូវតែស្បថថាការនិយាយការពិតនៅចំពោះមុខទេវតា។ សកម្មភាពនេះមានចែងនៅក្នុងនិតិវិធីតុលាការ។ ក្រឡាបញ្ជីបានអានពាក្យសម្បថ ហើយភាគីទាំងពីរថាតាម"។
(លោក ស្រី សូលីណា អាយុ ៤០ ឆ្នាំ ចៅក្រមក្រុងភ្នំពេញ)

"គេមានការភ័យខ្លាចចំពោះអ្នកតាណាស់។ កាលណាមនុស្សទាំងពីរនាក់មានទំនាស់នឹងគ្នា គេបាននាំគ្នាទៅស្បថនៅចំពោះមុខអ្នកតាស្រី។ ជនណាដែលបានភូតកុហកត្រូវបានទទួលការដាក់ទោស ហើយបានធ្លាក់ខ្លួនឈឺ។ នៅសាលាដំបូងក៏មានអ្នកតាដែរ គឺឈ្មោះអ្នកតាក្របាមក។ អ្នកតានោះពូកែណាស់។ សព្វថ្ងៃនេះ គេមិនសូវជឿទេ ហើយអ្នកតានេះក៏មិនសូវពូកែដែរ"។
(លោកសាន អាយុ ៧០ ឆ្នាំក្រុងស្វាយរៀង ខេត្តស្វាយរៀង)

ការភ័យខ្លាចអំណាចរបស់មេបាមកលើកូនចៅ ឬ ខ្មោចក៏មានខ្លាំងក្លាណាស់ដែរ។

"មេបា គឺជាបុព្វបុរស។ មេបាបានដាក់ទោសជនទាំងឡាយណាដែលបានប្រព្រឹត្តកំហុស។ គាត់ធ្វើឱ្យមានជំងឺឬអពមង្គលដល់អ្នកធ្វើខុស។ ជួនកាលធ្លាក់ទៅលើអ្នកម្នាក់ផ្សេងទៀតដូចជាកូន ប៉ុន្តែគេបានដឹងពីអ្នកណាដែលបានធ្វើកំហុស។ ឪពុកដែលបានធ្វើខុសអាចត្រូវបានដាក់ទោសដោយធ្វើឱ្យកូនមានជំងឺ។ កាលពីមុន មនុស្សបាននាំគ្នាទៅរកគ្រូទាយ (ហោរា)។ គ្រូទាយបានយកពងមាន់មកទាយដើម្បីឱ្យដឹងអំពីប្រភពជំងឺ។ កាលណាគេបានដឹងពីប្រភពជំងឺ គេធ្វើពិធីសែនជូនមេបា។ នៅទីនោះគឺជាវាលរាបនិងពុំមានគ្រូធ្មប់ទេ។ គ្រូធ្មប់មាននៅតំបន់ ភ្នំឬតំបន់ព្រៃដូចជាខេត្តសៀមរាប និង បាត់ដំបង"។
(លោក សារ៉ុន អាយុ ៦៧ ឆ្នាំឃុំនគរធំ ស្រុកសេមរាប ខេត្តសៀមរាប)

ផ្ទុយទៅវិញ កម្មត្រជាក់និងមិនអាចជៀសបាន គេអាចលុបលាងកំហុសប្រសិនបើគេធ្វើខុស ចំពោះអ្នកតា ឬមេបា។ អ្នកតា ឬមេបាឋិតជិតមនុស្ស។ អ្នកតា ឬមេបាបានទទួលសំណែនជាការលុបលាងកំហុសមាន : ភ្លេង សំណែន ស្លា ម្លូ បារី របាំ ការបន់ស្រន់។

"ជីដូន ជីតា មេបា អាចដាក់ទណ្ឌកម្មដល់មនុស្សនៅក្នុងគ្រួសាររបស់ខ្លួន។ កាលណាមានទំនាស់នៅក្នុងគ្រួសារ ខ្មោចអាចធ្វើឱ្យសមាជិកគ្រួសារឈឺ។ គេអាចរម្ងាប់ទំនាស់នោះដោយការសែនព្រេន"។

(លោក វ៉េត អាយុ ៥៧ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្ត សៀមរាប)

តាមការពិចារណារបស់អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ សង្គមមានលក្ខណៈជាប្រពៃណីបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធនៅជុំវិញព្រះមហាក្សត្រ(គឺសម្តេចព្រះសីហនុ)និងព្រះពុទ្ធសាសនា។ នៅពេលដែលព្រះមហាក្សត្រ និងព្រះពុទ្ធសាសនាត្រូវបានបដិសេធចោលនៅក្នុងទសវត្សឆ្នាំ៧០ សង្គមខ្មែរបានប្រែក្រឡាស់អស់។

"កាលពីមុន សង្គមស្អាតស្អំនិងមានភាពទំនើប។ ដើម្បីនិយាយពាក្យ "ស៊ី" គេបានប្រើពាក្យផ្សេងៗទៀតបាន។ នៅសម័យនោះ មនុស្សបានរស់នៅយ៉ាងល្អត្រឹមត្រូវគេគោរពមនុស្សចាស់។ គេពុំហ៊ានមើលងាយមនុស្សចាស់ទេ ដោយភ័យខ្លាចអំពើអកុសលដែលនាំឱ្យមានបាបកម្ម។ នៅពេលណាមានចាស់ៗអង្គុយ គេនាំគ្នាដើរអោនទៅពីខាងមុខគាត់។ សម្តេចព្រះសីហនុ បានដឹកនាំប្រទេសល្អណាស់។ មនុស្សទាំងអស់គោរពសាសនា។ គេធ្វើ អំពើល្អដើម្បីឱ្យបានទទួលលទ្ធផលល្អនៅជាតិក្រោយ។ មានចោរលួចតិចតួចណាស់។ នៅពេលអ្នកភូមិណាម្នាក់ ចង់រៀបចំពិធីអ្វីមួយឬកសាងគេហដ្ឋានមួយ អ្នកជិតខាងក៏មកជួយ។ គេមកទាំងអស់គ្នាដូចជាបងប្អូន។ អ្នកដឹកនាំគឺព្រះមហាក្សត្រសីហនុ។ សម្តេចព្រះនរោត្តមសីហនុ បានគោរពព្រះពុទ្ធសាសនាយ៉ាងល្អត្រឹមត្រូវ។ ប្រជាពលរដ្ឋបានគោរពព្រះមហាក្សត្រនរោត្តសីហនុនិងសាសនា។ កាលណាមានការឈ្លោះទាស់ទែងគ្នា គេបានស្វែងរកយុត្តិធម៌។ គឺពុំដូចជានៅក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ[៩៥] នោះទេដែលសម័យនោះគេបានសំលាប់ មនុស្សជាច្រើន។

នៅសម័យនោះពេលកើតមានបញ្ហាម្តងៗ គូជម្លោះទាំងពីរនាក់បាននាំគ្នាទៅផ្ទះមេភូមិ ហើយម្នាក់ៗបាននាំសាក្សីមួយនាក់ឬពីរនាក់ទៅជាមួយផង។ មេភូមិជាអាជ្ញាធរអាព្យាក្រឹត្យ។ មេភូមិបានសាកសួរកសិណសាក្សីណាដែលបានឃើញនឹងភ្នែក និងសួរដើម្បីស្តាប់ការពិត។ តើអ្នកណាធ្វើត្រូវ ហើយអ្នកណាធ្វើខុស ?

បញ្ហាទាំងនោះគឺៈ សត្វស៊ីដំណាំ កូនឈ្លោះគ្នាជាមួយកូនអ្នកជិតខាង គ្រួសារបែកបាក់គ្នាដោយរឿងដីធ្លី/សត្វគោបានធ្វើឱ្យខូចភ្លឺស្រែ។ នៅពេលណា សត្វស៊ីដំណាំហើយប្រសិនបើមានចំនួនតិច

---

[95] . គូសន្ទនាដែលជាអតីតខ្មែរក្រហម បាននិយាយអំពីរបប ប៉ុល ពត ពីខែមេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ១៩៧៩។

តូច មេភូមិបាននិយាយថា កុំនិយាយអ្វីតទៅទៀត គឺដោយអចេតនាទេ គឺមកពីខ្សែគោនោះវាដាច់។ ប្រសិនបើការខូចខាតមានចំនួនច្រើន មេភូមិស្តាប់ការតវ៉ារបស់ម្ចាស់ដី ហើយបានស្នើឱ្យម្ចាស់សត្វពាហនៈចេញប្រាក់សងការខូចខាត។ កាលណាមនុស្សពីរនាក់មានវិវាទរឿងព្រំដី មេភូមិបានទាញខ្សែរវាងដីទាំងពីរហើយបង្កើតព្រំដីត្រង់មួយ។

ច្បាប់ប្រពៃណីមានលក្ខណៈបែបនេះ។ គេមិនត្រូវឱ្យភាគីណាមួយខូចប្រយោជន៍ទេ។ ភាគីទាំងពីរត្រូវតែមានការពេញចិត្ត។ ប្រសិនបើគេពុំចង់ឱ្យការឈ្លោះគ្នាបន្តទៅវែងឆ្ងាយទៀតទេ គេត្រូវតែចែកជាពីរ ប្រសិនបើខាង "**ក**" ឈ្នះ ហើយខាង "**ខ**"ចាញ់ នោះបញ្ហានឹងបន្តទៅទៀត ប៉ុន្តែប្រសិនបើអាជ្ញាធរកាត់បញ្ហាជាពីរ គេក៏យល់ព្រម។

នៅសម័យនោះគេពុំមានបញ្ហាដីធ្លីច្រើនទេ ពីព្រោះមានដីសំរាប់រុករានច្រើនណាស់។

នៅសម័យនោះ មនុស្សគ្រប់រូបបានគោរពព្រះពុទ្ធសាសនា ហើយបានយល់អំពីសាមគ្គីភាព។ តាមក្បួនច្បាប់នៅក្នុងសាសនាព្រះពុទ្ធ កាលណាគេឈ្លោះទាស់ទែងគ្នា គេពុំមានសាមគ្គីភាពទេ ហើយគេនឹងស្លាប់។ មនុស្សម្នាក់ៗត្រូវចេះធ្វើការលះបង់ម្នាក់បន្តិចៗ ដើម្បីកុំឱ្យមានអ្នកចាញ់និងអ្នកឈ្នះ។

ប្រសិនបើគេបញ្ជូនរឿងទៅដល់តុលាការ ជនដែលមានទំនាស់ត្រូវធ្វើការស្បថនៅចំពោះមុខអ្នកតា។ គេរៀបរាប់អំពីរឿងរ៉ាវ និងធ្វើការស្បថៈ "ប្រសិនបើខ្ញុំភូតកុហក សូមអ្នកតាសំលាប់ខ្ញុំចុះ។ ប្រសិនបើខ្ញុំនិយាយការពិត សូមអ្នកតាជួយខ្ញុំឱ្យបាននៅរស់តទៅទៀត"។

នៅវត្តដងទង់មានអ្នកតាមួយអង្គមានឈ្មោះពូកែល្បីល្បាញគឺ "ព្រះអង្គដងទង់"។ នៅជំនាន់ខ្មែរក្រហម គេមានបំណងបំផ្លាញព្រះអង្គដងទង់ចោលដោយយកត្រាក់ទ័រមកឈូស តែរូបសំណាកអ្នកតានៅដដែល។ គឺមានតែអ្នកតាមួយនេះទេដែលគេពុំអាចកំទេចចោលបាន។ អ្នកតាព្រះអង្គដងទង់ពូកែណាស់។

កាលពីមុនមនុស្សគ្រប់រូបនាំគ្នាគោរពអ្នកតា។ គេមានការភ័យខ្លាចចំពោះអ្នកតា។ នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា យោធាម្នាក់បាននាំសង្សារទៅវត្ត។ ព្រះសង្ឃបានមានពុទ្ធដីកាហាមមិនឱ្យសង្សារស្រីមកដេកនៅក្នុងវត្តទេ។ យោធានោះពុំបានស្តាប់តាមព្រះសង្ឃមានពុទ្ធដីកាទេ ហើយបានដេកជាមួយសង្សារខ្លួន។ មួយថ្ងៃក្រោយមកយោធាម្នាក់នោះបានក្លាយទៅជាគរ។ គាត់បាននិយាយរៀបរាប់ឱ្យព្រះសង្ឃបានដឹងរឿងនេះ និងដើម្បីឱ្យព្រះសង្ឃជួយគាត់ក្នុងការសុំទោសអ្នកតា។ ព្រះសង្ឃពុំចង់ជួយយោធាម្នាក់នោះទេ តែព្រះសង្ឃមានពុទ្ធដីកាថាៈ "ដើម្បីអាច

និយាយបានវិញ ឯងត្រូវទៅសុំឱ្យឪពុកម្តាយឯងរៀបចំពិធីមួយដោយ មានការប្រគុំភ្លេងប្រពៃណី។ ត្រូវរៀបចំសំណែន៨តុដោយមានផ្កាឈូក ក្បាលជ្រូកមួយ មាន់មួយ សាច់ទាច្រើនចានជាមួយ និងទឹកត្រី បាយបួនចាន សម្លបួនចាន។ នៅពេលមានគ្រឿងសក្ការៈទាំងអស់នោះបានរៀបចំរួចស្រេច ហើយឯងនឹងអាចនិយាយបានវិញ។ ក្រោយមក យោធាម្នាក់នោះក៏និយាយបានវិញ។ ប្រជាពលរដ្ឋខ្មែរបានក្លាយទៅដូចជាសត្វនៅពេលស្រុកពុំមានស្តេច និងសាសនា (និយាយយោងទៅរបបខ្មែរក្រហម)។ សព្វថ្ងៃនេះ អ្វីៗបានត្រឡប់មកវិញអស់ហើយ ប៉ុន្តែនៅពុំសូវខ្លាំងដូចពីមុនទេ។ អ្វីៗបានផ្លាស់ប្តូរអស់ហើយ"។

(លោក ពូន អាយុ ៦០ ឆ្នាំមេភូមិ ( អតីតខ្មែរក្រហម ) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ( ភូមិទើបបង្កើតថ្មី )

## សំយោគជំពូក១ : មរតកពីអតីតកាលៈ

## ការដោះស្រាយទំនាស់មូលដ្ឋាន : សម័យមុនឆ្នាំ ១៩៧០

*សម័យសង្គមចាស់គឺសម័យមុនឆ្នាំ១៩៧០ ជាកាលបរិច្ឆេទដែលប្រទេសបានប្រែក្រលាស់ធ្លាក់ទៅក្នុងភ្លក់ភ្លើងសង្គ្រាម។ ការចងចាំរបស់អ្នកភូមិមានដោយកម្រណាស់នៅក្នុងសម័យទសវត្សឆ្នាំ៥០ ដែលជាអនុស្សាវរីយ៍នៃការរស់នៅដ៏សុខសាន្ត។*

*នៅក្នុងសង្គមមួយដែលបានកកើតឡើងតាំងពីច្រើនសតវត្សកន្លងមកតាមការរស់នៅបែបដាច់ៗពីគ្នានិងឯករាជភាពរៀងៗខ្លួន គ្រួសារនីមួយៗបានយល់ដឹងអំពីការគ្រប់គ្រងតាមគំរូបែបគ្រួសារ ដែលមានតែមាតាបិតា និងកូន។ លោក Jean Delvert[៩៦] បានសរសេរថា រដ្ឋបាលបារាំងបានសាកល្បងបង្កើតរចនាសម្ព័ន្ធសង្គមមួយ ដែលមានលក្ខណៈទូលាយ "មហាជនកសិករមួយដែលពុំមានរបៀប" ដោយបង្កើតក្របខ័ណ្ឌសិប្បនិម្មិតមួយគឺៈ ឃុំ និង ស្រុក។*

*ជារៀងរាល់ថ្ងៃ គ្រួសារទាំងឡាយមានការប្រុងប្រយ័ត្នជានិច្ច ដោយពុំធ្វើឱ្យរំខានដល់របៀបរបបក្រៅផ្លូវការដែលខ្លួនខ្មាតសំខាន់គឺត្រូវប្រុងប្រយ័ត្នដើម្បីថែរក្សាសភាពដែលគួរឱ្យទុកចិត្ត។ ការកត់សំគាល់ខុសខ្លះៗ ដែលគេបានទឹកឃើញគឺមានការឈ្លោះទាស់ទែងក្នុងគ្រួសារខ្លះៗ និងជាមួយអ្នកជិតខាងព្រមទាំងទំនាស់ដីធ្លី។*

*ក្នុងករណីមានបញ្ហានៅក្នុងគ្រួសារឬជាមួយអ្នកជិតខាង កង្វល់ទីមួយគឺការខិតខំទប់មនោសញ្ចេតនាដោយ ខ្លាចកុំឱ្យសភាពការណ៍មានសភាពធ្ងន់ធ្ងរថែមទៀតៈ ការភ័យខ្លាចមានការសងសឹក ភាពច្រណែននិន្ទា ឬ សេចក្តីលោភរបស់មន្ត្រីរាជការ និងការខ្លាចក្រែងការរំខានសណ្តាប់ធ្នាប់សង្គម និងខ្លាចវត្ថុសក្តិសិទ្ធិផ្តន្ទាទោសចំពោះអំពើណាដែលឃ្លាតចាកពីទម្លាប់សង្គម។*

*នៅក្នុងពេលមានទំនាស់ ប្រសិនបើចាំបាច់គ្រួសារនិងអ្នកជិតខាងត្រូវបានគេស្នើសុំឱ្យជួយផ្តល់គំនិត។ គេក៏បានផ្តល់ឱវាទជាច្រើនដើម្បីបន្ធូរបន្ថយសភាពការណ៍។*

*ជនដែលគេទទួលស្គាល់ដោយសារអំណាច ឬដោយសារចំណេះដឹងរបស់គាត់បានសាកល្បងធ្វើការសំរុះសំរួលរវាងភាគីមានទំនាស់ដោយខិតខំស្វែងរកដំណោះស្រាយដែលភាគីទាំងអស់អាចទទួលយកបាន ឬមួយក៏ បង្គាប់ឱ្យគោរពតាមសេចក្តីសំរេចរបស់ខ្លួនតែម្តង។ គេបានគោរពតាមពាក្យសំដីរបស់មនុស្ស*

---

[96] . Devert Jeam កសិករខ្មែរ (Harmattan) បោះពុម្ពឡើងវិញនៅឆ្នាំ ១៩៩៤

ចាស់ ។ ចំណេះដឹងផ្នែកសីលធម៌និងផ្នែកសាសនារបស់មនុស្សចាស់ដែលបានមកពីការរៀនសូត្រនៅតាមវត្តអារាម ហើយនិងការចងចាំរបស់គាត់អំពីកិច្ចការនៅក្នុងភូមិ ( អាត្រានុកូលដ្ឋាន សុរិយោដី របៀបចែកមរតក...) ត្រូវបានគេសាកសួរគាត់ ជារឿយៗ ។

ក្នុងករណីណាដែលត្រូវបានចាត់ទុកថា មានលក្ខណៈធ្ងន់ធ្ងរបំផុត ឬដោយគ្រាន់តែថា គាត់បានរស់នៅជិតគ្នានោះ គេក៏រត់ទៅរកមេភូមិដែរ ។ ពាក្យសំដីរបស់មេភូមិត្រូវបានគេគោរពនិងកោតខ្លាច ពីព្រោះមេភូមិជាដំណាងរដ្ឋបាលនៅក្នុងមូលដ្ឋាន ។

ការភ័យខ្លាចមានការសងសឹកពីសំណាក់ផ្នែករាជការ ពីមនុស្សមានអំណាច និងពីអាទិទេពពុំបានជំរុញឱ្យមានការបង្កបញ្ហា និងការរំខានដល់សណ្តាប់ធ្នាប់ឡើយ ។

សរុបមកឃើញថា បើនិយាយឱ្យចំគឺការអនុវត្តន៍តាមបែបប្រពៃណីនៃការដោះស្រាយនិងការបង្កាទំនាស់ពុំបានរៀបចំ និងចងក្រងជាក្រមឱ្យបានត្រឹមត្រូវទេ ។ អ្នកសំរុះសំរួលបានធ្វើការដោយយោងទៅលើបទពិសោធន៍របស់ខ្លួនផ្ទាល់ បុគ្គលិកលក្ខណៈ និងចំណេះដឹងរបស់ខ្លួន ។ ការធ្វើឱ្យមានការព្រមព្រៀងមូលមតិគ្នាជារឿយៗគឺជា អាទិទេពខ្ពស់ជាងគំនិតរកយុត្តិធម៌ដោយមានអ្នកចាញ់ និង អ្នកឈ្នះ ។

## ២. ការឈានចូលភាពអន្ធការៈ ១៩៧០-១៩៧៥

ថ្ងៃទី ១៨ ខែមិនា ឆ្នាំ១៩៧០ ព្រះអង្គម្ចាស់ សិរិមតៈ និងលោកឧត្តមសេនីយ លន់ នល់ បានធ្វើរដ្ឋប្រហារទំលាក់សម្តេចសីហនុ ហើយបានបង្កើតសាធារណរដ្ឋខ្មែរ។ គឺក្នុងកាលបរិច្ឆេទនេះ ព្រះរាជាណាចក្រកម្ពុជាប្រកបដោយសុខសន្តិភាពបានធ្លាក់ទៅក្នុងភាពចលាចល។ សង្គ្រាមនៅប្រទេសវៀតណាមបានរីករាលដាលចូលដល់ប្រទេសកម្ពុជា។ ការទំលាក់គ្រាប់បែកររបស់អាមេរិកកាន់តែមានសភាពខ្លាំងក្លាឡើងៗ និងធ្វើឱ្យភូមិទាំងអស់ត្រូវខ្ទាត់ខ្ទាយ[៩៧]។ កងទ័ពកុម្មុយនីស្តយៀកកុងបានចូលជ្រៅទៅក្នុងប្រទេស និងបានវាយប្រហារទៅលើកងទ័ពដែលមាននិន្នាការទៅរកអាមេរិករបស់លោក លន់ នល់។ កងទ័ពយៀកកុងចូលជាមួយអ្នកតស៊ូនៅក្នុងព្រៃ ដែលគេបានឱ្យឈ្មោះថា ខ្មែររំដោះ[៩៨]។ ទ័ពខ្មែររំដោះត្រូវបានគេស្គាល់ថា ជាកងទ័ពដែលបានប្រយុទ្ធនៅក្រោមផ្លាករបស់សម្តេច សីហនុ ដើម្បីរំដោះប្រទេសជាតិ។ ក្រោយពីពួកយៀកកុងបានដកចេញពីកម្ពុជានៅក្នុងឆ្នាំ ១៩៧២ ពួកខ្មែររំដោះបានរួមបញ្ចូលគ្នាជាមួយពួកខ្មែរក្រហមជាកងទ័ពតែមួយ។

ប្រជាកសិករ អ្នកជំនួញ អ្នកនេសាទ មន្ត្រីរាជការ...នៃព្រះរាជាណាចក្រដ៏តូចនេះ បានធ្លាក់ចូលទៅក្នុងទំនាស់ប្រដាប់អាវុធដែលមានលក្ខណៈហួសពីសមត្ថភាពរបស់ខ្លួនទាំងស្រុង ហើយដែលពួកគេបានក្លាយទៅជាតុក្កតាសំរាប់ការសំលាប់គ្នាទៅវិញទៅមកនៅក្នុងបរិបទនៃសង្គ្រាមត្រជាក់នៅក្នុងតំបន់។

យុវជនបាននាំគ្នាចូលធ្វើយុទ្ធជនជាមួយអ្នកមាននិន្នាការទៅខាងអាមេរិកនិងពួកកុម្មុយនីស្ត។ និស្សិតនៅតាមទីក្រុងបានចេញពីសកលវិទ្យាល័យនិងសាលានានា ដើម្បីស្លៀកពាក់ខោអាវទាហានរបស់កងទ័ពលោក លន់ នល់។ នៅតាមស្រុកស្រែចំការយុវកសិករត្រូវបានបំពាក់អាវុធ ហើយត្រូវបានបញ្ជូនឱ្យទៅច្បាំងជាមួយកងទ័ពរបស់ពួកសាធារណរដ្ឋ។

ចាប់តាំងពីការនិរទេសខ្លួនទៅទីក្រុងប៉េកាំងនៅថ្ងៃទី ២៤ ខែមិនា ឆ្នាំ១៩៧០ មក សម្តេចសីហនុ បានប្រកាសតាមវិទ្យុសុំឱ្យប្រជាជនចូលរួមក្នុងចលនាតស៊ូប្រដាប់អាវុធ។ អ្នកស្រុកស្រែចំការទាំងឡាយបានបះបោរទៅចូលខាងចលនាតស៊ូយ៉ាងឆាប់រហ័សបំផុត ដោយសារជំនឿនយោបាយ ដោយសារកំហឹងប្រឆាំងនឹងអ្នកទំលាក់គ្រាប់បែក[៩៩]

---

97 . នៅចន្លោះឆ្នាំ ១៩៦១ និង ១៩៧៥ យន្តហោះអាមេរិក បានទម្លាក់គ្រាប់បែកចំនួន ៥៣៧.០០០ តោននៅលើប្រទេសកម្ពុជាច្រើនជាងក្នុងពេលសង្គ្រាម លោកលើកទីពីរនៅទ្វីបអឺរ៉ុប។

98 . ខ្មែររំដោះ : គឺខ្មែរដែលបានប្រយុទ្ធដើម្បីរំដោះប្រទេសពីលោកលន់ នល់។

99 . ទាហានលោកលន់ នល់ ដែលពួកអាមេរិកបានជួយកងកម្លាំងទ័ពអាមេរិក ដែលមានមូលដ្ឋាននៅ វៀតណាមខាងត្បូង។

ឬនិយាយដោយងាយពីព្រោះពួកគេឋិតនៅក្នុងតំបន់ដែលកាន់កាប់ដោយពួក ទ័ពព្រៃ។ នៅចុងឆ្នាំ ១៩៧២ ចលនាតស៊ូបានត្រួតត្រាប្រទេសបានចំនួនបីភាគបួន[១០០] ។

នៅក្នុងតំបន់នានាដែលបានសំរេចបុព្វហេតុរបស់ខ្លួន ហើយពួកទ័ពព្រៃបានបង្កើតនិងដាក់ឱ្យអនុវត្តរចនាសម្ព័ន្ធថ្មីមួយជាបណ្តើរៗនៅចន្លោះឆ្នាំ១៩៧០-១៩៧៥។ ដោយសារការនាំយកគំនិតថ្មីៗចូលមកតាមលំនាំបដិវត្តន៍វប្បធម៌នៅប្រទេសចិន ឬដោយសារការឋិតនៅក្រោមអ្នកដឹកនាំថ្មីៗរបស់ខ្លួន ប្រជាកសិករបានមើលឃើញបន្តិចម្តងៗពីជីវភាពប្រចាំថ្ងៃរបស់ខ្លួន ដែលមានការវិវឌ្ឍន៍ឆ្ពោះទៅរកប្រព័ន្ធមួយដែលមានការបង្ខិតបង្ខំកាន់តែខ្លាំងឡើងៗ និងមានលក្ខណៈជាសហគមន៍។ សក្ខីកម្មមានការប្រែប្រួលអាស្រ័យដោយទីកន្លែង និងទិន្នាការរបស់បុគ្គលម្នាក់ៗផ្ទាល់។ ជាដំបូង យ៉ាងហោចណាស់ក៏ប្រជាពលរដ្ឋហាក់ដូចជាបានទទួលយល់ព្រមធ្វើតាមគំនិតបដិវត្តន៍ទាំងអស់នោះដែរ។ ប៉ុន្តែ អាកប្បកិរិយាថ្មីៗបានចាប់ផ្តើមធ្វើឱ្យមានការព្រួយបារម្ភខ្លះៗ។ ចំណែកអ្នកខ្លះទៀតបានទទួលយកបុព្វហេតុរបស់ខ្មែរក្រហមដោយក្តីសប្បាយរីករាយ។

មានតែប្រជាជននៅទីក្រុង និងនៅជុំវិញទីក្រុងទេដែលបានបន្តរស់នៅបែបធម្មតាដូចកាលពីមុន ទោះបីមានសង្គ្រាមនិងមានជនភៀសសឹកយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ដោយ។ នៅឆ្នាំ១៩៧៥ ប្រជាជនទាំងអស់នោះបានធ្លាក់ចូលទៅក្នុងការផ្លាស់ប្តូរសង្គមទាំងស្រុង។ ទីក្រុងនានាបានក្លាយទៅជាពុំមានប្រជាជនរស់នៅ ហើយប្រជាពលរដ្ឋទាំងនោះត្រូវបានគេជន្លៀសឱ្យទៅរស់នៅស្រុកស្រែចំការ ហើយបានទទួលភ័ព្វវាសនាយ៉ាងអាក្រក់បំផុត ដោយសារគេមានស្ថានភាពខុសប្លែកពីគេ(គឺអ្នកនៅខាងខ្មែរក្រហម)។

ដើម្បីបានយល់ច្បាស់ថាតើប្រជាជនរស់នៅជាមួយអ្នកដទៃ និងការដោះស្រាយទំនាស់របស់ខ្លួនយ៉ាងណានៅសម័យនោះ គឺជាការសំខាន់រំលឹកដល់បរិបទប្រវត្តិសាស្ត្រពិសេសតែមួយនេះ។ ពួកខ្មែរក្រហមមានឆន្ទៈបំផ្លាញសង្គមកម្ពុជាដែលមានគ្រឹះបែបប្រពៃណីបំផុតៈ គ្រួសារ សាសនា ការចង់បានឯករាជភាព ស្នេហាទឹកដី ដើម្បីបង្កើតពិភពមួយថ្មីស្រឡាងដែលមានសមភាពបំផុត ហើយដែលលើកតំលៃសមូហភាពឱ្យសំខាន់ជាងតំលៃបុគ្គលនិយម ដោយមិនរវល់គិតដល់អធិបតេយ្យភាពរបស់បុគ្គលម្នាក់ៗ និងទ្រព្យសម្បត្តិឡើយ។ សង្គមកម្ពុជាបច្ចុប្បន្ននេះនៅតែរងគ្រោះយ៉ាងខ្លាំងពីការប្រែក្រលាស់ទាំងស្រុងនេះនៃតំលៃ និងគោលចារិករបស់ខ្មែរ។ ឧបករណ៍ប្រពៃណីជាច្រើនដែលសំរាប់បង្កាទំនាស់និងអំពើហឹង្សាបានបាត់បង់អស់ ហើយប្រពន្ធ័ផ្សេងៗទៀតពុំទាន់ដាក់ឱ្យ មានដំណើរការពិតប្រាកដនៅឡើយ។

---

[100] . សូមមើលផែនទីនៅក្នុងឧបសម្ព័ន្ធ។

## ២.១. តំបន់ត្រួតត្រាដោយកងទ័ពលោក លន់ នល់

នៅក្នុងទីក្រុងនានា ប្រជាពលរដ្ឋបានកើនចំនួនច្រើនឡើងៗដោយសារតែការហូរចូលនៃជនភៀសសឹក ជាច្រើនដែលបានចាកចេញពីតំបន់ដែលមានការប្រយុទ្ធគ្នានៃទ័ពជើងគោក និងការទំលាក់គ្រាប់បែកពីលើអាកាស[១០១] ។ ប៉ុន្តែនៅក្នុងភូមិទាំងឡាយដែលឋិតនៅជុំវិញទីក្រុង ការរស់នៅប្រចាំថ្ងៃពុំមានការផ្លាស់ប្តូរជាមូលដ្ឋានទេ។ ការងារស្រែចំការនិងរចនាសម្ពន្ធ័រដ្ឋបាលនានានៅមានដំណើរការដដែល។ គេគ្រាន់តែបានធ្វើការផ្លាស់ប្តូរឈ្មោះនិងបានបង្កើតអង្គភាពថ្មីតូចៗតែប៉ុណ្ណោះ (ជាពិសេសគេបានអនុវត្តនៅក្នុងទីក្រុង)។ ដើម្បីធានាដល់ការត្រួតពិនិត្យភូមិឱ្យបានល្អ រដ្ឋបាលបានបង្កើតអនុអង្គភាពតូចៗនៃអ្នកភូមិដែលមានដប់គ្រួសារ គ្រប់គ្រងដោយមេដប់ខ្នង។ មេភូមិបានក្លាយទៅជាមេហាសិបខ្នង។ ជាទំនៀមទំលាប់ ទំនាស់និងបញ្ហានានា នៅក្នុងភូមិត្រូវបានដោះស្រាយជាមួយចាស់ទុំនិងអ្នកតំណាងផ្នែករដ្ឋបាលដោយប្រើប្រាស់វិធីសំរុះសំរួល ឬធ្វើការជំរះក្តីនៅតុលាការ ប្រសិនបើគេសង្កេតឃើញថាជាការចាំបាច់(ករណីព្រហ្មទណ្ឌរឿងដែលស្មុះដោះមិនចេញ)។

> "នៅឆ្នាំ១៩៧០ គេបានកែប្រែរចនាសម្ព័ន្ធ។ មានប្រធានមួយរូបសំរាប់ទទួលបន្ទុកផ្ទះ៥០ខ្នងដែលគេហៅថា មេ៥០ខ្នង និងប្រធានមួយរូបទទួលបន្ទុកផ្ទះ១០ខ្នងគឺមេដប់ខ្នង"។
>
> (លោកស្រី សុង អាយុ ៥២ ឆ្នាំក្រុងស្វាយរៀង ខេត្ត ស្វាយរៀង)

> "គេត្រូវតែទៅជួបមេដប់ខ្នងដើម្បីឱ្យគាត់ជួយដោះស្រាយបញ្ហាតូចតាច។ ប្រសិនបើគេពុំអាចដោះស្រាយបានទេ ឬប្រសិនបើបញ្ហានោះមានលក្ខណៈធ្ងន់ធ្ងរ គេទៅរកជួបលោកមេហាសិបខ្នងទៀត។ បញ្ហាតូចតាច គឺមានការជេរគ្នា។ ឯបញ្ហាធំៗគឺមានការវាយតប់គ្នា និងមានរបួស។ ការជេរគ្នាគឺភាគច្រើនជារឿងរបស់ស្ត្រីៗ។ ស្រីៗច្រើននិយាយអេចអូចហើយផ្សាយតៗគ្នាទៀត។ ស្រីផ្សេងៗទៀតបានស្តាប់ឮ ហើយបណ្តាលឱ្យមានការឈ្លោះគ្នា។ ស្រីៗជេរគ្នា បន្ទាប់មកប្តីក៏ចូលមកជួយ ហើយបានវាយគ្នា។ នៅក្នុងករណីបែបនេះ គេបានទៅរកជួបមេហាសិបខ្នង។ មេហាសិបខ្នងស្នើសុំឱ្យគូជំលោះទាំងពីរមកផ្ទះគាត់ដើម្បីធ្វើការដោះស្រាយ។ មេហាសិបខ្នងបានសាកល្បងឱ្យអ្នកទាំងពីរអង្គុយដោយឡែកពីគ្នានិងបានធ្វើការសាកសួរម្តងម្នាក់ៗ។ អ្នកដែលគេថាមានហេតុផលនោះ គឺគោរពមេភូមិ(មេហាសិបខ្នង)។ អ្នកដែលបានប្រព្រឹត្តខុសពុំមានការសប្បាយចិត្តជាមួយលោកមេភូមិឡើយ។ កាលណាគាត់ពុំយល់ព្រមតាមដំណោះស្រាយរបស់មេភូមិហើយគាត់ចង់ឈ្នះ គាត់ក៏បានបញ្ជូនរឿងនេះឡើងទៅជំទប់[១០២] (មេឃុំ)។ មេហាសិបខ្នង

---

[101] .ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញបានកើនឡើងពី ៥០០.០០០ ទៅ ២.០០០.០០០នាក់ នៅចន្លោះឆ្នាំ ១៩៧០ និង ១៩៧៥។

[102] . ជំទប់នៅទីនេះមានតួនាទីស្មើនឹងមេឃុំ

កោះហៅភាគីទាំងពីរ។ ប្រសិនបើភាគីទាំងពីរមិនបានមក បង្ហាញខ្លួនតាមការកោះហៅចំនួនបីដងរបស់មេហាសិបខ្ទងទេ រឿងនោះត្រូវបានបញ្ជូនទៅថ្នាក់លើទៀត។ មនុស្សគ្រប់រូបចូលចិត្តលោកជំទប់(មេឃុំ) ជាងមេហាសិបខ្ទង(មេភូមិ)។ ជំទប់អាចធ្វើលិខិតមួយទៅចៅសង្កាត់[១០៣] ប្រសិនបើគេមិនបានមកបង្ហាញខ្លួនតាមការកោះហៅ។ បន្ទាប់មក ចៅសង្កាត់បានធ្វើលិខិតមួយទៅប៉ុស្តិ៍នគរបាល ដើម្បីឱ្យចាប់អ្នកដែលរឹងរូស។ មានដីកាកោះហៅជាលាយល័ក្ខអក្សរជាច្រើនៈ មេដប់ខ្ទង មេហាសិបខ្ទង ជំទប់មេឃុំ ប៉ុស្តិ៍នគរបាល។ ឯកសារត្រូវបានរៀបចំដោយមានដីកាកោះហៅទាំងអស់ ហើយត្រូវបានបញ្ជូនទៅតុលាការក្នុងករណីធ្ងន់ធ្ងរ"។

(លោក វ៉ាន់ ណាត អាយុ ៥២ ឆ្នាំឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

## ២.២. តំបន់ត្រួតត្រាដោយចលនាតស៊ូ

### ចលនាតស៊ូបានធ្វើដំណើរទៅមុខយ៉ាងលឿន

ទឹកដីមួយភាគធំបានធ្លាក់យ៉ាងឆាប់រហ័សទៅក្នុងកណ្តាប់ដៃរបស់កងទ័ពព្រៃ។

"នៅឆ្នាំ១៩៦៨ មានបណ្តាញលួចលាក់មួយរវាងពួកខ្មែរក្រហមនៅក្នុងព្រៃ និងប្រជាពលរដ្ឋនៅក្នុងភូមិ។ ឪពុកមាខ្ញុំបានរស់នៅក្នុងព្រៃ។ ខ្ញុំបានទៅចូលរួមជាមួយគាត់។ ខ្ញុំពុំមានការងារធ្វើទេ។ ខ្ញុំបានគិតថា នយោបាយគឺល្អ។ គេបាននិយាយអំពីសមភាព ហើយមនុស្សមានសេចក្តីសប្បាយរីករាយ។ នៅឆ្នាំ១៩៧០ ក្រោយពេលធ្វើរដ្ឋប្រហារ ខ្ញុំបានចូលធ្វើទ័ពជាខ្មែររំដោះអស់រយៈពេលមួយខែកន្លះ។ បន្ទាប់មក ខ្ញុំបានចុះទៅតំបន់វាលរាប ដើម្បីធ្វើការឃោសនានៅក្នុងភូមិរំដោះមួយ[១០៤]"។

(លោក ទិត អាយុ ៥៤ ឆ្នាំអនុប្រធានភូមិ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត (ភូមិបង្កើតថ្មី))

"នៅឆ្នាំ១៩៧០ ភូមិនេះឋិតនៅក្រោមការកាន់កាប់របស់ពួកយៀកកុង។ ព្រះមហាក្សត្រឋិតនៅខាងខ្មែរក្រហម ហើយគេបានដើរតាមព្រះមហាក្សត្រ។ គេចង់នៅខាងសម្តេចសីហនុ គឺពុំមែននៅខាងលោក លន់ នល់ ទេ"។ (លោក យុយ អាយុ ៥៦ ឆ្នាំអនុប្រធានឃុំ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))។

"នៅឆ្នាំ១៩៧០ ពួកយៀកកុងបានចូលមកដល់ទីនេះ។ ពួកយើងមានអ្នកខ្លះបានឋិតនៅទីនេះ ហើយអ្នក ខ្លះទៀតបានធ្វើដំណើរទៅទីរួមខេត្ត សៀមរាបដើម្បីចូលបំរើការងារខាងលោក លន់

[103] . ជាយក្រុងភ្នំពេញ។ គេប្រើប្រាស់ការបែងចែករដ្ឋបាលនៅក្នុងទីក្រុង។ សង្កាត់នៅក្នុងទីក្រុង ដូចជាឃុំនៅជនបទ។

[104] . ពាក្យពេចន៍ដែលពួកខ្មែរក្រហមបានប្រើដើម្បីកំណត់ភូមិមួយដែលសត្រូវកាន់កាប់។

នល់។ តាគួនបានទៅទីនៅរួមខេត្តសៀមរាប ពីព្រោះគាត់បាននិយាយថា គេពុំបានបរិភោគគ្រប់គ្រាន់ទេនៅជាមួយពួកយៀកកុង។ ចំណែកខ្ញុំ ខ្ញុំបានរស់នៅទីនោះពីព្រោះវាធម្មតាទៅហើយៗ ខ្ញុំមិនដឹងទៅណា។ យន្តហោះរបស់ លន់ នល់ បានមកទំលាក់គ្រាប់បែបនៅក្នុងភូមិ។ យើងបានរត់ចូលក្នុងប្រាសាទបន្ទាយក្តី និងប្រាសាទតាព្រហ្ម។ ប្រជាពលរដ្ឋនៅទីនោះ ពុំបានធ្វើស្រែទាំងអស់ទេ។ ប្រជាជនរកបានប្រាក់កាសដើម្បីទិញអង្ករដោយសារការធ្វើជាកម្មករ (គូលី) របស់លោក Bernard Philippe Groslier[១០៥] ។ ដូចនេះក៏បានមានអង្ករ" ។

(លោក ប៉ែត អាយុ៧១ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្ត សៀមរាប)

តំបន់យុទ្ធសាស្ត្រខ្លះទៀតមានការប្រយុទ្ធគ្នាអស់រយៈពេលយ៉ាងយូរមុនធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ពួកខ្មែរក្រហម។

"នៅឆ្នាំ១៩៧០ ភូមិនេះគឺជាខ្សែបន្ទាត់ជួរមុខនៃការប្រយុទ្ធគ្នា។ នៅភាគខាងត្បូងគឺមានកងទ័ពលោក លន់ នល់ និងទាហានរបស់លោក ធីវ គី[១០៦] (វៀតណាមខាងត្បូង) នៅភាគខាងជើងគឺមានទ័ពខ្មែររំដោះ និងពួកយៀកកុង។ ព្រំដែនខ្មែរជាមួយវៀតណាមមានចំងាយ៤០០ម៉ែត្រ។ អ្នកភូមិចូលចិត្តទ័ពខ្មែររំដោះ ពីព្រោះពួកគេ និយាយថាគេឋិតនៅខាងសម្តេចសីហនុ។ សម្តេចសីហនុ គឺជាអ្នកដឹកនាំរបស់ចលនាតស៊ូខ្មែររំដោះ។ ពួកទ័ពខ្មែររំដោះធ្វើល្អជាមួយប្រជាពលរដ្ឋ។ ចំណែកឯទ័ពវៀតណាមខាងត្បូង ធីវ គី បានលួចប្លន់ទ្រព្យសម្បត្តិបានបាញ់បាន សំលាប់មនុស្ស និងបានរំលោភ លើរូបរាងកាយក្មេងស្រី។ ក្មេងស្រីជំទង់បានយកធ្យូងមកលាបមុខដើម្បីឱ្យឃើញមុខអាក្រក់ ឬមួយអង្គុយយោលកុមារម្នាក់ ដើម្បីធ្វើឱ្យពួកទាហានទាំងនោះជឿថាក្មេងស្រីជំទង់ទាំងអស់នោះ បានរៀបអាពាហ៍ពិពាហ៍អស់ហើយ និងពុំមែនជាស្រីក្រមុំទេ។ ក្រោយមកកងទ័ពវៀតណាមបានដកទៅប្រទេសវៀតណាមវិញ។ ពេលនោះគឺមានតែទ័ពខ្មែរច្បាំងជាមួយទ័ពខ្មែរ។ ទីនេះគឺត្រួតត្រាដោយខ្មែររំដោះ។ នៅឯស្ពានចំងាយបួនគីឡូម៉ែត្រពីនេះគឺមានទ័ពរបស់លោក លន់ នល់។ ប្រជាពលរដ្ឋមានការភ័យខ្លាចពីការច្បាំងគ្នា និងការទំលាក់គ្រាប់បែក។ គេបាននាំគ្នារត់ទៅគ្រប់ទិស។ គេបាននាំគ្នាលាក់ខ្លួន។ នៅឆ្នាំ១៩៧៤ ទ័ពខ្មែរក្រហមបានឈ្នះ។ ការប្រយុទ្ធគ្នាបានបញ្ចប់នៅទីនោះ" ។

(លោក វ៉ៃ អាយុ ៤៦ ឆ្នាំមេភូមិ ឃុំពពាក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង "ជិតព្រំដែនវៀតណាម ")

---

[105] . Bernord Philipp Groslier អភិរក្សតំបន់ប្រាសាទអង្គរ

[106] . ទាហានវៀតណាមខាងត្បូងដែលអាមេរិកបានហ្វឹកហ្វឺន

"ចាប់ពីឆ្នាំ១៩៧០ដល់១៩៧៥ យើងបានគិតតែពីសន្តិសុខរបស់យើង។ យើងពុំបានគិតអ្វីទៀតទេ។ ជួនកាលទ័ពខ្មែរក្រហមនៅចំងាយពីរបីទៅបួនគីឡូម៉ែត្រប៉ុណ្ណោះ ហើយយន្តហោះជាច្រើនបានហោះពីលើយើងដើម្បីទំលាក់គ្រាប់បែកលើពួកខ្មែរក្រហម។ យើងមានការភ័យខ្លាចថាពួកខ្មែរក្រហមនឹងមកដល់ភូមិនៅពេលយប់"។

(លោក សាន អាយុ ៧០ ឆ្នាំក្រុងស្វាយរៀង ខេត្ត ស្វាយរៀង)

ការនៅជាមួយភាគីម្ខាង ឬភាគីម្ខាងទៀតមិនមែនសុទ្ធតែជាការសំរេចដែលបានគិតទុកទេ។ ភូមិជាច្រើនបានចូលជាមួយអ្នកតស៊ូនៅពេលដែលពួកគេបានជំរុលទ័ពទៅមុខនិងកាន់កាប់ដីបានកាន់តែច្រើន។ ហេតុផលរបស់អ្នកនៅព្រៃមានទម្ងន់ខ្លាំងៈ គេប្រកាសថា គេនឹងនៅជិតប្រជាពលរដ្ឋនិងចង់បានសង្គមមួយដែលមានសមភាព មានសេចក្តីសុខសប្បាយ ប្រគល់អំណាចថ្វាយព្រះមហាក្សត្រវិញ ដោយធានារបៀបរបបសម្បូរណ៍បែបរបស់ប្រទេស។ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះ គេបានលើកខ្លួនឯងធ្វើជាមេដោយប្រើប្រាស់មធ្យោបាយបំភិតបំភ័យ។ ជនខ្លះមានការចាប់អារម្មណ៍ទៅលើគំនិតថ្មីៗ អ្នកខ្លះទៀតបានដើរតាមព្រះមហាក្សត្រ។ ប៉ុន្តែមនុស្សភាគច្រើនបានធ្វើអ្វីៗដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន និងការពារគ្រួសាររបស់ខ្លួនទោះបីមានផ្លាកខាងជាមេក៏ដោយ។

"ពីឆ្នាំ១៩៦៨ ដល់ ១៩៧២ ខ្ញុំបាននៅខាងទ័ពខ្មែររំដោះ។ ខ្ញុំស្រលាញ់គំនិតរបស់ទ័ពខ្មែររំដោះ។ ក្រោយមកខ្ញុំបានទៅនៅខាងលោក លន់ នល់ ពីព្រោះនៅខាងលោក លន់ នល់មានសិទ្ធិច្រើនជាង"។

(លោក ខៅ អាយុ ៤៦ ឆ្នាំមេភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្ត ស្វាយរៀង)

"នៅឆ្នាំ១៩៧០ ពួកយៀកកុងបានឱ្យពួកយើងស្តាប់វិទ្យុ ហើយយើងបានស្តាប់សម្តេច សីហនុអំពាវនាវឱ្យចូលចលនាតស៊ូ។ ខ្ញុំបានស្តាប់សម្តេច។ យើងទទួលយកពួកយៀកកុង។ ពួកយៀកកុងបាននៅខាងព្រះ មហាក្សត្រ"។

(លោកស្រី រ៉ាតា អាយុ ៥២ ឆ្នាំ "អតីតខ្មែរក្រហម" ឃុំដង់កុល ក្រុងកែប)

"យើងចូលចិត្តគំនិតថ្មីៗ។ ខ្ញុំជាយុជន ហើយខ្ញុំមានបំណងរស់នៅក្នុងសង្គមមួយដែលគ្មានអ្នកមាននិងគ្មានអ្នកក្រ។ យើងបានទៅធ្វើការជាមួយយុវជនដទៃទៀតតាមបឹងទន្លេ។ មានតែជនដែលធ្វើការល្អទេដែលត្រូវបានជ្រើសរើសឱ្យទៅធ្វើការនៅកន្លែងនោះ។ យើងមានសេចក្តីសប្បាយរីករាយណាស់ ទោះបីយើងបានធ្វើការច្រើន យ៉ាងណាក៏ដោយ"។

(លោកស្រី សារុន អាយុ ៤៥ ឆ្នាំ (អតីតខ្មែរក្រហម) ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅឆ្នាំ១៩៧០ ដំបូងខ្ញុំបាននៅខាងទ័ពខ្មែររំដោះ ពីព្រោះកងទ័ពនេះបាននៅក្នុងភូមិខ្ញុំ។ ពួកខ្មែររំដោះ មានគំនិតល្អណាស់ហើយមានចិត្តល្អណាស់។ ក្រោយមក ពួកនេះបានចាប់ផ្តើមធ្វើការរិតត្បិតលើចលនារបស់ប្រជាពលរដ្ឋ។ ចំណែកខ្ញុំ ខ្ញុំចង់ធ្វើដំណើរទៅណាមកណាតាមចិត្តខ្ញុំចង់ដោយពុំចាំបាច់មានសេចក្តីអនុញ្ញាតឡើយ។ ដូចនេះ ខ្ញុំបានសំរេចចិត្តមកតាមបងស្រីខ្ញុំនៅក្រុងសៀមរាប (នៅខាងលន់ នល់)"។

(លោក ខាល អាយុ ៦១ ឆ្នាំឃុំនគរធំ ស្រុក សៀមរាប ខេត្ត សៀមរាប)

"ខ្ញុំបានទៅជាមួយពួកខ្មែរក្រហម ដោយសារពួកនេះបានសុំខ្ញុំឱ្យទៅតាមពួកគេដើម្បីជួយសែងគ្រាប់រំសេវនិងស្បៀង។ ក្រោយមក ខ្ញុំក៏បានរស់នៅជាមួយពួកខ្មែរក្រហម។ ខ្ញុំបាននឹកគិតទៅគ្រួសារខ្ញុំជានិច្ច។ ប្រសិនបើខ្ញុំពុំព្រមទៅតាមពួកខ្មែរក្រហមទេ ខ្ញុំនឹងអាចមានបញ្ហាច្រើន។ នៅជំនាន់នោះគឺវាអញ្ចឹង យើងធ្វើតាមអ្នក ណាដែលបញ្ជាយើង"។

(លោក វួន អាយុ ៤៨ ឆ្នាំ (អតីតខ្មែរក្រហម) ឃុំបន្ទាយស្រី ស្រុកបន្ទាយស្រី ខេត្តសៀមរាប)

"ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ម្នាក់ៗគិតតែពីការការពារខ្លួនដើម្បីឱ្យផុតពីការប្រយុទ្ធ។ គេពុំបានគិតអំពីរឿងយោបាយទេ។ គេបានរស់នៅក្នុងលេណដ្ឋាន។ ប្រពន្ធនិងកូនបាននាំគ្នាទៅតាមឪពុករបស់ខ្លួន។ ប្រសិនបើឪពុកធ្វើទាហាន លន់ នល់ ពួកគេក៏ទៅខាង លន់ នល់ ដែរ។ ប្រសិនបើឪពុកធ្វើជាទាហានខ្មែរក្រហម ពួកគេក៏ទៅខាងពួកខ្មែរក្រហមដែរ។ នៅពេលដែលពួកខ្មែរក្រហមបានចូលមកនៅក្នុងឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានសំលាប់ជនដែលនៅខាង លន់ នល់ ទាំងអស់ហើយជួនកាលបានសំលាប់ទាំងគ្រួសារផងក៏មាន"។

( លោក ខៅ មេភូមិ អាយុ ៤៦ ឆ្នាំឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"គឺជាពេលមានសង្គ្រាម យើងមានការភ័យខ្លាច។ យើងមិនចង់ចាកចោលភូមិទេ។ តើធ្វើដំណើរទៅទីណា? ដើម្បីឱ្យបានសុខយើងពុំហ៊ានចោទសួរអ្វីឡើយ ហើយធ្វើអ្វីកុំឱ្យគេកត់សំគាល់អ្វីបាន។ ធ្វើយ៉ាងនេះ គេរួចខ្លួន។ ក្រុមខ្មែរក្រហមទីមួយល្អណាស់។ ពួកគេមិនលួចប្លន់ទ្រព្យសម្បត្តិទេ ហើយក៏និយាយស្លូតបូតផង"។

(លោក សារ៉េត អាយុ ៤៨ ឆ្នាំឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)។

បន្តិចម្តងៗប្រព័ន្ធថ្មីមួយត្រូវបានដាក់ឱ្យអនុវត្តន៏។ ប្រជាកសិករបានដឹងថា អ្វីដែលសំខាន់បំផុតគឺ : បដិវត្តន៏ ហើយដើម្បីឱ្យបដិវត្តន៏ធ្វើដំណើរទៅមុខគេត្រូវតែដាក់ចិត្តប្រឹងធ្វើការស្រែចំការ ហើយត្រូវកំទេចខ្មាំង។

## ការដាក់ឱ្យអនុវត្តន៍ប្រពន្ធ័ថ្មីមួយ

## ការធ្វើស្រែចំការ

ការធ្វើស្រែចំការ និងការផលិតស្រូវគឺជាអាទិភាពទីមួយ។ គេត្រូវតែចិញ្ចឹមយុទ្ធជននៅសមរភូមិមុខ។ នៅក្នុងតំបន់ដែលយើងបានធ្វើការជួបសម្ភាសន៍ ដីធ្លីបានឋិតនៅជាកម្មសិទ្ធិឯកជនរហូតដល់ឆ្នាំ ១៩៧៤-១៩៧៥ ។ យុវជនត្រូវបានគេដកចេញពីការងារកសិកម្មដើម្បីឱ្យចូលបំរើទ័ព។ របៀបប្រើប្រាស់និងទាញយកផលពីដីធ្លីក៏បានផ្លាស់ប្តូរ។ ឧបករណ៍ផលិតកម្ម ត្រូវបានគេប្រមូលដាក់រួមៈ គោ ក្របី រទេះ កង់ និងកំលាំងពលកម្មដែរ។ វិធានការនេះក៏បានសំដៅទៅដល់ការរៀបចំស្រុកស្រែចំការជាបណ្តើរៗ ដើម្បីប្រមូលដីធ្លីដាក់ជាកម្មសិទ្ធិសមូហភាពនៅពេលក្រោយមកទៀត។

"ពីឆ្នាំ១៩៧០ ដល់ ១៩៧៥ ខ្ញុំបានធ្វើជាទាហានខាងខ្មែរក្រហម។ កសិកម្មគឺជាអទិភាព។ គេត្រូវតែដាំស្រូវដើម្បីចិញ្ចឹមយោធានៅសមរភូមិមុខ និងធានាសន្តិសុខផ្ទៃក្នុង(...)។ ដីធ្លីជាកម្មសិទ្ធិរបស់ឯកជន ប៉ុន្តែមានការងាររួមគឺ ប្រវាស់ដៃ។ មានក្រុមធ្វើការដោយដៃ(ក្រុមពលកម្ម)។ គេនិយាយតែពីធ្វើការងារ។ ការងារសំខាន់បំផុតគឺដាំស្រូវ។ អ្នកដែលមកពីតំបន់ដែលមានការប្រយុទ្ធគ្នាជាមួយកងទ័ពលោក លន់ នល់ បានតាំងទីលំនៅនៅទីនេះ។ ចំណែកយើងជាប្រជាជនចាស់។ យើងបានចូលចលនាតស៊ូមុនជនទាំងនោះ។ ប្រធានភូមិនិង ប្រធានឃុំបានសាកល្បងអូសទាញអ្នកទាំងនោះឱ្យមករស់នៅទីនេះដើម្បីអាចឱ្យយើងមានកំលាំងខ្លាំងជាងទ័ពលន់ នល់"។
(លោក ក្រែម អាយុ៥៦ ឆ្នាំអនុប្រធានភូមិ "អតីតខ្មែរក្រហម"ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត "ភូមិបង្កើតថ្មី")

"យើងបានដាំដំណាំនៅលើដីរបស់យើងដូចកាលពីមុនដែរ។ ប៉ុន្តែមានប្រពន្ធ័ថ្មីមួយចំពោះគោក្របី។ អ្នកណាដែលពុំមានគោក្របីអាចខ្ចីគោក្របីគេបាន ហើយត្រូវតែធ្វើការសងគេវិញដើម្បីជាថ្នូរ។ របៀបប្រវាស់ដីត្រូវបានលុបបំបាត់(...)។ ប្រជាជនម្នាក់ៗនៅតែជាម្ចាស់កម្មសិទ្ធិលើដីរបស់ខ្លួន ប៉ុន្តែគេបានធ្វើការផ្លាស់ប្តូរពលកម្ម(ប្រវាស់ដៃ)ជាពិសេសចំពោះការដកស្ទូង។ គ្មានជនណាម្នាក់អាចប្រើអ្នកដទៃ ឬយកជននោះធ្វើជាទាសករ[១០៧] បានឡើយ(...)។ នៅរដូវប្រាំងគេបានឱ្យយើងទៅប្រកបមុខរបរផ្សេងទៀតដូចជាផ្នែកសិប្បកម្ម។ គេបានប្រើប្រាស់លុយកាក់រហូតដល់ឆ្នាំ១៩៧៤។ ក្រោយមក គេបានធ្វើការប្តូរគ្នាជាមួយអង្ករនិងបារី។ របបសមូហភាពត្រូវបានគេអនុវត្តន៍ជាបណ្តើរៗ។ គេបានធ្វើការរឹបអូស កង់ គោ មាន់ និង ក្របី ដើម្បីដាក់ឱ្យបំរើអ្នកដទៃផ្សេងទៀត។ បញ្ហាបានកើតមានឡើងដោយសារអ្នកម្ចាស់កង់ពុំចង់ជួសជុលកង់ទេ ដូច

107 . វណ្ណៈគឺជាជាន់ថ្នាក់។ គេបាននិយាយថា វណ្ណៈថ្នាក់លើនិងវណ្ណៈថ្នាក់ក្រោម។

ជាគេពុំបានទិញ គ្រឿងបន្លាស់ជាដើម។ ដូចនេះកង់នោះបានក្លាយទៅជាប្រើលែងបាន។ នៅឆ្នាំ១៩៧៥ ការផ្លាស់ប្តូរប្រព័ន្ធត្រូវបាន ធ្វើទាំងស្រុង"។

(លោក សេង អាយុ ៥៧ ឆ្នាំសង្កាត់ពងទឹក ក្រុងកែប "ភូមិបង្កើតថ្មី")

## ការកំទេចខ្មាំងសត្រូវ

វិធានការទីមួយរបស់ពួកទ័ពព្រៃគឺ ការដាក់មនុស្សដែលបានធ្វើតាមបុព្វហេតុខ្លួនជំនួសអ្នកតំណាងរដ្ឋការ។ គេនៅរក្សាមុខងារចាស់ដោយធ្វើការកែរិះខ្លះៗ។ មេភូមិ និង មេឃុំ ដោយមានប្រធានក្រុមជាជំនួយតទៅត្រូវទទួលបន្ទុករៀបចំការប្រជុំដើម្បីធ្វើការឃោសនានយោបាយ និងត្រួតពិនិត្យមនុស្ស។ ការប្រមូលប្រាក់ ពន្ធនិងអាករត្រូវបានលុបបំបាត់ចោល។ តួនាទីរបស់អ្នកសំរុះសំរួលក្នុងពេលមានទំនាស់ក្នុងភូមិស្រុកត្រូវបានគេរក្សាទុក ប៉ុន្តែរបៀបនៃការដោះស្រាយបានផ្លាស់ប្តូរបន្តិចម្តងៗ។ បុគ្គលម្នាក់ៗត្រូវបង្អោនខ្លួនដើម្បីផលប្រយោជន៍របស់ក្រុម ហើយទាំងអស់គ្នាត្រូវដាក់ខ្លួនឱ្យ"អង្គការ"។ ការប្រព្រឹត្តខុសរបៀបរបបត្រូវចាត់ទុកថាមានកំហុសចំពោះមុខអង្គការ មានតែជនដែលមានការលះបង់ខ្ពស់បំផុតចំពោះអង្គការទេ ទើបមានកិត្តិយសទទួលបន្ទុកតំណែងជាកម្មាភិបាល។ នៅក្នុងតំបន់ "ដែលរំដោះបានពីសត្រូវ" មនុស្សដែលគេចាត់ជាសត្រូវទីមួយគឺ ជនទាំងឡាយដែលមានទំនាក់ទំនងជាមួយរដ្ឋាភិបាល លន់ នល់។ អ្នកតំណាងរដ្ឋការក្នុងភូមិស្រុកគឺជាគោលដៅដែល គេផ្តោតទៅលើ។

ជោគវាសនារបស់ពួកគេគឺត្រៀមចាំព្រឹត្តិការណ៍ផ្សេងៗដែលនឹងមកដល់។

"ពួកខ្មែរក្រហមបានចូលមកក្នុងភូមិខ្ញុំ (ឃុំសូយរំង់ ខេត្តកំពង់ធំ) នៅឆ្នាំក្នុង១៩៧៣។ ខ្មែរក្រហម បានសុំឱ្យពួកយើងចាកចេញចំងាយពីរគីឡូម៉ែត្រពីកន្លែងដែលយើងរស់នៅ។ មេភូមិនិងមេឃុំត្រូវគេសំលាប់ចោល ហើយជំនួសដោយពួកខ្មែរក្រហម"។

(លោក ហាំ អាយុ ៥៧ ឆ្នាំសង្កាត់ពងទឹក ក្រុងកែប "ភូមិបង្កើតថ្មី")

"នៅឆ្នាំ១៩៧០ ពួកខ្មែរក្រហមបានចូលមកក្នុងភូមិ។ គឺពុំមានការផ្លាស់ប្តូរច្រើនទេរហូតដល់ឆ្នាំ១៩៧៦ នៅពេលដែលគេបានយកដីធ្លីដាក់ជាសមូហភាព។ មេភូមិចាស់នៅធ្វើការដដែល ក្រោយមកគេបានផ្លាស់គាត់ចេញ ពីព្រោះគាត់ពុំមានចិត្តស្មោះត្រង់ ហើយគេបានជ្រើសរើសមនុស្សម្នាក់ទៀត។ គឺជាការល្អ"។

(លោកស្រី សេង អាយុ ៤៧ ឆ្នាំ "អតីតខ្មែរក្រហម" សង្កាត់ពងទឹក ក្រុងកែប "ភូមិបង្កើតថ្មី")

"នៅឆ្នាំ១៩៧៣ ពួកខ្មែរក្រហមបានចូលមកដល់។ ពួកគេបានបង្ខំឱ្យយើងនាំគ្នាចាកចេញពីភូមិទៅរស់នៅក្នុងភូមិមួយទៀតដែលឋិតនៅក្បែរផ្លូវរទេះភ្លើង។ ពួកខ្មែរក្រហមបាននិយាយថា ភូមិ

នេះឋិតនៅជិតសមរភូមិប្រយុទ្ធពេក។ ពួកគេបានតែងតាំងមេភូមិនិងមេឃុំថ្មី។ ពួកគេទាំងនោះកាចណាស់។ ពួកគេប្រើអំណាចខ្លាំងណាស់ គឺហាមមិនឱ្យធ្វើដំណើរទេ"។

(លោក សម្បត្តិ អាយុ ៦១ ឆ្នាំសង្កាត់អង្គោល ក្រុងកែប ខេត្តកំពត)

"គេបានប្រមូលផ្តុំមនុស្សជាថ្មីនៅក្នុងភូមិ។ មេភូមិចាស់បានបាត់ខ្លួនដោយសារតែគាត់ជាមនុស្សខាងរដ្ឋបាល លន់ នល់។ មេភូមិថ្មីត្រូវបានស្នើឡើងដោយពួកខ្មែរក្រហម។ កាលពីមុនមានមេភូមិតែមួយទេ។ ចាប់តាំងពីឆ្នាំ១៩៧៤ មកគឺមានមនុស្សចំនួនប្រាំរូបៈ ប្រធានមួយរូប អនុប្រធានមួយរូប និងសមាជិកបីរូប។ ក្រោយមកជនទាំងប្រាំរូបនោះបានធ្វើជាអ្នកដឹកនាំសហករណ៍"។ (លោក រ៉ៃ អាយុ ៤៦ ឆ្នាំឃុំពពាក ស្រុកស្វាយទាប ខេត្តស្វាយរៀង)

"មនុស្សមានការភ័យខ្លាចពួកយៀកកុងនិងខ្លាចសង្គ្រាម។ ជនទាំងឡាយណាដែលបានបង្កើតបញ្ហា ឬដែលមានបំណងទៅចូលខាង លន់ នល់ នៅសៀមរាបត្រូវគេចាប់ចងដៃទៅក្រោយចងមុខហើយនាំទៅឱ្យមេពួកយៀកកុង។ ពួកមេៗយៀកកុងបាននិយាយថា ជនទាំងឡាយណាដែលបានធ្វើដំណើរចុះឡើងច្រើនគឺជាពួកគិញ។ ប្រសិនបើមានកំហុសធ្ងន់ធ្ងរ ជននោះត្រូវសំលាប់ចោល"។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំមេឃុំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"គេក្តាប់ការរស់នៅរបស់មនុស្សគ្រប់រូប។ ជួនកាលគេដឹងថា មានមនុស្សណាម្នាក់ធ្វើជាគិញរបស់លោក លន់ នល់។ នៅក្នុងករណីនេះ គេបានបញ្ជូនជននោះទៅថ្នាក់លើទៀត ហើយខ្ញុំពុំបានដឹងថាគាត់មានវាសនាបែបណានោះទេ។ គេត្រូវតែសាមគ្គីគ្នាដើម្បីឈ្នះ លន់ នល់។ រឿងនេះជារឿងសំខាន់កាលសម័យនោះ គឺត្រូវយកឈ្នះ លន់ ណុល។

(លោក ប៉ែល អាយុ ៥២ ឆ្នាំ "អតីតខ្មែរក្រហម "សង្កាត់ពងទឹក ក្រុងកែប)

ក្រោយពីសំលាប់ជនស្មោះត្រង់ជាមួយ លន់ នល់ ខ្មាំងសត្រូវគឺ "អ្នកមាន" ដែលគេចាត់ទុកដូចជាអ្នកកេងប្រវ័ញ្ចលើប្រជាជន។ គេឱ្យតំលៃទៅលើជនអ្នកក្រីក្រ។ ប្រធានថ្មីៗ ត្រូវបានជ្រើសរើសក្នុងចំណោមអ្នកក្រីក្រ និងអ្នកល្ងង់ខ្លៅ។ ការរៀបចំបែបនេះបានបើកទ្វារឱ្យមានការរំលោភគ្រប់បែបយ៉ាង។

"អ្នកដែលធ្វើឱ្យមានបញ្ហាគឺ "អ្នកមាន"។ ដូចនេះ នៅក្នុងភូមិមនុស្សទាំងអស់គ្នា ចង់ធ្វើជាអ្នកក្រីក្រ។ គេបានចាត់ទុកថា អ្នកមានជាវណ្ណៈមួយដែលសង្កត់សង្កិនវណ្ណៈផ្សេងៗទៀត។ គេបានប្រមូលកំលាំងទាំងអស់ ដើម្បីធ្វើសង្គ្រាមប្រឆាំង លន់ នល់។ មនុស្សជាច្រើនជាអ្នកក្រីក្រ ប៉ុន្តែត្រូវបានគេឱ្យតំលៃខ្ពស់។ គេចង់លើក អ្នកក្រីក្រឱ្យខ្ពស់ដើម្បីកាន់កាប់អំណាច។ ពួកខ្មែរក្រហមនិយាយថា គេត្រូវតែលើកតំកើងអ្នកក្រីក្រដើម្បីឱ្យពួក គេអាចកាន់កាប់អំណាចនៅគ្រប់

កន្លែងទាំងអស់។ គេស្រឡាញ់របបនេះដោយសារគេឱ្យតំលៃទៅលើអ្នកក្រីក្រ។ កាលពីមុនគេមានទំលាប់មានការភ័យខ្លាចជានិច្ច ប៉ុន្តែឥឡូវនេះមានការខុសគ្នា។ ដំបូង គេបានប្រឆាំងជាមួយអ្នកមាន ពីព្រោះគេជាអ្នកក្រីក្រ ហើយបន្ទាប់មកដោយសារអ្នកមានមានចំនួនតិចតួច គេបានក្រឡេកមកមើលក្នុងចំណោមគ្នាយើងម្តង ហើយយើងមានការភ័យខ្លាចគេចាត់ទុកយើងជាអ្នកមាន។ អ្នកមានគឺជាវណ្ណៈដែលជិះជាន់អ្នកក្រីក្រ។ នៅពេលបដិវត្តន៍បានចូលមកដល់ គេបាននិយាយថាគ្មានអ្នកមាន និងអ្នកក្រីក្រឡើយ។ គេមិនត្រូវការឱ្យមានវណ្ណៈខុសគ្នាឡើយ។ គឺមានតែវណ្ណៈអ្នកក្រីក្រប៉ុណ្ណោះ"។

(លោក ក្រែម អាយុ ៥៤ ឆ្នាំ អនុប្រធានភូមិ "អតីតខ្មែរក្រហម"ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្ត កំពត)

"នៅចន្លោះឆ្នាំ១៩៧០ និង១៩៧២ មេភូមិ និង មេឃុំខ្លះៗនៃរបបលោក លន់ នល់ ត្រូវបានគេប្តូរចេញ។ មេភូមិនិងមេឃុំថ្មីៗគឺជាអ្នកល្ងង់ខ្លៅ។ ពួកគេត្រូវបានជ្រើសរើសក្នុងចំណោមអ្នកក្រីក្រ។ ពួកគាត់គ្មានចេះអ្វីទាំងអស់។ ពួកគេមិនអាចដឹកនាំការងារឱ្យបានត្រឹមត្រូវទេ។ គេយល់បទបញ្ជាមិនបានច្បាស់ទេ និងបានអនុវត្តលើសពីបទបញ្ជាទៅទៀត។ កាលណាភរិយារបស់មេឃុំនិយាយថា "មនុស្សនេះពុំធ្វើឱ្យគាត់សប្បាយចិត្តទេ" ជននោះត្រូវបានសំលាប់ចោល។ គេត្រូវតែធ្វើឱ្យបានដូចអ្វីដែលប្រធាននិយាយ ពុំនោះសោតទេគេនិងអាចត្រូវសំលាប់ចោល។ ឧទាហរណ៍ ប្រសិនបើមានជនណាម្នាក់ជិះកង់ ហើយចង់ធ្វើដំណើរទៅត្រង់ ប្រសិនបើគេបានប្រាប់ឱ្យគាត់បត់ទៅខាងឆ្វេងគាត់ត្រូវតែបត់ទៅខាងឆ្វេងដោយពុំចាំបាច់ចង់ដឹងហេតុផលអ្វីទេ គឺគេត្រូវធ្វើរបៀបនេះ។ មេឃុំនិង មេភូមិទាំងអស់បានទទួលការបណ្តុះបណ្តាលផ្នែកនយោបាយ។ មេឃុំភាគច្រើនចេះអាននិងចេះសរសេរ។ ចំណែកឯមេភូមិជាអ្នកល្ងង់ខ្លៅ។ មានមេភូមិខ្លះចេះសរសេរអាចធ្វើរបាយការណ៍បាន។ មនុស្សខ្លាចប្រធានភូមិភូមិ។ យើងពុំអាចត្រៀមជាមុនអំពីអ្វីដែលអាចកើតមានបានឡើយ។ យើងខំប្រឹងប្រែងធ្វើការដើម្បីបានរស់រានមានជីវិត"។

(លោក យុយ អាយុ ៥៦ ឆ្នាំ (អតីតកម្មាភិបាលខ្មែរក្រហម) អនុប្រធានឃុំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ក្រុងកំពត)

សខ្មាំងសត្រូវប្រភេទទីបីបានលេចចេញឡើងក្នុងរយៈពេលច្រើនឆ្នាំកន្លងមកទៀត។ ខ្មាំងប្រភេទទីបីនេះ គឺសំដៅជនណាដែលគេហៅថា "អ្នកធ្វើពុត" ជំងឺសតិអារម្មណ៍ អ្នកធ្វើវិច្ឆេទកម្មបដិវត្តន៍ គឺជាជនទាំងឡាយដែលពុំបានធ្វើការតាមគោលដៅដែលអង្គការបានកំណត់។

នៅក្នុងប្រពន្ធ័ថ្មីនេះ គេលែងនិយាយអំពីជនទាំងឡាយណាដែលមានបញ្ហា និងមានទំនាស់នឹងគ្នាទៀតហើយ។ គឺមានតែជនដែលបានបង្កើតបញ្ហាហើយដែលគេឱ្យឈ្មោះថា "ខ្មាំងសត្រូវរបស់បដិវត្តន៍"។ មេភូមិ

ដែលភាគច្រើនជាអ្នកល្ងង់ខ្លៅ បានវិនិច្ឆ័យឱ្យជនទាំងឡាយមានទោសដោយមិនបាច់មានការជំនុំជំរះអ្វីទាំងអស់។ គេបានដាក់ទោសជនទាំងនោះ។ តុលាការនិងច្បាប់នានាដែលមានមុនឆ្នាំ ១៩៧០ ត្រូវបានគេបោះបង់ចោលអស់។

**ការដោះស្រាយនិងការបង្ក្រាបបញ្ហានិងទំនាស់ប្រចាំថ្ងៃ: "កំហុស"**

ការអនុវត្តន៍និងការសំរុះសំរួលរវាងជនដែលមានទំនាស់ដោយអ្នកទីបីម្នាក់ទៀតគឺ ចាស់ទុំ ឬអាជ្ញាធរមូលដ្ឋានត្រូវបានជំនួសបន្តិចម្តង១ ដោយការប្រជុំរួម ដោយមានការធ្វើស្វ័យទិតៀន ការចោទប្រកាន់ និងមានការដាក់ទោស។ ម្នាក់១ត្រូវនិយាយរៀបរាប់កំហុសរបស់ខ្លួន បើពុំនោះទេត្រូវរង់ចាំការចោទប្រកាន់។ ការដាក់ទណ្ឌកម្មមានតាំងពីការឃោសនាបែបនយោបាយ រួមផ្សំជាមួយការស្តីបន្ទោសនិងការបង្ខំឱ្យធ្វើការជាទំងន់រហូតដល់ស្លាប់ក៏មាន។ តាមមតិរបស់អតីតខ្មែរក្រហម និតិវិធីដែលត្រូវអនុវត្ត គឺមានលក្ខណៈច្បាស់លាស់ណាស់។ ក្នុងករណីមានកំហុស ជនទាំងនោះត្រូវបានទទួលការអប់រំដើម្បីកុំឱ្យជននោះប្រព្រឹត្តខុសម្តងទៀតឱ្យសោះ។ ប្រសិនបើជននោះបានប្រព្រឹត្តកំហុសចំនួនបីដងនិងមានការអប់រំផងនោះ ករណីនោះត្រូវបានបញ្ជូនទៅអាជ្ញាធរខ្ពស់បំផុត។ អ្នកភូមិដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម បានបកប្រែពាក្យអប់រំជាការ "កសាង"វិញ។

ចំពោះពួកគេគឺមានន័យថា "ការធ្វើការជាទំងន់" ឬ "សេចក្តីស្លាប់"។ អាជ្ញាធរក្រៅផ្លូវការ និងជាប្រពៃណីដូចជាចាស់ទុំ និងព្រះសង្ឃត្រូវបានផាត់ចេញ។ ដោយសារគ្មានរបាំងការពារជាប្រពៃណីរបស់ខ្លួន សង្គមខ្មែរចាប់ផ្តើមបាត់បង់គោលចារឹករបស់ខ្លួន។

ប៉ុន្តែសភាពការណ៍ប្លែក១គ្នាៈ អាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រស្រុកភូមិ ដែលងាយឬពិបាកត្រួតត្រា និងអាស្រ័យទៅតាមបុគ្គលិកលក្ខណៈរបស់មេភូមិថ្មី១។ កន្លែងខ្លះហាក់ដូចជានៅតែស្ងប់ស្ងាត់គួរសម។ កន្លែងផ្សេងទៀតសេចក្តីភ័យខ្លាចនិងការមន្ទិលសង្ស័យកើតមានជានិច្ច។ គេបានបំបិទមនោសញ្ចេតនា និងបញ្ហាខ្លួនផ្ទាល់ ដើម្បីកុំឱ្យមានឱកាសគេទិតៀននិងការដាក់ទណ្ឌកម្មបាន។ សំណាញ់ងងឹតបានធ្លាក់គ្របមកលើប្រជាពលរដ្ឋ។ ចំពោះអ្នកខ្លះ សំណាញ់នេះទើបតែបានបើកចេញនៅទសវត្ស៩០។

នៅទីកន្លែងណាដែលប្រធាន១មានការតឹងតែងខ្លាំង ការភ័យខ្លាចកើតមានជានិច្ច។ គឺពុំមានបទបញ្ជាណាក្រៅពីការខិតខំធ្វើការងារដោយពុំធ្វើឱ្យមានបញ្ហាអ្វីឡើយ។ ពាក្យទំនាស់ ការឈ្លោះគ្នា មានន័យថា "ខុសនឹងបដិវត្តន៍"។ អំពើនីមួយ១ទោះបីពុំមានន័យអ្វីក៏ដោយ ក៏អាចចាត់ទុកជាកំហុស និងត្រូវដាក់ទោសបានដែរ។ នៅក្នុងប្រព័ន្ធចាស់ គេបានស្វែងរកការសំរុះសំរួលគ្នាដើម្បីធ្វើឱ្យមានការព្រមព្រៀងគ្នា។ ចំណែក

ឯនៅក្នុងប្រព័ន្ធថ្មី គេខិតខំស្វែងរកអ្នកធ្វើកំហុសដើម្បីផ្តន្ទាទោសឬកំទេចចោល ដើម្បីបង្កើតសង្គមមួយស្អាតបរិសុទ្ធនិងរុងរឿង។ ប្រធានប្រើអំណាចផ្តាច់ការ។

"ចាប់ពីឆ្នាំ១៩៧០ នៅក្នុងភូមិគេបានប្តូរវិធីសាស្ត្រ។ កាលណាជនណាមានបញ្ហា មេភូមិបានធ្វើការសំរុះសំរួលគ្នា។ ប៉ុន្តែ គេពុំបានអញ្ជើញចាស់ទុំឱ្យមកចូលរួមទេ។ ការអនុវត្តន៍បែបថ្មីគឺ ធ្វើតាមសេចក្តីសំរេច របស់មនុស្សតែម្នាក់គឺប្រធាន។ គេត្រូវតែគោរពទៅតាមឋានន្តរសក្តិ។ កាលណាមេភូមិនិយាយអ្វីមួយគេ ត្រូវតែស្តាប់។ ប្រសិនបើយុំនិយាយផ្សេងទៅវិញ គឺសេចក្តីសំរេចរបស់អ្នកដែលមានឋានន្តរសក្តិខ្ពស់ជាង ត្រូវបានគេធ្វើតាម។ អ្នកនៅក្រោមត្រូវតែគោរពតាមដោយពុំត្រូវនិយាយអ្វីទាំងអស់។ ឧទាហរណ៍ ក្នុងករណីមានបញ្ហារវាងមនុស្សពីរនាក់ ប្រធានជាអ្នកនិយាយថា អ្នកនេះជាអ្នកមានកំហុស ហើយអ្នកនោះជា ស្លូតត្រង់។ ប្រសិនបើប្រធានខាងលើម្នាក់ទៀតនិយាយផ្ទុយទៅវិញ គឺគេត្រូវតែស្តាប់តាមអ្នកលើ គឺពុំមាន យុត្តិធម៌ទេ (... )។ ចាប់ពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៣ មនុស្សគ្រប់រូបអាចនិយាយស្តីបានដោយសេរី។ ក្រោយមក សេរីភាពមានកាន់តែតិចទៅៗ។ មនុស្សម្នាក់ៗកាន់តែមានសេចក្តីភ័យខ្លាចខ្លាំងឡើងៗ ហើយពុំចង់និយាយអំពីបញ្ហារបស់ខ្លួនឡើយ"។

(លោក ទិតអាយុ ៥៤ ឆ្នាំ អនុប្រធានភូមិ"អតីតខ្មែរក្រហម "សង្កាត់ពងទឹក ក្រុងកែប "ភូមិបង្កើតថ្មី" )

"នៅឆ្នាំ១៩៧១ ពួកខ្មែររំដោះបានចូលមកដល់ក្នុងភូមិ។ ការផ្លាស់ប្តូរបានចាប់ផ្តើមអនុវត្តន៍តាំងពីពេលនោះមក។ ភូមិនៅតែដដែល ប៉ុន្តែមានសមាគមមួយដែលបានចេញមកពីថ្នាក់លើដើម្បីធ្វើការឃោសនា នយោបាយ និងផ្តល់ពតិមានពីរណសិរ្សជួរមុខ។ នៅក្នុងពេលប្រជុំ គេបានប្រាប់ពួកយើងកុំឱ្យមានការខុសឆ្គង បើពុំនោះសោតទេ គេចោទថាបានប្រឆាំងបដិវត្តន៍។ មនុស្សគ្រប់រូបបានចាប់ផ្តើមមានការភ័យខ្លាចហើយពុំហ៊ាន និយាយអំពីបញ្ហារបស់ខ្លួនឡើយ។ គេមានការភ័យខ្លាចក្រែងធ្វើខុសនឹងត្រូវទទួលទោស។ គឺជាសង្គមផ្តាច់ការ។ នៅក្នុងពេលប្រជុំ គេបានធ្វើហាក់ដូចជាខំប្រឹងស្តាប់និងយកចិត្តទុកដាក់ចំពោះអ្វីដែលអ្នកដទៃបាននិយាយណាស់ ប៉ុន្តែតាមការពិតគេពុំបានស្តាប់សោះ។ នេះគឺគ្រាន់តែធ្វើកុំឱ្យមានបញ្ហាតែប៉ុណ្ណោះ។ ជារឿយៗ គេបានបង្កើតឱ្យ មាននាទីអប់រំសំរាប់រយៈពេលមួយថ្ងៃ ពីរថ្ងៃ ឬពីរសប្តាហ៍។ ក្រោយពីមានកំហុសច្រើនដងមក ជនមានកំហុសនោះត្រូវបានគេនាំយកទៅបាត់។ គេនិយាយថា "គេយកទៅរៀនសូត្រដើម្បីកុំឱ្យបង្កើតបញ្ហានៅពេលក្រោយ"។ អ្នកដែលបានទៅរៀនសូត្រ ពុំបានត្រឡប់មកវិញទេ។ ជននោះត្រូវបានគេសំលាប់ចោល។ គឺជាបទបញ្ជាដាច់ខាត។ ប្រសិនបើជនណាបានប្រព្រឹត្តខុសឆ្គង គេចោទថាជននោះជាខ្មាំង និងថាបានធ្វើការឃុបឃិតជាមួយរដ្ឋាភិបាល លន់ នល់

ដើម្បីបំផ្លាញបដិវត្តន៍។ ជនណាដែលបានលែងគោរបស់ខ្លួនឱ្យស៊ីដំណាំ ឬ ជនណាដែលខ្ជិលច្រអូស ត្រូវបានគេចាត់ទុកជាខ្មាំង។ ការដាក់ទោសគឺជាការអប់រំ។ អ្នកខ្លះបានចាកចេញទៅដើម្បីទទួលការអប់រំ។ អ្នកខ្លះបានត្រឡប់មកផ្ទះវិញ ហើយអ្នកខ្លះទៀតបានបិតនៅទីនោះរៀងរហូត។ ពួកខ្មែរក្រហមបានកត់ត្រាកំហុសទាំងអស់។ ពួកគេនិយាយថា អ្វីៗទាំងអស់ត្រូវបានចុះនៅក្នុងបញ្ជីទាំងអស់"។

(លោក សារុមអាយុ ៦២ ឆ្នាំអាចារ្យ វត្តភ្នំលាវ សង្កាត់ពងទឹក ក្រុងកែប)

"កំហុស គឺការមិនគោរពតាមបទបញ្ជា ការខ្ជិលច្រអូស ការមិនគោរពពេលវេលាធ្វើការ ការធ្វើពុតជាឈឺដើម្បីពុំទៅធ្វើការ និងមិនត្រូវនិយាយអ្វីទាំងអស់។ មនុស្សគ្រប់រូបមានសេចក្តីភ័យខ្លាចមិនហ៊ានធ្វើផ្តេសផ្តាស់ និងខ្លាចគេចោទប្រកាន់។ ពួកគេត្រូវនៅស្ងៀម"។

(លោក ទិតអាយុ ៥៤ ឆ្នាំអនុប្រធានភូមិ "អតីតខ្មែរក្រហម" សង្កាត់ពងទឹក ក្រុងកែប "ភូមិបង្កើតថ្មី")

"គេពុំនិយាយពីការសំរុះសំរួលទាស់តែសោះ កាលណាគេមានរឿងអ្វីមួយរវាងគ្នា និងគ្នា ។ អ្នកដែលជិតស្និទ្ធជាមួយខ្មែរក្រហម បានរាយការណ៍ពីអ្នកផ្សេងទៀតប្រាប់ទៅប្រធានភូមិ ហើយប្រធានភូមិសម្លាប់អ្នកទាំងនោះចោល។ ពួកខ្មែរក្រហម ពុំមានពេលវេលាសំរាប់គិតរឿងនោះទេ ពួកគេគិតតែពីចំបាំង។ អ្នកណាដែលបង្កើតបញ្ហាគឺជាសត្រូវ។ ជនណាដែលប្រឆាំងពួកខ្មែរក្រហមត្រូវបានចោទប្រកាន់ថាបានក្បត់បដិវត្តន៍។ នៅក្នុងភូមិថ្មី ខ្ញុំពុំមានដីដាំដំណាំទេ។ អ្នកណាបានស្គាល់មនុស្សនៅក្នុងភូមិអាចដាំដំណាំជាមួយពួកគេបាន បើពុំដូច្នោះទេ គេគ្មានអ្វីធ្វើឡើយ។ ភូមិដែលឋិតនៅក្នុងព្រៃ ត្រូវកងទ័ព លន់ នល់ ទំលាក់គ្រាប់បែក ពីព្រោះភូមិទាំងនោះ ឋិតនៅក្នុងតំបន់ដែលត្រួតត្រាដោយពួកខ្មែរក្រហម។ មានកើតទុរ្ភិក្ស។ គេបានធ្វើការផ្លាស់ប្តូរទីលំនៅកាលណា មានការទំលាក់គ្រាប់បែក។ នៅឆ្នាំ១៩៧៤ កងទ័ព លន់ នល់ ត្រូវបានវាយរុញច្រានទៅក្រោយវិញ ហើយគេអាចវិលត្រឡប់ទៅភូមិវិញបាន និងធ្វើការដាំដំណាំឡើងវិញ។ មួយឆ្នាំក្រោយមក ដីធ្លីរបស់យើងត្រូវបានប្រមូលដាក់រួម។ នៅចន្លោះឆ្នាំ១៩៧៤-១៩៧៥ ប្រធានភូមិបានចេញមកពីតំបន់ភ្នំ(ខាងលើ)។ គេពុំមានសិទ្ធិនិយាយជា មួយគាត់ឡើយ។ កាលណាជនណាម្នាក់មានបញ្ហា ហើយមេភូមិបានដឹងរឿងនោះ ជននោះនឹងបាត់ខ្លួនជាពុំខាន។ គេត្រូវនៅស្ងៀមស្ងាត់ដើម្បីកុំឱ្យមានរឿង និងកុំឱ្យគេសំលាប់ចោល។ និន្នាការជ្រុលនិយមបានកើតមានឡើងជាបណ្តើរៗចាប់តាំងពីឆ្នាំ១៩៧៣"។

(លោក សម្បត្តិអាយុ ៦១ ឆ្នាំមេភូមិ សង្កាត់អង្កោល ក្រុងកែប)

"កាលណាមានបញ្ហាកើតឡើងរវាងគ្នានិងគ្នា ពួកខ្មែរក្រហមយកអ្នកមានកំហុសចេញទៅ ហើយសំលាប់ជននោះដោយយកលេសថាពួកគេបានយកអ្នកមានកំហុសទៅធ្វើការអប់រំ។ នៅក្នុងស្រុកគេបាននិយាយថាមានបុស្តិ៍ និងពន្ធនាគាររបស់ពួកខ្មែរក្រហមជាច្រើន ប៉ុន្តែគេពុំដែលបានឃើញទាល់តែសោះ។ គេអាចធ្វើការដាក់ទោសមនុស្សចំពោះគ្រប់បញ្ហាទាំងអស់។ ឧទាហរណ៍ គេបានហាមមិនឱ្យធ្វើដំណើរតែម្នាក់ឯង។ គេធ្វើដំណើរជាក្រុម និងតាមទិសដែលអង្គការលើកំណត់។ គេមិនត្រូវដើរខុសផ្លូវរបស់អង្គការទេ បើពុំនោះសោតទេគេនឹងត្រូវទទួលទោស។ កាលណាប្រធានស្រុក ឬប្រធានឃុំបានដឹងអំពីជំលោះនៅក្នុងគ្រួសារមួយ ឬ ជំលោះរវាងមនុស្សដែលរស់នៅក្នុងភូមិគេបានធ្វើការសំរុះសំរួល។ ប្រសិនបើជំលោះបានបន្តទៅទៀត មនុស្សទាំងពីរត្រូវបានគេនាំយកទៅទីកន្លែងស្ងាត់កំបាំងមួយ។ នៅទីនោះ អ្នកទាំងពីរត្រូវទទួលការអប់រំអស់រយៈពេលមួយសប្តាហ៍។ កាលណាអ្នកទាំងពីរវិលត្រឡប់មកផ្ទះវិញ គេមានការភ័យខ្លាចណាស់ពីព្រោះគេត្រូវបានទទួលការគំរាមគំហែង។ ភូមិមានការផ្លាស់ប្តូរតិចតួចណាស់ ប៉ុន្តែគេមានការភ័យខ្លាច។ នៅពេលណាដែលប្រធានភូមិថ្មីជាមេខ្មែរក្រហម ធ្វើការសំរុះសំរួល គាត់ធ្វើការគំរាមគំហែងយ៉ាងខ្លាំង។ ឧទាហរណ៍ ប្រសិនបើគេឈ្លោះគ្នា មេខ្មែរក្រហមនិយាយថា យើងបានក្បត់អង្គការ មានន័យថាយើងបានប្រព្រឹត្តផ្ទុយនិងគោលការណ៍របស់អង្គការ ហើយដែលគេមិនត្រូវធ្វើឱ្យកើតមានជាថ្មីម្តងទៀតទេ។ គេមិនបានដឹងថា តើអង្គការមានន័យដូចម្តេចទេ?។ គេដឹងថាអង្គការមិនសំដៅមនុស្សទេ ហើយគេបានដឹងថាអង្គការមានន័យថាសេចក្តីស្លាប់ ប្រសិនបើគេបង្កើតបញ្ហា។ មានលទ្ធភាពពីរគឺ ស្លាប់ ឬ ជាប់ពន្ធនាគារ (នៅក្នុងវត្ត ឬ នៅក្នុងសាលា) ព្រះសង្ឃត្រូវបានឱ្យសឹកនៅឆ្នាំ ១៩៧៤"។

(លោក ឡុំ អាយុ ៥៣ ឆ្នាំសង្កាត់ពងទឹក ក្រុងកែប)

## ទស្សនៈរបស់ពួកខ្មែរក្រហម

អតីតកម្មាភិបាលខ្មែរក្រហម ចាត់ទុកថារបៀបថ្មីដែលផ្អែកលើការបង្ខិតបង្ខំ និងសេចក្តីភ័យខ្លាចជាមធ្យោបាយដ៏សំខាន់បំផុតដើម្បីធ្វើឱ្យបដិវត្តន៍ឈានទៅមុខ និងធ្វើការអភិវឌ្ឍន៍ប្រទេស។ នៅក្នុងសង្គមបែបប្រពៃណីមួយដែលមានការប្រុងប្រយ័ត្នក្នុងការថែរក្សាឯករាជភាព និងស្វ័យភាពរបស់ខ្លួន គំនិតថ្មីៗបានដាក់បង្គាប់នូវសញ្ញាណនៃរបៀបរបបសមូហភាព និងសាមគ្គីភាព។ កង្វល់ បញ្ហា និង ទំនាស់អន្តរបុគ្គល (រវាងបុគ្គល និងបុគ្គល) ត្រូវបានបំបិទ ឬត្រូវហាមឃាត់និងត្រូវដាក់ទោសដើម្បីជាគុណប្រយោជន៍ដល់សហគមន៍។

"អង្គការមានការតឹងតែងណាស់ ហើយល្អ។ ប្រសិនបើឈ្លោះគ្នា គេដាក់ទោសជននោះក្រោយពីព្រមានចំនួនបីដង។ មនុស្សមានការភ័យខ្លាច។ ទណ្ឌកម្មទាំងនោះពុំបានធ្វើអ្វីប្រជាជនទេ។ គឺជាទណ្ឌកម្មដើម្បីផលប្រយោជន៏ដល់សហគមន៏។ គឺជាការល្អ។ នៅសម័យនោះ គេបានធ្វើការប្រមូលផ្ដុំកំលាំងពលកម្មបានយ៉ាងងាយបំផុត។ ប្រសិនបើគេចង់កសាងផ្លូវថ្នល់ ឬទំនប់ទឹក គេហៅមនុស្សទាំងអស់ ហើយពួកគេធ្វើការរួមជាមួយគ្នា។ ការងារមានលក្ខណៈតឹងតែងណាស់ ប៉ុន្តែវាអនុញ្ញាតឱ្យអ្នកភូមិមានការរីកចំរើនឡើង។
គឺមានសាមគ្គីភាពរវាងមនុស្សគ្រប់រូប និងមានការឈ្លោះគ្នាតិចតួចណាស់។ ជនគ្រប់រូបមានការភ័យខ្លាចចំពោះបញ្ហា និងការហាមឃាត់។ អំពើដែលគេបានហាមឃាត់ភាគច្រើនគឺការមិនគោរពបទបញ្ជា។ ឧទាហរណ៏ ប្រសិនបើទិសដៅគេឱ្យជនណាម្នាក់រែកដីដប់បង្គី ហើយជននោះរែកបានតែប្រាំបីបង្គីនោះគឺជាកំហុស។ ធ្វើខុសម្ដង គឺត្រូវអប់រំម្ដង។ ចាប់ពីមានកំហុសបីដងនិងមានការអប់រំបីដងជាប់ៗគ្នាមក គឺត្រូវទទួលទណ្ឌកម្ម។ ទណ្ឌកម្មគឺ ត្រូវធ្វើឱ្យខ្លាច ប៉ុន្តែពុំមានប៉ះពាល់ដល់អាយុជីវិតរបស់មនុស្សឡើយ។

នៅក្នុងករណីធ្ងន់ធ្ងរខ្លះដូចជាការំលោភផ្លូវភេទលើនារីជាដើម គេបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ហើយពុំឱ្យមានការប្រព្រឹត្តខុសម្ដងទៀតឡើយ។ ការភ័យខ្លាច ការដាក់ទណ្ឌកម្មមានលក្ខណៈធំណាស់។ ប្រសិនបើមានការទាក់ទងទៅនិងសេចក្ដីស្នេហារវាងគូសង្សារជាយុវជន គេរៀបការឱ្យយុវជនទាំងនោះ។ ខ្ញុំបានទទួលបន្ទុកក្ដាប់យុវនារីមួយក្រុម។ យុវនារីដែលមានអាយុចាប់ពី ១៥ឆ្នាំឡើងទៅ ត្រូវបានប្រមូលផ្ដុំឱ្យរស់នៅជាមួយគ្នា។ ចាប់តាំង ពីឆ្នាំ១៩៧៣ ខ្ញុំជាប្រធានអង្គការនារីនៅក្នុងភូមិចំនួនបួន(ប្រធានយុវនារី)។ ខ្ញុំបានបង្រៀន យុវនារីទាំងអស់នោះឱ្យមានសាមគ្គីភាព ឱ្យចេះធ្វើការហត្ថកម្ម ហើយខ្ញុំបានបើកវគ្គអប់រំនយោបាយដើម្បីបង្រៀនយុវនារីទាំងនោះកុំឱ្យអ្នកដទៃមកធ្វើអាជីវកម្មពីលើខ្លួនបាន។

ខ្ញុំក៏បានពន្យល់អំពីរបបចាស់ ហើយខ្ញុំបាននិយាយអំពីអ្វីដែលល្អ និងអំពីអ្វីដែលអាក្រក់។ ខ្ញុំបានពន្យល់ថា កាលពីមុនមានអំពើហឹង្សានិងសង្គ្រាម។ បច្ចុប្បន្ននេះ គឺសន្តិភាពនិងសាមគ្គីភាពរវាងគ្នានិងគ្នា។ ខ្ញុំបាននិយាយទៅកាន់នារីទាំងនោះថា អាកប្បកិរិយាល្អគឺត្រូវស្ដាប់។ ការអប់រំមានរយៈពេលមួយថ្ងៃ បីថ្ងៃ ឬមួយសប្ដាហ៏។ គោលការណ៏សាមគ្គីភាពគឺល្អ។ គឺជាការរៀបចំមនុស្សដើម្បីឈានទៅរករបបសមូហភាព។ ប្រសិនបើមានជំលោះ រវាងអ្នកភូមិគេត្រូវនិយាយនៅពេលប្រជុំរួម ហើយគេនាំគ្នាផ្ដល់ការណែនាំ។ គេនិយាយតែពីអ្នកមានកំហុស[១០៨] ទេ។ ជួនកាលគេបាន

108 . គេបានសង្កេតឃើញថា គេពុំបានលើកឡើងពីជនរងគ្រោះទាល់តែសោះ។

ធ្វើការស៊ើបអង្កេតគ្នា។ ជនទាំងនោះស្តាប់។ នៅក្នុងពេលដំបូងនៃរបប លន់ នល់ មនុស្សម្នាទាំងអស់ពុំចង់យល់និងពុំស្តាប់ទេ។ ក្រោយមកគេបានចាប់ផ្តើមយល់ដឹង និងស្តាប់នៅក្នុងពេលមាននាទីអប់រំ។ ខ្ញុំពុំដឹងច្បាស់ទេថា តើមនុស្សទាំងអស់មានការយកចិត្តទុកដាក់អំពីអ្វីដែលបាននិយាយ ឬក៏ពួកគេមានសេចក្តីភ័យខ្លាចយើង និងភ័យខ្លាចការដាក់ទណ្ឌកម្មដែរឬទេ? ប៉ុន្តែគេអាចនិយាយបានថា នៅមុនឆ្នាំ១៩៧៣ មានការអភិវឌ្ឍន៍តិចតួច ហើយក្រោយមកគឺមានការអភិវឌ្ឍន៍។ (...)នៅចន្លោះឆ្នាំ១៩៧៣-១៩៧៥ ប្រសិនបើគេបានចោទប្រកាន់ជនណាម្នាក់ គឺប្រាកដជាជននោះបានប្រព្រឹត្តការខុសឆ្គងមែន។ យើងបានប្រជុំគ្នាដើម្បីនិយាយថា ជនណាឥតមានទោស និងជនណាដែលមានទោស(គេពុំភូតកុហកទេ)។ នៅឆ្នាំ១៩៧៩ អ្នកមានកំហុសអាចក្លាយទៅ ជាឥតមានកំហុស ហើយអ្នកឥតមានកំហុសក្លាយទៅជាមានកំហុសទៅវិញ។ គឺពុំសូវមានយុត្តិធមិទេ ហើយមានរឿងច្របូកច្របល់ច្រើនណាស់។ ចាប់តាំងពីឆ្នាំ១៩៧៣ មនុស្សមានភាពស្មើៗគ្នា។ កាលណាគេនិយាយរឿងអ្វីមួយ រឿងនោះគឺជាការពិត។ គឺពុំមានការលំអៀងទៅរកជនណាម្នាក់ឡើយ។ មនុស្សស្មើភាពគ្នានៅចំពោះយុត្តិធមិ។ ប្រសិនបើ សមាជិកគ្រួសារខ្ញុំម្នាក់មានកំហុស យើងហ៊ានបដិសេធ ឬបរិហារ។ ប្រសិនបើ សមាជិក គ្រួសារពុំបានធ្វើការបរិហារទេ អ្នកដទៃអាចធ្វើការបរិហារ ហើយសមាជិកគ្រួសារក៏ត្រូវទទួលទោសដែរ"។

(លោក អង់ អាយុ ៤៨ ឆ្នាំ (អតីតខ្មែរក្រហម)សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

អតីតកម្មាភិបាលខ្មែរក្រហមម្នាក់ទៀត បានអួតសរសើរអំពីប្រព័ន្ធថ្មីដែលមានយុត្តិធមិ ជាងប្រព័ន្ធចាស់ ។

"នៅមុនឆ្នាំ១៩៧០ ខ្ញុំជាសង្ឃនៅឈូក។ ខ្ញុំបានសឹកនៅខែមិថុនាឆ្នាំ១៩៧៥ ពីព្រោះខ្ញុំមានការធុញទ្រាន់ណាស់។ ខ្ញុំបានធ្វើដំណើរទៅភូមិកំណើត។ ពួកយៀកកុងបានច្បាំងជាមួយទ័ព លន់ នល់។ នៅពាក់កណ្តាលឆ្នាំ ១៩៧០ ពួកយៀកកុងបានកាន់កាប់ភូមិទាំងមូល។ មេភូមិ មេឃុំ មេស្រុកត្រូវបានផ្លាស់ចេញ។ គឺជាជនដែលរស់នៅទីនោះ។ ការនេះបានផ្លាស់ប្តូរចាប់តាំងពីឆ្នាំ១៩៧២-១៩៧៣។ ពួកខ្មែរក្រហមបានមកជំនួសពួកយៀកកុង។ នៅពេលនោះ គេបានចាប់ផ្តើមធ្វើការប្រជុំជាញឹកញាប់។ ការប្រជុំនេះធ្វើជំនួសការដោះស្រាយទំនាស់តាមបែបប្រព័ន្ធចាស់។ ប្រជាជនមានការស្រឡាញ់ប្រព័ន្ធថ្មីនេះ។ កាលពីមុន ប្រជាជនមានសេចក្តីភ័យខ្លាច។ គេខ្លាច មិនហ៊ាននិយាយស្តី។ គឺមានការសំឡុត ការគាបសង្កត់ពីអាជ្ញាធរ។ នៅក្នុងប្រព័ន្ធដែលមានការប្រជុំបញ្ហានានា ត្រូវបានធ្វើការជជែកពិភាក្សាដោយសេរី និងជាសាធារណៈ។ ឧទាហរណ៍ចំពោះបញ្ហាដីធ្លី គេបានធ្វើការជជែកពិភាក្សាបញ្ហាទាំងអស់គ្នា ម្នាក់ៗបានផ្តល់មតិរបស់ខ្លួន ហើយគេបានធ្វើការដោះស្រាយបញ្ហា។ គេនិយាយការ ពិត។ គ្មានជនណាម្នាក់ភូតកុហកឡើយ។

គេមានភាពស្មើៗគ្នា។ ជនណាដែលបានប្រព្រឹត្តខុសគេបាននិយាយថា "ខុសហើយ"។ កាលណាគេមើលឃើញអ្វីមួយដែលអាក្រក់គេនិយាយថា "មិនល្អ" កាលណាដែលគេមើលឃើញថាល្អគេនិយាយថា "ល្អ"។ គឺជាសាមគ្គីភាព គឺជារណសិរ្សរួបរួមជាតិកម្ពុជា។ គឺជាការល្អ ។ ក្រោយមក នៅឆ្នាំ ១៩៧៥ គឺមានការពិបាកឡើង"។
(លោក ក្រែម អាយុ ៥៤ ឆ្នាំមេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

ជាសង្គមមួយដ៏ប្រសើរ ដោយសារការធ្វើការងារ និងមិនបង្កើតឱ្យមានជំលោះ

"កាលណាមនុស្សមានទំនាស់ជាមួយគ្នា គេមិនប្រើរបៀបសំរុះសំរួលទេ គេធ្វើការប្រជុំរួម។ នៅកន្លែងដែលខ្ញុំរស់នៅ មនុស្សមានការរៀនសូត្រច្រើន ហើយគេបានចាត់ទុកថាគេមានសិទ្ធិស្មើគ្នាទាំងអស់។ ប្រធានៗនិយាយថា មនុស្សទាំងអស់មានសញ្ជាតិដូចគ្នា។ គេបានចែកដីធ្លីជាមួយអ្នកដែលទើបមកដល់ថ្មី (ប្រជាជនថ្មី)។ នៅក្នុងពេលប្រជុំ គេបានធ្វើការអប់រំប្រជាជនថ្មី។ គេបាននិយាយថា យើងត្រូវតែនិយាយពាក្យសំដីឱ្យបានល្អ។ គេបានធ្វើការណែនាំឱ្យប្រជាជនគិតតែពីការងារតែប៉ុណ្ណោះ។ គេបាននិយាយប្រាប់ប្រជាជនកុំឱ្យទៅបំរើរបប លន់ នល់។ អ្វីដែលសំខាន់បំផុតគឺ ខិតខំធ្វើការងារក្នុងផ្នែកកសិកម្ម ការសង់ទំនប់ទឹក និង ប្រព័ន្ធបង្ហូរទឹក។ នៅក្នុងរយៈពេលនេះ គឺពុំមានការឈ្លោះទាស់ទែងគ្នាទេ។ ដើម្បីបានរស់រានមានជីវិត គេពុំត្រូវនឹកគិតទៅដល់ការ ឈ្លោះទាស់ទែងគ្នាទេ"។ (លោក យុយ អាយុ ៥៦ ឆ្នាំអនុប្រធានឃុំ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

<u>បង្កើតឋានានុក្រមនៃស្ថានភាពមនុស្សដោយយោលទៅតាមជីវប្រវត្តិ</u>

នៅក្នុងសង្គមដែលហាក់ដូចជាមានភាពស្មើៗគ្នា ការរាប់រកមនុស្សអាចប្រែប្រួលទៅតាមប្រភេទមនុស្សដែលគេបានចាត់។ គេបានបង្កើតវណ្ណៈតាមឋានានុក្រម[១០៩]។ ការបែងចែក ស្ថានភាពមនុស្សប្រែប្រួលទៅតាមទីកន្លែងនិងប្រធានដែលក្តោបក្តាប់។ នៅក្នុងកន្លែងខ្លះគេបែងចែកអ្នកមានឱ្យដាច់ស្រឡះពីអ្នកក្រ នៅកន្លែងផ្សេង ទៀតគេបែងចែកអ្នកបំរើបុព្វហេតុខ្មែរក្រហមជាយូរមកហើយ ឱ្យដាច់ពីប្រជាជនថ្មីដែលភៀសខ្លួនមកពីតំបន់ដែលមានការប្រយុទ្ធគ្នា។ នៅកន្លែងដទៃទៀត គេបានកំណត់ប្រភេទប្រជាពលរដ្ឋពីកម្មករឥតមានដីធ្លីរហូតដល់អ្នកមានជាម្ចាស់កម្មសិទ្ធិដីធ្លី។ នៅទីបញ្ចប់ នៅកន្លែងខ្លះ ភាពខុសគ្នារវាងប្រជាពលរដ្ឋ ពុំគួរឱ្យកត់សំគាល់ប៉ុន្មានទេ។ វិធីប្លែកគេក្នុងការចាត់មនុស្សមានការប្រែប្រួលទៅតាមវណ្ណៈមនុស្ស។ ប្រសិនបើជនណាម្នាក់បានប្រព្រឹត្តខុសគន្លង បើជននោះនៅក្នុងវណ្ណៈអ្នកក្រីក្រ គេអាចអូសទាញ

[109] . វណ្ណៈគឺជាជាន់ថ្នាក់។ គេបាននិយាយថា វណ្ណៈថ្នាក់លើនិងវណ្ណៈថ្នាក់ក្រោម។

មកវិញដោយគ្រាន់តែអប់រំបែបឃោសនា។ ចំណែកជនដែលនៅក្នុងវណ្ណៈអ្នកមាន ឬប្រជាជនថ្មីអាច ប្រឈមមុខនឹងសេចក្ដីស្លាប់។

"ប្រជាពលរដ្ឋត្រូវបានចែកជាបួនវណ្ណៈគឺ កសិករក្រ កសិករមធ្យម កសិករថ្នាក់លើ និងអ្នកមាន។ ក្នុងករណីមានបញ្ហារវាងប្រជាពលរដ្ឋ វិធីបែបថ្មីអនុគ្រោះដល់កសិករទាំងបីវណ្ណៈដំបូង។ គេនិយាយថាពួកអ្នកមាន មានកំហុសជាញឹកញាប់។ គេតែងមានការសង្ស័យលើពួកអ្នកមានជានិច្ច។ គេនិយាយថា ពួកអ្នកមាន មានដោយសារតែកេងប្រវ័ញ្ចមនុស្ស។ ពួកអ្នកមានត្រូវបានទទួលការដាក់ទោសជាញឹកញាប់ ជាងអ្នកដទៃទៀត។ ការបែងចែកវណ្ណៈនេះមានការប្រែប្រួលទៅតាមតំបន់ ទៅតាមប្រធាន និងទៅតាមពេលវេលា។ ដូចនេះ នៅទីនោះ ខ្ញុំឋិតនៅក្នុងក្រុមវណ្ណៈអ្នកក្រីក្រ ប៉ុន្តែនៅក្នុងខេត្តកណ្ដាល ខ្ញុំអាចឋិតនៅក្នុងក្រុមវណ្ណៈមធ្យម។ នៅក្នុងទីកន្លែងផ្សេងទៀត គឺពុំមានការបែងចែកវណ្ណៈទេ។ ដល់ឆ្នាំ ១៩៧៣ គឺពុំទាន់តឹងតែងនៅឡើយទេ។ នៅឆ្នាំ ១៩៧៣ គេបានប្រមូលដីធ្លីដាក់ជាកម្មសិទ្ធិរួម និង បានលុបបំបាត់ក្រដាសប្រាក់។ នៅឆ្នាំ១៩៧៤ គេបានរៀបចំឱ្យប្រជាពលរដ្ឋហូបបាយរួមគ្នា នៅរោងបាយរបស់សហករណ៍។ ដល់ឆ្នាំ១៩៧៥ កងទ័ព(យោធា) អាចធ្វើដំណើរទៅសាកសួរសុខទុក្ខគ្រួសាររបស់ខ្លួនបាន។ នៅដើមឆ្នាំ១៩៧៣ បទបញ្ជាពុំទាន់មានលក្ខណៈតឹងតែងទេ ហើយកិច្ចការចេះតែមានដំណើរការទៅមុខ។ ចាប់ពីឆ្នាំ១៩៧៥ មកគឺកាន់តែតឹង អ្នកគ្មានទោសនិងអ្នកមានទោសត្រូវតែទទួលយកការវិនិច្ឆ័យ ដោយពុំមានប្រកែកអ្វីឡើយ"។

(លោក ទិត អាយុ ៥៤ ឆ្នាំអនុប្រធានភូមិ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត (ភូមិបង្កើតថ្មី))

"នៅឆ្នាំ ១៩៧០ មានការប្រយុទ្ធគ្នា។ យើងបាននាំគ្នារត់ទៅក្រុងកែប ដោយមានយករទេះ និងអង្ករទៅជាមួយ។ ដោយសារយើងពុំមានការងារ ពុំមានប្រាក់កាសសំរាប់ទិញអង្ករ យើងក៏ធ្វើដំណើរទៅស្រុកស្រែចំការផ្សេងទៀត។ នៅគ្រប់ដំណាក់នៃការឈប់សំរាក យើងបានសង់កូនខ្ទមតូចមួយនៅក្រោមដើមឈើ។ នៅភូមិរនើង ឪពុកខ្ញុំបានធ្វើជាកម្មករនៅចំការម្រេច។ គាត់បានរែកដី។ យើងមានការភ័យខ្លាចណាស់។ យើងជាប្រជាជនថ្មី ហើយឪពុកខ្ញុំបានគិតថា អ្នកភូមិនឹងសំលាប់គាត់ជាពុំខាន។ គេនាំគ្នាធ្វើការងាររួមគ្នានៅក្នុងចំការ។ ពួកគេគឺជាពួកខ្មែរក្រហម។ គេបានហៅពួកយើងថា ជាជនភៀសខ្លួន។ យើងពុំហ៊ានធ្វើអ្វីទាំងអស់ ដោយភ័យខ្លាចមានការ កត់សំគាល់ពីមេភូមិ។ ពួកគេអាចសំលាប់យើង។ ជាពិសេស នៅពេលយប់គេមកហៅយើង ហើយបន្ទាប់មកគេសំលាប់យើងគឺចប់ហើយ។ មានប្រជាជនមូលដ្ឋាន និងជនភៀសខ្លួនរស់នៅជាមួយគ្នា។ យើងត្រូវចូលរួមប្រជុំគ្រប់ពេល ហើយយើងបានទទួល

អង្ករ។ ពួកមូលដ្ឋានបានទទួលអង្ករច្រើនជាងពួកយើងគឺមួយកំប៉ុងក្នុងម្នាក់ៗ។ យើងដែលជាជនភៀសខ្លួន ពួកយើងមានចំនួនដប់គ្រួសារដែលជាសាច់ញាតិនឹងគ្នា។ យើងមានការភ័យខ្លាចណាស់។ ពួកមូលដ្ឋានពុំមានការភ័យខ្លាចមេភូមិឡើយ"។

(លោកស្រី សូម៉ាលី អាយុ ៤៨ ឆ្នាំសង្កាត់កែប ខ័ណ្ឌកែប ក្រុងកែប)

<u>លក្ខណៈនៃការរស់នៅមានការប្រែប្រួលទៅតាមទីកន្លែង</u>

នៅក្នុងទីកន្លែងផ្សេងទៀត លក្ខណៈនៃការរស់នៅពុំមានការលំបាកប៉ុន្មានទេ។ លក្ខណៈបែបនេះ ភាគច្រើនមាននៅទីកន្លែងដែលដាច់ឆ្ងាយពីគេ ហើយដែលអាជ្ញាធរពុំសូវមានវត្តមាន ឬមួយជាទីកន្លែងដែលមេៗត្រូវបានអ្នកភូមិចូលចិត្ត។ របបចាស់ ការបង់ប្រាក់ពន្ធនិងអាករត្រូវលុបបំបាត់ចោល។ ប្រជាកសិករបានបន្តដាំដំណាំនៅលើដីចំការរបស់ខ្លួនផ្ទាល់។ ក្នុងករណីត្រូវការចាំបាច់។ កសិករអាចហៅអ្នកដទៃឱ្យជួយគាត់។ គោក្របីត្រូវបានប្រមូលដាក់រួមដើម្បីធ្វើការងារស្រែចំការ និងការដឹកជញ្ជូន។ កសិករសំរបខ្លួនបានគួរសមជាមួយរបបថ្មី ប្រសិនបើប្រធានៗចេះសំរបសំរួល។ ប្រជាកសិករបានរស់រានមានជីវិតនៅពេលដែលគេចេះដាក់ខ្លួន និងចូលរួមប្រជុំដើម្បីស្តាប់ការឃោសនា។ គូសន្ទនាជាច្រើនរូបបានបញ្ជាក់យ៉ាងច្បាស់អំពីភាពខុសគ្នារវាងក្រុមខ្មែរក្រហមមុន និងក្រុមខ្មែរក្រហមដែលចូលមកនៅក្រោយឆ្នាំ១៩៧៥។

"ប្រធានៗមានលក្ខណៈខុសៗគ្នាដោយយោលទៅតាមទីកន្លែង។ គឺមានកន្លែងស្រួលដែលប្រជាជនបានបរិភោគបាយ និងមានកន្លែងខ្លះទៀតពិបាក ដែលប្រជាជនបរិភោគតែបបរ"។

(លោក ប៉ែត អាយុ ៧១ ឆ្នាំឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"ជាដំបូងមានដំណើរការល្អ។ មេៗល្អ។ គាត់បាននិយាយថា យើងមានសិទ្ធិស្មើៗគ្នាទាំងអស់។ យើងចូលចិត្តគំនិតរបស់គាត់ហើយយើងត្រៀមធ្វើការជានិច្ច។ គឺជាការល្អ។ បន្ទាប់មក ប្រធានល្អៗត្រូវបានគេសំលាប់ចោល ហើយហេតុការណ៍នេះបាននាំឱ្យមានការលំបាក។ ចាប់តាំងពីដំបូងរហូតដល់ឆ្នាំ១៩៧៥ និងក៏ដូចជានៅឆ្នាំ ១៩៧៧[១១០] អ្វីៗបានប្រព្រឹត្តទៅតាមធម្មតា។ យើងអាចទ្រាំទ្របាន។ ក្រោយមកគេបានចាប់ផ្តើមសំលាប់ប្រជាជនទាំងអស់។ មនុស្សល្អៗត្រូវគេសំលាប់ចោល។ មានតែជនពួកកាចៗទេដែលអាចរស់នៅតទៅទៀត បាន"។

(លោក ក្រាច់ អាយុ ៨៦ ឆ្នាំ ឃុំបន្ទាយស្រី ស្រុកបន្ទាយស្រី ខេត្តសៀមរាប)

"រហូតដល់ឆ្នាំ១៩៧៥ គឺពុំទាន់មានការលំបាកទេ។ គឺពុំទាន់មានប្រជាជនស្លាប់ច្រើនទេ។ មានតែមនុស្សដែលមកពីរបប លន់ នល់ ទេដែលត្រូវបានសំលាប់ចោល។ នៅពេលនោះគឺពុំទាន់មាន

---

110 . ការបោសសំអាតទ្រង់ទ្រាយធំចាប់តាំងពីឆ្នាំ១៩៧៧ ជាពិសេសនៅក្នុងជួរកម្មាភិបាលខ្មែរ ក្រហមដែលសង្ស័យថាបានធ្វើសម្ព័ន្ធភាពជាមួយពួកយៀក មិញ ឬដែលបានប្រឆាំងជាមួយវិធីរបស់ ពួកប៉ុល ពត ដែលពួកគេបានចាត់ទុកថាមានលក្ខណៈហួសហេតុពេក។

រោងបាយរួមនៅឡើយទេ។ យើងបានបរិភោគគ្រប់គ្រាន់។ យើងគ្រាន់តែមានការភ័យខ្លាចពីការទំលាក់គ្រាប់បែកនៃយន្តហោះរបស់លោក លន់ នល់"។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំមេឃុំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## ការភ័យខ្លាចនិង ការបង្ខិតបង្ខំជាមធ្យោបាយសំរាប់ត្រួតប្រជាពលរដ្ឋ

នៅក្នុងបរិបទដំបូងនៃការធ្វើសមូហកម្ម ការប្រជុំស្វ័យទិតៀននិងការដាក់ទោសគឺជាការបង្ខិតបង្ខំនិងជាការភ័យខ្លាចដែលបានបង្កកុំឱ្យមានបញ្ហា និងទំនាស់នានា។

"កាលពីមុនមានកើតបញ្ហាតិចតួចទេ មានការឈ្លោះទាស់ទែងគ្នាតិចតួចរវាងប្រជាជននៅក្នុងសម័យនោះ។ គឺជាសម័យកាលដែលប្រជាជនមានការជឿទុកចិត្តច្រើនទៅលើរបប ប៉ុល ពត។ ប្រជាជនមានសេចក្តី សង្ឃឹមនិងឆន្ទៈច្រើន។ គេមិនបានគិតពីការបង្កើតបញ្ហាទេ។ កាលពីដំបូងដីធ្លីនៅតែជាកម្មសិទ្ធិឯកជន។ ក្នុងសម័យសង្គមរាស្ត្រនិយម ទំនាស់រវាងប្រជាពលរដ្ឋមានច្រើនណាស់ដោយសារតែបញ្ហាដីធ្លី។ ប្រជាពលរដ្ឋមានលិខិតស្នាមបញ្ជាក់អំពីដីធ្លី ហើយបានឈ្លោះទាស់ទែងគ្នាជានិច្ច។ ប្រជាពលរដ្ឋបានបង់ប្រាក់ពន្ធអាករយ៉ាងច្រើនជូនរដ្ឋាភិបាល។ ចាប់តាំងពីឆ្នាំ១៩៧០ មកគឺពុំមានការបង់ប្រាក់ពន្ធអាករ និងលិខិតស្នាមដីធ្លីទៀតឡើយ។ អង្គការបានខ្ចីប្រាក់ជាច្រើនពីអ្នកមានដោយឱ្យការប្រាក់កំរិតទាបបំផុត។ អង្គការបានយកប្រាក់នោះទៅទិញក្រណាត់ ប្រេងឥន្ទនៈ...។ អ្នកភូមិអាចទិញទំនិញទាំងនោះ។ ប្រាក់ដែលលក់បានអង្គការបានយកទៅសងម្ចាស់បំណុលវិញ។ ប្រជាពលរដ្ឋស្រលាញ់ប្រពន្ធ័នេះ។ ចាប់តាំងពីឆ្នាំ១៩៧០មក គេបានធ្វើការប្រជុំរួម។ ការប្រជុំនេះបានដោះស្រាយបញ្ហានិងរឿងទាំងអស់ដូចជាការឈ្លោះគ្នាទំនាស់ប្តីប្រពន្ធ បញ្ហារវាងអ្នកមាននិងអ្នកក្រ។ គេបានសាកល្បងធ្វើការរួមប្រជុំគ្នារវាងអ្នកមាននិងអ្នកក្រ ដើម្បីធ្វើឱ្យពួកគេមានសាមគ្គីគ្នា។ ជនណាដែលពុំយល់អំពីបញ្ហានេះ ត្រូវទទួលការអប់រំ។ កាលណាមានការឈ្លោះគ្នា រឿងរ៉ាវទាំងអស់ត្រូវបានយកទៅជជែកនៅក្នុងពេលប្រជុំ។ ជនណាដែលមានកំហឹងខ្លាំងបានប្តឹងតវ៉ាដល់មេភូមិ។ ប៉ុន្តែមនុស្សមានការខ្មាស់អៀន ហើយពុំចង់និយាយទេ។ គេបានធ្វើការស្រាវជ្រាវ ហើយគេបានរកឃើញជនដែលបានធ្វើខុស ។ ការអប់រំគឺជាការព្រមានលើកទីមួយ។ ក្រោយពីធ្វើការព្រមានលើកទីបីមក បញ្ហានោះត្រូវបានបញ្ជូនទៅថ្នាក់លើទៀត ហើយគេបានតាមដានបន្តទៅទៀត។ កាលណាជនណាមានបញ្ហា គេសុខចិត្តនៅស្ងៀមមិននិយាយអ្វីទេ។ ចំណែកឯអ្នកជិតខាងក៏ពុំហ៊ានធ្វើ អ្វីដែរ"។

(លោក គ្រែម អាយុ ៥៦ ឆ្នាំ អនុប្រធានឃុំ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក (ភូមិបង្កើតថ្មី))

"គឺមានការលំបាករកស៊ីចិញ្ចឹមជីវិតណាស់នៅក្នុងរបបសម្តេចសីហនុ ប៉ុន្តែអ្វីៗចេះតែអាចទៅមុខជានិច្ច។ ចាប់តាំងពីឆ្នាំ១៩៧០មក គេបានធ្វើរណសិរ្សរួបរួមជាតិ។ មេភូមិនិង មេឃុំជាច្រើនត្រូវ

បានផ្លាស់ចេញ។ មេភូមិនិងមេឃុំជាច្រើនជាអនក្ខរជន។ ពួកហាណូយបានធ្វើការអប់រំជនទាំងនោះ។ ការនោះបានចាប់ផ្ដើមមានការប្រែប្រួល។ គេបានបង្កើតក្រុមធ្វើការងារក្រុមជួយគ្នាទៅវិញទៅមក ក្រុមសាមគ្គីរណៈសិរ្សរួបរួមជាតិ។ គេបានធ្វើការអប់រំមនុស្សដើម្បីឱ្យចេះជួយគ្នាទៅវិញទៅមក។ ការឈ្លោះគ្នាត្រូវបានហាមឃាត់។ គេបាននិយាយប្រាប់ប្រជាពលរដ្ឋថា ជនណាដែលបានធ្វើឱ្យមានបញ្ហានឹងត្រូវបញ្ជូនទៅតំបន់ភ្នំម្ហូ។ នៅទីនោះគេត្រូវតែធ្វើការងារ ធ្វើស្រែចំការ។ ជនខ្ជិលច្រអូសបានរកលេសថា ឈឺក្បាលដើម្បីគេចវេសមិនទៅធ្វើការងារ។ ពួកគេនៅផ្ទះនិងហូបបាយ។ ជនណាដែលខ្ជិលច្រអូសត្រូវបានបញ្ជូនទៅភ្នំម្ហូនិងមានប្រធានមួយរូបបានអប់រំជនទាំងនោះ។ មួយខែ ឬពីរខែក្រោយមក ទើបជនទាំងនោះបានវិលត្រឡប់មកផ្ទះវិញ ។ ក្រោយពីបានទទួលការព្រមានចំនួនបីដងមក ជនដែលមានការខ្ជិលច្រអូស និងជនទាំងឡាយដែលមិនគោរពតាមបទបញ្ជា ត្រូវបានបញ្ជូនទៅលើ។ នៅឯលើ គឺពុំមានការអប់រំទេ គឺមានតែធ្វើការងារ។ គេនិយាយថា "គេនឹងប្រគល់ស្លាបប៉ាកការមួយឱ្យ" តែតាមការពិតគេបានឱ្យចបកាប់មួយទៅឱ្យជនទាំងនោះ។ កាលណាចបកាប់នោះប្រើលែងកើត គេផ្ដល់ចបកាប់ឱ្យមួយទៀត "ពី ព្រោះគេអស់ទឹកខ្មៅហើយ"។ ជនទាំងនោះមានការភ័យខ្លាច ហើយមិនហ៊ានធ្វើការតវ៉ាទេ។ គេពុំបានគិតអំពី យុត្តិធម៌ទេ គេគិតតែពីបង្ខំមនុស្សឱ្យធ្វើការ។ ក្រោយពីបញ្ជូនទៅភ្នំម្ហូ អ្នកដែលមិនរាងចាលត្រូវបានបញ្ជូនទៅកំពង់ស្ពឺ ស្រែខ្ទុង និងរលាក់កងជើងដែលឋិតនៅជិតភ្នំឱរ៉ាល់។ កាលណាជនទាំងនោះបានទៅដល់តំបន់នោះ ពួកគេ ត្រូវស្លាប់ដោយសារជំងឺគ្រុនចាញ់។ ចំពោះជនណាដែលបានធ្វើការល្អ នៅក្នុងក្រុមសាមគ្គីគឺអ្វីៗក៏ប្រព្រឹត្តទៅបានល្អដែរ។ គេត្រូវតែមានការប្រុងប្រយត្ន័នៅលើខ្លួនឯងផ្ទាល់និងធ្វើការកសាងខ្លួនឯង។ ជនទាំងឡាយណាដែលបានធ្វើការកសាងខ្លួនឯងបានល្អ ត្រូវបានពួកខ្មែរក្រហមធ្វើការកោតសរសើរ។ នៅក្នុងពេលប្រជុំគេបានហៅប្រជាជនឱ្យឡើងនិយាយអំពីខ្លួនឯង។ ម្នាក់ៗបានលើកអំពីកំហុសខ្លួនឯង ហើយបន្ទាប់មកស្ដាប់ការណែនាំរបស់អ្នកដទៃ។ ការធ្វើរបៀបនេះគេហៅថាស្វ័យទិតៀន។ ឧទាហរណ៍ គេនិយាយថា "ខ្ញុំបានធ្វើកំហុសជាច្រើន ខ្ញុំសុំឱ្យអ្នកទាំងអស់គ្នាថ្កោលទោសខ្ញុំចុះ"។ អ្នកដទៃបាននិយាយថា "ទេ គឺខ្លួនអ្នកទេដែលត្រូវនិយាយអំពីកំហុស របស់អ្នក"។ ដូចនេះ ជនដែលឡើងធ្វើស្វ័យទិតៀនបាននិយាយថា "គ្មានអ្នកណាម្នាក់បានឃើញខ្ញុំលួចនិងបាន ឮខ្ញុំជេរគេទេ។ គ្មានជនណាម្នាក់ដឹងថា ខ្ញុំបានប្រព្រឹត្តខុសទេ។ ចំណែកខ្លួនខ្ញុំ ខ្ញុំសូមសារភាពថា ខ្ញុំបានធ្វើខុស។ សូមអ្នកទាំងអស់គ្នាកុំធ្វើត្រាប់តាមខ្ញុំ ហើយចាប់តាំងពីពេលនេះតទៅ ខ្ញុំនិងមិនប្រព្រឹត្តឱ្យខុសម្ដងទៀតឡើយ"។ ឧទាហរណ៍ នៅពេលធ្វើការប្រជុំលើកមុន គេបាននិយាយថា មានបញ្ហាចំនួនបីនៅក្នុងកម្មវិធីៈ ទីមួយគឺ ការកសាង ផ្លូវថ្នល់ទីពីរគឺ ការធ្វើស្វ័យទិតៀន និងទីបីគឺ ការដាំដំណាំ។

ពេលខ្លះមានមួយបញ្ហា ពេលខ្លះទៀតមានប្រាំបញ្ហា គឺតែងមានការប្រែប្រួល។ គេមានទិសដៅប្រចាំថ្ងៃឧទាហរណ៍ ការកសាងផ្លូវរហូតដល់ទីកន្លែងណាមួយ ឬការធ្វើបង្គិឱ្យបានច្រើន។ ប្រសិនបើគេពុំអាចអនុវត្តន៍ទិសដៅប្រចាំថ្ងៃបានទេ គេត្រូវតែបន្តធ្វើនៅពេលយប់ទៀត។ អ្នកបានប្រព្រឹត្តខុសគឺជាអ្នកខ្ជិលដែលមិនអាចសំរេចទិសដៅបាន។

ជួនកាល ការងារខ្លះងាយស្រួយជាងកាលនៅសម័យសង្គមរាស្ត្រនិយម ហើយជួនកាលពិបាកជាងកាលពីសម័យសង្គមរាស្ត្រនិយម។ ពិបាកព្រោះគេពុំអាចដើរហើរដោយសេរីបាន។ ប្រសិនបើគេបានធ្វើដំណើរទៅទីផ្សារ (ទីក្រុង) នៅពេលត្រឡប់មកវិញ គេអាចមានការសង្ស័យថា យើងជាគិញរបស់ លន់ នល់។ គេពុំអាចធ្វើដំណើរ ទៅលក់ពងមាន់ ពងទា និងស្លឹកគ្រៃនៅទីផ្សារបានទាល់ទៀតទេ។ គេចោទប្រកាន់យើងថា ជាខ្មាំងសត្រូវ និងជា អ្នកផ្តល់ពត៌មានឱ្យ លន់ នល់។ អ្វីដែលល្អគឺ សាមគ្គីភាពរវាងប្រជាពលរដ្ឋគ្នាឯង។ គឺពុំមានការឈ្លោះគ្នា ដូចកាលពីសម័យមុនទេ។ កាលពីសម័យមុន មនុស្សម្នាក់ៗគិតតែខ្លួនឯង ក្រោយមកមនុស្សគ្រប់រូបគិតតែពីធ្វើស្រូវ។ កាលណាអ្នកក្រីក្រពុំមានអ្វីបរិភោគទេ គេត្រូវតែធ្វើការទាំងអស់គ្នា។ គឺពុំមានវណ្ណៈទេ គេនិយាយ តែពីការធ្វើការងារនិងសមភាព។ ជនអ្នកមានបានរក្សាទុកគោនិងស្រូវអង្ករបស់ខ្លួន។ គ្រួសារអ្នកក្រីក្រអាច ខ្ចីស្រូវអង្ករបស់អ្នកមាន។ សម្តេច សីហនុ បានគង់នៅទីក្រុងប៉េកាំង។ ព្រះអង្គមានព្រះបន្ទូលតាមវិទ្យុថា ដើម្បីបានរស់គឺ ត្រូវជួយគ្នាទៅវិញទៅមក គឺត្រូវបង្កើតក្រុមសាមគ្គី។ ប្រជាពលរដ្ឋទាំងអស់បានធ្វើតាមព្រះអង្គ។ ព្រះអង្គមានតួនាទីយ៉ាងសំខាន់នៅក្នុងការឃោសនានយោបាយ។ ប្រជាពលរដ្ឋមានជំនឿទុកចិត្តទៅលើព្រះអង្គ ហើយបានធ្វើតាមបន្ទូលព្រះអង្គជានិច្ច"។

(លោក ពូនអាយុ ៦០ ឆ្នាំមេភូមិ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

"មានការប្រជុំជាច្រើន។ ប្រជាពលរដ្ឋខ្លាចមេភូមិ។ គាត់បានដាក់ខ្នោះអ្នកណាដែលមិនបានចូលរួមនៅក្នុងការធ្វើការងាររួមជាមួយអ្នកដទៃ(...)។ គឺពុំមានការឈ្លោះគ្នានិងពុំមានទំនាស់ទៀតទេ ពីព្រោះប្រជាជនខ្លាច។ គេធ្វើការប្រជុំនយោបាយដើម្បីអប់រំប្រជាពលរដ្ឋ និងដើម្បីកុំឱ្យប្រជាពលរដ្ឋចូលដៃខ្មាំងសត្រូវ"។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំមេឃុំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅឆ្នាំ១៩៧២ ប្រជាពលរដ្ឋត្រូវបានបញ្ជូនទៅតាសៀវ មានប្រធានមួយរូបចាំត្រួតមើលប្រជា-ពលរដ្ឋដែលធ្វើការនៅក្នុងស្រែ។ ទិសដៅគឺធ្វើស្រែ។ នៅសម័យនោះ ការឈ្លោះទាស់ទែងគ្នានិងទំនាស់ពុំមានទេ ព្រោះមនុស្សខ្លាច។ (...)គេពុំអាចស្រឡាញ់គ្នាដោយលួចលាក់ទេ ពីព្រោះ

អាក្រក់មើលណាស់ គឺត្រូវសំលាប់ចោល។ មានការរៀបចំអាពាហ៍ពិពាហ៍រួមគ្នាដោយមានចំនួនដប់គូរ ឬលើសពីចំនួននេះក៏មានដែរ។ អាពាហ៍ពិពាហ៍ដែលអង្គការរៀបឱ្យដូច្នេះគឺល្អ។ យុវនារីមានការអប់រំគេមិនអាក្រក់ទេ។ ពួកគេចេះស្តាប់បង្គាប់"។

(លោក ប៉ែត អាយុ ៧១ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"ដីធ្លីឋិតនៅជាកម្មសិទ្ធិឯកជនរហូតដល់ឆ្នាំ១៩៧៤។ ប្រជាពលរដ្ឋបានត្រៀមនៅឆ្នាំក្រោយនឹងមានសហករណ៍មួយហើយ។ ពាក្យចចាមអារាមដែលចេញមកពីទាហានខ្មែរក្រហមក៏បាននិយាយផងដែរថា ប្រជាពលរដ្ឋនឹងបរិភោគបាយរួម ប៉ុន្តែអាចរស់នៅជាគ្រួសារដោយឡែកពីគ្នា។ កម្មាភិបាលបានប្រើអំណាចផ្តាច់ ការរួចទៅហើយ១ប្រជាពលរដ្ឋខ្លាចកម្មាភិបាលទាំងនោះ។ ប្រជាពលរដ្ឋមិនបង្ហាញឱ្យឃើញថា ពួកគេមានបញ្ហាទេ ពួកគេបានលាក់ទុកបញ្ហានានាដោយស្ងាត់កំបាំងបំផុត ហើយក៏មិនបញ្ចេញរឿងរបស់ខ្លួននៅចំពោះមុខមនុស្ស ទាំងអស់ដែរ។ ប្រធានភូមិបានរៀបចំការប្រជុំមួយដងក្នុងមួយសប្តាហ៍ ឬមួយដងក្នុងពីរសប្តាហ៍។ គាត់បានហៅប្រជាពលរដ្ឋនៅភូមិទាំងអស់ឱ្យមកប្រជុំ។ គាត់បាននិយាយថា នេះគឺជាពេលវេលាមួយល្អសំរាប់បងប្អូននិយាយ (មានយោបល់)។ ប៉ុន្តែប្រជាពលរដ្ឋបានដឹងថា មិនត្រូវនិយាយច្រើនពេកទេដើម្បីកុំឱ្យមានបញ្ហា។ ជនណាបានធ្វើកំហុសត្រូវបានថ្កោលទៅ។ គេនិយាយថា ជនទាំងនោះជាភ្នាក់ងាររបស់អាមេរិក(CIA)។ ជនណាដែលបានធ្វើការតវ៉ាពីរឿងដីធ្លីត្រូវគេស្តីប្រដៅ។ គេចាត់ទុកជនទាំងនោះថា ជាពួកមូលធន។ គេត្រូវតែនៅស្ងៀមដើម្បីបានរស់។ គេបានស្នើសុំឱ្យប្រជាពលរដ្ឋនៅស្ងៀមស្ងាត់រៀងរាល់ពេល លើកលែងតែពេលធ្វើស្វ័យទិតៀន។ ពុំមានបទបញ្ជាច្បាស់លាស់ទេ គឺមានតែកំហុស។ គឺជាច្បាប់ដែលចេញមកពីបបូរមាត់។ ប្រសិនបើគេនិយាយថា: "នៅទីនោះគេមិនត្រូវកាប់មែកឈើទេ" ប្រសិនបើអ្នកណាកាប់មែកឈើ អ្នកនោះមានកំហុស។ តាមការពិតច្បាប់ គឺជាការគោរពបទបញ្ជា។ គេបានឮគេនិយាយអំពីច្បាប់របស់ពួកខ្មែរក្រហម ប៉ុន្តែគេពុំដែលបានឃើញច្បាប់នោះ ទាស់តែសោះ។ គេបានឮគេនិយាយអំពីរដ្ឋធម្មនុញ្ញ ប៉ុន្តែគេពុំដែលបានឃើញរដ្ឋធម្មនុញ្ញនោះទេ។ ការអប់រំគឺសំរាប់ ធ្វើការកែប្រែប្រជាជន។ គេត្រូវហូបតិច តែធ្វើការច្រើន។ នេះគឺជាការអប់រំ។ ចាប់តាំងពីឆ្នាំ១៩៧៤មកនៅពេលដែលការប្រយុទ្ធគ្នាត្រូវបានបញ្ចប់នៅទីនេះ គេបានចាប់ផ្តើមសំលាប់មនុស្សដោយសារប្រវត្តិរូបរបស់ជនទាំងនោះ។ គេសំលាប់ជនណាដែលនៅខាង លន់ នល់។ ក្រោយមកគេសំលាប់ដោយពុំមានការបែងចែកអ្វីឡើយ"។

(លោក វ៉ៃ អាយុ ៤៦ ឆ្នាំមេភូមិ ឃុំពពាក ស្រុកស្វាយទាប ខេត្តស្វាយរៀង)

## សំយោគជំពូក ទី១: មរតកពីអតីតកាល

## ការដោះស្រាយទំនាស់នៅមូលដ្ឋានៈ ការឈានចូលទៅក្នុងភាពអន្ធការៈ ១៩៧០-១៩៧៥

*ក្រោយរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ដែលទំលាក់សម្តេច សីហនុ និងនាំឱ្យលោកឧត្តមសេនីយ លន់ នល់ បានឡើងកាន់អំណាច ប្រទេសបានធ្លាក់ចូលទៅក្នុងភ្លក់ភ្លើងសង្គ្រាម។ ពួកឧទ្ទាមកុម្មុយនីស្ត និងពួកយៀកកុងបានបោះជំហានទៅមុខនៅក្នុងតំបន់ស្រុកស្រែចំការដោយមានការគាំទ្ររបស់សម្តេច សីហនុ ចាប់តាំងពីពេលដែលព្រះអង្គបាននិរទេសទៅទីក្រុងប៉េកាំងមក។ នៅចុងឆ្នាំ១៩៧០ ពួកចលនាតស៊ូទ័ពព្រៃ ដែលគេហៅថាខ្មែរក្រហមបានត្រួតត្រាទឹកដីមួយភាគធំនៃប្រទេស។ មានតែទីក្រុងនិងតំបន់នៅជុំវិញទីក្រុងទេដែលឋិត នៅក្នុងការកាន់កាប់របស់កងទ័ពលោក លន់ នល់ (មើលផែនទី)។*

*នៅស្រុកស្រែចំការ ថ្វីបើអ្នកខ្លះបានធ្វើតាមការអំពាវនាវរបស់សម្តេចសីហនុដែលបានបង្គាប់ឱ្យគេចូលរួមជាមួយយុទ្ធជនទ័ពព្រៃ មនុស្សចំនួនភាគច្រើនពុំបានជ្រើសរើសចូលជាក្រុមបក្សខាងណាទេ។ គឺដោយសារតែទីកន្លែងរស់នៅរបស់ប្រជាជន ឋិតនៅក្នុងតំបន់ភូមិសាស្ត្រនៅពេលកើតមានព្រឹត្តិការណ៍ទើបធ្វើឱ្យគេឋិតនៅខាងពួកខ្មែរក្រហម ឬនៅខាងទ័ពរបស់ លន់ នល់។*

*នៅក្នុងតំបន់ដែលត្រួតត្រាដោយពួកចលនាតស៊ូ របបថ្មីមួយត្រូវបានដាក់ឱ្យអនុវត្តន៍ជាបណ្តើរៗ។ មេភូមិជាច្រើនត្រូវបានដកចេញ និងជំនួសដោយមនុស្សនៃរដ្ឋអំណាចថ្មីលាក់មុខគឺ "អង្គការ"។*

*សង្គមថ្មីនេះធ្វើឱ្យគេមើលឃើញថាមានភាពស្មើគ្នា ប្រពន្ធ័មួយដែលមានឋានានុក្រមខ្លាំងត្រូវបានបង្កើតឡើង។ ប្រធានៗ មានអំណាចផ្តាច់ការ ។ គេបានចែកប្រជាជនទៅតាមប្រភេទដោយគេចាត់ទុកប្រភេទនិមួយៗមិនស្មើគ្នា។ គេបានរៀបចំប្រជាពលរដ្ឋឱ្យចូលជារបបសមូហភាពដោយប្រមូលមធ្យោបាយផលិតកម្ម កសិកម្ម ដាក់រួមទាំងអស់។*

*ការប្រជុំឃោសនានយោបាយ និងការប្រជុំស្វ័យទិតៀនត្រូវបានបង្កើតឡើង។ កសិករបានយល់ដឹងថាទិសដៅទីមួយគឺ ការចូលរួមជាមួយចលនាតស៊ូនិងការបំភ្លេចផលប្រយោជន៍របស់បុគ្គលផ្ទាល់ខ្លួន។ គេត្រូវធ្វើការដើម្បីបង្កបង្កើនផលស្រូវ និងជៀសវាងកុំឱ្យមាន"កំហុស"។ ជនណាដែលបានធ្វើខុសត្រូវតែសារភាពកំហុសជាសាធារណៈ ហើយត្រូវតែធ្វើតាមមតិរបស់សមមិត្តខ្លួន និងតាមការវិនិច្ឆ័យរបស់ប្រធាន។ កំហុសទាំងឡាយដែលត្រូវបានចាត់ទុកថា ធ្វើឱ្យប៉ះពាល់ដល់ដំណើរឈានទៅមុខរបស់បដិវត្តន៍ មានដូចជាមិនបានសំរេចទិសដៅ ការងារដែលអង្គការបានកំណត់។*

ចំពោះការដោះស្រាយនិងការបង្កាទំនាស់នៃការរស់នៅប្រចាំថ្ងៃ ការប្រែក្រលាស់ទាំងស្រុងត្រូវបានប្រតិបត្តិ ។ នៅក្នុងប្រព័ន្ធចាស់គេបានស្វែងរកការសំរុះសំរួលគ្នាដើម្បីធ្វើឱ្យមានការព្រមព្រៀងគ្នា ។ចំណែកឯនៅក្នុងប្រព័ន្ធថ្មី ការបង្កើតទំនាស់បង្កើតបញ្ហា ឬមានការឈោះទាស់ទែងគ្នា ត្រូវបានចាត់ទុកថាជាកំហុសមួយដែលរាំងស្ទះដល់ដំណើរឈានទៅមុខរបស់បដិវត្តន៍ ។ ជនទាំងឡាយណាដែលឋិតនៅក្នុងសភាពការណ៍បែបនេះគឺ អាចជាខ្មាំងសត្រូវ ។ អង្គការពុំស្វែងរកការសំរុះសំរួលឱ្យជនទាំងនោះទេ ប៉ុន្តែត្រូវដាក់ទោសនិងកំទេចខ្មាំងសត្រូវចោល ដើម្បីកសាងសង្គមមួយថ្មីស្អាតបរិសុទ្ធនិងរុងរឿង ។

ការភ័យខ្លាចបានចាប់ផ្តើម ។ គេចូលចិត្តបំបិទបញ្ហាដោយសារខ្លាចគេធ្វើការកត់សំគាល់ និងខ្លាចមានទោស ។ មនុស្សនាំគ្នាដាំដើមគ ។

សក្តីកម្មមានការប្រែប្រួលពីទីកន្លែងមួយទៅទីកន្លែងទៀត ។ ថ្វីបើនៅទីកន្លែងខ្លះ របៀបរបបថ្មីត្រូវបានដាក់បញ្ចូលបន្តិចម្តងៗ ហើយត្រូវបានទទួលយកដោយពេញចិត្ត តែនៅទីកន្លែងផ្សេងទៀត ប្រពន្ធ័ថ្មីៗមានលក្ខណៈតឹងតែងណាស់ ។

គេមើលឃើញស្រមោលដែលអាចកើតមានឡើងក្នុងទ្រង់ទ្រាយធំនៅពេលអនាគត ។ គឺរបបរាជានិយមបែបអាជ្ញាធិបតេយ្យ និងបិតុនិយមបែបបូរាណ បានប្រែក្លាយទៅជារបបជ្រុលនិយមផ្តាច់ការមានមូលដ្ឋានលើកសិកម្ម ។

## ៣. ឆ្នាំដែលមានការភ័យខ្លាចខ្លាំង៖ ១៩៧៥-១៩៧៩

នៅពេលបញ្ចប់សង្គ្រាមឆ្នាំ១៩៧០-១៩៧៥ គេគិតថាមានមនុស្សប្រហែល៧០០.០០០នាក់ដែលបានស្លាប់[111] បាត់បង់ជីវិត។ ជំនួយរបស់អាមេរិកមានការលំបាកណាស់ដើម្បីថែរក្សាទីកដីរបស់ពួកសាធារណៈរដ្ឋនិយម ដែលត្រូវបានព័ទ្ធជុំវិញ និងកាន់តែរួមតូចទៅៗ អស់រយៈពេលច្រើនឆ្នាំ ដោយសារការរុញច្រានរបស់កងកំលាំងបដិវត្តន៍។ ជនភៀសខ្លួនជាច្រើនបានរត់គេចចេញពីតំបន់ប្រយុទ្ធគ្នា ពីការទំលាក់គ្រាប់បែក និងទុរ្ភិក្ស ហើយបាននាំគ្នាមករស់នៅទីក្រុងភ្នំពេញ។ ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញបានកើនចំនួនបីដង។ សាធារណៈរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ ដែលត្រូវបានញាំញីដោយអំពើពុករលួយក៏រលំរលាយ។ សង្គ្រាមបានបញ្ចប់ និងបានបើកឱ្យមានសុបិនថ្មីមួយដ៏អាក្រក់។

ពួកខ្មែរក្រហមបានចូលមកកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ១៧មេសា ឆ្នាំ១៩៧៥ ហើយបានសំរេចធ្វើការជម្លៀសប្រជាពលរដ្ឋចំនួនពីរលាននាក់ជាបន្ទាន់ភ្លាមដើម្បីឱ្យទៅរស់នៅស្រុកស្រែចំការ។ ប្រជាពលរដ្ឋជាច្រើនបានស្លាប់នៅពេលដែលខ្លួនទើបបានចេញផុតពីទីក្រុង។ មនោគមវិជ្ជាផ្អែកលើនយោបាយកែទម្រង់ដីធ្លីទាំងមូលរបស់ពួកខ្មែរក្រហមគឺ ចង់ឱ្យប្រជាពលរដ្ឋទាំងអស់វិលត្រឡប់ទៅធ្វើការងារស្រែចំការវិញ។ នៅចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ប្រជាពលរដ្ឋខ្មែរទាំងអស់ត្រូវបានដាក់ឱ្យធ្វើការងាររួមនៅក្នុងសហករណ៍កសិកម្ម។ គំរោងការហួសវិស័យបានគ្រោងធ្វើការអភិវឌ្ឍន៍ផ្អែកកសិកម្ម បន្ទាប់មកឈានទៅសេដ្ឋកិច្ចឧស្សាហកម្មក្នុងរយៈពេលដប់ឆ្នាំទៅ ម្ភៃឆ្នាំ។ ដើម្បីសំរេចទិសដៅនេះ របៀបធ្វើការសមូហភាពបានប៉ះពាល់ដល់គ្រប់ទិដ្ឋភាពនៃការរស់នៅប្រចាំថ្ងៃ៖ ការងារ ការហូបចុក ការប្រជុំ...។

អ្នកធ្លាប់រស់នៅទីក្រុងដែលគេហៅថា "ប្រជាជនថ្មី" ត្រូវបានដាក់ឱ្យនៅក្រោមរបបយ៉ាងលំបាកបំផុត។ គេចោទប្រកាន់ប្រជាជនថ្មីថាជាអ្នកជិះជាន់គេនិងជាខ្មាំងសត្រូវរបស់បដិវត្តន៍។ ដូច្នេះ ប្រជាជនថ្មីជាច្រើននាក់ត្រូវបានសំលាប់ចោល។ ប្រជាជនថ្មីដទៃទៀតជាច្រើនពាន់នាក់ បានស្លាប់ដោយសារមិនធ្លាប់ធ្វើការងារនៅស្រែចំការ និង ដោយសារត្រូវបានបញ្ជូនជាញឹកញាប់ទៅកាន់តំបន់មានជំងឺគ្រុនចាញ់។

ជនដែលគេឱ្យឈ្មោះថា "ប្រជាជនចាស់" គឺជនទាំងឡាយណាដែលរស់នៅជាមួយអ្នកបដិវត្តន៍មុនពេលទីក្រុងភ្នំពេញធ្លាក់ទៅក្នុងកណ្តាប់ដៃពួកខ្មែរក្រហម។ ប្រជាជនចាស់ បានត្រៀមខ្លួនបានប្រសើរជាងដើម្បីចូលក្នុងរបបសមូហភាព និងការងារស្រែចំការ។ ក៏ប៉ុន្តែ ប្រជាជនចាស់ក៏ត្រូវទទួលរងភាពតឹងតែងនៃរបបជ្រុលនិយមមួយនេះដែរ។ ប្រជាជនចាស់មួយក្តាប់តូចដែលត្រូវបានបង្កើតតាំងពីដំបូងនៃបដិវត្ត ហើយ

---

[111]. ប្រជាពលរដ្ឋខ្មែរមានចំនួនប្រហែលប្រាំពីរលាននាក់ នៅចុងទសវត្សឆ្នាំ ១៩៦០។

ដែលបានអនុវត្តនីរិធាន ការរបស់ពួកខ្មែរក្រហមឥតល្បើងរហូតដល់ចប់នោះ គឺជាប្រភេទជនដែលគេមិនអាចបន្ទន់ចិត្តបាន។

ផែនការបួនឆ្នាំ បានគ្រោងបង្កើនផលិតផលស្រូវធ្វើតាមបែបប្រពៃណីឱ្យកើនឡើងពីមួយតោនក្នុងមួយហិកតារទៅបីតោនក្នុងមួយហិកតា។ ដើម្បីសំរេចគោលដៅនេះ ប្រទេសជាតិបានធ្វើយុទ្ធនាការក្នុងការងារធំៗ នៃការរៀបចំដីធ្លីកសិកម្ម។ ដីធ្លីទាំងអស់ត្រូវប្រមូលដាក់រួម។ ដីដែលមានក្បាលតូចៗត្រូវបានរៀបចំឡើងវិញ។ ដីស្រែតូចៗត្រូវបានធ្វើឱ្យទៅជាដីស្រែធំៗ រាងក្រឡាចតុរង្គមានជ្រុងមួយរយម៉ែត្រ។ ទំនប់ទឹកធំៗត្រូវបានកសាង ដែលជារឿយគ្មានន័យទាល់តែសោះ ពីព្រោះពុំមានមនុស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីដឹកនាំការងារ នោះ(បញ្ញាវ័ន្តជាច្រើនត្រូវបានសំលាប់ចោល)។ ឯលទ្ធផលចុងក្រោយពុំមានអ្វីគួរឱ្យអស្ចារ្យទេ។ ផលិតផល កសិកម្មហាក់ដូចជាមិនលើសពីកាលជំនាន់ទសវត្សឆ្នាំ៦០ទេ។ ប្រធានៗខ្មែរក្រហមនៅមូលដ្ឋានដែលមានការភ័យ ខ្លាចអំពីរបាយការណ៍ស្តីពី ចំនួនតួលេខនេះក៏បានរាយការណ៍បំផ្លើស ហើយបញ្ជូនផលិតផលទាំងអស់ទៅមជ្ឈិម។ លទ្ធផលគឺគ្រោះទុរ្ភិក្សសំរាប់ប្រជាជន លើកលែងតែកម្មាភិបាលរបស់ខ្មែរក្រហម។ ចាប់ពីឆ្នាំ១៩៧៧ រដ្ឋាភិបាលមជ្ឈិមចេះតែមានគំនិតភ័យខ្លាចខ្លួនឯងក៏រិះរកគំនិតដើម្បីកំទេចខ្មាំងសត្រូវ។ កម្មាភិបាលក្នុងសម័យមុនស្ទើរតែទាំងអស់ត្រូវបានតាមដាននិងសំលាប់ចោល(អតីតសហសេវិករបស់រដ្ឋាភិបាល លន់ នល់ និងអ្នកមាន) ហើយបានស្រាវជ្រាវរកអ្នកប្រឆាំងផ្សេងទៀត។ ចាប់ពីឆ្នាំ១៩៧៧ មកការបោសសំអាតដែលប៉ះពាល់ដល់ប្រជាជនទាំង អស់រួមទាំងកម្មាភិបាលខ្មែរក្រហមផងដែរ។

ក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃនៃរបបខ្មែរក្រហម ប្រជាជនប្រហែលមួយលានប្រាំពីរសែននាក់បានស្លាប់ដោយសារការអត់បាយ ការបាក់កំលាំង ដោយសារជំងឺ ឬត្រូវបានសំលាប់។

## ៣.១ ការបង្កើតរបៀបរបបថ្មីមួយ

បដិវត្តន៍ខ្មែរក្រហមដែលអ្នកនិពន្ធជាច្រើនបានហៅថាជា "របបស្រមើស្រម័យនិងឃាតករ" ជា "របបស្រមើស្រម័យលីលា" "របបប្រល័យពូជសាសន៍" "ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ" បានដាក់របៀបរបបថ្មីមួយឱ្យអនុវត្ត ហើយដែលតំលៃប្រពៃណីទាំងអស់ដែលគេចាត់ទុកថាសង្កត់សង្កិន ត្រូវបានគេបោះបង់ចោល បើពុំនោះសោតទេត្រូវបំផ្លាញចោល។ ព្រះសង្ឃត្រូវបានបង្ខំឱ្យសឹក ហើយវត្តអារាមត្រូវបំផ្លាញចោលសៀវភៅនានាត្រូវដុតចោល តុលាការនិងធនាគារត្រូវបានប្រែក្លាយទៅជាឃ្លាំង។ ទីក្រុងទាំងមូលគ្មានមនុស្ស។ បញ្ញាវ័ន្តត្រូវសំលាប់ ចោល ...។

"នៅក្នុងសម័យខ្មែរក្រហម គឺពុំមានការអប់រំសីលធម៌ទេ គឺមានតែការអប់រំនយោបាយ។ ការអប់រំនយោបាយ ពុំបានបង្ហាត់បង្រៀនអំពីកម្មផលទេ។ គេពុំបាននិយាយថា ជនណាសំលាប់គេនិងបានទទួលផលតាមអំពើដែលខ្លួនបានប្រព្រឹត្តនៅជាតិក្រោយទៀតទេ។ នៅក្នុងសម័យនោះ កូនអាចថ្កោលទោសឪពុកម្តាយរបស់ខ្លួន។ កូនអាចថ្កោលទៅឪពុកម្តាយដូចជាខ្មាំងសត្រូវ។ គ្មានក្បួនច្បាប់ដែលនិយាយអំពីការគោរពឪពុកម្តាយទេ។ អ្វីៗទាំងអស់បានប្រែត្រឡប់អស់"។
(លោក ហុង អាយុ ៦២ ឆ្នាំអតីតគ្រូបង្រៀនខេត្តស្វាយរៀង ស្រុកស្វាយរៀង ខេត្តស្វាយរៀង)។

"ពីមុន ដើម្បីឱ្យមនុស្សណាម្នាក់ធ្វើការ គេលួងលោមមនុស្សនោះ។ នៅឆ្នាំ១៩៧៥ ដើម្បីឱ្យមនុស្សធ្វើការគេត្រូវវាយជនទាំងនោះ"។
(លោក ពួន អាយុ ៦០ ឆ្នាំមេភូមិ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

ពួកខ្មែរក្រហមបានធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីកសាងសង្គមមួយស្អាតស្អំដែលមាន "សុភមង្គល សមភាព យុត្តិធម៌និងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់ គ្មានវណ្ណៈត្រូវគេជិះជាន់។ គឺជាសង្គមមួយដែលប្រជាជនទាំងអស់គ្នារស់នៅដោយសុខដុមនិងក្នុងមហាសាមគ្គីជាតិ ដើម្បីចូលរួមធ្វើការងារ បង្កបង្កើនផល កសាង និងការពារប្រទេសទាំងអស់គ្នា[១១២]"។ នៅក្នុងករណីនេះ ពួកខ្មែរក្រហមបានសំរេចគាស់រំលើងឬសគល់ទាំងអស់នៃអំពើអាក្រក់ដែលគេផ្ទាល់ សឹងតែពិបាកនឹងរកឬសគល់ឃើញ។ នៅក្នុងសង្គមបែបស្រមើស្រមៃហួសវិស័យនេះ ទំនាស់និងបញ្ហា ទាំងអស់ត្រូវគេបដិសេធចោល និងក៏ត្រូវហាមឃាត់មិនឱ្យកើតមានដែរ។ ដូចនេះ ទំនាស់អន្តរបុគ្គលពុំត្រូវមានទៀតទេ ពីព្រោះគេមានពាក្យបង្គាប់ឱ្យ"សាមគ្គី" និង"ឯកភាព"។ ការចង់ការពារផលប្រយោជន៍ផ្ទាល់ខ្លួន សិទ្ធិលើទ្រព្យសម្បត្តិត្រូវបានចាត់ទុកថាជាមានគំនិតអត្តទត្តបុគ្គលមូលធននិយម និងប្រឆាំងបដិវត្តន៍ត្រូវចាត់ទុកថាជា"កំហុស" ចំពោះអង្គការមជ្ឈឹមអនាមិកគឺ"អង្គការ"។ ទ្រព្យសម្បត្តិ សំខាន់ៗទាំងអស់ជារបស់រដ្ឋ ហើយត្រូវបានចាត់ទុកជាមធ្យោបាយផលិតកម្ម។ ប្រជាជនអាចមានតែទ្រព្យសម្បត្តិ សំរាប់ការប្រើប្រាស់ប្រចាំថ្ងៃប៉ុណ្ណោះ[១១៣]។ ទំនាស់ដីធ្លី ត្រូវតែលុបបំបាត់ចោលឱ្យអស់។ អ្នកណាដែលនៅមាន កម្មសិទ្ធិក្រាស់ជាមួយទ្រព្យសម្បត្តិ ឬព្យាយាមចង់បានទ្រព្យសម្បត្តិនោះជាកម្មសិទ្ធិរបស់ខ្លួនត្រូវបានគេលើកឡើង នៅពេលប្រជុំស្វ័យទិតៀន និងធ្វើការបរិហារ។ ការលួចស្បៀងអាហារដើម្បីឱ្យរួចផុតពីសេចក្តីស្លាប់ដោយអត់ អាហារត្រូវបានចាត់ទុកជាអំពើមួយប្រឆាំងបដិវត្តន៍។ នេះគឺជា"កំហុសមួយ" ហើយត្រូវតែមានទោសតាមដំណើរ

---

[112] . រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ: ០៥ ខែមករា ឆ្នាំ ១៩៧៦-បុព្វកថា។

[113] . រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ: ០៥ ខែមករា ឆ្នាំ១៩៧៦ មាត្រា២: មធ្យោបាយផលិតកម្មសំខាន់ៗទាំងអស់ គឺជាកម្មសិទ្ធិរួមនៃរដ្ឋប្រជាមានិត និងជាកម្មសិទ្ធិរបស់សហគមន៍។ ចំពោះទ្រព្យសម្បត្តិប្រើប្រាស់រាល់ថ្ងៃ គឺនៅតែជាកម្មសិទ្ធិរបស់បុគ្គលម្នាក់ៗ។

ហេតុ។ ការប្រព្រឹត្តិខុសគន្លងសង្គម ដូចជាការខឹងនិងការផិតក្បត់ស្វាមីឬភរិយាពុំអាចសំរុះសំរួលឡើងវិញតាមបែបប្រពៃណីបានឡើយ។ អំពើទាំងនេះត្រូវចាត់ជា"កំហុសសីលធម៌" ដែលត្រូវធ្វើការអប់រំហើយនិងអាចទទួលទណ្ឌកម្មទៀតផង។ នៅក្នុងសង្គមដែលគេចង់ឱ្យបានល្អឥតខ្ចោះនោះ ការលះបង់ចំពោះអង្គការត្រូវតែដាច់ខាត។ គំរោងការកសិកម្មធំៗត្រូវជំរុញនិងគេកេណ្ឌប្រជាជនទាំងអស់។ កម្មាភិបាលខ្មែរក្រហមចង់បង្ហាញថា បដិវត្តន៍របស់ពួកខ្លួនអាចធ្វើទៅបានលឿន និងប្រសើរជាងបដិវត្តន៍របស់សម្ពន្ធ័មិត្តចិននិងប្រទេសវៀតណាមដែលឋិតនៅជិតខាង។ ដូចនេះ គ្មានកំហុសមួយណាដែលត្រូវអត់អោនទេ។ ភ្នាក់ងាររបស់អង្គការតាមដានរក"កំហុស" ទាំងអស់ដែលអាចធ្វើឱ្យរាំងស្ទះដល់ដំណើរទៅមុខនៃបដិវត្តន៍ ហើយពួកគេក៏រៀបចំការត្រួតត្រាប្រជាជនយ៉ាងតឹងរឹងបំផុត។

គ្រួសារជាច្រើនបានផ្លាស់ទីលំនៅពីភូមិកំណើតរបស់ខ្លួនទៅរស់នៅទីកន្លែងផ្សេងទៀត រហូតដល់បាត់វត្តជាទីអាងរបស់ខ្លួនដូចជាអ្នកតានិងវត្តរបស់ខ្លួន។ កោសិកាគ្រួសារត្រូវបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ អង្គការបានរៀបចំអាពាហ៍ពិពាហ៍ហើយពុំអត់អោនឱ្យជនណាម្នាក់ ដែលមានទំនាក់ទំនងស្នេហាក្រៅពីប្តីប្រពន្ធឡើយ។ ប្តី ប្រពន្ធមានឱកាសជួបគ្នាតិចណាស់ កាលណាអ្នកទាំងពីរធ្វើការនៅការដ្ឋានខុសគ្នានិងឆ្ងាយពីគ្នា។ កូនត្រូវចាកចេញពីឪពុកម្តាយ និងបានទទួលការអប់រំជាសមូហភាពចាប់តាំងពីចូលវ័យក្មេង។ យុវជននិងមនុស្សពេញវ័យក្នុងអាយុដែលពេញកំលាំងបានចូលរួមក្នុងក្រុមកងចល័ត ហើយដែលត្រូវផ្លាស់ប្តូរទីកន្លែងទៅតាមការដ្ឋាន។ ស្មារតីឯករាជ្យដែលមានតំលៃថ្លៃសំរាប់ប្រជាជនខ្មែរ ត្រូវបានលុបបំបាត់ដើម្បីផលប្រយោជន៍របស់សមូហភាព។ រោងសហករណ៍ត្រូវបានកសាងនៅគ្រប់ទិសទីពេញទូទាំងប្រទេស។ គឺនៅក្នុងរោងទាំងនោះហើយដែលប្រជាជនត្រូវបរិភោគបាយរួម និងចូលរួមការប្រជុំនានា។ ប្រធានភូមិចាស់មានតួនាទីជាន់គ្នាជាមួយប្រធានសហករណ៍។ ប្រធាននិងអាជ្ញាធរជាច្រើនរូបមិនត្រូវបានជ្រើសរើសទៅតាមចំណេះដឹង និងកេរ្តិ៍ឈ្មោះរបស់គេឡើយ។ អំណាច ត្រូវប្រគល់ឱ្យជនណាដែលងាយពត់និងសាហាវបំផុត។ ជនទាំងនោះគឺ: ជនល្ងង់ខ្លៅ ក្មេងៗ និង ជនដែលស្ទិតស្ទាញក្នុងការពារបដិវត្តន៍។ ពាក្យសំដីរបស់អ្នកចាស់ទុំគេមិនត្រូវការទេ។ ចាស់ទុំក៏ត្រូវរក្សាភាពស្ងៀមស្ងាត់ដូចប្រជាជនទាំងអស់គ្នាដែរ។ គេមិនគ្រាន់តែខ្លាចទេ តែមានការភ័យរន្ធត់ចំពោះអង្គការ"ភ្នែកម្នាស់" ដែលមើលឃើញសព្វគ្រប់ទាំងអស់ ហើយមិនទុកចិត្តអ្នកជិតខាងសមាជិកគ្រួសារ។ អ្នកស៊ើបការសំងាត់ ឬកុមារអាចចោទប្រកាន់ទោសនិងធ្វើឱ្យស្លាប់បាន...។ ដើម្បីបានរស់ជាការប្រសើរ គឺមិនត្រូវធ្វើឃើញ ឬធ្វើដឹង ឬនិយាយអ្វីឡើយ "ត្រូវធ្វើគរដូចជាដាំដើមគរ[១១៤]"។

---

[114] . សុភាសិត-គរ មានន័យថានិយាយមិនកើត " សមមិត្ត, ត្រូវមានស្មារតីគោរពបទបញ្ជាទាំងអស់នេះជានិច្ច : កុំធ្វើចេះ, កុំធ្វើឮ, កុំធ្វើឃើញ, កុំនិយាយ "

នៅឆ្នាំ១៩៧៥ ការផ្លាស់ប្តូរមានគួរឱ្យកត់សំគាល់នៅតំបន់ស្រុកស្រែចំការ។ ការផ្លាស់ប្តូរមានលក្ខណៈដាច់ខាតសំរាប់ប្រជាជនអ្នកទីក្រុង។

"នៅឆ្នាំ១៩៧៥ អ្វីៗបានផ្លាស់ប្តូរអស់។ កាលពីមុន គឺពុំសូវមានការតឹងតែងទេ ប៉ុន្តែមិនអីទេ។ នៅចុងឆ្នាំ១៩៧៥ គេបានយកស្រូវទាំងអស់ទៅដាក់រួមនៅក្នុងជង្រុកតែមួយ។ គេបានប្រមូលចាន និងស្លាបព្រាទាំងអស់ ដើម្បីបរិភោគបាយរួមនៅសហករណ៍។ ដោយសារយើងធ្វើការរួមទាំងអស់នៅពេលថ្ងៃ ដូច្នេះនៅពេលយប់គេបានរៀបចំបាយរួមសំរាប់ពួកយើង។ ព្រំដីចាស់ៗនិងព្រំភូមិ ត្រូវបានកែប្រែ(...)។ មានការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន។ ប្រជាជននៅទីក្រុងភ្នំពេញបានមករស់នៅទីនេះ។ នៅទីនេះមានប្រជាជនច្រើនណាស់។ គេបានធ្វើការទាំងអស់គ្នាពេញមួយថ្ងៃ។ គេត្រូវតែធ្វើការកសាងទំនប់ទឹកតូចធំ។ ការងារមានសភាពយ៉ាប់យឺនណាស់។ គេត្រូវធ្វើការជានិច្ចហើយបរិភោគបាយ តិចតួច"។

(លោក សេង អាយុ ៥៧ ឆ្នាំសង្កាត់ពងទឹក ក្រុងកែប)

"នៅឆ្នាំ១៩៧៥ ខ្ញុំបានរស់នៅទីក្រុងភ្នំពេញជាមួយគ្រួសារខ្ញុំ។ គេបានបង្ខំឱ្យយើងធ្វើដំណើរឆ្ពោះទៅខេត្តបាត់ដំបង។ ខ្ញុំបានបាត់បង់កូនស្រីម្នាក់នៅពេលគេជម្លៀស។ ខ្ញុំពុំបានជួបកូនស្រីរបស់ខ្ញុំទេ។ ពេលទៅខេត្តបាត់ដំបង យើងមានការនឿយហត់អស់កំលាំងយ៉ាងខ្លាំង។ ជាសំណាងល្អយើងបានយកអង្ករទៅតាមខ្លួន។ មនុស្សជាច្រើនបានស្លាប់នៅពេលធ្វើដំណើរតាមផ្លូវ។ ពួកគេបាក់កំលាំងខ្លាំងណាស់។ ពួកខ្មែរក្រហមបានសំលាប់មន្ត្រីរបស់ លន់ នល់ ច្រើនណាស់នៅពេលចេញពីទីក្រុង។ យើងបានធ្វើដំណើរទៅដល់ភូមិមួយ ហើយយើងបានស្នាក់នៅក្នុងផ្ទះមួយជាមួយមនុស្សពីរគ្រួសារផ្សេងទៀត។ យើងមិនរករឿងគ្នាទេ។ យើងបានរៀនចេះបិទមាត់ធ្វើគរធ្វើថ្លង់។ គេបានប្រាប់ឱ្យពួកយើងទៅធ្វើការនៅក្នុងស្រែ។ នៅក្នុងភូមិដែលខ្ញុំបានរស់នៅក្នុងសម័យខ្មែរក្រហមគឺ យ៉ាប់ណាស់។ មនុស្សជាច្រើនបានស្លាប់ដោយសារអត់អាហារ និងដោយសារមានជំងឺ។ យើងគ្មានអ្វីហូបទេ ហើយក៏គ្មានថ្នាំសង្កូវដែរ។ ដំបូងនៅភូមិនោះមាន ៨០ គ្រួសាររស់នៅ ហើយនៅចុងក្រោយបំផុតគឺមានតែ ១៧ គ្រួសារទេដែលនៅរស់រានមានជីវិត"។

(លោក ឈួន អាយុ ៥៦ ឆ្នាំឃុំនគរ ស្រុកសៀមរាប ខេត្តសៀមរាប)

## ៣.២. ប្រព័ន្ធមួយមានការបង្ខិតបង្ខំដើម្បីត្រួតត្រាប្រជាជន

សង្គមទាំងមូល ត្រូវបានរៀបចំជាក្រុមតូចឬធំ ដើម្បីបំពេញភារកិច្ចក្នុងការសំរេចទិសដៅការងារដែលអង្គការបានកំណត់ព្រមទាំងធ្វើការប្រុងប្រយត្ន័ជានិច្ច ដើម្បីកុំឱ្យមាននរណាម្នាក់មករាំងស្ទះដល់ដំណើរការល្អរបស់ប្រព័ន្ធនេះបានឡើយ។ មនុស្សម្នាក់ៗ ត្រូវមានការលះបង់ខ្ពស់ចំពោះអង្គការ ធ្វើការឱ្យបានខ្លាំងក្លា

ក៏ដូចជាធ្វើការត្រួតពិនិត្យនិងរាយការណ៍អំពី "កំហុស" របស់ខ្លួននិង "កំហុស" អ្នកដទៃ។ អតីតខ្មែរក្រហមបានរំឭកពីរចនាសម្ព័ន្ធមូលដ្ឋានរបស់អង្គការនិងភារកិច្ចដែលត្រូវអនុវត្តន៍។ ខ្មែរក្រហមខ្លះទៀតបានចូលរួមទាំងស្រុង ដើម្បីបំរើអង្គការ។ ឯអ្នកខ្លះទៀតបានគិតថាខ្លួនជាអ្នកទោស របស់ប្រពន្ធ័មួយដែលបានធ្វើឱ្យប្រជាជនមានការភ័យខ្លាច ប៉ុន្តែពួកគេបានសហករណ៍ជាមួយអង្គការដើម្បីបានរស់រានមានជីវិតទៅទៀត។

"នៅឆ្នាំ១៩៧៥ គេបានរំដោះប្រទេសជាលើកទីពីរ។ នៅលើកទីមួយ គេបានរំដោះភូមិជាច្រើននៅឆ្នាំ ១៩៧២។ នៅលើកទីពីរនៅឆ្នាំ១៩៧៥គឺការរំដោះទីក្រុងនានា។ នៅឆ្នាំ១៩៧៥ ប្រព័ន្ធសង្គមមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនិងប្រពន្ធ័ដែលគេបានបង្កើតនៅឆ្នាំ១៩៧២។ ប្រពន្ធ័នេះកាន់តែមានលក្ខណៈតឹងតែងខ្លាំងឡើងៗ ហើយប្រជាជនបានហូបបាយរួម។ គេបានបង្កើតក្រុមតូចមួយមានបីគ្រួសារដែលគេឱ្យឈ្មោះថា"ពួក"។ ចំណែកឯ "ក្រុម" មានដប់ពីរគ្រួសារ។ នៅខាងលើមានឃុំ។ គ្រួសារនីមួយៗត្រូវត្រួតមើលគ្រួសារមួយទៀត។ សមាជិករបស់"ពួក" ត្រូវបានបញ្ចូលគ្នាដោយយោលទៅតាមផ្ទះដែលស្ថិតនៅជិតគ្នា។ គឺប្រធានក្រុមជាអ្នកប្រមូលផ្តុំផ្ទះ។ ប្រសិនបើសមាជិកនៅក្នុង"ពួក"មិនត្រូវគ្នា គេអាចមានលទ្ធភាពសុំប្តូរបាន។ សមាជិក"ពួក" ធ្វើការប្រជុំរៀងរាល់ថ្ងៃដើម្បីជជែកគ្នាអំពីផែនការនានា និងធ្វើការកែប្រែគ្នាទៅវិញទៅមក។ ទិសដៅទីមួយ គឺការងារពលកម្ម ឯទិសដៅទីពីរគឺស្វ័យទិតៀននិងការរាយការណ៍"។

(លោក សាម៉ុន អាយុ ៤២ ឆ្នាំ មេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត(ភូមិបង្កើតថ្មី))

"ខ្ញុំបានធ្វើទាហានរបស់ ប៉ុល ពត រហូតដល់ឆ្នាំ១៩៧៨។ ចាប់តាំងពីឆ្នាំ១៩៧៥ ការរៀបចំសង្គមមានការផ្លាស់ប្តូរយ៉ាងច្រើន។ ជីវភាពរបស់សហគមន៍កាន់តែមានសារៈសំខាន់ខ្លាំងឡើងៗជាមួយសហករណ៍។ គេបានឈានចូលដល់សម័យកាលនៃរបបផ្តាច់ការ។ កាលណាមេនិយាយថាទៅឆ្វេង គេត្រូវតែទៅឆ្វេង។ នៅសម័យនោះ ប្រជាជនមានការភ័យខ្លាចណាស់ រួមទាំងកម្មាភិបាលផងដែរ។ មនុស្សទាំងអស់គ្នាសុទ្ធតែមានការភ័យខ្លាចជានិច្ច។ គេមានបទបញ្ជាដើម្បីធ្វើការងារ។ គេត្រូវតែធ្វើការកសាងទំនប់ រែកដីលាមក និងដាំបន្លែ។ ប្រធានសហករណ៍ ជាអ្នកធ្វើផែនការទាំងអស់ ហើយគេត្រូវតែធ្វើតាមបញ្ជារបស់ប្រធានសហលរណ៍ទាំងអស់។ មនុស្សគិតតែពីធ្វើយ៉ាងណាឱ្យខ្លួនបានរស់ឱ្យបានហូប។ យើងទាំងអស់គ្នាជាអ្នកសល់ពីស្លាប់។ សព្វថ្ងៃនេះដូចឡើងឋានសួគ៌"។

(លោក ក្រែម អាយុ ៥៤ ឆ្នាំអនុប្រធានឃុំ(អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត)

## ការតាមដានរក "កំហុស"

នៅក្នុងសង្គមនេះ ដែលគេស្នើឱ្យធ្វើខ្វាក់ ធ្វើថ្លង់ ការប្រព្រឹត្តទាំងអស់ដែលពុំសមស្របត្រូវហាមឃាត់។ ការឈ្លោះទាស់ទែងគ្នាត្រូវហាមឃាត់ និងអាចទទួលទោស។ ប្រព័ន្ធត្រួតពិនិត្យដែលបានចាប់ផ្តើមដាក់ឱ្យអនុវត្តន៍ នៅស្រុកស្រែចំការចាប់តាំងពីឆ្នាំ១៩៧០ ត្រូវបានចាក់គ្រឹះយ៉ាងមាំទាំនៅប្រាំឆ្នាំក្រោយមក ម៉ាស៊ីនវិលពេញបន្ទុក ហើយចរន្តភ័យបារម្ភនាំឱ្យគេតាមដានតាំងពី"កំហុស"តូចតាចនៅក្នុងកាយវិការនៃការរស់នៅប្រចាំថ្ងៃ។ ដោយការខ្វល់ខ្វាយចង់ក្តោបក្តាប់មនុស្សឱ្យជាប់ គេក៏ចាត់បញ្ចូលទៅក្នុងក្របខ័ណ្ឌធម្មតានៃការប្រជុំនានា។ ការឈ្លោះគ្នាដែលបណ្តាលមកពីចំនុចមានវិវាទគ្នាមួយ ឬការស្តីបន្ទោសជនណាម្នាក់ក្នុងលក្ខណៈឯកជន ត្រូវចាត់ទុកជា "កំហុស"។

"ក្នុងករណីមានបញ្ហា គេបាននិយាយគ្នានៅក្នុង"ពួក"របស់គេ។ ប្រសិនបើបញ្ហានោះមិនត្រូវបានដោះស្រាយទេ គេបញ្ជូនបញ្ហានោះទៅឱ្យ"ក្រុម"ជួយដោះស្រាយ។ នៅពេលមុនដំបូង បញ្ហានានាមានលក្ខណៈដូចកាលពីសម័យមុនដែរ គឺមានជំលោះរវាងប្រជាជនគ្នាឯង។ ក្រោយមកគេបាននិយាយថា បញ្ហាទាំងអស់នោះ គឺជាកំហុសដែលប្រឆាំងអង្គការ។ ជនណាដែលមានបញ្ហា និងជនដែលបានបង្កើតបញ្ហាគឺមានកំហុសដូចគ្នាគឺជាការប្រឆាំងនិងអង្គការ។ គេនិយាយថា គឺជាជនដែលមិនចេះធ្វើការសាមគ្គី។ ជនណាដែលពុំបានធ្វើឱ្យមានសាមគ្គីភាពទេ គឺជាអ្នកប្រឆាំង និងគោលការណ៍របស់អង្គការ"។

(លោក សាម៉ុន អាយុ ៤២ ឆ្នាំឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

"គេបានធ្វើការប្រជុំជាច្រើនហើយដែលគេទអទូចឱ្យមានសាមគ្គីភាព និងឯកភាពជាតិ។ ឧទាហរណ៍ ប្រសិនបើគេឱ្យភ្ជួរស្រែមួយចំនួនពីរឬបីដង ហើយអ្នកភ្ជួរ១បានតែមួយដង នោះគេនិយាយថា អ្នកភ្ជួរពុំគោរពតាមឯកភាពជាតិទេ។ បុគ្គលពុំមានទេគឺមានតែអង្គការទេ។ ការខុសឆ្គងទាំងអស់ ត្រូវបានចាត់ទុកជាកំហុសប្រឆាំងនិងអង្គការ ប្រឆាំងនិងការងារ។ គេប្រៀបធៀបមនុស្សដូចជាអណ្តើក។ គឺគេពុំបានបញ្ចេញក្បាលនិងបញ្ចេញជើងទេ។ គេមានការជឿទុកចិត្តទៅលើមិត្តភក្តិតែពីរឬបីនាក់ប៉ុណ្ណោះដែលគេអាចមានជំនឿទុកចិត្ត។ គេអាចជួយគ្នាទៅវិញទៅមកបានក្នុងករណីមានជំងឺ ដើម្បីអាចជួយរកថ្នាំសង្កូវដោយលួចលាក់បំផុត"។

(លោក ឈួន អាយុ ៥៦ ឆ្នាំឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅក្នុងសម័យខ្មែរក្រហម គំនិតសុទ្ធតែល្អ តែអ្នកអនុវត្តន៍អាក្រក់។ សង្គមល្អណាស់។ អ្វី១មានដំណើរការល្អ។ មនុស្សម្នាពុំបានបង្កើតរឿងទេ។ កាលណាមានបញ្ហាអ្វីមួយ គេធ្វើការពិភាក្សាគ្នា។ គេអាចរៀបចំមនុស្សជា"ពួក"។ បុគ្គលម្នាក់១ តាមត្រួតពិនិត្យអាកប្បកិរិយារបស់បុគ្គល

ម្នាក់ទៀត និងបានធ្វើការត្រួតពិនិត្យខ្លួនឯងដែរ។ កាលណាមានការងារពលកម្ម ប្រសិនបើមានអ្នកខ្លះមិនបានទៅធ្វើការ អ្នកផ្សេងទៀតពិតជាមានការច្រណែន ហើយបានធ្វើការរាយការណ៍អំពីជននោះ។ គេត្រូវតែធ្វើឱ្យបានសំរេចតាមទិសដៅដែលបានកំណត់ បើពុំនោះសោតទេគេត្រូវធ្វើស្វ័យទិតៀន។ គឺមានលក្ខណៈដូចវត្តអារាមដែរ គឺមានបទបញ្ជាមួយ ជនណាដែលប្រព្រឹត្តល្មើសបទបញ្ជាត្រូវតែរាយការណ៍អំពីកំហុសរបស់ខ្លួន ហើយជននោះត្រូវបានទទួលការអប់រំពីប្រធានវត្ត។ ប្រសិនបើបុគ្គលម្នាក់មានកំហឹងជាមួយបុគ្គលម្នាក់ទៀត បុគ្គលរូបនោះអាចរាយការណ៍នៅពេលធ្វើការប្រជុំពួក ហើយបន្ទាប់មកអាចយករឿងនោះទៅរាយការណ៍នៅពេលប្រជុំក្រុម។ ប្រសិនបើមានការចោទប្រកាន់ខុស អ្នកដទៃទៀតអាចបង្ហាញការពិត និងការពារជនជាប់ចោទ។ មេក្រុមដោះស្រាយបញ្ហាហើយនិយាយថា នេះគឺជាមេរៀនសំរាប់យើងទាំងអស់គ្នា។ ប្រសិនបើបុគ្គលនោះពុំសារភាពកំហុសរបស់ខ្លួនទេ រឿងនោះត្រូវបញ្ជូនទៅប្រធានសហករណ៍ និងទៅមេឃុំ។ ប្រសិនបើ រឿងនោះជាករណីរបស់យុទ្ធជនមួយរូប[១១៥] យុទ្ធជននោះត្រូវតែចាកចេញពីជីវភាពជាយោធា ដូចព្រះសង្ឃមានកំហុសដែលត្រូវតែសឹកដូច្នោះដែរ។ នៅក្នុងកងទ័ពព្រៃគេត្រូវតែគោរពប្រធាន។ គេត្រូវតែធ្វើការតាមប្រធានជានិច្ច។ ចំពោះប្រជាពលរដ្ឋគេធ្វើបែបដូចគ្នាដែរ។ គេប្រាប់ថា "បើអ្នកឯងឈ្លោះគ្នា អ្នកឯងនឹងក្រជាមិនខាន។ អ្នកឯងត្រូវខាតបង់ពេលវេលា។ ប្រសិនបើ អ្នកឯងទុកពេលវេលានេះដើម្បីធ្វើការងារ អ្នកឯងនឹងបានទទួលផលសំរាប់ជីវភាពអ្នកឯង"។ ប្រសិនបើជាករណីធ្ងន់ធ្ងរ គឺត្រូវមានទោស។ ប្រសិនបើជារឿងទាស់ទែងប្តីប្រពន្ធ គេបានបំបែកប្តីនិងប្រពន្ធហើយឱ្យអ្នកទាំងពីរទៅធ្វើការឆ្ងាយពីគ្នា។ កាលណាអ្នកទាំងពីរបានជួបជុំគ្នាវិញគេមានសេចក្តីសប្បាយរីករាយណាស់ហើយលែងធ្វើឱ្យមានបញ្ហាទៀតហើយ។ គេក៏បានដាក់ទោសដែរ ដោយឱ្យទៅធ្វើការងារពលកម្ម។ គេបញ្ជូនមនុស្សឱ្យទៅធ្វើការនៅចំការរែកដីដើម្បីកសាងទំនប់ទឹក។ ពួកកងយោធាឈរត្រួតពិនិត្យមើលជនទាំងនោះជាពិសេស និងបង្ខំឱ្យជនទាំងនោះធ្វើការងារ"។

(លោក ឈុំ អាយុ ៥៤ ឆ្នាំមេភូមិ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

អតីតកម្មាភិបាលខ្មែរក្រហមមួយរូបបានធ្វើការបែងចែករវាង "កំហុសសេដ្ឋកិច្ច" និង "កំហុសសង្គម"។

"របស់សំខាន់ពីរដែលត្រូវគោរពគឺ សាមគ្គី និងឯកភាព។ គឺមានន័យថា គេមិនត្រូវគិតតែពីបុគ្គលខ្លួនឯងគិតពីមូលធនទេ ប៉ុន្តែគេត្រូវតែធ្វើរួមគ្នាដើម្បីអង្គការ។ គេបានបង្កើតឱ្យមានការ

---

[115] . ទាហានខ្មែរក្រហមត្រូវបានចាត់ទុកដូចជា វិរជន។

ប្រជុំអប់រំហើយគេបាននិយាយ អំពីកំហុសរបស់បុគ្គលនានា និងបានព្រមានបុគ្គលទាំងនោះកុំឱ្យប្រព្រឹត្តការខុសឆ្គងជាថ្មីទៀត។ នៅលើកក្រោយៗទៀត មនុស្សលែងធ្វើឱ្យមានការខុសឆ្គងទៀតហើយពីព្រោះគេមានការខ្មាសអៀន។ ប្រសិនបើគេបានធ្វើការប្រជុំអប់រំរៀងរាល់ថ្ងៃដដែលៗមនុស្សយល់ ហើយគេមានការខ្មាសអៀនប្រសិនបើគេបានធ្វើខុស។ គេបានធ្វើការអប់រំដោយយកឧទាហរណ៍ជាក់ស្តែងដើម្បីឱ្យមនុស្សបានយល់ដឹង។ ប្រធានឃុំបានបំពាក់បំប៉នរូបខ្ញុំ។ ខ្ញុំនិយាយតាមអ្វីដែលគាត់និយាយប្រាប់ ដោយរកឧទាហរណ៍ផ្សេងទៀត។ ឧទាហរណ៍ ខ្ញុំពន្យល់ថាសាមគ្គីភាព គឺជាការធ្វើការងាររួមទាំងអស់ៈ "បើការងារត្រូវបញ្ចប់នៅម៉ោងដប់មួយ ទាំងអស់គ្នាត្រូវធ្វើការរហូតដល់ម៉ោងដប់មួយ។ គេត្រូវចាប់ផ្តើមធ្វើការទាំងអស់គ្នា ហើយឈប់សំរាកទាំងអស់គ្នាដែរ ទោះបីមានអាកាសធាតុក្តៅយ៉ាងណាក៏ដោយ ទាំងអស់គ្នាត្រូវតែគោរពម៉ោងពេល គឺសាមគ្គីភាព"។ តាមបទបញ្ជា ជនណាបានធ្វើខុសចំនួនបីដងត្រូវមានទោស។ ឧទាហរណ៍ អ្នកមានទោសត្រូវតែលើកដីធ្វើភ្លឺស្រែ។ ប៉ុន្តែ រឿងនេះពុំមានញឹកញាប់ទេ។ មានការប្រជុំតាមពួកជារៀងរាល់ថ្ងៃកាលណាមានការងារច្រើន ហើយកាលណាមានការងារតិចតួច គេធ្វើការប្រជុំរៀងរាល់បីថ្ងៃម្តង។ មានការប្រជុំតាមក្រុមមួយដងក្នុងមួយសប្តាហ៍។ នៅក្នុងពេលប្រជុំតាមក្រុម គេបានលើកពីលទ្ធផលការងាររបស់"ពួក"ទាំងបួន។ ប្រធានក្រុម បានធ្វើការវាយតំលៃលទ្ធផលរបស់"ពួក"នីមួយៗ។ គាត់លើកពីចំណុចខ្លាំងនិងចំណុចខ្សោយទាំងអស់។ "ពួក"ផ្សេងៗត្រូវតែធ្វើតាមចំណុចខ្លាំង រីឯចំណុចខ្សោយត្រូវបានទទួលស្តីបន្ទោស។ តមក ប្រធានក្រុមប្រាប់សមាជិកក្រុមអំពីផែនការការងារដែលមេភូមិសំរេចរួចហើយ។ រៀងរាល់ដប់ប្រាំថ្ងៃម្តង ប្រធានក្រុមបានជួបប្រធានភូមិដើម្បីរាយការណ៍អំពីលទ្ធផលការងាររបស់ក្រុមគាត់។ នៅពេលប្រជុំគេក៏បានធ្វើស្វ័យទិតៀននិងធ្វើការរាយការណ៍ដែរ។ គឺមានសារៈសំខាន់ណាស់។ គេត្រូវតែធ្វើការអប់រំជនទាំងឡាយណាដែលមានការខ្វះខាត។ នៅសម័យនោះគឺ ល្អណាស់។ គេស្រួលអប់រំមនុស្ស។ សព្វថ្ងៃនេះគឺមានការលំបាក ណាស់មនុស្សលែងស្តាប់គ្នាហើយ។

មានកំហុសប្រឆាំងនឹងអង្គការ គឺកំហុសសេដ្ឋកិច្ច។ កំហុសសេដ្ឋកិច្ចគឺការមកធ្វើការយឺតពេលនិងឈប់ធ្វើ ការងារមុនពេលកំណត់។ ស្ទួងមិនលឿនក៏ជាកំហុសដែរ។ មិនធ្វើការនៅពេលក្តៅនិយាយថាគេឈឺក្បាលហើយ មិនចង់ទៅធ្វើការក៏ជាកំហុសដែរ។ ការលួចទ្រព្យសម្បត្តិរបស់អង្គការគឺជាកំហុសធ្ងន់ធ្ងរណាស់ ដូចជាលួចមាន់ ឬលួចអង្ករជាដើម។

នៅមានកំហុសសង្គមផងដែរ។ ឧទាហរណ៍ ម្តាយជេរកូនរបស់ខ្លួនឬ ជេរអ្នកជិតខាងក៏ជាកំហុស។ កំហុស ធ្ងន់ធ្ងរគឺនៅពេលមានមនុស្សពីរនាក់វាយគ្នា។

គេព្យាយាមសំរុះសំរួលរឿងរ៉ាវនោះ ហើយគេធ្វើការប្រមាន។ ឯទោសគឺការអប់រំក្នុងរយៈពេលដប់ថ្ងៃ និងធ្វើការងារផង"។

(លោក សាម៉ុន អាយុ ៤២ ឆ្នាំមេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី)

ជនរងគ្រោះបានទទួលការអប់រំឱ្យក្លាយទៅជាពេជ្ឈឃាតដើម្បីបានរស់។ នៅក្នុងបរិយាកាសមហាភ័យការរាយការណ៍និងការភូតកុហក ជារឿយៗបានក្លាយទៅជាទំរង់នៃការការពារខ្លួន។

"គឺពុំមានការឈ្លោះប្រកែកគ្នាទេ។ ការឈ្លោះប្រកែកគ្នាត្រូវបានហាមឃាត់។ គេដឹងតែពីធ្វើការងារ។ ពួកទាហានខ្មែរក្រហមរវល់តែរឿងការពារជាតិទេ។ ពួកគេមិនធ្វើការងារទេ។ យើងជាប្រជាជន យើងធ្វើការងារ។ នៅពេលល្ងាចក្នុងពេលប្រជុំស្វ័យទិតៀន គេបានធ្វើរបាយការណ៍សង្ខេបស្តីអំពីលទ្ធផលការងារប្រចាំថ្ងៃ។ គេផ្ទៀងផ្ទាត់មើលថា តើគេបានសំរេចទិសដៅដែរឬទេ។ គេបានលើកពីកំហុសនានា: អ្នកស្ទួងយឺត អ្នកធ្វើការ លឿនតែមិនល្អ អ្នកឈ្លោះជាមួយអ្នកម្នាក់ទៀត។ គេបានឡើងរាយការណ៍ពីខ្លួនឯង ឬត្រូវបានគេរាយការណ៍។ គេត្រូវតែទទួលសារភាព ។ ជនដែលរាយការណ៍និយាយដូច្នេះថា: "សមមិត្ត **ជិន** មិត្តឯងបាននិយាយពាក្យសំដី ទ្រគោះបោះបោកទៅកាន់សមមិត្តម្នាក់ទៀត។ ឥឡូវនេះមិត្តឯងមិនសូវធ្វើការទេ។ យើងសុំណែនាំមិត្តឯងកុំឱ្យធ្វើអាកប្បកិរិយាបែបនេះតទៅទៀត"។ អ្វីៗដែលគេបាននិយាយ គឺស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ប្រធាន ក្រុម ឬប្រធានភូមិ។ ប្រធានក្រុម និងមេភូមិក៏អាចត្រូវគេថ្កោលទោសដែរ និងត្រូវតែសារភាពចំពោះកំហុស របស់ខ្លួនដែរ។ នៅក្នុងពេលប្រជុំក្រុម គឺមានមនុស្សចំនួនដប់ពីរនាក់។ គេត្រូវនិយាយម្តងម្នាក់ៗ ថ្កោលទោសខ្លួនឯង និងថ្កោលទោសអ្នកដទៃ បន្ទាប់មកចាំស្តាប់ការណែនាំរបស់ប្រធានក្រុម។ ប្រសិនបើមានអ្នកណាម្នាក់ បានរាយការណ៍ពីយើង យើងត្រូវតែសារភាពជាដាច់ខាត។ យើងពុំមានជំរើសអ្វីទៀតឡើយ។ ប្រសិនបើជាការ ភូតកុហកមែនយើងពុំអាចនិយាយអ្វីបានទៀតឡើយ យើងមិនត្រូវបដិសេធការថ្កោលទោសនោះទេ។ គេពុំចាំបាច់បង្ខំឱ្យរាយការណ៍ពីអ្នកដទៃទេ ហើយក៏ពុំចាំបាច់រកកំហុសរបស់ខ្លួនឯងដែរ ក៏ប៉ុន្តែ ដើម្បីឱ្យគេឃើញថាល្អ និងដើម្បីឱ្យស្ងប់ស្ងាត់ គេត្រូវតែបង្ខំធ្វើការប្រឌិត។ យើងបានប្រឌិតសូម្បីតែរឿងកំប៉ិកកំប៉ុកយកមកនិយាយឱ្យគេស្តាប់ ដើម្បីបំពេញបេសកម្មរបស់យើងឱ្យបានដូចអ្នកដទៃទៀត។ មួយផ្នែកទៀត យើងមានការភ័យខ្លាចមិន ហ៊ានថាឱ្យគេដោយខ្លាចមិនត្រូវជាមួយគេនៅពេលក្រោយទៀត។ ក្រុមកុមារក៏ពូកែរាយការណ៍ដែរ។ ជួនកាល យើងត្រូវតែនៅក្រោយការប្រជុំពីព្រោះយើងត្រូវបង្ខំចិត្តដើម្បីបង្ហាញពីសាមគ្គីភាព។ តាមការពិត គឺពុំមាន សាមគ្គីភាពទេ។ យើងបានធ្វើហាក់ដូចជាមានសាមគ្គីភាពនៅពេលធ្វើការងាររួម និងពេលបរិភោគបាយ។ នៅ

ពេលដែលយើងត្រឡប់ទៅដល់ផ្ទះវិញ យើងគិតតែពីរឿងរបស់យើងប៉ុណ្ណោះ។ យើងពុំមានជំនឿទុកចិត្តទៅលើ អាជ្ញាធរខ្មែរក្រហមទេ ក៏ប៉ុន្តែយើងមានការទុកចិត្តទៅលើមនុស្សខ្លះជាប្រជាជនដូចយើងអញ្ចឹង។ មានការជួយគ្នាទៅវិញទៅមករវាងយើងទាំងអស់គ្នា ជាពិសេសចំពោះបញ្ហាថ្នាំសង្កូវ។ យើងបានធ្វើការប្តូរគ្នាទៅវិញទៅ មក"។

(លោកស្រី ចាន់ណា អាយុ ៤៨ ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

"កាលពីមុន នៅក្នុងភូមិប្រជាជនសុភាពរាបសាណាស់។ ប្រជាជនមិនចេះភូតកុហក និងមិនចេះលួចទេ។ នៅក្នុងសម័យខ្មែរក្រហម ដើម្បីបានរស់គេត្រូវរៀនភូតនិងរៀនលួច។ អ្នកដែលនិយាយតែការពិតពុំអាចរស់បានទេ។ ចំពោះខ្លួនខ្ញុំបានភូតកុហក ខ្ញុំបានលួចម្ហូបអាហារ ហើយខ្ញុំរួចខ្លួនបានរស់"។(លោកស្រី គៀន អាយុ ៤៧ ឆ្នាំ (អតីតខ្មែរក្រហម) ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

**ការរាយការណ៍និង ស្វ័យទិតៀនដែលប្រមូលផ្តុំទោសកំហុសត្រូវបានប្រើជំនួសការសំរុះសំរួល។** នៅក្នុងករណីខ្លះ ក្នុងទីកន្លែងខ្លះ និងជាមួយមនុស្សខ្លះ ជួនកាលប្រធានភូមិបានបន្តអនុវត្តន៍បែបប្រពៃណី នៃការសំរុះសំរួល ជាពិសេសចំពោះ បញ្ហាតូចតាចរវាងបុគ្គលនិងបុគ្គល។ ចំពោះបញ្ហាដែលគេនិយាយថា មានការទាក់ទងជាមួយអង្គការគឺជាបញ្ហាដែលមានសារៈសំខាន់ខ្លាំងណាស់ ហើយដែលមិនត្រូវពិភាក្សាគ្នាជាសំងាត់ គឺគេបានពិភាក្សាបញ្ហានោះនៅពេលមានការរួមប្រជុំ។ អំណាចរបស់ប្រធានភូមិមានសម្បើមជាងកាលពីមុន។ ប្រធានភូមិអាចធ្វើការវិនិច្ឆ័យបញ្ហាផ្សេងៗ ដើម្បីឱ្យសំលាប់មនុស្ស ឬឱ្យយកមនុស្សដាក់ពន្ធនាគារ។ ដូចនេះ មានប្រជាជនតិចណាស់ហ៊ាននិយាយរឿងរបស់ខ្លួនប្រាប់ប្រធានភូមិ។ លើកលែងតែមនុស្សដែលមានការជិតស្និទ្ធ ជាមួយប្រធានភូមិ។ ប្រជាជនចូលចិត្តនៅស្ងៀមជាជាងធ្វើឱ្យគេមានការចាប់អារម្មណ៏មកលើខ្លួន។ ប្រព័ន្ធ រាយការណ៏មានដំណើរការល្អសំរាប់មេភូមិ។

"ពុំមានបញ្ហាដីធ្លីអ្វីទេ។ ពីព្រោះដីធ្លីត្រូវបានប្រមូលដាក់រួមអស់។ មានបញ្ហាទំនាស់ប្តីប្រពន្ធតិចតួច ពីព្រោះប្តីប្រពន្ធត្រូវបានបំបែកគ្នាជាញឹកញាប់។ មនុស្សម្នាក់ៗមានការងារច្រើនណាស់ ហើយជួនកាលបានចាក ចេញទៅឆ្ងាយនិងមានរយៈពេលយូរទៀតផង។ គេបានជួបគ្នាតិចណាស់។ គឺជួបគ្នាម្តងរៀងរាល់ដប់ថ្ងៃ ហើយជួនកាលយូរជាងនេះទៀតក៏មាន។ បញ្ហាដែលច្រើនកើតមានគឺការលួច ឬមានរឿងជាមួយអ្នកដែលមិនចេះស្រលាញ់គ្នា។ កាលណាគេមានបញ្ហាជាមួយជនណាម្នាក់ គេបានទៅរកប្រធានភូមិ។ ប្រធានភូមិបានធ្វើការសំរុះសំរួល ដូចធម្មតាដោយធ្វើការប្រជុំភាគីទាំងពីរ ហើយឱ្យភាគីទាំងពីរនិយាយពីហេតុផល បន្ទាប់មកគាត់ក៏បានធ្វើការណែនាំ។ យើងមានការប្តឹងតវ៉ាតិចតួចដូចនៅសម័យសង្គមរាស្ត្រនិយមដែរ ពីព្រោះយើងមិនដឹងច្បាស់ថានឹងមានអ្វី អាចកើតឡើងដែរ។ ប្រធានភូមិបានហៅជនទាំងពីរនាក់មកប្រជុំ។

គាត់បានសុំឱ្យអ្នកទាំងពីរនិយាយរឿងឱ្យគាត់ស្តាប់ បន្ទាប់មកគាត់ក៏បានធ្វើការណែនាំអ្នកទាំងពីរ។ ខ្ញុំនឹកឃើញរឿងមួយគឺមានពេលមួយ មានមនុស្សម្នាក់ត្រឡប់ទៅដល់ផ្ទះរបស់ខ្លួនវិញ ហើយគាត់សង្កេតឃើញបាត់របស់របរជាច្រើន។ ជននោះស្រែកឱ្យអ្នកជិតខាង ហើយអ្នកជិតខាងក៏ឆ្លើយតបទៅគាត់វិញដែរ។ ជននោះទៅរកជួបប្រធានភូមិ ហើយប្រធានភូមិបាននិយាយថាគាត់ពុំអាចរកដំណោះស្រាយបានទេ ពីព្រោះគាត់ពុំដឹងថាអ្នកណាជាអ្នកលួចរបស់ទាំងអស់នោះ។ ប្រធានភូមិនិយាយថា ឱ្យបំភ្លេចរឿងនោះចោលទៅ និងកុំឱ្យបង្កើតបញ្ហា។ ប្រសិនបើគេស្គាល់អ្នកលួច ប្រធានភូមិអាចជួយបានហើយចាប់ចោរដាក់គុកបាន។ ប្រសិនបើជាបញ្ហាតូចតាច ដូចជាបញ្ហារវាងប្រជាជនគ្នាឯងគេធ្វើការអប់រំ ក៏ប៉ុន្តែប្រសិនបើជាបញ្ហាធំ ឧទាហរណ៍ ប្រសិនបើមានជនណាម្នាក់បានបង្កើតបញ្ហាប្រឆាំងនឹងអង្គការ ជននោះត្រូវបានចោទថាបានក្បត់អង្គការ ជននោះត្រូវតែសំលាប់ចោល ឬត្រូវជាប់ពន្ធនាគារ។ កាលណាជនណា ម្នាក់ត្រូវបានចោទប្រកាន់ថាក្បត់អង្គការ គេពុំអាចការពារខ្លួនបានទេ គេពុំអាចធ្វើការតវ៉ាបានទេ គេត្រូវតែ សារភាព។ ជួនកាលគឺមានការស៊ើបអង្កេត។ ប្រធានធ្វើការសាកសួរជនដទៃទៀត។ ប៉ុន្តែ នៅក្នុងករណីភាគច្រើន ជនជាប់ចោទត្រូវបញ្ជូនទៅពន្ធនាគារ ដោយពុំមានការស៊ើបអង្កេតអ្វីទេ និងត្រូវបានទទួលការសាកសួរយ៉ាងតឹង តែងបំផុត។ ជនទាំងនោះត្រូវតែសារភាពដោយខ្លួនឯង។ មានមនុស្សតិចណាស់ដែលរួចផុតពីការជាប់ពន្ធនាគារ។ ខ្ញុំបានឃើញជនខ្លះបានត្រឡប់មកផ្ទះវិញក្រោយពីជាប់ពន្ធនាគារអស់រយៈពេលបីខែឬមួយឆ្នាំ។ ជនទាំងនោះមានរាងកាយស្គាំងស្គមខ្លាំងណាស់ ហើយពុំនិយាយស្តីអ្វីឡើយ។

(លោក សេង អាយុ ៥៧ ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុមកែប ខេត្តកំពត (ភូមិបង្កើតថ្មី))

ក្រឡាសំណាញ់ចេះតែតូចចង្អៀតទៅដើម្បីទាក់បានកំហុសតូចតាច។ នៅចន្លោះស្ម័យទិតៀន ការរាយការណ៍ និងកងឈ្លប មានការប្រព្រឹត្តិប្រចាំថ្ងៃតិចណាស់ដែលរួចផុតពីសំណាញ់របស់អង្គការ។

"មានកងឈ្លប។ កងឈ្លបទាំងនោះមានភារកិច្ចធ្វើជាគិញតាមដានមនុស្ស ហើយធ្វើការរាយការណ៍អំពីជនទាំងនោះ។ ពួកគេបានធ្វើការជាមួយយើង ហើយត្រួតពិនិត្យមើលយើងទាំងអស់គ្នារៀងរាល់ពេល។ កាលណាជនណាម្នាក់ត្រូវបានរាយការណ៍ ប្រធានឈ្លបបាននាំជននោះទៅជួបប្រធានក្រុមដើម្បីធ្វើការអប់រំ បន្ទាប់មកជនជាប់ចោទអាចវិញត្រឡប់ទៅគេហដ្ឋានវិញបាន។ ចំពោះករណីធ្ងន់ធ្ងរ ជនជាប់ចោទត្រូវបានយកទៅដាក់ពន្ធនាគារឬសំលាប់ចោល។ ជនទាំងអស់នោះត្រូវបានចោទប្រកាន់ពីបទក្បត់អង្គការ។ កំហុសដែលប្រឆាំងនឹងអង្គការ គឺការលួចមាន់ សំលាប់គោ លួចបន្លែ។ គឺប្រធានក្រុមជាអ្នកសំរេចបញ្ជូនឬមិនបញ្ជូនអ្នកទោសទៅពន្ធនាគារ"។

(លោក សេង អាយុ ៥៧ ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុមកែប ខេត្តកំពត (ភូមិបង្កើតថ្មី))

## ការបែងចែកប្រជាជនតាមប្រភេទ និងការប្រកាន់អាក្សបកិរិយាប្លែកៗគ្នាចំពោះប្រជាជន

ដូចយើងបានឃើញពីខាងដើមមកហើយថា នៅចន្លោះឆ្នាំ១៩៧០-១៩៧៥ គេបានបែងចែកប្រជាជនទៅតាមប្រភេទដោយផ្អែកទៅលើជីវប្រវត្តិនិងទ្រព្យសម្បត្តិរបស់គេ។ ការបែងចែកប្រភេទប្រជាជន[១១៦] នេះបាន ចាប់អនុវត្តន៍ទៅលើប្រជាជនទាំងអស់ ចាប់តាំងពីឆ្នាំ១៩៧៥មក។ ជាថ្មីម្តងទៀត ការបែងចែកប្រភេទនេះមានមានលក្ខណៈធូរស្រាល ឬតឹងតែង ឬអាចមាន ឬពុំអាចមានអនុប្រភេទអាស្រ័យទៅតាមទីកន្លែង និងបុគ្គលិកលក្ខណៈរបស់ប្រធាន។ ជួនកាល គេប្រើពាក្យពេចន៍លាយឡំគ្នាទាំងអស់។ ជាទូទៅគេបានបែងចែកជាពីរវណ្ណៈសំខាន់គឺ "ប្រជាជនចាស់" គឺជនទាំងឡាយដែលនៅខាងបដិវត្តន៍នៅមុនពេលទីក្រុងបានធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហម ហើយនិង "ប្រជាជនថ្មី" ឬគេហៅថា "ប្រជាជន១៧ មេសា"។

នៅក្នុងករណីមាន "កំហុស" ការដាក់ទណ្ឌកម្មទៅលើប្រជាជនមានការប្រែប្រួលទៅតាមប្រភេទដែលគេបានបែងចែក។ គេចាត់ទុកថា "ប្រជាជនចាស់" "អ្នកពេញសិទ្ធិ" ឬ "កម្មករក្រីក្រ" ជាអ្នកបរិសុទ្ធ ហើយនៅក្នុងករណីមានកំហុស ប្រជាជនចាស់អាចត្រូវកែតម្រង់ឱ្យទៅតាមមាគ៌ាវិញ។ ចំណែកប្រជាជនប្រភេទផ្សេងទៀត ត្រូវបានគេសង្ស័យថា មានទំលាប់អាក្រក់ពិបាកកែប្រែ។ ពួកខ្មែរក្រហម មានការប្រុងប្រយ័ត្នណាស់ចំពោះជនទាំងនោះ។ ចំពោះអំពើផ្តេសផ្តាស់បន្តិចបន្តួចសោះ ពួកខ្មែរក្រហមបានចាត់ទុកប្រជាជនថ្មីថាមិនអាចធ្វើការអប់រំបានទេ ហើយក៏បានកំទេចចោលតែម្តង។

> "នៅឆ្នាំ១៩៧៦ គេបានបង្កើតគណៈកង។ នៅក្នុងភូមិនិងឃុំមានគណៈច្រើនណាស់។ គេបានហូបបាយរួមទាំងអស់គ្នានៅក្នុងរោងបាយសហករណ៍។ ប្រជាជនត្រូវបានគេរៀបចំជាក្រុមដោយយោងទៅតាមពេលវេលាដែលប្រជាជននោះបានមកនៅជាមួយរបបខ្មែរក្រហម។ គេបានឱ្យឈ្មោះថា "អ្នកភូមិចាស់" "មូលដ្ឋានចាស់" និង "អ្នកភូមិថ្មី"។ ប្រជាជនអ្នកភូមិថ្មី គឺជាអ្នកចំណូលថ្មី(អ្នកមកពីភូមិមួយទៀត)។ គេក៏ឱ្យឈ្មោះថា "កសិករចាស់" និង "កសិករថ្មី" ដែរ។ គេក៏ហៅថា "ប្រជាជនចាស់ មូលដ្ឋានចាស់" និង "ប្រជាជនថ្មី " ដែរ។
>
> គេបានចាត់តាំង "ប្រជាជនចាស់" ចំនួនពីរទៅបីនាក់ដើម្បីត្រួតលើ "ប្រជាជនថ្មី"។ នៅពេលប្រជុំគេនិយាយថា "ប្រជាជនថ្មី" និង "ប្រជាជនចាស់ "មានសិទ្ធិដូចគ្នា ។ គេបានស្នើឱ្យ "ប្រជាជន ចាស់" ត្រួតពិនិត្យ និងជួយ "ប្រជាជនថ្មី"។ តាមការពិត ប្រជាជនចាស់ពុំបានជួយប្រជាជនថ្មីទេ។

---

116 . នៅទីនេះ យើងនៅឆ្ងាយពីពាក្យពេចន៍នៅក្នុងបុព្វកថា នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ។ "(...)" ដោយយល់ឃើញថា សេចក្តីបងប្រាថ្នា របស់ប្រជាជនកម្ពុជាទាំងមូលនិងកងទ័ពបដិវត្តន៍កម្ពុជាទាំងមូលដែលចង់បានកម្ពុជាមួយឯករាជ្យ(...) ដែលមានសុភមង្គល, សមភាព, យុត្តិធមិ និងប្រជាធិបតេយ្យពិតប្រាកដ ដោយពុំមានអ្នកមាន ពុំមានអ្នកក្រ, ពុំមានវណ្ណៈជិះជាន់, ពុំមានវណ្ណៈត្រូវគេជិះជាន់ សង្គមមួយដែលមានការរស់នៅ ដោយសុខដុម និងក្នុងមហាសាមគ្គីជាតិដើម្បីចូលរួមក្នុង ការងារបង្កបង្កើនផល, កសាងនិងការពារប្រទេសទាំងមូល(...)។

"ប្រជាជនថ្មី" មានការលំបាកជាង "ប្រជាជនចាស់"ខ្លាំងណាស់។ ប្រជាជនថ្មី ពុំធ្លាប់ធ្វើការងារស្រែចំការទេ។ ប្រជាជនថ្មី ធ្វើការឆាប់ហត់ និងឆាប់ឃ្លានណាស់។ ប្រជាជនថ្មី បានធ្លាក់ខ្លួនឈឺ។ ប្រជាជនថ្មីជាច្រើននាក់ បានស្លាប់ដោយសារហេវហត់បាក់កំលាំង ឬ ដោយសារខ្វះស្បៀងអាហារ។ របបស្បៀងអាហារត្រូវបានកំណត់។ "ប្រជាជនថ្មី" ពុំអាចទ្រាំទ្របានទេ"។

(លោក ទិតអាយុ ៥៤ ឆ្នាំ អនុប្រធានសង្កាត់ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

"នៅឆ្នាំ១៩៧៥ ខ្ញុំបានរស់នៅក្នុងខេត្តកណ្តាល។ ខ្ញុំជាសមាជិកគណៈឃុំ។ គេបានធ្វើការប្រជុំអប់រំមួយដងក្នុងមួយសប្តាហ៍។ គេនិយាយថា "នៅថ្ងៃស្អែកយើងត្រូវទៅដាំចេកនៅកន្លែងនេះ"។ គេបានពន្យល់អំពីបទបញ្ជា ដោយលើកយកឧទាហរណ៍ជាក់ស្តែង។ បទបញ្ជា គឺជាភារកិច្ចដែលត្រូវបំពេញទៅតាមទិសដៅ។ ប្រធានភូមិបានពន្យល់អំពីរយៈពេលនៃភារកិច្ច ចំនួនអ្នកចូលរួម ចំនួនដើមដែលត្រូវដាំ ឬចំនួនដីដែលត្រូវរែក។ ជនណា ដែលពុំបានគោរពតាមពាក្យបង្គាប់នោះ គឺមានន័យថា បានធ្វើ"កំហុស"។ ការដាក់ទោសបានប្រែប្រួលទៅតាមប្រភេទនៃប្រជាជន។ ចំពោះពួក"កសិករក្រ" និង "កសិករថ្នាក់កណ្តាល" គឺគេធ្វើការអប់រំ។ ចំពោះ " កសិករថ្នាក់លើ" និង"ប្រជាជនថ្មី" គឺពុំមានការព្រមានច្រើនពេកទេ។ បើជននោះប្រព្រឹត្តកំហុសចំនួនពីរដង គឺគេកំទេចចោល ហើយ (សំលាប់ចោល)។ "កសិករក្រ" និង " កសិករកណ្តាល" គេធ្វើការអប់រំ។ គេពុំសំលាប់ចោលទេ លើកលែងតែមានកំហុសធ្ងន់ធ្ងរបំផុត។ កំហុសធ្ងន់ធ្ងរគឺ កាលណាមានការប៉ះពាល់ដល់សីលធម៌មនុស្សប្រុសលួចមានសាហាយ ឬជនណាដែលពុំគោរពតាមការបរិភោគបាយរួម។ ឧទាហរណ៍ ដូចជាជនណាដែលបានលួចសំលាប់មាន់ ដើម្បីលួចបរិភោគបាយនៅផ្ទះ។ គឺដោយសារតែការស្រេកឃ្លានហើយ បានជាប្រជាជនបានស្វែងរកម្ហូបអាហារ ហើយពួកគេត្រូវសំលាប់ចោលដោយសារបញ្ហានេះ។ នៅកន្លែងដែលខ្ញុំរស់នៅ មានកំហុសធ្ងន់ធ្ងរជាច្រើនដោយសាររឿងស្រី។ នៅសម័យនោះ ស្រីៗនៅទីក្រុងភ្នំពេញបានទៅដល់ភូមិ។ ស្រីៗទាំងនោះមានរូបរាងស្អាតនិង ថែរក្សាខ្លួនប្រាណណាស់។ ពួកទាហានបានទៅរកស្រីៗទាំងនោះ ហើយបានរំលោភលើរូបរាងកាយនាងយ៉ាងសំងាត់។ នៅពេលគេដឹងរឿង មនុស្សប្រុសនិងស្រីនោះត្រូវបានសំលាប់ចោល។ នៅក្នុងកន្លែងដែលខ្ញុំរស់នៅ ខ្ញុំមានអំណាច គេគោរពខ្ញុំ។ ក្នុងករណីមានការលួចស្រលាញ់គ្នាដោយលួចលាក់ ខ្ញុំបានបំបែកអ្នកទាំងពីរ។ ប្រសិនបើអ្នកទាំងពីរនៅកំលោះ ក្រមុំ ខ្ញុំបានរៀបចំការអ្នកទាំងពីរ។ ប្រសិនបើអ្នកទាំងពីរបានរៀបការរួចហើយពួកគេ ត្រូវបានទទួលការអប់រំ ហើយត្រូវទៅធ្វើការដ៏លំបាក។ រឿងនេះអាចមានចំពោះ"កសិករក្រ" និង" កសិករថ្នាក់កណ្តាល"។ តែបើរឿងនេះមានទាក់ទងទៅនឹង"កសិករថ្នាក់លើ"មានតែសំលាប់ចោល។ ជួនកាលគេបញ្ជូនអ្នកទាំងពីរទៅកន្លែងផ្សេង ទៅតំបន់ព្រៃពិបាកៗ"។ កាលណាមានកំហុសអ្វីមួយ

គេនិយាយថាៈ គឺខុសពីច្បាប់ ខុសពីវិន័យ។ គឺពុំមានអង្គការវិន័យជាលាយលក្ខ័អក្សរច្បាស់លាស់ទេ ប៉ុន្តែគេដឹងថា មានកំហុសប្រឆាំងនឹងអង្គការ។ តាមការពិតគឺមានកំហុសច្រើនជាងច្បាប់។ អ្វីដែលគេចងចាំគឺ នៅពេលខុសលើកទីមួយ និងខុសលើក ទីពីរ គេធ្វើការអប់រំដោយការព្រមាន។ នៅពេលខុសលើកទីបីគឺ ការដាក់ទោស។ ចំពោះការដាក់ទោស ជារឿយៗគឺការសំលាប់ចោល។ គេត្រូវតែធ្វើការប្រុងប្រយត្ន័ មិនត្រូវដើរឃ្លាតចេញពីមាគ៌ារបស់អង្គការឡើយ"។

(លោក ទិត អាយុ ៥៤ ឆ្នាំ អនុប្រធានសង្កាត់(អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

"នៅឆ្នាំ១៩៧៥ ខ្ញុំបានវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំវិញនៅក្បាលរមាស។ គេបានបែងចែកប្រជាជនជាបីប្រភេទគឺ "ប្រជាជនពេញសិទ្ធិ" "ប្រជាជនត្រៀម" និង "កសិករថ្មី" ឬ "ពួកថ្មី"។ ខ្ញុំឋិតនៅក្នុងក្រុមពួកថ្មី"។ នៅពេលនោះពុំមានយុត្តិធម៌ទេ គេប្រើតែកំលាំង។ ពុំមានតុលាការទេ។ ប្រធានភូមិមានអំណាច គ្រប់ទាំងអស់ក្នុងការកាត់សេចក្តី គាត់មានអំណាចសំលាប់មនុស្ស។ ប្រធានភូមិមានអំណាចសំលាប់មនុស្សម្នាក់ មនុស្សដប់នាក់ គ្រួសារទាំងមូល។ ក្នុងចំណោមប្រភេទប្រជាជនទាំងអស់ គឺមានតែ"ពួកថ្មី" ទេដែលមានមនុស្ស ស្លាប់ច្រើនជាងគេ។ គេបានធ្វើការស៊ើបអង្កេតអំពីកំហុស។ កំហុសតូចតាចគឺការដាំដំឡូងខ្លួនឯងដើម្បីហូបដោយ ស្ងាត់កំបាំងនៅពេលល្ងាច។ គេនិយាយថា នេះគឺជាការប្រឆាំងនឹងអង្គការ ប្រឆាំងនឹងសាមគ្គីភាពរវាងប្រជាជន។ នៅពេលប្រជុំ ប្រជាជនទាំងអស់បានជជែកគ្នាពីបញ្ហានេះ ហើយនិយាយថា តើត្រូវសំលាប់ចោល ឬដាក់ទោសផ្សេងទៀត។ កំហុសធ្ងន់ធ្ងរគឺ ដូចជាការដេកជាមួយស្រីផ្សេងម្នាក់ទៀតក្រៅពីប្រពន្ធរបស់ខ្លួន ឬមិនបានធ្វើការងារឱ្យបានសមល្មម។ គេនិយាយថា ជនទាំងនោះមានការខ្ជិលច្រអូស ទោះបីជាកំលាំងរបស់គាត់មិនអនុញ្ញាតឱ្យ គាត់ធ្វើការបានខ្លាំងក៏ដោយ។ កំហុសធ្ងន់ធ្ងរបំផុតគឺ ដូចជាការប្រើពាក្យសំដីអាក្រក់ប្រឆាំងនឹងអង្គការ។ នៅក្នុងករណីនេះ គេសំលាប់គ្រួសារទាំងមូលដើម្បីឱ្យបានច្បាស់ថាគេបានកំទេចពូជអាក្រក់ចោលឱ្យអស់។ គេពុំសូវមានការតឹងតែងជាមួយ"ពួកប្រជាជនពេញសិទ្ធិ" ទេ។ កំហុសរបស់ "ប្រជាជនពេញសិទ្ធិ" ត្រូវបានអត់អោនឱ្យ។ ចំពោះកំហុសធ្ងន់ធ្ងរ ពួកប្រជាជនពេញសិទ្ធិត្រូវដាក់ទោសដែរ ប៉ុន្តែពុំសូវមានការសំលាប់ចោលទេ។ ពីដំបូង គេក៏បានពិនិត្យមើលជីវប្រវត្តិដែរ។ ខ្ញុំបាននិយាយថា ខ្ញុំបានធ្វើទាហាន លន់ នល់ ប៉ុន្តែក្រោយមកខ្ញុំបានផ្លាស់ទៅរស់នៅ ភូមិមួយទៀត ហើយឯកសាររបស់ខ្ញុំបានបាត់បង់អស់។ ជួនកាលគេមិនសំលាប់អតីតទាហាន លន់ នល់ ទេ ដោយសារជនទាំងនោះមានគ្រួសារនៅខាង "ប្រជាជនពេញសិទ្ធិ"ដែលជួយការពារ។ ចំពោះរូបខ្ញុំ ខ្ញុំប្រឹងធ្វើការណាស់

ពួក "ប្រជាជនពេញសិទ្ធិ" ស្រលាញ់ខ្ញុំណាស់ និងបានជួយខ្ញុំ។ នៅពេលប្រជុំគេបាននិយាយតែពីការរឿងការ ងារ" ។

(លោក ឡៃ អាយុ ៥៧ ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប)

"នៅមុនឆ្នាំ ១៩៧៥ កាលណាជនណាម្នាក់បានធ្វើឱ្យមានបញ្ហាអ្វីមួយ គេនិយាយពីការអប់រំកសាង។ បន្ទាប់មក នៅឆ្នាំ១៩៧៥ គេនិយាយថា គ្រវាត់ចោល សំលាប់ចោល[១១៧] ។ នៅកន្លែងខ្លះមានមនុស្សស្លាប់ច្រើនណាស់ កន្លែងខ្លះមានមនុស្សស្លាប់តិច។ គេបានធ្វើការបែងចែកប្រជាជនជាបីវណ្ណៈគឺ វណ្ណៈកម្មករ វណ្ណៈកសិករ និង វណ្ណៈថ្នាក់លើ។ ការបែងចែកនេះមានដូចនៅក្នុងវត្តអារាមដែរគឺ មានលោកនេន លោកភិក្ខុ និងសង្ក្រាជ[១១៨] ។

កម្មករគឺជាអ្នកក្រីក្រជាងគេ។ គេបានបែងចែកកម្មករជាពីរក្រុមគឺ "កម្មករដែលមានតែបាតដៃទទេ" និង "កម្មករលីសែង"ឥតមានដីធ្លី។ របបថ្មីបានផ្តល់កិត្តិយលដល់កម្មករដែលមានតែដៃទទេ។ បន្ទាប់មកគឺមាន "កសិករលេខមួយ"ដែលមានដីស្រែចំការ ក៏ប៉ុន្តែពុំអាចធ្វើការចិញ្ចឹមជីវិតបានពេញមួយឆ្នាំទេ បន្ទាប់មកគឺ "កសិករ លេខពីរ" ដែលមានដីស្រែចំការ និងគោហើយដែលមានស្បៀងអាហារគ្រប់គ្រាន់សំរាប់មួយឆ្នាំៗ។ "វណ្ណៈលើ" ចែកជាពីរក្រុមដែរគឺ "វណ្ណៈមួយ" គឺជាជនទាំងឡាយដែលមាន កង់ រទេះ គោ ជ្រូក។ "វណ្ណៈពីរ" គឺជនទាំង ឡាយដែលមានអ្នកបំរើ និងមានដីរថែមទៀត។ ខ្ញុំបានដឹងរឿងនេះដោយសារខ្ញុំបានធ្វើជាប្រធាន។ ខ្ញុំបានយល់ដឹងនៅពេលមានការបណ្តុះបណ្តាល។

ក្រោយពីមានការបែងចែកវណ្ណៈនេះមក គេបានជ្រើសរើសប្រធានក្នុងចំណោមវណ្ណៈ កម្មករបាតដៃទទេ និងអនក្ខរជន។ អ្វីៗសុទ្ធតែក្រឡាប់ចាក់ទាំងអស់។ អ្វីៗដែលត្រូវទៅជាខុសហើយអ្វីដែលខុសទៅជាត្រូវ។ កាលណាគេចង់ឱ្យយើងនិយាយថា"ស" យើងត្រូវតែថា"ស"។ គេបានយកជើងធ្វើក្បាល យកក្បាលធ្វើជាជើង។ ពួកកម្មករមានសិទ្ធិច្រើនជាងអ្នកដទៃទៀត។ គេអត់អោនទោសយ៉ាងច្រើន ដល់ពួកកម្មករលើកលែងតែការ រំលោភផ្លូវភេទលើនារីដែលត្រូវតែសំលាប់ចោល។ ពួកកម្មករហូបបាយបីដងមួយថ្ងៃ។ ចំណែកឯ"វណ្ណៈថ្នាក់លើ" ហូបបានតែពីរដងទេក្នុងមួយថ្ងៃ។ ពួកវណ្ណៈថ្នាក់លើបានធ្វើខុសច្រើនណាស់។ ដោយសារពួកគេមានការស្រេក

---

117 . លែងទុកជីវិត : លែង មានន័យថាបោះចោល, ដោះលែង, ទុក មានន័យថាថែរក្សាជីវិត : ការរស់នៅ។

118 . នៅពេលសន្ទនាគ្នា អតីតកម្មាភិបាលខ្មែរក្រហមជាច្រើន បាននិយាយអំពីការបង្កើតប្រព័ន្ធ កុម្មុយនីស្តខ្មែរក្រហមនិងអង្គការសហគមន៍របស់បព្វជិត ស្របពេលគ្នា។ ភាពច្របូកច្របល់នៃមូលនិធិចាស់ៗតាមបែបប្រពៃណីនៅមានជានិច្ច ទោះបីមានឆន្ទៈនៃការកំទេចចោលក៏ដោយ។ ប្រពៃណីមួយបានមក កំចាត់ប្រពៃណីមួយទៀត។

ឃ្លានខ្លាំង ពួកគេមិនគោរពវិន័យទេ។ ពួកគេជាអ្នកមាន គេមើលងាយមនុស្សណាស់។ យើងបានគិតរឿងទាំងអស់នេះ ហើយយើងគេមិនចង់ឱ្យពួកវណ្ណៈថ្នាក់លើនេះមានរបស់របបច្រើនទេ។ ប្រជាជនពុំមានបញ្ហាទេ។ ប្រជាជនមានការខ្ជិលច្រអូស។ ប៉ុន្តែនេះគឺជាកំហុសរបស់ពួកអ្នកមាន ដែលបានធ្វើឱ្យប្រជាជនឋិតនៅក្នុងភាពល្ងង់ ខ្លៅ"។

(លោក ពួន អាយុ ៦០ ឆ្នាំ ប្រធានភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី)

"ប្រធានសហករណ៍មានសិទ្ធិសំលាប់មនុស្ស ប៉ុន្តែយើងពុំមានសិទ្ធិអ្វីទាំងអស់។ ប្រធានសហករណ៍គឺជាមនុស្សល្ងង់ខ្លៅ។ ពួកគេត្រូវបានជ្រើសរើសក្នុងចំណោមជនល្ងង់ខ្លៅបំផុត និងជនទាំងឡាយដែលបានចូលរួមច្រើនដងក្នុងពលកម្មមុនឆ្នាំ១៩៧០។ ពួកគេជា"ប្រជាជនចាស់"។ យើងគឺជា"ប្រជាជន១៧ មេសា "យើងបានរៀនសូត្រច្រើន ប៉ុន្តែយើងពុំអាចត្រូវបានចាត់តាំងជាប្រធានសហករណ៍ឡើយ។ អ្នកចេះដឹងត្រូវគេប្រមាថ"។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំ មេឃុំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"គេត្រូវតែធ្វើការងារ និងមិនត្រូវធ្វើឱ្យមានបញ្ហាឡើយ ត្រូវនៅឱ្យស្ងៀម។ មនុស្សដូចយើងដែលជា "ប្រជាជនថ្មី" ត្រូវគេសំលាប់ចោលប្រសិនបើយើងបង្កើតឱ្យមានបញ្ហា។ អ្នកដទៃទៀតគឺ "ប្រជាជនចាស់" បានទទួលការណែនាំ។ គេគ្រាន់តែយកទៅអប់រំ"។

(លោក ឈួន អាយុ ៥៧ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅក្នុងសម័យខ្មែរក្រហម មានមនុស្សបីប្រភេទៈ "ប្រជាជនពេញសិទ្ធិ" "ប្រជាជនបំរុង" និង "ប្រជាជន ១៧ មេសា"។

(លោក នាល អាយុ៣៩ ឆ្នាំ សង្កាត់អង្គកាល ក្រុមកែប ខេត្តកំពត)

ជញ្ជាំងមានត្រចៀកសូម្បីតែនៅពេលយប់ក៏ដោយ។

"នៅឆ្នាំ១៩៧៥ ខ្ញុំបានរស់នៅក្នុងផ្ទះថ្មីមួយចំងាយ១៥គីឡូម៉ែត្រពីភូមិកំណើត។ មានកងឈ្លបជាច្រើននាក់ដែលបានស៊ើបការរៀងរាល់ពេល។ នៅពេលយប់ មានជនម្នាក់បានស្រែកមមើថា ផ្ទះចាស់របស់គាត់ត្រូវអ្នកផ្សេងចូលមករស់នៅ។ ពួកឈ្លបនិយាយថា ជននោះមានអាកប្បកិរិយាជាមូលធន ពីព្រោះគាត់មានអារម្មណ៍ជិតជាប់នឹងផ្ទះរបស់គាត់។

គ្រប់កាយវិការទាំងអស់ត្រូវឃ្លាំមើល។ ឧទាហរណ៍ ប្រសិនបើមនុស្សប្រុសជា "ប្រជាជនថ្មី" ម្នាក់បានញញឹមទៅរកស្រីជា "ប្រជាជនចាស់"ម្នាក់ គាត់អាចត្រូវដាក់ទោសដោយសារតែអំពើដ៏សាមញ្ញមួយថា លួងលោមស្រីនោះឱ្យស្រលាញ់ខ្លួន។

អ្នកដែលបានគេផ្តោតលើខ្លាំងនោះគឺ អតីតទាហាន លន់ នល់ និងជនដែលមានកំណើតជាវៀតណាម។ ប៉ុន្តែភាគច្រើនផ្តោតលើអតីតទាហាន លន់ នល់ ហើយការដាក់ទោសមានកំរិតធ្ងន់បំផុត។

"ប្រជាជនចាស់"បានត្រួតពិនិត្យមើលពួកយើងខ្ញុំ។ ពួកគេមិនទុកចិត្តមកលើពួកយើងឡើយ ហើយបានចាត់ទុកពួកយើងជាខ្មាំងសត្រូវ។ នៅទីនេះ មានមនុស្សស្លាប់ច្រើនណាស់។ ក្នុងចំណោមមនុស្សប្រាំនាក់គឺមានមនុស្សពីរ ឬបីនាក់បានស្លាប់។ មានគ្រួសារជាច្រើនបានស្លាប់អស់ទាំងពូជ។ ការលំបាកបំផុតគឺការខ្វះស្បៀងអាហារ។ យើងពុំអាចហូបបន្លែ និងផ្លែឈើដែលយើងរកបាននោះទេ បើនៅរឹងយើងនឹងត្រូវជាប់ពន្ធនាគារ។ នៅឆ្នាំ១៩៧៧ មានការប្រជុំឃោសនាច្រើនណាស់។ នៅពេលនោះ ការចាត់ទុករវាង "ប្រជាជនចាស់" និង ប្រជាជនថ្មី " មានការខុសគ្នាបន្តិចបន្តួចទេ គឺគ្រាន់តែ "ប្រជាជនចាស់" មានអាទិភាពជាងប្រជាជនថ្មីបន្តិច។

នៅសម័យនោះ គេមានការភ័យខ្លាចរៀងរាល់ពេល។ គេមិនចង់និយាយអ្វីទេ។ គេលាក់ទុករឿងអ្វីៗនៅក្នុងខ្លួនទាំងអស់។ ជនណាដែលបាននិយាយ និងបានធ្វើការតវ៉ាត្រូវបានសំលាប់ចោល។ គេបានធ្វើការចោទ ប្រកាន់យើងថាមាននិន្នាការមូលធននិយម ដែលម្នាក់ៗមានសិទ្ធិធ្វើអ្វីៗតាមចិត្តចង់ និងមានកម្មសិទ្ធិឯកជន។ វិន័យរបស់ពួកខ្មែរក្រហមឱ្យយើងដឹងថា អ្វីៗទាំងអស់ជារបស់សមូហភាព និងមិនមែនជារបស់បុគ្គលផ្ទាល់ខ្លួនឡើយ។ គឺជាអំណាចផ្តាច់ការ។ ប្រសិនបើយើងធ្វើកំហុសអ្វីតូចមួយ គេចាត់ទុកយើងជាខ្មាំងសត្រូវ។ ជនណាហ៊ាន ធ្វើការតវ៉ាត្រូវសំលាប់ចោល។ គឺពុំមានទំនាស់រវាងបុគ្គលនិងបុគ្គលឡើយ។ ប្រសិនបើមានការឈ្លោះទាស់ទែងគ្នា ហើយគេបានដឹងរឿងនោះ មួយថ្ងៃក្រោយមកអ្នកទាំងពីរ ឬជនណាម្នាក់ក្នុងជំលោះត្រូវបាត់ខ្លួន"។

(លោក រឿង អាយុ ៤៥ ឆ្នាំ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

## លក្ខណៈនៃការរស់នៅប្រែប្រួលទៅតាមទីកន្លែង

វិន័យជាមូលដ្ឋានមានលក្ខណៈខ្លីពេក និងដាក់ឱ្យអនុវត្តន៍ឆាប់រហ័សពេក ហាក់ដូចជាមិនសូវបានយល់ច្បាស់ ហើយបានអនុវត្តន៍តាមរបៀបផ្ទាល់ខ្លួន ដោយយោលទៅតាមប្រធានមូលដ្ឋាននីមួយៗ។ សក្ខីកម្មបានបង្ហាញឱ្យឃើញថា មានតំបន់តឹងតែងបំផុត និងតំបន់ធូរស្រាលបំផុត។

"ឆ្នាំ១៩៧៥ ជាដំណាក់កាលមួយថ្មី។ ខ្ញុំបានធ្វើជាទាហានរបស់ខ្មែរក្រហម ហើយខ្ញុំបានធ្វើជាអ្នកយាមនៅទីក្រុង។ ទីក្រុងគ្មានមនុស្សរស់នៅទេ។ នៅទីក្រុងកំពត ពុំមានមនុស្សរស់នៅទេ។ ក្រោយមកខ្ញុំត្រូវបានតែងតាំងជាប្រធានផ្នែកជនពិការ។ ខ្ញុំត្រូវចិញ្ចឹមមនុស្សជាងបីរយនាក់។

ខ្ញុំធ្វើដំណើរច្រើន។ ខ្ញុំបានសង្កេតឃើញមានការខុសគ្នាពីទីកន្លែងមួយទៅទីកន្លែងមួយទៀត។ ខ្ញុំពុំមានសិទ្ធិនិយាយទេ ប៉ុន្តែខ្ញុំបានឃើញ។ មានភូមិខ្លះប្រជាជនហូបបាយ នៅភូមិដទៃទៀតប្រជាជនហូបបបរ ហើយនៅភូមិខ្លះទៀតប្រជាជនហូបបបរលាយព្រលិត។ អ្វីៗទាំងអស់អាស្រ័យលើប្រធានមូលដ្ឋាន និងគណៈតំបន់"។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំ មេឃុំ ឃុំនគរ ស្រុកសៀមរាប ខេត្តសៀមរាប)

"ចាប់តាំងពីឆ្នាំ១៩៧៧ មកខ្ញុំបានទៅរស់នៅតាមបណ្តោយព្រំដែនប្រទេសវៀតណាម។ ខ្ញុំបានផ្លាស់ប្តូរទីកន្លែងពីភូមិមួយទៅភូមិមួយ។ សភាពការណ៍ពុំដូចគ្នាទាំងអស់នោះទេ។ សភាពការណ៍នេះគឺអាស្រ័យដោយប្រធាននីមួយៗ និងដោយស្បៀងអាហារ។ មានកន្លែងខ្លះស្រួលដែលប្រជាជនទាំងអស់បានហូបបាយឆ្អែត ហើយគេពុំបានបែងចែកវណ្ណៈឱ្យខុសគ្នាខ្លាំងពេកទេ។ កន្លែងខ្លះទៀតតឹងខ្លាំងណាស់ ប្រជាជនមានការស្រេកឃ្លានខ្លាំងណាស់ និងមានការសំលាប់មនុស្សច្រើនណាស់។ ប្រជាជនត្រូវបានបែងចែកជាវណ្ណៈ ប៉ុន្តែសភាពការណ៍នេះគឺ អាស្រ័យទៅតាមទីកន្លែង។ ជួនកាលគេហៅប្រជាជនមកពីទីក្រុងថា"ប្រជាជន១៧ មេសា" ហើយនៅទីកន្លែងផ្សេងទៀតគេហៅថា "ប្រជាជនថ្មី" និងនៅកន្លែងក្រៅពីទីនេះទៀត គេពុំបានធ្វើឱ្យមានការខុសគ្នាជាមួយអ្នកដទៃឡើយ។ ទាំងអស់នេះ គឺអាស្រ័យដោយកម្មាភិបាលមូលដ្ឋាន។ ជនខ្លះទៀតបាននិយាយថាសាមគ្គីភាពគឺ មិនត្រូវធ្វើឱ្យមានការរើសអើងទេ។

ប្តីប្រពន្ធបានរស់នៅជាមួយគ្នា ប៉ុន្តែបានជួបមុខគ្នាតិចណាស់។ ប្តីប្រពន្ធបានធ្វើការនៅទីកន្លែងផ្សេងៗគ្នា ហើយជួនកាលបានចេញដំណើរទៅផ្សេងៗគ្នា អស់រយៈពេលមួយខែឬពីរខែដើម្បីលើកទំនប់ទឹក និងធ្វើប្រឡាយទឹក។ គេបានបំបែកកូនចេញពីឪពុកម្តាយ។ គេនិយាយថាឪពុកម្តាយជាកំលាំងទីមួយ ហើយគាត់ត្រូវតែធ្វើការឱ្យអង្គការ។ គឺលំបាកណាស់ ពីព្រោះតែខ្ញុំពុំអាចទទួលបន្ទុកមើលកូនខ្ញុំបាន និងពុំបានជួបមុខប្រពន្ធខ្ញុំឱ្យបានញឹកញាប់។ វិន័យតឹងតែងជាងកាលពីមុន។ ហូបរួមគឺលំបាកណាស់"។

(លោក សាម៉ុន អាយុ ៤២ ឆ្នាំ មេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើត))

## ការពង្រឹងប្រព័ន្ធចាប់តាំងពីឆ្នាំ ១៩៧៧

ចាប់តាំងពីឆ្នាំ១៩៧៧ របបនេះបោះពួយពេញទំហឹង។ បដិវត្តន៍ពុំបានទៅដល់ទីដៅទេ ដោយមូលហេតុៈខ្វះអ្នកជំនាញដើម្បីដឹកនាំធ្វើការងារសង់ទំនប់ទឹកធំៗ ហើយការដ្ឋានជាច្រើនបានរលំរលាយដោយសារគ្មានការគិតគូរមុនឱ្យបានហ្មត់ចត់។ ស្រូវត្រូវបាននាំចេញទៅក្រៅប្រទេសដើម្បីទិញអាវុធឬបានផ្ទុកនៅក្នុងឃ្លាំង ដើម្បីត្រៀមការធ្វើសង្គ្រាមប្រឆាំងពួកវៀតណាម ហើយប្រជាជនបានស្លាប់ដោយអត់អាហារ។

ចំពោះអ្នកដឹកនាំ ការរកហេតុផលពីរចនាសម្ព័ន្ធ គឺជាការទទួលស្គាល់កំហុសរបស់បដិវត្តន៍។ គេទម្លាក់កំហុសទាំងអស់តែទៅលើមនុស្សប៉ុណ្ណោះ។ គេបានតាមដានខ្មាំងសត្រូវបាននៅក្នុងជួររបស់ពួកខ្មែរក្រហមគ្នាឯង។ ពួកជនទាំងនោះត្រូវបានសង្ស័យថា បានធ្វើសម្ព័ន្ធភាពជាមួយពួកយៀកមិញឬបានប្រឆាំងនឹងវិធីរបស់ ប៉ុល ពត ហើយដែលគេយល់ថា មានលក្ខណៈដាច់ខាតជ្រុល។ មានជនខ្លះបានរត់គេចខ្លួនទៅប្រទេសវៀតណាម ហើយបានត្រឡប់មកវិញនៅក្រោយឆ្នាំ១៩៧៩ ដើម្បីកាន់មុខដំណែងជាអ្នកដឹកនាំនៅក្នុងរបបថ្មី។ នៅពេលនោះ ការបោសសំអាតដ៏ធំធេងមួយត្រូវបានធ្វើឡើងនៅពេញទូទាំងប្រទេស។

"ចាប់តាំងពីឆ្នាំ១៩៧៧ មានការចាប់កំហុសច្រើនណាស់ បន្ទាប់មកមានទាំងការដាក់ទោសទៀតផង។ ជនទាំងឡាយដែលបានសហការជាមួយ លន់ នល់ ត្រូវបានសំលាប់រួចទៅហើយ។ គេបានប្រមូលជីវប្រវត្តិរបស់ជនទាំងនោះ។ ពួកអ្នកមានក៏ត្រូវបានសំលាប់មួយចំណែកដែរ។ គេបានចាប់កំហុសពីមនុស្សគ្រប់ប្រភេទមានអ្នករឹងរូស អ្នកទំនាស់ ឧទាហរណ៍ គឺអ្នកដែលមិនចង់ឱ្យគេរុះរើផ្ទះរបស់ខ្លួនដើម្បីយកឈើទៅឱ្យអង្គការ។ អ្នកដែលក្បត់បដិវត្តន៍ជាឧទាហរណ៍ គឺអ្នកដែលមានទំនាក់ទំនងជាមួយពួកចោរព្រៃ ពួកខ្មែរក្រហមក្លែងក្លាយដែលបាននិយាយថា ពួកគេជាក្រុមរបស់ចលនាតស៊ូ អ្នកដែលបានសាកល្បងធ្វើការទាក់ទងជាមួយពួកខ្មាំងសត្រូវ។ គេនិយាយថា មានខ្មាំងសត្រូវ សេ អ៊ី អា(CIA)។ អ្នកដែលត្រូវចាប់កំហុស ត្រូវបានដាក់ទោសនិងសំលាប់ចោល"។

(លោក ម៉ុង អាចារ្យ វត្តភ្នំល្វី សង្កាត់ពងទឹក ក្រុមកែប)

"នៅឆ្នាំ១៩៧៧ មានមនុស្សស្លាប់ច្រើនណាស់ និងមានគំរោងសំលាប់មនុស្សជាច្រើនទៀត។ ឪពុកខ្ញុំដឹងខ្លួនថា គាត់អាចត្រូវគេសំលាប់ពីព្រោះគាត់មិននៅខាង"ប្រជាជន"។ គាត់ជាកម្មករជួសជុលម៉ាស៊ីនបូមទឹកជាច្រើន។ ថ្ងៃមួយ គេបានបញ្ជូនគាត់ឱ្យទៅជីករណ្តៅមួយសំរាប់កប់ខ្លួនគាត់។ គេនិយាយថា គាត់បានធ្វើកំហុសមួយ គឺគាត់បានជួសជុលម៉ាស៊ីនបូមទឹកមិនល្អ។ នោះគឺពុំមែនជាកំហុសរបស់គាត់ទេ គឺដោយសារពុំមានគ្រឿងបន្លាស់ម៉ាស៊ីនបូមទឹក។ ម៉ាស៊ីនបូមទឹកខូចជាញឹកញាប់។ ប៉ុន្តែនៅពេលយប់ ប្រធានផ្នែកមានការអាណិតអាសូរដល់ឪពុកខ្ញុំ ហើយគាត់បានបញ្ជូនឪពុកខ្ញុំឱ្យទៅនៅទីកន្លែងផ្សេងដើម្បីកុំឱ្យគេសំលាប់។ ឯរូបខ្ញុំ ខ្ញុំនៅក្នុងកងចល័ត។ ខ្ញុំចេះតែទៅធ្វើការទៅទំរាំដល់ថ្ងៃស្លាប់។ នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់។ ឪពុកខ្ញុំពុំចង់ ទៅតាមពួកខ្មែរក្រហមទេ ហើយពួកវាបានសំលាប់គាត់។ ឯរូបខ្ញុំ ខ្ញុំបានរស់នៅក្នុងក្រុមកងចល័ត។ ខ្ញុំបានរកលេស ថាខ្ញុំធ្វើដំណើរទៅរកអំបិល ដើម្បីបានឆ្លៀតឱកាសរត់គេចខ្លួន។ ខ្ញុំទៅរកម្តាយខ្ញុំ។ ខ្ញុំបានជួបគាត់នៅក្នុងភូមិកំណើតខ្ញុំ បន្ទាប់មកយើងផ្លាស់ប្តូរ

ទីកន្លែងដើម្បីធ្វើដំណើរទៅរកកន្លែងណាដែលគេអាចរកអ្វីហូបបាន។ ពួកខ្មែរក្រហមបានចូលមកក្នុងភូមិនៅពេលយប់ ហើយបានសំលាប់ប្រជាជនជាច្រើន"។

(លោកស្រី សូមាលី អាយុ ៤៨ ឆ្នាំ សង្កាត់កែប ក្រុមកែប)

"អ្នកខ្លះទៀតបាននិយាយដោយស្ងាត់ថាពួកគេមិនឯកភាពទេ។ ជួនកាល ពួកគេត្រូវបានចាប់កំហុស។ ដូចនេះនៅវិទ្យាល័យស្វាយរៀង សាស្ត្រាចារ្យពីរឬបីរូបត្រូវគេសំលាប់ចោល ពីព្រោះគេបានចោទប្រកាន់គាត់ថា ជាខ្មែរសេរីដូចជា សេ អ៊ី អា ជាដើម។ ការវិនិច្ឆ័យរបស់ពួកខ្មែរក្រហម បានប្រព្រឹត្តទៅនៅពេលធ្វើការប្រជុំ។ នៅឆ្នាំ១៩៧៦ មានការអានអំពីការចោទប្រកាន់នានា បន្ទាប់មក មានការសំលាប់មនុស្សនៅចំពោះមុខប្រជាជន ដើម្បីធ្វើឱ្យប្រជាជនមានការភ័យខ្លាច។ នេះគឺជាច្បាប់ព្រៃ។ សេចក្តីស្លាប់គឺជាការធម្មតា។ ខ្ញុំពុំបានយល់ពីពាក្យស្លោករបស់ខ្មែរក្រហមទាំងអស់ទេ។ ពួកខ្មែរក្រហមបាននិយាយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ គេត្រូវតែយល់ថា ជីវិតរបស់យើងឥតមានតំលៃអ្វីធំដុំទេ។ ចំពោះយើងដែលជាអ្នកគោរពព្រះពុទ្ធសាសនា យើងបានចាត់ទុកពួកខ្មែរក្រហមដូចជាជនឥតសាសនា ដែលមិនទាំងគោរពឪពុកម្តាយរបស់ខ្លួនផង"។

(លោក សាន អាយុ ៧០ ឆ្នាំ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តកំពត)

អតីតនារីកម្មាភិបាលខ្មែរក្រហមម្នាក់ដែលរស់នៅសព្វថ្ងៃនេះ រកឃើញហេតុផលដើម្បីគាំទ្រនយោបាយគ្មានន័យនេះ។

"គំនិតរបស់ពួកខ្មែរក្រហមគឺល្អ។ ប៉ុន្តែនៅក្នុងរបប ប៉ុល ពត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មេដឹកនាំនៅ មូលដ្ឋានភាគច្រើនពុំមានការទទួលខុសត្រូវឡើយ។ មេដឹកនាំទាំងអស់នោះ ពុំបានគិតគូរដល់ផលប្រយោជន៍របស់កសិករទេ។ ពួកគេបានសំលាប់ប្រជាកសិករ និងប្រជាជន។ មេដឹកនាំទាំងនោះ គឺជាជនក្បត់ជាតិ។ ពួកខ្មែរក្រហមបានកសាងទំនប់ទឹក ផ្លូវថ្នល់ ទំនប់តូចៗ ដើម្បីផលប្រយោជន៍របស់ប្រជាជន។ ដោយសារជនក្បត់ជាតិទាំងនោះ គេមើលឃើញតែអំពើអាក្រក់របស់ពួកខ្មែរក្រហម និងមិនឃើញអំពើល្អទេ។ នៅក្នុងសម័យ ប៉ុល ពត គឺពុំមែនតែប្រជាជនទេដែលត្រូវបានសំលាប់។ ពួកខ្មែរក្រហមក៏ត្រូវបានសំលាប់ដែរ ពីព្រោះតែពួកគេបានធ្វើការចោទប្រកាន់គ្នាឯង។

នៅក្នុងសម័យនោះ គេបានរស់នៅស្រួល និងមានសន្តិភាព។ នៅពេលត្រឡប់មកពីធ្វើការវិញនៅពេលល្ងាច ម្ហូបអាហារត្រូវបានរៀបចំទុកជាស្រេច។ គេពុំចាំបាច់ខំប្រឹងទេ។ កាលណាគេចង់បានអ្វីមួយ អ្នកម្នាក់ទៀតមកធ្វើឱ្យយើង: ស្បៀងអាហារ សំលៀកបំពាក់(...)។ មានប្រព័ន្ធ

ដោះស្រាយបញ្ហាល្អ យើងបានដោះស្រាយបញ្ហារវាងយើងទាំងអស់គ្នាដោយធ្វើការប្រជុំ ហើយគេធ្វើការអប់រំ។ គឺជាការប្រជុំស្វ័យទិទៀនរវាងយើងទាំងអស់គ្នាដែរ។ គេបានធ្វើការប្រជុំជាក្រុមតូចគឺ"ពួក"។ កាលណាខ្ញុំបានចាប់កំហុសពីជនណាម្នាក់ ខ្ញុំនិយាយទៅគាត់ថា "មិត្តឯងបានធ្វើកំហុសដែលពុំស្របតាមគោលការណ៍របស់អង្គការ ដូចនេះខ្ញុំចង់ឱ្យមិត្តឯងកែខ្លួនឱ្យបានល្អ"។ ជនដែលត្រូវគេចោទបានឆ្លើយថា "ខ្ញុំសូមទទួលស្គាល់កំហុសរបស់ខ្ញុំ ដូចនេះខ្ញុំសូមសន្យាថាខ្ញុំពុំធ្វើឱ្យមានកំហុសជាថ្មីទៀតឡើយ"។ មានការដាក់ទោស ប៉ុន្តែគេនិយាយទៅកាន់ជនដែលបានធ្វើខុសថា ត្រូវតែធ្វើតាមបទបញ្ជា។ គេក៏អាចធ្វើការទិតៀនក្នុងវង្សត្រកូលបានដែរដើម្បីជួយគ្នា។ ឧទាហរណ៍ បងប្រុសអាចនិយាយថា ប្អូនស្រីពុំបានដាំបាយឱ្យបានឆ្អិនល្អ ថាប្អូនស្រីពុំបានទៅរកអុសដុត ថាប្អូនស្រីពុំបានរែកទឹកដាក់ពាងឱ្យពេញ។ អ្នកត្រូវគេចោទប្រកាន់បានសារភាពកំហុសរបស់ខ្លួន។ គាត់ដឹងគុណចំពោះជនទាំងឡាយដែលបានបង្ហាញពីកំហុសរបស់គាត់។ គេមានការសប្បាយចិត្តដោយបានគេទិតៀន។ គេនិយាយថា "ពីមុនខ្ញុំខ្ជិល ខ្ញុំហត់ណាស់ ប៉ុន្តែនៅថ្ងៃស្អែកខ្ញុំនឹងធ្វើឱ្យបានល្អ"។ នៅក្នុងពេលប្រជុំ ម្នាក់ៗត្រូវតែលើកបង្ហាញពីកំហុសរបស់ខ្លួនដើម្បីឱ្យគេអប់រំ។ គេមានការសប្បាយចិត្ត កាលណាមានអ្នកណាម្នាក់បានលើកកំហុស។ គេបានរៀនសូត្រដើម្បីកែលំអ។

នៅពេលប្រជុំ អ្វីទាំងអស់សុទ្ធតែបានកត់ត្រាទុក។ មនុស្សម្នាក់ៗ មានសំណុំរឿងមួយ។ អ្នកដែលបានចូលក្នុងចលនាតស៊ូតាំងពីពេលយូរមកហើយ ហើយដែលពុំបានប្រព្រឹត្តឱ្យបានត្រឹមត្រូវល្អ គឺនៅតែមានឋានៈទាបដដែល។ ចំពោះអ្នកណាដែលបានគោរពបទបញ្ជាយ៉ាងត្រឹមត្រូវអាចឡើងបុណ្យស័ក្តិ(...)។ ដូចជាខ្ញុំដែលបានធ្វើការល្អ ខ្ញុំបានធ្វើជាប្រធានឃុំ។

នៅសម័យ ប៉ុល ពត ទោះគេពុំសូវមានសេរីភាពក្តី ប៉ុន្តែមានយុត្តិធម៌ និងមានសន្តិភាព។ មនុស្សម្នាក់ៗ បានធ្វើការត្រួតពិនិត្យដោយខ្លួនឯង និងបានទប់ស្កាត់បញ្ហានានា។ គឺពុំមានជំលោះ និងទំនាស់រវាងគ្នាឡើយ។

(លោកស្រី កាក់ អាយុ ៤៧ ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប)

នៅឆ្នាំ១៩៧៩ ក្រោយពីមានការប៉ះទង្គិចគ្នាជាច្រើនលើកនៅតាមបណ្តោយព្រំដែនកងទ័ពវៀតណាមបានរំដោះប្រទេសឱ្យរួចផុតពីពួកខ្មែរក្រហម ហើយបានតាំងនៅក្នុងប្រទេសនេះអស់រយៈពេល១០ឆ្នាំ។ កងទ័ពវៀតណាមចូលមកកម្ពុជាជាមួយនឹងក្រុមនយោបាយខ្មែរពីរក្រុម។ មួយក្រុម គឺជាពួកកុម្មុយនីស្តជើងចាស់ដែលបាននិរទេសខ្លួនក្នុងពេលប្រទេសបានទទួលឯករាជ្យនៅឆ្នាំ១៩៥៤ និងក្រុមអតីតកម្មាភិបាលខ្មែរក្រហមនិយមកណ្តាលដែលបានរត់គេចខ្លួនពីការបោសសំអាតពីឆ្នាំ១៩៧៧-១៩៧៨។ អ្នកទាំងនេះគឺជាអ្នកដឹកនាំថ្មីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

## សំយោគជំពូក ១: មរតកពីអតីតកាល

## ការដោះស្រាយទំនាស់មូលដ្ឋាន : ឆ្នាំដែលមានក្តីភ័យរន្ធត់ : ១៩៧៥-១៩៧៩

*ភាពកោលាហលជាច្រើនឆ្នាំនេះ បានបណ្តាលឱ្យមានការវិនាសអន្តរាយយ៉ាងខ្លាំងក្លា គ្រោងសាងនៃសង្គមកម្ពុជា និងបានបំផ្លាញគ្រឹះប្រពៃណីជាច្រើន ។ អ្វីៗបានក្រឡាប់ចាក់ទាំងអស់ ។ "គេបានត្រឡប់ជើងទៅជាក្បាល និងក្បាលទៅជាជើងវិញ" ។ នៅក្នុងទីកន្លែងភាគច្រើន ប្រព័ន្ធចាស់ត្រូវបានកំទេចចោលទាំងស្រុង ។ ប្រជាជនត្រូវបានជម្លៀសនិងបង្ខំឱ្យធ្វើការយ៉ាងធ្ងន់ធ្ងរ ដោយពុំមានម្ហូបអាហារគ្រាប់គ្រាន់ ។ សាសនាត្រូវហាមឃាត់មិនឱ្យមាន ។ ក្រដាសប្រាក់ត្រូវបំបាត់ចោល រចនាសម្ព័ន្ធរដ្ឋបាលចាស់ត្រូវបំផ្លាញចោល ។ វត្តអារាម សាលារៀន និង តុលាការបានក្លាយទៅជាឃ្លាំងផ្ទុកស្រូវ ។ មន្ត្រីចាស់នៃរបបលន់ នល់ និងបញ្ញវ័ន្ត ត្រូវគេតាមដាន និងសំលាប់ចោលជាញឹកញយ ។*

*ប្រព័ន្ធថ្មីបានប៉ះពាល់ដល់របស់ជាសារវ័ន្តគឺ គ្រួសារ ។ នៅក្នុងសម័យកាលដ៏ខ្មៅងងឹតរបស់ ពួកខ្មែរក្រហម សមាជិកគ្រួសារត្រូវបានបំបែកចេញពីគ្នា និងត្រូវធ្វើឱ្យចេះចោទប្រកាន់គ្នាទៅវិញទៅមក ។ ទំនាក់ទំនងជាឋានានុក្រមរវាងអ្នកចាស់ទុំ និងយុវជនបានបញ្ច្រាសគ្នាអស់ ។ ឪពុកម្តាយនិងមនុស្សចាស់ៗ ត្រូវបានគេមើលឃើញ ថាជាជនសំណល់នៃរបបប្រតិកិរិយាចាស់ ចំណែកឯក្មេងៗត្រូវបានលើកតំកើងឱ្យធ្វើជាអ្នកដំណាងនៃរបបបដិវត្តន៍ថ្មី ។ ក្មេងៗនិងអ្នកល្ងង់ខ្លៅ បានមកជំនួសកន្លែងបងៗនិងអ្នកចេះដឹង ។ ផលប្រយោជន៍របស់ក្រុមត្រូវនៅពីលើផលប្រយោជន៍របស់បុគ្គល ។*

*សាសនា ត្រូវបានបំបាត់ចោល ។ សុភាសិតនិងពាក្យប្រៀនប្រដៅដែលជាមរតកនៃប្រពៃណីរបស់ប្រជាជនត្រូវជំនួសដោយពាក្យស្លោកនយោបាយ ។*

*នៅក្នុងរបបដែលមើលឃើញហាក់ដូចជាសមភាពស្មើៗគ្នានេះ មនុស្សត្រូវបានចាត់ទៅតាមឋានានុក្រមដោយផ្អែកទៅលើជីវប្រវត្តិ ។ ជនក្រីក្របំផុតនិងអ្នកល្ងង់ខ្លៅបំផុតមានមុខងារជាអ្នកបញ្ជានិងមានប្រៀបលើអាជ្ញាធរនិងបញ្ញាវ័ន្តនៃរបបចាស់ដែលត្រូវបានសំលាប់ចោលដោយសារតែការធ្វើខុសបន្តិចបន្តួច ។ ការអនុវត្តន៍ការសំរុះសំរួលទំនាស់តាមបែបប្រពៃណីត្រូវបំបាត់ចោល ហើយយកការប្រជុំស្វ័យទិតៀន និងការចាប់កំហុសគ្នាមកជំនួសវិញ ។ ទំនាស់បញ្ហាទាំងអស់គឺជាការរាំងស្ទះដល់ដំណើរឈានទៅមុខរបស់បដិវត្តន៍ ។ គេត្រូវតែទទួលការអប់រំឡើងវិញ និងទទួលទោសពីបទប្រឆាំងបដិវត្តន៍ ។*

*ពួកខ្មែរក្រហមបានប្រើប្រាស់ការបំភិតបំភ័យ និងការត្រួតត្រាជាប្រចាំធ្វើជាអាវុធដើម្បីទប់ទល់គំនិតប្រឆាំង និងការសំដែងមនោសញ្ចេតនាផ្ទាល់ខ្លួន ។ ដើម្បីអួតពីអនុភាពនៃបដិវត្តន៍របស់ខ្លួន ពួកខ្មែរក្រហមបានសំអាងទៅលើហេតុផលមួយគឺ សង្គមមួយគ្មានពន្ធនាគារ គ្មានចោរ និងគ្មានទំនាស់ ប៉ុន្តែពួកខ្មែរ*

ក្រហមពុំបានបញ្ជាក់អំពីមធ្យោបាយផ្តាច់ការ ដែលពួកខ្លួនបានដាក់ឱ្យប្រជាជនអនុវត្តន៍ ដើម្បីបានឈាន ទៅដល់ទីដៅឡើយ ។ ទំនាស់ដីធ្លីពុំកើតមានឡើយដោយសារគេបានដាក់ដីធ្លីជារបស់សម្ពហភាព ។ ទំនាស់គ្រួសារបានថយចុះជា អប្បបរមាដោយសារតែការបំបែកសមាជិកគ្រួសារជាញឹកញាប់ និងការត្រួតពិនិត្យតាំងពីអំពើ និងកាយវិការតូចតាច ។ អ្នកដែលងាកចេញពីគោលការណ៍ជាមូលដ្ឋានគឺការធ្វើការងារ និងរក្សាការស្ងៀមស្ងាត់ ត្រូវមានទោសឬត្រូវសំលាប់ចោល ។

នៅក្នុងប្រពន្ធ័ដែលត្រឡប់ត្រឡិនបែបនេះ[១១៩] កាលណាមានទំនាស់កើតឡើង ការស្វែងរកពិរុទ្ធជនដើម្បីដាក់ទោសបានមកជំនួសការស្វែងរកការស្រុះស្រួលគ្នាបែបប្រពៃណីរវាងគូជម្លោះ ។ សង្គមទាំងមូលត្រូវបានកេណ្ឌ ឱ្យតាមដានរកអ្នកប្រព្រឹត្ត "កំហុស" ។ ផ្ទុយពីធ្វើឱ្យស្ងប់ទំនាស់ ទោះបីជាត្រូវបំបិទទំនាស់ក្តីរបបថ្មីបែរជាទាមទារឱ្យតាមដាននិងធ្វើការចាប់កំហុសជាសាធារណៈនូវគ្រប់ "កំហុស" ទាំងអស់ ។ សេចក្តីភ័យខ្លាចនិងការមិនទុកចិត្តគ្នា រវាងប្រជាជនគ្នាឯងបានឋិតនៅអស់ពេលដ៏យូរ ។

ក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត សង្គមកម្ពុជាដែលមានការរង្គោះរង្គើរយ៉ាងខ្លាំងនោះ បានធ្វើការសាកល្បងផ្សាភ្ជាប់សំណល់ប្រពៃណីដែលមានការរេចរិលយ៉ាងធ្ងន់ធ្ងរជាមួយនឹងគោលការណ៍ថ្មីៗ ដែលបានហូរចូលមកពីខាងក្រៅកាន់តែច្រើនឡើងវិញ ។

---

[119] . គេអាចធ្វើការសង្កេតឃើញថា អង្គការដែលចង់បំផ្លាញមូលដ្ឋានគ្រិះតាមបែបប្រពៃណី ដោយប្រែត្រឡប់មូលដ្ឋានគ្រិះទាំងនោះ ពុំអាចធ្វើឱ្យរួចផុត ពីភាពច្របូលច្របល់នៃវប្បធម៌ខ្មែរបានឡើយ: ការគោរពតាមឋានន្តរសក្តិ ភាពអ្នកលាក់មុខនៅចំពោះមុខប្រធាន ការចូលរួមនៅក្នុងចលនាកុម្មុយនីស្ត ដោយធ្វើត្រាប់តាមព្រះសង្ឃដែលគង់នៅតាមវត្តអារាមដោយគោរពតាមគោលការណ៍នានា ។

## ៤. ការកសាងឡើងវិញដ៏លំបាកៈ ១៩៧៩-១៩៩៣

រដ្ឋាភិបាលថ្មី ត្រូវបានបង្កើតនៅខែមករា ឆ្នាំ១៩៧៩ ដោយមានការឧបត្ថម្ភពីរបបវៀតណាម។ ប្រទេសកម្ពុជាបានក្លាយទៅសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ដោយធ្វើតាមឱវាទរបស់កម្មុយនីស្ត ប្រទេសជាតិបានបោះ ជំហ៊ានទៅក្នុងដំណាក់កាលនៃការកសាងប្រទេសឡើងវិញ នៅពេលដែលហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លាញទាំងស្រុង ។ គ្រួសារជាច្រើនបាន បែកខ្ញែកគ្នានិងមានកើតទុរ្ភិក្ស។

នៅក្នុងរយៈពេលដំបូង អ្នកដែលមានជីវិតរស់នៅ បានព្យាយាមធ្វើដំណើរត្រឡប់ទៅភូមិកំណើតរបស់ខ្លួនវិញតាមមធ្យោបាយដែលអាចធ្វើទៅបាន ដើម្បីទៅរកសមាជិកគ្រួសាររបស់ខ្លួនវិញ។ នៅក្នុងភាពច្របូកច្របល់នេះ គ្រួសារជាច្រើនបានរកស៊ីចិញ្ចឹមជីវិតមួយថ្ងៃសំរាប់មួយថ្ងៃ ហើយបានសាកល្បងធ្វើការប្រមូលរបស់របរទាំងអស់ដែលខ្លួនអាចធ្វើទៅកើត។ ប្រជាជនបានចូលទៅលួចរបស់របរផ្សេងៗដែលមាននៅក្នុងឃ្លាំង និងការដ្ឋានសំណង់របស់កម្ពុជាប្រជាធិបតេយ្យ។ ការសំលាប់ពួកអតីតខ្មែរក្រហមដោយមិនចាំបាច់មានការវិនិច្ឆ័យបានកើតមានឡើង។ សភាពការណ៍ដីធ្លីមានលក្ខណៈអាណាធិបតេយ្យទាំងស្រុង។ នៅកន្លែងជាច្រើន ដីស្រែរាងក្រឡាចតុរង្គរបស់ពួកខ្មែរក្រហមបានធ្វើឱ្យបាត់បង់ព្រំដីចាស់សំរាប់ដាំដំណាំ។ ម្ចាស់កម្មសិទ្ធិចាស់បានស្លាប់ ឬចេញ ទៅរស់នៅទីកន្លែងផ្សេងទៀត ឬមួយពុំទាន់បានវិលត្រឡប់មកវិញ។ ប្រជាជនម្នាក់ៗ តាំងទីលំនៅនៅកន្លែងណា ដែលខ្លួនអាចធ្វើបាន។ នៅទីក្រុងភ្នំពេញ ម្ចាស់កម្មសិទ្ធិជាច្រើន និងឯកសារដែលទាក់ទងទៅនឹងកម្មសិទ្ធិដីធ្លី បានបាត់បង់អស់នៅក្នុងពេលមានចលាចល។ ទីក្រុងបានក្លាយទៅជាទីកន្លែងរស់នៅគ្មានរបៀបភាគច្រើន គឺប្រជាជនមកពីស្រុកស្រែចំការ[១២០] មក។ សភាព-ការណ៍ដីធ្លីនេះក៏បានផ្ទុះឡើងយ៉ាងខ្លាំង។

មានប្រជាជនចំនួន២៥០.០០០ នាក់បានជ្រើសរើសយកការធ្វើដំណើរទៅព្រំដែនថៃ ដោយសំដៅទៅរកជំរុំជនភៀសខ្លួន។

ជីវភាពបានរៀបចំឡើងវិញដោយមានការលំបាកយ៉ាងខ្លាំង។ រដ្ឋាភិបាលបានរៀបចំឱ្យមានក្បាលម៉ាស៊ីនរដ្ឋបាលមួយ និងបានសំរេចការពារទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ និងទ្រព្យសម្បត្តិរបស់ពួកខ្មែរក្រហមដែលបានបោះបង់ចោល ដោយប្រកាសថាទ្រព្យសម្បត្តិទាំងនេះជាសម្បត្តិរដ្ឋទាំងអស់។

---

120 . ដោយឋិតនៅជាគោលដៅពិសេសរបស់ពួកខ្មែរក្រហម អ្នកទីក្រុងភ្នំពេញជាច្រើនបានស្លាប់។ អ្នកដែលមានជីវិតរស់នៅជាច្រើនទៀតបានជ្រើសរើសផ្លូវនិរទេសខ្លួនទៅជំរុំជនភៀសខ្លួននៅប្រទេសថៃ។ ក្នុងចំណោមជនទាំងនោះ មានអ្នកខ្លះបានចេញដំណើរទៅប្រទេសអ្នកទទួលមានៈ សហរដ្ឋអាមេរិក, បារាំង កាណាដា...

ដើម្បីបង្កើនផលិតផល និងត្រួតពិនិត្យប្រជាជន ជាដំបូងរដ្ឋាភិបាលបានបង្កើតក្រុមការងារកសិកម្មរួមគឺក្រុមសាមគ្គី។ ប៉ុន្តែប៉ុន្មានឆ្នាំក្រោយពីរបបខ្មែរក្រហម ប្រជាកសិករបានទាត់ចោលគ្រប់ទំរង់សមូលហភាព ហើយបានធ្វើស្រែចំការតាមបែបឯកជនវិញភ្លាមដែរ។ បន្ទាប់មកដើម្បីកុំឱ្យមានភាពអាណាធិបតេយ្យផ្នែកដីធ្លី និងដើម្បីជៀសវាងកុំឱ្យមានទំនាស់ដែលមិនអាចដោះស្រាយបាន រដ្ឋាភិបាលបានចេញអនុក្រឹត្យមួយដែលចែងថា ដីធ្លីជាកម្មសិទ្ធិរបស់រដ្ឋ។ រដ្ឋជាអ្នកទទួលបន្ទុកធ្វើការបែងចែកជូនគ្រួសារទាំងឡាយដែលរស់នៅលើដីធ្លីទាំងនេះ។ ប្រជាជនសំរបបានគួរសមទៅនឹងសភាពការណ៍ថ្មីនោះ។

ជីវភាពប្រចាំថ្ងៃ បានវិលត្រឡប់ទៅរកសភាពការណ៍ មុនសម័យខ្មៅងងឹតបន្តិចម្តងៗ។ ទីផ្សារ និង សាលារៀនបានបើកទ្វារឡើងវិញ។ ការធ្វើដំណើរ ទោះបីមានការលំបាកក្តីក៏អាចធ្វើទៅបាន។ ក្រដាសប្រាក់ត្រូវបានបង្កើតឱ្យមានឡើងវិញ។ ប៉ុន្តែសភាពការណ៍ ក៏នៅតែមានការលំបាក នៅក្រោមរបបកុម្មុយនីស្តនេះ នៅពេល ដែលអ្នកបានមកជួយរំដោះនោះត្រូវបានគេមើលឃើញយ៉ាងឆាប់ថា ជាអ្នកឈ្លានពានទៅវិញ។ សហគមន៍ អន្តរជាតិពុំបានទទួលស្គាល់រដ្ឋាភិបាលថ្មីនេះទេ ហើយក៏បានធ្វើការដាក់ទណ្ឌកម្មសេដ្ឋកិច្ចមកលើប្រទេសដែលនៅ មានការបង្ហូរឈាមនៅឡើយ។

ជំលោះប្រដាប់អាវុធបានចាប់ផ្តើមឡើងវិញ។ នៅក្នុងឆ្នាំ១៩៧៩ ពួកខ្មែរក្រហមពុំអាចទប់ទល់ប្រឆាំងនឹងការតស៊ូដ៏ខ្លាំងក្លានៃកងទ័ពវៀតណាមដ៏មានអនុភាពបានឡើយ។ ពួកខ្មែរក្រហមត្រូវបានរុញច្រានឱ្យទៅរស់នៅតាមបណ្តោយព្រំដែនថៃ។ នៅតាមបណ្តោយព្រំដែនថៃ ពួកខ្មែរក្រហមបានបង្កើតកងកំលាំងចំរុះជាមួយកំលាំងចលនាតស៊ូរបស់សម្តេចសីហនុដែលដឹកនាំដោយ ព្រះរាជបុត្ររបស់ព្រះអង្គគឺ ព្រះអង្គម្ចាស់រណឫទ្ធិ និង កំលាំងអ្នកជាតិនិយមរបស់លោក សឺន សាន។ ជាច្រើនឆ្នាំក្រោយមក ដោយមានជំនួយរបស់មហាអំណាចបរទេស[១២១] ពួកខ្មែរក្រហមបានប្រមូលផ្តុំឡើងវិញ ហើយទទួលធ្វើកិច្ចប្រតិបត្តិការលើទឹកដីដ៏ធំធេងក្នុងតំបន់ខាងជើងនិងខាងលិចប្រទេស។ ថវិកាជាតិពាក់កណ្តាលត្រូវបានបំរុងទុកសំរាប់ធ្វើសង្គ្រាម។ ទោះបីពុំមានវិធានការដែលមានលក្ខណៈដូចរបបមុនក៏ដោយ ការបំផិតបំភ័យ គំរាមគំហែង និងការបង្ខំក៏នៅតែធ្វើឱ្យប្រជាជនរស់នៅ ក្នុងការភ័យខ្លាច អាជ្ញាធរដដែល។ ប្រជាជននៅតាមភូមិ និងទីក្រុងបានចូលបំរើកងយោធា ឬធ្វើការជាកម្មករនៅតាមបណ្តោយព្រំដែនថៃ ដើម្បីកសាងខ្សែបន្ទាត់ការពារមួយដ៏វែងប្រឆាំងពួកខ្មែរក្រហមដែលគេឱ្យឈ្មោះថា "ផែនការ ក-៥" ចាប់តាំងពីឆ្នាំ១៩៨៥ មក។ ប្រជាជនជាច្រើនបានបាត់បង់ជីវិតនៅក្នុងតំបន់ទាំងនោះដោយសារជំងឺគ្រុនចាញ់ និងគ្រាប់មីន។ ដោយត្រូវ

---

[121] . នៅក្នុងពេលនេះ គឺប្លុកសូវៀតដែលបានជួយប្រទេសវៀតណាម និង ប្លុកចិនដែលនៅ ខាងពួកខ្មែរក្រហម។ ប្រទេសលោកខាងលិចជាច្រើនក៏បានផ្តល់ ជំនួយជាច្រើនដល់កម្លាំងអ្នកតស៊ូ។

គេដេញតាមចាប់ ឬអ្នកខ្លះទៀតចង់គេចឱ្យផុតពីការកេណ្ឌឱ្យចូលធ្វើទាហាន អតីតខ្មែរក្រហមនៅសេសសល់បានពង្រីកជួរកងទ័ពតស៊ូរបស់ខ្លួនឱ្យកាន់តែធំឡើងថែមទៀត។

ក្រោមការគាបសង្កត់អន្តរជាតិ និងដោយសារការដកខ្លួនថយទាំងផ្នែកយោធានិងហិរញ្ញវត្ថុរបស់សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតចេញពីប្រទេសវៀតណាម[១២២] កងទ័ពវៀតណាមបានដកចេញពីកម្ពុជានៅឆ្នាំ១៩៨៩។ រដ្ឋាភិបាលថ្មីមួយគឺ "រដ្ឋកម្ពុជា" ត្រូវបានបង្កើតឡើង។ រដ្ឋាភិបាលនេះមានសមាសភាពជនជាតិខ្មែរជាច្រើនដែលបានធ្វើការនៅក្នុងរបបមុន និងដែលបានរត់គេចខ្លួនទៅប្រទេសវៀតណាមនៅពេលដែលពួកខ្មែរក្រហមបានធ្វើការបោសសំអាត។

ច្បាប់ភូមិបាលមួយ បានទទួលស្គាល់កម្មសិទ្ធិរបស់ជនទាំងឡាយណាដែលបានកាន់កាប់ដីធ្លី និងបានដាំដំណាំនៅក្នុងសម័យនោះ។ ច្បាប់ថ្មីនេះ បានបញ្ចប់ចំណោទខាងផ្លូវច្បាប់ចំពោះជំលោះជាច្រើនដែលមានការទាក់ទងទៅនឹងដីធ្លី និងអាគារនានាដែលទាមទារដោយម្ចាស់កម្មសិទ្ធិមុនឆ្នាំ១៩៧៥។ ក៏ប៉ុន្តែ សំណុំរឿងពុំទាន់បានបញ្ចប់នៅឡើយទេ។ រហូតមកដល់សព្វថ្ងៃនេះ ប្រទេសត្រូវដោះស្រាយបញ្ហាដីធ្លីដែលជាចំណែកនៃមរតកក្នុងសម័យច្របូកច្របល់នោះ។

នៅឆ្នាំ១៩៩១ កិច្ចព្រមព្រៀងទីក្រុងប៉ារីសបានបើកឱ្យមានសេចក្តីសង្ឃឹមក្នុងការធ្វើការផ្សះផ្សាជាតិ និងការបញ្ចប់សង្គ្រាម។ ភាគីទាំងបួនដែលបានច្បាំងគ្នាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលនាំឱ្យមានការបោះឆ្នោតដោយសេរីនៅកម្ពុជា ក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។

ដើម្បីធ្វើការឆ្លុះបញ្ចាំងឱ្យបានច្បាស់អំពីភាពស្មុគស្មាញនៃបញ្ហាមួយចំនួនដូចជា ទំនាស់ដីធ្លី និងការ លំបាកក្នុងការដោះស្រាយបញ្ហាទាំងអស់នោះនៅក្នុងពេលបច្ចុប្បន្នកាលនេះ យើងនឹងបង្ហាញជូនអំពីបរិបទអាណាធិបតេយ្យ ដែលបានបន្តមកនៅក្រោយពេលបញ្ចប់របបខ្មែរក្រហម និងដំណោះស្រាយនានាដែលរដ្ឋាភិបាលថ្មីបានសំរេចដើម្បីរៀបចំប្រទេសឡើងវិញដើម្បីគ្រប់គ្រងប្រជាជន និងដោះស្រាយទំនាស់នៅតាមមូលដ្ឋាននានា។

## ៤.១. <u>ការកសាងក្របខណ្ឌជីវភាពឡើងវិញ</u>

### ការវិលត្រឡប់ទៅភូមិកំណើតវិញ

នៅក្នុងតំបន់ដែលកងទ័ពវៀតណាមបានរំដោះរួចហើយ ប្រជាជនខ្មែរដែលក្លាយខ្លួនជាមនុស្សអប្បប្រាជ្ញា និងមានការស្រេកឃ្លានយ៉ាងខ្លាំង បានខិតខំធ្វើដំណើរទៅស្រុកកំណើតរបស់ខ្លួន។ អ្វីៗទាំងអស់ត្រូវកសាង

[122] . ផលវិបាកនៃនយោបាយកែទំរង់របស់លោក Michael Gorbethev ។

ឡើងវិញ។ សភាពការណ៍មានលក្ខណៈអាណាធិបតេយ្យ ប៉ុន្តែសាមគ្គីភាពហាក់ដូចជាចេញរូបរាងឡើងយ៉ាងហោចណាស់ក៏នៅក្នុងដំណាក់កាលដំបូងដែរ។ ពេលនោះពុំមែនជាពេលឈ្លោះគ្នាទេ ប៉ុន្តែគឺជាពេលកសាងជំរក និងពេលរកស្បៀងអាហារ។ បន្ទាប់មក សភាពការណ៍បានវិវឌ្ឍន៍ទៅមុខ ហើយបញ្ហាដីធ្លីក៏ចោទមានឡើង។

ក្រោយឆ្នាំ១៩៧៩ភ្លាម ប្រជាជនបានគិតតែអំពីបញ្ហាជីវភាពផ្ទាល់ខ្លួនឯង និងកុំបានគិតពីជំលោះទេ។ ប្រជាជនបានជួយគ្នាទៅវិញទៅមក ត្រូវការគ្នាទៅវិញទៅមក។ ប្រជាជនមានគោតិចតួចណាស់ដើម្បីភ្ជួរស្រែ ចំការ មានសំភារៈតិចតួចសំរាប់សង់ផ្ទះ។ គេបានជួយគ្នាទៅវិញទៅមក។ អ្នកណាមានគោ និងសំភារៈបានឱ្យអ្នក ដទៃខ្ចីដើម្បីធ្វើការងារ(...)។ គេគិតតែធ្វើយ៉ាងណាឱ្យបានរស់ តែប៉ុណ្ណឹងគឺគ្រប់គ្រាន់ហើយ។ ប្រជាជនទាំង អស់ស្រលាញ់គ្នាណាស់ ហើយពុំមានបញ្ហារវាងគ្នានឹងគ្នាទេ។ សម័យនោះពុំទាន់មានលុយកាក់ទេ។ ប្រជាជន ទាំងអស់គ្នាមានជីវភាពស្មើៗគ្នា។ ប្រជាជនមានបញ្ហាដូចៗគ្នា និងជួយគ្នាទៅវិញទៅមក។ បន្ទាប់មក ជំលោះបានចាប់ផ្តើមដោយសារបញ្ហាដីធ្លី។ ប្រជាជនម្នាក់ៗចង់បានដីមានជីជាតិ(ដីល្អ)។ គឺមានរឿងជាច្រើននៅក្នុងគ្រួសារ។ បញ្ហាគឺនៅពេលដែលឪពុកម្តាយស្លាប់បាត់ទៅពុំបានធ្វើការបែងចែកដីឱ្យកូនៗនៅឡើយ។ កូនៗ ចាប់ផ្តើមឈ្លោះគ្នាឯងដើម្បីបានដីល្អ។ គឺមានជម្លោះច្រើនដូចកាលពីពេលមុនដែរ។ នៅក្នុងសម័យពួកខ្មែរក្រហម ប្រជាជនបានដឹងពីរបៀបលៃយ៉ាងណាឱ្យបានរស់រៀងៗខ្លួន។ គេរៀនចេះ ភូតកុហក់ ចេះលួច ចេះលាក់គំនិត និងចេះលាក់ពុត។ ក្រោយមកប្រជាជនពុំចង់ប្រគល់អ្វីទៅឱ្យអ្នកដទៃឡើយ។ អ្នកខ្លះបានវិលត្រឡប់ទៅរកតំលៃ"ប្រពៃណី" ហើយអ្នកខ្លះទៀតបាននៅថែរក្សាទំលាប់ចាស់ដដែល។ មនុស្សគិតតែ"ខ្លួនឯង" គេចង់តែគិតថាខ្លួនគេត្រូវ ហើយមិនចង់ពិភាក្សាជាមួយអ្នកណា។ គឺពិបាកណាស់។

(លោក ឈួន អាយុ ៥៧ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ចាស់ទុំបានសង្កេតឃើញថា សង្គមមានការផ្លាស់ប្តូរ។ ប្រជាជនបានវិលត្រឡប់ទៅពឹងលើខ្លួនឯងវិញ បន្តិចម្តងៗ ដោយខ្វល់ខ្វាយតែពីធ្វើយ៉ាងណាឱ្យបានរស់។ តំលៃប្រពៃណីបានប្រែក្រលាស់អស់។ ការភ័យខ្លាច និងការមិនទុកចិត្តអ្នកដទៃមានទំហំធំធេងណាស់ ។

"កាលពីជំនាន់សង្គមរាស្ត្រនិយមគឺពុំមានបញ្ហាច្រើនរវាងប្រជាជនគ្នាឯងទេ។ គឺពុំមានចោរនៅក្នុងភូមិទេ។ ក្រោយសម័យ ប៉ុល ពត ប្រជាជនមានលក្ខណៈខុសគ្នា។ គឺយ៉ាប់ទៅៗ។ ប្រជាជនពុំមានការជឿទុកចិត្តគ្នាទៅវិញទៅមកទេ និងពុំសូវចេះជួយគ្នាប៉ុន្មានទេ។ ម្នាក់ៗគិតតែពីខ្លួន

ឯង។ ម្នាក់ៗបានចេះដឹងក្នុងការរកវិធី ដោះស្រាយដោយខ្លួនឯងដើម្បីបានរស់និងមិនមានការទុកចិត្តទៅលើអ្នកដទៃឡើយ"។

(លោក សេង អាយុ ៥៧ ឆ្នាំ ឃុំពងទឹក ក្រុងកែប)។

"អ្វីដែលគេបានកត់សំគាល់ គឺការភ័យខ្លាច។ នៅក្រោយសម័យ ប៉ុល ពត ប្រជាជននៅតែមានការភ័យខ្លាចជាបន្តទៀត។ ប្រជាជននៅតែគិតពីការធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីបានរស់ និងពុំបង្កើតឱ្យមានបញ្ហាសោះឡើយ។ ប្រសិនបើប្រជាជនចង់ដាំដំណាំនៅលើដីមួយកន្លែងគាត់បានចាប់យកដីនោះ ហើយពុំបង្កើតឱ្យមានរឿង អំពីព្រំដីឡើយ។ គាត់ពុំមានគំនិតចង់ធ្វើជាម្ចាស់កម្មសិទ្ធិអ្វីទេ។ គាត់គិតតែពីធ្វើដូចម្តេចដើម្បីឱ្យខ្លួនគាត់និង គ្រួសារគាត់បានគង់វង្សអាយុជីវិត។ នៅពេលក្រោយមកទៀត ដោយសារជីវភាពមានលក្ខណៈប្រសើរឡើងហើយ ប្រជាជនពុំសូវមានការភ័យខ្លាចទេ ហើយគាត់បាននឹកគិតទៅដល់លុយកាក់។ ហេតុដូច្នេះហើយបានជាកើតមានទំនាស់ជាច្រើនរវាងប្រជាជនគ្នាឯង។ កាលពីមុន ប្រជាជនបានគិតតែពីធ្វើអ្វីៗដើម្បីបានរស់។ ក្រោយមកប្រជាជន គិតតែការចង់បានចង់មាន"។

(លោកស្រី សូម៉ាលី អាយុ ៤៨ ឆ្នាំ សង្កាត់កែប ក្រុងកែប)

"ប្រជាជនមានការផ្លាស់ប្តូរហើយ។ ក្មេងៗលែងគោរពមនុស្សចាស់ទៀតហើយ។ នៅក្នុងសម័យខ្មែរក្រហម របបបានប្រែត្រឡប់ផ្ទុយគ្នាអស់។ ក្មេងៗបញ្ជាមនុស្សចាស់(...)។ មនុស្សជាច្រើនបាននាំគ្នាផឹកស្រា គេចង់សប្បាយរីករាយ។ នៅសម័យ ប៉ុល ពត វាយ៉ាប់ គេមានកង្វល់ច្រើនណាស់ ហេតុដូចនេះហើយបានជាពួកគេ គិតតែពីការសប្បាយរីករាយ។ ការសេពសុរាមានចំនួនច្រើនហួសហេតុ ប៉ុន្តែគឺជាការបន្ធូរបរិយាកាស"។

(លោក សាន អាយុ ៥០ ឆ្នាំ អាចារ្យឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

នៅក្នុងភូមិដែលចូលទៅខាងកងទ័ពលោក លន់ នល់ មានមនុស្សស្លាប់ច្រើនណាស់។ គេត្រូវតែកសាងភូមិឡើងវិញដោយមនុស្សតែមួយភាគដែលនៅសល់។ សភាពការណ៍ដីធ្លីមានលក្ខណៈអាណាធិបតេយ្យ។

"នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់ ពួកខ្មែរក្រហមបានប្រាប់ពួកយើងឱ្យធ្វើដំណើរឆ្ពោះទៅទិសខាងលិច។ យើងបានធ្វើដំណើររហូតដល់ខេត្តបាត់ដំបង។ យើងមានការភ័យខ្លាចណាស់ ហើយពុំដឹងថាត្រូវទៅខាងណា។ មានការប្រយុទ្ធគ្នាជាច្រើនកន្លែង។ ក្រោយមកទាហានវៀតណាមបានប្រាប់យើងថា យើងអាចធ្វើដំណើរវិលត្រឡប់ទៅស្រុកកំណើតវិញបាន។ យើងបានវិលត្រឡប់មកស្រុកកំណើតវិញ។ អ្វីៗនៅក្នុងភូមិបានផ្លាស់ប្តូរអស់។ មានមនុស្សស្លាប់ច្រើនណាស់។ អ្នកស្រុកប្រហែលពាក់កណ្តាលបានស្លាប់ពីព្រោះពួកយើង ចូលខាងលោក លន់ នល់។

មនុស្សបានផ្លាស់ប្តូរ។ ភូមិក៏មានការប្រែប្រួលដែរ។ ផ្ទះរបស់យើងត្រូវបានរុះចោលអស់។ គេពុំឃើញមានសល់អ្វីឡើយ។ ព្រំដីចាស់ពុំមានតទៅទៀតឡើយ។ គឺមានតែដីធំៗរាងបួនជ្រុងស្មើ"។ (លោក ខៅ អាយុ ៤៦ ឆ្នាំ មេភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

## ការកសាងរចនាសម្ព័ន្ធរដ្ឋបាលឡើងវិញ

ភារកិច្ចមានទំហំធំធេងណាស់។ នៅក្នុងប្រទេសមួយ ដែលមានការវិនាសអន្តរាយធ្ងន់ធ្ងរបែបនេះ អ្វីៗទាំងអស់ត្រូវកសាងឡើងវិញ(ហេដ្ឋានរចនាសម្ព័ន្ធ ប្រព័ន្ធអប់រំ សុខាភិបាល...)។ នៅថ្នាក់មូលដ្ឋានរដ្ឋាភិបាល បានបង្កើតរចនាសម្ព័ន្ធរដ្ឋបាលមួយដែលមានលក្ខណៈដូចរចនាសម្ព័ន្ធរដ្ឋបាលមុនឆ្នាំ១៩៧០ ដែរ គឺមានៈ មេភូមិ មេឃុំ មេស្រុក។ អង្គភាពតូចមួយដែលមានភារកិច្ចចំបងគឺ រៀបចំធ្វើការងាររួមនៅតាមស្រែចំការ ត្រូវបានបង្កើតឡើងៈ ក្រុមសាមគ្គី។ ក្រុមសាមគ្គីនេះនៅមានរហូតដល់សព្វថ្ងៃនេះ ទោះបីប្រធានក្រុមបានបាត់បង់មុខងារ ទីមួយរបស់ខ្លួនក៏ដោយ។

អាជ្ញាធរមូលដ្ឋានមានតួនាទីសំខាន់ណាស់ និងមានលក្ខណៈនយោបាយច្រើនជាងកាលពីអតីតកាល ហើយនិងពុំសូវមានការឯកភាពពីប្រជាជនឡើយ។ អាជ្ញាធរនេះ គឺជាអ្នកតំណាងរបស់មូលដ្ឋានដែលមានអំណាចគ្រាន់ តែធ្វើតាមឱវាទរបស់កម្មុយនីស្ត ហើយឋិតនៅក្រោមការត្រួតពិនិត្យរបស់ពួកវៀតណាមដែលជាអ្នកមករំដោះកម្ពុជា។ ថ្វីបើជាអ្នករំដោះមែន តែគេនៅតែមើលឃើញវៀតណាមថាជាសត្រូវតាំងពីដូនតាមកដែរ។ ក្រៅពីមុខងារតាមប្រពៃណីជាអ្នកកាន់បញ្ជីអត្រានុកូលដ្ឋាន និងថែរក្សាសន្តិសុខនៅក្នុងភូមិ (ដូចជាមុខងារនគរបាល និងការដោះស្រាយទំនាស់ផ្ទៃក្នុងអនុវត្តន៍ការសំរុះសំរួលជាដើម) អាជ្ញាធរមូលដ្ឋានក៏ទទួលបន្ទុកធ្វើការប្រជុំឃោសនា នយោបាយ និងធ្វើការប្រជុំស្វ័យទិតៀន[១២៣] ដែរ ព្រមទាំងចូលរួមក្នុងការប្រមូលយុវជនឱ្យចូលបំរើកងទ័ព ដើម្បីប្រយុទ្ធប្រឆាំងនឹងកងកំលាំងឧទ្ទាម ហើយនិងធ្វើការជ្រើសរើសកម្មករ ដើម្បីឱ្យចូលធ្វើការងារយ៉ាងលំបាកបំផុត ក្នុងផែនការ ក-៥។ សមត្ថកិច្ចថ្មីនេះ បណ្តាលឱ្យប្រជាជនមានការភ័យខ្លាចមិនហ៊ានប្រគល់បញ្ហារបស់ខ្លួន ទៅឱ្យអាជ្ញាធរជានិច្ចទេ ដោយខ្លាចគេធ្វើការកត់សំគាល់ និងខ្លាចគេបញ្ជូនខ្លួនឱ្យទៅធ្វើការងារផែនការ ក-៥ ។ បណ្តាញអំណាចនានាប្រមូលផ្តុំនៅជុំវិញមនុស្សខ្លាំង ។ អ្នកខ្សោយ អ្នកក្រីក្រ ត្រូវគេផាត់ចោល។ ដូចនេះ ទោះបី ជារយៈពេលច្រើនឆ្នាំនៃការភ័យរន្ធត់ត្រូវបញ្ចប់ទៅហើយក្តី ក្របខ័ណ្ឌគាបសង្កត់មួយនៅតែបន្តទៅទៀត ហើយធ្វើឱ្យប្រជាជននៅតែមានការភ័យខ្លាច និងដែលបណ្តាលឱ្យបន្តមានទំនាស់ទៅទៀត។

ការជ្រើសរើសមេភូមិធ្វើឡើងដោយការបោះឆ្នោតរបស់ប្រជាជននៅក្នុងភូមិតាមសំណើររបស់អាជ្ញាធរថ្នាក់លើ។ ការធ្វើជំរើសបេក្ខជនត្រូវគិតអំពីជំហរនយោបាយ បុគ្គលិកលក្ខណៈ ព្រមទាំងកិរិតវប្បធម៌របស់

[123] . នៅក្រោមរូបភាពធូរស្រាលបើប្រៀបធៀបទៅនឹងរបបមុន។

បុគ្គលនីមួយៗ។ អ្នកចេះដឹងគឺជាគោលដៅកំទេចទីមួយរបស់ពួកខ្មែរក្រហម ហើយមានតែការអប់រំនយោបាយ មួយទេដែលអនុញ្ញាតឱ្យធ្វើតាំងពីច្រើនឆ្នាំកន្លងមក។ ដូចនេះ កំរិតនៃការចេះដឹងរបស់ប្រធានថ្មីៗជាទូទៅមានកំរិតទាបណាស់។ ទើបតែនៅឆ្នាំ១៩៨៩ រដ្ឋាភិបាលហាក់ដូចជាបានសាកល្បងផ្តល់ការបណ្តុះបណ្តាលមន្ត្រីនានា។ ប៉ុន្តែការអប់រំនេះ គឺសំដៅទៅលើការអប់រំនយោបាយដដែល។

"នៅឆ្នាំ១៩៧៩ ពួកវៀតណាមបានប្រាប់ឱ្យយើងជ្រើសរើសមេភូមិមួយរូប។ នៅក្នុងពេលប្រជុំពួកវៀតណាមបានសួរថា តើគ្រួសារណាដែលមានមនុស្សស្លាប់ច្រើនជាងគេ ហើយតើជនណាខ្លះដែលប្រឆាំងនឹងពួកខ្មែរក្រហមខ្លាំងជាងគេ។ គ្រួសាររបស់ខ្ញុំមួយភាគធំបានស្លាប់នៅក្នុងសម័យខ្មែរក្រហម ហើយខ្ញុំមានគំនិតប្រឆាំង នឹងពួកខ្មែរក្រហម។ ពួកវៀតណាមបានស្នើឱ្យខ្ញុំធ្វើជាមេភូមិ ហើយបានស្នើឱ្យសុំអ្នកភូមិយល់ព្រមតាមសំណើ។ អ្នកភូមិបានលើកដៃដើម្បីបញ្ជាក់អំពីការយល់ព្រមរបស់ខ្លួន។ នៅសម័យនោះ ខ្ញុំសប្បាយណាស់ យើងបានរំដោះ រួចហើយ។ យើងបានរស់នៅក្នុងសង្គមសេរីមួយ។ ក្នុងឋានៈជាមេភូមិ ខ្ញុំមានមុខងារច្រើនណាស់: គ្រប់គ្រងអ្នក ភូមិ ដោះស្រាយបញ្ហាផ្ទៃក្នុង រិះរកវិធានការដើម្បីតស៊ូប្រឆាំងនឹងពួកខ្មែរក្រហម ជ្រើសរើសមនុស្សឱ្យចូលបំរើកងទ័ព ឬទៅធ្វើផែនការ ក-៥ និងចេញសេចក្តីអនុញ្ញាតដើម្បីរៀបអាពាហ៍ពិពាហ៍ ឬបូជាសព(...)។ អាជ្ញាធរ វៀតណាមបានពន្យល់ខ្ញុំថា ត្រូវតែទប់ស្កាត់ពួកខ្មែរក្រហម ដើម្បីកុំឱ្យពួកវាវិលត្រឡប់មកវិញ។ ហេតុដូច្នេះហើយ បានជាគេត្រូវបញ្ជូនមនុស្សទៅធ្វើផែនការក-៥។

(លោក សម្បត្តិ អាយុ ៦១ ឆ្នាំ មេភូមិ សង្កាត់អង្គោល ក្រុងកែប)

"នៅទីនេះ ប្រជាជនធ្វើការជ្រើសរើសប្រធានភូមិ ។ នៅទីកន្លែងផ្សេងទៀត អ្នកដែលចេះនិយាយភាសាវៀតណាមបានទទួលមុខតំណែងជាប្រធាន។ ចំពោះរូបខ្ញុំ ខ្ញុំពុំមានដើមកំណើតនៅភូមិនេះទេ។ ខ្ញុំបានរៀបការប្រពន្ធដែលមានដើមកំណើតនៅភូមិនេះ។ ខ្ញុំគោរពប្រជាជននៅក្នុងស្រុកភូមិច្រើនជាងគោរពប្រជាជនដែលមកពីក្រៅដូចខ្ញុំ។ នៅពេលដែលខ្ញុំបានមកដល់ទីនេះ ខ្ញុំត្រូវតែស្វែងរកគ្នីគ្នាដោយហៅអ្នកទាំងនោះមកផឹកស៊ី ដោយរៀបចំធ្វើពិធីបុណ្យនានា។ ដើម្បីបានរស់គេត្រូវមានគ្នីគ្នា"។

(លោក ខៅ អាយុ ៤៦ ឆ្នាំ មេភូមិ ឃុំកំពត ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"គេបានដាក់ឱ្យអនុវត្តន៍ប្រព័ន្ធរដ្ឋបាលឡើងវិញបន្តិចម្តងៗ។ មេភូមិបានទទួលការណែនាំពីថ្នាក់លើ ហើយយកការណែនាំនេះមកអនុវត្តន៍នៅក្នុងភូមិ។ មានការប្រជុំឃោសនាជាច្រើន ដើម្បីពន្យល់អ្នកភូមិឱ្យចេះនិយាយ អូសទាញខ្មែរក្រហមឱ្យចុះចូលជាមួយរដ្ឋាភិបាល(...)។ នៅក្នុងភូមិ ប្រជាជនមានការភ័យខ្លាចការវាយប្រហារ របស់ពួកខ្មែរក្រហម។ អ្នកខ្លះបានចាកចេញទៅ

> រស់នៅក្នុងជំរំជនភៀសខ្លួននៅក្នុងទឹកដីថៃ(...)។ យើងមាន សេរីភាពច្រើនជាងកាលពីសម័យប៉ុល ពត ប៉ុន្តែយើងក៏ត្រូវបានត្រួតពិនិត្យយ៉ាងតឹងតែងណាស់ដែរ។ រដ្ឋាភិបាល មានការភ័យខ្លាចក្រែងពួកយើងវិលត្រឡប់ទៅរកពួកខ្មែរក្រហមវិញ។ ដើម្បីធ្វើដំណើរ យើងត្រូវមានសំបុត្រអនុញ្ញាត។ ប្រជាជនមានការភ័យខ្លាចច្បាប់ និងខ្លាចមេភូមិ"។
>
> (លោក សារុន អាចារ្យ អាយុ ៦២ ឆ្នាំ វត្តភ្នំលាវ សង្កាត់ពងទឹក ក្រុងកែប)

មុនងាររបស់មេភូមិមានលក្ខណៈនយោបាយជាងពីជំនាន់មុន។

> "ប្រជាជនបាននិយាយរកគ្នាឡើងវិញ។ យើងនៅមានសេចក្តីភ័យខ្លាច ប៉ុន្តែតិចជាងកាលមុន។ ប្រជាជនមិនទុកចិត្តរបបកម្មុយនីស្តឡើយ។ គេមានការភ័យខ្លាចគេកេណ្ឌចូលបំរើកងទ័ព ឬទៅធ្វើការងារ ក-៥(...)។ ប្រជាជនពុំគោរពអាជ្ញាធរដូចកាលពីសម័យសង្គមរាស្ត្រនិយមទេ។ ប្រធាន។ជាអ្នកជិតស្និទ្ធនឹងរដ្ឋាភិបាល។ គឺជារឿងនយោបាយ។ ប្រជាជនមិនដែលដឹងថារដ្ឋាភិបាលនឹងទាមទារអ្វីទៀតទេ។ មេភូមិត្រូវតែអនុវត្តនីបទបញ្ជារបស់រដ្ឋាភិបាល។ យើងមិនអាចនិយាយអ្វីបានទេ"។
>
> (លោក ឈួន ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## "ក្រុមសាមគ្គី" និង "បញ្ហាដីធ្លី"

ដើម្បីធានាផលិតផលស្បៀងដល់ប្រជាជន និងដើម្បីជៀសវាងទំនាស់ដីធ្លីធំដុំ រដ្ឋាភិបាលបានដាក់ចេញប្រតិបត្តិការធំ។ជាច្រើនៈ ការបង្កើត"ក្រុមសាមគ្គី"ដើម្បីបង្កើនផលិតផលកសិកម្ម និងធ្វើការបែងចែកដីធ្លីតាមរបៀបដើម្បីជៀសវាងកុំឱ្យមានទំនាស់ធំដុំ។

### "ក្រុមសាមគ្គី"

អង្គភាពថ្មីមួយត្រូវបានបង្កើតគឺក្រុមដែលប្រមូលផ្តុំជាងដប់គ្រួសារ។ ទោះបីលោក Viviane Frings បានធ្វើការកត់សំគាល់ថា ថ្វីបើក្រុមសាមគ្គីហាក់ដូចជាត្រូវបានបង្កើតជាពិសេសដើម្បីបង្កើនផលិតផលកសិកម្មក៏ដោយ ក្រុមសាមគ្គីនេះក៏អាចធានាឱ្យមានការត្រួតត្រាឱ្យបានជិតដិតទៅលើប្រជាជន[១២៤]។

---

124 ."ក្រុមសាមគ្គីពុំមែនគ្រាន់តែមានគោលបំណង ដើម្បីរៀបចំប្រជាពលរដ្ឋក្នុងការបង្កើនផលិតផលប៉ុណ្ណោះទេ ក្រុមសាមគ្គីក៏មានទិសដៅប្រមូលកម្លាំង ដើម្បីបំរើគោលដៅនយោបាយរបស់បក្ស និងដើម្បីកំចាត់សត្រូវ។ ការរៀបចំសង្គមឱ្យទៅជាក្រុមសាមគ្គី បានផ្តល់ភាពអនុគ្រោះដល់ការត្រួតពិនិត្យផ្នែក យោបាយនិងយោធា ពីព្រោះសមាជិកទាំងអស់ត្រូវតែរស់នៅនឹងកន្លែង ប្រសិនបើពួកគេចង់បានទទួលផលិតផលដែលជាចំណែករបស់ខ្លួន នៅពេលណាដែល ប្រធានក្រុមធ្វើការចែកផលិតផលនោះ, អង្គការសង្គមបានជួយសំរួលដល់ការប្រមូលស្រូវរបស់រដ្ឋាភិបាលដែលខ្លួនត្រូវការដើម្បីចិញ្ចឹមកម្មាភិបាល និង ទាហានរបស់ខ្លួន"។Frings Viviane សង្គមនិយម និង កសិករខ្មែរ, ១៩៩៧ *ទំព័រ* ៨៧។

អង្គភាពរដ្ឋបាលដ៏តូចនេះនៅតែមានរហូតសព្វថ្ងៃនេះនៅក្នុងភូមិជាច្រើន។ ទោះបីក្រុមបានបាត់បង់តួនាទីមួយរបស់ខ្លួនក៏ដោយ តែក្រុមនៅតែបន្តតួនាទីជាអង្គភាពដ៏តូចសំរាប់ត្រួតពិនិត្យប្រជាជនដដែល គឺគេអាចញាក់បាននៅពេលណាគេត្រូវការ។

ក្រុមបង្កបង្កើតផលកសិកម្មពុំមានដំណើរការល្អទេ។ ដោយស្អប់ខ្ពើមរបបសមូហភាពជ្រុលនិយម របស់កម្ពុជាប្រជាធិបតេយ្យ ប្រជាជនខ្មែរបានប្រកែកមិនធ្វើការងាររួមទៀតទេ។

"រដ្ឋាភិបាលបានប្រកាសថា គេត្រូវតែបង្កើតក្រុមជួយគ្នាទៅវិញទៅមកក្នុងផ្នែកការងារកសិកម្ម គឺក្រុមប្រវាស់ដៃជាបន្ទាន់។ ក្រោយមកមានការបែងចែកដីធ្លី។ ប្រជាជនមានការងាររួមច្រើនគួរសម។ ប្រជាជនហាក់ដូចជាបានធ្វើការងាររួមទាំងអស់គ្នា ប៉ុន្តែតាមការពិតប្រជាជនធ្វើការដាំដុះសំរាប់ខ្លួនឯងម្នាក់ៗ"។

(លោក សារុន អាចារ្យ អាយុ ៦២ ឆ្នាំ វត្តភ្នំលាវ សង្កាត់ពងទឹក ក្រុងកែប)

"យើងបានធ្វើការជាក្រុមសាមគ្គីអស់រយៈពេលមួយឆ្នាំ។ គេបានធ្វើការបែងចែកផលិតផលដល់ប្រជាជននៅក្នុងក្រុម។ ប្រជាជនពុំមានការពេញចិត្តចំពោះប្រព័ន្ធនេះទេ។ អ្នកដែលធ្វើការច្រើន និងអ្នកដែលមិនបានធ្វើការ បានទទួលបរិមាណស្រូវស្មើៗគ្នា។ យើងពុំសប្បាយចិត្តជាមួយអ្នកមិនបានធ្វើការទេ។ ប្រជាជនពុំមានការទុកចិត្តឡើយ ហើយចង់វិលត្រឡប់ទៅតាមប្រព័ន្ធចាស់វិញ គឺប្រជាជនម្នាក់ៗត្រូវធ្វើការដាំដុះនៅលើស្រែរបស់ខ្លួន។ គេបានសំរេចថា ត្រូវតែកាន់កាប់ដីធ្លីរបស់ជីដូនជីតារបស់ខ្លួនវិញ ហើយត្រូវធ្វើការតាមបែបបុគ្គលម្នាក់ៗ ទទ្ទឹមគ្នា និងធ្វើហាក់ដូចជានៅក្នុងក្រុមសាមគ្គី (...)។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំ មេឃុំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## ការបែងចែកដីធ្លី

បញ្ហាដីធ្លីគឺជាបញ្ហាសំខាន់ដែលត្រូវយកចិត្តទុកដាក់។ ដើម្បីជៀសវាងការចាប់យកដី និងផ្ទុះសំបែងដោយមិនស្មើភាពគ្នាដែលអាចបណ្តាលឱ្យមានទំនាស់ជាមួយម្ចាស់កម្មសិទ្ធិចាស់និងគ្រួសាររបស់គេ និងដោយឥតមានលទ្ធភាពដោះស្រាយបញ្ហាទាំងអស់នោះឱ្យមានប្រសិទ្ធភាពបាន ដោយសារតែខ្វះឯកសារឬខ្វះសាក្សី រដ្ឋាភិបាលបានសំរេចថាដីធ្លីទាំងអស់ជាកម្មសិទ្ធិរបស់រដ្ឋ។ រដ្ឋមានភារកិច្ចធ្វើការបែងចែកសាជាថ្មីដល់គ្រួសារដែលប្រើប្រាស់ដី។

ដូចនេះទំរង់ថ្មីមួយនៃអំណាចត្រូវបានប្រគល់ជូនអាជ្ញាធរមូលដ្ឋានគឺការបែងចែកដីធ្លី។ គ្រួសារនីមួយៗមានសិទ្ធិទទួលយកដីមួយកន្លែងតាមសមាមាត្រនៃចំនួនមនុស្សដែលមាននៅក្នុងគ្រួសារ។ ដីធ្លីត្រូវបាន

បែងចែកជូនកាលត្រឹមត្រូវ ឬជូនកាលមិនត្រឹមត្រូវអាស្រ័យដោយទីកន្លែង។ កន្លែងខ្លះមានភាពអនុគ្រោះជាងកន្លែងផ្សេងទៀត។ ម្ចាស់កម្មសិទ្ធិចាស់មិនអាចបានទទួលទំហំដីទាំងមូលដែលជាកេរ្តិ៍របស់ជីដូនជីតារបស់ខ្លួនមកវិញទេ ហើយអាជ្ញាធរមូលដ្ឋានខ្លះបានផ្តល់ដីយ៉ាងធំទូលាយ។ ប៉ុន្តែជាទូទៅ គ្រួសារនីមួយៗអាចទទួលដីសំរាប់ដាំដំណាំ និងដីសំរាប់សង់លំនៅដ្ឋាន។ ភាពតានតឹង ត្រូវបានអាជ្ញាធរមូលដ្ឋានបំបិទចោល ប៉ុន្តែគំនុំបានដក់ជាប់នៅក្នុងចិត្តគំនិតអស់រយៈពេលដ៏យូរ។

នៅពេលបច្ចុប្បន្ននេះ ប្រជាជនទូទៅហាក់ដូចជាបាននិយាយថា ពួកគាត់មានការស្រុះស្រួលចិត្តទៅនឹងការបែងចែកដីធ្លីនេះហើយ។ នៅពេលធ្វើការបែងចែកដីធ្លីអ្នកខ្លះបាននិយាយផ្សេងទៅវិញ។

> "គេបានធ្វើការបែងចែកដីធ្លី។ នៅសម័យសង្គមរាស្ត្រនិយម ប្រជាជនគោរពគ្នាណាស់។ ប្រជាជនសាមគ្គីគ្នា។ នៅក្រោយឆ្នាំ១៩៧៩ភ្លាម មនុស្សនៅគោរពគ្នាទៅវិញទៅមក។ បន្ទាប់មកនៅក្រោយពេលធ្វើការបែងចែកដីធ្លីសភាពការណ៍បានប្រែប្រួលអស់ មនុស្សគិតតែពីខ្លួនឯង។ ការបែងចែកដីធ្លីពុំបានធ្វើដោយស្មើភាពគ្នាទេ។ មេក្រុមដែលជាអ្នកទទួលបន្ទុកធ្វើការបែងចែកដីធ្លី បានយកដីមានទំហំធំសំរាប់ជារបស់ខ្លួន។
>
> នៅពេលដំបូងគឺជាក្រុមសាមគ្គី។ ក្រុមនីមួយៗដែលមានសមាជិកចំនួនដប់គ្រួសារ ត្រូវធ្វើការដាំដំណាំលើដីដប់ហិកតា។ គ្រួសារដែលមានកូនច្រើនបានដីចំនួនបីហិកតា គ្រួសារតូចបានដីចំនួនមួយហិកតា ប៉ុន្តែការធ្វើអាជីវកម្មត្រូវធ្វើរួមគ្នា។ ក្រោយមកទៀត រដ្ឋបានប្រកាសថាម្ចាស់កម្មសិទ្ធិចាស់មិនអាចកាន់កាប់ដីចាស់របស់ខ្លួន វិញបានទេ ដោយសារតែប្រដាសស្នាមរបស់ឃុំបានបាត់បង់ហើយនៅក្នុងសម័យ ប៉ុល ពត។ គេបាននិយាយថា គឺជាការត្រឹមត្រូវណាស់ក្នុងការបែងចែកដីឱ្យបានត្រឹមត្រូវជាជាងកាន់កាប់ដីដែលគេចង់បាន ឬដែលគេទាមទារដោយពុំមានភស្តុតាង។ គេបានធ្វើការបែងចែកដី ប៉ុន្តែអ្នកមានអំណាចបានយកដីយ៉ាងធំ និងដីល្អទៀតផង។ នៅសម័យនេះ ប្រជាជនពុំមានការរិតជីវភាពដូចគ្នាទាំងអស់នោះទេ។ អ្នកខ្លះជាមនុស្សខ្លាំងពីព្រោះពួកគេអាចរក្សាមាសទុកបានច្រើន ពីព្រោះពួកគេស្គាល់មន្ត្រីថ្នាក់លើនៅក្នុងផ្នែករដ្ឋបាលជាច្រើនអ្នក។ គេបានឃើញមានការកកើតក្រុមមនុស្សជាសម្ព័ន្ធមិត្តដែលជាអ្នកស្មោះត្រង់ជាមួយមនុស្សខ្លាំង។ បក្ខពួករបស់មនុស្សខ្លាំងអាចសុំដីបានល្អ។ គេពុំបានគិតអំពីដីរបស់ជីដូនជីតាទេ ហើយគេបានធ្វើការចែកដីថ្មីវិញ។ អ្នកដែលបានទទួលដីល្អ គឺជាប្រធានមូលដ្ឋាន។ ប្រធានទាំងអស់នោះមិនស្គាល់ព្រំដែនដីចាស់ទេ។ អ្នកមកពីក្រៅដែលបានឱ្យទ្រព្យសម្បត្តិដល់ប្រធាន ក៏បានដីល្អដែរ។ អ្នកមានចាស់ជូនកាលបានទទួលដីតិចជាងអ្នកក្រីក្រ"។
>
> ( លោក ខៅ អាយុ ៤៦ ឆ្នាំ មេភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"ពួកខ្មែរក្រហមបានជន្លៀសប្រជាជនចេញពីភូមិរហូតដល់អ្នកលឿង។ បន្ទាប់មក តាមការណែនាំរបស់ពួកវៀតណាម ប្រជាជនមួយចំនួនបានវិលត្រឡប់មកភូមិកំណើតវិញ។ នៅឆ្នាំ១៩៨០ មានការបែងចែកដីធ្លី។ យោងតាមកំណើនប្រជាជននៅក្នុងភូមិ និងយោងតាមទំហំដី គ្រួសារនីមួយៗបានទទួលដីមួយកន្លែងមានទំហំខុសៗគ្នា។ នៅទីនេះ ប្រជាជនចង់បានដីធំ ប៉ុន្តែពួកគាត់បានទទួលដីតូច។ ដំបូងប្រជាជនមិនសប្បាយចិត្តទេ ប៉ុន្តែក្រោយមកពួកគាត់មានសភាពស្ងប់ស្ងាត់វិញ។ នេះជាការសំរេចរបស់រដ្ឋាភិបាល។ នៅតំបន់ឆ្ងាយដាច់ស្រយាល ប្រជាជនបានធ្វើតាមចិត្តដែលខ្លួនចង់។ គាត់បានទទួលដីជីដូនជីតារបស់ខ្លួនវិញ"។

(លោក រឿង អាយុ ៤៥ ឆ្នាំ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"មានបញ្ហាដីធ្លីជាច្រើនបានកើតឡើងនៅមុនពេលមានការបែងចែកដីធ្លីរបស់រដ្ឋាភិបាល។ គឺមានមនុស្សជាច្រើនដែលបានវិលត្រឡប់មកភូមិកំណើតវិញយ៉ាងឆាប់ ហើយបានយកដីជាច្រើននិងបានធ្វើការដាំដំណាំនៅលើដីនោះ។ ក្រោយមកទៀត ម្ចាស់កម្មសិទ្ធិចាស់នៅក្នុងសម័យសង្គមរាស្ត្រនិយមបានត្រឡប់មកវិញ ហើយបានទាមទារដីរបស់ជីដូនជីតាខ្លួន។ គឺមានការលំបាកដោះស្រាយណាស់។ កាលណាគេបានធ្វើការបែងចែកដីរួចហើយ ក្រោយមកប្រជាជនដែលបានវិលត្រឡប់មកវិញយឺតពេលពុំអាចយកដីរបស់ឪពុកម្តាយខ្លួនបានឡើយ។ ប្រសិនបើជននោះនៅតែទាមទារដី ហើយប្រសិនបើអ្នកប្រើប្រាស់ដីថ្មីជាអ្នកសំរបសំរួល ជននោះអាចទិញដីរបស់ខ្លួនវិញ ឬប្តូរដីមួយផ្សេងទៀត"។

(លោក វ៉ាន់ ណាត អាយុ ៥២ ឆ្នាំ មេភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

នៅទីកន្លែងខ្លះដែលមានមនុស្សស្លាប់តិចហើយព្រំដីមានការប្រែប្រួលតិចតួច មានគ្រួសារជាច្រើនបានយកដីរបស់ជីដូនជីតាខ្លួនវិញដោយពុំចាំបាច់ធ្វើការបែងចែកទេ។ ប៉ុន្តែ ជួនកាលមានការប៉ះទង្គិចនៅក្នុងគ្រួសារជាមួយអ្នកខាង និងជាមួយអ្នកមកដល់ថ្មី។ បញ្ហានិងទំនាស់ថ្មីៗក៏បានកើតឡើង នៅពេលមានការវិលត្រឡប់របស់ជនទាំងឡាយណាដែលគេជឿថា បានស្លាប់បាត់ទៅហើយៗដែលបានធ្វើការទាមទារដីចាស់របស់ខ្លួនវិញ។

"នៅពេលដែលគេបានត្រឡប់មកភូមិកំណើតវិញ គឺអត់មានអ្វីទាំងអស់។ គេបានធ្វើការសាកល្បងរកទីតាំងផ្ទះចាស់ដើម្បីកសាងខ្ទមមួយ។ អ្នកខ្លះបានយកដីដ៏ល្អរបស់អ្នកដែលពុំទាន់បានត្រឡប់មកដល់វិញ ឬដែលស្លាប់(...) ។ គេពុំដឹងថា នរណាស្លាប់និងនរណានឹងត្រឡប់មកវិញទេ(...)។ អ្នកដែលបានមកដល់មុនគេ បានយកដីចាស់របស់ខ្លួន ឬយកដីរបស់អ្នកផ្សេងទៀត។ នៅពេលដែលប្រជាជនបានវិលត្រឡប់មកដល់ភូមិវិញ គេចង់បានដីចាស់របស់គេមកវិញដែរ។

ការនេះជួនកាលស្រួល ជួនកាលពិបាក។ អ្នកខ្លះបានប្រគល់ដីឱ្យម្ចាស់គេវិញ ដោយធ្វើការទូទាត់ជាមធ្យោបាយផ្សេងៗ(ស្រូវ មាស...) ប្រសិនបើជននោះបានចាប់ផ្តើមធ្វើការកាប់ឆ្ការ អ្នកខ្លះទៀតបានធ្វើការប្តូរដីផ្សេងទៀត។ អ្នកខ្លះពុំចង់ប្រគល់ដីឱ្យម្ចាស់គេទេ ហើយហេតុការណ៍នេះបានបង្កើតជាបញ្ហាយ៉ាងច្រើន។ សូម្បីតែក្នុងបច្ចុប្បន្នកាលនេះក្តី ប្រជាជននៅក្នុងភូមិនៅមានការចងគំនុំជាមួយគ្រួសារជាច្រើនទៀត ដែលពុំបានពិភាក្សាពីការប្តូរដីគ្នា ឬយកដីរបស់ខ្លួនវិញនៅសម័យនោះ"។

(លោក ខៅ អាយុ ៤៦ ឆ្នាំ ឃុំចេក ស្រុកស្វាយចេក ខេត្តស្វាយរៀង)

"នៅទីនេះគេពុំបានធ្វើការបែងចែកដីធ្លីទេ ដោយសារតែប្រជាជនគ្មានការផ្លាស់ប្តូរ និងពីព្រោះប្រជាជនបានស្គាល់ព្រំដីរបស់ខ្លួនដែរ។ គឺពុំមានបញ្ហាធំដុំទេ។ នៅមានដីទំនេរច្រើនណាស់។ អ្នកដែលបានមកដល់មុនគេ បានយកដីល្អនៅលើទួលខ្ពស់។ នៅពេលម្ចាស់កម្មសិទ្ធិចាស់បានវិលត្រឡប់មកដល់ភូមិ គាត់បានធ្វើការចរចារជាមួយមេភូមិនិងអ្នកប្រើប្រាស់ដីនោះ។ ប្រសិនបើម្ចាស់កម្មសិទ្ធិចាស់ចង់បានដីរបស់គាត់វិញ ហើយបើអ្នកប្រើប្រាស់ដីបច្ចុប្បន្នយល់ព្រម មេភូមិជួយធ្វើការចរចារ។ ប្រសិនបើដីនោះត្រូវគេកាប់ឆ្ការ អ្នកម្ចាស់កម្មសិទ្ធិចាស់ត្រូវផ្តល់អ្វីខ្លះជាថ្នូរទៅឱ្យអ្នកប្រើប្រាស់ដីបច្ចុប្បន្នៈ ដីមួយកន្លែងទៀត មេគោ មាស ប្រសិនបើគាត់មាននៅសល់។ ប្រសិនបើម្ចាស់ថ្មីមិនចង់ឱ្យដីទេ មេភូមិមានភារកិច្ចរកដីមួយកន្លែងទៀតសំរាប់ជូនអ្នកម្ចាស់កម្មសិទ្ធិចាស់។ មានបញ្ហាជាច្រើនរវាងប្រជាជនគ្នាឯង ប៉ុន្តែគេច្រើនតែបំភ្លេចបញ្ហាទាំងអស់នោះដើម្បីកុំឱ្យបង្កើតរឿងនៅពេលបច្ចុប្បន្នកាលនេះ។ មានមនុស្សម្នាក់ពុំចង់ប្រគល់ដីទៅឱ្យម្ចាស់កម្មសិទ្ធិចាស់ទេ ប៉ុន្តែបានយកមាសពីម្ចាស់កម្មសិទ្ធិចាស់ ដោយសន្យាថានឹងឱ្យដីវិញ។ អ្នកម្ចាស់កម្មសិទ្ធិចាស់ ចង់សំលាប់អ្នកម្ចាស់កម្មសិទ្ធិថ្មី។ មេភូមិបានធ្វើឱ្យរឿងនេះមានភាពស្ងប់ស្ងៀម (...)។ ឥឡូវនេះទៀត អ្នកទាំងពីរមិននិយាយរកគ្នាទេ ហើយជៀសវាងមិនដើរកាត់មុខផ្ទះគ្នាទៅវិញទៅមក។ ប៉ុន្តែពួកគេមិនធ្វើឱ្យមានបញ្ហាទេ(...)។ ជាទូទៅអ្វីៗបានប្រព្រឹត្តទៅយ៉ាងល្អពីព្រោះនៅទីនេះគឺជាភូមិចាស់ ហើយប្រជាជនកើតចេញពីគ្រួសារតែមួយនិងបានស្គាល់គ្នាតាំងពីយូរមកហើយ។ គេបានសំរបសំរួលគ្នាតាមការស្រុះស្រួលគ្នា។ នៅពេលក្រោយមកទៀត នៅពេលដែលម្ចាស់កម្មសិទ្ធិចាស់បាន ត្រឡប់មកដល់វិញក្នុងពេលជាច្រើនឆ្នាំក្រោយមក និងចង់បានដីរបស់ខ្លួនវិញ គេបាននិយាយថា ការនេះពុំអាចធ្វើទៅបានទេ ពីព្រោះដីនេះត្រូវបានដាំដំណាំអស់ពេលយូរមកហើយ។ អ្នកម្ចាស់កម្មសិទ្ធិចាស់បានយល់ព្រម ហើយមេភូមិបានផ្តល់ដីឱ្យមួយកន្លែងទៀត។ នៅក្នុងភូមិថ្មីៗ ដែលមានប្រជាជនជាច្រើនពុំបានស្គាល់គ្នានិងមានការប្រែ

ប្រួលយ៉ាងច្រើននោះ គេបានធ្វើកាបែងចែកដីធ្លី។ នៅទីនោះពុំសូវមានការសំរបសំរួលគ្នាទេ ប្រជាជនម្នាក់ៗ បានគិតតែពីខ្លួនឯង"។

( លោកស្រី តួយ អាយុ ៤៨ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"មានបញ្ហាជាច្រើនរវាងប្រជាជននៅក្នុងភូមិដែលទាក់ទងទៅនិងបញ្ហាដីធ្លី។ នៅទីនេះពុំសូវមានការរៀបចំផ្នែកកសិកម្មដែលមានទ្រង់ទ្រាយធំដូចនៅក្នុងសម័យ ប៉ុល ពត ទេ។ ទីនេះស្ថិតនៅជិតព្រំដែនវៀតណាមណាស់។ ប្រជាជនបានកាន់កាប់ដីដីដូចដីតារបស់ខ្លួនវិញ។ ប៉ុន្តែកាលណាគេមានបំណងចង់បានដីចាស់របស់ខ្លួន វិញនោះគឺមានបញ្ហា។ គេពុំយល់ព្រមទៅលើព្រំដីទេ ហើយអ្នកខ្លះទៀតមានបំណងចង់កាន់កាប់ដីរបស់ជនដែលស្លាប់ តែសមាជិកគ្រួសាររបស់អ្នកស្លាប់ក៏ចង់បានដីនោះដែរ ហើយក៏ឈ្លោះគ្នា"។

(លោក នាគ អាយុ ៣៨ ឆ្នាំ ស្រុកកំពង់ត្រាច ខេត្តកំពត)

"នៅទីនេះ នៅក្នុងសម័យខ្មែរក្រហមពុំសូវមានមនុស្សស្លាប់ច្រើនទេ ហើយគេអាចសំរបសំរួលគ្នាដើម្បីត្រឡប់ទៅយកព្រំដីចាស់វិញ។ គឺពុំមានបញ្ហាដីធ្លីច្រើនទេ។ យើងបានធ្វើការសំរបសំរួលគ្នា"។

(លោក ព្រុំ អាយុ ៥៩ ឆ្នាំ មេឃុំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)។

រដ្ឋបានធ្វើការបណ្តុះបណ្តាលមន្ត្រីជាច្រើនដើម្បីឱ្យចេះដោះស្រាយបញ្ហាដីធ្លីពិបាកៗ។ ថ្វីបើច្បាប់ទំនៀមទម្លាប់នៅអនុវត្តន៍នៅឡើយ ជាពិសេសចំពោះរឿងព្រំភ្លឺស្រែ និងការបង្ហូរទឹកនៅរដូវភ្លៀង ច្បាប់នេះក៏នៅមានកំរិតដែរ និងពុំមានលក្ខណៈរឹងមាំសំរាប់ដោះស្រាយបញ្ហានានានៅសម័យនោះទេ។ អំណើះតទៅគេត្រូវពឹងផ្អែក ទៅលើច្បាប់កាន់តែច្រើនឡើងៗ។

"នៅឆ្នាំ១៩៨៧ ខ្ញុំបានទទួលការបណ្តុះបណ្តាលនៅថ្នាក់ស្រុកជាមួយមន្ត្រីចំនួន៤៨នាក់ផ្សេងទៀតមានមេភូមិ មេឃុំ និងប្រធានសន្តិសុខភូមិ(អនុប្រធានភូមិ)។ ប្រធានស្រុកជាអ្នកបង្ហាត់បង្រៀន។ យើងបានយល់អំពីរបៀបដោះស្រាយទំនាស់ និងបានយល់អំពីច្បាប់។ មានមេរៀនជាច្រើន។ មេរៀនទាំងនេះ បានផ្តោតទៅលើបញ្ហាដីធ្លីៈ តើត្រូវដោះស្រាយបញ្ហាដីធ្លីតូចតាចបែបដូចម្តេច? បញ្ហាដីនិងផ្ទះដែលជារបស់រដ្ឋ។ យើងក៏បានរៀនអំពី ច្បាប់ដែរ។ តាមការពិតគឺជាការបណ្តុះបណ្តាលដោយផ្ទាល់មាត់ ពីព្រោះពុំទាន់មានច្បាប់ជាលាយល័ក្ខអក្សរពិតប្រាកដនៅឡើយទេ"។

( លោក វ៉ាន់ ណាត អាយុ៥២ ឆ្នាំ មេភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

## ៤.២. ការដោះស្រាយ និងការបង្ការទំនាស់ប្រចាំថ្ងៃនៅក្នុងតំបន់ត្រួតត្រាដោយរដ្ឋាភិបាល

### ការវិលត្រឡប់ទៅរកការអនុវត្តន៏តាមប្រពៃណីនៅក្នុងបរិបទផ្សេង

គឺជាសម័យចលាចលនៅពេលចាប់ផ្តើមធ្វើការកសាងជាតិឡើងវិញ។ ប្រភពបញ្ហានិងទំនាស់សំខាន់ៗ ជាង គេគឺមានទំនាក់ទំនងទៅនឹងបញ្ហាដីធ្លី។ នៅពេលនេះគេគិតយ៉ាងងាយថា ដីដែលអាចចិញ្ចឹមគ្រួសារបាន គឺឋិតនៅក្នុងលំដាប់ទីមួយ។ ប៉ុន្តែមូលហេតុផ្សេងទៀតនៃជំលោះក៏លេចឡើងដែរ។ បញ្ហាទាំងអស់នោះ មានលក្ខណៈខុសគ្នាបន្តិចពីសម័យឆ្នាំ៦០គឺមានៈ បញ្ហាសត្វស៊ីដំណាំ ជំលោះរវាងប្តីនិងប្រពន្ធ ជំលោះ រវាងកូនៗដែលក្លាយទៅ ជាជំលោះរវាងមាតាបិតា...។ ប៉ុន្តែអ្វីដែលបានផ្លាស់ប្តូរនិងមានការលំបាកក្នុងការ វាយតំលៃគឺ ទំនាក់ទំនងអន្តរបុគ្គល។ ប្រជាជនបានប្រកាន់យកគំនិតបុគ្គលនិយមវិញ ប៉ុន្តែនៅក្រោម រូបភាពនៃការមិនទុកចិត្តគ្នាដែលមានក៏រីតកាន់តែខ្លាំងឡើង។ អ្នកខ្លះបានក្បត់គ្នាឯងដើម្បីបានរស់។ ពួក អតីតខ្មែរក្រហមបានរស់នៅជាមួយជនទាំងឡាយ ដែលខ្លួនបានកំទេចកាលពីពេលមុន។ គេបានការពារខ្លួន ទប់ទល់នឹងអ្នកដទៃ។ អាវុធមានពាសពេញនៅក្នុងប្រទេស ហើយដែលបង្កគ្រោះឱ្យមានអំពើហឹង្សា ភ្លាមៗ។ ឧទាហរណ៏ នៅពេលឈ្លោះគ្នាជាមួយមនុស្សប្រមឹក គំនុំចាស់បានលេចចេញមកដែរ ហើយ សំលេងអាវុធបានផ្ទុះឡើងជាការបញ្ចប់ទំនាស់ដោយពុំចាំបាច់និយាយអ្វីឡើយ។

ដើម្បីដោះស្រាយទំនាស់មូលដ្ឋាន គេបានវិលត្រឡប់ទៅរកការអនុវត្តន៏តាមប្រពៃណីវិញ។ មេភូមិមាន តួនាទីជាអ្នកសំរុះសំរួលវិញ។ ឯមនុស្សចាស់ទុំក៏ត្រូវបានស្នើសុំឱ្យចូលរួមដែរ តែគាត់ពុំមានតួនាទីដូចកាល នៅក្នុងសម័យមុនសង្គ្រាមនិងសម័យខ្មែរក្រហមទេ។

នៅពេលដំបូងគឺពុំមែនជាពេលឈ្លោះគ្នាទេ ប៉ុន្តែជាពេលរកស្បៀងអាហារដើម្បីទ្រទ្រង់ជីវិតឱ្យបានរស់។

> "នៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺជាសម័យសង្គមនិយម។ ខ្ញុំបានធ្វើជាមេភូមិ។ មានការប្រជុំស្វ័យទិតៀន ប៉ុន្តែពុំសូវមានលក្ខណៈតឹងតែងដូចកាលពីមុនទេ។ យើងបានប្រមូល ផ្តុំគ្នាប្រជុំ។ បន្ទាប់មក យើងបានបង្កើតឱ្យមានការសំរុះសំរួលគ្នាតាមប្រពៃណីបន្តិចម្តងៗឡើង វិញ។ ក្នុងករណីមានការលួចគឺមានពន្ធនាគារមួយនៅឈូក។ នៅពេលដំបូង ប្រជាជនបានគិត តែពីរកស្រូវអង្ករ និងមិនចង់បរិភោគបបរទៀតឡើយ។ គេបានគិតតែពីការរកទទួលទាន និងមិន ធ្វើឱ្យមានរឿងឡើយ"។
>
> (លោក ក្រែម អាយុ ៥៤ ឆ្នាំ អនុប្រធានភូមិ (អតីតខ្មែរក្រហម ) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

ទោះបីជាអត្ថរសនៃការសំរុះសំរួលមានលក្ខណៈជាប្រពៃណី ប៉ុន្តែទំរង់នៃការសំរុះសំរួលមានលក្ខណៈ តាមបែបជាស្ថាប័នច្រើនជាង។

"កាលណាមានជំលោះ មានទំនាស់រវាងប្រជាជននៅក្នុងភូមិ គេបានប្រកាន់យកការអនុវត្តន៍ការស្វែងរកដំណោះស្រាយទំនាស់តាមរបៀបចាស់ឡើងវិញ។ ខ្ញុំជឿថា រដ្ឋាភិបាលសម័យនោះចង់បានដំណោះស្រាយដែលធ្វើដោយក្រុម។ នៅក្នុងក្រុមមានប្រធានភូមិ អនុប្រធានភូមិទទួលបន្ទុកសន្តិសុខ និងមានមនុស្សចាស់ទុំបីឬបួននាក់។ ខ្ញុំបានពិនិត្យឃើញថា របៀបថ្មីនេះពុំសូវមានការសំឡុតដូចសម័យសង្គមរាស្ត្រនិយមទេ។ គេបានធ្វើការសាកសួរមតិរបស់ប្រជាជនជាច្រើន"។

(លោក សារុម អាយុ ៦២ ឆ្នាំ អាចារ្យវត្តភ្នំលាវ សង្កាត់ពងទឹកក្រុងកែប ខេត្តកំពត)

ចាប់តាំងពីឆ្នាំ១៩៧៩មក ស្ថាប័នតុលាការត្រូវបានបង្កើតឡើងវិញដោយមានចៅក្រមខ្លះដែលបាននៅរស់ពីរបបចាស់ និងចៅក្រមខ្លះទៀតត្រូវបានបណ្តុះបណ្តាលដោយតក់ក្រហល់។ ចៅក្រមបានទទួលការគាំទ្រតិចតួចពីប្រជាជន ដោយសារតែមានការចោទប្រកាន់អំពីអំពើអយុត្តិធមិដែលមានទំនាក់ទំនងទៅនឹងអំពើពុករលួយ និងអសមត្ថភាព។ លើសពីនេះទៅទៀត អាជ្ញាធរមូលដ្ឋានបានសំរេចដោះស្រាយបញ្ហានៅក្នុងភូមិស្រុករបស់ខ្លួនដោយខ្លួនឯង។

"គឺមានប្រធានភូមិ អនុប្រធានភូមិទទួលបន្ទុកសន្តិសុខ អនុប្រធានទីពីរ និងសមាជិកបីរូបទៀត។ ខ្ញុំត្រូវបានតែងតាំងជាសមាជិកទីមួយទទួលបន្ទុកកិច្ចការយោធា។ នៅក្នុងទសវត្សឆ្នាំ៨០ មានទំនាស់រវាងប្រជាជនច្រើនជាងកាលពីសម័យសង្គមរាស្ត្រនិយម។ ខ្ញុំបានធ្វើអន្តរាគមន៍ជាញឹកញាប់ក្នុងឋានៈជាអ្នកសំរុះសំរួលក្នុងពេលមានទំនាស់។ ខ្ញុំមានវិធីមួយដែលផ្សំគ្នារវាងច្បាប់និងព្រះពុទ្ធសាសនា។ ខ្ញុំបានសាកល្បងនៅជាអព្យាក្រឹត្យ និងបានផ្តល់មតិយ៉ាងត្រឹមត្រូវដើម្បីឱ្យភាគីទាំងពីរមានភាពស្មើគ្នា ហើយនិងដើម្បីកុំឱ្យមានអ្នកចាញ់ និងអ្នកឈ្នះ។ ប្រសិនបើមានអំពើហឹង្សា ខ្ញុំពុំចង់ឱ្យមនុស្សទៅតុលាការទេ(...)។ គឺជាការប្រសើរណាស់ក្នុងការដោះស្រាយដោយខ្លួនយើង។ គេអាចដោះស្រាយករណីមានអំពើហឹង្សាជាមួយនឹងការសំរបសំរួលដោយលុយកាក់ឬ អ្វីផ្សេងទៀត(...)។ ខ្ញុំពុំចង់ឱ្យមនុស្សទៅតុលាការទេ។ ខ្ញុំចូលចិត្តធ្វើការអប់រំមនុស្ស។ គេមិនត្រូវប្រែក្លាយរឿងតូចឱ្យទៅជារឿងធំឡើយ។ មនុស្សចាស់ទុំ ក៏អាចធ្វើការណែនាំតាមបែបគោលការណ៍ផ្នែកសាសនាបានដែរ។ នៅពេលប្រជាជនបានមករកខ្ញុំដើម្បីដោះស្រាយបញ្ហាតូចតាច ខ្ញុំបានអប់រំជនទាំងនោះ។ ក្រោយមក គេក៏បានវិលត្រឡប់ទៅផ្ទះរបស់គេវិញ។ ប្រសិនបើបញ្ហានៅតែកើតមានជានិច្ចនោះ ខ្ញុំបានធ្វើការប្រជុំដើម្បីធ្វើការសំរុះសំរួលដែលកើតចេញពីការអប់រំ។ ក្រោយពីការសាកល្បងបីដងដោយឥតបានផលនោះមក ខ្ញុំបញ្ជូនរឿងនេះទៅគណៈឃុំ"។

(លោក វៃ អាយុ ៤៦ ឆ្នាំ ឃុំពពាច ស្រុកស្វាយទាប ខេត្តស្វាយរៀង)

ចាស់ទុំដែលមិនស្ថិតក្នុងក្របខណ្ឌរដ្ឋបាលត្រូវផាត់ចេញ

"កាលណាមានបញ្ហារវាងប្រជាជននៅក្នុងភូមិកើតឡើង ខ្ញុំបានដោះស្រាយបញ្ហានោះដោយមានជំនួយរបស់អនុប្រធានភូមិទទួលបន្ទុកសន្តិសុខ និងសមាជិកភូមិមួយរូបដែលទទួលបន្ទុកកិច្ចការស៊ីវិល ដូចមានចែងនៅក្នុងបទបញ្ជាស្រាប់។ គេបានយកប្រពៃណីរបស់ភូមិមកអនុវត្តន៏វិញដើម្បីដោះស្រាយកិច្ចការ(...)។ ខ្ញុំមិនពឹងចាស់ទុំឱ្យមកចូលរួមទេ ពីព្រោះរឿងនេះពុំមាននៅក្នុងបទបញ្ជា"។

(លោក សម្បត្តិ អាយុ ៦១ ឆ្នាំ មេភូមិ សង្កាត់ពងទឹក ក្រុងកែបខេត្តកំពត)

អត្ថន័យនៃយុត្តិធម៌និងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានជួនកាលត្រូវបានជំទាស់ប៉ុន្តែជំទាស់ដោយលាក់បំពួន។ គេពុំហ៊ាននិយាយអ្វីជាចំហរទេ។

"កាលណាប្រជាជនមានទំនាស់ គេបញ្ជូនរឿងនោះទៅតាមលំដាប់ថ្នាក់ផ្នែករដ្ឋបាលៈ មេក្រុម មេភូមិ មេឃុំ។ ជួនកាលត្រឹមត្រូវ ជួនកាលមិនត្រឹមត្រូវ គឺអាស្រ័យអ្នកដែលបានធ្វើការសំរុះសំរួល។ ជាទូទៅ មនុស្សពុំអព្យាក្រឹតទេ។ គេវាយតំលៃសភាពការណ៍ដោយយោលទៅតាមការចាប់អារម្មណ៏របស់ខ្លួនផ្ទាល់ និងទៅតាមទំនាក់ទំនងជាមួយជននោះ។ គ្រួសាររបស់មេភូមិមានប្រៀប។ ប្រធាន៧ជាអ្នកល្ងង់ខ្លៅ។ ក្មេង៧ពុំបានទទួលការអប់រំទាស់តែសោះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំនៃសង្រ្គាម និងក្នុងសម័យ ប៉ុល ពត។ ពួកគេពុំចេះដឹងអ្វីទេ។ ប្រធាន៧នៅក្នុងសម័យនោះ គឺជាអ្នកតំណាងនយោបាយ។ កាលពីមុន ក្នុងសម័យសង្គមរាស្រ្តនិយម ប្រជាជនស្រលាញ់មេភូមិ។ មេភូមិជាអ្នកនៅជិតប្រជាជន។ គឺពុំមាននយោបាយនិងការឃោសនាទេ។ ប្រជាជនរស់នៅឃ្លាតឆ្ងាយពី(កិច្ចការនយោបាយ)។ នៅក្នុងទសវត្សឆ្នាំ៨0 នយោបាយមានសារៈសំខាន់ណាស់។ ប្រជាជនពុំចង់ស្តាប់ការឃោសនារបស់ពួកកុម្មុយនីស្តឡើយ។ នៅចំពោះមុខប្រជាជនបានធ្វើហាក់ដូចជាគោរពរដ្ឋអំណាចណាស់ ហើយនៅខាងក្រោយគេបានជជែកគ្នា។ ក្នុងចំណោមប្រធាន៧គឺមានអ្នកល្អនិងអ្នកអាក្រក់។ យើងមិនអាចធ្វើអ្វីកើតទេតែមិនហាននិយាយដោយសារយើងខ្លាច"។

(លោក ឡៃ អាយុ ៥៧ ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប)

មុខងារមួយដែលគេបានផ្តល់អំណាចច្រើនជូនមេភូមិ និងការត្រួតពិនិត្យប្រជាជន គឺមុខងារជួយជ្រើសរើសមនុស្សឱ្យទៅធ្វើការផែនការ ក-៥ និងការចូលបំរើកងទ័ព។ មនុស្សពេញវ័យនិងមានកំលាំងបានរស់នៅក្នុង ការភ័យខ្លាចគេបញ្ជូនទៅរកវាសនាដ៏អាក្រក់ទាំងនោះ។

ជាថ្មីម្តងទៀត ប្រជាជនមិនចូលចិត្តធ្វើឱ្យមានការកត់សំគាល់ទេ ដើម្បីកុំឱ្យមានបញ្ហា។ ជាញឹកញាប់គេបានបំបិទបញ្ហារបស់ខ្លួន។

ទម្លាប់ប្រពៃណីរបស់ក្រុមមានអំណាចដែលកើតឡើងដោយរូបភាពមានអ្នកការពារ និងអ្នកត្រូវគេការពារបានបង្កើតឡើងវិញ។ ប៉ុន្តែរូបភាពមានលក្ខណៈផ្ទុយគ្នាវិញបើប្រៀបធៀបទៅនឹងរបបមុន។ មានតែជនដែលមានមធ្យោបាយគ្រប់គ្រាន់[១២៥] តែទើបអាចក្លាយទៅជាបក្ខពួកមិត្តរបស់ក្រុមមួយមានអំណាច និងត្រូវបានអនុគ្រោះ។ អ្នកខ្សោយ អ្នកក្រីក្រ និងជនណាដែលត្រូវចោទថាបានបង្កើតបញ្ហាដែលពុំមានការគាំទ្រត្រូវខ្ចាតចេញមុនគេ។ ការសំឡុតនិងការបង្ខិតបង្ខំជាមធ្យោបាយងាយស្រួលថ្មីមួយទៀត ប៉ុន្តែមានប្រសិទ្ធភាពដើម្បីបង្កាចលាចលនៅក្នុងភូមិ។

"ប្រជាជនពុំហ៊ាននិយាយប្រាប់មេភូមិពីបញ្ហារបស់ខ្លួនច្រើនទេដោយខ្លាចគាត់បញ្ជូនទៅ ក-៥ ។ ប្រធានភូមិបាននិយាយថា នៅក្នុងគ្រួសារមួយដែលមានមនុស្សចំនួនបីនាក់ គេត្រូវបញ្ជូនម្នាក់ឱ្យទៅក-៥ ហើយកាលណាជននោះត្រឡប់មកវិញ គេត្រូវបញ្ជូនម្នាក់ទៀត។ ប្រធានភូមិជាអ្នកជ្រើសរើសមនុស្សទៅ ក-៥។ ប្រធានភូមិ ពុំបានដាក់ឈ្មោះជនណាដែលជាសាច់ញាតិជិតរបស់គាត់នៅក្នុងបញ្ជីឡើយ"។

(លោក ប៉ែត អាយុ ៧១ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"ក្រោយឆ្នាំ១៩៧៩ សភាពការណ៍មានលក្ខណៈល្អ។ បន្ទាប់មកគឺមាន ក-៥។ មនុស្សប្រុសទាំងអស់មានការភ័យខ្លាចគេបញ្ជូនទៅក្នុងកំណែន។ ក្នុងសម័យនោះ កាលណាមេភូមិចង់ដកជនណាដែលបង្កើតបញ្ហាគាត់បានបញ្ជូនជនទាំងនោះទៅ ក-៥។ ពេលនោះមានការគាបសង្កត់យ៉ាងខ្លាំងពីអាជ្ញាធរ។ មានមនុស្សកំណាចជាច្រើនដែលបានប្រើប្រាស់នយោបាយ ដើម្បីបំរើផលប្រយោជន៍របស់ខ្លួនផ្ទាល់។ ឧទាហរណ៍ ប្រសិនបើខ្ញុំជាបក្ខពួក របស់អាជ្ញាធរហើយខ្ញុំចង់បានដីល្អមួយកន្លែង ខ្ញុំធ្វើការចោទប្រកាន់អ្នកម្ចាស់កម្មសិទ្ធិ។ ខ្ញុំចោទថា គាត់បានផ្តល់អង្ករឱ្យពួកខ្មែរក្រហមនៅក្នុងព្រៃ។ ជននោះត្រូវចាប់ខ្លួន ត្រូវជាប់ពន្ធនាគារ ហើយប្រសិនបើគេនៅតែទទូចទៀត គាត់ត្រូវសំលាប់ចោល។ ការធ្វើរបៀបនេះ ខ្ញុំអាចយកដីបាន។ ប៉ុន្តែ នៅសម័យនោះក៏មានបញ្ហាដីធ្លីបន្តិចបន្តួចដែរ។ គឺអាជ្ញាធរជាអ្នកដោះស្រាយការបែងចែក ហើយធ្វើហាក់ដូចជាល្អណាស់។ ដោយសារអាជ្ញាធរមានអំណាច ជនណាដែលមិនសប្បាយចិត្តលើការបែងចែកនោះពុំហ៊ាននិយាយអ្វីឡើយ។ កាលណាគេមិនស្រលាញ់នរណាម្នាក់ គឺជាការងាយបំផុតក្នុងការបង្កើតការអុកឡុកជននោះ។ គេធ្វើការចោទប្រកាន់ជននោះ"។

(លោក ឡៃ អាយុ ៥៧ ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប)

---

[125] . សមាជិកគ្រួសាររបស់មន្ត្រីរាជការ ឬ មានសម្ភារៈសំបូរបែប (តាំងពីរនេះកើតមាន ស្របគ្នា ជារឿយៗ)

"នៅសម័យមានសង្គ្រាមមេភូមិបានជ្រើសរើសមនុស្សសំរាប់ផែនការ ក-៥។ ក្មេងក្រីក្រភាគច្រើនបាន ទៅក-៥។ ប្រសិនបើគេឱ្យមេមាន់ទៅប្រធានភូមិ ប្រសិនបើគេបានរៀបចំពិធីបុណ្យ ឬជប់លៀងអ្វីមួយ ប្រធានភូមិបានលើកកាលបរិច្ឆេទចេញដំណើរទៅក-៥ ហើយបានត្រៀមចំពោះការមកដល់របស់យោធា ដែលបានមករកជនដែលត្រូវបានចាត់តាំងឱ្យទៅក-៥។ អ្នកណាដែលមានបងប្អូនជីដូនមួយជាថ្នាក់លើបានលាក់ខ្លួននៅក្នុងផ្ទះរបស់ខ្លួន។ ឥឡូវនេះនៅភូមិគ្រួសារក្រីក្រទាំងអស់មានមនុស្សស្លាប់ឬពិការច្រើនណាស់។ ពួកគេកាន់តែក្រីក្រ ទៅៗ។

គេបានស្នើសុំខ្ញុំឱ្យធ្វើការកងឈ្លបនៅក្នុងភូមិ។ គេបាននិយាយប្រាប់ខ្ញុំថា"គេមានមុខតំណែងផ្សេងក្រៅពីក-៥ ឬយោធា។ ប្រសិនបើឯងចង់ឯងអាចធ្វើជាឈ្លប"។ ខ្ញុំបានធ្វើជាឈ្លប (ដើម្បីឱ្យរួចផុតពីក-៥)។ ក្រោយ មកនៅឆ្នាំ១៩៩០ ខ្ញុំត្រូវបានប្រធានភូមិតែងតាំងឱ្យធ្វើការជាមេឃុំពីព្រោះខ្ញុំមានឈ្មោះល្បីថាជាអ្នកធ្វើការល្អ"។

(លោក ខៅ អាយុ ៤៦ ឆ្នាំ មេភូមិ ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង)

អាជ្ញាធរក៏មានការភ័យខ្លាចដែរ។ កាលណាការគាបសង្កត់ខ្លាំង អ្នកភូមិអាចសំដែងការមិនពេញចិត្ត។ គេអាចប្រើវិធីហិង្សា។

"កាលពីមុនខ្ញុំជាមន្ត្រីនៅក្រសួងពាណិជ្ជកម្មនៅទីក្រុងភ្នំពេញ។ រដ្ឋាភិបាលថ្មីបានស្នើឱ្យខ្ញុំធ្វើជាប្រធានភូមិ។ នៅពេលដំបូង ខ្ញុំមិនចូលចិត្តមុខដំណែងនេះទេ។ ខ្ញុំត្រូវធ្វើការជ្រើសរើសកម្មករដើម្បីបញ្ជូនទៅក-៥។ នៅពេលនោះប្រជាជនក្រីក្រណាស់ ហើយគេបានស្នើឱ្យពួកគាត់បញ្ឈប់ការងារទៅធ្វើ ក-៥ វិញ។ គេបានឱ្យខ្ញុំទៅ ក-៥ ប៉ុន្តែដោយសារខ្ញុំមានកូនច្រើន គេបានយល់ព្រមមិនឱ្យខ្ញុំទៅទេ។ មន្ត្រីរដ្ឋាភិបាលបាននិយាយថា ប្រធានត្រូវតែបង្ហាញឧទាហរណ៍ និងនាំបងប្អូនរបស់ខ្លួនទៅក-៥។ ចំពោះរូបខ្ញុំ ខ្ញុំមានសេចក្តីសន្តោសប្រណីដល់ជនជាច្រើន ហើយខ្ញុំក៏មានសេចក្តីភ័យខ្លាចជនទាំងនោះសំលាប់ចោលដែរ។ ប្រធានភូមិមុនហៀបនឹងត្រូវបាន ប្រជាជនសំលាប់ចោលដោយសារតែគាត់បានចុះឈ្មោះជនទាំងនោះនៅក្នុងបញ្ជីដែលត្រូវចេញដំណើរទៅ ក-៥។ ចំពោះរូបខ្ញុំ ខ្ញុំមានការភ័យខ្លាចគេសំលាប់ចោល។ ដូចនេះ ខ្ញុំបានប្រាប់ប្រជាជនឱ្យបានដឹងជាមុន។ កាលណាពួកសេនាជនបានមករកជនទាំងនោះនៅពេលយប់ ពួកគេបានរត់គេចខ្លួនទៅកន្លែងផ្សេងបាត់ទៅហើយ"។

(លោក វ៉ាន់ ណាត អាយុ ៥២ ឆ្នាំ មេភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

## ការវិលត្រឡប់ទៅរកការអនុវត្តន៍ផ្នែកសាសនាវិញ

ការវិលត្រឡប់មកស្រុកកំណើតវិញ ឬការតាំងទីលំនៅក្នុងភូមិថ្មី បានធ្វើឱ្យប្រជាជនបានរកឃើញបង្គោលសង្គមនិងសាសនារបស់ខ្លួនឡើងវិញ។ ទោះបីជាការខិតខំប្រឹងប្រែងក្នុងផ្នែកសាសនា ពុំមែនជាអាទិភាពមុនគេក៏ដោយ បន្តិចម្តងៗប្រជាជនបានរៀបចំពិធីផ្សេងៗដែលមានកាលពីអតីតកាល។ ប្រជាជនបានសង់អសនៈដាក់ពុទ្ធរូប និងអ្នកតាឡើងវិញដូចធម្មតា។ វត្តអារាមដែលភាគច្រើនត្រូវបានកំទេចចោល ឬបានទទួលការខូចខាតយ៉ាងខ្លាំង ត្រូវបានកសាងឡើងវិញនៅពេលក្រោយមកទៀត។ គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៨៩ ទើបព្រះពុទ្ធសាសនាត្រូវបានទទួលស្គាល់ជាផ្លូវការ។

អ្នកខ្លះបានសង្កេតឃើញថា ជំនឿសាសនាមានលក្ខណៈខ្លាំងជាងកាលពីសម័យមុន។

> "ពីដំបូង សាសនាពុំមានសភាពខ្លាំងកាដូចកាលពីមុនទេ។ ប្រជាជនបានទទួលការរងទុក្ខវេទនាយ៉ាងខ្លាំងហើយសាសនាក៏ពុំបានជួយពួកគាត់ដែរ។ បន្ទាប់មក ប្រជាជនបានចាប់ផ្តើមរៀបចំពិធីនានាឡើងវិញដើម្បីទាក់ទាញព្រេងសំណាងនិងវិបុលភាព(...)។ ប្រជាជនបានរៀបចំធ្វើរោងអ្នកតាឡើងវិញ។ ដោយសារប្រជាជនពុំសូវជឿទៅលើអ្នកតា ទើបអ្នកតាក៏ពុំសូវពូកែខ្លាំងក្លាដែរ។
>
> នៅក្នុងស្រុកទាំងមូលមានព្រះសង្ឃតែមួយអង្គតែប៉ុណ្ណោះ។ ព្រះសង្ឃអង្គនោះបាននិមន្តមកពីកម្ពុជា ក្រោម[១២៦]។ ប្រជាជនបាននិមន្តព្រះអង្គមកដើម្បីសូត្រធម៌បួងសួង"។
>
> (លោក ពួន អាយុ ៦០ ឆ្នាំ មេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

តួនាទីជាប្រពៃណីដែលអ្នកតានិងព្រលឹងរបស់ជីដូនជីតាមានក្នុងការទប់ស្កាត់អំពើអាក្រក់ទាំងឡាយតាមរយៈការកាច់នោះកំពុងត្រូវបានចោទសួរថា តើមានប្រសិទ្ធិភាពឬអត់។

> "ដំបូង ប្រជាជនពុំបានគិតទៅដល់សាសនាទេ។ ប្រជាជនជឿតែទៅលើអ្វីដែលមាននៅក្នុងចានបាយរបស់គេ។ ក្រោយមកនៅពេលដែលប្រជាជនមានស្រូវអង្ករនិងប្រាក់កាសបន្តិចបន្តួចមក ពួកគេបានរៀបចំដុតធូបនៅមុខរូបចំលាក់ ហើយបានចាប់ផ្តើមរៀបចំពិធីតាមប្រពៃណីឡើងវិញ។ ខ្ញុំបានទឹកឃើញដល់ការសង់ផ្ទះលើកទីមួយនៅក្នុងភូមិគីរីមេនន្ទ ដោយគេបានរៀបចំពិធីក្រុងពាលី[១២៧]។ យើងមានសេចក្តីរីករាយណាស់ដោយបានរៀបចំពិធីនេះឡើងវិញដូចកាលពីមុន(...)។ អ្វីដែលបានផ្លាស់ប្តូរនោះគឺ មនុស្សពុំសូវខ្លាចអ្នកតានិងខ្មោចទេ។ ប្រជាជនបាន

---

[126] . ទឹកដីវៀតណាមខាងត្បូង កាលពីមុនគឺជាទឹកដីមួយផ្នែកនៃអាណាចក្រខ្មែរដ៏ធំ។ ប្រជាពលរដ្ឋ ខ្មែរដើមបានរស់នៅតទៅទៀត។

[127] . ម្ចាស់ទឹកដីដែលឋិតនៅក្នុងពិភពមួយនៅខាងក្រោម។ គេជីករណ្តៅមួយនៅក្នុងដី ហើយគេធ្វើ ពិធីសែនព្រេនដល់ម្ចាស់ទឹកម្ចាស់ដី។

ឃើញមនុស្សស្លាប់ច្រើនណាស់ ដូច្នេះហើយបានជាគាត់មិនខ្លាចខ្មោចទាស់តែសោះ។ គាត់បានឃើញជនប្រព្រឹត្តអំពើអាក្រក់ជាច្រើន ហើយពុំឃើញមានកាច់អ្នកណាឡើយ។ តើអាចឱ្យជឿដូចម្តេចកើត? ប្រជាជនពុំសូវជឿទៅលើអ្នកតាទេ ហេតុដូចនេះហើយបានជាអ្នកតាក្លាយជាពុំសូវពូកែខ្លាំងក្លា"។

(លោកក្រាច់ អាយុ៥១ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## អ្នកខ្លះទៀតអាចសង្កេតឃើញអំពីអនុភាគរបស់អ្នកតាមានពិតមែន

"មានប្រធាននគរបាលមួយរូបឈ្មោះ ឌី ។ ថ្ងៃមួយលោក ឌី បានទៅលេងបៀរ។ គាត់បានលេងបន្លំគេ ប៉ុន្តែគាត់មានជំនឿថា ក្នុងឋានៈជាប្រធាន គាត់អាចធ្វើបាន។ ទោះបីគាត់បានចាញ់គេក៏គាត់អាចនិយាយថា គាត់ឈ្នះគេដែរ ហើយអ្នកដទៃទៀតត្រូវនៅស្ងៀម។ ប៉ុន្តែអ្នកដទៃទៀតបាននិយាយថា គាត់បានលេងបន្លំគេ។ ពេលនោះ គាត់មានកំហឹងហើយបាននិយាយថា "បើឯងនិយាយអញ្ចឹងឯងនឹងត្រូវជាន់មីនផ្ទុះ ឬមួយឯងនឹងត្រូវស្លាប់ដោយសារអ្នកតាព្រះអង្គវ៉ាយបំបាក់ក"។ អ្នកនៅក្រោមបង្គាប់លោក ឌី បានឆ្លើយតបវិញថា" គឺលោកទេដែលត្រូវមីនផ្ទុះ"។ លោកប្រធាន ឌី បានដើរចេញមកក្រៅដោយកំហឹង ហើយបានដើរទៅជាន់មីន។ គាត់បានត្រូវរបួសដោយអំបែងគ្រាប់មីននៅលើផ្ទៃមុខ នៅត្រង់ក និងបំពង់ក។ គាត់បាននៅរស់ដោយខ្វាក់ភ្នែកម្ខាង។ ឥឡូវនេះ មុនពេលចូលទៅមុខខ្លោងទ្វារវត្តគាត់បានដោះមួកឡើង"។

(លោក ពួន អាយុ ៦០ ឆ្នាំ មេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

## ៤.៣. ការដោះស្រាយនិងការទប់ស្កាត់ទំនាស់ប្រចាំថ្ងៃនៅក្នុងតំបន់ត្រួតត្រាដោយចលនាតស៊ូខ្មែរក្រហម

## ការត្រឡប់ទៅចូលពួកខ្មែរក្រហមវិញ

ជំលោះប្រដាប់អាវុធរវាងកងទ័ពរដ្ឋាភិបាលជាមួយ នឹងពួកខ្មែរក្រហមចេះតែរីករាលដាលតទៅទៀត។ ការជ្រើសរើសទ័ពថ្មីៗបានធ្វើឱ្យជួរទ័ពរបស់ចលនាតស៊ូកាន់តែមានទំហំធំឡើងៗ។ ចំពោះអ្នកនៅដាច់ពីសង្គម អ្នកដែលចង់គេចបញ្ហា ព្រៃដែលជាទីលំនៅរបស់ពួកខ្មែរក្រហមបានក្លាយទៅជាជំរករបស់ៈ ពួកអតីតខ្មែរក្រហម ដែលរដ្ឋាភិបាលថ្មីតាមរកយុវជនដែលរត់គេចខ្លួនពីផែនការក-៥ ជនទាំងឡាយដែលមានបញ្ហានៅក្នុងភូមិ។

"នៅតំបន់វាលរាប(ខាងរដ្ឋាភិបាល)ពុំមានយុត្តិធមិទេ។ គឺលុយកាក់ដែលដោះស្រាយអ្វីៗទាំងអស់។ ខ្ញុំបានចូលព្រៃ(ខ្មែរក្រហម) ពីព្រោះប្រជាជនស្រុកក្រោមបានទាត់ខ្ញុំចេញពីភូមិ។ ពួកគេបាននិយាយថា ខ្ញុំជាខ្មែរក្រហម។ រដ្ឋបាលនៅសម័យនោះប្រើអំណាចខ្លាំងណាស់ ហើយពុំធ្វើឱ្យអ្នកភូមិមានការជឿទុកចិត្តឡើយ។ នៅពេលណាប្រជាជនបានចេញពីភូមិដោយមានស្បៀងផង

នោះគេបានចោទថា មានទំនាក់ទំនងជាមួយពួកខ្មែរក្រហម។ ខ្ញុំគួរតែរស់នៅក្នុងភូមិ ពីព្រោះសភាពការណ៍បានសុខសាន្តហើយ ខ្ញុំមានផ្ទះមួយ។ ប៉ុន្តែខ្ញុំត្រូវបានចោទប្រកាន់ ហេតុដូចនេះខ្ញុំត្រូវតែវិលត្រឡប់ទៅចូលចលនាតស៊ូនៅក្នុងព្រៃ។ ខ្ញុំពុំចង់ធ្វើដំណើរទៅក្នុងព្រៃទេ ប៉ុន្តែប្រសិនបើខ្ញុំបន្តរស់នៅ(ស្រុកក្រោម)ខ្ញុំមានសេចក្ដីភ័យខ្លាចគេចាប់ខ្ញុំដាក់ពន្ធនាគារ ឬសំលាប់ចោល។ ប្រសិនបើខ្ញុំផ្សងសំណាងដោយរត់ចូលក្នុងព្រៃ ខ្ញុំមានសំណាងមួយគឺបានរួចផុតពីការចាប់ខ្លួនឬការស្លាប់។ ដូច្នេះ ខ្ញុំបានរត់ចូលក្នុងព្រៃ។ គឺមិនមែនមានតែអតីតខ្មែរក្រហមទេដែលបានរត់ត្រឡប់ចូលព្រៃវិញ។ មានជនខ្លះដែលរត់គេច ខ្លួនពីផែនការក-៥ក៏បានរត់ចូលព្រៃដែរ"។

(លោក ទិត អាយុ ៥៤ ឆ្នាំ អនុប្រធានឃុំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

ការវិលត្រឡប់ចូលចលនាតស៊ូវិញដើម្បីរត់គេចពីការភ័យខ្លាចប្រចាំថ្ងៃ ការភ័យខ្លាចប្រធាន៧ ការភ័យខ្លាចផែនការក-៥ ការភ័យខ្លាចអ្នកផ្សេងទៀតការបដិសេធការឃោសនារបស់របបមួយស្និទ្ធនឹងវៀតណាម គឺជា ហេតុផលផ្សេងទៀតនៃការវិលត្រឡប់ទៅចូល"បងប្អូន"ខ្មែរក្រហមវិញ។

"នៅឆ្នាំ១៩៨៤ ខ្ញុំបានវិលត្រឡប់ទៅចូលពួកខ្មែរក្រហមនៅក្នុងព្រៃវិញ។ នៅសម័យនោះប្រធានភូមិ បានជ្រើសរើសយុវជនឱ្យចូលបំរើកងទ័ព ឬទៅធ្វើផែនការក-៥។ ជារៀងរាល់ឆ្នាំមនុស្សក្នុងភូមិចំនួន១០នាក់ បានចេញដំណើរទៅការដ្ឋានក-៥។ គេបាននិយាយថា គេចេញដំណើរដោយជិះឡាន ហើយគេត្រឡប់វិញជិះចាន (កោដ្ឋ)។ ប្រធានភូមិអាចយកប្រជាជនដាក់ពន្ធនាគារ ឬបញ្ជូនទៅការដ្ឋានក-៥។ ខ្ញុំក៏បានសំរេចចិត្តចាកចេញ ទៅ(...)។

នៅសម័យនោះមនុស្សឃោរឃៅដាក់គ្នាណាស់។ ឪពុកម្ដាយខ្ញុំបាននិយាយប្រាប់ខ្ញុំថា នៅក្នុងរបបសម្ដេចសីហនុ(មុនឆ្នាំ១៩៧០) ប្រជាជនបានស្រលាញ់គ្នាណាស់ និងពុំមានអំពើហឹង្សាច្រើនទេ។ ភាពកាចសាហាវនិងអំពើហឹង្សា បានចាប់ផ្ដើមកើតមានឡើងនៅក្នុងសម័យ លន់ នល់។ នៅក្នុងសម័យ ប៉ុល ពត មនុស្សបានរស់នៅដោយទៀតត្រង់ណាស់ និងមិនបង្កើតឱ្យមានបញ្ហាជាមួយគ្នាឡើយ។ ក្រោយមក មនុស្សកាចសាហាវដូចសត្វនៅក្នុងព្រៃ។ មានការវាយប្រហារគ្នារវាងពួកទាហានវៀតណាម និងពួកខ្មែរក្រហមដែលរស់នៅក្នុងតំបន់ភ្នំ។ មានអាវុធច្រើនណាស់។ គេកាចសាហាវ ។ ខ្ញុំពុំអាចពន្យល់បានទេ ប៉ុន្តែខ្ញុំអាចនិយាយអំពីទិដ្ឋភាពរួមបាន។ ជាដំបូងគឺ មានភាពកាចសាហាវតែមួយចំនួនតូចទេ ហើយបន្ទាប់មកដោយសារសង្គ្រាម សភាពកាចសាហាវមួយចំនួនតូចនោះបានរីកធំឡើងៗ។ បញ្ហាគ្រួសារតូចតាចបានក្លាយទៅជាបញ្ហាធំ។ មនុស្សលែងស្លូតបូតទៀតហើយ។ គាត់បានការពារអ្វីដែលគាត់មាន។ ឧទាហរណ៍ កាលណាអ្នកណាម្នាក់យកដីម្នាក់ទៀត អ្នកទាំងពីរបានវាយប្រហារគ្នា។ គ្មានភាគីណាមួយចង់ចុះចាញ់

ឡើយ។ ម្នាក់ៗចង់ធ្វើការសងសឹក និងសំលាប់ភាគីម្ខាងទៀត។ និន្នាការនៃភាពកាចសាហាវនេះ បានដើរទៅទន្ទឹមគ្នាជាមួយនឹងអំពើឃោរឃៅ និងការគំរាមគំហែងរបស់អាជ្ញាធរមូលដ្ឋាន។ ប្រធានភូមិឬប្រធានឃុំបានធ្វើការសំរុះសំរួល ប៉ុន្តែប្រសិនបើប្រជាជនមិនស្តាប់គាត់ ហើយចាប់ឈ្លោះគ្នាទៀត ឬបង្កើតបញ្ហាទៀត ប្រធានបានដាក់ទោសជនទាំងនោះ។ ឧទាហរណ៍ ប្រសិនបើគ្រួសារ"ក"បានធ្វើការនៅលើដី របស់គ្រួសារ"ខ"ដោយពុំមានការអនុញ្ញាត ហើយប្រសិនបើគ្រួសារ"ខ"បានយកដីរបស់គ្រួសារ"ក"វិញ ប្រធានភូមិអាចដាក់ទោសអ្នកទាំងពីរ។ ដំបូងប្រធានភូមិបានធ្វើការគំរាមគំហែងអ្នកទាំងពីរ។ គាត់ធ្វើឱ្យអ្នកទាំងពីរខ្លាច ដោយនិយាយថាគាត់នឹងដាក់គុកអ្នកទាំងពីរ ដាក់ខ្នោះអ្នកទាំងពីរ ឬបញ្ជូនអ្នកទាំងពីរឱ្យទៅធ្វើផែនការក-៥។ គឺជាសម័យកម្មុយនីស្ត ហើយប្រធានភូមិអាចឱ្យមនុស្សជាប់គុកបានប្រសិនបើគាត់ធ្វើការរាយ-ការណ៍ពីជនទាំងនោះ។ ប្រជាជនពុំសូវហ៊ានទៅជួបប្រធានភូមិទេ។ គាត់មានអំណាចផ្តាច់ការមកលើពួកយើង។ ជនទាំងឡាយណាដែលមិនអាចទ្រាំទ្របាន បានវិលត្រឡប់ទៅចូលចលនាតស៊ូរបស់សម្តេចសីហានុ លោកសឺន សាន ឬមួយចូលកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)។ លើសពីនេះទៀត ប្រជាជនចង់ចូលរួមជាមួយខ្មែរគ្នាឯង។ គេពុំចង់ចូលជាមួយពួកវៀតណាមទេ។ ដូចនេះនៅឆ្នាំ១៩៨៤ ខ្ញុំបានវិលត្រឡប់ទៅចូលចលនាតស៊ូវិញ។ ពួកអ្នកតស៊ូបាននិយាយដោយស្មោះត្រង់"។

(លោក នាគ អាយុ ៣៨ ឆ្នាំ អាជីវករបន្ទប់វីដេអូមួយ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប(ភូមិបង្កើតថ្មី))

ការវិលត្រឡប់ទៅចលនាតស៊ូប្រដាប់អាវុធវិញ ដើម្បីរត់គេចខ្លួនពីទំនាស់ផ្ទាល់ខ្លួន និងការស្លាប់របស់សង្គមតូចមួយនៅក្នុងភូមិ។

"នៅឆ្នាំ១៩៩២ ខ្ញុំជាអ្នកជួសជុលទោចក្រយាន។ មានជនម្នាក់បាននិយាយថា ខ្ញុំជួសជុលទោចក្រយានមិនបានល្អទេ ថាខ្ញុំបានប្តូរគ្រឿងបន្លាស់ល្អ និងដាក់គ្រឿងបន្លាស់មិនល្អដើម្បីទុកគ្រឿងបន្លាស់ល្អសំរាប់លក់។ ខ្ញុំបាននិយាយថា ជាការមិនពិតទេ។ ជននោះបានទៅប្រាប់រឿងនេះដល់ប្រធានភូមិ។ ប្រធានភូមិបាននិយាយប្រាប់ខ្ញុំថា ឱ្យធ្វើការជួសជុលឱ្យបានល្អ ហើយឱ្យយកគ្រឿងចាស់មុនមកដាក់ឡើងវិញ។ ខ្ញុំបាននិយាយប្រាប់មេភូមិថា ខ្ញុំពុំបានយកគ្រឿងបន្លាស់កង់នោះទេ។ ពុំមាននរណាម្នាក់ជឿខ្ញុំទេ។ គេពុំបាននិយាយអ្វីនៅចំពោះមុខខ្ញុំ ប៉ុន្តែពួកគេពុំបានយកទោចក្រយានមកឱ្យខ្ញុំជួសជុលឡើយ។ ខ្ញុំបាននិយាយថា ដោយសារតែហេតុដូច្នេះហើយបានជាខ្ញុំទៅចូលពួកខ្មែរក្រហម។ គ្មានជនណាម្នាក់និយាយអ្វីទេ ប៉ុន្តែខ្ញុំបានសង្កេតឃើញថាប្រជាជនពុំចង់និយាយរកខ្ញុំឡើយ ខ្ញុំបានធ្វើដំណើរឆ្ពោះទៅរកពួកខ្មែរក្រហម"។

(លោក តី អាយុ ៣៧ ឆ្នាំ (អតីតខ្មែរក្រហម) ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## និរន្តភាពនិងការវិវឌ្ឍន៍នៃការអនុវត្តន៍របស់ពួកខ្មែរក្រហម

នៅក្នុងព្រៃ ប្រព័ន្ធចាស់របស់ពួកខ្មែរក្រហមនៅក្នុងខេត្តកំពតបានបន្តជារៀងរហូតក្រោមរូបភាពជាយោធា។ ទោះបីបទបញ្ជាមានលក្ខណៈតឹងតែងរៀងរហូតក៏ដោយ ប៉ុន្តែប្រព័ន្ធនេះមានលក្ខណៈទន់ភ្លន់។ ទិសដៅ និងវិន័យថ្មីៗមានលក្ខណៈបែបយោធា។ សង្គមត្រូវបានបែងចែកជាពីរប្រភេទ គឺប្រជាជនមូលដ្ឋានដែលទទួលបន្ទុកភស្តុភានិងកសិកម្ម និងពួកយោធាដែលជាវរជនរបស់ពួកខ្មែរក្រហម។ ចលនាតស៊ូខ្មែរក្រហមត្រូវការជួយឧបត្ថម្ភ ដូច្នេះសំលាប់មានចំនួនតិចតួចទេ។ ការបញ្ចេញមតិផ្ទាល់ខ្លួនពុំបានទទួលការលើកទឹកចិត្តទេ ក៏ប៉ុន្តែមានការអត់អោនជាងកាលពីរបបមុន។ ការដាក់ទោសចំពោះ "កំហុស" គឺការបន្ថយឋានន្តរស័ក្តិនៅក្នុងជួរកងទ័ពឬការដកចេញ (ដែលមានន័យថាស្លាប់) ចំពោះជនទាំងឡាយដែលមិនសូវមានគុណូបការៈចំពោះការតស៊ូ។ តរិយាបថល្អត្រូវបានផ្តល់រង្វាន់ដោយការតែងតាំងឱ្យឡើងថ្នាក់ខ្ពស់និងផ្តល់វត្ថុអនុស្សាវរីយ៍។ ប៉ុន្តែ ពួកអតីតខ្មែរក្រហមខ្លះ ចេះតែចង់ទៅរកប្រព័ន្ធចាស់ពីអតីតកាលដែលបានបង្កើត និងបានដាក់ទោសគ្រប់ទាំងអស់ដោយខុសទំនង។

អតីតទាហ៊ានខ្មែរក្រហមមួយរូបបានរំលឹកពីវិន័យយោធាដោយបញ្ជាក់អំពីគំនិតសហគមន៍។ បទបញ្ជារបស់ពួកខ្មែរក្រហមមានលក្ខណៈតឹងតែងណាស់ចំពោះការលួចនិងទំនាក់ទំនងផ្លូវភេទ ដែលមិនត្រូវមានក្រៅពីការរៀបអាពាហ៍ពិពាហ៍ឡើយ។

> "គេបានធ្វើការប្រជុំយុវជនអ្នកតស៊ូជាញឹកញាប់ៈ ការប្រជុំក្រុមតូចគឺហៅថា "ពួក" មានមនុស្សបីនាក់ រៀងរាល់ថ្ងៃបីថ្ងៃម្តង។ ការប្រជុំមេក្រុមរៀងរាល់សប្តាហ៍ដោយមានបួនពួកមានន័យថាមានមនុស្ស១២ នាក់ ការប្រជុំជាមួយអនុប្រធានកងអនុសេនាតូចរៀងរាល់ដប់ប្រាំថ្ងៃម្តង។ ការប្រជុំជាមួយអនុប្រធានកងអនុសេនាធំរៀងរាល់មួយខែកន្លះម្តង និងការប្រជុំជាមួយប្រធានកងវរៈសេនាធំ (ថ្នាក់វរសេនីឯក) រៀងរាល់បីខែម្តង។ ការប្រជុំទាំងអស់នោះ ត្រូវបានធ្វើដើម្បីអប់រំពួកយើងដើម្បីកុំឱ្យធ្វើខុស។ នៅមានការប្រជុំរបស់មេៗថ្នាក់កងពលទៀត (ឋានៈស្មើឧត្តមសេនីយ) ដើម្បីសំរេចថា តើត្រូវអនុវត្តបទបញ្ជាពីប៉ៃលិនយ៉ាងណា ?។
>
> នៅក្នុងក្រុមតូចៗហៅថាពួក គឺមានចំនួនបីនាក់ៈ ប្រធាន និងអនុប្រធានពីររូប។ ម្នាក់ៗត្រូវតាមដានមនុស្សពីរនាក់ទៀតហើយត្រូវរាយការណ៍អំពីកំហុសនៅពេលប្រជុំរៀងរាល់បីថ្ងៃម្តង។ ពួកគេបានស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយរបស់មនុស្សម្នាក់ៗ។
>
> គេត្រូវតែគោរពគោលការណ៍ពីរគឺ សាមគ្គីភាពនិងឯកភាព នៅក្នុងគោលបំណងដើម្បីថែរក្សាសន្តិសុខផ្ទៃក្នុង។

សាមគ្គីភាព ឧទាហរណ៍ គឺអាចមានការទាក់ទងទៅនឹងរបៀបបរិភោគ ការធ្វើដំណើរ និងការប្រយុទ្ធ។ កាលណាមានឧបសគ្គអ្វីមួយកើតឡើង គេត្រូវតែរួមគ្នាដោះស្រាយ។ នៅពេលមានការប្រយុទ្ធគ្នា អ្នកនៅជួរមុខត្រូវជួយអ្នកនៅក្រោយ។ ដូចនេះ កាលណាមានមនុស្សម្នាក់ស្លាប់គេត្រូវយកសពនោះទៅតាម។ ប្រសិនបើយើងទុកខ្មោចចោល ទាហានដែលនៅជួរក្រោយនឹងមិនចង់ធ្វើដំណើរទៅមុខទេ។ ពួកគេនឹងបាត់បង់សេចក្ដីក្លាហានអស់ជាមិនខាន។ គឺគេជួយគ្នាតាមរបៀបដូច្នេះ។ សាមគ្គីភាពគឺការស្រលាញ់គ្នាទៅវិញទៅមកដូចបងប្អូន។ អំពើនេះមានទាក់ទងទៅនឹងអាកប្បកិរិយាទាំងបួនគឺ ដេក ដើរ ឈរ ឬអង្គុយ[១២៨]។ ពេលបរិភោគបាយគេមិនត្រូវគិតតែពីខ្លួនឯងទេ។ គេត្រូវតែគិតដល់អ្នកដទៃផង។ ប្រសិនបើយើងមានបាយមួយចានអ្នកផ្សេងទៀតក៏ត្រូវមានបាយម្នាក់មួយចានដូចគ្នាដែរ។ នៅពេលធ្វើដំណើរ អ្នកមានបារីត្រូវតែចែកឱ្យអ្នកដទៃជក់ផង។ អ្នកណាបេះបានផ្លែឈើ ក៏ត្រូវចែកឱ្យអ្នកដទៃបរិភោគផង ។

ឯកភាព គឺធ្វើអ្វីៗ ឱ្យមានលក្ខណៈតែមួយ។ កាលណាមានបញ្ជាឱ្យធ្វើដំណើរទៅទីកន្លែងណាមួយគេត្រូវតែធ្វើដំណើរទៅទីកន្លែងនោះទាំងអស់គ្នា។ គេត្រូវភ្ជួររាស់ដីទាំងអស់គ្នា ឬបង្កើតជាក្រុមវាយលុកជាមួយអ្នកដឹកនាំគ្រាប់រំសេវដើម្បីជួយអ្នកដទៃ។ គេអាចធ្វើអ្វីកើតលុះត្រាតែគេរួមគ្នា។ ការធ្វើអ្វីមួយតែម្នាក់ឯងពុំអាចធ្វើទៅកើតទេ។

គេធ្វើការប្រជុំដើម្បីពង្រឹងសាមគ្គីភាពនិងឯកភាព។ គេនិយាយអំពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់អ្នកដទៃ។ គេបានធ្វើការប្រជុំស្វ័យទិតៀន។ ជនណាបានធ្វើការភូតកុហក ត្រូវទទួលការស្ដីបន្ទោសយ៉ាងខ្លាំងពីអ្នកដទៃ។ ជនណាលាក់បាំងកំហុសគឺបានធ្វើខុស។ ក្រោយពីការពន្យល់អំពីបញ្ហា គេបាននិយាយថាគេពុំត្រូវប្រព្រឹត្តកំហុសម្ដងទៀតឡើយ។ ជាទូទៅកំហុសទាំងឡាយត្រូវបានដោះស្រាយនៅក្នុងក្រុមតូចគឺពួក ប៉ុន្ដែបើជនណាម្នាក់ពុំចង់សារភាពកំហុសទេ បញ្ហានោះត្រូវបញ្ជូនទៅដល់ក្រុម។ នៅពេលប្រជុំក្រុមអ្នកទាំងដប់ពីររូបរបស់ក្រុម បានឡើងនិយាយម្នាក់ម្ដងៗ។ មេក្រុមមានសៀវភៅនិងប៊ិចមួយ ។ គាត់បានរៀបចំរបៀបវារៈ។ ឧទាហរណ៍សាមគ្គីភាពឯកភាព។ ម្នាក់ៗត្រូវមានសៀវភៅមួយនិងប៊ិចមួយ។ ប្រសិនបើប្រធានបទគឺឯកភាពមេក្រុមបានហៅកូនក្រុមម្នាក់ឱ្យឡើងនិយាយធ្វើស្វ័យទិទៀន បន្ទាប់មកមេក្រុមស្នើឱ្យកូនក្រុមទាំងអស់គ្នាធ្វើការទិតៀនជននោះ។ គេនិយាយថា "ប្រសិនបើ អ្វីមួយគេនិយាយនោះគឺជាការពិតនោះ គឺគ្រាន់ដើម្បីកែលំអគឺដើម្បីកែឱ្យត្រូវប៉ុណ្ណោះ។ គេត្រូវតែស្ដាប់។ ប្រសិនបើគេនិយាយនោះមានការខុសឆ្គង គេក៏ត្រូវតែស្ដាប់"។ មេក្រុមបានធ្វើការកត់ចំណាំអំពីការទិតៀន

---

128 . នៅទីនេះ គេសង្កេតឃើញមានការនិយាយយោងទៅការអប់រំបែបប្រពៃណី

នៅលើសៀវភៅ ហើយជននោះក៏ត្រូវតែកត់ចំណាំនៅលើសៀវភៅរបស់ខ្លួនដែរ។ នៅពេលត្រឡប់មកផ្ទះវិញ ជននោះអាចមើលការទិតៀនឡើងវិញនិងធ្វើការប្រុងប្រយត្ន័។ ជនណាដែលចេះសរសេរត្រូវជួយអ្នកដែលមិនចេះសរសេរ។ ជនអ្នកចេះអក្សរត្រូវធ្វើសេចក្ដីសង្ខេបឱ្យច្បាស់អំពីអ្វីដែលគេបាន និយាយ (...)។

នៅពេលប្រជុំ គេបានកំណត់ទិសដៅផ្នែកយោធាទៅតាមកងពល និងទៅតាមអាកប្បកិរិយាដែលត្រូវប្រកាន់ជាមួយប្រជាជន។ ឧទាហរណ៍ កងពលមួយមានទិសដៅធ្វើការវាយសំរុកចូលទៅក្នុងភូមិមួយនៅវាលរាប។ នៅពេលប្រយុទ្ធគ្នា គឺគេហាមមិនឱ្យយករបស់របររបស់អ្នកភូមិឡើយ។ ប្រសិនបើមានអ្នកភូមិណាម្នាក់បានធ្វើការតវ៉ា ប្រធានកងពលបានសួរមនុស្សគ្រប់គ្នាទាំងអស់ ថាតើជនណាបានលួចរបស់អ្នកភូមិ។ គឺត្រូវសងរបស់នោះឱ្យប្រជាជនវិញ។ ជនណាដែលបានរក្សារបស់នោះទុកដោយពុំនិយាយអ្វីសោះ ត្រូវបានទទួលការចោទប្រកាន់ពីអ្នកដទៃទៀត។ ជននោះពុំអាចនៅក្នុងចលនាតស៊ូបានទេ ហើយត្រូវតែត្រឡប់ចុះមកតំបន់វាលរាបវិញ។ យើងធ្វើការប្រយុទ្ធជាមួយទាហានរដ្ឋាភិបាល ប៉ុន្តែពុំប្រឆាំងនឹងប្រជាកសិករឡើយ។ ចលនាតស៊ូក៏ជាប្រជាកសិករដូចយើងដែរ។ អ្វីដែលយើងធ្វើគឺដើម្បីផលប្រយោជន៍របស់ប្រជាកសិករ។ ប្រសិនបើយើងជួយប្រជាជន ប្រជាជនក៏ជួយយើងដែរ។ គឺមានការលំបាកណាស់សំរាប់ទាហ៊ានរដ្ឋាភិបាលក្នុងការបំផ្លាញយុទ្ធសាស្ត្រនេះ។ ប្រជាជនជួយយើងច្រើនណាស់ ពីព្រោះពួកយើងមានមនោសញ្ចេតនាល្អជាមួយប្រជាជន (...)។

គឺពុំមានការដាក់ទោសទេ ចំពោះជនណាដែលមានកំហុសធ្ងន់ធ្ងរ។ ជនណាដែលបានធ្វើខុសត្រូវតែប្រមែប្រមូលទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ហើយធ្វើដំណើរចេញទៅ។ គេពុំបានគិតអំពីជោគវាសនារបស់ជននោះឡើយ។ ប្រសិនបើជននោះបានចុះទៅតំបន់វាលរាប ជននោះអាចត្រូវសំលាប់ចោលឬជាប់ពន្ធនាគារដោយសារទាហានរបស់រដ្ឋាភិបាល។ កាលណាយើងរស់នៅក្នុងព្រៃ យើងមានការភ័យខ្លាចក្នុងការធ្វើដំណើរទៅភូមិនៅតំបន់វាលរាប។ ពួកទាហ៊ានរដ្ឋាភិបាលបានស្គាល់មុខមាត់យើងច្បាស់ណាស់។ ប្រជាជននៅក្នុងភូមិមកផ្ដល់ពត៌មានឱ្យយើងបានដឹង អំពីសភាពការណ៍យ៉ាងសំងាត់បំផុត (...)។

យុទ្ធជនកំលោះៗបានរស់នៅរួមគ្នា។ ចំណែកឯយុវនារីក្រមុំបានរស់នៅក្នុងខ្ទមតូចៗដែលសង់នៅជុំវិញផ្ទះរបស់ប្រធាននារី ហើយដែលឋិតនៅក្បែរកន្លែងរបស់យុទ្ធជនកំលោះដែរ។ ប្រសិនបើយុទ្ធជនម្នាក់បានមើលឃើញយុវនារីស្អាតម្នាក់ដែលខ្លួនពេញចិត្ត យុវយុទ្ធជននោះទៅនិយាយជាមួយប្រធានយុវយុទ្ធជន ហើយប្រធានយុវយុទ្ធជននឹងទៅនិយាយជាមួយប្រធានយុវនារីដើម្បីឱ្យ

សួរយុវនារីដែលយុវយុទ្ធជននោះពេញចិត្ត។ ប្រសិនបើ យុវនារីនោះយល់ព្រមគេបានប្រាប់ទៅឪពុកម្តាយជាមុន ហើយគេបានរៀបអាពាហ៍ពិពាហ៍។ មានក្រុមភ្លេងមួយក្រុមបានប្រគុំនៅកំពង់ត្រាច។ ប្រសិនបើ យុវជនយុវនារីទាំងពីរនាក់បានស្រលាញ់គ្នាដោយពុំបានឆ្លងកាត់តាមប្រធានរៀងៗខ្លួនទេ តាមបទបញ្ជារបស់ចលនាតស៊ូអ្នកទាំងពីរត្រូវតែចាកចេញពីចលនាតស៊ូ[១២៩] (...) ។

នៅក្នុងពេលប្រជុំ គេអាចនិយាយអ្វីៗបានទាំងអស់។ មានពតិមានច្រើនណាស់ហើយមនុស្សសំដែងមតិរបស់ខ្លួន គឺដូចជានយោបាយនៅប្រទេសសង្គមនិយមនិងប្រទេសប្រជាធិបតេយ្យជាដើម។ យើងដឹងគ្រប់ទាំងអស់ចំពោះអ្វីដែលបានកើតមានឡើង។ ខ្ញុំបានគិតថាគឺជាការល្អ។ គឺពុំមានចោរ និងពុំមានអ្នកផិតក្បត់ទេ។ មានពន្ធនាគារសំរាប់សត្រូវដែលមកពីក្រៅ ប៉ុន្តែចំពោះយើងទាំងអស់គ្នា ជនណាបានប្រព្រឹត្តខុសឆ្គងត្រូវតែចាកចេញទៅ។ ជននោះពុំអាចធ្វើជាយុទ្ធជននៃចលនាតស៊ូបានទៀតឡើយ" ។

(លោក នួន អាយុ ៤២ ឆ្នាំ អនុប្រធានឃុំ ទទួលបន្ទុកសន្តិសុខ (អតីតខ្មែរក្រហម )សង្កាត់ពងទឹក ក្រុងកែប(ភូមិបង្កើតថ្មី))

តាមវិន័យយោធារបស់ចលនាតស៊ូនៅក្នុងព្រៃ អាកប្បកិរិយាសង្គមដែលមានលក្ខណៈ"អាក្រក់" ត្រូវធ្វើការអប់រំ និងដាក់ទោសស្ទើរដូចគ្នាក្នុងសម័យមុនដែរ។ ឯអាកប្បកិរិយា"ល្អ" ត្រូវបានជូនរង្វាន់ដោយមានការចាត់ តាំងដំឡើងឋានន្តរសក្តិខ្ពស់ និងជូនវត្ថុអានុស្សាវរីយ៍ទៀតផង។

"កាលនៅជាមួយចលនាតស៊ូ ខ្ញុំធ្វើការផ្លាស់ប្តូរទីកន្លែងជាច្រើនដង។ មានការប្រយុទ្ធគ្នាជាច្រើនលើកជាមួយកំលាំងរដ្ឋាភិបាល។ ប្រសិនបើកំលាំងរដ្ឋាភិបាលពុំបានធ្វើការវាយប្រហារយើងជាច្រើនដងទេ យើងអាចរស់នៅមួយកន្លែងអស់រយៈពេលមួយរដូវ និងអាចដាំបន្លែបាន។ ក្រៅពីនេះ យើងបានធ្វើការផ្លាស់ប្តូរទីកន្លែង។ យើងបាននាំគ្នាសំរាកនៅក្នុងខ្ទមតូចៗ។ ជួនកាលយើងបានធ្វើដំណើរចាកចេញទៅយ៉ាងឆាប់រហ័សដោយបោះបង់របស់របរចោលទាំងអស់។ ប្រធានមានលក្ខណៈខុសពីប្រធានភូមិនៅខាងក្រោម(ទីវាលរាប)គឺជាមេទ័ព។ មេទ័ព ទទួលបន្ទុកបីផ្នែកគឺ នយោបាយ សេដ្ឋកិច្ច និងយោធា។ នយោបាយគឺការឃោសនា គឺត្រូវពង្រឹងកំលាំងផ្ទៃក្នុងមានន័យថាពង្រឹងយោធានិងអ្នកភូមិ។ យើងក៏ត្រូវធ្វើសកម្មភាពនៅខាងក្រៅដែរ ដើម្បីឱ្យប្រជាជននៅក្នុងភូមិ ផ្សេងៗទៀតចូលរួមជាមួយយើង។ បណ្តាញរបស់សហការីយើងបានជ្រៀតចូលទៅក្នុងភូមិ និងមានអនុភាពខ្លាំង ណាស់។ មនុស្សម្នាក់ៗបានអប់រំមនុស្សម្នាក់ផ្សេងទៀត។

---

[129] . "ចាកចេញ" . "ចេញ" ក៏អាចមានន័យថា "សម្លាប់"។

សេដ្ឋកិច្ច គឺការអាចរកធនធានសេដ្ឋកិច្ច។ យើងបានដាំបន្លែនិងស្រូវកាលណាយើងអាចរស់នៅអស់រយៈពេលយូរនៅទីកន្លែងមួយ ឬអាចធ្វើដំណើរទៅប៉ៃលិនដើម្បីរកលុយកាក់ទិញស្រូវអង្ករពីអ្នកភូមិ។

ទទួលបន្ទុកយោធា គឺធ្វើការប្រយុទ្ធប្រឆាំងនឹងខ្មាំងសត្រូវមកពីក្រៅ។ ភូមិត្រូវចែកបីប្រភេទៈ ភូមិដែលបានរំដោះរួចហើយ ហើយយើងបានកាន់កាប់ភូមិដែលពួកខ្មាំងសត្រូវបានកាន់កាប់បណ្តោះអាសន្ន និងភូមិដែលកាន់កាប់ដោយពួកខ្មាំងសត្រូវ។ មានការងារស្រួលក្នុងការឃោសនានៅក្នុងភូមិប្រភេទទីមួយ និងភូមិប្រភេទទីពីរ ប៉ុន្តែមានការលំបាកណាស់នៅក្នុងភូមិប្រភេទទីបី។ យើងបានចូលទៅក្នុងភូមិនោះនៅពេលយប់ និងបានធ្វើការឃោសនាពីផ្ទះមួយទៅផ្ទះមួយទៀត។ ប្រសិនបើយើងពុំអាចចូល ដោយខ្លួនឯងទៅក្នុងភូមិប្រភេទទីបីបានទេ យើងបានបញ្ជូនគិញពីភូមិប្រភេទទីមួយនិងទីពីរឱ្យចូលទៅក្នុងភូមិនោះ។ ប្រសិនបើពួកគិញទាំងនោះពុំអាចពន្យល់ប្រជាជនអ្នកភូមិនោះឱ្យជឿបានទេ យើងបានធ្វើប្រតិបត្តិការយោធា។ គឺជាភូមិដែលនៅជាប់គ្នា។ នៅក្នុងភូមិ គេបានចាប់ជនទាំងឡាយដែលមានចំណងទាក់ទងជាមួយរដ្ឋាភិបាលៈ មេភូមិ មេក្រុម ក្រុមចោរប្លន់ ក្រុមចោរ និងពួកទាហាន។ យើងបានធ្វើការប្រជុំជនទាំងនោះដើម្បីធ្វើការអប់រំ។ ដំបូងយើងធ្វើការអប់រំ បន្ទាប់មកយើងបានធ្វើការព្រមានប្រសិនបើជនទាំងនោះនៅតែរឹងរូស ហើយទីបីគឺយើងសំលាប់ចោលតែម្តង។ យើងសំលាប់ចោល ពីព្រោះនៅក្នុងព្រៃពុំមានពន្ធនាគារទេ។

នៅក្នុងព្រៃ យើងបានធ្វើការប្រជុំច្រើនណាស់ មានការរៀនសូត្រ ការត្រួតពិនិត្យ។ នៅក្នុងការអប់រំ យើងបានបង្រៀនឱ្យចេះប្រកាន់អាកប្បកិរិយាល្អ។ សីលធម៌យោធាមានដល់ដប់ពីរប្រការ។ ជនណាដែលបាន គោរពតាមមាត្រាទាំងដប់ពីរយ៉ាងត្រឹមត្រូវនោះបានគឺអាចឡើងស័ក្តិ។ ជនណាដែលបានគោរពបានបន្តិចបន្តួច នៅតែជាទាហានធម្មតា។ ប្រការទីមួយ គឺសាមគ្គីភាព។ ប្រការទីពីរ គឺបាននិយាយថាមិនត្រូវប៉ះពាល់ទ្រព្យសម្បត្តិរបស់ប្រជាជនឡើយ។ គឺមិនត្រូវយករបស់ប្រជាជនឡើយដូចជាម្ទេសមួយផ្លែ អង្ករមួយគ្រាប់ សំបុកនាង មួយក៏ពុំត្រូវយកឡើយ។ មាត្រាទីបីបាននិយាយថា ត្រូវហ៊ានលះបង់ផលប្រយោជន៍ផ្ទាល់ខ្លួន ទ្រព្យសម្បត្តិ ផ្ទាល់ខ្លួន និងជីវិតរបស់ខ្លួនដើម្បីផលប្រយោជន៍រួមទាំងអស់គ្នា។ ខ្ញុំបានភ្លេចមាត្រាផ្សេងៗទៀត ប៉ុន្តែគឺជាបញ្ហា ស្និទ្ធស្នាលគ្នា ស្មោះត្រង់ ការជួយគ្នាទៅវិញទៅមក និង ការទទួលខុសត្រូវខ្លួនឯងនៅពេលធ្វើស្វ័យទិតៀន។ តាមយោបល់ខ្ញុំ ប្រសិនបើគេបានគោរពមាត្រាទាំងដប់ពីរនោះបានល្អ គេបានក្លាយទៅជាយោធាមួយដ៏ខ្លាំងណាស់ ហើយនៅលើសមរភូមិគេមិនចាញ់ទេ។ អាទិភាព

ត្រូវបានផ្តល់ឱ្យទៅទាហានដែលមានការពឹងផ្អែកទៅលើព្រៃង វាសនាជាតិ។ ប្រសិនបើគេប្រព្រឹត្តផ្ទុយទៅនឹងវិន័យ គេពុំបានឡើងស័ក្តិទេហើយបានទទួលការអប់រំជានិច្ច(...)។ គេត្រូវតែមានសាមគ្គីភាពនិងលាក់ទុកបញ្ហានានានៅក្នុងខ្លួនជានិច្ច។ ឧទាហរណ៍ ប្រសិនបើប្តីប្រពន្ធពីរនាក់ឈ្លោះទាស់ទែងគ្នាដូចជា ប្តីបានវាយតប់ប្រពន្ធ ប្រពន្ធពុំត្រូវនិយាយអ្វីទេ ពីព្រោះការនេះអាចធ្វើឱ្យប៉ះពាល់ដល់ការឡើងឋានន្តរស័ក្តិរបស់ប្តីគាត់។ មានតែនៅក្នុងករណីមានបញ្ហាប្តីប្រពន្ធធ្ងន់ធ្ងរបំផុតទេ ឬមានការវាយតប់គ្នារហូតដល់មានបែកឈាមទើបប្រធានមកធ្វើអន្តរាគមន៍។ ប្រធានធ្វើការណែនាំដល់ប្តីនៅពេលធ្វើការប្រជុំរួមគ្នា។ ប្រសិន បើមានការធ្វើខុសឆ្គងម្តងទៀតប្រធានកងពលបញ្ជូនជននោះឱ្យទៅសមរភូមិមួយទៀត ឬបញ្ចុះឋានន្តរស័ក្តិរបស់គាត់។ ឧទាហរណ៍ ប្រសិនបើជននោះជាអនុប្រធានកងពល គេបញ្ជូនគាត់ឱ្យទៅកន្លែងផ្សេងៗទៀតដោយមានទាំងការបញ្ចុះឋានន្តរស័ក្តិទៀតផង។ នៅពេលប្រព្រឹត្តខុសលើទីបី ជននោះពុំអាចធ្វើជាទាហ៊ានតទៅទៀតបានទេ ហើយបានក្លាយទៅជាកសិករធម្មតា។ ប្រសិនបើគាត់នៅបន្តទៅទៀត គេបានឱ្យគាត់ដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវនៅតាមបណ្តោយព្រំដែនឬឱ្យឃ្វាលមេគោ។ នៅក្នុងករណីធ្ងន់ធ្ងរបំផុតគាត់ត្រូវសំលាប់ចោល។ ប៉ុន្តែ ករណីនេះពុំសូវកើតមានញឹកញាប់ដូចកាលជំនាន់ ប៉ុល ពត ទេ។

កម្ពុជាប្រជាធិបតេយ្យបានលើកទឹកចិត្តយើងឱ្យប្រកាន់អាកប្បកិរិយាល្អ។ គេបានផ្តល់រង្វាន់ដែលមានន័យដូចគ្នាទៅនឹងឋានន្តរស័ក្តិដែរ។ គេឱ្យនាឡិកាដៃកាលណាឡើងជាប្រធានក្រុម ឱ្យវិទ្យុកាលណាឡើងជាប្រធានកងពលតូច ឱ្យម៉ាស៊ីនស្តាប់ចំរៀងនិងអាយកូម(Icom)មួយសំរាប់ប្រធានកងពលធំ ឱ្យម៉ូតូម៉ាកDream 100 មួយនិងទូរទស្សន៍មួយសំរាប់ប្រធានវរសេនាធំ។ មានរថយន្តមួយគ្រឿងសំរាប់ប្រធានកងពល។
ប្រព័ន្ធនេះបានដំណើរការល្អ។ យោធាម្នាក់ៗបានសរសេរមាត្រាទាំងនោះនៅក្នុងសៀវភៅ ហើយបានទន្ទេញចាំស្ទាត់។ ការធ្វើរបៀបនេះបានប្រព្រឹត្តទៅយ៉ាងល្អ គឺមានវិន័យ។ នៅក្នុងឆ្នាំ១៩៩៤ នៅពេលដែលគេបានចុះចូលគេបានបោះបង់ចោលប្រព័ន្ធនោះភ្លាម ប៉ុន្តែប្រព័ន្ធនេះនៅចាំក្នុងក្បាល។ ឧទាហរណ៍សាមគ្គី ប្រសិនបើខ្ញុំមានបញ្ហាអ្វីមួយជាមួយភរិយាខ្ញុំ ខ្ញុំបានគោរពតាមរបៀបអហឹង្សា ហើយខ្ញុំបានសាកល្បងឱ្យភរិយាខ្ញុំពន្យល់ខ្ញុំវិញ។ ប្រសិនបើមានសត្វអ្នកជិតខាងមកស៊ីដំណាំខ្ញុំ ខ្ញុំបានទៅពិភាក្សាជាមួយគាត់។ ប្រសិនបើកូនៗបានវាយតប់គ្នា ខ្ញុំមិនបានខឹងអ្វីដែលកូនៗនោះនិយាយឡើយ ហើយខ្ញុំក៏មិនខឹងឪពុកម្តាយរបស់កូនអ្នកផ្សេងដែរ ខ្ញុំគ្រាន់តែចាប់បំបែកក្មេងទាំងនោះ"។

(លោក នាគ អាយុ ៣៨ ឆ្នាំ អាជីវករបន្ទប់វីដេអូ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

ប្រធាន។ខ្លះបានប្រើវិធីតឹងតែងបំផុត។

"កាលពីពេលនៅក្នុងព្រៃ កាលណាមានជំលោះរវាងបុរសនិងនារី មេទ័ពបានដោះស្រាយបញ្ហាដោយសំលាប់អ្នកទាំងពីរ។ គឺមានការងាយស្រួលណាស់ពីព្រោះមានគ្រាប់កាំភ្លើងពេញ។ឡាំង។ មនុស្សដែលគេចោទប្រកាន់អំពីអំពើក្បត់ក៏ត្រូវបានសំលាប់ដែរគឺ ជនដែលពុំបានធ្វើតាមបញ្ជា ឬជនដែលបានលួចរបស់របរនៅក្នុងភូមិខាងក្រោម។ គេសំលាប់ងាយណាស់។ គេដាក់ឱ្យជននោះឈរនៅចំងាយសាមសិបម៉ែត្រ ហើយគេឱ្យជននោះក្រឡេកមើលឱ្យចំភ្នែកគេដើម្បីងាយស្រួលតំរង់។ នៅចំងាយសាមសិបម៉ែត្រគេបាញ់ស្លាប់ភ្លាម គឺងាយណាស់។ ក្រោយមកគេកប់សាកសពជននោះ ទោះបីជននោះនៅពុំទាន់ស្លាប់ក៏ដោយ"។

(លោក យូ អាយុ ៦២ ឆ្នាំ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត (ភូមិបង្កើតថ្មី))

ប៉ុន្តែ ទោះបីវិន័យនៅតែតឹងរឹងក៏ដោយ ជាទូទៅលក្ខណៈនៃការរស់នៅមានភាពធូរស្រាលបើប្រៀបធៀបទៅសម័យមុន។

"នៅមុនឆ្នាំ១៩៧៩ គេបានធ្វើការរហូត។ គេពុំបានឈប់សំរាកទាស់តែសោះ។ នៅក្រោយឆ្នាំ១៩៧៩ គឺមានលក្ខណៈខុសគ្នា។ គឺពុំមានការងារធ្វើទំនប់ទឹកធំ។ទេ។ គេពុំបានធ្វើស្រែទេនៅរដូវក្តៅ។ គេបានដាំពោត ដាំស្រូវ ដាំដំណាំយកមើម ដាំចេក-ដាំល្ហុង គេបានបោចស្មៅ គេបានធ្វើការត្រួតពិនិត្យចំការដំណាំមើលសត្វល្អិត និងបសុសត្វ។ មានមនុស្សប្រុសកាន់កាំភ្លើងដើម្បីថែរក្សាជំរំ។ ជួនកាលមេទ័ពស័ក្តិពីរឬស័ក្តិបីបានមកធ្វើការប្រជុំ។ ពួកគេបាននិយាយអំពីសភាពការណ៍យោធារបស់កងកម្លាំងពីខាងក្រៅ។ ពួកគាត់បានធ្វើការបកស្រាយអំពីផែនការរបស់ប្រជាជននៅក្នុងព្រៃអំពីវិធានការដែលត្រូវប្រកាន់យក ដើម្បីតស៊ូប្រឆាំងនឹងការគាបសង្កត់ពីខាងក្រៅ។ មានប្រធានមួយរូបទទួលបន្ទុកកិច្ចការវប្បធម៌ ប្រធានមួយរូបទទួលបន្ទុកសកម្មភាពសង្គម និងប្រធានមួយរូប ទទួលបន្ទុកកិច្ចការពារ។ ប្រធាន។បានធ្វើការប្រជុំរួមគ្នា និងបានធ្វើការសំរេចលើទិសដៅដែលត្រូវអនុវត្តន៍ ហើយបញ្ជូនទិសដៅនោះឱ្យទៅសមាជិករបស់ខ្លួន ឬមួយទិសដៅទាំងនោះត្រូវបានបញ្ជូនទៅសមាជិករបស់ខ្លួនដោយផ្ទាល់តែម្តង។ បន្ទាប់មកប្រធាន។បានសួរពួកយើងថា តើយើងយល់ស្របតាមវិធានការទាំងអស់នេះដែរឬទេ? ។ កាលណាមានជនខ្លះនិយាយថាទិសដៅទាំងនោះមានការលំបាកខ្លាំងពេក ប្រធាន។បានស្តាប់ហើយបានសំរបសំរួលទិសដៅទាំងនោះ។ គេធ្វើការប្រៀបធៀបហេតុការណ៍ទាំងអស់នេះជាមួយនឹងអ្វីដែលកើតមានកាលពីប៉ុន្មានឆ្នាំមុន ហើយគេបានរិះរកមធ្យោបាយដ៏ល្អប្រសើរដើម្បីផលិតស្រូវឱ្យបានច្រើន។ គេបានធ្វើសង្គ្រាមប្រឆាំងនឹងទាហ៊ានមកពីខាងក្រៅ។ ប្រសិនបើគេបានលួច

ទ្រព្យសម្បត្តិរបស់ប្រជាជននៅក្នុងភូមិនៅពេលមានការប្រយុទ្ធគ្នា ទាហ៊ានខាងក្រៅបានធ្វើការសងសឹកដោយធ្វើការវាយប្រហារ។ វិន័យរបស់ពួកខ្មែរក្រហមគឺល្អ។ មនុស្សម្នាក់ៗ មានការទទួលខុសត្រូវ។ គេអាចនិយាយអំពីខ្លួនឯងនៅពេលមានការប្រជុំ និងបាននិយាយអំពីអ្វីដែលខ្លួនបានធ្វើខុស (...)។

នៅឆ្នាំ១៩៨៤ ខ្ញុំបានទៅតាមប្តីរបស់ខ្ញុំនៅក្នុងព្រៃអស់រយៈពេលប្រាំមួយខែបន្ទាប់មកខ្ញុំ បានធ្វើដំណើរទៅខេត្តបាត់ដំបង។ ប្រធាននៅកន្លែងនោះគឺជាមេទ័ព។ បញ្ហាដែលកើតមានគឺការអត់ឃ្លាន គេមានស្បៀងតិចតួចណាស់សំរាប់បរិភោគ គេបានធ្វើការយ៉ាងច្រើន។ ប្រសិនបើមានបញ្ហាអ្វីមួយ គឺគេត្រូវធ្វើការប្រជុំក្រុមតែម្តង។ កាលណាមានជំលោះជាមួយជនណាម្នាក់ គេចូលចិត្តដោះស្រាយរឿងនោះនៅកំរិតថ្នាក់ពួក។ គឺជាការងាយស្រួលណាស់ ប៉ុន្តែជួនកាលមានការចោទប្រកាន់ពីថ្នាក់លើ ហើយហេតុការណ៍នេះបានឡើងទៅដល់ប្រធានក្រុម។ សភាពការណ៍ថ្មីគឺថាប្រជាជនដែលមានការអាក់អន់ចិត្តបាននិយាយពីរឿងនេះ។ ឧទាហរណ៍ ប្រសិនបើនៅពេលប្រជុំរបស់ថ្នាក់ពួកគេបាននិយាយថាមានជនណាម្នាក់បានធ្វើការតែបន្តិចបន្តួច ជននោះមានការខឹងខ្លាំងនិងបាននិយាយថា ពីព្រោះតែគាត់ពុំមានអ្វីបរិភោគ ហើយគាត់ពុំមានកំលាំងគ្រប់គ្រាន់ដើម្បីអនុវត្តន៍ការងារនោះ។ គេបដិសេធកំហឹងរបស់ជននោះ។ ចំណែកឯប្រធានក្រុមបាននិយាយទៅកាន់សមាជិកផ្សេងទៀតរបស់ "ពួក" ដើម្បីធ្វើការតាមដានជននោះ (...)។

នៅពេលប្រជុំប្រធានក្រុមបានសួរថាៈ "តើអ្នកបានដឹងថាអ្នកបានធ្វើអ្វីខ្លះ? អ្នកត្រូវសារភាព។ ប្រសិនបើអ្នកបានសារភាពនោះនឹងពុំមានការដាក់ទោសទេ ប៉ុន្តែត្រូវតែតាមដាន។ ប៉ុន្តែ ប្រសិនបើអ្នកពុំបានសារភាពទេ អ្នកត្រូវតែចាកចេញជាបន្ទាន់នៅក្រោយពេលប្រជុំ។ ប្រសិនបើអ្នកមិនចង់ចាកចេញទេ អ្នកត្រូវទទួលការអប់រំ(សំលាប់)។ គេបានធ្វើការទិតៀនបានតែនៅពេលប្រជុំប៉ុណ្ណោះ នៅខាងក្រៅគឺត្រូវហាមឃាត់។ កាលណាគេ បានទិតៀនជនណាម្នាក់គេត្រូវរកចំណុចសំរាប់ធ្វើការទិតៀនឱ្យបានច្រើន (...)"។

ក្នុងករណីមានកំហុសធ្ងន់ធ្ងរ ដូចជាការលួចទ្រព្យសម្បត្តិរបស់អ្នកភូមិ ប្រសិនបើអ្នកបានលួចរបស់នោះពុំបានសារភាពទេ មេក្រុមត្រូវតាមដាន។ ប្រសិនបើមេក្រុមបានរកឃើញអ្នកលួចគាត់បានប្រគល់របស់នោះទៅឱ្យអ្នកភូមិវិញ។ ឯអ្នកលួចបានរត់គេចខ្លួនទៅក្នុងតំបន់វាលរាប ពីព្រោះគាត់មានការភ័យខ្លាចមេក្រុមសំលាប់ចោល។ ខ្ញុំបាននឹកឃើញរឿងរបស់គ្រូពេទ្យម្នាក់នៅក្នុងចលនាតស៊ូដែលបានលួចរបស់របរអ្នកភូមិជាច្រើនដងៈ គ្រូពេទ្យនោះត្រូវបានអប់រំ ហើយត្រូវសំលាប់ចោល"។ (លោកស្រី សារី អាយុ ៤៧ ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប(ភូមិបង្កើតថ្មី))

"នៅឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់មកភូមិកំណើតនៅដងទង់វិញ(ខាងរដ្ឋាភិបាល)។ ប្រព័ន្ធថ្មីពុំសូវមានលក្ខណៈរឹងមាំនិងពុំសូវតឹងតែងដូចកាលពីមុនទេ។ គឺពុំសូវមានយុត្តិធម៌និងសាមគ្គីភាព។ នៅក្រោយឆ្នាំ១៩៧៩ ប្រជាជននៅក្នុងភូមិបានគិតទៅដល់អង្គការក្នុងកំរិតតិចតួចណាស់។ ប្រជាជនបានគិតតែពីបញ្ហារបស់គ្រួសារខ្លួនប៉ុណ្ណោះ។ ប្តីខ្ញុំបានរស់នៅក្នុងព្រៃជាមួយចលនាតស៊ូ។ ប្រជាជនបានធ្វើការទិតៀនរូបខ្ញុំដោយសារតែតួនាទីរបស់ប្តីខ្ញុំ។ ខ្ញុំត្រូវបានគេចោទប្រកាន់ថា មានបណ្តាញគិញ្ចរបស់ពួកខ្មែរក្រហមនៅក្នុងភូមិ។ ខ្ញុំមានការភ័យខ្លាច អាជ្ញាធរចង់ចាប់ខ្ញុំយកទៅដាក់ពន្ធនាគារ។ ខ្ញុំបានទៅតាមប្តីខ្ញុំនៅក្នុងព្រៃ។ មានការផ្លាស់ប្តូរខ្លះៗ។ គេបានបោះបង់ចោលការងារសង់ទំនប់ទឹកធំៗនិងការជីកប្រឡាយ(...)។ វិន័យពុំមានលក្ខណៈតឹងតែងដូចកាលពីមុនទៀតឡើយ។ នៅពេលធ្វើការប្រជុំស្វ័យទិតៀន ប្រជាជនពុំបានទទួលយកការចោទទាំងអស់ទេ ហើយបាននិយាយឆ្លើយតបវិញ។ កាលពីមុនគេពុំបាននិយាយអ្វីទាស់តែសោះ។ គេបានទទួលយល់ស្របតាមការទិតៀន។ គឺប្រសើរជាងកាលពីឆ្នាំ១៩៧៥។ ប្រសិនបើគេបានចោទយើង យើងទទួលយក យើងទទួលខុសត្រូវចំពោះអំពើទាំងនោះ ហើយយើងបានធ្វើការកែខ្លួនវិញ។ យើងអាចពន្យល់អំពីការចោទប្រកាន់ខុសទេ ប៉ុន្តែយើងមិនបានធ្វើការបះបោរទេ។ នៅក្រោយឆ្នាំ១៩៨៣ ពួកបងៗពុំសូវទទួលខុសត្រូវទេ។ គាត់លែងទទួលយកការចោទទៀតហើយ ហើយក៏បដិសេធមិនទទួលស្គាល់កំហុសរបស់ខ្លួន។ ប្រធានៗគឺជាយោធា។ ទាហានចាស់ៗបានគោរពតាមបទបញ្ជា ប៉ុន្តែយុវជនក្មេងៗមិនសូវគោរពវិន័យឡើយ"។

(លោកស្រី សែន អាយុ ៤៨ ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប(ភូមិបង្កើតថ្មី))

"នៅក្នុងព្រៃ វិន័យពុំមានលក្ខណៈតឹងតែងដូចកាលពីឆ្នាំ១៩៧៥ដល់១៩៧៩ទេ។ គឺពុំមានការដាក់ទោសកំរិតធ្ងន់ធ្ងរទេ ប៉ុន្តែមានការបញ្ចុះឋានន្តរស័ក្តិ។ ជនណាដែលសកម្មអាចឡើងស័ក្តិ។ ជនណាដែលមិនសកម្មនៅលើសមរភូមិពុំបានឡើងស័ក្តិទេ។ ធ្វើជាប្រធានគឺ ត្រូវជួយគេ ប្រធានបែងចែកស្បៀងអាហារ ផ្តល់គោ រទេះ លុយកាក់។ គឺពុំមានវណ្ណៈទេ មានតែសក្តិយសដែលម្នាក់ៗអាចដណ្តើមបានដោយសារការងាររបស់ខ្លួន។ ពុំមានបញ្ហាវាងគ្នាយើងទេ។ យើងបានរួបរួមគ្នាតែមួយដើម្បីធ្វើការប្រយុទ្ធ"។

(លោក ទិត អាយុ ៥៤ ឆ្នាំ អនុប្រធានឃុំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប (ភូមិបង្កើតថ្មី))

អតីតមេទ័ពខ្មែរក្រហមដែលស្គាល់តែវិន័យយោធា បានសារភាពពីការលំបាកក្នុងការគ្រប់គ្រងភូមិមួយនៅក្នុងពេលសព្វថ្ងៃនេះ។

"នៅក្នុងរយៈពេលនោះ ខ្ញុំបានគ្រប់គ្រងទាហ៊ានជាច្រើន។ បច្ចុប្បន្នកាលនេះខ្ញុំគ្រប់គ្រងអ្នកភូមិ។ គឺមានការខុសគ្នា។ ជាមួយពួកទាហាន កាលណាគេឱ្យទិសដៅមួយគេអាចទទួលលទ្ធផលពីទិសដៅនោះ។ ពួកទាហានគោរពតាមបទបញ្ជា។ ចំពោះប្រជាជន កាលណាយើងកំណត់ទិសដៅរួចហើយ យើងពុំសូវបានទទួលលទ្ធផលច្រើនទេ។ គឺមានការលំបាកណាស់"។

(លោក សាម៉ុន អាយុ ៤២ ឆ្នាំ មេភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាង ស្រុកឈូក ខេត្តកំពត(បង្កើតថ្មី))

**បញ្ហារស់នៅជាមួយអតីតខ្មែរក្រហមនៅក្នុងភូមិ:** ការបំបាត់ទំនាស់និងការសងសឹកគ្រប់រូបភាពទាំងអស់។

នៅឆ្នាំ១៩៧៩ ប្រជាជនភាគច្រើនដែលបានរស់នៅជាមួយពួកខ្មែរក្រហម(លើកលែងតែមេធំៗ) បានឆ្លៀតឱកាសវិលត្រឡប់មករកភូមិកំណើតខ្លួនវិញនៅពេលដែលពួកខ្មែរក្រហមបាក់ទ័ព ក្នុងក្ដីសង្ឃឹមដើម្បីវិលទៅរកជីវភាពសុខស្រួលដូចធម្មតាវិញ។

របបថ្មីមានការស្វាគមន៍អាចទទួលយកបាន ដោយហេតុថារបបនោះបានរំដោះប្រទេសឱ្យផុតពីការកាន់កាប់របស់ពួកខ្មែរក្រហម។ នៅពេលជំនុំជំរះក្ដីដែលបានប្រព្រឹត្តទៅចំពោះមុខតុលាការប្រជាជននៅខែសីហាឆ្នាំ១៩៧៩ របបថ្មីបានផ្ដន្ទាទោសប្រហារជីវិតដោយកំបាំងមុខចំពោះអតីតមេដឹកនាំសំខាន់ៗរបស់ខ្មែរក្រហម និងបានប្រយុទ្ធជាមួយខ្មែរក្រហមតាមផ្លូវយោធា។ នៅក្នុងភូមិគេធ្វើការតាមដានអតីតកម្មាភិបាលខ្មែរក្រហមដើម្បីចាប់ពួកនោះដាក់ពន្ធនាគារ និងកំទេចចោលគ្រប់ប្រភពនៃការឃោសនានយោបាយ។

នៅឆ្នាំ១៩៧៩ ប្រតិកម្មយ៉ាងឆាប់រហ័សទីមួយរបស់អ្នកភូមិគឺ សំលាប់ពួកអតីតខ្មែរក្រហមដែលវិលត្រឡប់មកភូមិវិញ និងជនទាំងឡាយដែលត្រូវគេស្គាល់ថាជាអ្នកដែលបានប្រព្រឹត្តអំពើឃោឃៅពីមុនមក។ បន្ទាប់មក ប្រជាជនបានគោរពតាមការណែនាំរបស់រដ្ឋាភិបាលដែលបានស្នើសុំឱ្យមានការបន្ធូរបន្ថយ និងបានប្រកាសថាមានតែតុលាការទេដែលត្រូវទទួលដោះស្រាយបញ្ហានោះ។ អតីតកម្មាភិបាលខ្មែរក្រហមខ្លះដែលបានវិលត្រឡប់មករកជីវភាពរបស់ខ្លួននៅក្នុងភូមិកាលពីមុនពេលមានសង្គ្រាម ត្រូវបានអាជ្ញាធរតាមចាប់ហើយត្រូវបង្ខំចិត្តវិលត្រឡប់ទៅចូលជាមួយចលនាតស៊ូប្រដាប់អាវុធវិញ។ អ្នកខ្លះទៀតបានរស់នៅជាមួយប្រជាជន ហើយធ្វើជាបំភ្លេចរឿងនោះចោល។

"ពួកអតីតខ្មែរក្រហមបានវិលត្រឡប់មកភូមិវិញ។ នៅពេលនោះពួកគេខ្លាចយើងណាស់។ ប្រជាជនដូចជាយើងខ្ញុំគោរពសាសនា។ យើងពុំចង់ធ្វើការសងសឹកទេ។ នៅទីនេះគេពុំបានសំលាប់ពួកអតីតប្រធានសហករណ៍ទេ។ នៅទីកន្លែងផ្សេងទៀតប្រជាជនបានសំលាប់ប្រធានសហករណ៍។ នៅទីនេះ គេបានធ្វើតាមនយោបាយ រដ្ឋាភិបាលដែលបានប្រកាសថាកុំឱ្យសងសឹក"។

(លោក សម្បត្តិ អាយុ ៤៥ ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

"នៅដើមឆ្នាំ១៩៨០ ប្រជាជននៅក្រុងសៀមរាបបានមកដល់ភូមិនេះ។ ពួកគេបានស្វែងរកកូនប្រុសខ្ញុំ។ ពួកគេបាននាំកូនប្រុសខ្ញុំចូលទៅក្នុងព្រៃហើយសំលាប់ចោល(...)។ ពួកគេបាននិយាយថា កូនប្រុសរបស់ខ្ញុំជាខ្មែរ ក្រហមហើយវាបានប្រព្រឹត្តអំពើអាក្រក់ច្រើនណាស់។ ខ្ញុំពុំជឿថានោះជារឿងពិតទេ(...)។ កូនប្រុសខ្ញុំជាគ្រូពេទ្យនៅក្នុងពន្ធនាគារមួយ។ វាមិនបានធ្វើអ្វីអាក្រក់ទេ(...)។ ប្រជាជននៅទីនោះពុំបាននិយាយអ្វីទាស់តែសោះ។ ក្នុងចំណោមពួកគេជាច្រើនគឺជាខ្មែរក្រហម ប៉ុន្តែគេពុំបានធ្វើអ្វីដល់ជនទាំងនោះឡើយ។ គេបានទុកឱ្យជនទាំងនោះរស់នៅដោយសុខស្រួល។ មនុស្សមករកតែកូនប្រុសខ្ញុំម្នាក់ប៉ុណ្ណោះ"។
(លោកស្រី សេន អាយុ ៧២ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ក្នុងកំឡុងទសវត្សឆ្នាំ១៩៩០ យុទ្ធជនខ្មែរក្រហមបានបាត់បង់ទឹកដីរបស់ខ្លួនដោយធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់កំលាំងរដ្ឋាភិបាល។ មេទ័ពនិងពលទាហ៊ានរបស់គេបានមកសុំចុះចូលជាបន្តបន្ទាប់ ហើយបានវិលត្រឡប់មករស់នៅជិតសត្រូវរបស់ខ្លួនកាលពីពេលមុន។ ពេលវេលាបានឈានមកដល់ការសំរុះសំរួលជាតិបងប្អូនខ្មែរបានត្រឡប់មករួបរួមគ្នាវិញ។

"នៅពេលដែលពួកខ្មែរក្រហមបានវិលត្រឡប់មកតាំងទីលំនៅនៅក្នុងភូមិ ជាមួយគ្រួសាររបស់គេវិញ គេពុំបាននិយាយអ្វីទេ។ ប្រធានភូមិបានធ្វើការប្រជុំមួយហើយបាននិយាយថា"ប្រសិនបើគេចង់ធ្វើការសងសឹកប្រជាជនខ្មែរនឹងស្លាប់អស់។ យើងជាខ្មែរទាំងអស់គ្នា យើងរស់នៅក្នុងសង្គមតែមួយយើងត្រូវចេះស្រុះស្រួលគ្នា"។

ខ្ញុំពុំចង់ធ្វើការសងសឹកឱ្យឪពុកខ្ញុំដែលត្រូវពួកខ្មែរក្រហមសំលាប់នោះទេ ពីព្រោះប្រសិនបើខ្ញុំសំលាប់ជនដែលសំលាប់ឪពុកខ្ញុំ កូនប្រុសគាត់និងសំលាប់ខ្ញុំវិញ។ លើសពីនេះទៀត ប្រសិនបើខ្ញុំសំលាប់ជនដែលសំលាប់ឪពុកខ្ញុំ ការនេះក៏ពុំអាចធ្វើឱ្យគាត់អាចរស់មកវិញដែរ។ ប្រសិនបើខ្ញុំសំលាប់ ហើយការនោះបានធ្វើឱ្យឪខ្ញុំមានជីវិតរស់ឡើងវិញ នៅក្នុងករណីនេះ ខ្ញុំនឹងសំលាប់ជនដែលបានសំលាប់ឪពុកខ្ញុំ។ ផ្ទុយទៅវិញ អំពីនេះពុំបានបំរើឱ្យអ្វីទាំងអស់"
(លោក សម្បត្តិ អាយុ៤៨ ឆ្នាំ សង្កាត់កែប ក្រុងកែប)

"នៅក្នុងពេលបច្ចុប្បន្នកាលនេះ ដោយសារតែការអប់រំផ្នែកសាសនា ប្រជាជនមានលក្ខណៈស្ងៀមស្ងាត់។ គេត្រូវតែប្រតិបត្តិតាមការបង្ហាត់បង្រៀនរបស់ព្រះពុទ្ធ។ នៅសម័យ ប៉ុល ពត ខ្ញុំបានបាត់បង់គ្រួសារខ្ញុំ។ ខ្ញុំបានឃើញមនុស្សដែលបានសំលាប់ឪពុកម្តាយខ្ញុំ។ ឥឡូវនេះ ខ្ញុំបានឃើញពួកគេរៀងរាល់ថ្ងៃ។ ដោយសារការបង្ហាត់បង្រៀនរបស់វត្តអារាម ខ្ញុំបានសាកល្បងបំភ្លេចអំពើរបស់ជនទាំងនោះ។ គឺនឹងមានអំពើនៃផលកម្ម។ ជនណាដែលបានប្រព្រឹត្តអំពើអាក្រក់នឹងទទួលផល

អាក្រក់នៅក្នុងជាតិក្រោយ។ មានតុលាការរបស់ពួកយមរាជគឺ ចៅក្រមរបស់ពួកនរក។ នៅក្នុងទ្រឹស្តីរបស់ព្រះពុទ្ធសាសនាមានពិភពពីរគឺ ពិភពនៃការរស់នៅសព្វថ្ងៃដែលមានតុលាការរបស់មនុស្ស និងពិភពនៅជាតិក្រោយទៀតដែលមានចៅក្រមរបស់ពួកនរក(...)។ ក្នុងពេលបច្ចុប្បន្នកាលនេះ ពួកអតីតខ្មែរក្រហមបាននាំគ្នាទៅវត្តអារាមដើម្បីធ្វើអំពើជាកុសល"។

(លោក សុត អាយុ ៦៤ ឆ្នាំ អាចារ្យ វត្តព្រៃតាកុយ សង្កាត់អង្កោល ក្រុងកែប)

"មានគ្រួសារអតីតខ្មែរក្រហមខ្លះបានមកតាំងទីលំនៅនៅក្នុងភូមិ នៅពេលដែលពួកគេបានមកចុះចូល។ ពួកគេត្រូវបានធ្វើសមាហរណកម្មយ៉ាងល្អ។ អ្នកខ្លះមានគ្រួសារនៅទីនេះ អ្នកខ្លះទៀតបានរៀបអាពាហ៍ពិពាហ៍ជាមួយនារីនៅទីនេះ។ ឥឡូវនេះពួកគេមានអាកប្បកិរិយាស្លូតបូតណាស់ ហើយពួកគេបាននិយាយដូចយើងដែរ គឺពួកគេស្អប់អំពើប្រល័យពូជសាសន៍ណាស់។ អ្នកដែលមានគ្រួសារនៅទីនេះបានរកឃើញថា ឪពុកម្តាយរបស់គេត្រូវបានសំលាប់។ គេមានការទុក្ខព្រួយ គេមានការសោកស្តាយណាស់។ អ្នកខ្លះទៀតបាននិយាយថា គេមានវិប្បដិសារីខ្លាំងណាស់ ហើយបានធ្វើតាមបទបញ្ជាដ៏អាក្រក់។ អ្នកខ្លះទៀតបាននិយាយថា គឺជាការល្អតែជនទាំងនោះពុំបង្កើតបញ្ហាឡើយ។ ឥឡូវនេះ រឿងទាំងនោះបានចប់ហើយ"។

(លោក សារិន អាយុ ៥៩ ឆ្នាំ សង្កាត់អង្គកោល ក្រុងកែប)

ប៉ុន្តែនៅពីក្រោយសំបកនៃការសំរុះសំរួលនិងភាពសុខដុមដែលបានរកឃើញឡើងវិញ ការមិនទុកចិត្តគ្នានៅតែមានជាប់ជានិច្ច។ ជារៀងរាល់ថ្ងៃ ថ្វីបើទំនាក់ទំនងរវាងគ្នានិងគ្នាមានលក្ខណៈធម្មតាឡើងវិញក្នុងជីវិតប្រចាំថ្ងៃ នៅពេលមានការលំបាកបានមកដល់ មនោសញ្ចេតនានៃការមិនទុកចិត្តគ្នាក៏បានកើតមានជាថ្មីឡើងវិញ។

"មនុស្សនេះអាក្រក់ណាស់ គឺជាអតីតខ្មែរក្រហម។ គេពុំបាននិយាយអ្វីទេអស់រយៈពេលច្រើនឆ្នាំមកហើយ។ អ្វីៗបានប្រព្រឹត្តទៅយ៉ាងល្អ ប៉ុន្តែឥឡូវនេះគេនិយាយថាជននោះបានសំលាប់ជនម្នាក់ឈ្មោះប៉ាល់។ គឺគាត់ ហ្នឹងហើយ គាត់ជាមនុស្សអាក្រក់"។

(លោក បូ អាយុ ៥២ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## ៤.៤. រដ្ឋកម្ពុជា (១៩៨៩-១៩៩២)

កងទ័ពវៀតណាមបានដកចេញពីប្រទេស ប៉ុន្តែបានរក្សាទុកក្បាលម៉ាស៊ីនរដ្ឋបាលនៅនឹងកន្លែង។ កងកំលាំងរដ្ឋាភិបាលពុំសូវមានអនុភាពនៅចំពោះមុខពួកខ្មែរក្រហមដែលបានឈ្លះសមរភូមិនោះទេ។ នៅក្នុងភូមិការ រស់នៅបានប្រព្រឹត្តទៅដូចឆ្នាំមុនៗ ដែរ។ ផែនការ ក-៥ ត្រូវបានបញ្ចប់។

"នៅសម័យរដ្ឋកម្ពុជាគឺពុំសូវមានយុត្តិធម៌ច្រើនទេ។ ប្រធានភូមិមានអំណាចច្រើនណាស់ ហើយគាត់អាចធ្វើការគាបសង្កត់ទៅលើអ្នកក្រីក្រ។ ប្រធានភូមិបានជួយអ្នកទាំងឡាយណាដែលគាត់មើលឃើញថាអាចជួយគាត់វិញនៅពេលក្រោយ គាត់ពុំបានគិតគូរដល់អ្នកក្រីក្រទេ។ យើងមានអារម្មណ៍ថា គ្មានអ្នកណាការពារយើង។ យើងបានយកចិត្តទុកដាក់តែពីការមិនធ្វើឱ្យរំខានដល់អ្នកផ្សេងទៀតប៉ុណ្ណោះ"។

(លោក ពូ សង្កាត់អង្គោល ក្រុងកែប)។

ការផ្លាស់ប្តូរបានចាប់ដំណើរការបន្ទាប់ពីកងកំលាំងអង្គការសហប្រជាជាតិបានមកដល់

"នៅឆ្នាំ១៩៩៣ គឺមានការផ្លាស់ប្តូរដោយសារវត្តមានរបស់អង្គការសហប្រជាជាតិ។ ប្រជាជនបានចាប់ផ្តើមនិយាយអំពីអ្វីដែលគាត់ចង់ធ្វើ។ ប្រជាជនមានការសប្បាយចិត្ត របបសង្គមបានវិលត្រឡប់មកវិញ សន្តិភាព បានវិលត្រឡប់មកវិញ។ កងកំលាំងអន្តរជាតិបានមកជួយយើង"។

(លោក ខៅ អាយុ ៤៦ ឆ្នាំ មេភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

# សំយោគជំពូក ១: មរតកពីអតីតកាល
# ការដោះស្រាយទំនាស់មូលដ្ឋាន: ការកសាងឡើងវិញដ៏លំបាក: ១៩៧៩-១៩៩៣

*សភាពការណ៍នៅកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំមានសភាពច្របូកច្របល់ណាស់ ។ ការវិលត្រឡប់ទៅភូមិកំណើតវិញ ឬការតាំងទីលំនៅលើទឹកដីមួយថ្មីពុំមែនប្រព្រឹត្តទៅដោយគ្មានការលំបាកនោះទេ ។ សង្គមនិងក្របខ័ណ្ឌមនុស្សបានផ្លាស់ប្តូរអស់ ។ សភាពការណ៍ដីធ្លីមានលក្ខណៈអាណាធិបតេយ្យ ។ ម្ចាស់កម្មសិទ្ធិចាស់ពុំបានវិលត្រឡប់មកវិញទាំងអស់គ្នាទេ ។ ឯកសារដីធ្លីបានបាត់បង់អស់នៅក្នុងពេលមានចលាចលនោះ ។*

*ដើម្បីបង្ក្រាបសភាពការណ៍ដែលអាចបង្កឱ្យមានទំនាស់ រដ្ឋាភិបាលបានបង្កើតឱ្យមានរចនាសម្ព័ន្ធរដ្ឋបាលមួយឡើងវិញ និងបានដាក់វិធានការជាបន្ទាន់ ។ រដ្ឋាភិបាលបានសំរេចចិត្តបោះបង់គំនិតចាស់ទាំងអស់ដែលទាក់ទងទៅនឹងកម្មសិទ្ធិនិងការចែកដីធ្លីពីអតីតកាល ហើយផ្តល់អំណាចដល់អាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើការបែងចែកដីធ្លីឡើងវិញ ។ ដើម្បីបង្កើនផលិតផលកសិកម្ម ប៉ុន្តែនៅក្នុងគំនិតត្រួតពិនិត្យប្រជាជនផងដែរ ការធ្វើការងាររួមនៅក្នុងភូមិត្រូវបានបង្កើតឱ្យមានឡើង ។*

*រដ្ឋបាលថ្មីមានលក្ខណៈដូចរដ្ឋបាលកាលពីជំនាន់មុនខ្មែរក្រហមដែរ តែមានការត្រួតពិនិត្យនយោបាយទៅលើប្រជាជនយ៉ាងខ្លាំង ។*

*ប៉ុន្តែបន្តិចម្តងៗ ប្រជាជនខ្មែរបានរកឃើញបង្គោលប្រពៃណីរបស់ខ្លួនឡើងវិញ ។ ក្រោយពីបានរស់នៅក្រោមការឃោសនារបស់សង្គមនិយមអស់រយៈពេលជាច្រើនឆ្នាំមក ប្រជាជនខ្មែរបានប្រឆាំងនឹងគោលបំណងនៃការធ្វើការងាររួម ហើយបានវិលត្រឡប់ទៅរកការអនុវត្តន៏បែបបុគ្គលរៀងៗខ្លួនវិញ ។ នៅក្នុងន័យនេះ គេអាចនិយាយបានថា ប្រជាជនខ្មែរពុំបានធ្វើការផ្លាស់ប្តូរអ្វីយ៉ាងសំខាន់នោះទេ ។ ជាការពិតណាស់ ទំនាក់ទំនងរវាងប្រជាជនបានធូរស្រាលមកវិញ ក្រខ័ណ្ឌនៃរចនាសម្ព័ន្ធវប្បធម៌បានរេចរិល ប៉ុន្តែតាំងតែពីសង្គមនៅក្នុងទសវត្ស៦០ មកម្លេះ គំនិតបុគ្គលនិយមមានគេនិយមច្រើនរួចទៅហើយ ។*

*តួនាទីរបស់អាជ្ញាធរមូលដ្ឋានហាក់ដូចជាពុំបានផ្លាស់ប្តូរអ្វីជាសំខាន់ឡើយ ។ ទំនាក់ទំនងតាមឋានានុក្រមដែលមានជាប្រពៃណីមកនោះ ត្រូវបានរក្សាទុកដដែលតាមរូបភាពខុសៗគ្នា និងបែបជ្រុលហួសនៅក្នុងរយៈពេលដែលមានរបបគ្រប់គ្រងខុសៗគ្នា ។*

*ចាប់តាំងពីពេលដែលគេបានប្រគល់អំណាចឱ្យមក អាជ្ញាធរបានប្រើប្រាស់អំណាចនិងរំលោភអំណាច ដូចនៅក្នុងពេលដែលពួកមន្ត្រីគ្រប់គ្រងមុនដែរ ។ អ្នកខ្សោយពុំអាចពឹងផ្អែកលើសាមគ្គីភាពពីអ្នកផ្សេងទៀត*

ឡើយ និងបានដោះស្រាយបញ្ហា ដោយពឹងផ្អែកទៅលើកំលាំងរបស់ខ្លួនផ្ទាល់ ។ ការសំឡុតនិងការបង្ខិតបង្ខំបានធ្លាក់មកលើអ្នកពុំសូវមានអ្នកការពារដែលចូលចិត្តបំបិទបញ្ហារបស់ខ្លួន ។ ជនទាំងឡាយណាដែលឋិតនៅក្នុងបណ្តាញ នៃអំណាចបានពឹងផ្អែកបក្ខពួករបស់ខ្លួនដើម្បីសំរបសំរួលបញ្ហាឱ្យបានប្រសើរឡើង ។

គេសង្កេតឃើញថា សារៈសំខាន់នៃទំនាស់មានទាក់ទងទៅនឹងការការពារមធ្យោបាយផ្គត់ផ្គង់គ្រួសារ (ដីចំការដំណាំ) និងកិត្តិយសដែលត្រូវគេប្រមាថ ហើយដែលអាចបណ្តាលឱ្យមានការផាត់ចេញពីសង្គម (ជំលោះ ការជេរ) ។ អ្វីៗទាំងអស់ដែលនៅក្រៅគ្រួសារ និងក្រៅទឹកដីរបស់ខ្លួនមិនសូវសំខាន់សំរាប់កសិករដូចជាអ្នករស់នៅទីក្រុងទេ ។ មនុស្សម្នាក់ៗបានការពារទីតាំងរបស់ខ្លួន ។

នៅក្រោយសម័យខ្មែរក្រហម អាជ្ញាធរមូលដ្ឋានត្រូវបានបង្កើតឱ្យមានឡើងវិញ និងមានតួនាទីជាអ្នកសំរុះសំរួលនៅពេលមានទំនាស់មូលដ្ឋាន ។ ការអនុវត្តន៏បានវិវឌ្ឍន៏បន្តិចម្តងៗ ។ គេបានសង្កេតឃើញថាការ អនុវត្តន៏មានលក្ខណៈជាស្ថាប័នច្រើន ហើយពុំសូវពឹងផ្អែកទៅលើចាស់ទុំនៅក្នុងភូមិទេ ។

នៅក្នុងសម័យនោះ ការអនុវត្តន៏ដំណោះស្រាយនិងការទប់ស្កាត់ទំនាស់ក៏អាស្រ័យទៅលើបុគ្គលិកលក្ខណៈនិងក៏រិតវប្បធម៌របស់ប្រធានភូមិនិងប្រធានឃុំដែរ ។ គេបានសង្កេតឃើញថា មានការបញ្ចូលការឃោសនានយោបាយ និងចំណេះដឹងផ្អែកច្បាប់តិចតួចខ្លះៗប៉ុណ្ណោះ ។

ជំពូក ២

# ការដោះស្រាយជម្លោះនៅថ្នាក់មូលដ្ឋាន

ស្ថានការណ៍បច្ចុប្បន្ន

# ១៩៩៣-២០០១
# ការរៀបចំឱ្យមានសន្តិភាព និងការបើកចំហទៅកាន់ពិភពលោកខាងក្រៅ

ឆ្នាំ១៩៩៣ កត់សំគាល់នូវពេលប្រែប្រួលថ្មី។ បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាព ដែលចុះហត្ថលេខាក្នុងខែតុលា១៩៩១ នៅទីក្រុងប៉ារីសរវាងភាគីជម្លោះបួន[១៣០] គេបានសំរេចថា ត្រូវមានអាជ្ញាធរអន្តរកាលមួយនៅប្រទេសកម្ពុជាក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិដែលគេហៅថា អ៊ុនតាក់[១៣១]។ អាជ្ញាធរនេះមានគោលដៅចំបងរៀបចំការបោះឆ្នោតដោយសេរី ដោយមានការបង្កើតគណបក្សនយោបាយ ការដកអាវុធពីភាគីទាំងអស់ ការធ្វើមាតុភូមិនិវត្តជនភៀសខ្លួន២៥០០០០នាក់ ពីជំរុំនៅប្រទេសថៃ ព្រមទាំងការផ្សព្វផ្សាយគោលការណ៍សិទ្ធិមនុស្ស។

មុនការបោះឆ្នោតបន្តិច ខ្មែរក្រហមដកខ្លួនចេញពីដំណើរការសន្តិភាព។ ពួកខ្មែរក្រហមចាប់កាន់អាវុធឡើងវិញ ព្រមទាំងត្រួតត្រាទឹកដីទូលំទូលាយនៅភាគខាងជើង និងខាងលិចប្រទេស។ ទោះជាយ៉ាងណាក្តី ការបោះឆ្នោតនៅតែប្រព្រឹត្តទៅនៅក្នុងផ្នែកដទៃទៀតនៃប្រទេស ហើយប្រទេសកម្ពុជាបានបើកទ្វារសន្យាដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសន្តិភាព។

អ៊ុនតាក់បើកទ្វារចំហយ៉ាងទូលំទូលាយដល់ជំនួយបរទេស។ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចាប់ធ្វើការលើវិស័យផ្សេងៗដូចជា ការអភិវឌ្ឍន៍ជនបទ សុខភាព ការអប់រំ សិទ្ធិមនុស្ស ការដោះមីន ។ល។

បន្ទាប់មក ក្នុងកម្លុងទសវត្សឆ្នាំ១៩៩០ សន្តិភាពបានរីកចំរើន ហើយតំបន់ដែលត្រួតត្រាដោយខ្មែរក្រហមក៏រួមថយចុះ បន្ទាប់ពីការចុះចាញ់របស់ពួកមេខ្មែរក្រហម។ ក្នុងឆ្នាំ១៩៩៩ ដោយសារមរណៈភាពនៃ ប៉ុល ពត និង ការចាប់ខ្លួនមេចុងក្រោយរបស់ខ្មែរក្រហម គឺតាម៉ុក រដ្ឋាភិបាលកម្ពុជានៅទីបញ្ចប់បានកាន់កាប់ទឹកដីទាំងអស់។ ក្នុងនាមនៃការផ្សះផ្សាជាតិ ខ្មែរជាសត្រូវគ្នាពីមុន ក៏បានរៀនរស់ជាមួយគ្នាឡើងវិញនៅថ្ងៃនេះ។

---

[130] ខ្មែរក្រហម កងកម្លាំងរាជានិយមរបស់ព្រះអង្គម្ចាស់រណឫទ្ធិ ហ៊ុនសុិនប៉ិច និងកងកម្លាំងជាតិនិយមរបស់ សឺន សាន រ.ជ.រ.ប.ខ ជាសម្ព័ន្ធមិត្តនឹងគ្នាប្រឆាំង រដ្ឋាភិបាលរដ្ឋកម្ពុជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ។

[131] អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា។

ការជួបប្រទះនឹងតម្លៃផ្សេងៗមកពីពិភពលោកខាងក្រៅដូចជា គោលការណ៍សិទ្ធិមនុស្សដែលនាំមកដោយអង្គការក្រៅរដ្ឋាភិបាល ការរីកដុះដាលនៃគណបក្សនយោបាយ ការតាំងឱ្យមានសន្តិភាព និងការចាប់ផ្តើមអភិវឌ្ឍន៍ សេដ្ឋកិច្ច ទាំងអស់នេះនឹងមានអនុភាពលើការអនុវត្តការគ្រប់គ្រង និងការបង្កាជម្លោះ។

នៅក្នុងតំបន់ទីក្រុង និងជុំវិញទីក្រុង អាជ្ញាធរមូលដ្ឋានបាត់បង់អំណាចរបស់ខ្លួនមួយភាគ ហើយបន្ធូរបន្ថយការគាបសង្កត់លើប្រជាជន។ បណ្តាញអំណាចស្របក៏កើតឡើង ដោយពឹងផ្អែកលើគណបក្សនយោបាយប្រឆាំង ហើយមួយចំណែកលើអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល។ គោលការណ៍សិទ្ធិមនុស្សដែលផ្សព្វផ្សាយជាចំបងតាមវិទ្យុ ត្រូវបានទទួលដោយប្រជាជនទោះបីជាគេបានយល់ច្រើន ឬតិចយ៉ាងណាក្តី។ ទោះជាយ៉ាងណាក្តី ទោះបីហាក់ដូចជាមានការផ្លាស់ប្តូរក្តី គេនៅតែសង្កេតឃើញថា ឫសគល់វប្បធម៌ចាស់នៅតែដោតជាប់ជានិច្ច(ឯកត្តនិយម ឋានានុក្រម បិតុនិយម ក្រុមពួក)។

# I, ជម្លោះ

ជម្លោះដែលបានរកឃើញក្នុងរយៈពេលធ្វើការអង្កេត ស្ទើរតែដូចគ្នាទាំងអស់នៅទីកន្លែងដែលយើងបានធ្វើការសន្ទនា គឺជម្លោះដីធ្លី ការឈ្លោះប្តីប្រពន្ធ និងការឈ្លោះជាមួយអ្នកជិតខាង។ ជម្លោះខ្លះមានលក្ខណៈពិសេសសំរាប់តំបន់ណាមួយ ដូចជានៅភាគខាងជើងនៃប្រទេសដែលមានកងកម្លាំងយោធាកំពុងរំសាយជម្លោះមានចំនួនច្រើនទាក់ទងនឹងការដកហូតដីអ្នកស្រែចំការ ជម្លោះពីដែននេសាទនៅទន្លេសាបរវាងអ្នកនេសាទតូចតាច និងម្ចាស់ឡូត៍នេសាទ។ល។ ករណីទាំងនេះដែលគួរឱ្យចាប់អារម្មណ៍ជាពិសេស និងដែលកើតឡើងក្នុងពេលបច្ចុប្បន្នមិនអាចសិក្សាបានទេបើគ្មានពេលគ្រប់គ្រាន់។

## ១, ជម្លោះដីធ្លី

ជម្លោះសំខាន់បំផុតនោះ គឺជម្លោះទាក់ទងនឹងរឿងដីធ្លី។ ដូចដែលយើងបានពិពណ៌នាខាងមុខនេះរួចហើយស្ថានភាពដីធ្លីមានលក្ខណៈស្មុគ្រស្មាញជាពិសេស បន្ទាប់ពីយុគសម័យខ្មៅងងឹតនៃរបបខ្មែរក្រហម។ នៅឆ្នាំ១៩៧៩ ការចែកដីធ្លីដល់គ្រួសារទាំងឡាយ បានអនុញ្ញាតជាលើកដំបូងឱ្យក្របខ័ណ្ឌរាជការចូលក្នុងស្ថានភាពអនាធិបតេយ្យ។ នៅពេលនោះ ព្រំដែនដីនិងកម្មសិទ្ធិនៅមិនជាក់លាក់។ ការប្តឹងផ្តល់គ្នាមានច្រើនសន្ធឹកសន្ធាប់ ហើយមធ្យោបាយដោះស្រាយមានស្តួចស្តើង។ ច្បាប់ជាប្រពៃណីមិនរឹងមាំ ហើយច្បាប់ថ្មីស្តីពីដីធ្លីអ្នកស្រុកក៏មិនទាន់ស្គាល់ ហើយក៏មិនទាន់អនុវត្ត[១៣២]។ ជាងនេះទៀត ដោយសារការរីកដាលខាងផ្នែកប្រជាសាស្ត្រ អ្នកស្រែធម្មតាដែលចង់រស់នៅលើទីដីគ្រួសារមួយឱ្យដាច់ចេញពីអ្នកជិតខាងនោះជារឿយៗមិនអាចធ្វើបានទេ។ ចំនួនការប៉ះទង្គិចជាមួយអ្នកជិតខាង និងការប៉ះទង្គិចដោយសារព្រំដែនដីមានកាន់តែច្រើនឡើង។

### ១,១, ជម្លោះដីធ្លីនៅស្រុកស្រែ

នៅក្នុងភូមិថ្មីៗ[១៣៣] ឬភូមិចាស់ដែលមានប្រជាជនមួយចំនួនមកពីខេត្តផ្សេងៗ ស្ថានភាពដីធ្លីនៅទីនោះមិនមានលក្ខណៈស្ថិតស្ថេរទេ។ ប្រជាជនទាំងនោះ មិនជាតាំងចិត្តនៅជាប់លាប់ក្នុងភូមិទាំងនេះទេ ហេតុដូច្នេះការដោះដូរដីធ្លី គឺជារឿងសំខាន់នៅទីនោះ ដូចជាមានការលក់ ការជួល ការឱ្យខ្ចីជាបណ្តោះអាសន្នជាដើម។ ស្ថានការណ៍រឹតតែស្មុគ្រស្មាញថែមទៀត ដោយសារបែបបទ និងប័ណ្ណកម្មសិទ្ធិមានមិនគ្រប់គ្រាន់នៅកន្លែងខ្លះ អាជ្ញាធរដែលចាត់ចែងចែកដីធ្លីក៏មានសិទ្ធិកំណត់ព្រំដែនដីជាថ្មី ព្រមទាំងការចាត់ចែងចែកដីជាថ្មីដែរ។ បញ្ហាក៏កើតមានដូចគ្នា ចំពោះជនដែលមកដល់ក្រោយពេលការបែងចែកដីជាផ្លូវការរួចមក។

---

132 ច្បាប់១៩៨៩ ឆ្នាំ១៩៩៤ និងច្បាប់ដែលទើបអនុម័តក្នុងឆ្នាំ២០០១

133 ភូមិដែលទើបបង្កបង្កើតថ្មី ដើម្បីទទួលប្រជាជនស្ថិតក្នុងសភាពមិនឋិតស្ថេរ ពួកអ្នកមាតុភូមិនិវត្តន៍មកពីជំរុំភៀសខ្លួនក្នុងឆ្នាំ១៩៩៣ ពួកអ្នកផ្លាស់ទីកន្លែង ក្នុងរយៈពេលមានជម្លោះអាវុធ អតីតខ្មែរក្រហមចុះចូល អ្នកក្រគ្មានដីធ្លី ឬមនុស្សដែលរត់គេចបញ្ហានៅក្នុងភូមិកំណើតរបស់ខ្លួន។

ជនទាំងនោះចរចាជាមួយម្ចាស់ដី ដើម្បីសុំតាំងទីជាបណ្ដោះអាសន្ននៅលើដីមួយ ហើយបន្ទាប់មកក៏ទាមទារដីដែលតាំងទីនោះ ដោយសំអាងលើច្បាប់ ប្រពៃណីដែលទទួលស្គាល់កម្មសិទ្ធិរបស់អ្នកប្រើប្រាស់ដី។

ស្ថានភាពនៃភូមិបូរាណដែលប្រជាជនបានរស់នៅជាប់លាប់រហូតមក គឺមានលក្ខណៈផ្សេងទៅវិញ។ អ្នកភូមិខ្លះក្នុងបណ្ដាអ្នកភូមិទាំងអស់នោះមិនខ្វល់នឹងការបែងចែកទេ ហើយបានចាប់យកដីទៅតាមព្រំដែនដីដែលមានតាំងពីបុព្វជនរបស់គេ។ ជម្លោះដែលពាក់ព័ន្ធក្នុងស្ថានភាពបែបនេះ គឺព្រំដែនដីដែលប្របេះប្របោចដោយអ្នកជិតខាង បញ្ហាបង្ហូរទឹកនៅរដូវភ្លៀង និងការទាមទារមរតក។

ទាក់ទងនឹងការកាន់កាប់ និងការដោះដូរដីក្រោយពីឆ្នាំ១៩៧៩នោះ ការច្របូកច្របល់ក្លាយទៅជារឿងធម្មតាទៅហើយ។ ជាទូទៅ ប្រធានភូមិ និងប្រធានឃុំ ជារឿយៗគ្មានអំណាចនឹងដោះស្រាយជម្លោះដីធ្លីទេ។ គាត់ច្របូកច្របល់ វិធានជាប្រពៃណីដែលទទួលស្គាល់សិទ្ធិលើដីធ្លីដូនតា ឬទម្រង់មួយនៃកម្មសិទ្ធិ (ផលុបភោគ) នៃអ្នកដែលកាន់កាប់ ឬប្រើប្រាស់ដីជាមួយនឹងច្បាប់សរសេររបស់រដ្ឋដែលទទួលស្គាល់តែកម្មសិទ្ធិរបស់អ្នកប្រើប្រាស់ដី ក្រោយឆ្នាំ១៩៧៩ ព្រមទាំងអ្នកដែលទទួលដីដែលចែកឱ្យដោយអាជ្ញាធរ។

នៅថ្នាក់មូលដ្ឋាន គេសង្កេតឃើញថា ច្បាប់សរសេរមិនសូវមានអ្នកណាដឹងប៉ុន្មានទេ ហើយក៏មិនសូវបានអនុវត្តទេ។ គេពឹងផ្អែកដោយរីករាយលើការព្រមព្រៀងគ្នាជាមិត្តភាព ឬ ក៏យករឿងទៅឱ្យប្រធានមូលដ្ឋានជាអ្នកដោះស្រាយឱ្យទៅតាមឆន្ទៈរបស់គាត់។

នៅភូមិចាស់មួយ បុរសម្នាក់រំលឹកអំពីបញ្ហាដីធ្លីនិងកំណើនប្រជាសាស្ត្រ។

> "បញ្ហាដែលសំខាន់ជាងគេគឺបញ្ហាដីធ្លី។ មានជម្លោះអំពីព្រំដែនដី។ បុរសម្នាក់រៀបចំស្រែរបស់គាត់ហើយរំកិលភ្លឺទៅលើស្រែរបស់អ្នកជិតខាង។ បើគាត់ធ្វើដូច្នេះបន្តិចម្ដងៗ អ្នកជិតខាងប្រហែលជាមិនហ៊ានតវ៉ាទេ។ ប៉ុន្តែ បើគាត់ធ្វើច្បាស់ក្រឡែតពេក បើគេឃើញថាភ្លឺវៀច អ្នកជិតខាងក៏ខឹង។ មានបញ្ហាមួយនៃអ្នកដែលដាំដុះលើដីដែលមានម្ចាស់ ប៉ុន្តែដីនោះមិនបានប្រើប្រាស់យូរលង់ណាស់មកហើយ។ បុរសនោះសុំការអនុញ្ញាតពីម្ចាស់ដើម ដើម្បីដាំដុះលើដីនោះ ហើយសុខចិត្តឱ្យភាគផលខ្លះនៃដំណាំជាថ្នូរនឹងការប្រើប្រាស់ដី។ បើគាត់ប្រើប្រាស់ដីនោះយូរ ទៅគាត់ចាត់ថាដីនោះជារបស់គាត់ ហើយគាត់មិនចង់ប្រគល់ដីនោះទៅឱ្យម្ចាស់ដើមវិញទេ នៅពេលម្ចាស់នោះសុំមកវិញ។ គេឃើញដូចគ្នា ចំពោះករណីផ្សេងៗដែលអ្នកប្រើប្រាស់ថ្មីលក់ដីនោះបន្ត។ ដូច្នេះម្ចាស់ដីដើម និងម្ចាស់ថ្មីត្រូវមានជម្លោះនឹងគ្នា។ ទោះធ្វើយ៉ាងណាក៏នៅតែមានបញ្ហាជានិច្ច។ បើម្ចាស់ដើមមិនព្រមឱ្យដីគេខ្ចីទេនោះ វានឹងមានគំនុំ។ ឥឡូវនេះពិបាកណាស់ ព្រោះថាមានមនុស្សច្រើន ហើយដីល្អមានតិច។ គេមិនអាចកាប់ ឆ្ការដីនៅជុំវិញភូមិបានទៀតទេ ព្រោះគេហាម

ឃាត់។ គេហាមមិនឱ្យកាប់ឈើនិងឆ្ការព្រៃដាំដំណាំ។ គ្រួសារមានដីតូចៗដែលត្រូវចែកឱ្យកូនទៀត"។ (លោក ឈួន អាយុ ៥៧ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

នៅភូមិថ្មីមួយ ប្រធានភូមិចាត់ការបែងចែកដីធ្លីជាថ្មី

"គេឱ្យដីយើងបានទំហំ៣០ម៉ែត្រទទឹង ៥០០ម៉ែត្របណ្តោយ។ យើងកាប់ឆ្ការដីបានមួយផ្នែក។ ឥឡូវនេះប្រធានមូលដ្ឋានចង់ឱ្យដីយើងមួយផ្នែកទៅឱ្យអ្នកដែលមកដល់ថ្មី។ គាត់ចង់លក់ដីមួយផ្នែករបស់យើងដែលជាដីដែលគាត់ចែកឱ្យដោយដៃគាត់។ គ្មានអ្នកណាយល់ព្រមទេ ប៉ុន្តែយើងខ្លាចគាត់។

(អ្នកស្រីសុវណ្ណ អាយុ៣២ ឆ្នាំ ឃុំ ត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត"ភូមិថ្មី")

## ១.២. ជម្លោះទាក់ទងនឹងការសាងសង់នៅទីក្រុង

នៅភ្នំពេញ បញ្ហាទាក់ទងនឹងការសាងសង់ត្រូវបានពិពណ៌នាថា ជាមូលហេតុចំបងនៃការធ្វើបណ្តឹងទៅការិយាល័យសង្កាត់។ ក្នុងចំណោមម្ចាស់ដើមដែលបានចាកចោលទីក្រុងក្នុងឆ្នាំ ១៩៧៥ នៅពេលរបបខ្មែរក្រហម ឡើងកាន់អំណាចនោះ ម្ចាស់ជាច្រើនត្រូវស្លាប់ ឬចាកចេញទៅរស់នៅបរទេស។ នៅឆ្នាំ១៩៧៩ ផ្ទះដែលបោះបង់ចោលក្នុងរយៈពេលជិត៤ឆ្នាំ ត្រូវបានចុះទុនកែកុនឡើងវិញដោយប្រជាជនដែលភាគច្រើនមានដើមកំណើតមកពីស្រុកស្រែ។ ច្បាប់ដែលបដិសេធការទាមទារឱ្យការទទួលស្គាល់កម្មសិទ្ធិមុនឆ្នាំ១៩៧៥ ទទួលស្គាល់សិទ្ធិកម្មសិទ្ធិនៃអ្នកដែលកាន់កាប់ទីកន្លែងក្រោយឆ្នាំ១៩៧៩។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលបាក់ស្រុតខ្លាំងពេកនោះត្រូវបានស្តាឡើងវិញបន្តិចម្តងៗ។ ប្រឈមមុខនឹងការគ្មានសេវាកម្មទីក្រុង ដូច្នេះអ្នកស្រុកថ្មីនៃទីក្រុងភ្នំពេញចាប់ប្រកាន់យកអាកប្បកិរិយាអ្នកជនបទដែលស្តែងចេញជាការចង់បានឯករាជ្យភាពពីអ្នកជិតខាង។ រឿងនេះមិនមែនប្រព្រឹត្តទៅដោយមិនបង្កបញ្ហានោះទេ។ នៅក្នុងផ្ទះល្វែងចាស់ជាសមូហភាពមួយ អ្នករស់នៅម្នាក់សង់ប្រព័ន្ធបង្ហូរទឹកផ្ទាល់ខ្លួន ហើយជួនកាលសង់ជណ្តើរផ្ទាល់ខ្លួន។

ដោយសារមានកំណើនប្រជារាស្ត្រ និងការឡើងថ្លៃដីនិងផ្ទះល្វែងនៅភ្នំពេញ អ្នករស់នៅទីនោះជារឿយៗត្រូវពង្រីកកន្លែងរស់នៅរបស់ខ្លួន ទោះបីជាត្រូវទន្ទ្រានលើកន្លែងសាធារណៈ ឬលើកន្លែងអ្នកជិតខាងក្តី។

"នៅភ្នំពេញ តែងតែមានបញ្ហាទាក់ទងនឹងការសាងសង់ជានិច្ច ឧទាហរណ៍ដូចជា មានដំបូលថ្មីមួយសង់លូតលើដីអ្នកជិតខាងជាដើម។ នៅរដូវភ្លៀង ទឹកហូរចូលដីអ្នកជិតខាង។ មានផ្ទះខ្លះដែលម្ចាស់នៅជាន់ទីមួយៗ សង់ជណ្តើរឯកជនហើយហាមមិនឱ្យអ្នកដទៃទៀតប្រើ។ នៅផ្ទះល្វែង

អ្នកនៅជាន់លើបោសសំរាមទម្លាក់តាម ជណ្តើររួម ហើយអ្នកនៅជាន់ក្រោមទទួលសំរាមធ្លាក់លើក្បាលខ្លួន។ ពួកគេមិនសប្បាយចិត្តទេ។ មានបញ្ហារឿងទឹកស្អុយ។ កាលណាបំពង់បង្ហូរទឹកស្ទះឬបំពង់ខាងក្រោមបាក់បែក អ្នកនៅជាន់លើមិនចង់ចេញថ្លៃជួសជុលទេ។ ព្រោះបញ្ហានេះមិនរំខានដល់ខ្លួនដោយផ្ទាល់ទេ។ គេនៅតែចាក់ទឹកកខ្វក់ ជាហេតុធ្វើអោយទឹកនោះលិចលើអ្នកជិតខាង។ ដូចគ្នាដែរ កាលណាអ្នកនៅជាន់លើស្រោចផ្កានៅរានហាលរបស់ខ្លួន អ្នកនៅជាន់ខាងក្រោមរអ៊ូរទាំ។ គាត់ទៅរកចៅសង្កាត់។ ចៅសង្កាត់កោះហៅអ្នកដែលបានបង្កើតបញ្ហា។ ចៅសង្កាត់សួររករឿងហេតុពីអ្នកមានកំហុស ហើយឱ្យគាត់ហត្ថលេខាលើលិខិតមួយ ដើម្បីសន្យាថាឈប់ធ្វើកំហុសនេះតទៅទៀត។ បើជម្លោះនៅតែបន្ត ចៅសង្កាត់អាចសុំឱ្យនគរបាលសង្កាត់ធ្វើអន្តរាគមដូចជាទៅរានហាល ហើយរឹបអូសយកផ្កាចេញ។ បើម្ចាស់ផ្កាមិនព្រមគាត់អាចធ្វើបណ្តឹងទៅខ័ណ្ឌ។ ដើម្បីដាក់ពាក្យបណ្តឹងបាន គាត់ត្រូវបង់ថ្លៃពី១៥០០០រៀល ទៅ២០០០ រៀល។ អ្នកក្រជាងគេនោះ មិនអាចដាក់ពាក្យប្តឹងបានទេ។ បើគេមិនធ្វើបណ្តឹងស្របតាមនីតិវិធីទេនោះ ហើយបើ សិនគេមិនអាចបង់ថ្លៃទេនោះ បញ្ហារបស់គាត់គ្មានអ្នកណាពិចារណាឱ្យទេ"។

(លោក ឡេង អាយុ ៣១ឆ្នាំ នគរបាលភ្នំពេញ)

"បញ្ហាដែលកើតមានញឹកញាប់ជាងគេ គឺទាក់ទងនឹងសំណង់ថ្មីៗ។ មានករណីមួយឬពីរ ក្នុងមួយខែៗ។ នៅឆ្នាំ១៩៧៩ មនុស្សទាំងឡាយបានកាន់កាប់ផ្ទះដែលគេរកបាន។ រហូតមកដល់ឆ្នាំ១៩៩៣ គ្រួសារជាច្រើនបែងចែកផ្ទះ ឬផ្ទះល្វែង ដែលនៅជារួមគ្នា។ បន្ទាប់មក មានការអភិវឌ្ឍន៍សេដ្ឋកិច្ច។ គេចង់បានកម្មសិទ្ធិឯកជនម្នាក់ៗ ហើយបានចាប់ផ្តើមសាងសង់នៅគ្រប់ទីកន្លែងគ្មានសល់ ដូចជាលើដី នៅកន្លែងចន្លោះមាត់ជណ្តើរ លើរានហាល លើដំបូល។ បច្ចុប្បន្ននេះ មានបញ្ហាជាច្រើនក្នុងការរស់នៅជិតខាងគ្នា។ ឧទាហរណ៍ សំណង់ថ្មីបិទផ្លូវខ្យល់ និងពន្លឺចូលក្នុងល្វែងមួយ ហើយមនុស្សជាច្រើនត្អូញត្អែរពីរឿងនេះ។ គេសង់ជាន់លើ ហើយបញ្ចប់បំពង់បង្ហូរទឹកត្រឹមជាន់របស់ខ្លួន។ អ្នកនៅខាងក្រោមមិនសប្បាយចិត្ត។ មានបញ្ហាក្មេងនៅជាន់លើបោះសំរាមមកក្រោមដែរ"។

(លោក ឡែម អាយុ៥០ឆ្នាំ ប្រធានសង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ភ្នំពេញ)

## ២, ជម្លោះប្តីប្រពន្ធ

ការឈ្លោះប្រកែកប្តីប្រពន្ធត្រូវបានពិពណ៌នា ដោយអាជ្ញាធរមូលដ្ឋានថា ជាប្រភេទទី២នៃជម្លោះ។ ការឈ្លោះប្រកែកនេះ ជាញឹកញាប់នាំឱ្យមានអំពើហិង្សាក្នុងគ្រួសារ។ គេបានលើកឡើង ហេតុផលច្រើនយ៉ាង គឺ ភាពក្រីក្រ ការគ្មានមុខរបរ ការលែងល្បែងស៊ីសង ការប្រច័ណ្ឌ ការស្រើបស្រាលចង់បានសំភារៈមក

បំពេញបំណងរបស់ខ្លួន ការជ្រើតជ្រែកពីសំណាក់ឪពុកម្តាយ ការរៀបការដោយម្តាយឪពុកទុកដាក់។ ការលែងលះត្រូវបានរិត ត្បិតដោយប្រពៃណី ប៉ុន្តែអាចធ្វើទៅបានដោយងាយ បើមិនមានការយល់ព្រមគ្នាទៅវិញទៅមក។ ប៉ុន្តែការ លែងលះមានការពិបាក បើការសុំលែងលះធ្វើឡើងដោយសហព័ទ្ធតែម្ខាង។

## ២.១. ហេតុផលដែលលើកឡើង

"មានករណីជាច្រើនទាក់ទងនឹងការឈ្លោះប្រកែកគ្នាក្នុងគ្រួសារ។ ប្តីដើរលែងច្រើនពេក។ គាត់ផឹកស្រាហើយត្រឡប់មកផ្ទះវិញ។ ប្រពន្ធក៏ឈ្លោះប្រកែក។ ការឈ្លោះប្រកែក ក៏កាន់តែធ្ងន់ធ្ងរឡើង ហើយបុរសក៏វាយប្រពន្ធ។ ប្តីមានស្រីញី ហើយគាត់ចង់ឱ្យប្រពន្ធដើរចេញនឹងអាលគាត់បានរៀបការជាមួយស្រីថ្មីមួយទៀត។ ដូច្នេះ ប្តីក៏ក្លាយទៅជាមនុស្សកាចជាមួយប្រពន្ធ ដើម្បីធ្វើឱ្យប្រពន្ធដើរចេញ។ ការប្រច័ណ្ឌពីខាងប្រុសក៏មាន ពីខាងស្រីក៏មាន។ គេចោទគ្នាថា មានសហាយ។ មានករណីជាច្រើនដែលគ្រួសារធំមួយរស់នៅក្នុងផ្ទះល្វែងតូចមួយ ហើយដោយសារតែការរស់នៅប្រជ្រៀតគ្នា គ្រួសារនោះក៏ឈ្លោះគ្នា។"

(អ្នកស្រីសំបូរ អាយុ៥១ ឆ្នាំ ប្រធានសង្កាត់ផ្សារថ្មី១ ខ័ណ្ឌដូនពេញ ភ្នំពេញ)

### ការស៊ីផឹក និង ល្បែងស៊ីសង

"អំពើហិង្សាក្នុងគ្រួសារភាគច្រើនទាក់ទងទៅនឹងការផឹកស្រា និងការលេងបៀ ដែលជាការធ្វើឱ្យខាតបង់ប្រាក់ ប៉ុន្តែក៏មានការប្រច័ណ្ឌ ការមានស្រី និងការលែងចង់នៅជាមួយប្រពន្ធផងដែរ"។

(លោក ស៊ីថូ អ្នកស៊ើបអង្កេតនៃអង្គការសិទ្ធិមនុស្សមួយ អាយុ៣៣ឆ្នាំ ក្រុងកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

### ការខ្វះខាតប្រាក់ និងការស្រម័យចង់បានកិត្តិនាមក្នុងសង្គម

នៅក្នុងប្រទេសដែលខ្ទេចខ្ទាំមួយ ដែលមនុស្សម្នាក់ៗដឹងតែពីពឹងផ្អែកលើការប្រើកម្លាំងផ្ទាល់ខ្លួន ចង់បានប្រាក់ដើម្បីយកមកសំដែងឱ្យឃើញ កត្តាទាំងអស់នេះនៅតែជាឧបករណ៍បឋមសំរាប់ការគង់វង់ជីវិត។ ប្រាក់អាច ឱ្យគេការពារទល់នឹងជោគវាសនាអាក្រក់ដូចជា ជម្ងឺ ផលដំណាំខូចខាត បញ្ហាយុត្តិធម៌។ល។ និងបង្កាបានខ្លះទល់ នឹងជម្លោះជាមួយមនុស្សដទៃទៀត។ ដូច្នេះ ក្នុងសង្គមនោះ ដែលទំនាក់ទំនងឋានានុក្រម និងឯកត្តនិយមជារឿងសំខាន់ ប្រការដែលមនុស្សម្នាក់តាំងខ្លួនឯងជាបងូន ឬជារៀមច្បងធៀបទៅនឹងមនុស្សម្នាក់ទៀតនោះ គឺជាកត្តាកំណត់ដែលគេតែងតែប្រើពេលណាមានបញ្ហារវាងមនុស្សពីរនាក់។ ឧទាហរណ៍ យើងរកឃើញរឿងមួយ នៅពេលមានគ្រោះថ្នាក់ចរាចរមួយនៅក្នុងក្រុង (មនុស្សទាំងអស់នោះ មិនស្គាល់គ្នាទេ) ភាគីទាំងពីរ ស្វែងមើលគ្នាទៅវិញទៅមកដើម្បីឱ្យដឹងថា អ្នកណាដែលត្រូវមានប្រៀបលើគេនៅពេលជជែកគ្នា ហើយអ្នកណាត្រូវចុះញ៉មអ្នកណា។ ការបង្ហាញពីសញ្ញាខាងក្រៅថាខ្លួនជាអ្នកមាន គឺជាការមានខែលដើម្បីការពារទល់នឹងការតបតរបស់មនុស្សដែល ខ្លួនគិតថា តូចទាបជាង

ខ្លួន។ ដូច្នេះ ជាការសំខាន់ដែលត្រូវមានប្រាក់ និងដែលអាចសំដែងឱ្យគេឃើញថាមានប្រាក់។ ចំណុចទីពីរនេះត្រូវបានគេរកឃើញ ជាពិសេសសំរាប់ជីវភាពក្នុងក្រុង។

## ភាពក្រីក្រ

"ប្រុស១ ដែលគ្មានការងារធ្វើ ហើយគ្មានប្រាក់ត្រូវនៅផ្ទះ។ គេគ្មានធ្វើអ្វីទាំងអស់។ មិត្តភ័ក្ត្រមករក ហើយបបួលទៅផឹក។ គេផឹកសប្បាយ។ ពេលចូលផ្ទះវិញប្រពន្ធខឹងហើយប្តីឆ្លើយតបដោយនិយាយខ្លាំង១ ឬ វាយដំ។ ប្រពន្ធមិនសប្បាយចិត្តទេ ពីព្រោះគ្មានអ្វីទទួលទាននៅផ្ទះហើយប្តីចាយលុយដើម្បីផឹកស៊ី"។

(លោក កាក់ អាយុ៥២ ឆ្នាំ សង្កាត់ពងទឹកក្រុងកែបខេត្តកំពត)

"ក្នុងករណីភាគច្រើន គឺប្រពន្ធដែលធ្វើបណ្តឹងមុន។ គាត់និយាយថា ប្តីគាត់ដើរលេងច្រើនពេក មិនយកចិត្តទុកដាក់នឹងគាត់ទេ មិនធ្វើការ មិនរកប្រាក់ គិតតែពីផឹក។ ប្រពន្ធរអ៊ូរទាំជាញឹកញាប់ ដោយសារគ្មានប្រាក់។ គាត់ចង់ឱ្យប្តីរកប្រាក់ចូលផ្ទះ។ ជួនកាល គឺឪពុកម្តាយក្មេកដែលមកប្តឹងជំនួសកូនរបស់គាត់"។

(លោក ឆុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

"ការឈ្លោះប្រកែកគ្នារវាងមនុស្សទាំងឡាយ និងរវាងប្តីប្រពន្ធជារឿយ១ទាក់ទងនឹងលក្ខខ័ណ្ឌសេដ្ឋកិច្ចដុនដាប។ បុរសគ្មានការធ្វើ ហើយគាត់គិតតែពីផឹក។ គាត់គិតតែចាយ។ កាលណាគាត់វិលមកផ្ទះវិញ ប្រពន្ធគាត់ មិនសប្បាយចិត្ត ហើយស្តីបន្ទោសប្តី។ ប្រពន្ធនិយាយថា គាត់មិនអាចចិញ្ចឹមកូនដោយគ្មានប្រាក់ទេ។ ប្តីចង់ទប់កុំឱ្យមានការឈ្លោះប្រកែក ហើយគាត់ក៏វាយប្រពន្ធ។ រឿងនេះមានជាធម្មតាទៅហើយ។ សិទ្ធិនារី គឺជាសិទ្ធិរបស់អ្នកទន់ខ្សោយ។ ប្រុស១មកប្តឹងញឹកញាប់ដូចស្ត្រីដែរ។ គេនិយាយថា គេចង់លែងលះប្រពន្ធ ព្រោះ"ប្រពន្ធជាស្រីមិន ល្អ"ប្រពន្ធចាយប្រាក់អស់" ប្រពន្ធមិនចេះគិតគូរ ហើយធ្វើឱ្យខាតបង់ប្រាក់អស់"។ ក៏ប៉ុន្តែ តាមពិតប្រុស១ចាយវាយច្រើនជាងស្រី១។ ក្នុងច្បាប់ គេនិយាយថា បុរសនិងស្ត្រីមានសិទ្ធិដូចគ្នា ប៉ុន្តែ ការពិតជាក់ស្តែង ស្ត្រីគេចាត់ទុកថាទាបជាងបុរស។ ហេតុដូច្នេះហើយ កាលណាស្ត្រីប្តឹងពីរឿងរបស់ខ្លួន ស្ត្រីតែងតែនិយាយបំភ្លើសពាក្យសំដីរបស់ខ្លួន។ ពួកគេធ្វើដូច្នេះដើម្បីឱ្យគេស្តាប់ ព្រោះគេដឹងថាគ្មានអ្នកណាសូវស្តាប់ពួកគេទេ។ នៅក្នុងការឈ្លោះ ប្រកែកគ្នារវាងប្តីប្រពន្ធ ប្តីមានកំហុសញឹកញាប់ជាងប្រពន្ធ។ ស្ត្រីជាច្រើនសុខចិត្តអត់ទ្រាំមិននិយាយស្តី សុខចិត្តទ្រាំការលំបាក ហើយសង្ឃឹមថា ប្រុស១នឹងស្ងប់ចិត្តឈប់ខឹង។ ដោយហេតុថា ស្ត្រីជាអ្នកខ្សោយ វិធីតែមួយដើម្បីរំលត់កំហឹងនោះ គឺការអត់ទ្រាំ"។(លោក ប៊ូ អាយុ ៥៧ ឆ្នាំ ប្រធានភូមិ ឃុំ ស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

ធនធានហិរញ្ញវត្ថុរបស់សហព័ន្ធមិនដល់កំរិតដែលគេស្រម័យចង់បានប្រាក់

"មានបញ្ហាជាច្រើនទាក់ទងនឹងប្រាក់។ គេចង់បានប្រាក់ដើម្បីទិញអ្វីមួយដែលមានលក់នៅទីផ្សារ នៅក្នុងហាងថ្មីៗ។ គេចង់បានប្រាក់ជានិច្ច។ បុរសម្នាក់ចង់បានប្រាក់ក៏ទៅលួចមាសនៅក្នុងផ្ទះ ឬមាសដែលគេពាក់។ ស្ត្រី ទៅធ្វើជាស្ត្រីពេស្យាហើយប្តីមិនថាអ្វីទេ។ ភាគច្រើនជាស្ត្រីដែលចង់បានប្រាក់។ ស្ត្រីចង់បង្ហាញឱ្យអ្នកដទៃឃើញថា ខ្លួនមានប្រាក់។ បើប្តីរកប្រាក់ចូលផ្ទះមិនបានទេ នោះគាត់ក៏ខឹង"។

(លោក សារ៉ា អាយុ៥២ឆ្នាំ អនុប្រធានសង្កាត់ផ្សារកណ្តាល ១ ខ័ណ្ឌដូនពេញ ភ្នំពេញ)

"ពួកក្មេងៗស្រម័យចង់បង្កើនកំរិតជីវភាពរបស់ខ្លួន ហើយចង់សប្បាយ។ ទាំងប្រុសទាំងស្រីគិតតែពីដើរលេង។ អ្នកដែលមានមិត្តភ័ក្រ្តជាអ្នកមាន ស្រម័យចង់បានសំលៀកបំពាក់ស្អាតៗ មានម៉ូតូល្អ មានទូរស័ព្ទដៃល្អៗ។ ពួកគេច្រណែននឹងអ្នកដទៃ ហើយស្រម័យចង់បានប្តី ឬប្រពន្ធអ្នកមាន។ អ្នកមានប្រាក់តិចចាប់ផ្តើមចាយវាយ ដើម្បីទិញរបស់ល្អៗ ហើយចំណូលគ្រួសារត្រូវចាយទៅលើរបស់អស់នោះ។ ក្នុងចំណោមប្តីប្រពន្ធ អ្នកដែលមិនសូវខ្វះខ្វាយចាប់ខឹង ហើយបញ្ហាក៏ចាប់ផ្តើម។ អ្នកដែលចាយធំមើលងាយសហព័ន្ធរបស់ខ្លួនដែលក្រ។

(លោក ឆុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

<u>អាពាហ៍ពិពាហ៍ដែលរៀបចំដោយឪពុកម្តាយ ប្តីប្រពន្ធក្មេងៗ</u>

"មានបញ្ហាប្តីប្រពន្ធរៀបការនៅក្មេងពេក ដែលរៀបចំដោយឪពុកម្តាយ។ ប្រពន្ធស្រម័យចង់បានរថយន្ត ហើយប្តីមានតែម៉ូតូ។ ក្មេងស្រីស្អាតៗជាកូនអ្នកក្ររកប្តីជាអ្នកមាន។ បើពួកគេយកប្តីក្រដូចខ្លួន ពួកគេមិនសប្បាយចិត្តទេ ហើយក៏ឈ្លោះជាមួយប្តី។ ស្ត្រីនោះរកប្តីមួយទៀតដែលមានជាងប្តីដើម។ គេនិយាយថា "គោលឿនសីកក ស្រីល្អសីកគូថ"។ ក្នុងករណីមានការសុំលែងលះជួនកាលបញ្ហាច្រើនបង្កដោយឪពុកម្តាយជាងប្តីប្រពន្ធខ្លួនឯង។ ឧទាហរណ៍ បើស្រីជាអ្នកមានម្នាក់ជំនះរៀបការជាមួយប្រុសក្រម្នាក់ ឪពុកម្តាយខាងស្រីព្យាយាមទាមទារឱ្យ លែងលះ។ ក្នុងករណីនេះ ខ្ញុំគិតថា គូស្រករក្មេងៗត្រូវតែបែកចេញពីឪពុកម្តាយខាងស្រី"។

(លោក សម្បត្តិ អាយុ៥៥ឆ្នាំ ប្រធានសង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ភ្នំពេញ)

<u>ការសុំលែងលះ</u>

ពេលណាមានការឈ្លោះគ្នាធម្មតារវាងប្តីប្រពន្ធ អ្នកដែលទៅរកអ្នកផ្សះផ្សាទាមទារមុនដំបូងបំផុតឱ្យអ្នកជួយខាងក្រៅនេះ ស្តីប្រដៅ និងតម្រង់ផ្លូវសហព័ន្ធដែលរងបណ្តឹងនេះ។ ក្នុងករណីមានជម្លោះខ្លាំងសហព័ន្ធម្នាក់ ឬ សហព័ន្ធទាំងពីរនាក់សុំបែកផ្លូវគ្នា។ ការលែងលះតាមការព្រមព្រៀងទៅវិញទៅមកប្រព្រឹត្ត

ទៅក្នុងរបៀបមិនផ្លូវការទេ[១៣៤]។ ប្តីប្រពន្ធទាំងពីរបែកផ្លូវគ្នាដោយខ្លួនឯង។ គេត្រូវការជំនួយពីរាជការតែក្នុងករណីសុំរៀបការជាថ្មី ព្រោះគេត្រូវការក្រដាសស្នាមចុះហត្ថលេខាដោយអតីតសហព័ទ្ធដែលអនុញ្ញាតឱ្យគេរៀបការជាលើកទីពីរ។ ការសុំលែងលះពីសំណាក់សហព័ទ្ធតែម្ខាងជារឿយៗ មានច្រកចេញផ្សេងក្រៅពីការអត់ទ្រាំនឹងអាពាហ៍ ពិពាហ៍អាក្រក់។ ប្រពៃណីមិនគាំទ្រឱ្យគូស្រករបែកគ្នាទេ។

"ជារឿយៗប្រពន្ធជាអ្នកប្តឹង។ គាត់និយាយថាប្តីគាត់គ្មានការងារធ្វើ ដើរលេង លេងបាល់ ឈ្លោះនឹងគាត់ កាលណាគាត់ស្តីបន្ទោស។ ជាញឹកញាប់ប្រពន្ធចង់ឱ្យខ្ញុំប្រដៅប្តីគាត់ ដើម្បីឱ្យប្តីគាត់ល្អ។ ប្តីប្តឹងថា ប្រពន្ធគាត់មិនស្តាប់គាត់ ហើយចេះតែដើរលេង។ ករណីសុំលែងលះ កម្រមានណាស់។ ជាគោលការណ៍ មនុស្សទាំងអស់ចូលចិត្តដោះស្រាយរឿងប្តីប្រពន្ធជាមួយគ្រួសារគេរៀងៗខ្លួន ឬជាមួយចាស់ទុំ ប៉ុន្តែចំពោះអ្នកដែលបាត់បង់ឪពុកម្តាយ ឬ រស់នៅឆ្ងាយពីចាស់ទុំ គេតែងតែមករកខ្ញុំ។ ភូមិនេះធំ មានមនុស្សជាង៥០០នាក់ ហើយមានចាស់ទុំតែ១០នាក់។

ជាទម្លាប់ចំពោះការលែងលះ មនុស្សបែកផ្លូវគ្នាដោយខ្លួនឯង ដោយមិនបានប្រាប់អ្វីទាំងអស់ជាមួយអាជ្ញាធរដឹង ប៉ុន្តែ បើអ្នកណាមួយក្នុងចំណោមប្តីប្រពន្ធទាំងពីរនាក់មិនចង់លែង ពេលនោះវាកើតជាជម្លោះ។ ក្នុងរយៈពេល២០ឆ្នាំនេះ ខ្ញុំបានឃើញការលែងលះនេះ៦ករណីដែលដោះស្រាយនៅឃុំ។

មានបញ្ហាផ្សេងៗជាមួយនឹងអាពាហ៍ពិពាហ៍ដែលរៀបចំដោយឪពុកម្តាយ។ ក្មេងៗវាមិនស្រឡាញ់គ្នាទេ ហើយមួយរយៈពេលខ្លីបន្ទាប់ពីអាពាហ៍ពិពាហ៍ទៅ គេមិនចង់រស់នៅជាមួយគ្នាទៀតឡើយ"។

(លោក សាវេត អាយុ៥០ឆ្នាំ ប្រធានភូមិ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

សព្វថ្ងៃនេះ គេហាក់ដូចជាឃើញថា ការសុំលែងលះច្រើនតែកើតចេញពីស្ត្រី។ មិនដូចករណីដែលពោលខាងមុនទេ គឺសម័យកាលបានផ្លាស់ប្តូរ ហើយហេតុផលនៃការលែងលះគ្នាក៏ដូច្នោះដែរ។

"បន្ទាប់ពីឆ្នាំ១៩៧៩ ភ្លាម ភាគច្រើនបុរសជាអ្នកសុំលែងលះ។ បុរសជាច្រើនបានស្លាប់ ហើយស្ត្រីមេម៉ាយ ក៏នៅសល់ច្រើន។ បុរសមានតម្លៃច្រើន ហើយគេសំរេចជារឿយៗថា នឹងលែងលះប្រពន្ធចាស់ ដើម្បីយកប្រពន្ធក្មេង។ ឥឡូវនេះ ដោយសារមនុស្សជំនាន់ថ្មី គេមានសមភាព បុរសបានបាត់បង់តម្លៃហើយ។ ប្រុសក៏ដូចជាស្ត្រី ជាអ្នកសុំលែងលះ។ ហេតុផលនៃការសុំលែងលះជារឿយៗគឺមកពីហេតុផលសេដ្ឋកិច្ច។ សហព័ទ្ធមួយស្តីបន្ទោសសហព័ទ្ធមួយទៀតថា មិនបានរក

[134] យោងតាមច្បាប់ ការលែងលះអាចធ្វើបានតែក្នុងតុលាការ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងគេធ្វើផ្ទុយទៅវិញ។ ជាងនេះទៀត ឯកសារអាពាហ៍ពិពាហ៍ ជារឿយៗមិនមានទេ។

ប្រាក់ គិតតែពីដើរលេង ហើយចាយវាយប្រាក់។ មានបញ្ហាជាមួយឪពុកម្ដាយក្មេកដែរ។ បើបុរសរស់នៅជាមួយគ្រួសារខាងស្រី នោះនឹងមានបញ្ហា។ កូនប្រសាប្រុស និងឪពុកម្ដាយក្មេក មិនសូវត្រូវគ្នា។ ដូចគ្នា បើកូនស្រីរស់នៅផ្ទះឪពុកម្ដាយក្មេកជាមួយប្ដី បើឪពុកម្ដាយក្មេកមិនពេញចិត្តពីរបៀបកូនប្រសាបំរើទេនោះ ឪពុកម្ដាយនោះបង្គាប់ឱ្យកូនខ្លួនឯងសុំលែងលះប្រពន្ធ។ រឿងនេះនៅតែអាចធ្វើបានទោះបីជាកូនប្រុសស្រឡាញ់ប្រពន្ធក៏ដោយ។ ឪពុកម្ដាយចង់បំបែកបំបាក់អាពាហ៍ពិពាហ៍។ បើកូនប្រុសនៅក្មេង គេនឹងស្ដាប់បង្គាប់ឪពុកម្ដាយ។ មានករណីដែលពួកក្មេងៗស្រឡាញ់គ្នា ហើយពង្រាត់គ្នាបាត់"។

(លោក សុវណ្ណារុំ ព្រះរាជអាជ្ញា តុលាការខេត្តកំពត)

## ៣. ជម្លោះជាមួយអ្នកជិតខាង

យើងបានលើករួចមកហើយពីបញ្ហានៃការរស់នៅប្រជ្រៀតគ្នាដែលទាក់ទងនឹងសំណង់"រជិបរជុបគ្មានក្បួនខ្នាត"នៅទីក្រុង។ នៅស្រុកស្រែ ការរស់នៅប្រកៀកគ្នាជាមួយផ្ទះអ្នកជិតខាងមិនមែនមិនបង្កើតបញ្ហាទេ ដូចជាសត្វលែងចោលឱ្យដើរសេរីទៅស៊ីដំណាំគេ ព្រំដែនដីដែលបំពានគ្នា សិទ្ធិប្រើប្រាស់ច្រកចូលដែលត្រូវគេបិទសម្លេង បំពងបាសហេតុការប្រច័ណ្ឌ បំណុលមិនសង ការឈ្លោះគ្នាដោយស្រវឹង...។

<u>ជម្លោះក្មេងៗដែលរាលដាលដល់ឪពុកម្ដាយ</u>

"កូនរបស់ឈ្មោះហឿន បានវាយកូនរបស់ខុល។ ហឿនបានជេរប្រទេចខុល។ គាត់ជេរថា "អាក្រធ្វើឫក ជាមាន"។ ខុល និងហឿន វាយតប់គ្នា ម្នាក់ៗចោទប្រកាន់កូនរបស់ម្នាក់ទៀត។ ខ្ញុំចូលធ្វើអន្តរាគមន៍ ព្រោះប្រពន្ធអ្នកឈ្លោះគ្នាម្នាក់មករកខ្ញុំ។ គាត់ភ័យ ថាបើវាយគ្នាដូច្នេះនាំឱ្យមានរបួសស្នាម។ ខ្ញុំបាននិយាយថា ក្មេងឈ្លោះគ្នាវាជារឿងធម្មតាទេ ក្រោយពីវាខឹងគ្នាជាទូទៅវាស្វាត់ទៅវិញហើយ។ បញ្ហានេះ កើតមានម្ដងទៅពីរដងក្នុងមួយឆ្នាំ"។

(លោក សាវ៉ាត អាយុ៥០ឆ្នាំ ប្រធានភូមិ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

<u>សិទ្ធប្រើប្រាស់ច្រកចូល</u>

"ម៉ូតូតែងតែបរប្រកៀកនឹងផ្ទះខ្ញុំ។ ខ្ញុំបានដាំផ្កាមួយជួរដើម្បីបង្វែងផ្លូវមួយម៉ែត្រ ហើយឈួនក៏ខឹងឆ្ងល់នឹង ខ្ញុំដោយនិយាយថា ខ្ញុំធ្វើដូច្នេះដោយចេតនា ដើម្បីឱ្យគាត់ដឹងថាខ្ញុំមិនចង់ឱ្យគាត់ជិះកាត់មុខផ្ទះខ្ញុំទៀត។ ខ្ញុំមិនបាន និយាយអ្វីទេ។ ក្នុងរយៈពេលមួយខែ គាត់ក៏ប្រើប្រាស់ផ្លូវមួយទៀត។ ឥឡូវនេះ គាត់ជិះកាត់មុខផ្ទះខ្ញុំទៀត ប៉ុន្តែ គាត់លែងមើលខ្ញុំទៀតហើយ"។

(លោកហួន អាយុ៥៥ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ការប្រច័ណ្ឌ និងការជេរប្រមាថ

"គី ខឹងនឹងសុវណ្ណ។ សុវណ្ណជាប្រពន្ធចុង ប្ដីរបស់គី។ គីចង់វាយសុវណ្ណ។ កាលណា គី ឃើញសុវណ្ណ គីហៅ សុវណ្ណ ថាជាស្រីពេស្យា"។

(អ្នកស្រីសុភា អាយុ ២៨ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ចំនួនករណីជម្លោះក្នុងភូមិនីមួយៗ ពិបាកនឹងប្រមាណឱ្យដឹងណាស់។ បញ្ហា ជួនកាលអាចបំបិទ ឬដោះស្រាយបានក្នុងគ្រួសារ។ បញ្ហាដែលលើកយកមកឱ្យប្រធានភូមិដោះស្រាយ ត្រូវបានចាត់ទុកថា ជាបញ្ហាធ្ងន់។ ក្នុងកម្លុងពេលសន្ទនា ប្រធានភូមិនានាបានឱ្យយើងដឹងថា ពួកគាត់ដោះស្រាយបានរឿងតិចណាស់ អ្នកខ្លះនិយាយថា បានដោះស្រាយ៤ ឬ៥ ករណីក្នុងមួយឆ្នាំ អ្នកខ្លះទៀតថា បាន ២ ឬ៣ ករណីក្នុងមួយខែ។ ជារឿយៗ គេចាំបានតែរឿងណាសំខាន់ៗប៉ុណ្ណោះ។

## ៤. ជម្លោះជាមួយមនុស្សមកពីក្រៅ

ករណីកម្រទាំងនេះ ទាក់ទងជាពិសេសនឹងជម្លោះដីធ្លី។ ក៏ប៉ុន្តែ ជម្លោះទាំងនេះធ្ងន់ធ្ងរណាស់ ហើយមានប្ដឹងផ្ដល់គ្នារហូតដល់តុលាការជាន់លើ។ ដីមួយចំនួនត្រូវបានកាន់កាប់ដោយមនុស្សមកពីក្រៅ។ រឿងនេះកើត ឡើងជាពិសេសនៅក្នុងតំបន់មានធនធានល្អ(តំបន់អភិវឌ្ឍន៍ជនបទ ដែលទទួលអត្ថប្រយោជន៍ពីហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ល្អ និងតំបន់ដែលមានជំនួយ ពីអង្គការអន្តរជាតិ) ឬតំបន់ជិតជំរុំយោធា (ចាប់តាំងពីចប់សង្គ្រាម និងមានការកាត់រំសាយទ័ពមក យោធាខ្លះរកដីដើម្បីតាំងលំនៅដ្ឋាន)។

# II. ការដោះស្រាយជម្លោះ

ការដោះស្រាយជម្លោះនៅថ្នាក់មូលដ្ឋាន ប្រែប្រួលទៅតាមស្ថានភាពភូមិសាស្ត្រនៃទីកន្លែង ព្រមទាំងប្រែប្រួលទៅតាមបុគ្គលិកលក្ខណៈ និងកំរិតចំណេះដឹងនៃមនុស្សដែលចូលពាក់ព័ន្ធ គឺជម្លោះ និងអ្នកធ្វើអន្តរាគមខាង ក្រៅ។

នៅក្នុងកម្លុងពេលសន្ទនា យើងបានកត់សំគាល់ឃើញរបៀបខុសគ្នាក្នុងការដោះស្រាយ និងចាត់ចែងជម្លោះ។ ការស្រង់ករណីជាតួលេខដែលមានជាបន្ទាប់ មិនអាចចាត់ទុកថាអស់ទេ។ ជំរើសមានកំណត់នូវសំណាក ព្រមទាំងតំបន់ខ្លះដែលពិសេសសំរាប់ការអង្កេត(អតីតតំបន់ខ្មែរក្រហម) មិនអាចតំណាងឱ្យជាស្ថិតិនូវអ្វីដែលកើតជាថៃដន្យនៅទូទាំងប្រទេសកម្ពុជាទេ។

ដូច្នេះ បរិមាណពតិមានដែលប្រមូលនៅក្នុងមាតិកានិមួយៗមានការប្រែប្រួលខុសគ្នាយ៉ាងច្រើន។ ការស្រាវជ្រាវដទៃទៀតដែលទូលំទូលាយជាង និងស៊ីជំរៅជាង អនុញ្ញាតឱ្យពិភាក្សាបានយ៉ាងប្រសើរនូវប្រធានបទដ៏ស្មុគស្មាញនេះ ហើយនិងអាចយល់ពីយន្តការដែលនៅពីខាងក្រោម។ នៅទីនេះ យើងបង្ហាញតែពីទ្រង់ទ្រាយធំៗ ដែលលេចឡើងក្នុងពេលសន្ទនាដែលបានធ្វើក្នុងកម្លុងពេលសិក្សានេះ ព្រមទាំងចំណុចសង្កេតខ្លះដែលបានរកឃើញនៅក្នុងឱកាសសិក្សាពីភូមិសាស្ត្រពីមុន។

ដូច្នេះ យើងបានរកឃើញនូវឥរិយាបថជាច្រើនចំពោះមុខបញ្ហាដែលអាចប្រែក្លាយទៅជាជម្លោះឬអត់។ យើងបានកត់សំគាលឃើញថា បញ្ហាអាចកំចាត់បាន អាចបំបិទ អាចចៀសវាងបាន កុំឱ្យវាក្លាយទៅជាជម្លោះ ហើយជម្លោះនេះទៀតសោតក៏អាចកំចាត់ បំបិទ ចៀសវាង ច្រានចោល សំរបសំរួលដោយសមធម៌ចរចាជាគុណ ប្រយោជន៍ដល់គូកន បំភ្លេច ឬ ក៏អាចបញ្ជូនទៅអាជ្ញាធរថ្នាក់លើបាន។

នៅក្នុងការដោះស្រាយបញ្ហា និងទំនាស់ គេសង្កេតឃើញមានការខុសគ្នាគួរឱ្យកត់សំគាល់រវាងទីកន្លែងឆ្ងាយ កន្លែងដាច់ស្រយ៉ាល និងកន្លែងនៅជិតក្រុងនិងជិតផ្លូវថ្នល់។ ប្រជាជនដែលរស់នៅទីកន្លែងដាច់ពីគេស្ថិត នៅមួយចំណែកធំក្នុងក្របខ័ណ្ឌនៃប្រព័ន្ធចាស់ដែលការត្រួតត្រារបស់អាជ្ញាធរមូលដ្ឋាននៅក្តាប់រឹងមាំនៅឡើយ។ ផ្លូវថ្នល់លំបាកលំបិនធ្វើឱ្យមិនសូវមានការធ្វើដំណើរ និងមិនសូវបើកទ្វារទៅរកទីក្រុង។ កំរិតការអប់រំនៅខ្សោយ ជាទូទៅ។ មធ្យោបាយទទួលពតិមានដូចជាវិទ្យុ និងទូរទស្សន៍មិនសូវមានប្រើដូចនៅក្នុងតំបន់ទីក្រុង និងជុំវិញ ទីក្រុងទេ។ គណបក្សនយោបាយប្រឆាំងនៅទីនោះ មិនសូវហ៊ានលេខមុខលេចមាត់ទេ។

នៅទីកន្លែងជិតទីក្រុង មនុស្សទាំងឡាយមានជីវភាពធូរធាជាង មានការអប់រំជាង ចំហរទៅរកពិភពខាងក្រៅជាង ហើយនិងមានលទ្ធភាពប្រើប្រាស់មធ្យោបាយពតិមានច្រើនជាង[១៣៥]។ យើងបានរកឃើញថាការគាប សង្កត់របស់អាជ្ញាធរមូលដ្ឋាននៅទីកន្លែងទាំងនោះមិនសូវខ្លាំងប៉ុន្មានទេ។

## ១. ដោះស្រាយបញ្ហាដោយខ្លួនឯង

ពេលណាបញ្ហាមួយកើតឡើង តិរិយាបថទីមួយគឺដំបូងត្រូវទប់ចិត្ត។ ការទប់ចិត្តអាចឱ្យគេវាយតម្លៃបញ្ហា និងតុល្យភាពកម្លាំងដែលមាន ព្រមទាំងលទ្ធភាពពឹងពាក់លើគូកន ដែលមានមកហើយ ឬអ្នកអាចក្លាយជាគូកន។

ប្រឈមមុខបញ្ហាជាមួយអ្នកណាម្នាក់ដែលខ្លាំងជាងខ្លួនឯងទាមទារឱ្យមានការប្ដេជ្ញាចិត្តយ៉ាងធំ។ មនុស្សខ្លាំង អ្នកធំ គឺជាមនុស្សអ្នកមាន ជាយោធា ហើយនិងជាមនុស្សដែលមានគូកននៅក្នុងក្រុមអ្នកមានអំណាច។

អ្នកខ្សោយ អ្នកតូច ជាអ្នកក្រ ជាអ្នកដែលគ្មានមធ្យោបាយនឹងមានគូកន ជាអ្នកមកពីខាងក្រៅភូមិ ហើយជាអ្នកដែលអ្នកមូលដ្ឋានពិបាកនឹងទទួលយក។ សមាជិកគណបក្សនយោបាយប្រឆាំងក៏អាចបញ្ចូលក្នុងពពួកមនុស្សទាំងនោះដែរ។

### ១.១. ការចៀសវាង

កាលណាអតុល្យភាពកម្លាំងរវាងភាគីមានខ្លាំងពេក ការខ្លាចក្រែងបង្កើតបញ្ហាឱ្យកាន់តែធំ និងការខ្លាចក្រែងមានការសងសឹក ឬនាំឱ្យខាងបង់ច្រើន ការខ្លាចក្រែងគេចំណាំមុខទុក ទាំងអស់នេះជារឿយៗនាំឱ្យគេមិននិយាយនិងមិនធ្វើអ្វីទាំងអស់។ ជាងនេះទៅទៀត គេប្រកាន់យកតិរិយាបថស្ថិតនៅឆ្ងាយពីអ្នកដែលបានបង្កើតបញ្ហា។

> "នៅទីនេះ គេក្រណាស់។ មានជម្លោះតិចណាស់រវាងគ្នានិងគ្នា។ បើអ្នកជិតខាងម្នាក់មកដាំដំណាំលើដីខ្ញុំ ខ្ញុំទុកឱ្យគេដាំទៅជាការល្អជាង។ ដីក៏តូចដែរ។ អ្នកជិតខាងមិនអាចធ្វើអ្នកមានអ្នកបានអ្វីប៉ុន្មានទេជាមួយដីនោះ។ ខ្ញុំខ្ជិលធ្វើអន្តរាគម។ ខ្ញុំជាសមាជិកនៃសមាគមមួយដែលផ្សព្វផ្សាយអំពើហិង្សា។ ខ្ញុំមិននិយាយអ្វីទាំងអស់ ខ្ញុំទុកឱ្យគេធ្វើតាមចិត្ត។ ខ្ញុំគ្មានបំណងចង់ឃើញរឿងកើតធ្ងន់ធ្ងរទេ។ ខ្ញុំមិនឱ្យអ្នកដទៃមានការខ្មាស់ទេ។ បើខ្ញុំ និយាយថាមានបញ្ហា មនុស្សទាំងអស់គ្នាមិនសប្បាយចិត្តទេ គេខ្មាស់។ ដើម្បីរក្សាកិត្តិយស និងសាមគ្គីភាព ការល្អគឺត្រូវបោះបង់ចោលដីឱ្យទៅអ្នកដែលបានយក។ ដីនោះមិនថ្លៃទេ។ ខ្ញុំមិនចង់ឱ្យបញ្ហាតូចមួយធ្វើឱ្យបែកបាក់សាមគ្គី

[135] កាសែតមានអាន តែអ្នកនៅក្នុងក្រុងប៉ុណ្ណោះ។

ទេ។ បើអ្នកណាម្នាក់ទៀតនៅតែយកដីនោះ ខ្ញុំអាចនិយាយទៅគាត់ដោយចំហ និងដោយត្រង់។ ខ្ញុំនឹងពន្យល់អំពីមារយាទរបស់គាត់ឱ្យគាត់ស្តាប់។ ប៉ុន្តែ បើបញ្ហាវាសំយាន់ខ្លាំង ខ្ញុំនឹងទៅរកប្រធានភូមិឱ្យរកយុត្តិធម៌ឱ្យ។ បើរកយុត្តិធម៌មិនបានទេ យើងត្រូវឡើងទៅថ្នាក់លើទៀត។ នៅថ្នាក់លើ យើងមានអង្គការសិទ្ធិមនុស្ស ឬតុលាការ"។

(លោកសារិន អាយុ៥៩ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ទទួលស្គាល់ និង ទទួលយកសភាពរបស់ខ្លួន ព្រមទាំងរបាំងសង្គម ដើម្បីចៀសវាងបញ្ហា។

"យុត្តិធម៌មានន័យថា កាលណាភាគីពីរយល់ព្រមនឹងគ្នា។ ខ្ញុំជាអ្នកក្រ។ បើខ្ញុំមានបញ្ហាជាមួយអ្នកមាន ខ្ញុំត្រូវជ្រើសរើសបោះបង់បណ្តឹង ដើម្បីកុំឱ្យបណ្តឹងនោះឡើងទៅថ្នាក់ខ្ពស់ពេក ព្រោះខ្ញុំដឹងថាខ្ញុំនឹងចាញ់។ ខ្ញុំព្យាយាមកុំឱ្យមានបញ្ហាជាមួយអ្នកមាន ព្រោះពួកគេជាអ្នកមានអំណាច។ យកល្អ គឺថាម្នាក់ៗត្រូវគិតពីខ្លួនឯង។ ម្នាក់ៗរស់នៅតាមរបៀបខ្លួន ហើយប្រឹងប្រែងរកប្រាក់តាមលទ្ធភាពរបស់ខ្លួន។ អ្នកដែលមានមុខងារខ្ពស់រស់នៅជាមួយគ្នាគេ ហើយយើងរស់នៅជាមួយគ្នាយើង។ យើងមិនទៅក្បែរមនុស្សនៅផ្នែកម្ខាងទៀតនៃភូមិទេ។ គេជាអ្នកមាន"។

(អ្នកស្រី នឿន អាយុ៥០ ឆ្នាំ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

ការខ្លាចមិនហ៊ាននិយាយនៅតែមានកម្រិតខ្ពស់។ ចាស់ទុំម្នាក់មិនជឿថា មានការផ្លាស់ប្តូរទេ។

"ឥឡូវនេះ គេនិយាយប្រាប់យើងថា គេមានសិទ្ធិពេញលេញ ប៉ុន្តែគេមិនស្គាល់ព្រំដែននៃសិទ្ធិនោះទេ។ គេនិយាយតែពីសិទ្ធិផ្ទាល់ខ្លួនរបស់គេ ហើយគេមិននិយាយពីសិទ្ធិរបស់អ្នកដទៃទេ។ សិទ្ធិរបស់មេធំជាងសិទ្ធិរបស់យើងជានិច្ច។ គេមានសិទ្ធិនិយាយតាមចិត្តចង់។ ប្រជាពលរដ្ឋមានសិទ្ធិនិយាយ ប៉ុន្តែមិនហ៊ាននិយាយ។ ប៉ុន្តែគ្រាន់បើជាងពីមុន។ ចំពោះខ្ញុំ ខ្ញុំមិនខ្លាចទេ ប៉ុន្តែយើងជាខ្មែរ យើងដឹងថាកាលបើយើងជាអ្នកតូច យើងមិនត្រូវនិយាយអ្វីទាំងអស់។ យើងបានរៀនចេះចាំថា"អ្នកស្លូតស្លាប់ អ្នកកាចមានភ័ព្វអាយុយឺនយូរ"។ គេនិយាយដែរថា គេមិនអាចផ្លាស់ប្តូរសង្គមបានទេ អ្នកកាចនៅតែកាចជានិច្ច ហើយមនុស្សអាក្រក់ នៅតែធ្វើអាក្រក់។ "ឆ្អែកន្ទុយខ្សៀន គេមិនអាចតម្រង់បានទេ"។ បើខ្ញុំមានបញ្ហា ខ្ញុំមិនត្រូវនិយាយអ្វីទាំងអស់។ យើងមិនអាចផ្លាស់ប្តូរអ្វីបានទេ"។

(លោក សុទ្ធ អាយុ៦៤ឆ្នាំ អាចារ្យ ឃុំអង្កាល់ ក្រុងកែប ខេត្តកំពត)

ដោយខ្លាចខ្លួនឯងធ្លាក់ក្នុងជម្លោះ គេចៀសវាងធ្វើអន្តរាគមក្នុងរឿងអ្នកដទៃ។

"កាលណាមានបញ្ហានៅផ្ទះអ្នកជិតខាង បើគេមិនសុំទេនោះ យើងត្រូវស្តាប់ពីចម្ងាយ ប៉ុន្តែយើងមិនត្រូវចូលទៅឡូកឡំទេ។ បើយើងចូលអន្តរាគម យើងនឹងមានបញ្ហាបន្ទាប់ពីនោះ"។

(អ្នកស្រី គង់ អាយុ៣៩ឆ្នាំ ឃុំអង្កាល់ ក្រុងកែប ខេត្តកំពត)

ម៉ុនជាមនុស្សក្មេងម្នាក់ដែលមកតាំងលំនៅនៅក្នុងភូមិថ្មីមួយនិងនៅដាច់ពីគេ។ ដោយក្រ មិនចេះអីនិង គ្មានគូកនទឹងគេ គាត់យល់ថា ដើម្បីរស់គាត់ត្រូវចៀសវាងបញ្ហា គិតតែធ្វើការហើយត្រូវនៅឱ្យស្ងៀមស្ងាត់។

"ខ្ញុំខ្លាចមិនហ៊ាននិយាយទេ។ នៅមានខ្លួនតែមួយ។ ខ្ញុំជាអ្នកក្រ។ នៅទីនេះគ្មានអ្នកណាជួយខ្ញុំទេ។ ខ្ញុំដឹងច្បាស់ថា ខ្ញុំត្រូវតែធ្វើការហើយកុំឱ្យមានបញ្ហា។ មិនមានបញ្ហាទេ ប៉ុន្តែខ្ញុំខ្លាចវានឹងមានបញ្ហា។ បើមានបញ្ហា ខ្ញុំមិនត្រូវនិយាយអ្វីទាំងអស់ ហើយគិតតែពីធ្វើការ។ ខ្ញុំឮគេនិយាយពីសិទ្ធិមនុស្សតាមវិទ្យុ ប៉ុន្តែខ្ញុំមិនយល់ទេ។ ខ្ញុំចេះអាន ចេះសរសេរ ប៉ុន្តែខ្ញុំមិនយល់រឿងធំៗទាំងនោះទេ។ សំខាន់ត្រូវចេះអាន ចេះសរសេរ។ ក្នុងពេលសង្គ្រាមសាលាខ្ញុំស្ថិតនៅជិតសមរភូមិហើយត្រូវបានគេដុតឆេះអស់"។

(លោកម៉ុន អាយុ២៨ឆ្នាំ ឃុំត្រពាំងភ្លាំង ឃុំឈូក ខេត្តកំពត - ភូមិថ្មី)

## ១.២. ការបំបាត់បញ្ហា

ក្នុងករណីដែលគេគិតថា ការសំរុះសំរួលមិនអាចធ្វើទៅរួច ឬ ធ្វើលែងកើតទៀតហើយនោះ មនុស្សដែលគេហៅថាជាអ្នកធ្វើឱ្យខូចរបៀបរបបសង្គមត្រូវតែទាត់ចោល ឬក៏ថាកំទេចចោលតែម្តងក្នុងករណីដែលធ្ងន់ធ្ងរជ្រុល។

### ការផាត់ចេញពីសង្គម

តំរិយាបថមួយនៃការទាត់ចោល មានន័យថា ឱ្យមនុស្សម្នាក់ ឬគ្រួសារមួយត្រូវដាក់ឱ្យស្ថិតនៅដាច់ឆ្ងាយពីគេដោយចៀសវាងកុំឱ្យមានការទាក់ទងជាមួយមនុស្សនោះ ឬគ្រួសារនោះ ឬក៏ជំរុញឱ្យមនុស្សនោះ ឬគ្រួសារនោះចាកចេញបើជននោះបង្ក ឬគេមានអារម្មណ៍ថាជននោះ ឬគ្រួសារនោះបានបង្កការច្របូកច្របល់។ ករណីទាំងពីរនេះ អាចប្រដូចទៅនឹងការដាក់ឱ្យនៅក្រៅសង្គម។

<u>ការបណ្តេញ ការចាកចេញ</u>

គេធ្វើការគាបសង្កត់លើមនុស្សម្នាក់ ដើម្បីឱ្យគេចាកចេញ។ វាអាចជាការបំភិតបំភ័យដោយពាក្យសំដី ឬផ្លូវកាយ។ បើអ្នកណាម្នាក់មានការគាំទ្រតិចនៅក្នុងភូមិ ដំណោះស្រាយសំរាប់មនុស្សនោះ (និងជូនកាលគ្រួសារទាំងមូល) ជារឿយៗ គឺត្រូវចាកចេញទៅកន្លែងផ្សេងដើម្បីរុករានដីថ្មីមួយទៀត។ ការអនុវត្តនេះដែលហាក់ដូច ជាមានច្រើនគួរសមក្នុងសម័យមុនសង្គ្រាម ឥឡូវនេះមិនស្រួលប៉ុន្មានទេ។ លទ្ធភាពរកដីទំនេរអាចធ្វើទៅបាន ប៉ុន្តែបច្ចុប្បន្ននេះវាពិបាកដោយសារកំណើនប្រជារាស្ត្រ និងនីតិវិធីរដ្ឋបាលរឹតតែស្មុគស្មាញ(ដូចជាលិខិតអនុញ្ញាតឱ្យផ្លាស់ទីលំនៅ/សេចក្តីត្រូវការដីធ្លី)។

ឪពុកម្តាយកាត់កាល់"កូនអាក្រក់"។

"បើកូនអាក្រក់ ឪពុកម្តាយអាចសំរេចផ្តាច់ចំណងមេបា ហើយបដិសេធការទទួលខុសត្រូវ និងករណីយកិច្ច ទាំងអស់ចំពោះកូន។ ឪពុកម្តាយចុះផ្សាយក្នុងកាសែតជូនដំណឹងថា មនុស្សនោះលែងជាកូនរបស់ខ្លួនទៀតហើយ ហើយបដិសេធការទទួលខុសត្រូវទាំងអស់ និងការទទួលបន្ទុកចំពោះអំពើអាក្រក់របស់កូននោះ។ រឿងនេះកើត ឡើងនៅក្នុងករណីដែលកូនធ្វើជាចោរ។ កូននោះលួចគេ ហើយនគរបាលមករកឪពុកម្តាយ"។

(អ្នកស្រី ភិន អាយុ ២១ឆ្នាំ ភ្នំពេញ)

## ការបំបាត់រូបកាយ

សេចក្តីស្លាប់ ជួនកាលជាមធ្យោបាយតែមួយដែលប្រើដើម្បីបំបាត់បញ្ហា។ វាអាចជារឿងរវាងមនុស្សពីរនាក់ ក៏ដូចជារឿងរបស់មនុស្សក្នុងភូមិពួតដៃគ្នាប្រឆាំងនឹងមនុស្សម្នាក់។

ករណីជម្លោះមិនបានដោះស្រាយ បំបិទមិនបាន ឬដែលកើតឡើងធ្វើឱ្យខូចខាតជាសាធារណៈ អាចផ្ទុះទៅជាគំនុំ និងមានការសងសឹកឃៅឃៅជាបន្ត។ មានករណីហិង្សាភ្លាម១ជាច្រើន ដែលជួនកាលនាំទៅរកឃាតកម្ម ដែលកើតមកពីហេតុផលនៃបញ្ហាចាស់ដែលមិនបានដោះស្រាយ។ ករណីដែលមានការឆ្លើយតបតាមរបៀបហិង្សាគឺពិតជាមាន ប៉ុន្តែមានដោយកម្រ។ ការនេះកើតឡើងដោយមកពីការស្រវឹង ឬដោយមកពីគំនុំចាស់ដែលឆាបឆេះឡើងវិញដោយសារការអុជអាលថ្មី ហើយដែលធ្វើឱ្យរឿងនោះផ្ទុះឡើងវិញ។

គេសង្កេតឃើញករណីជាច្រើនដែលគេយកអំពើហិង្សាជាការដោះស្រាយនៅក្នុងស្ថានការណ៍រាំងស្ទះនៅក្នុងជម្លោះមួយ។ អំពើហិង្សាអាចសំដែងចេញដោយផ្ទាល់ ចាប់ពីដើមជម្លោះ ដោយគ្មានការព្យាយាមសំរុះសំរួល។ ការប៉ះទង្គិចគ្នាខាងរូបកាយអាចបណ្តាលរហូតដល់ទៅសម្លាប់គ្នា ប្រសិនបើគូជម្លោះមានអាវុធ (អំពើនេះហាក់ដូចជាកើតមានជាធម្មតានៅក្នុងបរិបទក្រោយសង្គ្រាម)។ ផលដែលកើតចេញពីអំពើហិង្សាផ្ទាល់នេះ គឺជាការភ័យខ្លាចដែលនាំឱ្យមានការបំបិទបញ្ហា។ ប៉ុន្តែ ពិសពុលនៃបញ្ហាដែលពុំបានដោះស្រាយមិនបានរលាយសាបសូន្យទៅតាមពេលវេលាទេ។ ការគុំគួននៅតែមាន ហើយថ្ងៃក្រោយនឹងកើតមានការប៉ះទង្គិចគ្នា សូម្បីតែមានរឿងកំប៉ិកកំប៉ុកក្តី។

ដូចនេះ អំពើហិង្សាពន្យាពេល និងរីកកាន់តែធំឡើង ក្លាយទៅជាការឆ្លើយតបចំពោះការខ្លាចជម្លោះចំហ។ នៅក្នុងភូមិជាច្រើន គ្រួសារជាច្រើនដែលមានទំនាស់កាលពីអតីតកាលហើយដែលពុំបានឈានដល់ការព្រមព្រៀងគ្នានោះ បានលាក់រឿងនៅក្នុងខ្លួនជានិច្ច។ សេចក្តីភ័យខ្លាចការអុជអាលឱ្យរិតតែឈ្លោះគ្នាដោយសារតែកាយវិការណាមួយដែលមិនសមស្រប អាចជៀសវាងជាអតិបរិមាពីមនុស្សដែលគេមានជម្លោះជាមួយដោយការរក្សាអាការៈខាងក្រៅដូចជាល្អជាមួយគ្នា។ គេរកឃើញឥរិយាបថផ្ទុយគ្នាចំពោះអំពើហិង្សា។

អំពើហិង្សាត្រូវបានបដិសេធជាឯកច្ឆ័ន្ទ បើវាកើតឡើងដោយមិនបានដឹងមុន ហើយធ្វើឱ្យខូចខាតដល់ស្ថេរភាពគ្រួសារមួយ ឬក្រុមមួយ។ ផ្ទុយទៅវិញ អំពើហិង្សាអាចត្រូវបានប្រើជាមធ្យោបាយចុងក្រោយដើម្បីស្តារភាពសុខដុមរម្យនាឡើងវិញ( ការព្រួតគ្នាវាយចោរ ឬគ្រូធ្មប់ជាដើម) ។

នៅទីនេះ ជម្លោះដីធ្លីត្រូវបានដោះស្រាយដោយការសម្លាប់គូជម្លោះម្នាក់ រួមជាមួយនឹងសេចក្តីប្រាថ្នារបស់ប្រពន្ធរបស់ជនរងគ្រោះចង់បំបិទរឿងចោលដោយខ្លាចមានការសងសឹក។

> "ប្តីខ្ញុំមានបញ្ហាដីធ្លីតាំងពីយូរមកហើយ ជាមួយនឹងមនុស្សមកពីស្រុកខាងកើត។ រឿងនោះកើត ៥ ឆ្នាំមក ហើយគេបានយកដីមួយដុំពីប្តីខ្ញុំ ហើយរឿងនេះបានកើតទៅជាការឈ្លោះប្រកែកគ្នា។ ថ្ងៃមួយ ប្តីខ្ញុំចេញដំណើរទៅធ្វើការនៅស្រែជាមួយកូនពីរនាក់។ នៅពេលព្រលប់បន្តិច ខ្ញុំបានឮសូរសម្លេងកាំភ្លើងនៅឯឆ្ងាយ បន្ទាប់មកកូនទាំងពីរត្រឡប់មកផ្ទះវិញដោយគ្មានប្តីខ្ញុំមកជាមួយ។ ខ្ញុំខ្លាចណាស់ ខ្ញុំពួននៅផ្ទះខ្ញុំពេញមួយយប់។ ព្រឹកស្អែកឡើងខ្ញុំទៅស្រែ ហើយខ្ញុំរកឃើញប្តីខ្ញុំដេកស្លាប់( ដោយសារគ្រាប់កាំភ្លើង) ។ ប្រធានភូមិបានធ្វើការអង្កេត ប៉ុន្តែគាត់គ្មានបានរកឃើញអ្វីទាំងអស់។ ពួកនគរបាលមកផ្ទះខ្ញុំហើយសាកសួរខ្ញុំថា តើប្តីខ្ញុំដែលមានជម្លោះជាមួយអ្នកណាដែរឬទេ។ ខ្ញុំឆ្លើយថា មានជាមួយអ្នកជិតខាងដែលមកពីស្រុកខាងកើត។ នគរបាលបានធ្វើការអង្កេតនៅផ្ទះអ្នកជិតខាង។ ប៉ុន្តែខ្ញុំមិនចង់ឱ្យគេឯងដឹងឮរឿងនេះខ្ចរខ្ចាយទេ។ ខ្ញុំខ្លាចពួកឃាតករសងសឹកខ្ញុំ។ ខ្ញុំត្រូវបាននគរបាល ក្រុងកែបកោះហៅ។ គេធ្វើការអង្កេត ប៉ុន្តែរកឃាតករមិនឃើញទេ។ ខ្ញុំដឹងថាអ្នកណាជាអ្នកសម្លាប់ ប៉ុន្តែយើងគ្មានភស្តុតាង។ ខ្ញុំសុខចិត្តមិននិយាយរឿងនេះទៀតទេ។ ខ្ញុំខ្លាចគេសងសឹក។ បើឃាតករជាប់គុក កូនរបស់គេនិងបងប្អូនជីដូនមួយគេនឹងមកសងសឹកខ្ញុំ។ ខ្ញុំសុខចិត្តនៅស្ងៀម។ ស្លាប់មួយបានហើយកុំឱ្យស្លាប់ច្រើនទៀត"។
> ( អ្នកស្រី សូលី អាយុ៤០ឆ្នាំ ឃុំអង្កាល់ ក្រុងកែប ខេត្តកំពត)

មនុស្សដែលមានអកប្បកិរិយា ធ្វើឱ្យខូចរបៀបរបបភូមិស្រុកនាំឱ្យមានការបដិសេធពីសំណាក់អ្នកស្រុក។ ការបដិសេធនេះអាចប្រែក្លាយទៅជាការបំបាត់រូបកាយមនុស្សដែលរងការចោទប្រកាន់។ កាលណាសភាពស្ងប់ស្ងាត់ត្រឡប់មកវិញហើយ មនុស្សក្នុងស្រុកនោះរួមដៃគ្នាលាក់ឈ្មោះអ្នកសម្លាប់គេ។ ក្នុងកម្លុងពេលសិក្សាភូមិសាស្ត្រប្រទេសខ្មែរខាងមុខនេះ យើងបានរកឃើញករណីខ្លះៗ។

<u>បំបាត់បញ្ហាចោរលួច</u>

> "ចោរលួចគោទាំងពីរត្រូវបានសម្លាប់។ ល្អណាស់។ វាលែងមានបញ្ហាលួចក្នុងភូមិទៀតហើយ។ ឥឡូវមានសភាពស្ងប់ស្ងាត់។ ពិតមែនហើយ តាមច្បាប់គេត្រូវឱ្យការណ៍ទៅនគរបាលពីរឿង

ចោរលួចដើម្បីឱ្យនគរបាលចាប់ពួកចោរ ដើម្បីឡើងតុលាការ។ ប៉ុន្តែ មនុស្សខ្លាចមិនហ៊ានរាយការណ៍ពីចោរទេ។ ចោរមានប្រាក់។ គេមានប្រាក់ គេឱ្យនគរបាល និងអ្នកធ្វើការនៅតុលាការ រួចចោរត្រឡប់មកភូមិដដែល។ ពួកចោរដឹងថា អ្នកណាជាអ្នករាយការណ៍ រួចហើយគេនឹងសងសឹក។ ពួកចោរចង់សម្លាប់អ្នកណាដែលប្តឹង។ ឥឡូវនេះ វាស្លាប់អស់ហើយ។ យើងបានសុខ។ យើងសប្បាយ។ យើងមិនដឹងថា អ្នកណាជាអ្នកសម្លាប់ចោរទេ"។

(លោក ហ៊ួយ អាយុ៧០ឆ្នាំ អាចារ្យស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង(សីហា ១៩៩៨)

បំបាត់មនុស្សដែលមានអាកប្បកិរិយាមិនសមស្របដោយចោទប្រកាន់គេថា ជាមេធ្មប់

"គេជាមនុស្សកាច។ គេមិនត្រូវទៅចូលរួមបុណ្យសពមនុស្សនោះ។ បើមានមនុស្សច្រើនទៅបុណ្យសព មុខជាគេថាមនុស្សនោះជាមនុស្សល្អ ជាមនុស្សគ្មានទោស។ បើមានមនុស្សតិចទៅបុណ្យគេថាមនុស្សនោះជាអ្នកមានទោស។ គាត់ជាមនុស្សកាច ជាធ្មប់។ គាត់បានបង្កឱ្យមានជម្ងឺ និងបញ្ហាដល់អ្នកជិតខាង និងដល់គ្រួសាររបស់គាត់។ មនុស្សផងទាំងពួងខឹងនឹងគាត់ ប៉ុន្តែគេខ្លាច។ ពេលស្រីខ្មៅធ្លាក់ខ្លួនឈឺ រូបអារក្សបាននិយាយថា គឺរូបគាត់ដែលបានធ្វើឱ្យស្រីខ្មៅឈឺ។ គាត់មានចរិតលក្ខណៈពិសេស។ គាត់មិននិយាយដូចអ្នកដទៃទេ។ គាត់ផ្លាស់ប្តូរអាកប្បកិរិយាជានិច្ច។ ពួកធ្មប់ យើងត្រូវសម្លាប់វា វាបង្កឱ្យមានរឿងឧបទ្រពច្រើនណាស់"។

(អ្នកស្រី យៀង អាយុ៤២ ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប (តុលា ១៩៩៤)

"មនុស្សនេះមកជួបខ្ញុំដើម្បីសុំឱ្យខ្ញុំការពារគាត់។ គាត់ថា គេចង់សម្លាប់គាត់។ ខ្ញុំមិនអាចធ្វើអ្វីដើម្បីជួយគាត់ទេ។ គាត់ជាធ្មប់។ ធ្មប់ជាពួកអាក្រក់។ វាបង្កើតបញ្ហាដល់មនុស្ស។ វាធ្វើឱ្យមនុស្សឈឺ។ មនុស្សនេះបានធ្វើឱ្យមនុស្សពីរនាក់ក្នុងភូមិស្លាប់។ គេត្រូវសម្លាប់ពួកធ្មប់ចោល"។

(លោក សាម៉ាល់ ប្រធានភូមិ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប(មករា ១៩៩៥))

## ១.៣. សន្ទនាជាមួយភាគីម្ខាងទៀត

ការនិយាយបញ្ហាជាមួយភាគីម្ខាងទៀតអាចធ្វើទៅបានជាពិសេស បើសិនជាបញ្ហាមួយកើតឡើងជាលើកដំបូង ហើយគេគិតថារកចំណុចត្រូវគ្នាបាន។ បើបញ្ហាកើតឡើងដដែលៗឬបើសិនគេមានអារម្មណ៍មិនស្រួលជាមួយម្នាក់ទៀតទេនោះ(មនុស្សដែលមានឋានៈខ្ពស់ជាង ឬដែលគេមិនសូវស្គាល់) គេសុំឱ្យអ្នកណាម្នាក់ក្នុងគ្រួសារ ឬ មិត្តភ័ក្រ្តណាម្នាក់ទៅជួបអ្នកម្ខាងទៀត ដើម្បីពិនិត្យបញ្ហា និងស្វង់រកចំណុចដែលធ្វើអាចទៅរួច។ តិរិយាបថនេះ ចៀសវាងការបាក់មុខក្នុងករណីមានការប្រកែកមិនព្រមទទួលយកការសំរុះសំរួល។

អ្នកស្រែម្នាក់ដែលមានតាំងលំនៅក្នុងភូមិថ្មីមួយ អាចធ្វើការសន្ទនាដោយត្រង់ៗជាមួយអាជ្ញាធរបានគ្រប់រឿងទាំងអស់។ អាជ្ញាធរអាចលាតត្រដាងបញ្ហាឱ្យគេដឹងឮគ្រប់ៗគ្នា។ ការធ្វើដូច្នេះ អាចទាក់ទាញឱ្យមានការគុំគួន។

"ខ្ញុំមកទីនេះដើម្បីបានដី។ អ្នកភូមិនិងអាជ្ញាធរជាមនុស្សមានការរៀនសូត្រ ហើយគេអត់អោនឱ្យគ្នាទៅវិញទៅមក។ កាលណាគេមានបញ្ហា មានការឈ្លោះប្រកែកគ្នា អ្នកខ្លះមានការអៀនខ្មាស់នឹងនិយាយអំពីបញ្ហារបស់ខ្លួន ហើយមិននិយាយអ្វីទាំងអស់ ហើយអ្នកដែលចង់ឈ្នះក៏ទៅជួបប្រធានក្រុម។ គេត្រូវគោរពឋានានុក្រមៈ ដំបូងគឺប្រធានក្រុម បន្ទាប់មកប្រធានភូមិ។ ចំពោះខ្ញុំ កាលណាខ្ញុំមានបញ្ហាជាមួយអ្នកណាម្នាក់ ខ្ញុំចូលចិត្តដោះស្រាយបញ្ហាទាំងនោះដោយផ្ទាល់ខ្លួន។ កាលណាគេប្ដឹងប្រធានក្រុម និងប្រធានភូមិ បន្ទាប់មកគេនឹងមានអារម្មណ៍មិនស្រួលជាមួយអ្នកជិតខាង។ វាអាចមានការគុំគួន។ កាលណាមានរឿងសរសេរចុះក្នុងបញ្ជីខ្មៅហើយ គេមិនអាចលុបវិញបានទេ។ រឿងនោះអាចធ្វើឱ្យគេខឹង។ កាលណាអ្នកណាម្នាក់ខឹង មនុស្សផងទាំងពួងខ្លាច។ គេមិនអាចដឹងថា មានអ្វីនៅក្នុងមនុស្សនោះទេ (មិនដឹងថាមនុស្សនោះគិតយ៉ាងម៉េចទេ) ហើយគេមិនអាចដឹងថាមនុស្សនោះនឹងធ្វើអ្វីមួយពេលក្រោយមកទៀត។ គេខ្លាចត្រូវបានសម្លាប់ បើកំហឹងនោះធំពេក។ ចំពោះខ្ញុំ ខ្ញុំព្យាយាមធ្វើស្លូតជាមួយអ្នកជិតខាង ហើយខ្ញុំចៀសវាងបញ្ហា។ កាលណាខ្ញុំមានបញ្ហា ខ្ញុំគិត។ បើអ្នកម្ខាងទៀតទាបជាងខ្ញុំ (មិនសូវមានការរៀនសូត្រ) ខ្ញុំត្រូវពន្យល់គាត់អំពីបញ្ហា ហើយពន្យល់គាត់ថា តើត្រូវដោះស្រាយយ៉ាងណា។ បើខ្ញុំនិយាយ ដោយភាពស្លូតបូត គាត់ស្ដាប់។ បើអ្នកម្ខាងទៀតខ្ពស់ជាងខ្ញុំ ខ្ញុំហ៊ាននិយាយថា "អ្វីដែលលោកធ្វើនោះ មិនត្រូវច្បាប់ទេ"។

(លោក សាម៉ាត អាយុ៤៥ ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត —ភូមិថ្មី)

ក៏ប៉ុន្តែ ការសន្ទនាតែងតែមានការពិបាកជានិច្ចនឹងទម្លុះឱ្យចេញដោយសារទម្ងន់នៃប្រពៃណី។

"ក្នុងជីវិតប្រចាំថ្ងៃ ជួនកាលមានបញ្ហាតិចតួចជាមួយអ្នកជិតខាង។ ខ្ញុំនៅស្ងៀមពីដំបូង។ ខ្ញុំមិននិយាយសោះ តែបន្ទាប់មក បើរឿងនោះរំខានខ្ញុំពេក ខ្ញុំព្យាយាមនិយាយរឿងនោះជាមួយអ្នកជិតខាង។ ជាគោលការណ៍ មនុស្សម្នាក់ៗចង់ទុកបញ្ហានៅក្នុងខ្លួន។ ពីមួយថ្ងៃទៅមួយថ្ងៃ គេបៀមទុកការឈឺចាប់ ហើយកាលណាវាផ្ទុះ គឺធ្ងន់ណាស់។ គេបង្រៀនយើងឱ្យនៅស្ងៀមចាប់តាំងពីក្មេងមកម្លេះ។ គេថាយើងត្រូវជៀសវាងបញ្ហា។ យើងព្យាយាមមិនជេរប្រមាថអ្នកដទៃ។ កាលណាយើងជាអ្នកតូច យើងត្រូវបង្អោនខ្លួនចំពោះមុខអ្នកធំ។ គេនិយាយថា អ្នកមាន មានទឹក

មាត់ប្រែ នេះមានន័យថា អ្នកមានអាចនិយាយអ្វីតាមចិត្តគេចង់។ គេក៏និយាយដែរថា អ្នកមានប្រាក់អាចធ្វើឱ្យខ្មោចរាំបាន នេះមានន័យថា គេអាចធ្វើអ្វីបានទាំងអស់"។
(លោក សយ អាយុ៤៨ឆ្នាំ ភ្នំពេញ)

### ១.៤. ការឈ្លោះគ្នាជាចំហ

បញ្ហាអាចរីកធំទៅជាឈ្លោះគ្នាបាន។ ការជេរប្រមាថគ្នាមានជារឿយៗ ហើយជូនកាលក្លាយទៅជាការវាយតប់គ្នា។ ក៏ប៉ុន្តែ មិនសូវមានរបួសទេ។ គេសង្កេតឃើញថា ការជេរប្រមាថគ្នាអាចចាត់ទុកថាសំខាន់ជាងរបួសផ្លូវកាយស្រាលទៅទៀត[១៣៦]។ ការសន្ទនាដោយត្រង់ៗមិនអាចធ្វើទៅបានទៀតឡើយ។ ស្ថានការណ៍អាចនៅ តែស្ទះនៅក៏រិតនោះ ឬក៏វិវត្តទៅតាមការស្នើសុំដោយភាគីណាមួយ។ គេនឹងស្វែងរកភាគីទីបីដើម្បីជួយស្រាយបញ្ហា។

## ២. រកជំនួយពីជនទីបី: ការសំរុះសំរួល

បញ្ហាតូចៗត្រូវបានដោះស្រាយក្នុងគ្រួសារ។ គេចូលចិត្តចាត់ចែងបញ្ហាឱ្យឆ្ងាយពីអ្នកដទៃ។ បើគេគិតថាបញ្ហានោះសំខាន់ គេសុំឱ្យមានវត្តមានភាគីទីបីដែលមានអំណាចគេទទួលស្គាល់។ នៅពេលនោះភាគីនោះនឹងមានតួនាទីជាអ្នកសំរុះសំរួល។ គេសង្ឃឹមថា អ្នកសំរុះសំរួលឱ្យដំបូន្មានហើយនិងដាក់ស្នើដំណោះស្រាយបើសិនជាមាន។ ស្ត្រី ដែលត្រូវប្តីវាយសុំឱ្យអ្នកសំរុះសំរួលប្រដៅទូន្មានប្តីរបស់ខ្លួន ដើម្បីកែឥរិយាបថប្តី ឬសុំលែងលះ បើសិនជាស្ថានការណ៍វាយ៉ាប់យ៉ឺនខ្លាំងពេក។ មានអ្នកដែលត្រូវការយុត្តិធម៌ ហើយក៏មានអ្នកកេងយកប្រយោជន៍ពីទំនាក់ទំនងល្អរបស់ខ្លួនជាមួយអ្នកសំរុះសំរួល ដើម្បីធ្វើការគាបសង្កត់លើភាគីម្ខាងទៀត។

ក្នុងកម្លុងពេលជួបសន្ទនានេះ យើងបានសង្កេតឃើញថា តួនាទីរបស់អ្នកសំរុះសំរួលធ្លាក់ត្រឹមប្រធានភូមិ។ គឺជាអាជ្ញាធររដ្ឋបាល ដែលគេទទួលស្គាល់មុនគេថាមានអំណាចចាត់ចែងជម្លោះនៅថ្នាក់មូលដ្ឋាន។ អំណាចនេះជាផ្នែកមួយនៃមុខងារផ្លូវការនៃអ្នកតំណាងរដ្ឋបាលមូលដ្ឋាន។ ដំបូន្មានរបស់ចាស់ទុំជូនកាលត្រូវបានគេស្នើសុំដែរ ប៉ុន្តែសំខាន់ក្នុងរឿងគ្រួសារ។ ពួកចាស់ទុំត្រូវបានគេចាត់ទុកមុនដំបូងគេបង្អស់ថាជាសាក្សីនៃរឿង។ មនុស្សខ្លះ ដែលមានកេរ្តិ៍ឈ្មោះថាជាអ្នកមានចំណេះដឹង ក៏អាចគេស្នើសុំឱ្យផ្តល់យោបល់ដែរ ដើម្បីធ្វើការសំរុះសំរួល(បើភាគីទាំងពីរទទួលស្គាល់) ឬដើម្បីធ្វើការគាបសង្កត់លើភាគីម្ខាងទៀតក្នុងឋានៈជាសាក្សី។

---

136 យើងបានរកឃើញករណីជាច្រើនដែលបង្ហាញឱ្យឃើញថា ការខូចខាតខាងផ្លូវកាយប្រសើរជាងការខូចខាតផ្លូវចិត្ត(ការជេរប្រមាថ)ដែល បណ្តាលឱ្យមានការបាក់មុខ ហើយនិងការដាក់ឱ្យនៅឆ្ងាយពីសង្គម។

ក្នុងពេលធ្វើអង្កេត យើងមិនបានជួបប្រទះករណីដែលលោកសង្ឃចូលពាក់ព័ន្ធដោយផ្ទាល់ក្នុងការចាត់ចែងជម្លោះគ្រួសារទេ។

## ២.១. នីតិវិធី

យើងបានរកឃើញថានីតិវិធីនៃការសំរុះសំរួលមានមូលដ្ឋានលើបែបបទដូចគ្នាពីកន្លែងមួយទៅកន្លែងមួយ ប៉ុន្តែមានការប្រែប្រួលបន្តិចបន្តួចទៅតាមបុគ្គលិកលក្ខណៈរបស់អ្នកសំរុះសំរួល។

យោងតាមនីតិវិធីដែលបានអនុវត្តរួម អ្នកប្ដឹងទៅនិយាយពីបញ្ហារបស់ខ្លួនឱ្យអ្នកសំរុះសំរួល(ដែលទទួលស្គាល់ដោយភាគីទាំងពីរ)ស្ដាប់។ បើអ្នកសំរុះសំរួលយល់ឃើញថា ករណីនោះចាំបាច់ឱ្យខ្លួនធ្វើអន្តរាគមគាត់នឹងកោះហៅភាគីជម្លោះទាំងសងខាងមកប្រជុំដើម្បីធ្វើការសំរុះសំរួល។ នៅពេលប្រជុំនោះ អ្នកសំរុះសំរួលសុំឱ្យភាគីម្ខាងៗរៀបរាប់រឿងហេតុរបស់ខ្លួន ហើយបន្ទាប់មកគាត់និយាយទៅគូជម្លោះទាំងពីរ។ គោលដៅរបស់អ្នកសំរុះសំរួលគឺត្រូវធ្វើឱ្យភាគីទាំងពីរសះជានឹងគ្នា។ ដូច្នេះ ហេតុផលរិះគន់របស់គាត់គឺផ្ដោតទៅរកទិសដៅនេះ។ នៅពេលចប់កិច្ចប្រជុំ បើរកឃើញការព្រមព្រៀង ឬបើកំហឹងស្ងប់ទៅវិញ ហើយដែលយល់ថាគេប្រកាន់ខ្ជាប់នឹងចំណុចនេះ ភាគីបង្ហាញការព្រមព្រៀងរបស់ខ្លួន ឬការយោគយល់គ្នាទៅវិញទៅមកតាមរយៈការយល់ព្រមជាពាក្យសំដី ឬការងក់ក្បាល ការសុំទោស ឬឃ្លាមួយដែលគួរសម។ ការប្រជុំចប់ដោយមានការញញឹមញញែម និងការនិយាយកំប្លែងលេង ដែលបញ្ជាក់ភាពសុខដុមរមនានឹងគ្នាឡើងវិញ។

ពេលណាការសំរុះសំរួលត្រូវធ្វើឡើងដោយអាជ្ញាធររដ្ឋបាល ហើយបើសិនជាបានដល់ការព្រមព្រៀងមួយចំណុចដែលសះជានឹងគ្នានោះ អាចឬមិនអាចចុះក្នុងលិខិតមួយដែលហៅថាលិខិតសន្យា។ លិខិតនេះ គេធ្វើជាភស្តុតាងនៃដំណោះស្រាយជម្លោះ ហើយជាការប្ដេជ្ញារបស់ម្នាក់ៗថានឹងគោរពតាមការសន្យាដែលខ្លួនបានធ្វើ។ ភាគីទាំងពីរព្រមទាំងសាក្សី ផ្ដិតមេដៃលើលិខិតនោះ។

បើគ្មានការព្រមព្រៀងគ្នាទេ ហើយគេនៅតែប្ដឹង គេអាចបើកប្រជុំផ្សេងៗទៀតដើម្បីសំរុះសំរួល។ ក្រោយពីព្យាយាមបីឬបួនដងដោយគ្មានលទ្ធផល បណ្ដឹងនោះត្រូវបញ្ជូនបន្តទៅឱ្យអាជ្ញាធរថ្នាក់លើបើភាគីមួយនៃភាគីទាំងពីរនៅរក្សាបណ្ដឹងនោះ។

នៅក្នុងរយៈពេលជួបពិភាក្សា មនុស្សច្រើនគ្នាបានបញ្ជាក់ហើយបញ្ជាក់ទៀតថា ការសំរុះសំរួលនេះមិនមែនជាសាលក្រមទេ។ ការសំរុះសំរួលមិនស្វែងកំណត់ថា អ្នកណាជាអ្នកខុស ហើយអ្នកណាជាជនរងគ្រោះទេ ដែលមានន័យនៅទីនេះថាជា"អ្នកចាញ់" និង"អ្នកឈ្នះ"។ ការសំរុះសំរួលនាំភាគីទាំងពីរទៅរកការព្រមព្រៀងមួយ ដែលម្នាក់ៗត្រូវខំប្រឹងប្រែង ដើម្បីខិតទៅរកម្នាក់ទៀត។

"ការសំរុះសំរួលមានមូលដ្ឋានលើរឿងហេតុ។ គេស្តាប់ភាគីទាំងពីរ ហើយគេស្នើដំណោះស្រាយ។ គ្មានអ្នកណាឈ្នះ គ្មានអ្នកណាចាញ់ទេ"។

(លោកសម្បត្តិ អាយុ៥៥ឆ្នាំ ប្រធានសង្កាត់ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ភ្នំពេញ)

ជាគោលការណ៍ ការសំរុះសំរួលធ្វើនៅផ្ទះអ្នកសំរុះសំរួល ឬ នៅកន្លែងវិវាទ ជាពិសេសចំពោះករណីជម្លោះដីធ្លី។ គ្រួសារ ឬ សាក្សីដែលស្នើសុំដោយភាគី អាចឬមិនអាចមានវត្តមាន អាស្រ័យទៅលើសេចក្តីសំរេចរបស់ប្រធានភូមិ។

## ២.២. អ្នកសំរុះសំរួល

### អ្នកសំរុះសំរួលក្រៅផ្លូវការ

កាលណារឿងមិនសំខាន់ណាស់ណា ឬ ក៏រឿងនោះនៅអាចនិយាយគ្នាបាន ភាគីមួយ ឬភាគីទាំងពីរ រកអ្នកសំរុះសំរួលដែលនៅជិត។ កិច្ចប្រជុំដើម្បីសំរុះសំរួល អាចធ្វើទៅបានលុះត្រាណាតែភាគីទាំងពីរទទួលស្គាល់អំណាចរបស់អ្នកសំរុះសំរួល។ អ្នកសំរុះសំរួលនោះ អាចជាព្រឹទ្ធាចារ្យនៃគ្រួសារធំដែលនៅជុំគ្នា ជាអតីតអ្នករាជការ ឬជាមនុស្សមានការរៀនសូត្រ ជាអ្នកតំណាងមូលដ្ឋាននៃគណបក្សនយោបាយមួយ ឬជាអ្នកតំណាងសមាគម(កំរមានអង្គការមកពីខាងក្រៅណាស់)។

<u>មេគ្រួសារ</u>

មេគ្រួសារមានតួនាទីសំខាន់ ក្នុងករណីគ្រួសារធំៗដែលគោរពព្រឹទ្ធាចារ្យរួម។ យើងបានរកឃើញថា ព្រឹទ្ធាចារ្យរួមនេះ ទាក់ទងជាពិសេសនឹងគ្រួសារចិនកាត់ខ្មែរ ដែលភាគច្រើនមាននៅទីក្រុង។ នៅស្រុកស្រែ អំណាចរបស់ជីដូនជីតាមិនសូវបានទទួលស្គាល់ទេ ហើយមានតែកាលពីអតីតកាលទេដែលគេស្តាប់គាត់។

"គេចូលចិត្តដោះស្រាយបញ្ហាក្នុងគ្រួសារ។ គេខ្លាចប្រធានភូមិ ទោះបីគេមិនបានបង្កបញ្ហាក្តី។ បើគេចង់ទៅតុលាការដោយត្រង់ៗតែម្តង មេភូមិនៅកន្លែងនេះមិនសប្បាយចិត្តទេ។ គាត់នឹងនិយាយថា ធ្វើដូច្នេះ គឺខុសច្បាប់ ហើយបើយ៉ាងណាៗនៅពេលក្រោយគាត់នឹងមិនរវល់នឹងយើងទៀតឡើយ"។

(អ្នកស្រី សែន អាយុ៣៥ ឆ្នាំ ឃុំត្រពាំងភ្លាំង ខេត្តកំពត — ភូមិថ្មី)

"គ្រួសារជួយដោះស្រាយបញ្ហាផ្ទៃក្នុងតូចតាច។ បើរឿងនេះត្រូវបានដោះស្រាយខាងក្នុងគ្រួសារ គឺជាការល្អណាស់។ ប៉ុន្តែ ឧទាហរណ៍ នៅក្នុងករណីជម្លោះប្តីប្រពន្ធ គ្រួសារខាងប្រពន្ធនឹងកាន់ជើង និងការពារប្រពន្ធ ហើយគ្រួសារខាងប្តីនឹងកាន់ជើងប្តី ជាពិសេសក្នុងករណីប្តីប្រពន្ធក្មេងៗ។ ជម្លោះតូចតាចក្លាយទៅជាធំរវាងគ្រួសារទាំងពីរ។ គ្រួសារម្ខាងស្តីបន្ទោសគ្រួសារម្ខាងទៀតថា មានកូនអាក្រក់"។ (អ្នកស្រី ចាន់ អាយុ៤២ ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

"ជាងឈើម្នាក់ឈ្មោះតាហឿន ជាមនុស្សមានកេរ្តិ៍ឈ្មោះ។ គាត់មានគ្រួសារធំ ហើយគាត់ដោះស្រាយបញ្ហាទាំងអស់ដែលប៉ះពាល់គ្រួសារគាត់។ គាត់មានអំណាចជាងប្រធានភូមិទៅទៀត។ ប្រធានភូមិនោះជាមនុស្សស្លូត។ តាហឿន មានអាយុច្រើនជាង។ ពីមុនគាត់បួសជាលោកសង្ឃនៅវត្ត ហើយគាត់ចេះច្រើនណាស់ទាក់ទងនឹងរឿងជាងឈើ និងសាសនា"។
(លោកវេត អាយុ៥៧ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅទីនេះ មានគ្រួសារជាច្រើនជាកូនកាត់ចិនខ្មែរ។ គ្រួសារជារឿងសំខាន់សំរាប់ពួកចិន។ ពួកគេចេះច្បាស់ក្នុងការដោះស្រាយបញ្ហារវាងពួកគេ។ ក្នុងជម្លោះដប់គ្រួសារដែលជាប់ខ្សែចិន ដោះស្រាយបានទាំង១០ ចំណែកឯគ្រួសារដែលមានវង្សត្រកូលជាខ្មែរ ដោះស្រាយបានតែប្រាំបីទេ"។
(លោកធុំ អាយុ៥០ ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

ប្រធានសមាគមជាតិខាងមីក្រូឥណទានមានតួនាទីជាអ្នកសំរុះសំរួលក្នុងភូមិ ប៉ុន្តែគេធ្វើជាអ្នកសំរុះសំរួលសំរាប់តែសមាជិករបស់សមាគមប៉ុណ្ណោះ។

"ខ្ញុំធ្វើការសំរុះសំរួលក្នុងបណ្តាសមាជិកនៃសមាគម។ ខ្ញុំអប់រំប្តីនិងប្រពន្ធ ហើយក្នុងពេលប្រជុំខ្ញុំនិយាយអំពីហិង្សានិងសាមគ្គីភាព។ ខ្ញុំពឹងផ្អែកលើក្បួនច្បាប់ប្រពៃណីផង និងក្បួនច្បាប់របស់សមាគមផង។ ប្រធានភូមិយល់ព្រមឱ្យសមាគមធ្វើសកម្មភាពរបស់ខ្លួន ព្រោះយើងមានការយល់ព្រមពីក្រសួងមហាផ្ទៃ"។
(លោកសារិន អាយុ ៥៩ឆ្នាំ ប្រធានសមាគមឥណទានតូចៗ និងអភិវឌ្ឍន៍ជនបទ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ជំនួយរបស់មនុស្សម្នាក់ខាងក្រៅដែលមានឥទ្ធិពលដល់គ្រួសារអាចស្នើសុំបាន ប៉ុន្តែចំពោះតែករណីដោះស្រាយបញ្ហាមិនបាន។ ជំនួយនេះអាចនឹងត្រូវច្រានចោលដោយគ្មានដឹងគុណបន្តិចបន្តួចសោះ។ ដូច្នេះគេចេះចាំ ថាមិនត្រូវឡូកឡំនឹងកិច្ចការអ្នកដទៃទេ ដោយខ្លាចថា នៅពេលក្រោយគេនឹងត្រូវចោទប្រកាន់ថាលំអៀង បើសិនជាការដោះស្រាយនោះប្រែជាមិនល្អ។ ការបាក់មុខនៅចំពោះអ្នកណាម្នាក់ពីខាងក្រៅអាចនាំឱ្យគេច្រានមនុស្សនោះចោល។

"ក្មេងស្រីម្នាក់នៅក្នុងភូមិរៀបការជាមួយបរទេសម្នាក់។ ដោយហេតុថា ខ្ញុំរស់នៅប្រទេសបារាំងគ្រួសារខាងស្រីបានសុំឱ្យសុំជួយ ពីព្រោះកូនស្រីក្បាលរឹង។ កូនស្រីនោះមិនចង់ដេកជាមួយបរទេសនោះទេ ហើយបរទេសនោះបាននិយាយថា បើកូនស្រីមិនដេកជាមួយខ្លួន ដូច្នេះនាងនឹងមិនបានបណ្ណាការទេ។ ខ្ញុំបាននិយាយទៅកូនស្រីថា នាងភ្លើ ហើយថាបើនាងដេកកុំឱ្យមានរឿងនាងនឹងបានអ្វីដែលនាងចង់បាន ពីព្រោះបរទេសនោះចាស់ហើយជាអ្នកមាន។ ម្តាយយល់ព្រម គាត់គំរាមកូនគាត់។ កូនស្រីដែលភ្លីភ្លើនៅតែរឹងចចេស។ បរទេសនោះឡើយណាយនឹង

នាងក៏សុំលែងលះ។ កូនស្រីនោះក៏ព្រម ប៉ុន្តែក្រោយមកនាងមិនសប្បាយចិត្តទេ ពីព្រោះបរទេសនោះមិនបានទិញម៉ូតូនិងផ្ទះឱ្យ។ នាងចង់បានប្រាក់ ប៉ុន្តែនាងមិនព្រមរាបសារនឹងគាត់ទេ។ បន្ទាប់មកបរទេសក៏បកមករកសេចក្តីសំរេចរបស់គាត់វិញ ហើយគាត់និយាយមកខ្ញុំ ឱ្យខ្ញុំសួរទៅនាងស្រីនោះថា តើនាងចង់មករកគាត់វិញឬយ៉ាងណា។ នាងនោះខឹងគាត់ណាស់ ហើយមិនចង់បានគាត់ទេ។ បរទេសនោះអស់តិរះ ហើយបែរមកស្រឡាញ់ក្មេងស្រីម្នាក់ ដែលធ្វើការនៅក្បែរផ្ទះខ្ញុំ។ គាត់បានរៀបការជាមួយនាង ហើយនាងនោះមានផ្ទៃពោះហើយ។ បរទេសនោះសប្បាយចិត្តណាស់។ ឥឡូវនេះ នាងស្រីទីមួយនោះខឹងនឹងខ្ញុំសម្បើមណាស់។ គាត់ហៅខ្ញុំថាជាស្រីគំរក់ស្រីសំផឹង និងការជេរប្រទេចខ្ញុំដោយពាក្យផ្សេងៗទៀតនៅមុខមនុស្សទាំងអស់ ថ្វីបើខ្ញុំបានព្យាយាមជួយនាងយ៉ាងណាក៏ដោយ។ នាងនេះពិតជា សត្វតិរច្ឆានមែន! គ្រួសារនាងនោះក៏គាត់ប្រឆាំងនឹងខ្ញុំដែរ ព្រោះគេមិនបានប្រាក់ពីបរទេសនោះ។ ខ្ញុំប្តឹងទៅប្រធានឃុំ។ ប្រធានឃុំប្រាប់នាងស្រីនោះឱ្យសុំទោសខ្ញុំ ហើយបង់ប្រាក់ឱ្យខ្ញុំ ១០០,០០០រៀល ដោយសារជេរប្រមាថខ្ញុំ។ ខ្ញុំបានសំរេចថា មិនយកប្រាក់ទេ តែទាមទារឱ្យសុំទោសខ្ញុំ"។

(អ្នកស្រី ឆុន អាយុ ៥២ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប —សីហា ២០០០)

ចាស់ទុំ

ដោយសារអំណាចធំត្រូវបានប្រគល់ដោយគណបក្សនយោបាយសម្លេងភាគច្រើនទៅប្រធានភូមិ និងមួយផ្នែកទៀតដោយហេតុមកពីសម័យចលាចល ដែលធ្វើឱ្យមានការបាក់ស្រុតជាខ្លាំងនូវចំណងសង្គមជាពិសេសរវាង ជំនាន់មួយទៅជំនាន់មួយ តួនាទីរបស់ចាស់ទុំមិនសូវគេលើកតំកើងដូចពីអតីតកាលទេ។

"ក្នុងសម័យសង្គមរាស្ត្រនិយម គេអាចសុំជំនួយពីចាស់ទុំ ប៉ុន្តែឥឡូវនេះមិនដូច្នេះទេ។ ពីដើមគេសុំឱ្យ ចាស់ទុំធ្វើជាសាក្សី។ គេមានទំនុកចិត្តលើពាក្យសំដីរបស់គាត់។ ឥឡូវនេះ គេលែងសុំឱ្យគាត់ជួយទៀតហើយ ព្រោះមិនសូវមាន ចាស់ទុំដែលមានសមត្ថភាពជួយ ហើយឥឡូវនេះគេស្វែងរកនីតិវិធីរដ្ឋបាលច្រើនជាង"។

(លោកសារិន អាយុ៥៩ឆ្នាំ ប្រធានសមាគមមីក្រូឥណទាន និងអភិវឌ្ឍន៍ជនបទ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

"គេអាចសុំជំនួយពីចាស់ទុំ ប៉ុន្តែមានតែមនុស្សជំនាន់មុនទេដែលគោរពចាស់ៗ ក្មេងឥឡូវគេលែងស្តាប់ចាស់ៗទៀតហើយ។ ក្មេងៗមើលវីឌីអូច្រើនណាស់។ ក្មេងៗមិនទៅវត្តទេ។ លោកនេនមិនចេះអ្វីទេ ហើយក៏បួសមិនយូរប៉ុន្មាននៅវត្តដែរ"។

(លោក សាវេត អាយុ៥០ឆ្នាំ ប្រធានភូមិ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

ដោយហេតុមកពីសង្គ្រាម ចំនួនមនុស្សដែលមានអាយុជាចាស់ទុំបានថយចំនួន។ នៅភូមិថ្មីដែលភាគច្រើន មានប្រជាជនក្មេងៗមិនមាន ឬមានចាស់ទុំតិចណាស់។

"នៅទីនេះ ក្នុងភូមិនេះគ្មានចាស់ទុំដែលចេះដឹងទេ។ គេអាចសុំជំនួយពីចាស់ទុំ ប៉ុន្តែគាត់មាន តួនាទីត្រឹមតែជាសាក្សីប៉ុណ្ណោះ"។

(អ្នកស្រី សារី អាយុ ២៨ ឆ្នាំ ឃុំអង្គាល់ ក្រុងកែប ខេត្តកំពត)

របបខ្មែរក្រហមដែលបានរំលំក្បួនច្បាប់សង្គមបានបើកផ្លូវឱ្យមានសភាពការណ៍ដូច្នេះ គឺក្មេងកើតជំនាន់ ខ្មែរក្រហមមិនគោរពចាស់ទុំទេ។

"ឥឡូវនេះ គេនិយាយថា មានភាពស្មើគ្នារវាងមនុស្សចាស់និងក្មេង។ គេនិយាយថា មនុស្សទាំង អស់ស្មើភាពគ្នា។ មិនគួរឱ្យជឿទាល់តែសោះ។ ហេតុដូច្នេះ ហើយបានជាក្មេងលែងស្តាប់ចាស់។ ពីមុនកូនគោរពឪពុក ម្តាយ។ ក្នុងជំនាន់ប៉ុលពត កូនត្រូវគេបំបែកចេញពីឪពុកម្តាយ ហើយបាន រៀនរឿងអាក្រក់ៗ។ ឥឡូវនេះ វាធំអស់ហើយ ហើយគេលែងគោរពយើងទៀតហើយ។ ពីមុន ក្មេងទៅវត្ត ឥឡូវមានតែចាស់ៗទេដែលទៅ។ ពីមុនកាលណាគេត្រូវការដំបូន្មាន និងចង់ជួប សំរុះសំរួល គេទៅរកចាស់ទុំនិងប្រធានភូមិ។ គាត់នៅជិតយើង។ ឥឡូវនេះគឺ ប្រធានភូមិដែល ជាអ្នកដោះស្រាយគ្រប់រឿងទាំងអស់ គាត់ជាមនុស្សបានតែមាត់ ជាមនុស្សធូរធា ជានាហ្មឺន។ បើមានគេសុំឱ្យខ្ញុំជួយដោះស្រាយបញ្ហា ខ្ញុំនឹងធ្វើការសំរុះសំរួល។ ខ្ញុំប្រាប់ពួកគេថា "បើអ្នកឯង ទៅឃុំ ទៅស្រុក ឬទៅតុលាការ តើអ្នកឯងត្រូវចាយលុយប៉ុន្មាន?"។ យកល្អត្រូវដោះស្រាយ បញ្ហាក្នុងភូមិ។ នៅក្នុងភូមិ គេមិនបាច់ចាយលុយទេ។ ប្រធានភូមិបានសុំខ្ញុំ២ ឬ៣ ដងឱ្យខ្ញុំមក ជួយគាត់ក្នុងពេលសំរុះសំរួល។ រឿងនេះកំរណាស់"។

(លោកជ្រុយ អាយុ៧២ ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

ប្រធានភូមិម្នាក់សំគាល់ឃើញថា ចាប់តាំងពីសម័យខ្មែរក្រហមមក ចាស់ទុំខ្លាចមិនហ៊ានធ្វើអន្តរាគមក្នុង ជម្លោះខាងក្រៅគ្រួសារគាត់ឡើយ ដោយខ្លាចមានការសងសឹក។

"ពីមុនគេគោរពចាស់ទុំ គាត់មិនខ្លាចអ្នកណាទេ។ គាត់អាចនិយាយបាន។ ឥឡូវនេះ បើខ្ញុំសុំឱ្យ ចាស់ទុំមកជួយខ្ញុំក្នុងពេលសំរុះសំរួល គាត់មិនមកទេ។ ដូចមនុស្សភាគខ្លះដទៃទៀតក្នុងភូមិដែរ ចាស់ទុំខ្លាចមិនហ៊ានឡូកឡំនឹងរឿងអ្នកដទៃទេក្នុងពេលនេះ។ សង្គមរិតតែតឹងតែងទៅ។ គេ លែងគោរពចាស់ទុំដូចពីមុនទៀតហើយ។ បើចាស់ទុំនិយាយអ្វីមួយដែលផ្ទុយនឹងផលប្រយោជន៍ អ្នកណាម្នាក់ គាត់អាចនឹងមានបញ្ហា។ ក្មេងៗលែងខ្លាចមនុស្សចាស់ទៀតហើយ។ គេមិនសួរ

គោរពចាស់ទុំទេ ហើយគេគិតតែខ្លួនឯង។ ចាស់ទុំខ្លាចគេធុញទ្រាន់ បើគាត់និយាយ។ គឺចាប់ពីប៉ុល ពត មក។ គេលែងហ៊ាននិយាយអ្វីប្រឆាំងនឹងមនុស្សទៀតហើយ។ ចាស់ៗខ្លាចគេសងសឹក។ គាត់យកតែរួចខ្លួន គាត់ស្តាប់ តែគាត់មិនហ៊ានធ្វើអន្តរាគម។

(អ្នកស្រី សារេត អាយុ៦៥ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

<u>នាទីរបស់ព្រះសង្ឃ</u>

ចៅអធិការវត្ត ដែលយើងបានជួបបានបែងចែកយ៉ាងច្បាស់រវាងកិច្ចការរបស់គ្រហស្ថ និងកិច្ចការរបស់សហគមន៍សង្ឃ។ លោកមិនតាំងខ្លួន មិនពាក់ព័ន្ធ ឬ មិនបានស្នើសុំពីគ្រហស្ថឱ្យដោះស្រាយបញ្ហាគេទេ។ ក៏ប៉ុន្តែ នៅក្នុងវត្តអារាម វិន័យតឹងរឹងណាស់ ហើយវិន័យនេះត្រូវស្ថិតក្រោមបទបញ្ជាដែលមានចែងក្នុងសៀវភៅវិន័យ។ ចៅអធិការចាត់ចែងដោះស្រាយជម្លោះផ្ទៃក្នុងសហគមន៍សង្ឃ។ ស្របនឹងការបង្រៀនគោលការណ៍ពុទ្ធសាសនា បទបញ្ជានោះដែលគ្រប់គ្រងអាកប្បកិរិយាអាក្រក់ និងការដាក់ទណ្ឌកម្មដែលចេញពីអាកប្បកិរិយានោះ ចូលរួមក្នុងការបង្ការបញ្ហាផ្ទៃក្នុងរបស់វត្តអារាម។

"អាត្មាមានអំណាចដោះស្រាយតែបញ្ហាផ្ទៃក្នុងរបស់វត្តប៉ុណ្ណោះ។ យើងសូត្របទវិន័យរបស់ព្រះពុទ្ធសាសនាជានិច្ច ហើយព្រះសង្ឃទាំងអស់ស្គាល់បទវិន័យនោះ គឺកុំសម្លាប់មនុស្ស ឬសត្វ កុំលួចគេ កុំប្រព្រឹត្តកាម កុំផឹកស្រា និងអ្វីផ្សេងៗទៀតជាច្រើន។ មានកំហុសពីរយ៉ាង។ មួយៈ មិនគោរពបទវិន័យ។ ពីរៈ ឈ្លោះគ្នារវាងសង្ឃ។ នៅក្នុងវត្ត អាត្មាដោះស្រាយភាគច្រើនបញ្ហាជម្លោះរវាងសង្ឃ។ បើសិនជាជម្លោះធ្ងន់ធ្ងរ អាត្មាសុំឱ្យសង្ឃពីរអង្គមកជួបអាត្មា ហើយអាត្មាឱ្យលោកទាំងពីរអង្គនោះធ្វើអ្វីទៅតាមគោលការណ៍សន្តិភាព។ លោកសង្ឃពីរអង្គទៀតជួយអាត្មា ហើយអាត្មាសុំយោបល់លោកដើម្បីវិនិច្ឆ័យរឿង។ បើមានរឿង មានដាក់ទណ្ឌកម្មដូចជាឱ្យបោចស្មៅ ឬ រែកទឹកដាក់ពាង។

រាល់ល្ងាច មានប្រជុំមួយក្រោយពេលសូត្រធម៌នៅពេលល្ងាច។ អាត្មាឱ្យដំបូន្មានដល់លោកសង្ឃកុំឱ្យធ្វើខុស។ មានប្រព័ន្ធមួយដើម្បីឃ្លាំមើលសង្ឃគ្នាឯង។ នៅថ្ងៃសីល លោកសង្ឃផ្តុំជាក្រុមពីបីទៅបួនអង្គ ហើយមានពុទ្ធដីកាម្តងមួយអង្គៗ អង្គណាបានធ្វើអាក្រក់ និងធ្វើអ្វីផ្សេងទៀត។ ការធ្វើដូច្នេះជួយរក្សាសន្តិភាព និងបង្កាបញ្ហា"។

(ចៅអធិការវត្ត ព្រៃតាកុយ ជន្មាយុ ៣០វស្សា សង្កាត់អង្កោល ក្រុងកែប ខេត្តកំពត)

"អាត្មាធ្វើការដោះស្រាយជម្លោះផ្ទៃក្នុងវត្តអារាម ប៉ុន្តែអាត្មាមិនរវល់នឹងបញ្ហារបស់មនុស្សនៅខាងក្រៅទេ។ មានធម៌សំរាប់ការប្រព្រឹត្តរបស់ព្រះសង្ឃ។ កំហុស និងទណ្ឌកម្មសំរាប់កំហុសនោះមានសរសេរទាំងអស់។ ដើម្បីចៀសវាងកំហុស មានវិធីមួយដើម្បីសង្កេតគ្នាទៅវិញទៅមករវាង

ព្រះសង្ឃ។ យើងចាប់គូរគ្នា ភិក្ខុមើលសាមណេរ។ នៅថ្ងៃសីលយើងធ្វើការប្រជុំ ហើយយើងអប់រំសង្ឃឱ្យស្រឡាញ់គ្នាដូចបងប្អូន ឱ្យរួមសាមគ្គីគ្នាដូចម្រាមដៃ។ យើងជំរុញឱ្យអាន និងហាត់រៀនធម៌ព្រះពុទ្ធ ហើយយើងប្រាប់ឱ្យរួមសាមគ្គីគ្នាដូចត្រីនិងទឹក។ អាត្មា សួរលោកសង្ឃឱ្យនិយាយប្រាប់ថា មានអ្វីកើតឡើងខ្លះក្នុងសប្តាហ៍។ បើលោកសង្ឃមួយអង្គខឹងនឹងមួយអង្គទៀត អាត្មាសួររកហេតុផលគ្រប់អង្គ។ បើលោកសារភាពហេតុផល អាត្មាឱ្យដំបូន្មាន និងអប់រំលោកដោយពន្យល់ពីសាមគ្គីភាព។

មានទណ្ឌកម្ម។ ព្រះសង្ឃដែលធ្វើខុស ជាឧទាហរណ៍ ត្រូវរែកទឹកបំពេញពាង បោចស្មៅ ឬជីកស្រះ។ បើព្រះសង្ឃណាបានធ្វើកំហុសធំហើយមិនសារភាព អាត្មាអាចហៅអាចារ្យប្រធានភូមិនិងប្រធានឃុំមកពិចារណា ដើម្បីសុំឱ្យលោកចាកសិក្ខាបទ។ ប៉ុន្តែរឿងនេះមិនងាយមានទេ។ អាត្មាបានឮគេនិយាយធ្លាប់មានរឿងដូច្នេះកាលពីដើម។ បើមានកំហុសធ្ងន់ គេចូលចិត្តទុករឿងរវាងគ្នាឯង ដើម្បីកុំឱ្យខូចកេរ្តិ៍ឈ្មោះរបស់វត្ត"។

"នៅថ្ងៃសីល មានតែចាស់ៗទេដែលមកវត្ត។ គេនិយាយគ្នាពីរឿងសាសនា និងវប្បធម៌។ នៅក្នុងវត្ត គេដោះស្រាយតែបញ្ហារបស់វត្ត មិនមែនបញ្ហាខាងក្រៅវត្តទេ។ មានបញ្ហាតូចតាចដែលកើតឡើង ភាគច្រើនជាមួយនឹងលោកនេន។ ឧទាហរណ៍ បើសាមណេរមួយអង្គបានចាកចេញពីវត្តដោយគ្មានការអនុញ្ញាតអាត្មានឹងកោះហៅសាមណេរហើយពន្យល់ថា អាកប្បកិរិយារបស់លោកមិនល្អទេ។ យើងធ្វើការសំរុះសំរួលទៅតាមធម៌ព្រះពុទ្ធ។ ក្នុងករណីមានបញ្ហាធំ យើងប្រជុំសង្ឃទាំងអស់ ហើយយើងនិយាយអំពីបញ្ហាដើម្បីឱ្យទាំងអស់គ្នាយល់។ អាត្មាសុំឱ្យអ្នកដែលធ្វើកំហុសរៀបរាប់អំពីកំហុសរបស់ខ្លួននៅចំពោះមុខទាំងអស់គ្នា។ កាលណាសង្ឃសារភាពកំហុសរបស់ខ្លួន អាត្មាឱ្យដំបូន្មានដល់សង្ឃនោះ ហើយសង្ឃដទៃទៀតក៏ស្តាប់ដែរ។ នៅថ្ងៃសីល យើងនិយាយអំពីកំហុសដែលបានប្រព្រឹត្ត ហើយយើងរំលឹកពីគោលការណ៍ព្រះពុទ្ធសាសនា"។
(ចៅអធិការវត្ត ភ្នំលីវ សង្កាត់ពងទឹក ខេត្តកំពត)

អ្នកដែលស្ថិតក្នុងស្ថានភាពពិបាកអាចមកវត្ត ដើម្បីស្វែងរកការពន្យល់ និងការធ្វើឱ្យរសាយតាមរបៀបសាសនា។

"អាត្មាមិនអាចធ្វើការសំរុះសំរួលរវាងគ្រួសារបានទេ ប៉ុន្តែអាត្មាបានធ្វើឱ្យទុក្ខលំបាកនិងជម្ងឺរបស់គេបានធូរស្រាល។ មនុស្សម្នាមកទីនេះ កាលណាគេមានបញ្ហាសុខភាព ប៉ុន្តែគេមិនឱ្យអាត្មាដោះស្រាយបញ្ហាគ្រួសារទេ។ គេមកដើម្បីព្យាបាលជម្ងឺផ្លូវកាយ និងជម្ងឺផ្លូវចិត្ត។ ដើម្បីព្យាបាលជម្ងឺនេះ

គេធ្វើពិធីស្រោចទឹកមន្ត ឬពិធីដេញខ្មោចបិសាច គេធ្វើខ្សែគាថា និងផ្សំថ្នាំ។ យើងសូត្រធម៌ពុទ្ធសាសនា។ លោកសង្ឃយកចិត្តទុកដាក់នឹងផ្លូវសាសនា និង ផ្លូវងងឹត។ លោកមិនយកចិត្តទុកដាក់នឹងផ្លូវសំភារៈរបស់មនុស្សទេ។ ជម្ងឺទាំងនោះ គឺជាជម្ងឺដែលធ្លាប់និងខ្មោចធ្វើ។ គេធ្វើពិធីសាសនាដើម្បីដេញឥទ្ធិពលអាក្រក់។ ចំពោះជម្ងឺតូចតាច គេផ្សំថ្នាំ។ នៅពេលមនុស្សសុំធ្វើពិធីសាសនា អ្នកខ្លះរៀបរាប់រឿងរបស់ខ្លួនដោយលំអិត ហើយអ្នកខ្លះទៀតសុំធ្វើពិធីដោយគ្មានពន្យល់ថាហេតុអ្វី។ អាចមានគេសុំឱ្យជួយសំរុះសំរួលគ្នាដែរ។ កាលណាយើងមកដល់ភូមិចំពេលមានបញ្ហា យើងអាចនិយាយបានខ្លះ។ ផ្ទុយទៅវិញ យើងមិនធ្វើអន្តរាគមទេ។ ដើម្បីបន្ធូរការឈ្លោះប្រកែកគ្នា យើងប្រើពាក្យដកស្រង់ចេញពីសាសនាព្រះពុទ្ធ។ អាត្មានិយាយថា "អាត្មាសុំកុំឱ្យញោមឈ្លោះប្រកែកគ្នា យើងត្រូវអត់អោនឱ្យគ្នា។ ញោមជាអ្នកជិតខាងនឹងគ្នា វាធម្មតាទេដែលសត្វស៊ីដំណាំ។ សូមឱ្យអត់អោនគ្នា ហើយរស់នៅដោយសុខនឹងគ្នា"។

(ចៅអធិការវត្តព្រៃតាកុយ ជន្មាយុ៣០វស្សា សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

"គេសុំដំបូន្មានពីព្រះសង្ឃតែកាលណាមានរឿងជាមួយមនុស្សក្នុងគ្រួសាររបស់គេ។ ព្រះសង្ឃឱ្យដំបូន្មានទូទៅ ប៉ុន្តែមិនចូលក្នុងរឿងគ្រហស្ថទេ។ ព្រះសង្ឃមានដីកាថា "បើញោមខឹង ញោមត្រូវស្ងប់ស្ងាត់" "បើញោមក្រ ញោមត្រូវធ្វើការ" "បើញោមធ្វើល្អ ញោមនឹងបានបុណ្យ" "បើញោមក្រក្នុងជាតិនេះ ក៏ព្រោះតែញោមមានកម្មពីជាតិមុន"។ ឥឡូវនេះ ញោមត្រូវប្រឹងប្រែងធ្វើអំពើល្អ ដើម្បីជាតិមុខ"។

(លោកសាវេត អាយុ៥០ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

ប្រធានភូមិម្នាក់ឱ្យដំបូន្មានដល់ប្តីប្រពន្ធដែលស្ថិតក្នុងសភាពលំបាកឱ្យគោរពសាសនា ស្តាប់ពាក្យសំដីព្រះសង្ឃ។

"កាលណាជម្លោះប្តីប្រពន្ធស្ងប់ស្ងាត់ទៅ ខ្ញុំឱ្យដំបូន្មានដល់ប្តីប្រពន្ធទៅវត្តដើម្បីស្តាប់ការប្រៀនប្រដៅរបស់ព្រះសង្ឃ។ ខ្ញុំឱ្យដំបូន្មានដល់គេឱ្យធ្វើទាននៅវត្ត និងសុំសីលដើម្បីដេញឧបទ្រពចង្រៃ និងត្រឡប់មកភាពស្ងប់ស្ងាត់វិញ"។

(លោកតៃ អាយុ៤៨ឆ្នាំ ប្រធានភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

តទៅនេះ ជាមនោសញ្ចេតនារបស់សមាជិកបុគ្គលិកអង្គការសិទ្ធិមនុស្សមួយ។

"ព្រះសង្ឃអាចដើរតួជាអ្នកបន្ធូរបរិយាកាសក្នុងគ្រួសារ។ លោកមិនជួយដោះស្រាយបញ្ហាទេ ប៉ុន្តែទូន្មាន ជាពាក្យសំដីឱ្យស្ងប់ស្ងាត់ និងអត់អោនគ្នាទៅវិញទៅមក។ អ្នកដែលកាន់ធម៌ព្រះពុទ្ធធ្វើតាមគោលការណ៍ព្រះពុទ្ធ ហើយនឹងមានឥរិយាបថស្ងប់ស្ងាត់។

ប៉ុន្តែ ឥទ្ធិពលរបស់ព្រះសង្ឃចុះថយ ពីព្រោះលោកមិនបានកាន់វិន័យត្រឹមត្រូវ។ ប្រពៃណីហាមឃាត់ព្រះសង្ឃមិនឱ្យទទួលលុយដោយផ្ទាល់ទេ។ ឥឡូវនេះ គេប្រគេនប្រាក់ដោយត្រង់ៗដល់ព្រះសង្ឃ កាលណាគេនិមន្តលោកមកឱ្យសូត្រមន្ត។ កាលណាមានបញ្ហាគេអាចប្រគេនប្រាក់ឱ្យលោកដើម្បីឱ្យលោកសូត្រមន្តនាំសុភមង្គល និង បន្ថយបញ្ហា"។

(លោក សម អ្នកស៊ើបអង្កេតអង្គការសិទ្ធិមនុស្សមួយ អាយុ៣២ឆ្នាំ ក្រុងកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

## អ្នកសំរុះសំរួលផ្លូវការ : អាជ្ញាធររដ្ឋបាល

ប្រធានក្រុម គឺជាអាជ្ញាធររដ្ឋបាលទាបជាងគេ។ ដោយកាលពីដើមគេហៅងារនេះដើម្បីបង្កើតជាក្រុមការងារនៅក្នុងការដ្ឋានក្នុងកម្ពុជឆ្នាំ១៩៨០ តួនាទីរបស់ប្រធានក្រុមបានចុះថយយ៉ាងសម្បើម ហើយនៅទីក្រុងវិញ គឺបាត់តែម្តង។ នៅក្នុងតំបន់ដាច់ស្រយាលដែលមានទីលំនៅនៅរប៉ាត់រប៉ាយ នៅពេលនេះប្រធានក្រុមនៅតែជាអាជ្ញាធររដ្ឋបាលទីមួយដែលនៅជិត ដែលគេទាក់ទងក្នុងករណីមានបញ្ហា។ ក្នុងពេលមានវឹកវរ(មានចោរ មានភេរវកម្ម)ឬ ពេលបោះឆ្នោត(ខ្សែរយៈនយោបាយ) គេនៅតែអាចធ្វើឱ្យប្រធានក្រុមមានតួនាទីសកម្មឡើងវិញ ទាំងនៅស្រុកស្រែ ទាំងនៅទីក្រុង។

ប្រធានភូមិនៅតែជាគូសន្ទនារដ្ឋបាលសំខាន់ជាមួយប្រជាជនជនបទ។ ប៉ុន្តែ មុខងាររបស់ប្រធានភូមិមិនសូវបានលើកដំកើងទេ គេមិនសូវខ្លាច និងគោរពដូចកាលពីអតីតទេ។ ក្នុងឋានៈជាមនុស្សនៅក្នុងភូមិស្រុកដែរនោះ ប្រធានឃុំមានអំណាចលើប្រធានភូមិជាច្រើន។ គាត់មានការិយាល័យមួយគឺសាលាឃុំ ហើយមានអំណាចតុលាការដែលធ្វើឱ្យគេខ្លាច។ នៅពីលើមេឃុំ គឺអាជ្ញាធររដ្ឋបាល(ចៅហ្វាយស្រុក ឬមេស្រុក និងចៅហ្វាយខេត្ត) ដែលស្ថិតនៅឆ្ងាយក្នុងន័យភូមិសាស្ត្រ និងទំនាក់ទំនង។ គេញញើតនឹងជួបអ្នកទាំងនេះ។ គេមិនសូវពឹងពាក់អាជ្ញាធរទាំងនេះទេ។ តួនាទីរបស់អ្នកទាំងនេះ ភាគច្រើនគឺបញ្ជូនរឿងទៅនគរបាល ឬតុលាការ។ អ្នកទាំងនេះមិនសូវបានរៀបចំការប្រជុំដើម្បីសំរុះសំរួលទេ។ គេស្តីបន្ទោសអាជ្ញាធរទាំងនេះថា អូសបន្លាយពេលរឿង ឬភ្លេចរឿងរបស់គេ។

នៅទីក្រុងអាជ្ញាធរដែលគេទៅពឹងពាក់គឺចៅសង្កាត់ដែលត្រូវគ្នានឹងដំណែងប្រធានឃុំនៅស្រុកស្រែ។ ការអង្កេតយ៉ាងឆាប់រហ័សលើអ្នករស់នៅទីក្រុង បានអនុញ្ញាតឱ្យផ្ទៀងផ្ទាត់ឃើញថា ឈ្មោះអាជ្ញាធរដែលជាប្រធានក្រុម និងប្រធានភូមិមិនសូវមានគេស្គាល់ប៉ុន្មានទេ (គេថែមទាំងមិនស្គាល់ទីលំនៅទៀតផង)។ ការិយាល័យសង្កាត់និងខ័ណ្ឌសំខាន់គួរសម ហើយគេស្គាល់ទីកន្លែងការិយាល័យទាំងនោះ។ អ្នកនៅភ្នំពេញដែលមានការរៀនសូត្រ មិនញញើតនឹងធ្វើបណ្តឹងដោយត្រង់ៗទៅការិយាល័យនគរបាល ឬតុលាការទេ បើមានរឿងសំខាន់។

## ២.៣. ការប្រើប្រាស់ការសំរុះសំរួល

អាជ្ញាធរមូលដ្ឋាន មានតែចំណេះដឹងបន្តិចបន្តួច ដើម្បីយល់និងដោះស្រាយបញ្ហានៅក្នុងមណ្ឌលរបស់ខ្លួន ក្នុងរបៀបមួយដែលមានសមធម៌។ អាជ្ញាធរទាំងនោះចាត់ការជារឿយៗដោយប្រើសាទិសវិនិច្ឆ័យ(បញ្ញាដែលបានមកពីការពិសោធន៍របស់ខ្លួន) រួមផ្សំជាមួយនឹងចំណេះដឹងច្បោលៗខាងច្បាប់ គោលការណ៍ប្រពៃណីពុទ្ធសាសនា និងសិទ្ធិមនុស្សដែលបានចេះដឹងថ្មីៗ។ គេសង្កេតឃើញថា គ្រឹះប្រពៃណីចាស់ត្រូវបានរិចរិលយ៉ាងខ្លាំង ហើយមិនសូវមាំទាំសំរាប់ការអនុវត្តបច្ចុប្បន្ននៅក្នុងដំណោះស្រាយជម្លោះទេ។ ប្រធានមូលដ្ឋានមួយចំនួនធំបានសារភាព អំពីការខ្វះខាតចំណេះដឹងក្នុងវិស័យគ្រប់គ្រងជម្លោះ។ គេហាក់ដូចជាឃើញថា ការអប់រំបណ្តុះបណ្តាលខ្លីៗដែលមានអត្ថន័យឃោសនាច្រើននៅក្នុងនោះ ត្រូវបានផ្តល់ខ្លះៗក្នុងទសវត្សរ៍៨០ ប៉ុន្តែសព្វថ្ងៃនេះ ការបណ្តុះបណ្តាលនេះមានការខ្វះខាតយ៉ាងខ្លាំង។ ថែមលើនេះទៀតគឺការខ្វះខាតការអប់រំទូទៅដល់មនុស្សក្រុមអាយុដែលបានរស់នៅតែក្នុងសង្គ្រាមហើយមិនបានរៀន។

> "ដើមបណ្តឹងកាន់ពាក្យបណ្តឹងមក។ យើងស្តាប់រឿងរ៉ាវរបស់គាត់ បន្ទាប់មកយើងកោះហៅអ្នកដែលត្រូវបានចោទកាលពីថ្ងៃមុន។ យើងសុំឱ្យអ្នកជាប់ចោទរៀបរាប់រឿង។ យើងកត់ត្រារឿងរបស់គាត់ រួចចាប់ផ្តិតមេដៃគាត់លើក្រដាស។ បន្ទាប់មកយើងឱ្យភាគីទាំងពីរមកជួបជុំគ្នា។ រួចយើងអានក្រដាសទាំងពីរឱ្យគេស្តាប់ម្តងមួយៗ។ នៅទីនេះ នៅត្រឹមកំរិតយើង គ្មានមាត្រាច្បាប់ទេ គ្មានក្រឹត្យទេ។ គ្មានអ្នកណាឈ្នះ គ្មានអ្នកណាចាញ់ទេ។ គេត្រូវរកការព្រមព្រៀងទៅវិញទៅមកមួយ។ គេចងរកដំណោះស្រាយមួយដែលទទួលយកបានចំពោះភាគីទាំងពីរ។ គេទទួលការបណ្តុះបណ្តាលលើប្រធានបទផ្សេងៗ កាលពីសម័យរដ្ឋកម្ពុជា ប៉ុន្តែឥឡូវនេះគ្មានការបណ្តុះបណ្តាលទៀតទេ។
>
> (លោកឡែម អាយុ៥០ឆ្នាំ ប្រធានសង្កាត់ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ភ្នំពេញ)

> "កាលណាអ្នកណាម្នាក់មកដាក់ពាក្យប្តឹងនៅការិយាល័យរដ្ឋបាល គេប្រហែលជាបានសរសេរបណ្តឹងរួចទៅហើយ ឬក៏ឱ្យអ្នកណាម្នាក់ដែលគេស្គាល់ជួយសរសេររួចទៅហើយ ប៉ុន្តែជារឿយៗគឺយើងជាអ្នកជួយតាក់តែងឱ្យគាត់។ អ្នកដែលដាក់ពាក្យបណ្តឹងឱ្យប្រាក់ ២០០០ ទៅ ៣០០០ រៀល ដើម្បីចេញថ្លៃតែងពាក្យបណ្តឹង ហើយនិងសោហ៊ុយផ្នែករដ្ឋបាល។ ពាក្យបណ្តឹងនោះដាក់ជូនទៅប្រធានសង្កាត់ដែលជាអ្នកសំរេចថាត្រូវបន្តរឿងនោះ ឬអត់។ បើគាត់សំរេចថាត្រូវយកចិត្តទុកដាក់នឹងរឿងនោះ គាត់បញ្ជូនពាក្យបណ្តឹងទៅឱ្យរងរបស់គាត់ដើម្បីចុះក្នុងបញ្ជី។ បន្ទាប់មកដើមបណ្តឹងត្រូវបានកោះហៅដើម្បីមករៀបរាប់ដំណើររឿង។ ក្រោយមកទៀតជនដែលត្រូវចោទក៏ត្រូវបានកោះហៅដោយឡែកមកកាន់ការិយាល័យ ឱ្យមករៀបរាប់រឿងតាមដំណើររបស់

ខ្លួន។ តមកទៀត បើរឿងនោះដោះស្រាយមិនបានទេនោះ ជនទាំងពីរត្រូវបានកោះហៅរួមគ្នាមកការិយាល័យដើម្បីធ្វើការសំរុះសំរួល"។

(លោក ឆុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

"ខ្ញុំបានរៀនធ្វើការសំរុះសំរួល ដោយសង្កេតរបៀបធ្វើរបស់ប្រធានឃុំ។ ខ្ញុំទាញយកគំរូដែលបានមកពីការពិសោធន៍របស់ខ្ញុំដែរ។ ខ្ញុំផ្អែកលើគំនិតពុទ្ធសាសនាបន្តិចបន្តួចដែរ ព្រោះឪពុកខ្ញុំជាអាចារ្យ។ ក្នុងករណីអំពើហឹង្សាក្នុងគ្រួសារ ខ្ញុំនិយាយទៅកាន់មនុស្សប្រុសថា "បើអ្នកឯងវាយអ្នកដទៃ ខ្ញុំសួរថា អ្នកឯងឈឺដែរឬទេ? បើគេបានវាយអ្នកឯងរួចហើយ អ្នកឯងដឹងថាអាហ្នឹងឈឺដែរឬទេ? បើអ្នកឯងថាអញ្ចឹងអ្នកឯងមិនត្រូវធ្វើបាបអ្នកដទៃទេ។ គេមិនត្រូវធ្វើអាក្រក់ទេ។ បើអ្នកឯងឈឺកាលណាគេវាយអ្នកឯង អ្នកឯងអាចយល់ថា អ្នកដទៃក៏គេឈឺចាប់ដែរ។

(លោក វណ្ណាត អាយុ៥២ឆ្នាំ ប្រធានភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

"ពេលខ្ញុំត្រូវរកដំណោះស្រាយចំពោះបញ្ហាមួយ ខ្ញុំត្រូវធ្វើការអង្កេត។ ខ្ញុំស្តាប់អ្វីដែលអ្នកជិតខាងនិយាយ។ បើខ្ញុំរកឃើញការពិត សេចក្តីសំរេចនឹងធ្វើទៅតាមរឿងពិត។ មានន័យថា ខ្ញុំយកមតិរបស់មនុស្សដែលមិនចូលដៃខាងណា។ ខ្ញុំមិនស្តាប់គ្រួសារមានជម្លោះនិយាយទេ។ ជារឿយៗខ្ញុំព្យាយាមរកដំណោះស្រាយដែលគិតគូដល់មនោសច្ចេតនាច្រើនជាងច្បាប់។ ប៉ុន្តែបើធ្វើដូច្នេះទៅមិនរួចទេនោះ គឺប្រធានឃុំជាអ្នកដោះស្រាយរឿង"។

(លោកល័ក្ខ អាយុ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

"នៅទីនេះ គេមិនស្គាល់ក្បួនច្បាប់ពីបូរាណទេ។ គេមិនចេះអាន។ ក្នុងពេលធ្វើការសំរុះសំរួលគ្មានច្បាប់ជាក់លាក់ទេ គេធ្វើទៅតាមបទពិសោធន៍ផ្ទាល់ខ្លួន។ គេបានលទ្ធផលវិជ្ជមានផងអវិជ្ជមានផង។

(អ្នកស្រី សែន អាយុ៤៧ឆ្នាំ ប្រធានសមាគមស្ត្រី (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ជួនកាលមុខងាររបស់ប្រធានភូមិលុបបាត់ដោយសារភូមិរបស់គាត់នៅជិតអ្នកតំណាងរាជការម្នាក់ទៀត ព្រមទាំងសមត្ថកិច្ចរបស់តំណាងរាជការនោះដូចជា: អនុប្រធាននគរបាល សេនាជន ប្រធានក្រុម។

ជួបជាមួយប្រធានក្រុម។

"កាលយើងនៅក្មេង យើងគ្មានអ្វីធ្វើទេ។ យើងឈ្លោះគ្នាកាលណាយើងគ្មានការងារធ្វើ(ជាមួយប្តីខ្ញុំ)។ កាលណាបញ្ហាធ្ងន់ ខ្ញុំដេកគ្រែផ្សេងគ្នាចំនួន១០ ឬ១៤ថ្ងៃ។ ខ្ញុំមិនព្រមចុះចាញ់ទេ។ បើយើងមិនស្រុះស្រួលទេនោះ ខ្ញុំទៅជួបប្រធានក្រុម ហើយខ្ញុំសុំឱ្យគាត់ធ្វើការសំរុះសំរួល។ ខ្ញុំសុំឱ្យគាត់និយាយទៅប្តីខ្ញុំនិងឱ្យគាត់ស្តីប្រដៅ។ ប្រធានក្រុមទៅជួបប្តីខ្ញុំនៅទីលានបាល់ទះ ហើយ

និយាយប្រាប់ប្ដីខ្ញុំឱ្យខំធ្វើការ និងឈប់បង្កើតជម្លោះ។ ខ្ញុំចូលចិត្តទៅជួបប្រធានក្រុមព្រោះគាត់រស់នៅក្បែរខ្ញុំ ហើយយើងស្គាល់គ្នា។ ប្រធានភូមិនៅឆ្ងាយ ហើយខ្ញុំមិនទៅរំខានគាត់ដោយសាររឿងតូចតាចទេ"។

(អ្នកស្រី ហាន អាយុ២៤ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត—ភូមិថ្មី)

ជួបជាមួយអនុប្រធានភូមិទទួលបន្ទុកសន្តិសុខ។

"គេចូលចិត្តនិយាយនឹងខ្ញុំជាជាងនិយាយជាមួយប្រធានភូមិ ព្រោះខ្ញុំនិយាយល្អជាង"។

(លោក ល័ក្ខ អាយុ៣៨ឆ្នាំ សង្កាត់អង្កុល ក្រុងកែប)

## ២.៤. របៀបធ្វើការសំរុះសំរួល

យើងបានរកឃើញឥរិយាបថខុសៗគ្នានៃអាជ្ញាធរមូលដ្ឋាន ក្នុងការចាត់ការដោះស្រាយជម្លោះក្នុងមូលដ្ឋាន។ ហេតុផលនៃការខុសគ្នានេះ ភាគច្រើនមកពីបុគ្គលិកលក្ខណៈ កំរិតអប់រំ ប្រវត្តិជីវភាព និងទីកន្លែងរស់នៅរបស់ជនដែលត្រូវសាកសួរជាជាងវិធីដែលមានសរសេរក្នុងក្បួនច្បាប់។

### ១. អំណាចនិយម និងបិតុនិយម

ឥរិយាបថនេះភាគច្រើនត្រូវបានរកឃើញនៅកន្លែងឆ្ងាយៗនិងដាច់ស្រយ៉ាល។ ដោយហេតុមកពីការជ្រើសរើសតំបន់អង្កេតរបស់យើង យើងបានប្រមូលករណីមួយចំនួនសំខាន់គួរសមនៃប្រភេទនេះ។ តាមពិត យើងបានធ្វើការជាច្រើនក្នុងតំបន់ពិសេសៗដែលមានសមាមាត្រខ្មែរក្រហមចុះចូលថ្មី[១៣៧] ច្រើន។ យើងសូមឱ្យប្រយ័ត្នប្រយែងលើការបកស្រាយជាយថាហេតុ ឬការវាយតម្លៃជាស្ថិតិ។ យើងហាក់ដូចជាឃើញថា នៅក្នុងតំបន់ដទៃទៀតដែលនៅឆ្ងាយ ប៉ុន្តែត្រូវបានរំដោះចាប់តាំងពីឆ្នាំ១៩៧៩មក ឥរិយាបថនេះក៏ត្រូវបានគេរកឃើញដែរ។ ប៉ុន្តែគេអាចសង្កេតឃើញថា នៅក្នុងតំបន់ដាច់ស្រយ៉ាលទាំងមូល ការយោងទៅរកគំរូបិតុនិយមដែលប្រើអំណាចតាមបែបប្រពៃណីស្ទើរតែមានដូចគ្នា ទោះបីជានិន្នាការនយោបាយរបស់មេយ៉ាងណាក៏ដោយ។

អំណាចនិយម

"មានច្បាប់របស់រដ្ឋ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំប្រើការគិតផ្ទាល់ខ្លួនរបស់ខ្ញុំ។ មុនដំបូង ខ្ញុំធ្វើការអង្កេតលើភាគីទាំងពីរ។ បើប្រពន្ធប្ដឹងថាប្ដីវាយ ខ្ញុំផ្ទៀងផ្ទាត់មើលហេតុផល។ បើព្រោះតែប្ដីលេងបៀ និងផឹកស្រា គឺគាត់អាក្រក់។ ឧទាហរណ៍ នៅក្នុងផ្ទះក្បែរខ្ញុំ **ឡុក** វាយប្រពន្ធហើយដេញប្រពន្ធចេញពីផ្ទះ។ ខ្ញុំបានដោះស្រាយរឿងនេះដោយប្រើច្បាប់រដ្ឋ និងច្បាប់ធម្មនុញ្ញ(!)។

[137] ១៩៩៤ : ចំការបី(ភ្នំវល្លិ)

ខ្ញុំជាចៅក្រម ហើយខ្ញុំកាចដើម្បីធ្វើឱ្យគេខ្លាច។ បើខ្ញុំមិនកាច គេមិនខ្លាចខ្ញុំទេ។ ខ្ញុំបានដាក់បទបញ្ជាគឺត្រូវនិយាយម្តងម្នាក់។ ខ្ញុំបានកត់ទុកក្នុងសៀវភៅខ្ញុំថា **ឡុក** បាននិយាយមុនគេ។ ខ្ញុំសួរទៅ គាត់ថា"មានរឿងអី?"។ គាត់បានឆ្លើយថា "ប្រពន្ធខ្ញុំជាមនុស្សអាក្រក់"។ វាបានចេញពីផ្ទះបី ឬ បួនដង ដើម្បីទៅ លក់អង្ករ។ វាមានសហាយ។ **ឡុក** បានបណ្តេញប្រពន្ធច្រើនដងឱ្យចេញពីផ្ទះ។ ខ្ញុំមិនទាន់បានវិនិច្ឆ័យនៅឡើយទេ ហើយបន្ទាប់មកខ្ញុំបានសួរទៅប្រពន្ធថាមានអ្វីកើតឡើង : "អ្នកឯងមានលក់អង្ករដែរឬទេ?" "ទេ ខ្ញុំមិនបានលក់ អង្ករទេ ខ្ញុំទៅខ្ចីអង្ករគេ ព្រោះយើងមិនមានអង្ករ។ នៅពេលគាត់(ប្តី)ចូលផ្ទះ គាត់វាយខ្ញុំហើយបណ្តេញខ្ញុំ"។ នៅពេលនោះ ខ្ញុំធ្វើជាចៅក្រម ហើយខ្ញុំបាននិយាយឱ្យគេខ្លាច។ ខ្ញុំបានពន្យល់កំហុសទីមួយទៅប្រពន្ធ: "បើគ្មានអង្ករនៅផ្ទះ អ្នកឯងមិនត្រូវចេញដើម្បីដុតកំហឹងឱ្យប្តីទេ។ ឥឡូវនេះ អ្នកឯងនឹងនៅផ្ទះ ហើយមិនត្រូវចេញទៀតទេ។ ចាប់ពីឥឡូវនេះទៅ អ្នកឯងមិនត្រូវចេញពីផ្ទះទៀតទេ។ បើអ្នកឯងចេញ អ្នកឯងនឹងត្រូវចោទប្រកាន់ថា មានសហាយ"។ បន្ទាប់មក ខ្ញុំបាននិយាយទៅកាន់ប្តីអំពីកំហុសទីពីរ : "អំណើះតទៅប្រពន្ធឯងនឹងនៅផ្ទះ។ បើខ្វះអង្ករ គឺឯងត្រូវទៅរកអង្ករ។ បើឯងនៅតែវាយប្រពន្ធទៀត ឯងត្រូវជីកដី១៥ម៉ែត្រគុបនៅឯវត្ត។ គឺដើម្បីជួយសាសនា"។ ខ្ញុំបាននិយាយទៅកាន់ប្រពន្ធថា បើប្តីវាយគាត់ទៀត គាត់ត្រូវមកជួបខ្ញុំ។ ខ្ញុំនឹងធ្វើឱ្យវាខ្លាច។ ចាប់ពីពេលនោះមក ប្តីមិនហ៊ានវាយប្រពន្ធគាត់ទៀតទេ។ ពេលគាត់ផឹកគាត់ចូលផ្ទះដេក។ មនុស្សទាំងអស់នៅម្តុំនេះ ដឹងពីរបៀបដែលខ្ញុំបានដោះស្រាយរឿងនេះ។ អ្នកទាំងអស់នោះនិយាយថាល្អ។ បន្ទាប់ពីនោះមក មនុស្សដទៃទៀតក្នុងភូមិមិនហ៊ានបង្កើតបញ្ហាទេ។ អ្នកផ្សេងក្រៅពីខ្ញុំមិនអាចឱ្យដំបូន្មានដល់ប្តីប្រពន្ធនេះទេ។ មនុស្សនៅទីនេះស្តាប់ខ្ញុំ"។

(លោក ចាន់ អាយុ៦០ ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម)ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"បើប្តីជាអ្នកសុំលែងលះ ខ្ញុំតឹង។ ខ្ញុំមិនដែលយល់ព្រមឱ្យលែងលះទេ។ ប្តីចង់រកប្រពន្ធមួយទៀត ហើយខ្ញុំដឹងថា ស្ត្រីដែលប្តីលែងពិបាករកប្តីមួយទៀតណាស់។

(លោក ជាតិ អាយុ៤៦ឆ្នាំ ប្រធានភូមិ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

នៅទីនេះ ក្របខ័ណ្ឌប្រើអំណាចនៅតែមាន ហើយគោលការណ៍សិទ្ធិមនុស្សគ្រាន់តែជាភាសាថ្មីសំរាប់ឱ្យប្រជាជនចាប់អារម្មណ៍ ដោយឥតបានធ្វើឱ្យនិយមន័យពិតរបស់វាបានជ្រាបចូលមនុស្សទាំងនោះទេ។

"ក្នុងករណីអំពើហឹង្សាក្នុងគ្រួសារ គឺស្ត្រីដែលមកប្តឹងជាញឹកញាប់។ ប្តីបានផឹកស្រា។ គាត់ចូលមកផ្ទះ គាត់រករឿង និងវាយប្រពន្ធ។ មានករណីមួយដែលប្តីបានវាយប្រពន្ធនឹងក្តាបន្ទះ។ ប្រពន្ធទៅប្តឹងប្រធានក្រុម។ ប្រធានក្រុមធ្វើការប្រជុំសំរុះសំរួល។ ដោយហេតុថា ប្តីប្រពន្ធនេះមិន

បានយល់ ហើយដោយហេតុថា ប្រធានក្រុមមិនមានអំណាចគ្រប់គ្រាន់ ប្ដីចាប់ផ្ដើមវាយប្រពន្ធតទៅទៀត។ គាត់មិនវាយក្បាលទេ ព្រោះក្បាលអាចបាក់។ បើគាត់វាយក្បាលវានាំឱ្យមានឈាម គឺអាក្រក់ណាស់។ ប្រពន្ធទៅប្ដឹងប្រធានភូមិ។ មនុស្សនៅក្នុងភូមិមិនយល់ពីសិទ្ធិមនុស្សទេ។ គេមិនចង់ស្ដាប់អ្នកដទៃទេ។ គេយល់យ៉ាងណាគេប្រកាន់យ៉ាងនោះ ហើយគេនៅតែមានគំនុំ។ ម្នាក់ៗចង់ឈ្នះ ហើយមិនចង់សំរុះសំរួលជាមួយអ្នកដទៃទេ។ ប្ដីនឹងប្រពន្ធស្រែកដាក់គ្នាហើយម្នាក់ៗសុទ្ធតែនិយាយថាខ្លួនមានហេតុផល។ អ្វីដែលល្អនោះគឺ ត្រូវសំរួលបញ្ហា ហើយនឹងសំរុះសំរួលគ្នា។ រឿងឡើងរហូតមកដល់ខ្ញុំ។ នៅក្នុងពេលសំរុះសំរួល មនុស្សទាំងអស់នៅជិតខាងក៏មកដែរ។ គេអាចធ្វើអន្តរាគម។ ខ្ញុំនិយាយទៅអ្នករងគ្រោះថា "ហេតុអ្វីបានជានាងត្រូវគេវាយ?"។ នាងនោះបានឆ្លើយថាព្រោះប្ដីនាងស្រវឹង។ ខ្ញុំបានសួរទៅប្ដីថា ហេតុអ្វីបានជាវាយប្រពន្ធ។ គាត់ឆ្លើយថា បាយមិនឆ្អិនពេលគាត់ត្រឡប់មកផ្ទះវិញ ថាប្រពន្ធគាត់ធ្វើឱ្យបាត់មាន់ ថាលែងគោចោលមិនមើលទៅស៊ីដើមចេក ហើយគាត់គិតថាប្រពន្ធគាត់មានសហាយ ព្រោះប្រពន្ធនោះដើរលេងច្រើនពេក។ ប្រពន្ធបានឆ្លើយថា គឺថាប្ដីទេដែលដើរលេងគ្រប់ពេល ហើយថាប្ដីនោះជាអ្នកឈ្លោះពេលចូលដល់ផ្ទះ។ នៅពេលនោះ ខ្ញុំយល់បញ្ហាអ្នកទាំងពីរ ហើយខ្ញុំបានដឹងថាអ្នកណានិយាយពិត អ្នកណានិយាយមិនពិត។ ដូច្នេះ ខ្ញុំព្យាយាមសំរុះសំរួលដោយផ្អែកលើសិទ្ធិមនុស្ស ហើយខ្ញុំអប់រំគេថា :"មនុស្សយើងទាំងអស់ស្មើភាពគ្នា។ គ្មានអ្នកណាខ្ពស់ជាង គ្មានអ្នកណាទាបជាងទេ។ គ្មានអ្នកណាត្រូវបានគេបំពានវាយដំដោយអ្នកដទៃទេ។ គឺមិនល្អទេ។ គឺមិនល្អទេ ដែលទុកអ្នកដទៃដូចជាទាសករ។ មនុស្សទាំងអស់គឺជាមនុស្ស មិនមែនសត្វទេ។ ដូច្នេះ កាលណាមានបញ្ហាគេអាចនិយាយគ្នាបាន គេមិនត្រូវប្រើហឹង្សាតទៅទៀតទេ ព្រោះមនុស្សយើងមានភាសានិយាយ។ លោកអាចនិយាយ។ លោកមានសេរីភាពនឹងនិយាយ។ ឥឡូវនេះ លោកត្រូវស្រុះស្រួលហើយឈប់ឈ្លោះគ្នា។ ខ្ញុំបាននិយាយថា គាត់ត្រូវឈប់ឈ្លោះគ្នា"។ ខ្ញុំបាននិយាយយ៉ាងខ្លាំង។ ខ្ញុំមិនមែននិយាយតែចំពោះគាត់ទេ ខ្ញុំចង់ឱ្យអ្នកដទៃស្ដាប់ផងដែរ។ ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នាឮ។ ខ្ញុំបានសុំឱ្យអ្នកជិតខាងទាំងអស់ជួបប្រជុំ ហើយក្រោយមកគេមិនចង់ឈ្លោះគ្នាទៀតទេ។ គេបានយល់។ អ្នកឈ្លោះគ្នាខ្លាចកាលណាគេនិយាយនៅចំពោះមុខមនុស្សទាំងអស់គ្នា។ គេខ្មាស់។ គេនៅស្ងៀម"។

(លោកឡុង អាយុ៥៣ឆ្នាំ អនុប្រធានឃុំ ឃុំព្រាំងភ្លាំង ស្រុកឈូក ខេត្តកំពត)

នៅក្នុងភូមិមួយដែលឋានានុក្រមបែបចាស់របស់ប្រធានយោធាខ្មែរក្រហម[១៣៨] នៅរក្សាសភាពដើមក្រោមរចនាសម្ព័ន្ធរដ្ឋបាលរបស់រដ្ឋាភិបាល ការចេញពីក្របខ័ណ្ឌមូលដ្ឋានដើម្បីសុំជំនួយខាងក្រៅ ត្រូវបានចាត់ទុកថា ជាការក្បត់នឹងប្រព័ន្ធចាស់។ អ្នកដែលហ៊ានធ្វើវិលង ត្រូវទទួលការគាបសង្កត់។

"គេបានឱ្យដីយើង ៣០ x ៥០០ ម៉ែត្រ ហើយយោធានៅឃុំជិតខាងបានរំលោភយកដីមួយភាគដែលយើងមិនទាន់បានកាប់ឆ្ការ។ ដីនោះជារបស់យើង។ អាជ្ញាធរមូលធរមូលដ្ឋានបានឱ្យយើងកាលពីឆ្នាំ ១៩៩៤។ បញ្ហានេះទាក់ទងនឹងមនុស្ស ៤៦ គ្រួសារ។ យើងបានដាក់បណ្តឹងទៅកែប ៣ឆ្នាំមកហើយ បន្ទាប់មកទៅតុលាការ។ មានគេនិយាយប្រាប់ខ្ញុំថា ក្រុងកែបមិនអាចធ្វើអ្វីប្រឆាំងនឹងយោធាបានទេ។ អង្គការលីកាដូ[១៣៩] មកពីរដងហើយ។ ពីមុន នៅពេលយោធាបានយកដី យើងនៅមានអាវុធ ហើយយើងចង់សម្លាប់យោធាទាំងនោះ។ យើងអាចប្រយុទ្ធបាន។ បន្ទាប់មក គេបានដកហូតអាវុធពីយើង ប៉ុន្តែគេមិនដកពីយោធាទេ។ ដូច្នេះ យើងបានដកដំណាំយោធានោះចោល ហើយគេក៏បានដកដំណាំយើងចោលដែរ។ ខ្ញុំបាននិយាយទៅអាជ្ញាធរថា បើគេមិនចង់ជួយយើងទេនោះ យើងនឹងឡើងទៅតុលាការ។ ថ្ងៃមួយមនុស្សប្រដាប់អាវុធមួយចំនួនមកផ្ទះខ្ញុំទាំងយប់ ហើយគេបានប្រាប់ខ្ញុំថា បើខ្ញុំប្តឹងទៅតុលាការខ្ញុំនឹងចាញ់ ថាគេនឹងដុតផ្ទះខ្ញុំនិងដេញខ្ញុំចេញ។ ពួកនេះជាមិត្តភ័ក្រ្តជាមួយប្រធាននៅទីនេះ។ ពួកគេប្រាប់ខ្ញុំថា កុំចង់យកពងមាន់ទៅជល់នឹងថ្ម។ "អ្នកឯងខ្សោយណាស់ មិនត្រូវបង្កើតបញ្ហាជាមួយអ្នកខ្លាំងទេ"។ ខ្ញុំខ្លាចហើយខ្ញុំទៅជួបខាងសិទ្ធិមនុស្ស។ ខាងសិទ្ធិមនុស្សបាននិយាយបញ្ហាដីធ្លីនេះប្រាប់ទៅអភិបាលខេត្តរង។ ឥឡូវនេះខ្ញុំជឿថា មនុស្សដែលបានគំរាមកំហែងខ្ញុំមិនហ៊ានសម្លាប់ខ្ញុំទេ ព្រោះគេដឹងថាមនុស្សសំខាន់ម្នាក់បានដឹងរឿងនោះទៅហើយ។ អភិបាលរងបាននិយាយថា គាត់នឹងយកចិត្តទុកដាក់នឹងរឿងនេះ ប៉ុន្តែមកទល់ពេលនេះមិនទាន់មានរឿងអ្វីធំដុំកើតឡើងនៅឡើយទេ។ ខ្ញុំបានជួបតារិន[១៤០] ហើយនិយាយថា ពីដើមគាត់ជាចៅហ្វាយយើង ហើយយើងមានទំនុកចិត្តលើគាត់ ប៉ុន្តែឥឡូវនេះ គាត់បានបោះបង់កូនចៅអស់ហើយ។ តារិនមិនចង់ចូលលាយឡំក្នុងរឿងនេះទេ។ គាត់បាននិយាយប្រាប់ខ្ញុំថា ខ្ញុំមិនត្រូវសុំជំនួយពីខាងក្រៅទេ ប៉ុន្តែត្រូវដោះស្រាយបញ្ហាយើងរវាងគ្នាយើងវិញ។ គាត់និយាយថា ជាបញ្ហាដែលគាត់ពិបាកដោះស្រាយ ជារឿងរវាង

---

138 ប្រធានភូមិជាអតីតវីរៈសេនីយឯកខ្មែរក្រហម ហើយអនុប្រធានរបស់គាត់ជាអតីតអ្នកនៅក្រោមបង្គាប់គាត់កាលពីនៅយោធា។ អតីតប្រធានភូមិភាគ យោធាបានធ្វើសមាហរណកម្មក្នុងជួរកងទ័ពរដ្ឋាភិបាលតាំងពីពេលនោះមក។ គាត់នៅតែគ្រប់គ្រងអតីតយុទ្ធមិត្តរបស់គាត់ ព្រមទាំងប្រជាជនក្រីក្រដែលមក តាំងទីលំនៅនៅលើដីថ្មីដែលរដ្ឋាភិបាលប្រគល់ឱ្យ។

139 អង្គការសិទ្ធិមនុស្ស

140 អតីតខ្មែរក្រហមជាន់ខ្ពស់ ដែលរស់នៅមាត់ភូមិ។ គាត់បានធ្វើសមាហរណកម្មក្នុងតំណែងយោធាមួយសំខាន់ក្នុងកងទ័ពរដ្ឋាភិបាល ប៉ុន្តែនៅតែគិតគូរ បញ្ហារបស់អតីតទាហ៊ាន និង"កូនចៅ"របស់គាត់។

អតីតយុទ្ធមិត្តកាលពីនៅក្នុងព្រៃម្យ៉ាង ហើយនិងម្យ៉ាងទៀតរវាងអតីតយុទ្ធមិត្តនៅក្នុងស្រុក ដែលបានជួយយើងកាលពីយើងនៅតស៊ូ។ បើរឿងនេះកើតឡើងរវាងមនុស្សមកពីខាងក្រៅតារិន នឹងជួយយើង។ គាត់ជាមនុស្សល្អនិងយុត្តិធម៌ គ្រាន់បើជាងប្រធានភូមិដែលភ្លេចរឿងដែល រៀបរាប់ប្រាប់គាត់ ហើយដែលខឹងបើគេមិនស្តាប់គាត់។ ក្នុងករណីនេះ គាត់និយាយថា កុំរំខាន ហើយត្រូវដោះស្រាយរឿងយើងដោយខ្លួនយើង"។

(អ្នកស្រី សេង អាយុ៤៣ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

នៅក្នុងភូមិដាច់ស្រយាលមួយ ហើយដែលកាន់កាប់ភាគច្រើនដោយអតីតខ្មែរក្រហមចុះចូលក្នុងឆ្នាំ ១៩៩៦ គេមិនបំភ្លេចទម្លាប់ចាស់ដោយងាយនោះទេ។

"គេបានដាក់គុកខ្ញុំពីឆ្នាំ ១៩៧៩-១៩៩២។ គេនិយាយថា ខ្ញុំជាខ្មែរក្រហម។ សូម្បីតែខ្ញុំមិនបាន សម្លាប់មនុស្សដោយផ្ទាល់ក៏ដោយ ក៏គេនៅតែច្រឡំថា ខ្មែរក្រហមទាំងអស់បានសម្លាប់។ គេនិយាយថា:"ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់"។ បន្ទាប់មក ខ្ញុំបានមករស់នៅទីនេះក្នុង ឆ្នាំ១៩៩៦ ដើម្បីបានដីថ្មី ពីព្រោះដីខ្ញុំនៅឈូកតូចពេកមិនអាចចិញ្ចឹមគ្រួសារបាន។ ប្រធានឃុំ ស្គាល់គ្រួសារខ្ញុំ(យុទ្ធជនខ្មែរក្រហម)។ គាត់បានស្នើទៅអ្នកភូមិឱ្យខ្ញុំធ្វើប្រធានភូមិ។ អ្នកស្រុកក៏ បោះឆ្នោតឱ្យខ្ញុំធ្វើជាប្រធានភូមិ។

ក្នុងឋានៈជាប្រធានភូមិ ខ្ញុំត្រូវបង្កើតជាក្រុមតូចៗដែលមានគ្នាបីទៅប្រាំនាក់(ពួក) ត្រូវចែកដីឱ្យ គេ និង ត្រូវដោះស្រាយបញ្ហាផ្ទៃក្នុង។

ជាមួយនឹងប្រព័ន្ធរៀបចំជាពួកដូច្នេះ គេអាចឃ្លាំមើលជម្លោះរវាងមនុស្ស និងអាចបញ្ជូនពត៌មាន ដល់អ្នកទាំងនោះបាន។ ប្រធានឃុំរៀបចំការប្រជុំជាមួយប្រធានភូមិ ហើយនិយាយពីទិសដៅ និងពត៌មានក្នុងស្រុក: អ្វីដែលត្រូវដាំដុះ ច្បាប់ស្តីពីការហាមឃាត់ការកាប់ដើមឈើ អាកប្បកិរិយា ល្អដែលត្រូវប្រកាន់យក។ នៅរដូវប្រាំង យើងប្រាប់អ្នកស្រុកកុំឱ្យលែងសត្វដើរសេរី ដើម្បីជៀស វាងកុំឱ្យវាស៊ីដំណាំ។ បើសត្វស៊ីដំណាំគេ ម្ចាស់សត្វត្រូវចេញសងថ្លៃដំណាំដែលសត្វបានបំផ្លាញ។ យើងនិយាយអំពីការបែងចែកដីដែរអំពីអ្វីដែលត្រូវដាំ ហើយនៅពេល ណា។ យើងនិយាយដែរថា ត្រូវចៀសវាងជម្លោះប្តីប្រពន្ធ និងចៀសវាងការប្រច័ណ្ឌ។ ខ្ញុំទទួលពត៌មានពីប្រធានឃុំ ហើយ ខ្ញុំបញ្ជូនបន្តឱ្យទៅប្រធានក្រុម។ ហើយបន្ទាប់មកទៀត ប្រធានក្រុមឱ្យពត៌មានទៅតាមផ្ទះ នីមួយៗ។ កាលណាគេមានវិន័យតឹងរឹង គេនឹងគ្មានបញ្ហា។ មនុស្សមើលគ្នា និងកែគ្នាទៅវិញ ទៅមក។ គេមើលនិងកែឥរិយាបថអាក្រក់។ នៅទីនេះគ្មានចោរទេ។

(លោក ម៉ុន អាយុ៥៤ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

នៅក្នុងតំបន់មួយ ដែលកាលពីដើមត្រួតត្រាដោយខ្មែរក្រហម ការប្រជុំផ្សព្វផ្សាយពតិមានផ្អែកលើប្រព័ន្ធគ្រប់គ្រង និងត្រួតត្រាចាស់លើប្រជាជននៅតែត្រូវបានរៀបចំនៅឡើយ ។

"យើងធ្វើការប្រជុំដោយអញ្ជើញមនុស្សម្នាក់ក្នុងមួយគ្រួសារឱ្យមកប្រជុំ។ ជាការប្រជុំដើម្បីប្រាប់ឱ្យមនុស្សធ្វើការល្បាតយាមមើលពួកចោរ ឱ្យយើងការពារកុំឱ្យអ្នកក្រៅមកទីនេះ និងឱ្យយើងចងគោឱ្យជាប់នៅរដូវភ្លៀងកុំឱ្យវាទៅស៊ីដំណាំគេ។ ជួនកាល យើងធ្វើការប្រជុំតែថ្នាក់ក្រុមទេ ហើយក្រុមនឹងផ្តល់ពតិមានបន្តទៅឱ្យគ្រួសារនីមួយៗ។ យើងប្រាប់ឱ្យប្រធានក្រុមដាស់តឿនមនុស្ស។ ចំពោះបញ្ហាវិវាទមនុស្ស ខ្ញុំធ្វើការអប់រំដើម្បីឱ្យមនុស្សចេះមើលគ្នាទៅវិញទៅមក។ ខ្ញុំមិនចង់ដោះស្រាយរឿងសត្វស៊ីដំណាំម្តងមួយៗទេ។ យើងដឹងច្បាស់ហើយចំពោះចំណុចនេះ។ ម្ចាស់សត្វដែលស៊ីដំណាំអ្នកជិតខាងត្រូវតែសងថ្លៃដំណាំគេ។ គឺមនុស្សទាំងនោះជាអ្នកដោះស្រាយវិវាទគ្នាគេ។ លើចំណុចនេះ ចាន់លី[141] ដឹងច្បាស់ហើយ។ ម្នាក់ៗត្រូវមានវិន័យត្រូវមើលខ្លួនឯង។ នៅពេលដែលយើងចូលជាមួយរដ្ឋាភិបាល និងពេលគេឱ្យដីយើងដើម្បីតាំងទីលំនៅចាន់លីបាននិយាយថា អ្នកណាលែងសត្វចោលមិនមើលឱ្យដើរស៊ីដំណាំគេ អ្នកនោះត្រូវសងថ្លៃដំណាំ ៥០០០០(ប្រាំម៉ឺន)រៀលដល់ម្ចាស់ដំណាំ។ ហើយបើសិនជាមានបញ្ហា បើគេមិនចង់ចេញថ្លៃសងគឺចាន់លីជាមនុស្សដែលត្រូវទៅទារលុយ។ កាលណាមានបញ្ហាដូច្នេះនៅក្នុងភូមិ ខ្ញុំនិយាយថា: "អ្នកឯងមានចាំសំដីរបស់ចាន់លីទេ? បើអ្នកឯងបានឮច្បាស់ពីបទបញ្ជា អ្នកឯងត្រូវគោរពបទបញ្ជា បើមិនដូច្នេះទេគាត់នឹងមកជួបអ្នកឯង"។ មនុស្សទាំងអស់ខ្លាច ពីព្រោះគេគោរពគាត់ណាស់ ហើយគេនឹងមិនបង្កើតរឿងទេ"។

(លោក ឡុង អាយុ៥៣ ឆ្នាំ អនុប្រធានឃុំ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

ចំពោះអ្នកដែលស្គាល់តែព្រៃ និងវិន័យយោធា ការប្រជុំផ្សព្វផ្សាយពតិមានផ្តល់នូវក្របខ័ណ្ឌមួយដល់ជីវភាពថ្មី។ ការឱ្យតាំងទីលំនៅលើដីដាំដំណាំមួយកន្លែង និងការសន្យាផ្តល់អនាគតមួយក្នុងសន្តិភាពគឺជាការមួយគួរជាទីពេញចិត្តណាស់ទៅហើយ។

"ការប្រជុំនេះ ខ្ញុំគិតថាល្អ។ គេបានទទួលការអប់រំ ហើយគេស្តាប់។ គេប្រាប់ឱ្យយើងការពារទល់នឹងពួកចោរមកពីក្រៅ ហើយនិងកុំឱ្យយើងលួចគ្នាឯង បើមិនដូច្នេះទេ នឹងមានការដាក់ទណ្ឌកម្ម។ គ្មានការលួចប្លន់ទេនៅទីនេះ។ ទោះជាយ៉ាងណាក្តីគ្មានចោរទេ ព្រោះមនុស្សទាំងអស់សុទ្ធតែក្រណាស់គ្មានអ្វីអោយលួចទេ។ នៅពេលប្រជុំ គេប្រាប់ឱ្យយើងខំធ្វើការដាំដុះដើម្បីបង្កើនជីវភាព

[141] អតីតប្រធានយោធាខ្មែរក្រហមក្នុងមូលដ្ឋាន ដែលចាប់ពីពេលនោះមកបានធ្វើសមាហរណកម្មចូលក្នុងកងទ័ពរដ្ឋាភិបាលហើយ ប៉ុន្តែនៅរក្សាការត្រួតត្រា លើយុទ្ធមិត្តរបស់គេកាលពីអតីតកាល។

យើង។ បើគេធ្វើការច្រើន គេរកលុយបាន។ គេអប់រំយើងឱ្យមានសាមគ្គីភាព និងជួយគ្នាទៅវិញទៅមក។ ប្រធាននិយាយថាបើយើងមិនជួយគ្នាទេ តើម្នាក់ៗនឹងមានអ្វីសំរាប់រស់។ បើយើងជួយគ្នា យើងបានចំណេញច្រើន"។

(ក្រុមស្ត្រីដែលមានស្ត្រីបីនាក់ អាយុ២៥ដល់ ៤០ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"នៅទីនេះគេគោរពសិទ្ធិគ្នាបានល្អណាស់ ហើយគេរស់នៅសុខនឹងគ្នា។ យើងមានសន្តិភាព ហើយយើងប្រឹងធ្វើការ យើងអាចប្រមូលភោគផលបាន។ យើងមានការប្រជុំអប់រំដែលយើងអាចរៀនដាំដុះឱ្យបានផលល្អ ឱ្យចេះដាំសព្វមុខ។ គេប្រាប់អោយយើងមើលសត្វអោយបានល្អកុំឱ្យស៊ីដំណាំគេ។ ល្អយើងយកចិត្តទុកដាក់។ បើគេមិននិយាយ យើងមិនយកចិត្តទុកដាក់ប៉ុន្មានទេ ហើយសត្វនឹងដើរស៊ីដំណាំអ្នកជិតខាង។ ខ្ញុំគិតតែធ្វើការ។ បញ្ហាតែមួយនៅទីនេះ គឺខ្វះឧបករណ៍ដើម្បីធ្វើនិងកាប់ឆ្ការដី។ មួយជីវិតខ្ញុំ ខ្ញុំស្គាល់តែកន្លែងនេះ ហើយចង់ធ្វើការនៅទីនេះដោយសន្តិភាព និងមិនចង់បង្កើតរឿងទេ"។

(លោក សារ៉ុន អាយុ ៣៥ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

អ្នកដែលមកពីស្រុកក្រោមដើម្បីមកតាំងទីលំនៅក្នុងភូមិថ្មីនៅខាងខ្មែរក្រហម សុខចិត្តដកថយនៅចំពោះមុខឥរិយាបថប្រើអំណាចរបស់ប្រធានមូលដ្ឋានដោយសារភាពថា គេគ្មានអំណាចនឹងរួបរួមគ្នាដើម្បីធ្វើឱ្យគេស្តាប់។

"គេបានយកដីពីយើងមួយភាគដែលគេបានចែកឱ្យយើងដើម្បីយកទៅធ្វើផ្លូវ។ យើងបានចេញថ្លៃ ៣០០០០រៀលរួចទៅហើយ ដើម្បីបានលិខិតកម្មសិទ្ធិជាលើកដំបូង។ បន្ទាប់ពីសាងសង់ផ្លូវរួចហើយ គេបានទារ ២០០០០រៀលថែមទៀតដើម្បីធ្វើលិខិតជាថ្មី។ យើងមិនអាចប្តឹងទេ។ យើងគ្មានសិទ្ធិអំណាចទេ។ ប្រធានភូមិអាចសំរេចតាមអំពើចិត្តគាត់នឹងយកដីមួយដុំ។ គាត់ជាអ្នកមានអំណាចជាងគេ។ គាត់ដូចជាស្តេច។ គេបានប្រាប់យើងថា នឹងមានគំរោងអភិវឌ្ឍន៍នៅទីនេះ ប៉ុន្តែយើងនៅមិនទាន់ឃើញនៅឡើយ។ យើងមិនហ៊ានជួបប្រជុំគ្នាដើម្បីនិយាយអំពីបញ្ហាទាំងនេះទេ។ ប្រធានបានប្រាប់យើងថា បើអ្នកណាបង្កើតបញ្ហាអ្នកនោះនឹងត្រូវបណ្តេញចេញ។ អ្នកដែលមិនបង្កើតបញ្ហា អ្នកនោះត្រូវគេរាប់អាន។ បើយើងនិយាយអំពីបញ្ហារបស់យើងឱ្យប្រធានភូមិស្តាប់គាត់នឹងខឹង ហើយយើងខ្លាចក្រែងមានអ្វីអាចនឹងកើតឡើង។ កាលណាប្រធានភូមិនៅក្បែរយើង យើងមិនហ៊ាននិយាយទេ។ យើងមកពីស្រុកមួយទៀតដែលនៅទីនោះយើងគ្មានដីទេ។ នៅទីនោះយើងអាចនិយាយស្រួលជាមួយប្រធានភូមិជាងប្រធានភូមិនៅទីនេះ។ យើងនៅឆ្ងាយពីអ្នកដទៃ ហើយពួកប្រធានៗមានអំណាចច្រើនណាស់លើយើង។ យើងដូចជាខ្លា

នៅក្នុងទ្រុង យើងមិនអាចនិយាយអ្វី ធ្វើអ្វីទាំងអស់។ នៅទីនេះយើងមិនសូវស្គាល់គ្នាទេ។ យើងមកពីភូមិផ្សេងៗគ្នា។ ពិបាកណាស់។ មានមនុស្សច្រើនក្រុមណាស់។ កាលណាយើងមានពេលស្គាល់គ្នា និង កាលណាយើងឃើញថា មនុស្សទាំងអស់ស្លូត យើងនឹងទទួលរាប់រកគេ។

យើងចង់បានសិទ្ធិនិយាយអំពីបញ្ហាយើង។ យើងនិយាយដោយលាក់លៀមរវាងគ្នាយើង ប៉ុន្តែយើងមិននិយាយជាចំហទេ។ យើងគ្មានមេដើម្បីជួយនិងដឹកនាំយើងទេ។ យើងជាអ្នកក្រនិងជាអ្នកតូច"។

(ក្រុមអ្នកភូមិ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

នៅក្នុងភូមិមួយឆ្ងាយពីទីរួមខេត្ត នៅក្បែរព្រំដែនវៀតណាម ប្រធានភូមិដែលកាន់ការតាំងតែពីឆ្នាំ ១៩៧៩ ហាក់ដូចជាផ្លាស់ប្តូរបន្តិចបន្តួចនូវវិធីរបស់គាត់តាំងពីជំនាន់នោះមក។

"នៅទីនេះគ្មានបញ្ហាក្នុងភូមិទេ។ គឺខ្ញុំដែលជាអ្នកគ្រប់គ្រងមនុស្សទាំងអស់។ ខ្ញុំប្រាប់មនុស្សទាំងអស់កុំឱ្យបង្កើតរឿង ហើយឱ្យនៅឱ្យស្ងៀម។ ឥឡូវនេះយើងលែងមានអាវុធដើម្បីធ្វើឱ្យគេខ្លាចដើម្បីឱ្យគេនៅស្ងៀមទៀតហើយ ប៉ុន្តែខ្ញុំធ្វើឱ្យគេខ្លាចដោយនិយាយថា អ្នកណាបង្កើតបញ្ហាអ្នកនោះនឹងចូលគុក។ ខ្ញុំនិយាយដែរថា អ្នកដែលបង្កើតបញ្ហាអ្នកនោះអាចនឹងត្រូវសម្លាប់ដោយអ្នកដែលខ្លួនបង្កើតបញ្ហាជាមួយ។ ប៉ុន្តែទីនេះ គ្មានបញ្ហាទេ។ មនុស្សទាំងអស់នៅស្ងប់ស្ងៀម"។

(លោក លីវ អាយុ៥៥ឆ្នាំ ប្រធានភូមិ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

អំណាចក៏អាចជាមធ្យោបាយមួយដើម្បីជួយដោះកុនអវិជ្ជា អសមត្ថភាពរបស់មេ និង ការគ្មានក្បួនច្បាប់ជាក់លាក់។

"ការធ្វើការសំរុះសំរួលជាសមត្ថកិច្ចរបស់យើង។ យើងគ្មានអំណាចឱ្យលែងលះទេ។ ដោយហេតុថាយើង មិនអាចសំរេចឱ្យគេលែងលះ យើងប្រាប់កុំឱ្យគេលែងលះគ្នា ព្រោះនេះមិនមែនជាការងាររបស់យើងត្រូវសំរេចឱ្យលែងលះទេ"។

(លោក ដាវុធ អាយុ៥៦ឆ្នាំ ប្រធានឃុំ ឃុំអង្កុលក្រុងកែប ខេត្តកំពត)

"នៅពេលធ្វើការសំរុះសំរួល ខ្ញុំមិនចង់ឱ្យភាគីមកជាមួយសាក្សីច្រើនទេ។ គេមិនអាចត្រូវគ្នាទេ អ្នកទាំងអស់នោះមកធ្វើឱ្យឡប់។ ដើម្បីចៀសវាងកុំឱ្យមានសាក្សី ខ្ញុំមានបច្ចេកទេសមួយ។ ខ្ញុំប្រាប់ថា បើសាក្សីចង់និយាយ គេត្រូវឱ្យប្រាក់ខ្ញុំ១០០០០រៀល និងបារីមួយកញ្ចប់។ គ្មានអ្នកណាឱ្យប្រាក់ទេ ដូច្នេះគ្មានអ្នកណាមក ហើយគេនៅស្ងៀម។ ប្រធានភូមិបានឃើញថា នេះជា

គំនិតល្អមួយ។ បើមានសាក្សីច្រើនពេករឿងនេះទៅជាធំ ហើយជួនកាលមនុស្សអាចវាយគ្នាទៀតផង"។ (លោកល័ក្ខ អាយុ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្គុល ក្រុងកែប ខេត្តកំពត)

នៅទីនេះ អំណាចត្រូវបានប្រើដើម្បីគុណប្រយោជន៍ដល់មនោសញ្ចេតនាអាណិតអាសូរ។

"បុរសម្នាក់មានដីពីសង្គម។ គាត់បានបែកពីប្រពន្ធទីមួយតាំងពីសម័យសង្គមរាស្ត្រនិយមមកម្លេះ ហើយគាត់បានរៀបការប្រពន្ធថ្មី។ ប្រពន្ធទីមួយក៏បានរៀបការជាថ្មី ហើយមានកូនទៀតផង។ បុរសនោះស្លាប់ ប៉ុន្តែប្រពន្ធទីពីររបស់គាត់ប្រើប្រាស់ដីនោះចាប់តាំងពីឆ្នាំ១៩៧៩។ ប្រពន្ធទីពីរនោះបានធ្វើលិខិតកាន់កាប់ដីដែលគាត់មានដោយបង់ថ្លៃជាស្រូវ។ កូនប្រពន្ធទីមួយ ទាមទារដីរបស់ឪពុកខ្លួនពីប្រពន្ធទីពីររបស់ឪពុក។ ប្រពន្ធទីពីរបដិសេធ ព្រោះគាត់ក្រនិងចាស់ផង ហើយមានតែដីមួយដុំនោះដែលគាត់ដាំដុះជាមួយកូនប្រុសចិញ្ចឹមរបស់គាត់។ ប្រពន្ធទីពីរមកជួបខ្ញុំដើម្បីឱ្យខ្ញុំជួយគាត់ ព្រោះកូនរបស់ប្រពន្ធទីមួយកាចដាក់គាត់។ កូនមួយនៃប្រពន្ធទីមួយ មុនដំបូងបានចាប់ផ្តើមទាមទារសិទ្ធិធ្វើស្ករពីដើមត្នោតមួយដើម បន្ទាប់មកពីរដើម ហើយឥឡូវនេះ ដោយអាងលេសមរតកពីឪពុក គេចង់យកដីថែមទៀត។ ប្រពន្ធទីពីរមកជួបខ្ញុំដោយផ្ទាល់ ព្រោះខ្ញុំរស់នៅក្បែរគាត់។ ខ្ញុំបានទាក់ទងជាមួយប្រធានភូមិ ព្រោះបើគ្នាច្រើនវាស្រួលនឹងដោះស្រាយបញ្ហាមួយ។ នៅពេលធ្វើការសំរុះសំរួល មានប្រធានភូមិ ខ្ញុំ ប្រពន្ធទីពីរ កូនពីររបស់ប្រពន្ធទីមួយនិងសាក្សីប្រាំនាក់។ ខ្ញុំបាននិយាយថា ខ្ញុំមិនដឹងរឿងរបស់គ្រួសារនេះទេ ប៉ុន្តែខ្ញុំទទួលស្គាល់សិទ្ធិលើដីធ្លីចំពោះអ្នកណាដែលកាន់កាប់តាំងពីឆ្នាំ១៩៧៩ និងអ្នកដែលមានលិខិតកម្មសិទ្ធិ។ មានច្បាប់មួយដែលនិយាយថា ម្ចាស់ម្នាក់ៗមានសិទ្ធិកាន់កាប់ដី១៧កុង។ គឺច្បាប់១៩៧៩។ នៅឆ្នាំ១៩៨៩ គេបានធ្វើក្រដាសស្នាមចំពោះឈ្មោះទាំងអស់ណាដែលកាន់កាប់ដីនៅពេលនោះ។ មនុស្សទាំងអស់គ្មានលិខិតស្នាមអ្វីទេ ប៉ុន្តែឈ្មោះរបស់គេនិងទីកន្លែងដីធ្លីមានចុះនៅឃុំ។

ប្រពន្ធទីពីរបាននិយាយថា "ដីនេះជារបស់ខ្ញុំតាំងពីខ្ញុំរៀបការជាមួយឪពុកកូននេះ ហើយអ្នកណាក៏ដឹងដែរ។ ខ្ញុំបានឱ្យដើមត្នោតរួចហើយ ប៉ុន្តែខ្ញុំមានតែដីនេះទេ ខ្ញុំចាស់ហើយក្រទៀត ដូច្នេះខ្ញុំចង់ឱ្យដីនេះទៅកូនចិញ្ចឹមខ្ញុំ ក្នុងលក្ខខ័ណ្ឌដែលវាថែទាំខ្ញុំ"។ ខ្ញុំបានតែងលិខិតសន្យាតាមការទាមទារនេះ។ ខ្ញុំបានសុំឱ្យទាំងអស់គ្នាផ្តិតមេដៃ។ គេទាំងអស់យល់ព្រម។ ខ្ញុំមិនចង់ព្រមតាមការទាមទាររបស់ប្រពន្ធទីមួយទេ។ គាត់មានរោងរិឌ័អូ ហើយគ្មានបញ្ហារឿងលុយកាក់ទេ។ ខ្ញុំអាណិតប្រពន្ធទីពីរដែលចាស់និងក្រ"។

(លោកល័ក្ខ អាយុ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្គុល ក្រុងកែប ខេត្តកំពត)

បិតុនិយម

តាមប្រពៃណី មេទុកដូចជាឪពុកដែលបញ្ជាលើកូនរបស់ខ្លួន។ ដូចដែលឪពុកល្អនឹងមានកូនល្អ មេល្អនឹងត្រួតត្រាមនុស្សដែលមិនបង្កើតបញ្ហា។

"គ្មានបញ្ហារវាងមនុស្សទេ បើមេល្អ។ បើសំណាបល្អ ផលក៏ល្អដែរ។ គឺមេដែលធ្វើឱ្យមនុស្សល្អឬអាក្រក់"។

(លោក ចាន់ អាយុ៦០ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម)ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"ជាការល្អត្រូវធ្វើការប្រជុំមួយ ធ្វើដូច្នេះវានឹងជំរុញឱ្យយើងធ្វើការ។ ធ្វើដូច្នេះវានឹងរំលឹកខ្ញុំឱ្យនឹកដល់រឿងល្អៗ។ គឺទុកដូចជាយើងនៅក្នុងគ្រួសារតែមួយ។ ចំពោះខ្ញុំ ខ្ញុំរំលឹកឡើងវិញជានិច្ចនូវរឿងដដែលៗឱ្យកូនខ្ញុំស្តាប់ ហើយវាក៏ស្តាប់។ ប្រធានឃុំ និងប្រធានភូមិធ្វើដូចគ្នា ហើយគេក៏ស្តាប់។ បើគ្មានមេ គឺមិនល្អទេ។ ត្រូវមានអ្នកណាម្នាក់ដើម្បីដឹកនាំ។ គឺដូចជាហ្វូងសត្វគ្មានអ្នកឃ្វាល។ ត្រូវមានអ្នកឃ្វាល បើមិនដូច្នេះទេ សត្វនឹងដើររត់រាយ។ វាមិនដឹងទៅទីណា"។

(លោក សុខុល អាយុ៥៧ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

ឥឡូវនេះ សាសនានិងសាមគ្គីភាពត្រឡប់មកវិញហើយ។ វាគ្រាន់បើជាងកាលពីសម័យសង្គមរាស្ត្រនិយមទៅទៀត ព្រោះមានផ្លូវល្អ មានម៉ូតូច្រើនជាងកាលនោះ។ គេរកឃើញសីលធម៌ពីមុនវិញហើយ។ ខ្ញុំប្រាប់ឱ្យក្មេងៗគោរពចាស់ៗ។ មេត្រូវបង្ហាញគំរូឱ្យអ្នកដទៃ ធ្វើការល្អ មិនផឹកមិនលេងបៀ។ បើគ្រូល្អ សិស្សក៏ល្អ។ បើគ្រូអាក្រក់ សិស្សក៏អាក្រក់"។ បើគេជាមេល្អ យើងមិនខឹងទេ។ ប៉ុន្តែ គេបង្ហាញកម្លាំងដើម្បីឱ្យកូនចៅគោរព"។

(លោក ចាន់ អាយុ៦០ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"កូនចៅ"ចុះញ៉មនឹងអំណាច ទោះបីដាក់ឈ្មោះថាយ៉ាងម៉េចក៏បាន។

"យើងដូចជាអាយ៉ង ហើយយើងស្តាប់អ្វីដែលអង្គការ[១៤២] ប្រាប់ឱ្យយើងធ្វើ។ អង្គការគឺល្អ។ អង្គការប្រាប់យើងឱ្យធ្វើអ្វីដែលត្រូវធ្វើ។ យើងធ្វើតាម។ បើយើងមិនប្រឆាំងនឹងអង្គការទេនោះ យើងនឹងគ្មានបញ្ហា។ អ្នកដែលប្រឆាំងនឹងអង្គការជាមនុស្សល្ងង់។ គេមិនគោរពទេ គេត្រូវគោរពអ្នកដែលចេះដឹង អ្នកដែលនៅពីលើយើង"។

(អ្នកស្រី សារុំ អាយុ៥២ឆ្នាំ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តសៀមរាប)

[142] ទោះបីខ្មែរក្រហមលែងមាននៅក្នុងតំបន់ចាប់តាំងពី១៩៧៩ទៀតហើយក្តី នៅក្នុងភូមិដាច់ស្រយាលមួយនៃខេត្តស្វាយរៀង ក៏ដូចជាភូមិដទៃទៀតជាច្រើននៃប្រទេសកម្ពុជា គេប្រើពាក្យខ្មែរក្រហម អង្គការ ដើម្បីហៅរដ្ឋាភិបាល។ គេគ្មានបញ្ហាក្នុងការស្តាប់បង្គាប់អាជ្ញាធរមូលដ្ឋានទេ ទោះបីអាការៈខាងក្រៅយ៉ាងណាក្តី។

## ២. បណ្តេញចេញ ផាត់ចេញ

នៅកំពត បើវិធីចាស់របស់ខ្មែរក្រហមដែលដាច់ខាតក្នុងការគ្រប់គ្រងបញ្ហា ឧទាហរណ៍ដូចជាការបំបាត់រូបមនុស្សជាដើម លែងត្រូវបានទទួលស្គាល់ទៀតហើយនោះ អតីតប្រធានយោធាខ្មែរក្រហមដែលត្រូវបានតម្លើងជាប្រធានភូមិនិងប្រធានឃុំ ដើម្បីជាថ្នូរនឹងការផ្សះផ្សាជាតិ ចាប់អនុវត្តរបបថ្មី ហើយក្នុងករណីខ្លះគេជ្រើសរើសយកដំណោះស្រាយដែលស្រួល គឺការបំបាត់បញ្ហាដោយបណ្តេញមនុស្សចេញ។ នៅទីនេះ យើងបានរកឃើញឧទាហរណ៍នានា ដែលប្រធានមូលដ្ឋានព្យាយាមធ្វើការគាបសង្កត់លើមនុស្សដែលមិនយល់ស្របនឹងខ្លួន ឱ្យចាកចេញទៅនៅកន្លែងផ្សេង។

បណ្តេញមនុស្សចេញតាមផ្លូវរដ្ឋបាល :

"ឥឡូវនេះ របៀបដឹកនាំមនុស្សទំនើបណាស់។ មនុស្សលែងខ្លាចទៀតហើយ ជាពិសេសមនុស្សដែលមកពីខាងក្រៅ។ គេមិនចង់ស្តាប់ទេ។ បើមានបញ្ហាច្រើនពេកជាមួយអ្នកទាំងនោះ ខ្ញុំស្នើសុំឱ្យគេទៅរស់នៅកន្លែងផ្សេង។ ប៉ុន្តែខ្ញុំគ្មានអំណាចបណ្តេញគេទេ។ វិធីតែមួយគឺត្រូវសរសេរទៅប្រធានភូមិកំណើតរបស់គេ(គឺកន្លែងដែលគេរស់នៅពីមុន) ហើយសុំឱ្យគាត់ប្រាប់ទៅមនុស្សនោះឱ្យត្រឡប់ទៅភូមិកំណើតវិញ។ គឺជាអ្នកនៅក្រៅច្បាប់។ គេមានសិទ្ធិ ប៉ុន្តែគេមិនគោរពច្បាប់ទេ។ ដើម្បីចៀសវាងកុំឱ្យបញ្ហារីកធំ ខ្ញុំសុំឱ្យអ្នកទាំងនោះចាកចេញ ពីព្រោះខ្ញុំមិនចង់ធ្វើបាប។ ខ្ញុំមិនអាចធ្វើបាបគេបានទេ ពីព្រោះយើងជាខ្មែរទាំងអស់គ្នា។

ខ្ញុំចូលចិត្តនិយាយពីបញ្ហាមនុស្សទាំងអស់នៅពេលប្រជុំជាជាងដោះស្រាយបញ្ហាម្តងម្នាក់ៗ។ នេះមិនល្អទេ នាំឱ្យខាតពេលអ្នកដទៃ។ កាលសម័យខ្មែរក្រហម គេចំណាយពេលច្រើនណាស់ដើម្បីធ្វើការប្រជុំ និងដើម្បីនិយាយបញ្ហាពីអ្នកមួយទៅអ្នកមួយ កាលណាគេធ្វើស្វ័យទិតៀន។ គេបង្ខាប់ឱ្យធ្វើការ។ មិនយុត្តិធម៌ទេ។ មនុស្សទាំងអស់ត្រូវតែនិយាយ ហើយបើមានអ្នកណាម្នាក់មិនចូលចិត្តអ្នកដទៃ គេមុខជានិយាយកុហកដើម្បីឱ្យអ្នកដទៃទទួលទណ្ឌកម្ម។ ឥឡូវនេះប្រជាពលរដ្ឋចង់បានសន្តិភាព។ នៅទីនេះមានការងារច្រើនណាស់។ ប្រជាពលរដ្ឋកាប់ឆ្ការដើម្បីភ្ជួររាស់នៅរដូវខាងមុខ។ នៅទីនេះ យើងរស់នៅឆ្ងាយពីមណ្ឌលធ្វើសេចក្តីសំរេច(ក្រុង) យើងដោះស្រាយជម្លោះ និងតាមអ្វីដែលយើងចេះ។ ជាទូទៅ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតការបកស្រាយរឿងគឺខុសគ្នា។ កាលណាមានបញ្ហាច្រើនពេករវាងមនុស្ស ជាការប្រសើរគេត្រូវទៅរកកន្លែងផ្សេង។ នៅទីនេះ យើងចង់បានតែមនុស្សធ្វើការ និងមនុស្សដែលមិនបង្កើតបញ្ហា។ គេត្រូវប្រាប់ឱ្យមនុស្សនៅស្ងៀមស្ងាត់ ហើយបើគេមិនសប្បាយចិត្តទេ គេត្រូវតែចាកចេញ"។

(លោក យូ អាយុ៥៦ ឆ្នាំ អនុប្រធានឃុំ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

មនុស្សម្នាក់មកពី"ខាងក្រៅ"ទទួលការគាបសង្កត់ពីអ្នកភូមិទាំងមូល ហើយត្រូវតែចាកចេញ។

"ស្ត្រីម្នាក់បានខ្ចីប្រាក់ ៦០០០០រៀល ពីម្ចាស់បំណុលម្នាក់ ដើម្បីទិញស្រូវ។ កូនប្រុសរបស់ម្ចាស់បំណុលបានវាយកូនជ្រូកស្ត្រីនោះ។ ស្ត្រីនោះទាមទារប្រាក់ ៦០០០០រៀល ជាសំណង។ ម្ចាស់បំណុលបាននិយាយថា គាត់យល់ព្រមឱ្យ៣០០០០រៀល ហើយទារឱ្យស្ត្រីនោះសងប្រាក់គាត់វិញ ៣០០០០រៀលសល់ពីប្រាក់ទាំងអស់ដែលគាត់បានឱ្យខ្ចី។ ប្រធានក្រុមយល់ព្រមចំពោះដំណោះស្រាយនេះ ហើយប្រាប់ឱ្យស្ត្រីនោះឱ្យប្រាក់៣០០០០រៀលទៅម្ចាស់បំណុលវិញ។ ស្ត្រីនោះមិនសុខចិត្តទេ ហើយបានទៅជួបប្រធានភូមិ។ ប្រធានភូមិបាននិយាយដូចគ្នានឹងប្រធានក្រុមដែរ។ ថ្ងៃស្អែកឡើង ស្ត្រីនិងគ្រួសារគាត់បានចាកចេញពីភូមិនោះ។ គាត់បានលក់ដីថ្លៃ៨០០០០ រៀល។ ស្ត្រីនោះមកពីក្រៅ។ នៅទីនេះ មនុស្សទាំងអស់ជាគ្រួសារតែមួយ។ គេស្រឡាញ់គ្នាណាស់ គេស្គាល់គ្នាច្បាស់។ ស្ត្រីនោះមកពីក្រៅ។ គាត់ប្រហែលជាខ្លាច ហើយត្រូវចាកចេញ។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាគាត់ខ្លាច។ នៅទីនេះ មនុស្សទាំងអស់ជាបងប្អូននឹងគ្នា ហើយកាលណាមានរឿងប្រាក់ដូច្នេះ ស្ត្រីនោះប្រហែលជាគិតថា អ្នកស្រុកនៅទីនេះនឹងសម្លាប់គាត់។ ប៉ុន្តែគ្មានអ្នកណាធ្វើបាបគាត់ទេ"។

(អ្នកស្រី ឬទ្ធិ អាយុ២២ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

អ្នកដែលបង្កើតបញ្ហា ដែលហ៊ានបញ្ចេញមតិប្រឆាំងនឹងអាជ្ញាធរមូលដ្ឋាន និងពួកចោរ ត្រូវបណ្តេញឱ្យចេញពីភូមិ។ គេមិនញញើតនឹងបំភិតបំភ័យអ្នកទាំងនោះទេ ដោយបន្លឺពាក្យគំរាមសម្លាប់ចោល។

"ពីដំបូង អាជ្ញាធរមូលដ្ឋាននៃអតីតខ្មែរក្រហមបំភិតបំភ័យមនុស្ស។ គេនិយាយថា : "អ្នកណាបង្កើតបញ្ហា គេនឹងសម្លាប់អ្នកនោះធ្វើជាជី"។ តាមពិត ខ្ញុំមិនជឿថាគេបានសម្លាប់អ្នកណាម្នាក់ទេ ប៉ុន្តែកាលណាអ្នកណាម្នាក់មានបញ្ហា អ្នកនោះត្រូវតែចាកចេញ។ ករណីធ្ងន់ធ្ងរដែលគេនិយាយថានឹងសម្លាប់មនុស្សនោះ គឺករណីលួច។ រឿងនេះកើតឡើងចំពោះមនុស្សម្នាក់ដែលបានលួចម៉ាស៊ីនដេររបស់កម្មវិធីអភិវឌ្ឍន៍មួយនៃអង្គការអន្តរជាតិ។ គេបាននិយាយថា គេនឹងសម្លាប់ចោរនោះ ប៉ុន្តែខ្ញុំជឿថា គ្មានអ្នកណាសម្លាប់គាត់ទេ។ គាត់ត្រូវតែចាកចេញ"។

(លោក កែន បុគ្គលិក នៃអង្គការអន្តរជាតិ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

នៅទីនេះ ការចាត់ការដោះស្រាយបញ្ហាមនុស្សហឹង្សាម្នាក់ដោយការបណ្តេញឱ្យនៅក្រៅភូមិ។

"មនុស្សម្នាក់បានចាយវាយប្រាក់ គាត់ដើរលេងច្រើនណាស់។ ប្រពន្ធគាត់ក៏ធ្វើដូចគ្នា។ ប្តីខឹង។ គាត់បាននិយាយថា ប្រពន្ធគាត់មានសហាយ។ គាត់ប្រច័ណ្ឌ។ កាលណាមនុស្សប្រុសប្រច័ណ្ឌ គេនឹងឈ្លោះជាមួយប្រពន្ធ។ ក្រោយពីការឈ្លោះមក ប្រពន្ធមកជួបខ្ញុំ ហើយសុំឱ្យខ្ញុំជួយធ្វើការ

ប្រជុំសំរុះសំរួល។ គាត់ចង់ឱ្យប្តីគាត់ចុះហត្ថលេខាលើលិខិតសន្យាធ្វើយ៉ាងណាឱ្យប្តីលែងដើរលេងទៀត។ ប្តីមក ហើយខ្ញុំសរសេរក្នុងលិខិតសន្យាថា បើប្តីនៅតែដើរលេង គេត្រូវតែចុះចេញពីផ្ទះដោយគ្មានយកអ្វីទៅជាមួយ។ បើប្តីមិនព្រម គេអាចឡើងទៅលើបានរហូត ហើយទៅជួបអនុប្រធានភូមិ និងប្រធានភូមិ។ ជាគោលការណ៍ ខ្ញុំដោះស្រាយរឿងនេះបាន៩០%។ អ្នកដែលមិនចង់ស្តាប់ គឺអ្នកមកពីក្រៅ"។

(លោក នួន អាយុ ៤២ ឆ្នាំ អនុប្រធានភូមិ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

នៅក្នុងភូមិមួយនៅស្រុកក្រោម គេរកឃើញឥរិយាបថនៃការដោះស្រាយជម្លោះ ដោយការបំបាត់ប្រភពបញ្ហា។

"នៅទីនេះ ទម្លាប់គឺមិនត្រូវនិយាយអ្វី។ កាលណាប្រពន្ធត្រូវប្តីវាយ បើគាត់មិនប្តឹងទេ គ្មានអ្នកណាហ៊ាននិយាយទេ។ នេះជារឿងគ្រួសារ។ ប្រពន្ធកម្រទៅប្តឹងណាស់ ពីព្រោះក្រោយពីត្រូវវាយមកប្រពន្ធចង់រស់នៅជាមួយប្តីរបស់ខ្លួន។ ប៉ុន្តែ បើស្ថានការណ៍មិនអាចទ្រាំទ្របាន ប្រពន្ធនឹងប្តឹងទៅប្រធានភូមិ។ ក្រោយពីការព្រមានលើកទីបី ប្តីត្រូវចេញពីភូមិដោយមិនឱ្យយកអ្វីទៅជាមួយដូចដែលមានសរសេរនៅក្នុងលិខិតព្រមានលើកទីពីរ។ មានរឿងមួយកាលពីឆ្នាំទៅ។ ប្រពន្ធមិនខ្មាស់នឹងទៅប្តឹងប្រធានភូមិទេ។ ប្តីបានចុះហត្ថលេខាសន្យាថានឹងលែងវាយប្រពន្ធទៀត បើពុំនោះទេគាត់ត្រូវតែចុះចេញ។ ប្តីត្រូវតែចុះចេញ កាលណាគាត់ចាប់ផ្តើមវាយម្តងទៀត"។

(លោក សាម៉ាត អាយុ៤៥ឆ្នាំ ឃុំតាកែន ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

នៅទីនេះ ឥរិយាបថដូចគ្នា តែនីតិវិធីដើម្បីបណ្តេញមនុស្សចេញទន់ភ្លន់ជាង។

"នៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ គេចូលចិត្តធ្វើការសំរុះសំរួលជាជាងការលែងលះ។ បើប្តីវាយប្រពន្ធ ប្រពន្ធចង់លែងលះ តែប្តីមិនចង់។ គេធ្វើការសំរុះសំរួលដោយសរសេរលិខិតសន្យាមួយដែលនៅក្នុងនោះប្តីសន្យាថា លែងវាយប្រពន្ធទៀត។ បើប្រពន្ធមិនព្រមព្រោះប្តីវាយខ្លួនខ្លាំងពេក រឿងនោះនឹងឡើងទៅសង្កាត់ ហើយស្ថានីយនគរបាលនឹងធ្វើអន្តរាគមន៍។ គេនឹងធ្វើលិខិតសន្យាមួយជាថ្មី ប៉ុន្តែបើប្តីនៅតែវាយប្រពន្ធរហូតដល់បែកឈាម នគរបាលនឹងធ្វើទណ្ឌកម្មប្តីដូចជាឱ្យបោចស្មៅ ហើយរែកដីមួយថ្ងៃ។ បើប្តីចាប់វាយម្តងទៀត ប្រពន្ធអាចរត់ទៅផ្ទះឪពុកម្តាយខ្លួន ប៉ុន្តែប្រពន្ធតែងតែខ្មាស់អ្នកជិតខាង។ ជាទូទៅ ប្តីដែលវាយប្រពន្ធនៅតែវាយ។ ប្តីទាំងនោះតែងតែថាខ្លួនឈប់វាយហើយ តែបន្ទាប់មកនៅតែវាយ។ បើប្តីប្រពន្ធគ្មានកូន ហើយបើស្ថានការណ៍តឹងតែងសំរាប់ប្រពន្ធពេក ខ្ញុំជួយសំរួលដោយរីករាយឱ្យលែងលះ ប៉ុន្តែបើប្តី ប្រពន្ធមានកូន យើងព្យាយាមរារាំងកុំឱ្យមានការលែងលះ។

ក្នុងករណីតឹងតែងបំផុត កាលណាមនុស្សប្រុសឃៅឃៅហួសហេតុ ហើយយើងបានប្រឹងប្រែងច្រើនដងដើម្បីធ្វើការសំរុះសំរួល យើងបានដាក់ទណ្ឌកម្មរួចហើយនោះ ដូច្នេះយើងបង្ខំឱ្យមនុស្សប្រុសនោះចេញពីភូមិ។ ខ្ញុំព្យាយាមការពារប្រពន្ធដោយប្រាប់ឱ្យគាត់ទៅផ្ទះឪពុកម្តាយគាត់ ហើយខ្ញុំនាំប្តីទៅល្បាតដើម្បីចាប់ចោរ។ កាលណាគាត់ធុញទ្រាន់ គាត់នឹងចាកចេញពីភូមិ។

(លោក ល័ក្ខ អាយុ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្គុល ក្រុងកែប ខេត្តកំពត)

<u>ការតតាំងនឹងគាបសង្កត់របស់អាជ្ញាធរមូលដ្ឋាន</u>

នៅក្នុងភូមិដាច់ស្រយ៉ាលតែឯង និងសព្វថ្ងៃនេះ ភាគច្រើនក្នុងភូមិនៅជុំវិញក្រុង ឬនៅជិតផ្លូវធ្វើចរាចរ ធំៗ យើងបានរកឃើញថា ចំនួនមនុស្សដែលហ៊ានតតាំងនឹងការគាបសង្កត់ និងការបំភិតបំភ័យពីសំណាក់អាជ្ញាធរមូលដ្ឋានកាន់តែកើនឡើង។

ស្រីពៅ បានតតាំងនឹងការបំភិតបំភ័យ និងការគាបសង្កត់របស់ប្រធានភូមិ។ នាងនិយាយថា ដោយសារតែកំរិតអប់រំរបស់នាងខ្ពស់ជាងកំរិតធម្មតា។

"ខ្ញុំមកនៅដីនេះតាំងពីឆ្នាំ១៩៧៩។ កាលពី៥ឆ្នាំមុន ម្ចាស់ដើម**សម្បត្តិ**(ដែលបានដីនោះកាលពីសម័យសង្គមរាស្ត្រនិយម) បានលក់ដីទៅឱ្យមនុស្សម្នាក់ទៀតឈ្មោះ**រដ្ឋ** ហើយបន្ទាប់មក **រដ្ឋ**ក៏មកទាមទារដីពីខ្ញុំ។ ខ្ញុំមិនចង់ចេញទេព្រោះជាដីរបស់ខ្ញុំ ខ្ញុំនៅទីនេះតាំងតែពីឆ្នាំ១៩៧៩។ **រដ្ឋ**បានប្រាប់ខ្ញុំថា គាត់នឹងបំផ្លាញផ្ទះខ្ញុំ បើខ្ញុំមិនឱ្យដីទៅគាត់។ យើងបានធ្វើការប្រជុំសំរុះសំរួលមួយជាមួយប្រធានក្រុម។ ប្រធានក្រុមធ្វើការគាបសង្កត់មកលើខ្ញុំ គាត់និយាយថា **រដ្ឋ**ជាម្ចាស់ចាប់តាំងពីពេលគាត់ទិញដីនេះមកម្លេះ។ គាត់មានលិខិតទិញចុះហត្ថលេខាដោយអតីតប្រធានភូមិ។ ប្រធានភូមិនោះគិតថា គាត់ត្រូវតែជួយគ្រួសារ**រដ្ឋ**ដែលមានជាងខ្ញុំ។ អ្នកជិតខាងបានឃើញប្រធានភូមិផឹកស៊ីជាមួយ**រដ្ឋ**។ គេជាមិត្តភ័ក្រនឹងគ្នា។ ប្រធានក្រុមបានព្យាយាមធ្វើការគាបសង្កត់មកលើខ្ញុំ ប៉ុន្តែគាត់មិនដឹងថា ខ្ញុំបានរៀននៅស្រុកក្នុងឋានៈជាប្រធានសមាគមស្ត្រីទេ។ ខ្ញុំមិនព្រមចាញ់ ហើយរឿងនេះបានឡើងទៅភូមិ រួចសង្កាត់ និងស្រុក។ មនុស្សក្នុងភូមិមកខាងខ្ញុំ ឬទៅខាងរដ្ឋ ។ អ្នកក្រៗ គឺ២ ភាគ៣នៃភូមិមកខាងខ្ញុំ ហើយអ្នកមានៗទៅខាង**រដ្ឋ**។ គេស្គាល់គ្នា គេផឹកស៊ីជាមួយគ្នា។ ឥឡូវនេះ ប្រធានភូមិ និងប្រធានសង្កាត់ស្លាប់អស់ហើយ។ រដ្ឋមិនសូវមានបង្អែក ហើយក៏ឈប់និយាយពីរឿងនេះទៀត។ ខ្ញុំមិនព្រមចាញ់ទេ ព្រោះខ្ញុំបានទទួលការអប់រំ ខ្ញុំមិនខ្លាចទេ"។

(អ្នកស្រី ស្រីពៅ អាយុ ៤៨ឆ្នាំ សង្កាត់កែប ក្រុងកែប ខេត្តកំពត)

## ៣. ការបំបិទបញ្ហា

ក្នុងឧទាហរណ៍ជាបន្ទាប់នេះ បញ្ហាត្រូវបានគេបំបិទក្នុងគោលបំណងរក្សាការព្រមព្រៀងគ្នាជាធ្លុងមួយនៃសង្គមដើម្បីលាក់ការអៀនខ្មាស់ ពីព្រោះគេចាត់ទុកថា បញ្ហាមិនសំខាន់ ឬពីព្រោះគេមិនដឹងថាដោះស្រាយយ៉ាងណា។ អ្នកសំរុះសំរួល ជារឿយៗលើកយកប្រពៃណីដើម្បីគាំទ្រការអនុវត្ត។ យើងរកឃើញជាពិសេសនូវតិរិយាបថនេះនៅក្នុងពេលដោះស្រាយបញ្ហាសង្គម ដូចជាជម្លោះប្តីប្រពន្ធ ការរស់នៅជាសង្គម។ <u>និយាមដែលគេទទួលយកនោះគឺត្រូវនៅស្ងៀមស្ងាត់</u> ។

នៅក្នុងសង្គមមានលក្ខណៈប្រពៃណី ជនបទ និងគ្មានការទាក់ទងគ្នានេះ ការរក្សាឯកភាពនៃចង្កោមគ្រួសារ(ដែលមាន ឪពុក ម្តាយ និងកូន)គឺជាការសំខាន់ណាស់។ គ្រួសារ និងអ្នកសំរុះសំរួលខំប្រឹងរក្សាការមូលមតិ ឬការព្រមព្រៀងគ្នាក្នុងគ្រួសារ។ ផ្ទុយទៅវិញ បើសហព័ទ្ធទាំងពីរសុខចិត្តលែងលះគ្នា អ្នកសំរុះសំរួលអនុគ្រោះឱ្យបែកគ្នា ដោយសារមានការស្រុះស្រួលគ្នា។ យើងរកឃើញនូវការស្ទាក់ស្ទើរខ្លះនៃអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយជម្លោះប្តីប្រពន្ធ។ គេមិនសូវសប្បាយប៉ុន្មានទេ។ គេមិនហ៊ានជ្រៀតជ្រែកក្នុងរឿងប្តីប្រពន្ធជានិច្ចទេ។

"កាលណាខ្ញុំធ្វើការសំរុះសំរួល ខ្ញុំសុំឱ្យប្តីនិងប្រពន្ធមកផ្ទះខ្ញុំ។ គ្រួសារទាំងសងខាងតែងតែមកជាមួយប្តីប្រពន្ធទាំងនោះ។ គេបានពិភាក្សាបញ្ហារួចហើយ ហើយគ្រួសារនិមួយៗរួមដៃគ្នានៅពីក្រោយកូន។ ខ្ញុំមិនចង់ឱ្យអ្នកជិតខាងមកទេ បើមិនដូច្នេះទេមានមនុស្សច្រើនពេក ហើយគ្មានអ្នកណាស្តាប់អ្នកណាទេ។ អ្នកមកមុន អ្នកនោះនិយាយពីទស្សនៈរបស់ខ្លួន។ បើមនុស្សទាំងពីរនិយាយខ្លាំងហើយខឹង ខ្ញុំសុំឱ្យស្ងប់ស្ងៀម ហើយនិយាយអ្វីងាយៗ។ ជាគោលការណ៍ ក្រោយពីមានជម្លោះខ្លាំងៗមក គេត្រូវទុកពេលមួយថ្ងៃដើម្បីឱ្យកំហឹងស្ងប់ទៅវិញ។ ក្រោយពីបានស្តាប់មនុស្សទាំងពីរមក ខ្ញុំឱ្យដំបូន្មានដល់គេ។ ខ្ញុំនិយាយទៅគេដូចជាឪពុកនិយាយទៅកាន់កូន។ ចំពោះប្រពន្ធ ខ្ញុំនិយាយថា: "យើងជាស្រី ត្រូវអត់អោនឱ្យមនុស្សប្រុស។ ឯងត្រូវខន្តី ហើយនៅឱ្យស្ងៀម"។ ចំពោះប្តីដែលកាចពេក ខ្ញុំស្តីបន្ទោសពីចរិតលក្ខណៈរបស់គេថា:" ឯងមិនត្រូវវាយប្រពន្ធឯងទេ។ វាជាអំពើអាក្រក់។ បើប្រពន្ធរបួសឯងខាតបង់ប្រាក់ព្យាបាលពេទ្យ។ មនុស្សប្រុសដូចតែគ្នាទេ។ គេត្រូវរក្សាកិត្តិយស។ តាមប្រពៃណីខ្មែរ គេគ្មានសិទ្ធិធ្វើអ្វីដែលគេចង់ ដូចជាដាល់ឬវាយអ្នកណាម្នាក់ទេ។ ឯងវាយអ្នកណាម្នាក់ដែលជាមនុស្សដូចឯងដែរ។ ឯកគ្មានសិទ្ធិទេ"។

បន្ទាប់មក ខ្ញុំនិយាយទៅអ្នកទាំងពីរថា "យើងមានកូន យើងមានចៅ។ កាលណាឪពុកនិងម្តាយបែកគ្នាទៅ កូននឹងនៅកំព្រា"។ យើងនិយាយឱ្យចេះខ្មាស់ថា: "បើឯងបែកគ្នា បើឯង

ឈ្លោះគ្នា អ្នកជិតខាងគេនឹងសើចពីឯង។ រឿងនេះធ្វើឱ្យខូចកិត្តិយសគ្រួសារឯង។ កូនឯងនឹងពិបាករកប្រពន្ធរកប្ដី។ គេនឹងនិយាយថា គេមិនចង់រៀបការជាមួយកូនប្រុស ឬកូនស្រីរបស់គ្រួសារអាក្រក់ទេ។ ម្នាក់ៗទាំងអស់គ្នាគេមិនត្រូវឈ្លោះគ្នាទេ យើងធំហើយ ហើយយើងមានអាយុដំណាលគ្នា ដូច្នេះយើងឈ្លោះគ្នាធ្វើអ្វី?"។ ខ្ញុំនិយាយដែរថា មិនត្រូវធ្វើអ្វីខ្វះការពិចារណាទេ:"អ្នកឯងវាយគ្នា ថ្ងៃស្អែកអ្នកឯងត្រូវគ្នាវិញ។ បើយើងនៅតែឯង ឬនៅលីវ យើងពឹងផ្អែកលើខ្លួនឯង ប៉ុន្តែបើគេមានប្ដីមានប្រពន្ធនិងមានកូន យើងពិបាកលែងគ្នាណាស់។ អ្នកឯងទៅណា? វាពិបាកនឹងត្រឡប់មកផ្ទះឪពុកម្ដាយវិញណាស់។ កាលណាយើងមានផ្ទះច្រើន ហើយចែកចានឆ្នាំងគ្នា នោះនឹងមានបញ្ហា។ បើយើងចង់ហូបនៅម៉ោង៣ ហើយម្ដាយចង់ហូបនៅម៉ោង៥ នោះនឹងមានទំនាស់។ យើងត្រូវនៅក្រោមបញ្ជាឪពុកម្ដាយ តែយើងបាត់ទម្លាប់នេះទៅហើយ។ រស់នៅតែឯងស្រួលជាងរស់នៅរួមគ្នា។ រស់នៅជាមួយគ្រួសារផ្សេងទៀត វាពិបាកណាស់!"។ ពេលខ្ញុំនិយាយទាំងអស់នេះទៅ គេយល់គួរសម។

ខ្ញុំជាប្រធានភូមិតាំងតែ២០ឆ្នាំមកហើយ ហើយប្រហែល៨ លើ១០គូរ ដែលស្រុះស្រួលគ្នាឡើងវិញហើយ ២គូរទៀតខ្ញុំបញ្ជូនទៅឃុំ។

ខ្ញុំធ្វើការសំរុះសំរួលដោយនិយាយផ្ទាល់មាត់។ ខ្ញុំធ្វើក្រដាសស្នាម តែកាលណាប្ដីប្រពន្ធទាំងពីរព្រមព្រៀងលែងលះគ្នា។ ក្រដាសមួយសំរាប់ខ្ញុំ មួយសំរាប់ប្ដី និងមួយទៀតសំរាប់ប្រពន្ធ។ ក្នុងករណីធ្ងន់ធ្ងរ ខ្ញុំសុំឱ្យចាស់ទុំមកជួយនិយាយនឹងគេ។ ចាស់ទុំជួយខ្ញុំ។ គាត់ធ្វើការគាបសង្កត់លើមនុស្សទាំងនោះដោយនិយាយពាក្យក្នុងប្រពៃណី"។

(លោក ថារេត អាយុ៥៧ឆ្នាំ ប្រធានភូមិ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

"នៅក៏រិតយើង គេអាចធ្វើតែការសំរុះសំរួលប៉ុណ្ណោះ គេមិនអាចចេញសាលក្រមបានទេ។ កាលណាមនុស្សចង់លែងគ្នា ខ្ញុំធ្វើយ៉ាងណាឱ្យគេបានជួបជុំគ្នាយ៉ាងលឿនកុំឱ្យបាក់បែកគ្នាទាន់។ ខ្ញុំស្ដាប់គេ ហើយខ្ញុំព្យាយាមរកហេតុផលសព្វបែបយ៉ាងដើម្បីឱ្យគេរស់នៅរួមគ្នា។ ខ្ញុំប្រាប់គេថា : "ពីមុនអ្នកឯងនៅជុំគ្នា អ្នកឯងមានអនុស្សាវរីយ៍ជាមួយគ្នាច្រើន។ អស់ពេលច្រើនហើយដែលអ្នកឯងមានអនុស្សាវរីយ៍ជាមួយគ្នា អ្នកឯងមិនអាចបែកគ្នាយ៉ាងលឿនដូច្នេះទេ។ បើមួយខឹងនឹងមួយ អ្នកឯងនឹងខាតទាំងអស់គ្នា"។

(អ្នកស្រី ប៉ាន់ ប្រធានសង្កាត់ សង្កាត់ផ្សារកណ្ដាល២ ខ័ណ្ឌដូនពេញ ភ្នំពេញ)

"ក្នុងកម្លុងពេលសំរុះសំរួលរវាងប្ដីប្រពន្ធ ខ្ញុំនិយាយថា: ពីមុនអ្នកឯងស្រឡាញ់គ្នា។ អ្នកឯងមានកូន។ នៅជាមួយគ្នាទៅដើម្បីចិញ្ចឹមកូន!។ ឈប់ឈ្លោះគ្នាទៅ!។ បើអ្នកឯងផឹក អ្នកឯងឈ្លោះគ្នា

ហើយមិនធ្វើការ អ្នកឯងខាតបង់ប្រាក់។ បើឯងវាយប្រពន្ធ ហើយប្រពន្ធឯងទៅពេទ្យ ឯងខាតបង់ប្រាក់ជាច្រើន ព្រោះថ្លៃព្យាបាលថ្លៃណាស់។ ឈ្លោះគ្នារបៀបហ្នឹងនាំឱ្យខាតប្រាក់។ គេត្រូវឈប់ឈ្លោះគ្នា។ ស្ងប់ទៅ"។

ខ្ញុំឱ្យដំបូន្មាន។ បើប្ដីប្រពន្ធចង់លែងលះគ្នា ខ្ញុំនិយាយថាៈ"មានចានច្រើនក្នុងរាវ។ បើឈ្លោះគ្នាច្រើន វាធ្វើឱ្យចានរណ្ដំគ្នាបែក"។ បើបញ្ហាមិនសំខាន់ គេត្រូវនៅស្ងប់ស្ងៀម ហើយកុំគិតវាទៀត។ បើមានបញ្ហាជាមួយ អ្នកជិតខាង គេក៏ត្រូវអត់អោនដែរ។ សំខាន់ត្រូវមានការទាក់ទងល្អជាមួយអ្នកជិតខាង ក្នុងករណីមានបញ្ហា គេអាចជួយ"។
(លោក ឡែម អាយុ៥០ឆ្នាំ ប្រធានសង្កាត់ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ភ្នំពេញ)

"យើងស្ដាប់ភាគីទាំងពីរ បន្ទាប់មកយើងឱ្យដំបូន្មាន ឬព្យាយាមរកដំណោះស្រាយមួយ។ ក្នុងករណីប្ដីប្រពន្ធមិនត្រូវគ្នា យើងព្យាយាមសំរុះសំរួលនិងនិយាយប្រាប់អំពីផលវិបាកនៃអំពើរបស់គេ។ គេនិយាយថាៈ"ការលែងលះ អំពើហិង្សា ការជេរប្រមាថគ្នា មិនមែនជាដំណោះស្រាយនៅក្នុងគ្រួសារទេ។ ដំណោះស្រាយនោះគឺ ការអត់អោន ការអត់ធន់និងការទទួលស្គាល់កំហុស។ យើងចេញពីមនុស្សមួយទៅរស់នៅជាមួយមនុស្សម្នាក់ទៀតជាការមិនល្អទេ"។ យើងនិយាយពីរឿងជាក់ស្ដែងផងដែរថាៈ "បន្ទាប់ពីលែងលះគ្នាទៅតើវានឹងទៅជាយ៉ាងណា? តើអ្នកឯងរស់នៅយ៉ាងម៉េចនៅទីណា? ចុះកូនអ្នកឯងនឹងទៅជាយ៉ាងណា?"។ ប៉ុន្តែ បើគេមិនស្ដាប់យើងទេនោះ យើងទុកឱ្យពួកគេទៅតុលាការ"។
(លោក ផុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

នៅទីនេះ <u>ការបារម្ភក្នុងការការពាររបៀបរៀបរយសង្គមនៃភូមិមួយ</u>បានគ្របលើឆន្ទៈធ្វើការស៊ើបអង្កេតតាមការស្នើសុំរបស់មនុស្សមកពីក្រៅ។

"ដុំ ជានគរបាល។ គាត់រៀបការ ហើយមានកូនពីរ។ គាត់ជាអ្នកមានដើមកំណើតក្នុងភូមិ។ គាត់បានជាប់កិច្ចសន្យាជាមួយនារីក្មេងម្នាក់នៅភូមិមួយទៀត ដើម្បីមកធ្វើការនៅផ្ទះគាត់ជាអ្នកបំរើ។ នារីនោះទៅប្ដឹងប្រធាន ភូមិដោយប្រាប់ថា ដុំ បានរំលោភនាង។ ដុំ និយាយថារឿងនេះមិនពិតទេ។ យើងធ្វើការសំរុះសំរួលជាមួយក្មេងស្រីនោះ បុរសនោះ ប្រធានភូមិ និងចាស់ទុំពីរបីនាក់ទៀត។ ចាស់ទុំម្នាក់បានវិភាគសភាពការណ៍ ហើយបាននិយាយទៅក្មេងស្រីថា ប្រហែលជានាងស្រម័យ គឺស្រម័យថាបានធ្វើប្រពន្ធ។ ក្មេងស្រីញ័រ និយាយម្ដងលិចម្ដងកើត ហើយយំ។ ម្ដងនាងនិយាយពិត បន្ទាប់មកថាមិនពិត។ នៅពេលគេសួរថា នាងចង់បានអ្វី នាងនិយាយថាចង់ទាមទារប្រាក់ ២០០០០ ឬ ៣០០០០រៀល។ ខ្ញុំបាននិយាយទៅក្មេងស្រីនោះ ដោយនិយាយ

ខ្លាំងៗថាៈ"ឥឡូវនេះពិតឬមិនពិត? បើឯងមិនច្បាស់លាស់ទេ ឯងត្រូវប្រមូលអារម្មណ៍ ហើយគិតគូរឱ្យហ្មត់ចត់។ បើឯងប្រឌិតរឿង វាគ្មានប្រយោជន៍ទេ"។

ខ្ញុំនិយាយទៅមនុស្សប្រុសថាៈ "គេមិនត្រូវធ្វើអ្វីភ្លីភ្លើជាមួយមនុស្សនៅក្រៅគ្រួសារយើងទេ។ គេត្រូវនៅស្ងៀម។ គេត្រូវទុករឿងឱ្យស្ងាត់ចៀសវាងកុំឱ្យខ្មាស់គេ"។

យើងមិនបានធ្វើការស៊ើបអង្កេតទេ។ យើងធ្វើលិខិតសំរុះសំរួលមួយ ដោយសរសេរថា បណ្តឹងនោះមិនពិត ហើយថា គេមិនត្រូវនិយាយកុហក និងធ្វើបណ្តឹងសាថ្មីទេ។ ក្មេងស្រីនោះត្រឡប់ទៅភូមិនាងវិញ។ ក្មេងនោះមិនខ្មាស់គេទេ ព្រោះនាងនោះមកពីភូមិផ្សេង។ បើក្មេងស្រីនោះមានស្រុកកំណើតនៅភូមិយើង យើងនឹងពិភាក្សារឿងនេះជាមួយគ្រួសារនាង។ យើងនឹងនិយាយក្នុងគ្រួសារដើម្បីគិតគូរការសងជាប្រាក់ដែលនឹងត្រូវចិត្តភាគីទាំងសងខាង"។

(លោក ពឿន អាយុ៦៨ ឆ្នាំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

រឿងដែលប្រធានភូមិមិនចាត់ថាសំខាន់បែរជាពិបាកនឹងដោះស្រាយ។ រឿងនោះគឺ ការដកខ្លួនចេញ។

"ជម្លោះប្តីប្រពន្ធ ចាប់តាំងពីឆ្នាំ៩៨មកខ្ញុំឃើញមានតែពីររឿង។ គឺជាស្ត្រីដែលមកប្តឹង។ ក្នុងករណីទាំងពីរនេះ ខ្ញុំចង់ធ្វើការប្រជុំសំរុះសំរួល។ ខ្ញុំបាននិយាយថា រឿងនោះគ្មានភស្តុតាង។ ត្រូវមានភស្តុតាង។ បើគ្មានភស្តុតាង ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេ។ មានរឿងប្រពន្ធប្រច័ណ្ឌជាច្រើន។ ប្រពន្ធទាំងនោះនិយាយថា ប្តីមានស្រី ហើយថាខ្ញុំត្រូវមកដើម្បីនិយាយឱ្យប្តីខ្លាច។ បើគ្មានភស្តុតាង ខ្ញុំមិនដឹងធ្វើយ៉ាងម៉េចទេ។ ខ្ញុំនិយាយថា : "បើនាងប្រាប់ខ្ញុំថា ប្តីនាងទៅផ្ទះស្រីមួយទៀត នាងត្រូវមានភស្តុតាង។ បើខ្ញុំមិនដែលឮ បើខ្ញុំមិនដឹង ខ្ញុំមិនអាចនិយាយអ្វីបានទេ។ ជាការប្រសើរបើគេអប់រំខ្លួនឯង ហើយបើគេគិតគូររឿងនោះតែឯង។ ជាការគួរឱ្យខ្មាស់ដែលនិយាយរឿងទាំងនេះនៅមុខអ្នកដទៃ ចាស់ៗ និងលោកសង្ឃ។ យើងមិនចង់ដឹងច្រើនពេកទេ។ កាលណាប្តីផឹក ហើយចូលផ្ទះ បើយើងមិនឮអ្វីសោះ គឺគ្មានបញ្ហាទេ"។

(លោក ម៉ុន អាយុ៥៤ ឆ្នាំ ប្រធានភូមិ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"មនុស្សទាំងអស់មិនដែលឆ្លើយតបនឹងការកោះហៅទេ។ យើងស្វែងរកមនុស្សទាំងនោះ។ យើងអាចជួបជនជាប់ចោទនៅផ្ទះ ហើយសុំឱ្យគាត់និយាយពីហេតុការណ៍របស់ខ្លួន និងព្យាយាមសំរុះសំរួលរឿងនោះជាមួយគាត់។ បើមានបណ្តឹងបានដាក់ទៅតុលាការដែរនោះ យើងទុកឱ្យតុលាការជាអ្នកដោះស្រាយ។ បើមិនអាចរកជនជាប់ចោទឃើញទេនោះ យើងសុំឱ្យដើមបណ្តឹងដកបណ្តឹងរបស់ខ្លួនវិញ"។

(លោក ផុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

កុំលើកបញ្ហាឡើងព្រោះខ្លាចគំនុំ

"ជ្រូក បានស៊ីដើមដំឡូង។ ម្ចាស់ចំការទារ៥០០០រៀលក្នុងដើមដំឡូងមួយដើមដែលបានបំផ្លាញ។ ខ្ញុំនិយាយទៅគាត់ថា :"គឺអ្នកជិតខាងអ្នកឯងទេ គឺថៃដន្យដែលធ្វើឱ្យអ្នកឯងរស់នៅក្បែរគ្នា។ បើអ្នកឯងមានបញ្ហា ក្នុងជីវិតអ្នកឯង មានតែអ្នកជិតខាងទេដែលអាចជួយឯង។ មិនត្រូវបង្កើតរឿងនឹងគ្នាទេ"។ ខ្ញុំព្យាយាមនិយាយឱ្យមនុស្សស្ងប់ ហើយឱ្យដំបូន្មាន ដើម្បីកុំឱ្យគេនាំរឿងតទៅទៀត។ ខ្ញុំនិយាយថា ទាមទារឱ្យសងដើមដំឡូងវិញ គឺជាការមិនល្អទេ។ តទៅអនាគតអាចមានគំនុំ ហើយអ្នកជិតខាងនឹងមិនជួយអ្នកឯងទេ។ បើមនុស្សទាំងពីរចង់ត្រូវគ្នាតទៅទៀត គេត្រូវទុកការខូចខាតដើមដំឡូងនោះជាអសារបង់ទៅ"។

(លោក ម៉ុន អាយុ៥៤ឆ្នាំ ប្រធានភូមិ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

បំបិទរឿងដើម្បីរក្សាទំនាក់ទំនងល្អជាមួយអ្នកជិតខាងក្នុងករណីត្រូវការគេនៅពេលខាងមុខ។

"ខ្ញុំនិយាយថា: "ជាបញ្ហាតូចតាច មិនត្រូវបែកបាក់មិត្តភាពទេ។ បើមានផ្ទះឆេះ មានតែអ្នកជិតខាងទេដែលអាចជួយ។ អ្នកឯទៀតនៅឆ្ងាយណាស់។ កាលណាយើងឈឺក៏ដូចគ្នា។ គេត្រូវការអ្នកជិតខាង។ មិនត្រូវឈ្លោះជាមួយអ្នកជិតខាងទេ"។

(លោក វណ្ណាត អាយុ៥២ឆ្នាំ ប្រធានភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

ឈរលើប្រពៃណី ហើយជំរុញឱ្យបង្អោនខ្លួន និងសុខចិត្តអត់ទ្រាំ

គ្រឹះចាស់នៃប្រពៃណី និងសាសនា ចាក់ចូលជ្រៅក្នុងអំពើនៃជីវភាពប្រចាំថ្ងៃ។ ទោះជាយ៉ាងណាក្តី ផ្ទុយពីចំណេះដឹងដែលចរឹកទុកជាក្បួនខ្នាតពិតប្រាកដ គេបែរជាចម្លងចរិយាមារយាទ កាយវិការ និងពាក្យសំដីដែលគេដាក់ឈ្មោះថា "ប្រពៃណី" ឬ "តាមពីដើម"។ គេឮជារឿយៗពាក្យថា "គេធ្វើដូច្នេះ ព្រោះវាជាប្រពៃណី" ដើម្បីពន្យល់ ឬបញ្ជាក់ហេតុផលត្រឹមត្រូវនៃអំពើដោយពុំចាំបាច់យោងទៅដល់បទបញ្ជា ឬក្រមច្បាប់ណាមួយជាក់លាក់។

ក្នុងកម្លុងពេលប្រជុំសំរុះសំរួល យើងបានរកឃើញការនិយាយបញ្ចៀងទៅរកសុភាសិត និង គោលការណ៍សាសនាព្រះពុទ្ធ។ ក្នុងពេលអង្កេត យើងបានរកឃើញថា ការនិយាយយោងទៅរកប្រពៃណីវិលជាពិសេសជុំវិញទ្រឹស្តីកម្មផល (អ្នកដែលមានបញ្ហាថ្ងៃនេះត្រូវទទួលផលនៅជាតិក្រោយ អំពើនៅថ្ងៃនេះជាលក្ខខ័ណ្ឌនៃការចាប់ភពនៅជាតិមុខ) និងទៅរកការគោរពចរិយាមារយាទត្រឹមត្រូវ ដែលប្រកាន់យកឥរិយាបថបង្អោនខ្លួន និងស្ងប់ ស្ងៀម។

កាលណាគេនិយាយពីយុត្តិធម៌ សុភាសិតមួយតែងតែនឹកដល់ជានិច្ច ៖ "យើងដូចជាគ្រាប់ស្រូវក្នុងត្បាល់កិន ដែលកិនបំបែកពីលើផងពីក្រោមផង"។ បើ"អ្នកតូច" មានបញ្ហាជាមួយតុលាការ គេនឹងត្រូវទ្រមគ្រប់ជ្រុង។

ការនិយាយយោងទៅប្រពៃណី ត្រូវបានប្រើជាពិសេសក្នុងករណីជម្លោះប្តីប្រពន្ធ។ ការគាបសង្កត់លើដើមបណ្តឹងឱ្យចៀសវាងការបែកបាក់ប្តីប្រពន្ធ គឺជាការសំខាន់។ ប្រពន្ធដែលត្រូវប្តីវាយដំ ត្រូវបង្អោនខ្លួនចុះចាញ់ និងសុខចិត្តទ្រាំដោយមិនមានសេចក្តីសង្ឃឹម។ ការសំរុះសំរួលដែលធ្វើនៅថ្នាក់មូលដ្ឋាន មិនងាយអនុញ្ញាតឱ្យស្ត្រីគេចឱ្យផុតពីអាពាហ៍ពិពាហ៍ដែលមិនសមប្រកប សូម្បីតែគេសុំលែងលះ។

<u>គោលការណ៍ពុទ្ធសាសនា</u> ដែលបង្រៀនអំពីការមិនតបត និងអហឹង្សា ព្រមទាំងទ្រឹស្តីកម្មផល ត្រូវបានបកស្រាយនៅទីនេះថា ជាការសុខចិត្តទទួលស្ទើរតែមិនអាចចៀសវាងបាននូវជោគវាសនាអាក្រក់ដោយទទួលយកលទ្ធផលនៃអំពើពីអតីត និងដោយការប្រកាន់យកឥរិយាបថស្ងប់ដើម្បីត្រៀមខ្លួនចាំជាតិមុខ។

ដូច្នេះ អាពាហ៍ពិពាហ៍អពមង្គល គឺលទ្ធផលនៃកម្មអាក្រក់។ តាមប្រពៃណី អាពាហ៍ពិពាហ៍ដែលមិនចំរើនគឺមកពីស្ត្រី។

> "ខ្ញុំនិយាយទៅខាងស្រីថាៈ "ជីវិតឯងគឺជាលទ្ធផលពីជាតិមុន។ បើអ្នកណាគេក្រជាងឯងពីមុន ហើយឥឡូវគេមានជាង នេះមកពីផលនៃអំពើល្អ ឬ អំពើអាក្រក់។ គេត្រូវទ្រាំទៅ"។ ក្នុងករណីលែងលះប្រពន្ធនឹងរស់នៅលំបាកក្នុងឋានៈជាស្រីក្បាលមួយ។ តាមប្រពៃណី កាលណាមានតែស្រីនៅតែឯងគេតែងតែគិតថា កំហុសកើតមកពីស្រីនោះ។ ប្រុសអាចរៀបការជាថ្មីដោយស្រួល។ គេមិនថាកំហុសមកពីប្រុសទេ។ ចំពោះស្ត្រីនៅតែឯង គេនិយាយថា ស្រីនោះត្រូវបានប្តីបោះបង់ចោល ព្រោះជាស្រីមិនល្អ។ គេតែងតែស្នើកុំឱ្យប្រុសរៀបការជាមួយស្រីដែលរៀបការរួចទៅហើយនោះ។ ស្រីនេះគ្មានតម្លៃអ្វីទេ។ គេមិនចេះទ្រាំទ្រប្តីទេ។ ទោះបីជាកំហុសកើតមកពីប្រុសក្តី ទោះបីគេផឹក គេវាយប្រពន្ធក្តី គេមិនថាអ្វីដល់ប្រុសនោះទេ។ គាត់អាចរៀបការជាថ្មី បើប្រពន្ធគាត់ចុះហត្ថលេខាលើលិខិតអនុញ្ញាតឱ្យគាត់រៀបការ ទោះបីជាគ្មានលិខិតលែងលះក៏ដោយ។ រឿងនេះគឺវាអញ្ចឹង"។
>
> (លោក វណ្ណាត អាយុ៥២ឆ្នាំ ប្រធានភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

គេបង្អាក់កុំឱ្យមានជម្លោះទៅថ្ងៃមុខ ដោយលើកផលនៃអំពើអាក្រក់ទៅជាតិមុខ។

> "កាលណាមនុស្សពីរនាក់ឈ្លោះគ្នា មនុស្សម្នាក់ក្នុងចំណោមពីរនោះត្រូវនៅស្ងៀម ទោះជាត្រូវអត់អោនក្តី ឬសុខចិត្តទ្រាំក្តី។ ភ្លើងកំហឹងរលត់ឯង ហើយនិងមានសន្តិភាពឡើងវិញ។ ខ្ញុំក៏បាន

ព្យាយាមពិភាក្សាបញ្ហាកម្មពៀរនៃអំពើដែរ។ ខ្ញុំនិយាយថា "បើអ្នកឯងមានបញ្ហាកាលពីជាតិមុន នេះហើយជាលទ្ធផល។ បើអ្នកឯងខឹងឥឡូវនេះ បើអ្នកឯងចង់សងសឹក អ្នកឯងនឹងទទួលផលនៅជាតិមុខ។ អ្នកឯងត្រូវងាកមើលទៅក្រោយ ហើយរំលឹកដំបូន្មាន ដូនតាឡើងវិញ។ អ្នកឯងត្រូវធ្វើជាគ្រូសារគំរូដែលមិនបង្កើតបញ្ហា អ្នកដទៃនឹងគោរពអ្នកឯង"។

(លោក សាន អាយុ៧០ឆ្នាំ អាចារ្យ ឃុំចេក ស្រុកស្វាយជុំ ខេត្តស្វាយរៀង)

យ៉ាងណាក្តី ប្រពៃណីនិងការនិយាយយោងទៅកម្មនឹងមិនសូវមានផលទៅលើប្រជាជនក្រុងភ្នំពេញទេ។

"មនុស្សនៅស្រុកស្រែ និងមនុស្សអាយុលើសពី ៤០ ឆ្នាំ និយាយពីកម្ម។ គេនិយាយថា សភាពនៃជីវិតបច្ចុប្បន្នគឺជាកម្មវិបាកនៃអំពើពីជាតិមុន។ ប៉ុន្តែ ពួកក្មេងៗមិនចាត់ទុកថាកម្មទេ។ គេមិនទៅវត្តទេ។ តាមការពិសោធន៍ជីវិតប្រចាំថ្ងៃរបស់គេ គេច្រើននិយាយថា គេគ្មានសំណាង ឬគេប្រណិប័តមិនបានត្រឹមត្រូវជាមួយអ្នកធំ។ ឧទាហរណ៍ គេថា គេមិនបានចេញថ្លៃស្រី (ពេស្យា) ឱ្យមេដើម្បីឱ្យមេជួយ។

ទោះបីក្នុងចំណោមមនុស្សអាយុចាស់ក្តី ក៏មានមនុស្សដែលមិនជឿលើការប្រៀនប្រដៅរបស់ព្រះពុទ្ធដែរ។ គេទៅវត្តដើម្បីធ្វើបុណ្យភ្ជុំបិណ្ឌ លើសពីនេះទៅទៀតគឺដើម្បីបង្ហាញនិងរក្សាឈ្មោះរបស់គេដោយឱ្យជា ប្រាក់ទៅវត្តគឺមិនមែនដោយសារគេជឿពិតប្រាកដទេ។ បើគេមិនទៅវត្ត អ្នកជិតខាងនឹងនិយាយដើម។ គេនិយាយថា តើមនុស្សនេះមកពីណា? តើគេកាន់សាសនាគ្រីស្ត ឬអី? ឥឡូវនេះកាលណាចំណេះដឹងកើនបន្តិចម្តងៗ ជំនឿកាន់តែចុះថយ"។

(លោក សួយ អាយុ ៤៨ឆ្នាំ ភ្នំពេញ)

តាមប្រពៃណី យើងបានរកឃើញថា ការវាយប្រពន្ធខ្លួនឯង មិនត្រូវបានចាត់ទុកថាធ្ងន់ធ្ងរទេ បើ"ប្រពន្ធមិនហូរឈាមចេញពីក្បាល"។ នៅក្នុងករណីដែលមានជាបន្ទាប់ទៅនេះ រឿងទាក់ទងច្រើននឹងការខ្វះការគោរព ចំពោះមនុស្សម្នាក់ដែលមានវ័យចំណាស់ (យាយដៃវាយឪពុកក្មេក) ជាងការវាយប្រពន្ធខ្លាំង។

"ញ៉ឹលទៅផឹក។ គាត់ចូលមកផ្ទះវិញ។ គាត់បានវាយប្រពន្ធគាត់រហូតបាក់ដៃ។ ឪពុកក្មេកគាត់ចង់ចូលមកជួយ។ ញ៉ឹល កន្ទ្រាក់បានដំបងហើយចង់វាយឪពុកក្មេក។ អ្នកជិតខាងមកធ្វើអន្តរាគមនិងឃាត់គាត់។ ញ៉ឹល នៅតែខឹង។ គាត់ចង់បំផ្លាញផ្ទះចោលហើយបានដាល់ជញ្ជាំង។ គាត់បានយកគោរបស់ឪពុកក្មេកហើយចាកចេញទៅ។ ឪពុកក្មេកបានសុំឱ្យខ្ញុំធ្វើអន្តរាគមដើម្បីយកគោមកវិញ។ ខ្ញុំបានជួបញ៉ឹល ហើយខ្ញុំបានប្រាប់ឱ្យគាត់ឱ្យគោទៅវិញ ព្រោះដល់រដូវភ្ជួររាស់ហើយ។ ខ្ញុំបានប្រាប់គាត់កុំឱ្យបំផ្លាញផ្ទះ ហើយមករស់នៅជាមួយប្រពន្ធវិញ ព្រោះគេមានកូនដល់ទៅប្រាំពីរនាក់។ ញ៉ឹល មិនចង់ស្តាប់ទេ។ ខ្ញុំបាននិយាយទៅឪពុកក្មេកថា ដោយសារគាត់មិនត្រូវគ្នាជាមួយ

កូនប្រុសារប្រុស យកល្អគាត់ត្រូវចាកចេញពីផ្ទះដោយខ្លួនឯង។ ឪពុកម្តាយក្មេកបានយល់ព្រម ហើយបានសំរេចឱ្យផ្ទះគាត់ទៅកូនស្រីហើយក៏សង់ផ្ទះតូចមួយសំរាប់គាត់នៅក្បែរនោះ។ គាត់យកតែគោមួយនឹមទេ ហើយទុកពីរនឹមទៀតឱ្យកូនស្រី។ ខ្ញុំបានសុំឱ្យញ៉ីលសុំទោសដល់ឪពុកក្មេកដោយសារហ៊ានយារដៃរកវាយគាត់។ ប្រពន្ធទទួលយកសំណើនោះ។ ប្រពន្ធសប្បាយចិត្តណាស់ដែលប្តីបានសុំទោសឪពុកក្មេក។

ទោសដែលធ្វើទៅលើឪពុកក្មេកធ្ងន់ជាងទោសវាយប្រពន្ធ។ គេត្រូវដឹងគុណឪពុកម្តាយ និងឪពុកម្តាយក្មេក ពីព្រោះឪពុកម្តាយទ្រាំទ្រនឹងការលំបាកខ្លាំងណាស់ដើម្បីចិញ្ចឹមកូន។ វាយប្រពន្ធមិនល្អទេ ប៉ុន្តែគឺជាប្រពន្ធ ហើយ នេះជារឿងនៅក្នុងគ្រួសារ”។

(លោក សម្បត្តិ អាយុ៦១ឆ្នាំ ប្រធានភូមិ ឃុំអង្កុល ក្រុងកែប ខេត្តកំពត)

ការពន្យល់របស់ប្រពន្ធដែលត្រូវប្តីវាយ។

“ប្តីខ្ញុំគាត់ផឹក។ ពេលគាត់ចូលផ្ទះខ្ញុំនិយាយថា ខ្ញុំមិនសប្បាយចិត្តទេ ពីព្រោះគាត់បានឱ្យគេខ្ចីគោមួយនឹមដោយគ្មានការអនុញ្ញាតពីខ្ញុំ។ គោនោះជារបស់ឪពុកខ្ញុំ។ ខ្ញុំបានប្រាប់ថា ខ្ញុំបានសន្យាឱ្យអ្នកផ្សេងទៀតខ្ចីគោនោះហើយ។ ជម្លោះកាន់តែខ្លាំងឡើង ហើយយើងក៏វាយតប់គ្នា។ ឪពុកម្តាយខ្ញុំចូលធ្វើអន្តរាគម ដើម្បីបំបែកយើង។ ប្អូនប្រុសខ្ញុំទៅប្តឹងប្រធានភូមិ។ ប្រធានភូមិមកជាមួយអនុប្រធានភូមិ។ ប្រធានភូមិបាននិយាយថា យើងត្រូវឈប់ឈ្លោះគ្នា។ ដោយហេតុថា ប្តីខ្ញុំជាអ្នកបង្កអំពើហិង្សាខ្ញុំត្រូវជាអ្នកនិយាយមុន។ ខ្ញុំបាននិយាយពីភាពទន់ខ្សោយរបស់ស្ត្រី គឺមិនមានកម្លាំងកាយដើម្បីសងសឹកប្រុសទេ។ កម្លាំងតែមួយរបស់ស្ត្រី គឺជេរប្រុស។ ខ្ញុំគ្មានកម្លាំងដូចប្រុស ហើយខ្ញុំមានកូនតូច ខ្ញុំមិនអាចវាយប្តីខ្ញុំទេ។ ខ្ញុំបាននិយាយថា ប្តីខ្ញុំជាអ្នកចង់លែងលះ គឺមិនមែនខ្ញុំទេ។ ខ្ញុំមានកូនច្រើនណាស់ដែលត្រូវចិញ្ចឹម។ កូនខ្លះទៅរៀន។ ល្អត្រូវធ្វើលិខិតសន្យា។ នៅក្នុងលិខិតគេបានសរសេរថា បើប្តីខ្ញុំដើរលេងច្រើនពេក ប្រពន្ធមានសិទ្ធិស្តីបន្ទោស ប៉ុន្តែមិនត្រូវជេរបញ្ចោរប្តីទេ។ បើប្រពន្ធមិនជេរប្តីទេនោះ ប្តីមិនប្រើហិង្សាទេ ហើយគេអាចស្រុះស្រួលបាន។ គេបានសរសេរដែរថា បើពេលណាមានជម្លោះប្តីវាយប្រពន្ធ គេនឹងធ្វើតាមលិខិតសន្យា ដើម្បីបញ្ជូនប្តីទៅប៉ុស្តិ៍នគរបាលសង្កាត់។ ប្តីខ្ញុំបានធ្វើការសន្យាថានឹងមិនធ្វើដូច្នោះទៀត។ ខ្ញុំព្យាយាមធ្វើឱ្យខ្លួនខ្ញុំស្ងប់ និងស៊ូអត់ទ្រាំចាំមើលថា តើគាត់គោរពលិខិតសន្យាឬយ៉ាងណា។ ខ្ញុំមិនចង់ឱ្យរឿងកាន់តែធំ ព្រោះខ្ញុំមានកូនត្រូវចិញ្ចឹម ហើយខ្ញុំត្រូវការប្តី។ បើគាត់មិនគោរពខ្ញុំទេ ខ្ញុំនឹងប្រាប់ឱ្យប្រធានភូមិដឹង។ នៅប្រទេសខ្មែរ ស្ត្រីធ្វើការនៅចំការដូចប្រុសដែរ

ប៉ុន្តែលើសពីនេះទៅទៀតស្រីមានការងារនៅផ្ទះ ហើយមានកូនទៀត។ ស្រីត្រូវមានសិទ្ធិដូចគ្នា ហើយត្រូវមានសិទ្ធិលើសប្រុសទៀតផង។ ខ្ញុំបានស្តាប់វិទ្យុថា ស្រីមានសិទ្ធិច្រើនជាងប្រុស"។

(អ្នកស្រី គង់ អាយុ៣៩ឆ្នាំ ឃុំសង្កាល់ ក្រុងកែប ខេត្តកំពត)

នៅក្នុងករណីជម្លោះប្តីប្រពន្ធ ការសូត្រអំពីប្រពៃណីគ្មានបានចំណេញអ្វីដល់ប្រពន្ធដែលស្ថិតនៅក្នុងស្ថានភាពលំបាកក្នុងការរស់នៅជាប្តីប្រពន្ធទេ។

"កាលណាខ្ញុំធ្វើការសំរុះសំរួលមួយ ខ្ញុំគិតដល់ប្រពៃណីដែលកំណត់លក្ខណៈវិនិច្ឆ័យនៃប្រពន្ធល្អ គឺការប្រោសប្រណី និងការអត់អោន។ ខ្ញុំនិយាយទៅខាងស្រីថា គេត្រូវគាំទ្រជីវិតរបស់គេ ហើយត្រូវអត់ទ្រាំ"។

(លោក សារិន អាយុ៥៩ឆ្នាំ ប្រធានសមាគមមូលដ្ឋានខាងមីក្រូឥណទាន និងអភិវឌ្ឍន៍ជនបទ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ទីនេះ ម្តាយរបស់ក្មេងស្រីម្នាក់ ដែលចង់លែងលះទទួលស្គាល់ថា ការអនុវត្តរបស់ប្រធានភូមិ ដែលត្រូវធ្វើការគាបសង្កត់លើប្តីប្រពន្ធ ដើម្បីរារាំងការលែងលះគឺជាការល្អ។

"កូនស្រីខ្ញុំនៅក្មេង។ វារៀបការជាមួយប្រុសខ្ជិល។ ថ្ងៃមួយវាឈ្លោះគ្នា ហើយកូនស្រីខ្ញុំបានជេរប្រមាថឪពុកម្តាយប្តីវា។ ប្តីវាខឹងណាស់។ ខ្ញុំនិយាយនឹងប្តីខ្ញុំថា យើងត្រូវរង់ចាំមើលថាកូនស្រីខ្ញុំនឹងរៀនរស់បន្តិចម្តងៗជាមួយប្តីវា វានៅក្មេងហើយវាទាមទារច្រើនពេក វាត្រូវចេះអត់អោន។ កូនស្រីខ្ញុំខឹងកាលណាប្តីវាទៅលេងបាល់ទះ ឬលេងប៊ីយ៉ានៅក្រៅម៉ោងធ្វើការ។ ប្តីមិនចង់លែងលះទេ តមកឪពុកម្តាយវាមកហើយនិយាយថា កូនស្រីខ្ញុំបានជេរប្រមាថគាត់ ថាប្តីវាខ្ជិល។ យើងទៅជួបប្រធានភូមិទាំងអស់គ្នា។ ខ្ញុំមិនសប្បាយចិត្តទេ ព្រោះកូនស្រីខ្ញុំទើបរៀបការបីខែមុន ហើយខ្ញុំបានចំណាយប្រាក់មួយលានរៀលដើម្បីរៀបពិធីការ។ ប្រធានភូមិបានរៀបចំការប្រជុំសំរុះសំរួលមួយជាមួយអនុប្រធានភូមិទទួលបន្ទុកផ្នែកសន្តិសុខ ហើយនិងតាជុំដែលជាមនុស្សមានឥទ្ធិពលម្នាក់នៅក្នុងភូមិ។ អនុប្រធានភូមិបានសុំឱ្យកូនប្រុសរៀបរាប់រឿង បន្ទាប់មកគាត់សុំឱ្យកូនស្រីខ្ញុំនិយាយ។ យើងជាឪពុកម្តាយ មិនមានសិទ្ធិនិយាយទេ។ ប្រធានភូមិ និងអនុប្រធាននិយាយថា គេមិនត្រូវលែងលះគ្នាទេ។ បន្ទាប់មក គាត់ទុកពេលមួយអាទិត្យឱ្យប្តីប្រពន្ធគិត។ ពីដំបូងប្តីកូនស្រីខ្ញុំមិនចង់លែងលះទេ បន្ទាប់មកវាក៏យល់ព្រម។ បើតាមខ្ញុំ នៅទីនេះមានយុត្តិធម៌ល្អណាស់។ តួនាទីរបស់អាជ្ញាធរ គឺមិនមែនបំបែកបំបាក់អាពាហ៍ពិពាហ៍ទេ ដូច្នេះគាត់ធ្វើការគាបសង្កត់ ដើម្បីធ្វើឱ្យប្តីប្រពន្ធខ្លាច។ ប៉ុន្តែ បើវាទាំងពីរចង់លែងលះ អាជ្ញាធរនឹងយល់ព្រម"។

(អ្នកស្រី ឆែម អាយុ៤៨ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

## ៤. ការព្រមព្រៀងជាមិត្តភាព

បច្ចេកទេសនៃការសំរុះសំរួលមានតួនាទី "ធ្វើឱ្យស្ថានការណ៍ស្មុគ្រស្មាញទៅជាស្រួល"ហើយជាបច្ចេកទេសមួយដែលគេចូលចិត្តណាស់ កាលណាវាអនុញ្ញាតឱ្យមានការព្រមព្រៀងគ្នាជាមិត្តភាពរវាងភាគីពីរ។ ម្នាក់ៗបោះជំហានទៅរកម្នាក់ទៀតដើម្បីឱ្យមានការព្រមព្រៀងគ្នាដែលគ្មានអ្នកណាចំណេញគ្មានអ្នកណាខាត។ គ្មានអ្នកណាបាក់មុខ ហើយតុល្យភាពត្រូវបានស្តារមកវិញ។ វាអាចជាការព្រមព្រៀងគ្នាលើឥរិយាបថដែលត្រូវប្តូរ (ឧទាហរណ៍ ប្តីសន្យាថានឹងលែងវាយប្រពន្ធ ហើយប្រពន្ធសន្យាថា លែងដើរលេង) ឬលើការសងទូទាត់ផ្នែកហិរញ្ញវត្ថុ (ឧទាហរណ៍ អ្នកដែលបង្កឱ្យមានគ្រោះថ្នាក់ អ្នកដែលបានធ្វើឱ្យគេរបួស ឬបានសម្លាប់គេ សងប្រាក់ដែលបានចរចារួចទៅឱ្យម្នាក់ទៀត)។

<u>ការស្រុះស្រួលគ្នា ឬការធ្វើសម្បទានទៅវិញទៅមក</u>

"យើងមានសមត្ថកិច្ចធ្វើការសំរុះសំរួល ប៉ុន្តែមិនវិនិច្ឆ័យទេ។ គេអាចវិនិច្ឆ័យតែនៅតុលាការ។ ខ្ញុំស្តាប់ភាគីម្ខាង ហើយបន្ទាប់មកភាគីម្ខាងទៀត ហើយខ្ញុំព្យាយាមឱ្យភាគីទាំងពីរឈានទៅរកគ្នាទៅវិញទៅមក។ ខ្ញុំមិនកាន់ ជើងអ្នកណាទាំងសងខាង។ នៅក្នុងការសំរុះសំរួល ភាគីទាំងពីរត្រូវសុខចិត្តលះបង់អ្វីម្នាក់បន្តិច។ បើសត្វបានស៊ីដំណាំ គេមិនទាមទារចំនួនដែលខាតបង់ទាំងអស់ទេ គេទាមទារតិចជាងបន្តិចដើម្បីឱ្យមានសាមគ្គីភាព"។

(លោក ជាល អាយុ៥១ឆ្នាំ ប្រធានភូមិ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"នៅទីនេះ យើងអាចដោះស្រាយបញ្ហាព្រំដែនដីបានយ៉ាងងាយ។ នៅឆ្នាំ ១៩៩៤ គេបានចែកដីជាឡូតិ៍ៗ ទទឹង៣០ម៉ែត្រ បណ្តោយ៥០០ម៉ែត្រ។ កាលណាមានវិវាទ យើងអាចគូសព្រំដែនដីយ៉ាងងាយដោយវាស់ដី។ បើ អ្នកណាម្នាក់បានយកដីម្នាក់ទៀត បានកាប់ឆ្ការ គេទារពីម្ចាស់ដីទីមួយឱ្យសងថ្លៃកាប់ឆ្ការ។ បើម្ចាស់គ្មានប្រាក់ទេ គាត់អាចទារអ្វីដែលស្មើគ្នា ជាដីដែលមិនទាន់កាប់ឆ្ការរបស់អ្នកម្ខាងទៀត។ ម្នាក់ៗបានម្នាក់បន្តិច"។

(លោក ឈុំ អាយុ៥៤ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម)សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ការលែងលះដែលរៀបចំដោយប្រធានភូមិ ក្នុងពេលដែលប្តីប្រពន្ធទាំងពីរព្រមព្រៀងចង់បែកគ្នា។

"ឡុំ ជាប្រពន្ធដែលចាយខ្ជះខ្ជាយ។ គាត់មិនទុកលុយទេ។ ឪពុកម្តាយខាងប្តីចង់ឱ្យគាត់លែងលះប្រពន្ធនោះ។ ប្តីក៏ចង់លែងលះដែរ។ ចំពោះខ្ញុំ ខ្ញុំមិនចង់ឱ្យគេលែងលះគ្នាទេ ហើយខ្ញុំនិយាយថាៈ "អ្នកឯងរៀបការ ហើយអ្នកឯងមានកូន"។ បន្ទាប់មក ឡុំបាននិយាយថា ខ្លួនក៏ចង់លែងលះដែរ។ គេបានធ្វើលិខិតមួយដែលទទួលស្គាល់ថា ប្តីនិងប្រពន្ធយល់ព្រមលែងលះគ្នា ហើយចែក

ទ្រព្យសម្បត្តិគ្នា។ អ្វីដែលជារបស់អ្នកណាម្នាក់នៅមុនពេលរៀបការត្រូវឱ្យទៅអ្នកនោះវិញ ហើយអ្វីដែលរកបានរួមត្រូវចែកជាពីរ។ បើគេបានទិញគោមួយនឹម ម្នាក់ៗត្រូវបានគោមួយ។ គេចែកស្រូវជាពីរចំណែក។ បើមានកូន កូនច្បងត្រូវនៅជាមួយឪពុក ហើយកូនប្អូនត្រូវនៅជាមួយម្តាយ។ កូនតូចៗត្រូវនៅជាមួយម្តាយ។ ជារឿយៗ បើប្រពន្ធចង់ទុកផ្ទះ គេឱ្យសិទ្ធិទៅគាត់។ បើប្តីមិនព្រមទេ ផ្ទះត្រូវរុះរើ ហើយម្នាក់យកឈើពាក់កណ្តាល"។

(លោកសាវេត អាយុ៥៥ឆ្នាំ ប្រធានភូមិ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ក្នុងករណីជម្លោះដីធ្លី ប្រពៃណីនាំមកនូវជំនួយដ៏ធំនៅក្នុងការដោះស្រាយជម្លោះតូចៗអំពីព្រំដែនដី កម្មសិទ្ធិលើដើមឈើស៊ីផ្លែ ឬប្រឡាយទឹក។ នៅក្នុងករណីជម្លោះដីធ្លីសំខាន់ៗ ហើយដែលទាក់ទងនឹងកម្មសិទ្ធិដីប្រពៃណី(ដីដូនតា ការយកផលពីដី ដីមរតក)ច្របូកច្របល់ ឬក្លាយទៅជាស្រពិចស្រពិល ជាគុណប្រយោជន៍ចំពោះច្បាប់ (ជាពិសេសក្នុងទីកន្លែងដែលមានការចែកដី) ឬយ៉ាងហោចណាស់ជាគុណប្រយោជន៍ចំពោះអ្នកចេះប្រពៃណីនោះដែរ។

"ដីទាំងអស់ជារបស់តាម៉ៅជាយូរណាស់មកហើយៗឥឡូវនេះដីនេះត្រូវបានចែកក្នុងចំណោមកូន និងចៅរបស់តាម៉ៅ។ អ្នកទាំងនោះរស់នៅក្បែរគ្នា។ នៅឆ្នាំ១៩៧៩ មានមនុស្សមករស់នៅទីនេះ ហើយបានយកដីដូនតា។ នៅឆ្នាំ១៩៨៣ យាយយិន(ដែលគ្មានដីសោះនៅទីនេះមុនឆ្នាំ១៩៧៥) ដែលជាប្រពន្ធទីពីររបស់អ្នកណាម្នាក់នៅទីនេះ បានសុំតាំងទីលំនៅលើដីមួយផ្នែករបស់ក្មួយស្រីគាត់។ ក្មួយនោះបានអនុញ្ញាតឱ្យ។ បន្ទាប់មកយាយយិនបានឱ្យចៅគាត់មកតាំងទីលើដីក្បែរគាត់។ ឥឡូវនេះ ក្មួយស្រីគាត់ចង់យកដីមួយផ្នែកនោះដើម្បីពង្រីកផ្ទះគាត់។ យាយយិនមិនចង់ឱ្យទេ។ គាត់ថា ដីនោះជាដីរបស់គាត់។ គេបានធ្វើប្រជុំសំរុះសំរួលមួយជាមួយគ្រួសារទាំងមូល។ គ្រួសារបាននិយាយថា យាយយិនត្រូវប្រគល់ដីមួយផ្នែកនោះទៅវិញ។ គេបានស្រែកដាក់យាយយិន ហើយយាយយិនក៏ខឹង។ ខ្ញុំបានស្តាប់។ គ្រួសារមានហេតុផល។ ខ្ញុំនិយាយថា តាមច្បាប់ដីនោះជារបស់អ្នកដែលបានកាន់កាប់តាំងពីឆ្នាំ១៩៧៩។ ដូច្នេះ ដីនោះត្រូវតែជារបស់យាយ។ ប៉ុន្តែនៅទីនេះ យើងជាបងប្អូនគ្នាទាំងអស់នៅលើដីនេះ ហើយស្គាល់គ្នាច្បាស់ផង ដូច្នេះគួរចេះគោរពគ្នាសាមគ្គីគ្នា និងធ្វើអ្វីទៅតាមប្រពៃណី។ យាយត្រូវឱ្យដីមួយដុំទៅក្មួយវិញ។ នៅទីនេះជាភូមិចាស់ គេធ្វើតាមប្រពៃណី គេចូលចិត្តធ្វើតាមច្បាប់ដូនតា។ អ្នកទាំងអស់យល់។ បើគេធ្វើតាមច្បាប់លើរឿងដូច្នេះ មនុស្សមិនយល់ទេ។ គេមិនអាចធ្វើដូច្នេះបានទេ។ គេត្រូវនៅសាមគ្គីគ្នា"។

(លោក ជាល អាយុ៥១ឆ្នាំ ប្រធានភូមិ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ច្បាប់ប្រពៃណីជួយដល់ការដោះស្រាយប្រព័ន្ធទឹកកសិកម្ម

"បញ្ហាទឹកដីទាក់ទងជាពិសេសនឹងរឿងព្រំដែន បញ្ហាអ្នកជិតខាង។ កាលណាគេលើកភ្លឺស្រែជួន កាលអ្នកខ្លះរំកិលភ្លឺបន្តិចដើម្បីឱ្យបានចំណេញដី ឬក៏បំផ្លាញភ្លឺចោល។ ជួនកាលគេធ្វើដោយអចេតនា។ ខ្ញុំទៅកន្លែងដីនោះដើម្បីផ្ទៀងផ្ទាត់ ហើយទាញខ្សែដើម្បីធ្វើឱ្យភ្លឺរត់ត្រង់វិញ។ ដូច្នេះនៅរដូវភ្លៀងមានបញ្ហាទឹកស្រែដែលទប់ដោយភ្លឺ។ គេអនុវត្តច្បាប់ប្រពៃណី(ច្បាប់បូរាណ)។ ម្ចាស់ស្រែខាងលើទឹកជាម្ចាស់ភ្លឺខាងក្រោមទឹក ហើយអាចបើកភ្លឺបង្ហូរទឹកចេញពីស្រែខ្លួន។ គាត់អាចបង្ហូរទឹកទៅខាងដែរ។ បើម្ចាស់ស្រែខាងក្រោមទឹកនឹងស្រែសងខាងមិនព្រម នោះវាមានការឈ្លោះប្រកែកគ្នា។ គេត្រូវគោរពច្បាប់ពីបូរាណដែលនិយាយថាត្រូវធ្វើតាមទិសចរន្តទឹក"។

(លោកសាវេត អាយុ៥០ឆ្នាំ ប្រធានភូមិ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ)

នេះជាឧទាហរណ៍នៃការប្រជុំសំរុះសំរួលមួយរវាងប្រធានភូមិ ប្រធានក្រុម និងក្រុមមួយស្តីពីបញ្ហាដីធ្លី។

"មានផ្លូវមួយត្រង់ជាយូរយាណាស់មកហើយ។ ដីនោះជារបស់ប្តីប្រពន្ធចាស់ៗពីរនាក់ឈ្មោះយិ និង ហឿន។ ដោយហេតុថា ផ្លូវនោះមានភក់ គាត់បានធ្វើផ្លូវវាងមួយលើដីនៅក្បែរផ្លូវ ដោយមានការអនុញ្ញាតពីម្ចាស់ដី។ សព្វថ្ងៃនេះ កូនស្រីរបស់ម្ចាស់ដីចង់យកដីវិញហើយសុំឱ្យយកទៅតាមបន្ទាត់ផ្លូវចាស់។ តាយិ និងយាយ ហឿន ទារឱ្យសងគាត់១០០០០០រៀល ដើម្បីយកបន្ទាត់ផ្លូវចាស់ដែលកាត់មុខផ្ទះគាត់ ហើយដែលឥឡូវនេះពុះចំការគាត់ជាពីរចំណែក។ នៅពេលបញ្ហាចាប់ផ្តើម ខ្ញុំបានធ្វើការប្រជុំមួយជាមួយអ្នកស្រុកទាំងអស់នៅក្នុងក្រុម(ទាំងអស់គ្នាកើតចេញពីគ្រួសារធំតែមួយ)ដែលដើរតាមផ្លូវនោះ។ គេទាំងអស់គ្នាបាននិយាយថា គេព្រមឱ្យយកតាមបន្ទាត់ផ្លូវចាស់ព្រោះវាត្រង់។ ខ្ញុំបានសុំឱ្យរៃលុយគ្នាមួយគ្រួសារ១០០០០រៀល ក្នុងចំណោមគ្រួសារទាំង១៤។ ផ្ទុយទៅវិញ គេព្រមឱ្យ៥០០០រៀល។ ខ្ញុំនិយាយទៅស្ត្រីដែលចង់យកដីវិញនោះឱ្យជួយចេញគ្នា២០០០០រៀល។ គាត់ក៏បានយល់ព្រម។ បញ្ហាបែរជាចេញមកពីគ្រួសារទីបីគឺកូនប្រុសតាយិ និងយាយហឿន ដែលទាមទារ១០០០០០ រៀលដែរ ដើម្បីឱ្យផ្លូវនោះកាត់មុខផ្ទះរបស់ខ្លួន។ ខ្ញុំបាននិយាយទៅគាត់ថា ករណីរបស់គាត់ខុសពីអ្នកដទៃ ហើយគេឱ្យប្រាក់ទៅតែឪពុកម្តាយរបស់គាត់ទេ ព្រោះគាត់ចាស់ហើយក្រ ហើយសុំឱ្យគាត់ជួយគាត់ផងទៅ។ ខ្ញុំឱ្យយាយហឿនចែកប្រាក់នោះជាមួយកូនគាត់ទៅ ប៉ុន្តែគាត់មិនចង់ចែកសោះ។ សំរាប់ពេលនេះរឿងនោះត្រូវបានបញ្ចប់ហើយ។ ប្រធានភូមិបានធ្វើការប្រជុំសំរុះសំរួលពីរដងហើយ តែគ្មានបានលទ្ធផលសោះ។ យើងរង់ចាំមើល"។

(លោកសារឿន អាយុ៤១ឆ្នាំ ប្រធានក្រុម សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

នៅក្នុងខណៈសន្ទនាគ្នានេះ ស្ត្រីម្នាក់មកហើយនិយាយថា ប្រធានភូមិសុំឱ្យប្រធានក្រុមមកជួយគាត់ ដើម្បីធ្វើការសំរុះសំរួលរឿងនេះ។ យើងបានទៅដល់ទីកន្លែងជម្លោះ។ មនុស្សចំនួនប្រមាណ២០នាក់អង្គុយនៅក្នុងចំការមួយនៅជុំវិញប្រធានភូមិដែលសរសេរកំណត់ហេតុអង្គប្រជុំសំរុះសំរួល ដែលប្រហែលជាបានចាប់ផ្ដើមរួចហើយ។ ប្រធានភូមិប្រាប់ប្រធានក្រុមយ៉ាងលឿនឱ្យបានដឹងពីការជឿនលឿននៃរឿងនេះ។ ការពិភាក្សានៅពេលនោះ ផ្ដោតជុំវិញរឿងចំនួនប្រាក់ដែលគ្រួសារនិមួយៗត្រូវចេញឱ្យយាយហឿន។ ការប្រជុំនេះមានលក្ខណៈជាគ្រួសារនិងរីករាយ។ បរិយាកាសនៃអង្គប្រជុំប្រែប្រួលពីការនិយាយកំប្លែងលែងទៅជាការធ្វើជាខឹង។ ពួកស្រីៗលេងនិងចោលពាក្យឆ្លាតៗស្ដីអោយប្រុសៗ។ ស្រីៗទាំងនោះពោលពាក្យមិនពិរោះដាក់ប្រធានក្រុមហើយនិយាយថា ប្រធានក្រុមនោះនឹងស្រោតគេឱ្យនៅនទោលគក បើគេត្រូវបង់ថ្លៃនោះ។ ប្រធានក្រុមនិយាយយ៉ាងម៉ឺងម៉ាត់ ហើយបង្ហាញហេតុផលដើម្បីជំរុញឱ្យគ្រួសារទាំងអស់ចេញថ្លៃ។ ប្រធានក្រុមនិយាយដោយកាយវិការល្ងោនថាគាត់ឱ្យ១០០០០រៀល។ ប្រធានភូមិចុះឈ្មោះ និងទឹកប្រាក់នៅក្នុងលិខិតសន្យា។ អ្នកដ៏ទៃទៀតនិយាយថា គេនឹងឱ្យ៥០០០រៀល ហើយប្រធានភូមិក៏ចុះឈ្មោះ និងទឹកប្រាក់ដែរ។ ស្ត្រីម្នាក់មិនសប្បាយចិត្តទេ ហើយថា គាត់មិនចង់ចេញថ្លៃផ្លូវដែលគាត់ដើរតាមពីមុនដោយមិនបាច់បង់ប្រាក់នោះទេ។ ប្រធានក្រុមនិយាយទៅគាត់ថាៈ "អ្នកឯងមានស្រែច្រើន ដូច្នេះលក់អង្ករប្រាំគីឡូទៅ"។ មនុស្សទាំងអស់សើច។ យាយម្នាក់ប្រាប់ឱ្យប្រធានក្រុមកត់លើក្រដាសថា អ្នកណាបានបង់ប្រាក់ទើបអាចដើរតាមផ្លូវនេះបាន។ ប្រធានក្រុមនិយាយទៅឱ្យកូនប្រុសតាយីនិងយាយហឿនថា នេះមិនមែនជាអំណោយជាប្រាក់ទៅឱ្យយាយតាចាស់ៗទេ ប៉ុន្តែគឺជាសាច់ប្រាក់ប្រមូលបានដើម្បីជួយចេញថ្លៃគាត់ធ្វើបុណ្យនៅឯវត្ត។ ដូច្នេះនៅតែទារប្រាក់ពីកូនប្រុសនោះដែរ។ ទោះស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត កូនតាយីសុខចិត្តមិន ទាមទារប្រាក់។ ប្រធានក្រុមនិយាយថា គេត្រូវអាណិតតាយាយពីរនាក់នោះ គឺបើមានប្រាក់គ្រួសារទាំង១៤នោះនឹងរៀបចំធ្វើបុណ្យមួយឱ្យសប្បាយ។ គ្រួសារទាំងអស់ដែលមានមុខក្នុងអង្គប្រជុំនោះសុខចិត្តបង់ប្រាក់ទាំងអស់គ្នា។ ប្រធានភូមិក៏បានចុះឈ្មោះគ្រួសារដែលមិនមក ព្រមទាំងចុះទឹកប្រាក់៥០០០រៀល នៅពីមុខគ្រួសារនិមួយៗនោះ។ ការព្រមព្រៀងក៏ត្រូវបានរកឃើញ ហើយការពិភាក្សាបែរទៅរកកម្មវត្ថុដ៏ទៃទៀត ដូចជាថ្លៃត្រីផ្សេងៗ។ ប្រធានក្រុមប្រកាសថានៅ ថ្ងៃស្អែកទាំងអស់គ្នាត្រូវជួបជុំគ្នានៅវត្ត[១៤៣] ដើម្បីជាសញ្ញានៃសាមគ្គីភាព ហើយម្នាក់ៗត្រូវរៀបចំបាយយកទៅបរិភោគនៅទីនោះ និងរៀបចំចង្ហាន់លោកផងដែរ។ នៅពេលនោះប្រធានភូមិឱ្យទាំងអស់គ្នាចុះហត្ថលេខាលើលិខិតសន្យារបស់យាយហឿន។ លិខិតនេះសន្យាថា នឹងមិនទាមទារដីផ្លូវនោះទេ។ បន្ទាប់មក ប្រធានភូមិ និងប្រធានក្រុមឱ្យបោះបង្គោលដែលកំណត់ព្រំដែនកន្លែងធ្វើផ្លូវតទៅអនាគត ហើយគាត់ប្រាប់ឱ្យប្រុសៗខ្លះមកជុំគ្នានៅថ្ងៃស្អែកដើម្បីធ្វើផ្លូវ។

---

143 ក្រុមល្ខោនចល័តការមានសម្ដែងនៅទីវត្តនៅល្ងាចនោះដែរ។

ប្រធានក្រុមជាអ្នកដឹកនាំការពិភាក្សា។ ប្រធានភូមិមានភារកិច្ចចុះឈ្មោះមនុស្សដែលព្រមបង់ប្រាក់ធ្វើផ្លូវនៅលើលិខិតសន្យា។ គាត់ជាអ្នកតាក់តែងលិខិតសន្យាដែរ ដែលនៅក្នុងលិខិតនោះ យាយតាពីរនាក់ទទួលស្គាល់ថា គាត់បានឱ្យដីជាថ្នូរនឹងប្រាក់ប្រមូលបានឱ្យគាត់ ហើយសន្យាថានឹងមិនទាមទារអ្វីទៀតទេ។

នេះជាសេចក្ដីស្នើនៅក្នុងការសំរុះសំរួលដែលធ្វើឡើងដោយប្រធានភូមិ ថានឹងកាត់បញ្ហាទៅជាពីរ ហើយសំណើនោះមិនបានធ្វើឱ្យទិតពេញចិត្តទេ តែគាត់យល់ព្រម ទោះបីប្រធានភូមិសម្រេចយ៉ាងនោះក្ដី។

"មានត្រពាំងទឹកមួយនៅចន្លោះស្រែពីរ ដែលមានចម្ងាយពីគ្នាប្រមាណ១០ ទៅ២០ម៉ែត្រ។ ទិត និងយូ ជាម្ចាស់ស្រែ។ ម្នាក់ៗចង់ពង្រីកដីរបស់ខ្លួន ហើយទាមទារយកកម្មសិទ្ធិលើត្រពាំងទឹក។ ពីមុនត្រពាំងនេះមិនមែនជារបស់អ្នកណាម្នាក់ទេ។ ខ្ញុំបានស្នើកាត់ត្រពាំងជាពីរ ដើម្បីឱ្យម្នាក់ៗបានមួយចំណែក។ គ្មានអ្នកណាមួយចង់បានដូច្នេះទេ។ ដូច្នេះខ្ញុំនិយាយថា ត្រពាំងនេះត្រូវដាក់ជាត្រពាំងសាធារណៈ។ បើចង់ចចេស អ្នកទាំងពីរត្រូវខាតត្រពាំងនោះ"។

(លោក ខាល់ អាយុ៤៩ឆ្នាំ ប្រធានភូមិ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

នេះជាចម្លើយរបស់ទិត :

"រឿងមិនទាន់បានដោះស្រាយនៅឡើយទេ។ ខ្ញុំមិនពេញចិត្តនឹងសំណើរបស់ប្រធានភូមិទេ។ មានដីទំនេរនៅចន្លោះដីខ្ញុំ និងដីយូ។ ខ្ញុំបានកាប់ឆ្ការដីនោះរហូតទាល់នឹងត្រពាំង។ យូបានទៅប្ដឹងប្រធានភូមិ រួចសង្កាត់ទៀត។ ខ្ញុំបានកាប់ឆ្ការដីនោះតាំងតែពីឆ្នាំ១៩៧៩ ដីនេះជារបស់ខ្ញុំ។ ពីដើមដំបូងខ្ញុំយល់ព្រមឱ្យដីនោះមួយចំណែក ប៉ុន្តែយូឈ្លើយពេក ដែលខ្ញុំសម្រេចចិត្តថាមិនត្រូវឱ្យ។ គាត់បាននិយាយថា ខ្ញុំគ្មានសិទ្ធិបន្តធ្វើស្រែលើដីនោះទេ។ ដំណោះស្រាយរបស់ប្រធានភូមិគឺត្រូវចែកដីជាពីរ។ ខ្ញុំមិនយល់ព្រមទេ។ នៅសាលាសង្កាត់ពួកគេនៅតែនិយាយដដែល។ ខ្ញុំបានបដិសេធ។ យូនិយាយថា គេយល់ព្រមទុកដីឱ្យនៅជាដីសារធារណៈ។ ខ្ញុំចង់ដាំដើមឈើនៅជុំវិញត្រពាំង តែយូហាមឃាត់ខ្ញុំ។ គាត់បានលក់ដីគាត់ឱ្យនគរបាលម្នាក់ បន្ទាប់មកនិយាយថា ដីខាងត្រពាំងជាដីសាធារណៈ។ ខ្ញុំមិនសប្បាយចិត្តនឹងដំណោះស្រាយរបស់ប្រធានភូមិទេ ប៉ុន្តែខ្ញុំមិនចង់ឱ្យរឿងក្លាយជាធំ ហើយបង្កើតបញ្ហាតទៅទៀតទេ។ ដូច្នេះខ្ញុំទទួលយក។ ខ្ញុំមិនចង់ខឹងនិងយូទេ។ ខ្ញុំគិតថា ប្រធានភូមិជាមនុស្សល្អ។ គេទាំងអស់គ្នាចាត់ទុកគាត់ជាឪពុកដែលមើលកូនចៅ។ ខ្ញុំខកចិត្តនឹងដំណោះស្រាយនៃរឿងនេះ។ ខ្ញុំបានកាប់ឆ្ការដី ខ្ញុំធ្វើដីនេះ ប៉ុន្តែគេឱ្យចែកដីនេះ។ តែក៏ល្អដែរ ខ្ញុំយល់ព្រមតាមសំណើរបស់ប្រធានភូមិ និងចៅសង្កាត់"។

(លោកទិត អាយុ៤៧ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ចម្លើយរបស់យូ :

"ទិតចង់រំកិលដីស្រែមករកដីខ្ញុំ។ គាត់បានកាប់ឆ្កាដើនោះ។ ខ្ញុំចង់ដាំបង្គោលដើម្បីសំគាល់ព្រំដែនដីខ្ញុំ។ ទិតបាននិយាយថា ខ្ញុំគ្មានសិទ្ធិយកដីដែលខ្ញុំមិនបានកាប់ឆ្ការទេ។ ខ្ញុំនិយាយថា ខ្ញុំយកតែដីទំនេរប៉ុណ្ណោះ។ ខ្ញុំចង់ យកត្រពាំងនឹងដាំដើមឈើ។ ខ្ញុំនិយាយថា ត្រពាំងជារបស់ខ្ញុំ ព្រោះតាខ្ញុំបានប្រើប្រាស់ត្រពាំងនោះ។ គាត់ទៅជួបប្រធានភូមិ ហើយប្រធានភូមិបានស្នើកាត់ត្រពាំងជាពីរ។ ខ្ញុំចង់បានត្រពាំងទាំងមូលរបស់ជីតាខ្ញុំ។ នៅទីបញ្ចប់ ប្រធានភូមិនិយាយថា ដីនោះជាដីសាធារណៈ ហើយអ្នកណាក៏អាចទៅត្រពាំងនោះដែរ។ ខ្ញុំស្តាប់គាត់"។

(លោក ទិត អាយុ៥៣ ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

<u>ការសំរុះសំរួលរឿងហិរញ្ញវត្ថុ</u>

រឿងមួយចំនួនត្រូវបានដោះស្រាយតាមរយៈការចរចាផ្នែកហិរញ្ញវត្ថុ។ រឿងនេះទាក់ទងជាពិសេសនឹងករណីគ្រោះថ្នាក់ចរាចរ ទ្រព្យសម្បត្តិត្រូវបំផ្លាញដោយអចេតនា បញ្ហារវាងមនុស្ស ប៉ុន្តែក៏ទាក់ទងនឹងករណីព្រហ្មទណ្ឌដែរ។

"ករណីព្រហ្មទណ្ឌជាច្រើនត្រូវបានដោះស្រាយដោយការសងប្រាក់។ អ្នករំលោភត្រូវជួយជនរងគ្រោះ ឬ គ្រួសាររបស់គេ។ គេចូលចិត្តឱ្យអ្នករំលោភបង់ប្រាក់ជាជាងឱ្យគេដាក់គុក ជាពិសេសក្នុងករណីអចេតនា ដូចជា គ្រោះថ្នាក់ចរាចរជាដើម។ ឧទាហរណ៍ បើសិនជាមនុស្សម្នាក់ស្លាប់ក្នុងគ្រោះថ្នាក់មួយ គ្រួសាររបស់ជនរងគ្រោះនោះនឹងទាមទារប្រាក់ពីអ្នកបើកបរទោះបីគាត់គ្មានការទទួលខុសត្រូវក៏ដោយ។ គេមិនសូវមើលទៅអ្នកណាដែលជាអ្នកធ្វើខុស និងអ្នកដែលមានហេតុផលទេ។ គឺអ្នកដែលបង្កឱ្យមានការស្លាប់ ទោះបីអចេតនាក្តី ដែលត្រូវបង់ប្រាក់ឱ្យទៅគ្រួសារអ្នកស្លាប់ ទោះបីជាកំហុសនោះជាកំហុសរបស់អ្នកស្លាប់ក៏ដោយ។

ឧទាហរណ៍ រថយន្តតាក់ស៊ីមួយទៅជល់នឹងរថយន្តកាមីញ៉ុងមួយ។ អ្នកបើកបរតាក់ស៊ីត្រូវស្លាប់។ អ្នកបើកបរកាមីញ៉ុងទាមទារឱ្យគ្រួសារអ្នកបើកបរតាក់ស៊ីសងថ្លៃខូចខាតកាមីញ៉ុងរបស់ខ្លួន។ យើងព្យាយាមកាត់បន្ថយទឹកប្រាក់ដែលអ្នកបើកបរកាមីញ៉ុងទាមទារ ដើម្បីកុំឱ្យគ្រួសារកំពុងកាន់ទុក្ខមានបន្ទុកធ្ងន់ពេក។ ដូច្នេះ យើងត្រូវធ្វើការសំរុះសំរួល។ យើងជួយឱ្យភាគីទាំងពីរនិយាយគ្នា ហើយធ្វើឱ្យការទាមទារដែលអាចទទួលយកបានចំពោះភាគីទាំងសងខាង"។

(លោក ឡែម អាយុ៥០ឆ្នាំ ប្រធានសង្កាត់ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ភ្នំពេញ)

ម្តងនេះ នគរបាលជាអ្នកបំពេញតួនាទីជាអាជ្ញាកណ្តាលនៅក្នុងការតថ្លៃរឿងប្រាក់កាសមួយ។ ជារង្វាន់ចំពោះសេវាល្អរបស់នគរបាលទាំងនោះ គេបានទទួលភាគរយនៃទឹកប្រាក់ចរចា។ រឿងនេះមិនអាចប្រព្រឹត្តទៅដោយគ្មានជម្លោះផ្ទៃក្នុងតទៅទៀតឡើយ។

"អ្នកបររ៉ឺម៉កម្នាក់បើកជល់នឹងតាក់ស៊ីមួយ។ អ្នកបើកបរនោះត្រូវស្លាប់។ គឺជាកំហុសរបស់អ្នកបើករ៉ឺម៉ក។ ប្រពន្ធអ្នកបើករ៉ឺម៉កបានសុំឱ្យនគរបាលធ្វើអន្តរាគមដើម្បីទាមទារប្រាក់៥០០០ដុល្លាពីអ្នកបរតាក់ស៊ីដើម្បីទូទាត់ការស្លាប់របស់ប្តីគាត់។ ស្ត្រីនោះមានផ្ទៃពោះ ហើយគ្មានប្រភពចំណូលទេ។ ដោយមកជាមួយនគរបាលមួយក្រុមយើងបានដើរតួជាអ្នកកណ្តាលនៅក្នុងការពិភាក្សារឿងលុយកាក់នេះ ដោយម្តងកាន់ជើងអ្នកម្ខាង និងម្តងកាន់ជើងអ្នកម្ខាងទៀតរហូតដល់រកឃើញការព្រមព្រៀងទៅវិញទៅមក។ យើងបានបង្ហាញការស្នើសុំទៅអ្នកបើកតាក់ស៊ី។ អ្នកបរនោះនិយាយថា ប្រាក់ដែលទាមទារនោះច្រើនពេក។ យើងបានពិភាក្សាជាមួយប្រពន្ធអ្នកបររ៉ឺម៉កដោយពន្យល់គាត់ថា ត្រូវតែបន្ថយប្រាក់ដែលគាត់ទាមទារ។ ក្រោយពីពិភាក្សាម្តងជាមួយភាគីម្ខាង និងម្តងជាមួយភាគីម្ខាងទៀតអស់រយៈពេលបីឬបួនថ្ងៃមក ភាគីទាំងពីរព្រមព្រៀងគ្នាលើទឹកប្រាក់៥២០ដុល្លា។ អ្នកបរតាក់ស៊ីក៏បានឱ្យ៥០ដុល្លាទៅប្រធានអង្គភាពនគរបាលដែរ ដែលបានជួយក្នុងរឿងនេះ។ ទឹកប្រាក់នេះ ជាគោលការណ៍ត្រូវជា១០%នៃទឹកប្រាក់ដែលបានចរចារួច។ តាមទម្លាប់ ប្រធានអង្គភាពនគរបាលត្រូវចែកប្រាក់នេះក្នុងចំណោមសមាជិក១៥នាក់នៃក្រុមនគរបាល ហើយតំកល់ប្រាក់៤០%នៃប្រាក់នេះនៅក្នុងកេះខ្មៅ។ ប្រាក់នេះប្រើសំរាប់ករណីមានបញ្ហាក្នុងរង្វង់អង្គភាពនគរបាល ដូចជាសំរាប់ជម្ងឺ ពិធីបុណ្យសពជាដើម។ បើប្រាក់នោះមិនបានចំណាយក្នុងឆ្នាំនោះទេ គេត្រូវចែកចាយទៅវិញជារង្វាន់ប្រចាំឆ្នាំដល់នគរបាល។ ប៉ុន្តែ នគរបាលខ្លះលាក់ទឹកប្រាក់ដែលបានមកពីការផាកពិន័យដើម្បីទុកសំរាប់ខ្លួនឯង។ ពេលណានគរបាលដទៃទៀតដឹងពីចំនួនទឹកប្រាក់ដែលគេឃើញ ហើយមានការខុសគ្នាជាមួយនឹងប្រាក់ដកល់ក្នុងកេះខ្មៅ នោះនឹងមានការឈ្លោះប្រកែកគ្នានៅក្នុងប៉ុស្តិ៍នគរបាល។ រឿងនេះមានជាញឹកញាប់"។

(លោកឡេង អាយុ៣៨ឆ្នាំ នគរបាល ភ្នំពេញ)

## ការទូទាត់គ្នាជាទឹកប្រាក់ចំពោះដំណាំដែលសត្វស៊ី

"មានបញ្ហាសត្វស៊ីដើមឈើស៊ីផ្លែ។ កាលណាជ្រូកឬគោធ្វើឱ្យខូចខាត គេព្យាយាមនិយាយគ្នាជាមួយម្ចាស់សត្វ។ បើការខូចខាតមិនធំប៉ុន្មាន គេមិននិយាយទេ ឬគេបង្កាដោយគ្រាន់តែប្រាប់ម្ចាស់ឱ្យប្រយ័ត្នសត្វ។ បើការខូចខាតធំដុំ គេទាមទារឱ្យសងទូទាត់ជាប្រាក់។ ចំពោះដើម

ស្វាយមួយដើមគេទារប្រាក់៥០០០រៀល មួយដុល្លា សំរាប់ដើមដូងមួយដើម ៥០០០រៀលសំរាប់ដើមសាម៉ារមួយដើម។ គេមិនគិតពីដើមចេកទេ ព្រោះមានដើមចេកច្រើនណាស់។ នឹងមានការឈ្លោះគ្នា បើមនុស្សពីរនាក់មិនព្រមព្រៀងគ្នាលើទឹកប្រាក់ដែលត្រូវសង ឬបើអ្នកណាម្នាក់នៃអ្នកទាំងពីរកុហក។ ពេលនោះ គេទៅជួបប្រធានក្រុម។ ប្រធានក្រុមប្រាប់ឱ្យមនុស្សទាំងពីរឱ្យនៅស្ងៀម សុំឱ្យសាក្សីនិយាយការពិត និងសុំឱ្យបំភ្លេច ឬសុំឱ្យកំណត់ទឹកប្រាក់សងឱ្យបានត្រឹមត្រូវ។ បើម្ចាស់ដំណាំដែលត្រូវបំផ្លាញមិនសប្បាយចិត្ត គេត្រូវទៅជួបប្រធានភូមិទៀត។ តួនាទីរបស់ប្រធានក្រុមគឺ គ្រប់គ្រងទឹកដីរបស់ខ្លួនឱ្យបានល្អ។ បើគាត់មិនអាចដោះស្រាយរឿងបានទេនោះ រឿងនោះនឹងឡើងទៅលើទៀត។ ជាគោលការណ៍ គាត់ចង់ដោះស្រាយរឿងនៅថ្នាក់គាត់ដើម្បីកុំឱ្យគេនិយាយថា គាត់មិនចេះគ្រប់គ្រងមនុស្ស"។

(អ្នកស្រី ចេក អាយុ២២ ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ករណីរំលោភសេពសន្ថវៈមួយក៏អាចដោះស្រាយដោយការទូទាត់ជាប្រាក់ដែរ។

"បើកូនស្រីត្រូវបានគេរំលោភ ជាគោលការណ៍កូននោះមិននិយាយអ្វីទាំងអស់ ព្រោះខ្មាស់គេ។ បើកូនស្រី នោះនៅក្រមុំព្រហ្មចារី គេដឹងថាខ្លួនគេនឹងពិបាករកប្ដី។ ប៉ុន្តែ គេអាចធ្វើការសំរុះសំរួលដោយស្ងាត់ៗជាមួយអ្នកដែលរំលោភ។ មនុស្សរំលោភនោះបង់ថ្លៃទូទាត់ឱ្យគ្រួសារខាងស្រី។ បើគេដឹងរឿង អ្នកសំរុះសំរួលអាចព្យាយាមឱ្យកូនស្រីនោះរៀបការជាមួយមនុស្សប្រុស បើមនុស្សប្រុសនោះមិនទាន់មានប្រពន្ធ។ គេធ្វើដើម្បីកិត្តិយសកូនស្រី"។

(លោក ប៉ុល អាយុ៦២ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ប្រធានភូមិម្នាក់ប្រឹងប្រែងសំរុះសំរួលរឿងមួយ ដោយគិតដល់ករណីយកិច្ចរបស់ឪពុកចំពោះកូន។

"មនុស្សម្នាក់មានកូនប្រុសមួយជាមួយប្រពន្ធទីមួយ។ ក្រោយពីលែងលះគ្នា កូនរស់នៅផ្ទះយាយ ហើយឪពុកបានចុះចេញទៅរស់នៅជាមួយប្រពន្ធមួយទៀតក្នុងឆ្នាំ១៩៨៥។ នៅពេលដែលឪពុកចាកចេញទៅអាជ្ញាធរមូលដ្ឋានបានសំរេចថា ដីរបស់ឪពុកនោះបានក្លាយទៅជារបស់កូននិងយាយ។ នៅឆ្នាំ១៩៨៦ ឪពុកត្រឡប់មកវិញ។ គាត់មកនៅផ្ទះយាយ ហើយវាយកូន។ កូនបានចាកចេញនៅឆ្នាំ១៩៨៨ ទៅនៅជាមួយម្ដាយនៅភូមិក្បែរនោះ។ ថ្មីៗនេះ កូនមានគ្រោះថ្នាក់ម៉ូតូមួយ។ កូននោះបានបុកម៉ូតូមួយទៀត ហើយត្រូវបានឃាត់ខ្លួនដោយដោយនគរបាល។ នគរបាលទាមទារឱ្យកូននោះសងថ្លៃខូចខាតម៉ូតូមួយទៀតក្នុងរយៈពេល៥ថ្ងៃ។ កូនបានទៅសុំប្រាក់ពីឪពុក តែឪពុកមិនឱ្យ។ ពីរថ្ងៃក្រោយមក កូនបានប្ដឹងឪពុកដោយទាមទារដីមួយផ្នែកដែលមានផ្ទៃ១៧កុង។ ដីទាំងអស់មាន៤០កុង ប៉ុន្តែដីដែលនៅសល់ជារបស់យាយតាមការសំរេចរបស់អាជ្ញាធរ។ ខ្ញុំបានកោះហៅឪពុកឱ្យមកដោះស្រាយរឿងនេះ។ ខ្ញុំមិនចង់ធ្វើអន្តរាគមតាមផ្លូវច្បាប់

ទេ ប៉ុន្តែខ្ញុំចង់គិតគូរដល់មនោសញ្ចេតនារវាងឪពុកនិងកូនវិញ ហើយព្យាយាមសំរុះសំរួលគេ។ ខ្ញុំនិយាយទៅឪពុកថា គាត់ត្រូវទទួលខុសត្រូវចំពោះកូនគាត់ ថាគាត់បង្កើតកូនមកហើយត្រូវថែរក្សាកូន។ កូនបានទារប្រាក់២០០០០០រៀលពីឪពុក។ គេក៏បានព្រមព្រៀងគ្នា។ ឪពុកយល់ព្រមឱ្យ១៨០០០០រៀលនៅថ្ងៃបន្ទាប់។ នៅក្នុងលិខិតសន្យាយើងសរសេរថា កាលណាឪពុកឱ្យប្រាក់ គាត់អាចយកដីមួយចំណែកពីយាយ(ដែលស្លាប់ហើយ)ផងដែរ បើគាត់ធ្វើបុណ្យសពនៅវត្តឱ្យយាយ។ ល្អណាស់ ជាអំពើល្អមួយ។ នៅថ្ងៃស្អែក ឪពុកនិយាយថា អាចឱ្យបានតែ១០០០០០រៀលទេ ហើយគាត់ចង់យកដីទាំងអស់ ដោយគ្មានប្រាក់អ្វីតបស្នងផ្សេងទៀតទេ។ កូនមិនព្រម។ ឪពុកមិនចង់ធ្វើសម្បទានទេ។ យើងបានបញ្ជូនរឿងទៅសង្កាត់។ ការសំរុះសំរួលមិនអាចទៅរួច ពីព្រោះឪពុកចង់បានទាំងអស់។ បក្សពួកខាងឪពុកបានពន្យុះគាត់ឱ្យអូសបន្លាយរឿងនោះដើម្បីបានចំណេញ។ ឪពុកនិយាយថា ខ្ញុំបានបង្ខំឱ្យគាត់ចុះហត្ថលេខាលើលិខិតសន្យាដោយនិយាយថា គាត់ត្រូវចេញប្រាក់ ១៨០០០០ រៀល។ ប្រធានឃុំបាននិយាយដូចខ្ញុំដែរ។ គាត់និយាយថា មនុស្សទាំងអស់មានសិទ្ធិនិងស្វែងរកអាហារប្រចាំថ្ងៃ ហើយបើឪពុកយកដីទាំងអស់ កូនគ្មានអីស៊ីទេ។ គាត់និយាយថា ឪពុកត្រូវឱ្យប្រាក់ទៅកូន ហើយកូនត្រូវលះបង់សិទ្ធិលើដីនោះ។ កូនមានគ្នីគ្នាច្រើនមកជួយ។ ឥឡូវនេះ យើងរង់ចាំការកោះហៅជាលើកទីពីរពីប្រធានសង្កាត់។ គេបាននិយាយប្រាប់ខ្ញុំថា គេចង់ស្នើចែកដីឱ្យយុត្តិធម៌ គឺកូននឹងបាន២០កុង ហើយឪពុក២០កុងដែរ។ កូនអាចលក់ដីរបស់ខ្លួនដើម្បីសងថ្លៃខូចខាតម៉ូតូគេ"។

(លោក ល័ក្ខ អាយុ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្កុល ក្រុងកែប ខេត្តកំពត)

ទម្លាប់ធ្វើការសំរុះសំរួលជាមិត្តភាព ដែលមានការតបស្នងជាប្រាក់កាសតាមការចរចាគ្នានេះ ត្រូវបានគេចូលចិត្តជាពិសេស។ បញ្ហាដោះស្រាយរួចដោយដំណោះស្រាយជាក់ស្តែង។

"ល្អ ត្រូវធ្វើការសំរុះសំរួល។ បើជនរងគ្រោះមិនបានប្រាក់ទាំងអស់ដែលខ្លួនបាត់បង់នេះគឺមកពីគេចង់រក្សា ត្រូវមានសាមគ្គី និងអត់អោនគ្នា។ គឺដោយសារទេពកោសល្យអ្នកដែលបានធ្វើការសំរុះសំរួលដែលធ្វើជាមនុស្សពីរនាក់បានអ្វីម្យ៉ាងម្នាក់។ គឺជាការសំរុះសំរួលអាក្រក់ កាលណាម្នាក់បានទាំងអស់ ហើយម្នាក់ទៀតគ្មានបានអ្វីសោះ។ ជនរងគ្រោះត្រូវជួយអ្នកដែលធ្វើខុសមកលើខ្លួន។ ឧទាហរណ៍ អ្នកបើកបរកាមីញ៉ុងម្នាក់បុកម៉ូតូមួយតម្លៃ១០០០ ដុល្លា។ អ្នកបើកបរកាមីញ៉ុងគ្មានប្រាក់ច្រើនទេ ព្រោះគាត់គ្រាន់តែជាអ្នកបរឡាន។ គាត់និយាយទៅម្ចាស់ម៉ូតូថាគាត់អាចឱ្យបានតែ៨០០ ដុល្លាប៉ុណ្ណោះ។ បើជនរងគ្រោះព្រម គេធ្វើពួកម៉ាកជាមួយ។ នៅតុលាការ មានម្នាក់ដែលជាអ្នកខាត គឺពិបាកណាស់។ គាត់នឹងខ្មាស់គេ។ គេលែងគោរពគាត់ទៀតហើយ។ (លោកតុន អាយុ៥៣ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

បរាជ័យនៃការព្យាយាមធ្វើការសំរុះសំរួលរបស់អាជ្ញាធរមូលដ្ឋាន មានញឹកញាប់នៅតំបន់ដែលមានមនុស្សរស់នៅកកកុញ តំបន់ចំហទៅកាន់ប្រទេសទាំងមូលដែលមនុស្សមិនសូវស្ដាប់មេដឹកនាំមូលដ្ឋាន។

"ពូបូ និងពូហ៊ុយ ជាបងប្អូនស្រីនឹងគ្នា។ ពូហ៊ុយមានដីតាំងពីឆ្នាំ១៩៧៩។ ពីរឆ្នាំក្រោយមកប្អូនស្រីម្នាក់ក៏បានសុំនៅក្បែរដីគាត់។ ពូហ៊ុយបានសង់ផ្ទះមួយ ហើយបានតម្លើងតូបលក់ទំនិញមួយដើម្បីលក់កាហ្វេនៅផ្សារ។ ខ្មែរក្រហមបានសម្លាប់ប្ដីពូហ៊ុយនៅឆ្នាំ១៩៨៩ ហើយពីរនាក់បងប្អូនចាកចេញទៅនៅភ្នំពេញនៅឆ្នាំ១៩៩០ ពីព្រោះ ជីដូនមួយម្នាក់នៅទួលស្វែរសេឡង់បានទិញផ្ទះមួយដែលអ្នកទាំងពីរអាចមកនៅបាន។ នៅឆ្នាំ១៩៩៣ ពូបូត្រឡប់មកទីនេះ។ ពេលនោះគាត់ចង់សង់ផ្ទះមួយលើដីពូហ៊ុយ ប៉ុន្តែបងស្រីគាត់មិនអនុញ្ញាតិឱ្យសង់។ ដូច្នេះ ជម្លោះក៏កើតឡើង។ ខ្ញុំធ្វើការសំរុះសំរួល ហើយខ្ញុំបានស្នើដំណោះស្រាយ ដោយនិយាយថា "អ្នកឯងជាបងប្អូននឹងគ្នា អ្នកឯងត្រូវជានានឹងគ្នា។ រឿងដីនេះ វាលែងមានប្រយោជន៍អ្វីទៀតហើយកាលណាអ្នកឯងស្លាប់ទៅ។ អ្នកឯងជាបងប្អូននឹងគ្នា ត្រូវចែកគ្នានិងសះជានឹងគ្នា។ ដើម្បីមានជីវិតរស់នៅល្អ ម្នាក់ៗត្រូវមានដី។ អ្នកឯងជាស្រី ជាបងប្អូននឹងគ្នា អ្នកឯងដូចគ្នា។ បើអ្នកឯងឈ្លោះគ្នា វាខ្មាស់គេ។ អ្នកជិតខាងគេនិយាយដើម"។ ខ្ញុំបានស្នើឱ្យបងប្អូនពីរនាក់ នោះចែកដីគ្នា ហើយឱ្យពូបូឱ្យប្រាក់បន្តិចទៅពូហ៊ុយដើម្បីសងថ្លៃផ្ទះ។ ពូហ៊ុយមានផ្ទះនៅភ្នំពេញ ហើយគាត់មិនត្រូវការផ្ទះពីរទេ។ ទាំងពីរនាក់មិនចង់ស្ដាប់ខ្ញុំទេ។ ខ្ញុំបញ្ជូនរឿងនេះទៅខ័ណ្ឌ"។

(អ្នកស្រី យុន អាយុ ៥៣ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ការចរចាប្រាក់កាសដែលធ្វើឱ្យខូចប្រយោជន៍មួយផ្នែកដល់ជនរងគ្រោះ ដើម្បីអនុញ្ញាតឱ្យអ្នករំលោភសងទៅតាមលទ្ធភាពដែលគេមាន មិនមែនសុទ្ធតែអាចទទួលយកទេ។

"ក្នុងសម័យរដ្ឋកម្ពុជា ខ្ញុំអាចដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស។ បើអ្នកណាម្នាក់វាយម្នាក់ទៀត ខ្ញុំនិយាយទៅជនរងគ្រោះថា "ទឹកប្រាក់ប៉ុន្មាន ដែលអ្នកឯងទាមទារពីអ្នករំលោភ"។ បើគាត់និយាយថា ៥០០០០០ រៀល ខ្ញុំស្នើ ២០០ ០០០ ទៅ ៣០០ ០០០ រៀល ហើយដល់ថ្ងៃសំរុះសំរួលទឹកប្រាក់ត្រូវកំណត់ត្រឹម២០០០០០រៀល។ ខ្ញុំធ្វើឱ្យភាគីទាំងពីរខិតទៅរកគ្នាម្នាក់បន្តិច ហើយរបៀបនេះគឺធ្វើទៅរួច។ នៅជំនាន់នោះ គេអរគុណ។ តែឥឡូវនេះ ជនរងគ្រោះទាមទារប្រាក់ច្រើន ហើយជានិច្ចជាកាលមិនចង់ចុះទេ។ គេចង់បានទឹកប្រាក់ទាំងអស់ដែលបានខាតបង់ ហើយគេមិនគិតគូរដល់អ្នករំលោភទេ។ មិនសូវមានសាមគ្គីភាពទេឥឡូវនេះ"។

(លោក វណ្ណៈ អាយុ ៥៣ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

## ៥. អនុគ្រោះនិយម

ភាពលំអៀងនៃអាជ្ញាធរមូលដ្ឋានទៅរកបក្សពួក(មនុស្សក្នុងគ្រួសាររបស់គេ នៅក្នុងគណបក្សជាមួយគ្នា មនុស្សខ្លាំងដោយសារមុខងារឬទ្រព្យសម្បត្តិ) ព្រមទាំងអសមត្ថភាពរបស់គេនៅក្នុងការដោះស្រាយជម្លោះ (ចរិតលក្ខណៈ ស្លូត ភាពល្ងង់ខ្លៅ ការខ្លាច) ត្រូវបានរំលឹកឡើងវិញជាញឹកញាប់ក្នុងកម្លុងពេលធ្វើការសន្ទនា ជាពិសេសក្នុងតំបន់ទីក្រុង និងជុំវិញក្រុង ឬនៅតាមដងផ្លូវធំៗដែលប្រជាជនមានការអប់រំចំហរទៅរកពិភពខាងក្រៅ ហើយដែលមិនសូវដឹកច្រមុះបាន ដូចជានៅទីកន្លែងដាច់ស្រយាល។

<u>លំអៀងទៅបក្ខពួក</u>

"នៅទីនេះ ប្រធានភូមិមានគ្រួសារធំ។ គេជាសាច់ញាតិ បើមិនជិតក៏ឆ្ងាយជាមួយមេគ្រួសារ។ មានមនុស្សតិចណាស់ដែលមកពីក្រៅ។ ប្រធានភូមិលំអៀងទៅសាច់ញាតិជិតរបស់គាត់ ហើយនិងអ្នកដែលនៅក្នុងគណបក្សជាមួយ "។

(អ្នកស្រី ដារុំធ អាយុ៥១ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

"មានអយុត្តិធម៌ជាច្រើននៅក្នុងភូមិ។ មានក្រុម មានពួក។ ឧទាហរណ៍ នៅពេលដែលកាកបាទក្រហមមកចែកអំណោយ មានតែមនុស្សជាសាច់ញាតិប្រធានភូមិ និងបក្សពួកគាត់ទេ ដែលមានឈ្មោះក្នុងបញ្ជី។ រឿងនេះ ដូចគ្នាជាមួយនឹងអង្គការអន្តរជាតិ។ កាលណាអង្គការសុំឱ្យប្រធានភូមិធ្វើបញ្ជីអ្នកក្រ គាត់ចុះឈ្មោះសាច់ញាតិគាត់ អនុប្រធាន និងប្រធានក្រុម។ កាលណាប្រធានភូមិត្រូវដោះស្រាយជម្លោះ គាត់ធ្វើការគាបសង្កត់លើមនុស្សដែលមិននៅខាងគាត់។ មានមនុស្សច្រើនក្រុមណាស់ដែលមានអំណាច គឺអ្នកដែលប្រធានភូមិស្គាល់ច្បាស់ ក្រុមក្នុងគណបក្សនយោបាយ គ្រួសារអ្នកមាន៦គ្រួសារ និងរាជការដែលមានតំណែងល្អ។ ខ្ញុំខ្លាចមិនហ៊ាននិយាយប្រាប់អ្នកឯងនូវការពិតទេ ព្រោះបើខ្ញុំនិយាយគេនឹងនិយាយថា រដ្ឋាភិបាលខ្មែរមិនល្អ ហើយពេលនោះបរទេសលែងឱ្យប្រាក់។ គេនិយាយពីសិទ្ធិមនុស្ស ប៉ុន្តែមានអ្នកមានសិទ្ធិ និងអ្នកអត់សិទ្ធិ។ អ្នកមានសិទ្ធិមានសិទ្ធិរំលោភអ្នកអត់សិទ្ធិ។ អ្នកគ្មានសិទ្ធិគឺជាអ្នកដែលមិននៅក្នុងក្រុមណា "។

(លោក សុង អាយុ អាយុ៦០ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

មនុស្សម្នាក់មកនៅក្នុងភូមិថ្មីមួយដែលគ្មានអ្នកការពារគាត់។

"មានសាមគ្គីភាពយ៉ាងខ្លាំងក្នុងចំណោមមនុស្សទាំងអស់។ ខ្ញុំពឹងផ្អែកតែលើខ្លួនខ្ញុំ និងលើអ្នកជិតខាងខ្ញុំ បើខ្ញុំមានបញ្ហា។ មុននឹងមកនៅទីនេះ ខ្ញុំគិតថាមកនៅដើម្បីឱ្យបានសុខ ខ្ញុំមិនត្រូវមានបញ្ហាទេ។ បើគេឈ្លានពានខ្ញុំ ខ្ញុំគួរកុំនិយាយអ្វីទាំងអស់ហើយនៅស្ងៀម។ នៅទីនេះ ពួកអតីតខ្មែរក្រហមគេស្គាល់គ្នាគេ។ ចំណែកខ្ញុំ ខ្ញុំគ្មានបក្សពួកនឹងគេទេ ដូច្នេះខ្ញុំត្រូវនៅស្ងប់ស្ងាត់ បើពុំ

នោះទេ អង្រែនឹងបុកខ្ញុំអោយក្លាយជាម្សៅ។ ខ្ញុំជាអ្នកតូច ហើយខ្ញុំដឹងថា មានអយុត្តិធម៌ច្រើនជាងយុត្តិធម៌។ អំណាចគឺនៅក្នុងកណ្តាប់ដៃអ្នកខ្លាំង។ ប្រធានភូមិចូលចិត្តអ្នកមានអំណាច និងអ្នកដែលនិយាយបញ្ចើចបញ្ចើថាគេជាអតីតយុទ្ធមិត្ត។ កាលណាគេចង់អូសទាញការអនុគ្រោះពីអ្នកណាម្នាក់ដែលមានអំណាច គេត្រូវផ្តល់សេវាកម្មដល់អ្នកនោះ គេនឹងទៅជួបនិងបង្ហាញឱ្យឃើញថាគេសរសើរអ្នកនោះ។ ខ្ញុំជាអ្នកថ្មីមួយក្នុងចំណោមអ្នកថ្មីដែលមកទីនេះមុនគេ។ បើគេមានបញ្ហា គេត្រូវមានប្រាក់ និងមានខ្សែទំនាក់ទំនង។ ដើម្បីមានទំនាក់ទំនង គេត្រូវបញ្ជោរមនុស្សសំខាន់។ បើគេមិនបញ្ជោរមនុស្សមានអំណាចទេនោះ គេគួរតែចៀសវាងបញ្ហា"។

(លោកឫទ្ធី អាយុ ៥៧ ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

<u>បក្សពួកនយោបាយ</u>

នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ និងបន្ទាប់មកក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ គេឃើញមានការលេចចេញគណបក្សជាច្រើន។ អាជ្ញាធររដ្ឋបាលដែលជាប់ខ្សែជាមួយគណបក្សកាន់អំណាចនៅពេលនេះបានបាត់បង់អំណាចផ្តាច់មុខលើប្រជាជនហើយ។ មានតស្សរជនលេចមុខក្នុងភូមិ ហើយបង្កើតស្នូលតូចៗនៃគណបក្សប្រឆាំង។ មួយផ្នែកនៃអំណាចរបស់មេដឹកនាំក្នុងមូលដ្ឋានដែលមានមូលដ្ឋានលើការធ្វើឱ្យគេខ្លាចត្រូវរលុបបាត់យ៉ាងច្រើននៅក្នុងតំបន់ទីក្រុងនិងតំបន់នៅជិតទីក្រុង និងតាមដងផ្លូវ។ នៅទីកន្លែងឆ្ងាយៗ និងដាច់ស្រយាល អំណាចរបស់អាជ្ញាធរមូលដ្ឋានលើប្រជាជននៅតែសំខាន់ជានិច្ច។

"អ្នកដែលនៅខាងគណបក្សនយោបាយរបស់ប្រធានភូមិ អ្នកនោះត្រូវទទួលការអនុគ្រោះ។ ប្រធានភូមិមិនប្រឆាំងអ្នកដទៃដោយចំហទេ ប៉ុន្តែគាត់ទុករឿងឱ្យនៅស្អុយរលួយ។ គាត់មិនដោះស្រាយបញ្ហាទេ គាត់ធ្វើដូចជាមិនមានបញ្ហាអញ្ចឹង។ ឥឡូវនេះមានគណបក្សច្រើនក៏ដោយសារមនុស្សមិនសប្បាយចិត្តនឹងសង្គមបច្ចុប្បន្ន។ បើគេសប្បាយ គេមិនទៅរកអ្នកណាទៀតទេ។ ពីមុនមានយុត្តិធម៌នៅតុលាការ។ ឥឡូវនេះសូម្បីតែមានអត្ថបទច្បាប់ល្អៗក្តី ការអនុវត្តច្បាប់មិនល្អទេ។ អំណើះតទៅគេត្រូវចាយប្រាក់គ្រប់កន្លែងហើយច្រើនទៀត ដូចជានៅតុលាការ ពេទ្យជាដើម។ អ្នកដែលគ្មានប្រាក់គេមិនព្យាបាលទេ សូម្បីតែគេជិតស្លាប់ហើយក៏ដោយ។ កាលណាអ្នកក្រមានបញ្ហា គេមិនដឹងទៅរកអ្នកណាទេ។ មនុស្សក្នុងគណបក្សប្រឆាំងនៅស្ងៀម បើពុំដូច្នោះទេ អាជ្ញាធរមូលដ្ឋានអាចបង្កើតរឿងដាក់ពួកគេ។

(លោក សារិន អាយុ៥៩ឆ្នាំ ប្រធានសមាគមមូលដ្ឋាននៃមីក្រូឥណទាននិងអភិវឌ្ឍន៍ជនបទ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ប្រធានភូមិដែលភាគច្រើនកាន់អំណាចតាំងពីឆ្នាំ១៩៧៩មក មិនអនុគ្រោះដល់ការបែងចែកអំណាចនេះទេ។

"នៅទីនេះ មនុស្សជាច្រើនល្ងង់។ មានបញ្ហាកាន់តែច្រើនឡើង១ ពីព្រោះមនុស្សមិនគោរពគ្នា ហើយលែងខ្លាចគ្នា។ គឺចាប់តាំងពីឆ្នាំ១៩៩៨មក ចាប់តាំងពីការបោះឆ្នោត និងការរីកដុះដាលគណបក្សច្រើន។ កាលណាគេធ្វើការប្រជុំដើម្បីធានាសន្តិសុខភូមិដោយសារការកើតចោរខ្ញួញ មនុស្សដើរចេញកណ្តាលប្រជុំ។ គេគិតថា គេមានសិទ្ធិដើរចេញ។ ពីមុនមានតែគណៈបក្សមួយគត់ទាំងអស់គ្នាដើរទៅតាមទិសដៅតែមួយ។ ឥឡូវនេះដោយសារមានគណបក្សច្រើន ម្នាក់១មានគំនិតដោយខ្លួន ហើយទៅតាមទិសរបស់គេ។ គេខ្វះការគោរព និងសាមគ្គីភាព។ ដោយសារមានគណបក្សច្រើន មានមនុស្សច្រើនក្រុមដែរ។ នៅពេលប្រជុំភូមិ អ្នកខ្លះនិយាយថា គេមិនសប្បាយចិត្តទេ។ គេថា គេមិនពេញចិត្តនឹងរបៀបសំរុះសំរួលរបស់ខ្ញុំព្រមទាំងរបស់ប្រធានភូមិដែរ។ មនុស្សដែលបោះឆ្នោតឱ្យគណបក្សប្រឆាំងមានទំនុកចិត្តលើតំណាងមូលដ្ឋានរបស់គេដើម្បីដោះស្រាយបញ្ហា។ គេលែងមកជួបយើងទៀតហើយ។ ប៉ុន្តែកាលណាគេធ្វើការសុំរុះសំរួលគឺមានអយុត្តិធម៌ ព្រោះគេការពារតែបក្ខពួកគ្នាគេ។ មនុស្សបន្ទោសយើងថាលំអៀងទៅខាងបក្ខពួកយើង ប៉ុន្តែគេធ្វើអញ្ចឹងដូចគ្នាសំរាប់ពួកគេ។

(លោក ល័ក្ខ អាយុ ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខសង្កាត់អង្គល ក្រុងកែប ខេត្តកំពត)

"ក្នុងសម័យរដ្ឋកម្ពុជា គេខ្លាចយើង។ ចាប់តាំងពីមានគណបក្សនយោបាយច្រើនមកគឺស្មុគ្រស្មាញណាស់។ កាលណាគេធ្វើការប្រជុំផ្សាយពត៌មាន ឧទាហរណ៏ដូចជាកាលណាអ្នកណាម្នាក់មកពីការិយាល័យកសិកម្មក្រុងកែប ដើម្បីបង្រៀនពីរឿងកសិកម្មជាដើម អ្នកដែលនៅខាងគណបក្សប្រឆាំងគេមិនមកទេ។ បើគេមកវិញគេធ្វើហាក់ដូចស្តាប់អញ្ចឹង " ។

(លោក សាវេត អាយុ ៥៥ឆ្នាំ ប្រធានភូមិសង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

អនុប្រធានភូមិសារភាពថា គាត់គ្មានអំណាច នៅចំពោះមុខស្ថានការណ៏ថ្មីដែលគាត់បាត់បង់ភាពផ្តាច់មុខក្នុងការដោះស្រាយជម្លោះនៅមូលដ្ឋាន។ នៅចំពោះការគ្មានក្បួនខ្នាតប្រពៃណីជាក់លាក់ក្រុមបក្ខពួកថ្មី១ ផ្អែកលើច្បាប់ដើម្បីពង្រឹងអំណាចរបស់គេ។

"បណ្តាញគណបក្សនយោបាយប្រឆាំងពឹងផ្អែកលើបណ្តាញឃោសនាចាស់របស់ខ្មែរប្រហមនៅក្នុងភូមិ។ ខ្ញុំបាត់បង់ទំនុកចិត្តពីមនុស្សផងទាំងពួង ពីព្រោះខ្ញុំនិយាយត្រូវនិងត្រង់ ហើយដូច្នេះគេមិនសប្បាយចិត្តទេ។ ក្នុងពេលមួយនោះ ក្មេងប្រុសម្នាក់អាយុ១៧ឆ្នាំ ត្រូវបានចាប់ខ្លួន ព្រោះវាបានលួចមាន់។ ក្មេងនោះនៅខាងមនុស្សគណបក្សប្រឆាំង។ មេរបស់គេនិយាយថា តាមច្បាប់គេមិនអាចធ្វើអ្វីក្មេងនោះបានទេ ពីព្រោះវាអាយុតិចជាង១៨ឆ្នាំ។ ចំណែកខ្ញុំ១និយាយថា ក្មេង

នោះត្រូវសងថ្លៃមាន់ទៅអ្នកដែលក្មេងនោះលួច។ គេមិនបាននិយាយអ្វីទាំងអស់ទៅក្មេងនោះ។ ខ្ញុំខឹងណាស់។ ឥឡូវ ក្មេងក្រោមអាយុ១៨ឆ្នាំនិយាយថា គេមានសិទ្ធិ ហើយច្បាប់មិនអនុវត្តចំពោះគេទេ។ គេថា គេដើរតាមមនុស្សផ្សេងវិញ។ គេលែងស្តាប់ហើយ។ ខ្ញុំធុញទ្រាន់ណាស់ ខ្ញុំចង់ឈប់ហើយ។ មនុស្សគ្មានសីលធម៌។ ម្នាក់ៗយកច្បាប់ធ្វើជាខែល"។

(លោក ល័ក្ខ អាយុ ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្គុល ក្រុងកែប ខេត្តកំពត)

នៅក្នុងតំបន់មួយដែលមានសង្គ្រាមបំផ្លាញយូរយាមកហើយ ប្រធានភូមិលែងចង់ចូលក្នុងការរើកញែកនយោបាយទៀតហើយ។ ការតាំងការិយាល័យគណបក្សនយោបាយនៅក្នុងមណ្ឌលរបស់គាត់អាចធ្វើបានលុះត្រាតែគ្មានការធ្វើសកម្មភាពនយោបាយ។

"ខ្ញុំធុញទ្រាន់នឹងសង្គ្រាមនិងការបែកបាក់។ បើគណបក្សនយោបាយមកទីនេះ គេអាចនៅបានបើគេមិនបង្កបញ្ហា ហើយគេមិនធ្វើការឃោសនា។ អ្នកដែលបង្កបញ្ហា ខ្ញុំត្រូវប្រាប់ឱ្យគាត់ចេញ។ នៅទីនេះ គេសុំតែរស់ដោយសុខសាន្ត គេមិនចង់ឈឺក្បាលទេ"។

(លោក សាម៉ុន អាយុ ៤២ឆ្នាំ ប្រធានភូមិ (អតីតខ្មែរក្រហម) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

<u>សម្ព័ន្ធភាពគ្រួសារ ឬ ញាតិសន្តាន : សាក្សី</u>

អ្នកដែលគេហៅថា សាក្សីនោះ គឺភាគច្រើនជាមនុស្សញាតិសន្តាន ឬ អ្នកជិតខាងជាដៃគូភាគីមួយនៃភាគីដែលមកជជែកការពារ និងគាំទ្រការអះអាងរបស់ខ្លួន។ ដូច្នេះ សាក្សីមិនមែនសុទ្ធតែអាព្យាក្រឹត្យទេហើយ តុល្យភាពនៃកម្លាំងរវាងភាគីនានាអាចត្រូវបានប៉ះពាល់ដោយសារវត្តមានរបស់សាក្សី។

ប្រធានភូមិពីរនាក់និយាយថា បានបំបែកសាក្សីដែលបំពានខ្លាំងពេក។

" មុនពេលធ្វើការសំរុះសំរួល ខ្ញុំព្យាយាមទុកឱកាសទាំងអស់ឱ្យទៅខាងប្រពន្ធទីពីរ។ ខ្ញុំគិតថា កូនប្រពន្ធទីមួយព្យាយាមរំលោភលើប្រពន្ធទីពីរ ដោយនាំសាក្សីច្រើនមកជាមួយដើម្បីជួយគាំទ្រគាត់។ ខ្ញុំបានឃើញថា គាត់ព្យាយាមប្រមូលគ្នាជាក្រុមពួក។ ដូច្នេះខ្ញុំនិយាយថា ការសំរុះសំរួលមិនអាចធ្វើទៅបានដោយមានសាក្សីច្រើនពេក ហើយខ្ញុំគំរាមទារប្រាក់ ១០០០០ រៀលក្នុងសាក្សីម្នាក់។ ខ្ញុំនិយាយថា "បើអ្នកឯងបង់១០០០០រៀល អ្នកឯងមានសិទ្ធិនិយាយ។ បើអ្នកឯងមិនបង់ទេ កុំនិយាយ"។ ខ្ញុំធ្វើការគាបសង្កត់លើកូនប្រុសនោះ ដើម្បីកុំឱ្យវានាំសាក្សីមក និងដើម្បីឱ្យមានយុត្តិធម៌។ បើខ្ញុំមិនធ្វើដូច្នោះទេ ស្ត្រីនោះនឹងបាត់បង់ដី។ ប្រពន្ធទីពីរខ្សោយណាស់ ចំណែកឯកូនប្រពន្ធដើមមានបក្ខពួកច្រើន។ ប្រពន្ធទីពីរមានតែខ្លួនឯងម្នាក់ ហើយអាចសង្ឃឹមតែលើអាជ្ញាធរដើម្បីជួយគាត់"។

(លោក ល័ក្ខ អាយុ ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្គាល់ក្រុងកែប ខេត្តកំពត)

" គេខឹងណាស់ ។ គេស្រែក ហើយជួនកាលវាយគ្នាក្នុងការិយាល័យ ។ វាអាចមានគ្នាច្រើន បើញាតិសន្ដាន និងសាក្សីមកជាមួយគាត់ ។ ក្នុងករណីនេះ យើងប្រាប់ឱ្យពួកគាត់នៅស្ងៀម ហើយឱ្យញាតិសន្ដាន និងសាក្សីនៅខាងក្រៅ" ។

( លោក ឆុំ អាយុ ៥០ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

ក្នុងករណីមានបញ្ហាប្រាក់ក្លាយទៅជាឧបករណ៍អំណាចកាន់តែខ្លាំងឡើង ដែលធ្វើឱ្យមានការខុសគ្នារវាងអ្នកស្រែទាំងឡាយដែលពីដើមរស់នៅក្នុងប្រៀបស្មើគ្នា ។ ប្រាក់ប្រើសំរាប់បង្ហាញកិត្តិនាម សំរាប់ទិញបក្ខពួក និង និទ្ទណ្ឌភាព ។

"ពីមុន មនុស្សទាំងអស់ដូចតែគ្នា ឥឡូវនេះប្រាក់ធ្វើឱ្យមនុស្សខុសគ្នា ។ ប្រាក់ជំនួសសាមគ្គីភាព ។ បើគេគ្មានប្រាក់ គេគ្មានមិត្តភ័ក្រ ។ ប្រាក់ធ្វើឱ្យយើងបាត់បង់ទំនុកចិត្តលើគ្នា ។ គេលែងនិយាយពីសន្តិភាពទាំងស្រុងទៀតហើយ ។ គេរង់ចាំ ហើយគេនិយាយថាសន្តិភាពនឹងបាត់ទៅវិញ ។ គេគិតតែខ្លួនឯង ហើយគេគិតតែត្រៀមអនាគតដ៏ពិបាក ។ នេះជាតុល្យភាពមិនស្ថិតស្ថេរ" ។

( លោក វេត អាយុ ៥៧ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

"ពីមុនក្នុងសម័យសង្គមរាស្ត្រនិយម ច្បាប់តឹងរឹង ហើយមនុស្សទាំងអស់ខ្លាច ។ ឥឡូវនេះ អ្នកមានធ្វើអ្វីបានតាមចិត្តគេចង់ ។ គេដឹងថា ជាមួយប្រាក់ គេអាចទិញអ្វីបានទាំងអស់ ។ បើគេចង់ឱ្យរឿងដោះស្រាយទៅខាងគេ គេតម្លើងរឿងឱ្យខ្ពស់ជានិច្ច ហើយអ្នកក្រត្រូវតែបោះបង់ចោល" ។

( លោក សាន អាចារ្យ អាយុ ៧០ឆ្នាំ ឃុំចេក ស្រុកស្វាយជុំ ខេត្តស្វាយរៀង)

"បើយើងប្ដឹងទៅនគរបាល យើងឱ្យប្រាក់ពី ៥ទៅ១០ដុល្លា ដើម្បីឱ្យនគរបាលយកចិត្តទុកដាក់រឿងយើង ។ នគរបាលមិនទាររទេ ប៉ុន្តែយើងដឹងថា បើយើងមិនឱ្យទេនោះ នគរបាលមិនធ្វើអ្វីទាំងអស់ ។ បើអ្នកបង្កបញ្ហាជាអ្នកមានវិញ គេអាចឱ្យប្រាក់រឹតតែច្រើនហើយនគរបាលភ្លេចរឿងទាំងអស់" ។

( លោក សួយ អាយុ ៤៨ឆ្នាំ អ្នកស្រុកភ្នំពេញ)

"គេអាចទិញអ្វីក៏បាន ។ ជាគោលការណ៍ គឺមនុស្សអាក្រក់ដែលឱ្យប្រាក់ទៅសាក្សីដើម្បីឱ្យសាក្សីមកខាងខ្លួន ។ ឧទាហរណ៍ បើមនុស្សវាយគ្នា អ្នករំលោភខ្លាចត្រូវទណ្ឌកម្ម ដូច្នេះជននោះចេញថ្លៃឱ្យសាក្សីដើម្បីការពារគេ ។ ជារឿយៗ អ្នកដែលបានឃើញពិតៗនូវអ្វីដែលបានកើតឡើងមិនចង់ធ្វើអន្តរាគម និងមិននិយាយអ្វីទាំងអស់ ដោយខ្លាចគេចោទថា ចូលដៃចូលជើងជាមួយអ្នកណាម្នាក់" ។ ( អ្នកស្រី សារ៉ន អាយុ ៤៦ឆ្នាំ ក្រុងកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

"មានមនុស្សដែលចូលចិត្តតែបង្កជម្លោះជាមួយអ្នកដទៃ។ អ្នកទាំងនោះចង់បានប្រាក់ ហើយជឿថាអ្វីក៏ធ្វើបានព្រោះគេមានប្រាក់ និងបង្អែក។ គេហៅអ្នកទាំងនេះថា ពួកកាប់ចាក់។ អ្នកដែលមានប្រាក់អាចធ្វើអ្វីបានទាំងអស់។ គេថា "អ្នកមានប្រាក់ អាចទិញខ្មោចឱ្យកិនស្រូវឱ្យ"។ ឧទាហរណ៍ ខ្ញុំមានមិត្តភ័ក្រម្នាក់ដែលរស់នៅក្បែរសិប្បកម្មគ្រឿងដែកមួយ។ អ្នកជិតខាងត្អូញត្អែរពីសម្លេងម៉ាស៊ីនអារដែក ជូនកាលរហូតដល់កណ្តាលអាធ្រាត។ មិត្តខ្ញុំទៅជួបចៅសង្កាត់ ប៉ុន្តែគ្មានបានការអ្វីទេ។ បន្ទាប់មកវាបាននិយាយជាមួយប្រធានខ័ណ្ឌ និងប្រធានការិយាល័យរៀបចំក្រុងនៅសាលាក្រុងភ្នំពេញ។ មិត្តខ្ញុំស្នើឱ្យមានការដោះស្រាយមួយ គឺសិប្បករគ្រឿងដែកអាចធ្វើការក្នុងម៉ោងធ្វើការពីម៉ោង៧ ដល់១២ និង ១៤ដល់១៧។ ម្ចាស់សិប្បកម្ម បានបដិសេធ ហើយដោយសារគាត់ជាអ្នកមាន គាត់ចាយប្រាក់គ្រប់ជាន់ថ្នាក់រាជការ ដើម្បីអាចបន្តធ្វើការបាន។ ស្ថានការណ៍នោះនៅស្ទះត្រឹមនោះ។ មិត្តខ្ញុំនិងអ្នកជិតខាងមិនអាចធ្វើអ្វីបានទេ។ ម្ចាស់សិប្បកម្មបាននិយាយទៅពួកគេថា បើមិនសប្បាយចិត្តទេ គេត្រូវរើផ្ទះចេញពីនោះទៅ"។

(លោក ឡេង អាយុ ៣៨ឆ្នាំ នគរបាល ភ្នំពេញ)

## ៦. ការដកខ្លួនថយនៃអ្នកសំរបសំរួល : ការខ្លាច ការខ្វះសមត្ថភាព និងការគ្មានទឹកចិត្ត

ប្រធានភូមិភាគច្រើនមិនសូវមានការអប់រំទេ ហើយក៏មិនសូវបានបណ្តុះបណ្តាលឱ្យដោះស្រាយជម្លោះដែរ។ អ្នកខ្លះខ្លាចមិនចង់បង្កើតសំអប់ជាមួយអ្នកខ្លាំង។ អ្នកខ្លះទៀតលែងមានទឹកចិត្តបំពេញមុខងារ។ គេតែងតែប្រកាន់យកដំណោះស្រាយមួយគឺសុខចិត្តដកខ្លួនថយ ។

"ប្រធានភូមិអាចដោះស្រាយតែបញ្ហាតូចតាច។ បើគាត់មិនអាចដោះស្រាយបញ្ហាបាន គាត់បំបាត់បញ្ហាហើយគាត់និយាយថា គាត់មិនចង់និយាយពីបញ្ហានោះទេ។ គឺព្រោះគាត់មិនដឹងថាគាត់ត្រូវធ្វើយ៉ាងណា ហើយគាត់មិនចង់ឱ្យគេមិនសប្បាយចិត្ត។ គាត់មិនចង់អោយបញ្ហាក្លាយទៅជាធំ។ បើអ្នកណាចាក់ប្រេងលើភ្លើង បើអ្នកណាម្នាក់បានឃើញរបស់អ្វីមួយដែលធំ គាត់និយាយទៅអ្នកនោះថា កុំនិយាយ និងកុំធ្វើអ្វីទាំងអស់។ ជារឿយៗ គេបោះបង់រឿងចោល។ បើគេយករឿងទៅលើគេត្រូវចាយប្រាក់ដើម្បីឱ្យអាជ្ញាធរយកចិត្តទុកដាក់លើរឿងយើង"។

(អ្នកស្រីហៀង អាយុ៧៧ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

"ខ្ញុំបញ្ជូនរឿងអស់ពាក់កណ្តាលទៅចៅសង្កាត់។ គឺពិបាកដោះស្រាយជម្លោះណាស់។ មនុស្សមិនយល់ពីច្បាប់ប៉ុន្មានទេ។ គឺពិបាកនឹងធ្វើអោយគេយល់។ បើខ្ញុំទទូចចង់ឱ្យគេយល់ គេមិនសប្បាយនឹងខ្ញុំ"។

(លោក សាវេត អាយុ៥៥ឆ្នាំ ប្រធានភូមិសង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

មនុស្សមិនគោរពប្រធានភូមិប៉ុន្មានទេ ហើយប្រជាជនក៏មិនទៅពិគ្រោះជាមួយគាត់ ពីព្រោះគេនិយាយថា គាត់ស្លូតពេក។

"ប្រធានមិនធ្វើអ្វីឱ្យយើងសោះ។ គាត់មិនប្រកាន់យកតិរិយាបទអ្វីមួយ។ គាត់មិនចង់បង្កើតរឿង ដូច្នេះគាត់មិននិយាយ។ គាត់ស្លូតពេក។ ប្រធានភូមិខាងត្បូងសកម្មជាង។ គេខ្លាចគាត់។ នៅទីនេះប្រធានភូមិមិនហ៊ានធ្វើអ្វីទេ"។

(អ្នកស្រី ហឿង អាយុ ៤៥ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

ភាពអសកម្ម

នៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធឋានានុក្រមបុរាណ មេដឹកនាំមូលដ្ឋានមិនមានអំណាចនឹងធ្វើអ្វីប្រឆាំងនឹងមនុស្សដែលខ្លាំងជាងខ្លួនទេ។ នៅចំពោះមុខកម្លាំងអាវុធរបស់ពួកយោធា ប្រធានភូមិគ្មានអំណាចដោះស្រាយណាមួយក្រៅពីដោះខ្លួនទេ។

"គេបានឱ្យដីខ្ញុំមួយកន្លែងនៅចំការបី។ ខ្ញុំបានគាស់រានដីនោះតាមដំបូន្មានរបស់ប្រធានភូមិ ហើយខ្ញុំបានដាំពោតល្ហុង។ល។ បន្ទាប់មកដីនោះមានតម្លៃ។ គ្រូពេទ្យយោធាម្នាក់ជាមិត្តនឹងតារិនបាននិយាយថា គាត់ចង់បានដីខ្ញុំ។ គាត់មានដីនៅក្បែរដីខ្ញុំ។ ខ្ញុំបានដាំដើមឈើ២០ដើមលើដីខ្ញុំ ហើយគាត់កាប់ដើមឈើនោះអស់១៧ដើម។ គាត់ចង់បានដីខ្ញុំ ប៉ុន្តែខ្ញុំបាននិយាយទៅគាត់ថា ខ្ញុំមិនខ្លាចស្លាប់ទេ។ យើងបានធ្វើការប្រជុំសំរុះសំរួលមួយជាមួយប្រធានភូមិ។ ប្រធានភូមិបានទទួលស្គាល់ថា ខ្ញុំជាម្ចាស់ដី ប៉ុន្តែប្រធានភូមិនោះមិនហ៊ានកំរើក។ បន្ទាប់មក ខ្ញុំបានទទួលការគាបសង្កត់គួរសមដែរ ហើយខ្ញុំបានលក់ដីខ្ញុំថ្លៃ៣០០ដុល្លា។ ការគ្រប់គ្រងការបែងចែកដីគឺអនាធិបតេយ្យ។ ពីដំបូងប្រជាពលរដ្ឋមានសិទ្ធិលើដី បន្ទាប់មក ពេលណាមេៗមូលដ្ឋានបានឃើញថាដីជាប្រាក់ គាត់ចាប់ផ្តើមយកដីច្រើនដុំដែលគាត់បានចែកដើម្បីយកទៅលក់ឱ្យអ្នកមានមកពីក្រៅ មានទាំងអ្នកមកពីភ្នំពេញផង។ មិនមានដំណោះស្រាយពិតទៅនឹងបញ្ហាដីនោះទេ។ ប្រធានសន្តិសុខភូមិដោះស្រាយបញ្ហាបានឆាប់ ហើយនិយាយថា : "សុំឱ្យអត់អោន សុំឱ្យអត់អោន"។ នេះមានន័យថា គេត្រូវទទួលយល់ព្រមទាំងអស់ សូម្បីតែគេយកដីយើងក្តី"។

(អ្នកស្រី សំអុល អាយុ ៥៨ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

ការគ្មានអំណាច នៃប្រធានភូមិ (ឧទាហរណ៍ អតីតវរៈសេនីយខ្មែរក្រហម) ដើម្បីដោះស្រាយបញ្ហាមួយដែលចោទប្រកាន់មនុស្សម្នាក់ដែលការពារដោយយោធាម្នាក់ ដែលបានប្រយុទ្ធក្នុងកងទ័ពម្ខាងទៀតក្នុងសម័យសង្គ្រាម។ យោធានោះពឹងផ្អែកលើបណ្តាញបក្ខពួកដែលប្រធានភូមិមិនអាចចូលបាន។

"នៅឆ្នាំ១៩៩៤ ពេលយើងចុះមកពីភ្នំ រដ្ឋាភិបាលនៅទីនេះបានឱ្យដីខ្ញុំមួយកន្លែង។ ក្រោយមក (ក្រោយពីការចែកចាយដី) បុរសម្នាក់មកនៅទីនេះជាមួយម្ដាយក្មេក ប្រពន្ធ និងកូនគាត់។ ខ្ញុំអាណិតគាត់ ហើយខ្ញុំនៅតែម្នាក់ឯងលើដីដ៏ធំនេះ ចាប់តាំងពីខ្ញុំមេម៉ាយមកម្លេះ។ ខ្ញុំអនុញ្ញាតឱ្យពួកគេនៅលើដីខ្ញុំមួយចំណែក។

ឆ្កែខ្ញុំមានទម្លាប់នៅក្នុងផ្ទះរបស់គេ។ ថ្ងៃមួយប្រពន្ធគាត់បានដើរមករកឆ្កែ ហើយឆ្កែក៏ខាំគាត់។ គាត់ខឹងណាស់។ ខ្ញុំបានទទួលខ្លួនរកថ្នាំឆ្កែឆ្កួតឱ្យ ប៉ុន្តែស្ត្រីនោះបានវាយខ្ញុំ រួចមកគាត់ក៏គេចទៅជំរុំយោធាដើម្បីទៅរកប្ដីគាត់។ របួសធ្ងន់ណាស់ ខ្ញុំក៏ទៅដេកពេទ្យអស់ពីរអាទិត្យ។ ស្ត្រីនោះខ្លាចខ្ញុំស្លាប់ ក៏ធ្វើលិខិតមួយទៅនគរបាលដោយចោទខ្ញុំថា បានវាយគាត់ក្នុងពេលគាត់កំពុងមានផ្ទៃពោះ។ គាត់បាននិយាយថា គាត់បានរលូតកូន។ គាត់បានឱ្យលុយទៅគ្រូពេទ្យម្នាក់ដើម្បីឱ្យគ្រូពេទ្យនោះធ្វើសំបុត្រពេទ្យដែលនិយាយថា គាត់កំពុងមានផ្ទៃពោះ។ ពេលខ្ញុំចេញពីមន្ទីរពេទ្យមកវិញ ប្រធានភូមិ មិត្តភ័ក្រ្ត ប្រធានគណៈកម្មាធិការនារីបានឱ្យយោបល់ខ្ញុំ ឱ្យខ្ញុំប្ដឹងទៅតុលាការ និង អង្គការសិទ្ធិមនុស្ស។

មនុស្សទាំងនោះ (គ្រួសារអ្នករំលោភ) សុទ្ធតែអាក្រក់។ ពួកគេបានគេចពីភូមិកំណើត ព្រោះប្រពន្ធគាត់បានដុតផ្ទះអ្នកជិតខាង។

ប្រធានភូមិ និងប្រធានសង្កាត់បានកោះហៅប្រពន្ធគាត់ នៅពេលខ្ញុំដេកពេទ្យ។ គាត់មិនមកទេ។ ពេលនគរបាលបានកោះហៅគាត់ គាត់ថា គាត់មានអ្នកធំ។ នៅទីនេះ យើងមិនចង់ឱ្យរឿងឡើងទៅលើទេដើម្បីកុំឱ្យចុះសោហ៊ុយច្រើន។ យើងចង់ដោះស្រាយនៅសាលាសង្កាត់។ ប្រពន្ធគាត់នោះក៏មក ហើយបានទារប្រាក់១០លានរៀល ដើម្បីទូទាត់ថ្លៃដែលគាត់ហៅថា រលូតកូន។ ខ្ញុំបានទារ៥លានរៀល ដើម្បីទូទាត់ថ្លៃពេទ្យ។ គឺពូប្រធានភូមិ ដែលបានចេញថ្លៃពេទ្យឱ្យខ្ញុំ។ គាត់គិតគូរពីកូនចៅ ដូចកាលពីយើងនៅភ្នំទាំងអស់គ្នា។ ស្ត្រីនោះមិនព្រមសង។ យើងមិនអាចធ្វើអ្វីបានទេ។ ស្ត្រីនោះមានខ្នងជាទាហានថ្នាក់ខ្ពស់។ គាត់និយាយថា មិនខ្លាចទេ ព្រោះគាត់មានខ្នង។ គាត់ថា គាត់នឹងដកបណ្ដឹង ព្រោះគាត់អាណិតស្ត្រីមេម៉ាយ។

នៅទីបញ្ចប់ ពូប្រធានភូមិបាននាំខ្ញុំទៅតុលាការដើម្បីប្ដឹង។ គាត់បានចេញថ្លៃដឹកនាំចំណីអាហារ និងប្រាក់ ប្រដាប់ក្ដី។ ខ្ញុំទៅតាមការកោះហៅរបស់តុលាការជាមួយពូប្រធានភូមិ។ ស្ត្រីនោះថាពូជាអ្នកជួយខ្ញុំ។ គាត់មិនខ្លាចទេ។ ប៉ុន្តែ នៅពេលដែលតារិន[១៤៤] មកភ្នំពេញ គាត់ខ្លាចហើយ

[144] អតីតប្រធានតំបន់យោធាខ្មែរក្រហម ដែលនៅតែគិតគូរពីបញ្ហារបស់អតីតកងទ័ពរបស់គាត់។

គាត់បានរើផ្ទះទៅនៅក្នុងបន្ទាយទាហាន។ បើតារិននៅទីនោះ រឿងវាងាយទេ។ គាត់ឱ្យដំបូន្មានល្អៗ។ មនុស្សទាំងអស់គោរពគាត់ គាត់ជាមេឃោជា ប៉ុន្តែគាត់នៅតែយកចិត្តទុកដាក់លើកូនចៅដូចកាលពីមុន។ គាត់និយាយគេស្តាប់។ ឥឡូវនេះ រឿងឡើងដល់តុលាការហើយ។ ពូប្រធានភូមិបាននិយាយប្រាប់ខ្ញុំថា យកល្អគួរតែដករឿងនោះទេ។ គាត់ខ្លាចគេសម្លាប់ខ្ញុំ។ ឪពុករបស់ស្ត្រីនោះបានប្រាប់ឱ្យគាត់វាយខ្ញុំដល់ស្លាប់។ ពូប្រធានភូមិចង់ឱ្យការដោះស្រាយធ្វើទៅតាមច្បាប់។ គាត់ថា គឺតុលាការដែលជាអ្នកវិនិច្ឆ័យ។ ពូប្រធានភូមិជាអតីតខ្មែរក្រហម ហើយគ្រួសារស្រីនោះនៅខាងទាហានរដ្ឋាភិបាល។ បញ្ហាកើតមានច្រើនតែជាមួយអ្នកថ្មី។ ពួកយើងជាមនុស្សនៅព្រៃ យើងស្មោះត្រង់ហើយស្លូត។ ពួកមកថ្មីមកច្រើនតែពីភូមិដែលគេគេចវៀស ព្រោះគេបានបង្កើតបញ្ហានៅទីនោះ។ ពួកមកទីនេះ មកនៅក្នុងភូមិ ថ្មី"។

(អ្នកស្រី ពៅ អាយុ២៨ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ប្រពន្ធប្រធានភូមិរំលឹកពីអន្តរាគមរបស់ប្តីគាត់។

"យើងបានឱ្យប្រាក់ជាច្រើនដល់មនុស្សផ្សេងៗរបស់តុលាការជាច្រើនលើកច្រើនគ្រា ដើម្បីឱ្យគេគិតគូររឿងយើងគឺអស់ពី៣ទៅ៤សែនរៀល ប៉ុន្តែយើងមិនបានចម្លើយអ្វីសោះពីពាក្យបណ្តឹងរបស់យើង។ ស្ត្រីដែលបានវាយស្រីពៅនៅក្នុងបន្ទាយទាហានជាមួយប្តីគាត់។ គាត់មានកម្លាំងអាវុធ។ ចំពោះយើង(ប្រធានភូមិ ប្រពន្ធគាត់ និងជនរងគ្រោះ) យើងគ្មានអាវុធដើម្បីសម្លាប់គាត់ទេ។ គាត់ដឹងថា គាត់មានទាហានជាអ្នកការពារ"។

(អ្នកស្រី ណៅ អាយុ៤៦ឆ្នាំ ប្រពន្ធប្រធានភូមិ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ស្ត្រីម្នាក់នៃគ្រួសារជនរំលោភ មើលឃើញរឿងផ្សេងទៅវិញ។

"ស្រីពៅជាស្រីអាក្រក់។ វាមេម៉ាយ ហើយយកប្តីអ្នកដទៃដើម្បីបានប្រាក់។ គឺជាស្រីពេស្យា។ វាសមតែគេវាយ"។

(អ្នកស្រី និន អាយុ៤៥ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ប្រធានភូមិនេះ ត្រូវបានតែងតាំងចាប់តាំងពីឆ្នាំ១៩៧៩មកម្លេះ តាមកោរស្នើសុំរបស់អាជ្ញាធរឃុំ។ គាត់ត្រូវបានចាត់តាំងដោយមិនដឹងខ្លួន តែគាត់មិនចង់ឱ្យអាជ្ញាធរថ្នាក់លើមិនសប្បាយចិត្ត ដូច្នេះគាត់សុខចិត្តទទួលយកមុខងារថ្មីរបស់គាត់។ ប៉ុន្តែ គាត់សារភាពថា នៅពេលនោះគាត់មិនដែលពេញចិត្ត ឬ ក៏បំពេញតួនាទីជាប្រធានភូមិទេ។ នៅពេលមានរឿងប្តីប្រពន្ធមួយ គាត់លំអោនទៅតាមបុគ្គល <u>ប្រើអំណាច</u> ដែលជារបស់ឪពុកស្ត្រីក្មេងទើបរៀបការ។

យោបល់របស់ប្តីប្រពន្ធក្មេងៗមានគេយកចិត្តទុកដាក់តិចតួចណាស់។ ក្មេងដែលទើបរៀបការនិយាយ ប្រាប់យើងពីរឿងរបស់គាត់ ៖

"ចាស់ទុំបានស្នើឱ្យខ្ញុំរៀបការជាមួយរដ្ឋា។ ខ្ញុំស្គាល់នាង ហើយខ្ញុំស្រឡាញ់នាងណាស់ ប៉ុន្តែខ្ញុំមិនបានគិតថា នឹងរៀបការជាមួយនាងទេ។ គ្រួសារយើងស្រឡាញ់គ្នាណាស់ ហើយស្គាល់គ្នាច្បាស់ទៀត។ នៅពេលដែលចាស់ទុំ និយាយឱ្យខ្ញុំរៀបការជាមួយរដ្ឋា ខ្ញុំបានយល់ព្រម។ យើងក៏រៀបការនឹងគ្នាអស់រយៈពេល៣ឆ្នាំហើយ។ គ្រួសារខ្ញុំ បានឱ្យប្រាក់៥សែនរៀល ដើម្បីរៀបចំពិធីរៀបការ។ យើងមានកូនមួយ។ យើងបែកគ្នាបាន៩ខែហើយ។ ជម្លោះបានចាប់ផ្តើម នៅពេលដែលប្រពន្ធខ្ញុំចេញដើរលេង ហើយគាត់មិនឆ្លើយពេលខ្ញុំហៅគាត់។ នៅពេលគាត់ចូលផ្ទះវិញ ខ្ញុំបានទាត់គាត់មួយជើងនិងវាយមួយរំពាត់គោ។ គាត់បានចោលកៅអីនិងស្បែកជើងលើក្បាលខ្ញុំ។ បន្ទាប់មក គាត់ក៏ដេកលក់ក្រោយពីជេរខ្ញុំអស់ចិត្ត។ បងប្រុសគាត់មកនាំគាត់ទៅផ្ទះឪពុកម្តាយវិញ។ ថ្ងៃស្អែក គាត់ប្តឹងខ្ញុំទៅប្រធានភូមិ។ ប្រធានភូមិនិយាយថា ឱ្យរង់ចាំ៥ថ្ងៃដើម្បីឱ្យស្ងប់កំហឹង"។

(លោកវ៉ន អាយុ២៣ឆ្នាំ ក្មួយប្រធានភូមិ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

ប្រធានភូមិដែលមានវត្តមាននៅពេលសម្ភាសន៍នេះចាប់និយាយ បុរសក្មេងលាក់មុខនៅពីក្រោយគាត់ ៖

"មួយអាទិត្យក្រោយមក ឪពុកខាងស្រីមកជួបខ្ញុំហើយនិយាយថា ៖ "កូនខ្ញុំគ្រាន់តែដើរលេងបន្តិចបន្តួច ហើយប្តីវាវាយ។ ខ្ញុំសុំឱ្យកូនប្រសារខ្ញុំមករស់នៅផ្ទះខ្ញុំ ដើម្បីឱ្យខ្ញុំអាចមើលវាបានខ្លះ"។ កូនប្រុសនិយាយថា គេមិនអាចចាកចោលផ្ទះខ្លួនបានទេ ព្រោះគេត្រូវមើលថែទាំជ្រូកគោ។ ឪពុកកូនស្រីខឹង រួចដកយកជ្រូកទៅផ្ទះគាត់។ កូនប្រុសទៅមើលប្រពន្ធគាត់ហើយសួរថា ជ្រូកវាយ៉ាងម៉េចទៅហើយ។ ប្រពន្ធគាត់និយាយថា ជ្រូកលក់ហើយៗប្រាក់ដែលលក់បាននោះសំរាប់ចេញថ្លៃចាក់ថ្នាំការពារសត្វរបស់ឪពុកគាត់។ បន្ទាប់មក នៅពេលដែលប្រពន្ធនោះស្រុះស្រួលជាមួយប្តីគាត់វិញ គាត់បានប្រាប់ប្តីគាត់ថា ឪពុកគាត់បានទុកជ្រូក។ កូនស្រីនិងកូនប្រុសស្រឡាញ់គ្នានិងចង់មករួមរស់ជាមួយគ្នាវិញ។ កូនប្រុសទៅជួបកូនស្រី ហើយសួរនាងថា តើគាត់អាចយកកូនទៅជាមួយគាត់បានដែរឬទេ។ ប្រពន្ធប្រាប់ថាឱ្យយកកូនទៅ ហើយបន្ទាប់មកប្រពន្ធក៏គេចពីផ្ទះឪពុកដើម្បីទៅនៅជាមួយប្តីវិញ។ ប្រពន្ធបានចាកចេញទៅដោយគ្មានការអនុញ្ញាតពីឪពុកដើម្បីយកកូនទៅនៅជាមួយនាង។ ឪពុកមិនថាអ្វីទេ។ នៅពេលថ្ងៃត្រង់ កូនស្រីនោះក៏ត្រឡប់មកផ្ទះគាត់វិញជាមួយប្តីនាង។ បងប្រុសគាត់មកហៅឱ្យនាងទៅផ្ទះឪពុកវិញ ប៉ុន្តែនាងមិនចង់ទៅទេ។ ម្តាយនាងបានមកនៅពេលយប់តាមបញ្ជារបស់ឪពុក ហើយប្រាប់នាងថាបើនាងមិនចូលផ្ទះនៅ

យប់នោះទេ ឪពុកនឹងសម្លាប់នាងចោល ហើយគាត់នឹងសម្លាប់ជ្រូកចោលដែរ។ ម្តាយខ្លាចឪពុក។ នៅពេលបុរសក្មេងនោះត្រឡប់ចូលផ្ទះគាត់វិញនៅពេលយប់ គាត់ឃើញឪពុកក្មេកនិងមនុស្សផ្តុំគ្នានៅមុខផ្ទះគាត់។ បុរសនោះភ័យណាស់ ហើយក៏មកជួបខ្ញុំ។ កូនស្រីគេចចូលក្នុងផ្ទះយាយគាត់ពីព្រោះគាត់ខ្លាចឪពុកសម្លាប់គាត់។ អ្នកទាំងពីរចង់រស់នៅជាមួយគ្នា ប៉ុន្តែគេខ្លាចឪពុកក្មេក។ ក្រោយមក តាមការស្នើសុំរបស់ម្តាយ ខ្ញុំទៅជួបកូនស្រីនោះស្ងាត់ៗ ហើយគាត់បានប្រាប់ខ្ញុំដោយខ្លាំងៗថា គាត់លែងចង់ត្រឡប់ទៅជាមួយប្តីគាត់វិញហើយ គាត់មិនចង់បានផ្ទះអ្វីទាំងអស់ ប៉ុន្តែគាត់ចង់បានកូន។

រឿងនេះពិបាកណាស់។ នៅពេលប្រជុំសំរុះសំរួល កូនប្រុសសុំទោសឪពុកម្តាយក្មេកដែលបានវាយកូនស្រីគាត់។ កូនស្រីមិនចង់ស្តាប់ប្តីគាត់ ឬឪពុកគាត់ទេ។ គឺឪពុកដែលធ្វើបានធ្វើសំណើនិងដែលដឹកនាំការសន្ទនាគ្នា។ ខ្ញុំគ្មានបាននិយាយអ្វីទេ វាគ្មានបានប្រយោជន៍អ្វី ព្រោះឪពុកចេះនិយាយហើយ។ ឪពុកនិយាយទៅ បុរសក្មេងនោះ ថា : "ហេតុអ្វីឯងវាយកូនអញ ព្រោះវាលេងបៀឬ? ហេតុអ្វីបានជាប្តីអាចលេងបៀ ហើយប្រពន្ធមិនអាច?"។

អស់រយៈពេល៤ខែ ដែលការដោះស្រាយរឿងនេះមិនអាចទៅណាបាន។ ខ្ញុំបានបញ្ជូនរឿងនេះទៅឱ្យប្រធានឃុំ ប៉ុន្តែគ្មានបានការអ្វី។ ខ្ញុំគិតថា ឪពុកម្តាយខាងស្រីចង់ឱ្យឪពុកម្តាយខាងប្រុសមកជួបគាត់ដើម្បីអង្វរគាត់ឱ្យទទួលយកកូនប្រុសនោះវិញ។ គាត់ធ្វើហាក់ដូចជាឱ្យឪពុកម្តាយខាងប្រុសមកដណ្តឹងកូនស្រីឱ្យកូនប្រុសម្តងទៀតអញ្ចឹង។ ឪពុកកូនស្រី សុំឱ្យឪពុកខាងប្រុសដាក់ខ្លួនបន្តិច។ ប៉ុន្តែ ដោយហេតុថា នៅពេលនេះឪពុកខាងប្រុសឈឺធ្ងន់ ម្តាយខាងប្រុសមិនអាចធ្វើសេចក្តីសំរេចទេ។ គេត្រូវរង់ចាំ"។

(លោកគីម អាយុ៦៤ឆ្នាំ ប្រធានភូមិ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

ម្តាយរបស់កូនប្រុស :

"ខ្ញុំគិតថា កូនស្រីនឹងត្រឡប់មកនៅជាមួយប្តី ប៉ុន្តែនាងខ្លាចឪពុក។ យើងមិនបានទាមទារឱ្យសងថ្លៃបណ្ណាការពេលរៀបអាពាហ៍ពិពាហ៍ទេ[១៤៥]។ យើងអាចធ្វើបាន ប៉ុន្តែយើងមិនចង់ធ្វើឱ្យរឿងវែងឆ្ងាយទេ។ ត្រូវទុកឱ្យកូនមករស់នៅជាមួយគ្នាដោយខ្លួនវា"។

(អ្នកស្រី វ៉ាត អាយុ៥០ឆ្នាំ សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

---

[145] គឺគ្រួសារខាងប្រុសដែលចេញថ្លៃបណ្ណាការ។

ការខ្វះខាតទឹកចិត្តៈ

នៅក្នុងសង្គមបូរាណនេះ ដោយម្នាក់ៗរៀនចេះដឹងការគ្រប់គ្រងដោយខ្លួនឯង តំណែងរបស់ប្រធានភូមិដែលជាអំណាចដែលដាក់បង្គាប់មកពីខាងក្រៅ មិនមែនសុទ្ធតែគេត្រូវការគ្រប់ពេលនោះទេ។ ពីដើមគេខ្លាច ពីព្រោះប្រធានភូមិមានអំណាចចាប់បង្ខំច្រើន តែឥឡូវនេះតំណែងរបស់គាត់លែងមានតម្លៃទៀតហើយ។ ប្រធានភូមិមួយចំនួនបានសារភាពពីការគ្មានទឹកចិត្តរបស់គាត់នៅក្នុងការធ្វើឱ្យសំរេចភារកិច្ចដែលទាមទារឱ្យមានតួនាទីរបស់គាត់ ៖ ការកាន់កាប់អាត្រានុកូលដ្ឋាន តួនាទីជាគូសន្ទនាជាមួយអង្គការខាងក្រៅ ការប្រជុំគណបក្ស ការសំរុះសំរួល។ល។ ដោយបានផលតបស្នងជាប្រាក់កំរៃខ្សត់ខ្សោយបំផុត។ ការខ្លាចអាជ្ញាធរថ្នាក់លើថាមិនកើត បានបង្ខំឱ្យគាត់បំពេញការងាររដ្ឋបាល ដោយសារតែខានមិនបាន។ សកម្មភាពដែលមិនទំនងជាទាក់ទាញការយកចិត្តទុកដាក់ពីប្រធានឃុំ ជួនកាលគាត់ខ្ជិលខ្ជា មិនអើពើតែម្តង រួមទាំងការសំរុះសំរួលផងដែរ។ នៅថ្នាក់លើ ប្រធានឃុំដែលមានអំណាចច្រើនជាង ជាពិសេសអំណាចបញ្ជូនរឿងឱ្យទៅនគរបាលចាត់ការ ជាហេតុធ្វើឱ្យប្រធានឃុំមានគេខ្លាច និងគោរពជាង។

> "កាលណាមានជម្លោះរវាងមនុស្សពីរនាក់ ខ្ញុំមិនចង់ដឹងថាអ្នកណាខុស និងអ្នកណាមានហេតុផលទេ។ ខ្ញុំរកឃើញហេតុផលដើម្បីនិយាយថា អ្នកទាំងពីរមានកំហុសដូចគ្នា ឬ ក៏អ្នកទាំងពីរមានហេតុផល។ ខ្ញុំនិយាយពីរឿងខុសជាទូទៅ ហើយនិងការចាំបាច់ត្រូវសំរុះសំរួលគ្នា។ ជួនកាលគេពិបាកនឹងដឹងការពិត។ អ្នកខ្លះមកប្តឹង ហើយប្រឌិតរឿងដើម្បីបានប្រាក់។ គេពិបាកនឹងស្រាយបញ្ហា កាលណាមនុស្សកុហក។ ខ្ញុំជាប្រធានភូមិតាំងតែពីឆ្នាំ១៩៨៥ ហើយខ្ញុំធុញទ្រាន់ណាស់។ ខ្ញុំចង់ឈប់ ប៉ុន្តែបក្សនឹងចោទថា ខ្ញុំលែងស្រឡាញ់បក្ស។ ខ្ញុំមិនអាចឈប់បាន។ ក្នុងឋានៈជាប្រធានភូមិ គឺទាមទារឱ្យធ្វើការ ត្រូវធ្វើការប្រជុំ ជាប់រវល់រឿងអត្រានុកូលដ្ឋាន ហើយនិងស្តាប់រឿងរបស់ប្រជាជន។ មនុស្សមានបញ្ហាជានិច្ច យើងជឿថា បញ្ហាត្រូវបានដោះស្រាយរួច តែបន្ទាប់មក បញ្ហាត្រឡប់មកវិញដដែល។ យើងខាតបង់ពេលវេលា តែមិនបានប្រាក់កំរៃប៉ុន្មាន"។
>
> (លោក ជាល ប្រធានភូមិ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

តួនាទីរបស់ប្រធានក្រុមលែងសូវសំខាន់។

> "ខ្ញុំចង់ឈប់ធ្វើជាប្រធានក្រុម។ ខ្ញុំមានការងារធ្វើ ហើយខ្ញុំគ្មានប្រាក់ខែជាប្រធានក្រុមទេ។ ខ្ញុំទៅនេសាទពេលយប់ ហើយខ្ញុំមិនចង់ធ្វើឱ្យគេដាស់ខ្ញុំពេលថ្ងៃដើម្បីស្តាប់រឿងរបស់គេទេ។ ជាទីបញ្ចប់ ខ្ញុំមានការងារតិចជាងប្រធានភូមិច្រើនណាស់។ គេមិនសូវមានអ្វីមកប្តឹងខ្ញុំទេ ហើយក៏មិនសូវមានអ្នកណាមករំខានខ្ញុំដែរ។ ខ្ញុំមិនមានចំណេះដឹងដូចប្រធានភូមិទេ។ ខ្ញុំគ្មានឯកសារ

របស់ប្រជាជនទេ ខ្ញុំមិនចេះសរសេរទេ។ តួនាទីរបស់ខ្ញុំគឺផ្តិតមេដៃលើលិខិតសន្យាដែលតែង ដោយប្រធានភូមិ កាលណាខ្ញុំធ្វើជាសាក្សីពេលប្រជុំសំរុះសំរួល។ ទាំងនេះគ្មានប្រយោជន៍ អ្វីដែលខ្ញុំត្រូវរៀនទៀតទេ ព្រោះខ្ញុំទៅតាមក្រោយប្រធានភូមិ បើគាត់និយាយថា យ៉ាងម៉េច វាយ៉ាងនោះហើយ"។

(លោក គឿង អាយុ៤៥ឆ្នាំ ប្រធានក្រុម សង្កាត់ អង្គាល់ក្រុងកែប ខេត្តកំពត)

<u>ការខ្លាចមិនហ៊ានធ្វើអន្តរាគម និងមិនចង់ឱ្យបក្ខពួកដែលមានស្រាប់ ឬអនាគតបក្ខពួក មិនសប្បាយចិត្ត :</u>
ប្រធានភូមិពីរនាក់មិនហ៊ានធ្វើអ្វីដោយខ្លាចមានការសងសឹកពីសំណាក់មនុស្សមានអំណាចជាងខ្លួនៈ យោធាម្នាក់ និងអ្នកមានម្នាក់។

"ស្រ្តីមេម៉ាយ និងកូនបួននាក់មានដីមួយកន្លែង ហើយគ្រួសារនៅជិតខាងបានលេបយកដីគាត់មួយ ល្វែង ចំនួន៣ម៉ែត្រ។ ប្រធានភូមិ មិនដឹងធ្វើយ៉ាងម៉េច។ ភាគីទាំងពីរប្រកាន់ជំហររៀងៗខ្លួន។ ហើយបើប្រធានភូមិឱ្យដីទៅស្រីមេម៉ាយ គ្រួសារមួយទៀតមិនសប្បាយ ហើយបើគាត់ឱ្យដីទៅ គ្រួសារនោះ អ្នកមេម៉ាយមិនសប្បាយចិត្ត។ គ្រួសារជិតខាងនោះមានបងប្អូនជីដូនមួយជាអ្នករាជ ការនៅទីក្រុង ហើយប្រធានភូមិមិនចង់ធ្វើអ្វីដែលធ្វើឱ្យគេមកប្រឆាំងនឹងគាត់វិញទេ។ ប្រធាន ភូមិខ្លាចសន្តិសុខគាត់នៅពេលយប់។ ចាប់តាំងពីមានគណបក្សប្រឆាំងមក ប្រធានភូមិខ្លាច។ មានមនុស្សដទៃទៀតដែលមានអំណាចបន្តិចបន្តួច ហើយគេអាចមកប្រឆាំងនឹងគាត់។ នៅទី នេះមានគ្រួសារយោធាជាច្រើន ហើយគេមានអាវុធ។ ប្រធានភូមិចង់ឈប់ធ្វើជាប្រធាន ប៉ុន្តែ គាត់ខ្លាចអាជ្ញាធរថ្នាក់លើ"។

(អ្នកស្រី វីណា អាយុ៤៨ឆ្នាំ ប្រធានភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"ពិបាកនៅក្នុងភូមិមួយដែលមានអ្នកក្រផង និងអ្នកមានផង។ បើអ្នកមានយកដីមួយភាគពីអ្នក ក្រ អ្នកក្រខ្លាច ប៉ុន្តែគាត់មកនិយាយប្រាប់ខ្ញុំពីរឿងនោះ។ ខ្ញុំធ្វើការសំរុះសំរួលរវាងអ្នកទាំងពីរ។ ខ្ញុំនិយាយការពិត។ អ្នកមានយល់ពីអ្វីដែលខ្ញុំនិយាយ។ គេយល់ថា គេធ្វើខុស ប៉ុន្តែគេខឹងនឹងខ្ញុំ ព្រោះខ្ញុំមិនយោគយល់គេ។ រឿងវាអញ្ចឹង។ បន្ទាប់មក គេអាចមានគំនុំហើយបង្កើតបញ្ហាឱ្យ ខ្ញុំ"។

(លោកខាវ អាយុ៤៦ឆ្នាំ ប្រធានភូមិ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

ប្រធានភូមិម្នាក់មិនហ៊ានធ្វើអន្តរាគមទេ ដោយខ្លាចធ្វើឱ្យមិត្តភ័ក្រ្តមិនសប្បាយចិត្ត និងធ្វើឱ្យដាច់បណ្តាញ ទំនាក់ទំនង។

"ស្ត្រីម្នាក់ឈ្មោះ ហៀន មកនិយាយប្រាប់ខ្ញុំថា ប្ដីគាត់ និងគាត់ ព្រមព្រៀងគ្នាដើម្បីលែងលះ។ ស្ត្រីនោះ និយាយរឿងច្រើនណាស់។ ប្ដីគាត់ឈ្មោះជៀល បានចុះចេញទៅនៅផ្ទះម្ដាយគេ ដោយនិយាយថា គេអស់ចិត្តនឹងប្រពន្ធ ព្រោះប្រពន្ធចាយវាយប្រាក់គ្រួសារអស់។ ហៀន ចង់ឱ្យប្ដីគាត់ត្រឡប់មកមើលសុខទុក្ខកូនវិញ ឬបើមិនដូច្នេះទេ គាត់ត្រូវឱ្យប្រាក់រាល់បីខែម្ដង ដើម្បីចិញ្ចឹមកូន។ ស្ត្រីនោះទាមទារប្រាក់៣០០០០រៀល ក្នុងមួយខែ ក្នុងកូនមួយ។ ទាំងពីរនាក់ នោះមានកូនពីរ ដូច្នេះត្រូវចេញប្រាក់៦០០០០រៀលសំរាប់កូន។ ជៀល មិនយល់ព្រមទេ។ លើសនេះទៅទៀត ប្រពន្ធចង់យកផ្ទះ ព្រមទាំងម៉ូតូមួយថ្លៃពី៣០០ ទៅ៤០០ដុល្លា។ តាមច្បាប់ បូរាណ អ្នកដែលចុះពីផ្ទះ បាត់បង់សិទ្ធិលើផ្ទះនោះ។ ជៀល ចង់លក់ឈើធ្វើផ្ទះ ហើយយកពាក់ កណ្ដាល។ ជៀលមិនចង់ចូលភូមិវិញទេ។ គាត់មិនចង់ពិភាក្សាទេ។ ខ្ញុំមិនអាចធ្វើអ្វីបានទេ។ ស្ដាប់តាមដំបូន្មានរបស់អតីតអ្នករាជការម្នាក់ដែលរស់នៅក្នុងភូមិ ហៀនបានប្ដឹងទៅតុលាការ។ តុលាការបានកោះហៅប្ដីប្រពន្ធទាំងពីរ។ ជាល មិនមកទេ គាត់លាក់ខ្លួន។ គាត់ខ្លាចគេយក ម៉ូតូគាត់។ ខ្ញុំលែងរវល់នឹងរឿងនេះហើយ ព្រោះគេមិនពឹងខ្ញុំឱ្យធ្វើអន្តរាគម ហើយគេមិន ចង់ស្ដាប់ខ្ញុំទៀតផង។ វាពិបាកនឹងនិយាយពីរឿងលែងលះ ហើយជួយចែកទ្រព្យសម្បត្តិកាលណា យើងស្គាល់ទាំងប្ដី និងទាំងប្រពន្ធ។ តទៅមុខ គេអាចនឹងចោទប្រកាន់ខ្ញុំថា លំអៀងទៅអ្នកណា ម្ខាង សូម្បីតែគេព្រមព្រៀងគ្នានិងចុះហត្ថលេខាលើកិច្ចសន្យាក្ដី"។

(លោកជាល អាយុ៥១ឆ្នាំ ប្រធានភូមិ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

បុរសម្នាក់ដែលមានការរៀនសូត្រម្នាក់ចូលចិត្តភាពស្ងៀមស្ងាត់ នៃវត្តអារាមជាជាងតំណែងជាប្រធាន ភូមិ។

"គេបានស្នើឱ្យខ្ញុំធ្វើជាប្រធានភូមិ ឬប្រធានឃុំ ព្រោះខ្ញុំមានការរៀនសូត្រ។ ខ្ញុំមិនចង់ទេ ព្រោះខ្ញុំ ខ្លាចអ្នកស្រុកស្អប់ខ្ញុំ។ កាលណាយើងត្រូវដោះស្រាយបញ្ហា យើងមិនត្រូវសំរេចថា អ្នកណាជា អ្នកឈ្នះ ហើយអ្នកណាជាអ្នកចាញ់ទេ បើពុំដូច្នោះទេ គេមិនសប្បាយចិត្ត ហើយវានឹងមានគំនុំ"។

(ចៅអធិការវត្តធម្មគីរីបុប្ផា សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

អាជ្ញាធរស្រុកលំអៀងទៅបក្ខពួកអនាគត ជាហេតុធ្វើឱ្យខូចប្រយោជន៍ដល់ជនរងគ្រោះក្រីក្រម្នាក់ដែល គ្មានបង្អែក។

"អ្នកជិតខាងបានកសាងអគារមួយនៅចំពីលើព្រំដែនដីយើងទាំងពីរ។ ជាន់លើនៃអគាររបស់គាត់ ធំជាងជាន់នៅខាងក្រោម ហើយស៊ីលំហខាងលើនៃដីរបស់យើង។ ម្ចាស់អគារបានឱ្យប្រាក់ច្រើន ពាន់ដុល្លាដល់ចៅសង្កាត់ ដើម្បីបានការអនុញ្ញាតសាងសង់។ នៅពេលកំពុងសង់ ឈើមួយដុំមាន

ទាំងដែលគោលផងធ្លាក់លើផ្ទះយើង។ ខ្ញុំទៅប្ដឹងសង្កាត់ ប៉ុន្តែគេមិនស្ដាប់ខ្ញុំទេ។ គេថា គេមានសិទ្ធិអនុញ្ញាត ឬហាមឃាត់ការសាងសង់ ហើយការសាងសង់នោះត្រឹមត្រូវតាមច្បាប់។ ខ្ញុំនិយាយថា សំណង់នោះរីកធំខាងលើ ហើយដំបូលស៊ីលំហនៃដីខ្ញុំ។ គេថា ខ្ញុំភ្នែកខ្វាក់។ ខ្ញុំចង់យកដំបងវិញ ហើយទៅប្ដឹងតុលាការ ប៉ុន្តែមនុស្សនៅសង្កាត់មិនចង់ឱ្យដំបងខ្ញុំវិញទេ។ ផ្ទុយទៅវិញ គេកាន់ជើងអ្នកឱ្យលុយទៅគេ ឬអ្នកដែលធ្វើអ្វីឱ្យគេ ហើយមិនរវល់ពីអ្នកតូចតាចទេ"។

(អ្នកស្រី បូលីន អាយុ៤២ឆ្នាំ សង្កាត់បឹងកេងកង៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ)។

ការសញ្ជឹងគិតរបស់អ្នកស្រុកម្នាក់លើឥរិយាបថអល់អែកនៃអាជ្ញាធរមូលដ្ឋាន នៅក្នុងរយៈកាលមុនពេលបោះឆ្នោត និងការខ្លាចមិនហ៊ានឱ្យអ្នកបោះឆ្នោតមិនពេញចិត្ត។

"នៅទីនេះគឺគណបក្ស ច (គណបក្សប្រឆាំង) ដែលបានឈ្នះឆ្នោតពីអាណត្តិមុន។ អភិបាលស្រុកមិនសប្បាយចិត្តនឹងចំនួនសន្លឹកឆ្នោតរបស់គណបក្សគាត់ទេ(គណបក្សកាន់អំណាច)ហើយស្ដីបន្ទោសប្រធានឃុំ និងប្រធានភូមិ។ អភិបាលស្រុកបាននិយាយថា អ្នកទាំងអស់ត្រូវប្រឹងធ្វើការថែមទៀតដើម្បីអូសទាញមនុស្សទៅខាងគាត់។ ឥឡូវនេះ ប្រធានភូមិនិងប្រធានឃុំព្យាយាមមិនធ្វើឱ្យមនុស្សមិនសប្បាយចិត្តទេ ដើម្បីឱ្យគេបោះឆ្នោតឱ្យពួកគាត់។ កាលណាមានជម្លោះ ពួកគាត់មិនចង់ចាត់ការអ្វីទេ ដើម្បីកុំឱ្យមនុស្សមិនសប្បាយចិត្ត។ កាលណាគេទៅជួបគាត់ដើម្បីដោះស្រាយបញ្ហា គាត់មិនចង់ធ្វើអន្តរាគមជ្រៅទេ ហើយគាត់មិនធ្វើអ្វីទាំងអស់។ អ្នកដែលខ្លាំងអាចធ្វើអ្វីក៏បានតាមចិត្តគេចង់"។

(លោក ណុក អាយុ៣៥ឆ្នាំ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

<u>អសមត្ថភាព និងអវិជ្ជា</u>

ប្រធានភូមិម្នាក់ដែលបានតស៊ូយូរមកហើយនៅក្នុងព្រៃ វាយតម្លៃចំណេះដឹងដែលគាត់មាន ដើម្បីដោះស្រាយជម្លោះក្នុងមូលដ្ឋាន។ នៅក្នុងការអនុវត្តប្រចាំថ្ងៃរបស់គាត់ គាត់ព្យាយាមរួមផ្សំសំណល់ខ្លះពីបុរាណជាមួយនឹងអ្វីដែលគាត់បានចេះក្នុងកម្លុងពេលនៃប្រវត្តិសាស្ត្រចលាចលថ្មីៗនេះ។ គាត់សារភាពអំពីភាពអវិជ្ជារបស់គាត់ ហើយដើម្បីកុំឱ្យប្រព្រឹត្តអយុត្តិធម៌តទៅទៀត គាត់រៀន "ច្បាប់ពិត"។

"បើមនុស្សប្រុសវាយប្រពន្ធខ្លាំង ខ្ញុំចូលធ្វើអន្តរាគម។ ខ្ញុំនិយាយថា"ការរួមគ្នាជាកម្លាំង។ នៅក្នុងសង្គមមួយ បើគ្មានសាមគ្គីភាពទេនោះ គឺយើងស្លាប់។ យើងរស់ដោយសារមានសាមគ្គីភាព។ ដើម្បីមានសាមគ្គីភាព គេត្រូវនិយាយការពិត។ គេត្រូវនិយាយត្រង់។ កាលណាមនុស្សវាយគ្នាក្នុងគ្រួសារ វាមានតែអ្នកខាត គ្មានអ្នកណាចំណេញទេ។ កាលណាគេឈ្លោះគ្នា គេវាយគ្នា គេវាយចានវាយឆ្នាំង។ បើគេវាយអ្នកណាម្នាក់ គេខាតប្រាក់ គេត្រូវសងជម្ងឺចិត្ត"។ ខ្ញុំនិយាយ

ពីសិទ្ធិរបស់រដ្ឋាភិបាលដែរ(ច្បាប់): "យោងតាមសិទ្ធិមនុស្ស ទៅតាមភាពធ្ងន់ធ្ងរនៃបញ្ហា អ្នកឯងត្រូវសងថ្លៃខូចខាត។ បើអ្នកឯងវាយគេដល់ស្លាប់ គឺត្រូវជាប់ច្បាប់ព្រហ្មទណ្ឌ។ អ្នកឯងនឹងទៅតុលាការ អ្នកឯងនឹងជាប់គុក។ កាលណាគេនិយាយពីសិទ្ធិរដ្ឋាភិបាលគឺវាខ្ពស់ណាស់។ តមកគេមិនអាចនិយាយអ្វីតទៅទៀតទេ។ រឿងនេះ ខ្ញុំចេះមកពីប្រធានឃុំ ហើយប្រធានឃុំចេះមកពីអភិបាលស្រុក។ ខ្ញុំស្តាប់វិទ្យុ និងអានកាសែតដែរ។ ក្នុងវិទ្យុគេនិយាយពីសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី។ នៅក្នុងវិទ្យុគេនិទានរឿងខ្លីៗ ដែលមានតួអង្គស្ថិតក្នុងស្ថានភាពលំបាក។ យើងរៀនសិទ្ធិមនុស្សតាមរបៀបហ្នឹង។ គេផ្សាយច្រើនណាស់តាមវិទ្យុ។ ខ្ញុំមិនចេះអ្វីធំដុំទេ ហើយខ្ញុំព្យាយាមអប់រំអ្នកភូមិ។ ខ្ញុំគ្មានការបណ្តុះបណ្តាលអ្វីជាក់លាក់ទេ ហើយខ្ញុំអាចមានកំហុស។ ខ្ញុំសង្ឃឹមថានៅពេលអនាគត នឹងមានការបណ្តុះបណ្តាលល្អៗ ដែលធ្វើឱ្យយើងធ្វើការបានល្អ។ បើខ្ញុំនៅល្ងង់ ខ្ញុំអាចថា ឬធ្វើអ្វីមិនល្អ អ្វីមិនត្រូវច្បាប់ ហើយចូលគុក ព្រោះខ្ញុំមិនចេះច្បាស់ថា ត្រូវធ្វើយ៉ាងណា។ បើខ្ញុំយល់ច្បាប់មិនច្បាស់ ខ្ញុំអាចអនុវត្តមិនល្អ។ ដូច្នេះ ក្នុងសម័យខ្មែរក្រហម ពីដំបូងគេមានចេតនាល្អ ហើយគេប្រតិបត្តិតាម។ គេនិយាយពីសាមគ្គីភាព និងសមភាពរវាងអ្នកមាន និងអ្នកក្រ។ តមក គេមិនបាច់ពិចារណាថា អ្វីដែលគេកំពុងធ្វើនោះខុស ឬត្រូវទេ។ បន្ទាប់មកមនុស្សនិយាយថា គេកាច ខ្មែរក្រហមកាច។ នេះមិនមែនជាចេតនារបស់យើងចង់កាចទេ ប៉ុន្តែគេគ្មានការអប់រំ ហើយគេមិនបានយកចិត្តទុកដាក់នឹងអ្វីដែលគេកំពុងធ្វើ។

ខ្ញុំត្រូវបានគេដាក់គុកពីឆ្នាំ១៩៧៩ ដល់១៩៨២ ព្រោះខ្ញុំជាខ្មែរក្រហម ហើយអ្នកផងគេថាខ្ញុំកាច។ ខ្ញុំមិនកាចទេ។ ខ្ញុំត្រង់ជានិច្ច ហើយខ្ញុំធ្វើតាមអ្វីដែលមេប្រាប់ខ្ញុំឱ្យធ្វើជានិច្ច។ បើមានមនុស្សកាចមនុស្សនោះគឺជាអ្នកឱ្យបញ្ជាមកខ្ញុំ។ ខ្ញុំត្រូវតែធ្វើតាម។

ខ្ញុំមានកំរិតអប់រំខ្សោយ។ ដូច្នេះ មិនគ្រប់គ្រាន់សំរាប់ដោះស្រាយបញ្ហាក្នុងភូមិទេ។ ខ្ញុំមិនសូវមានការរៀនសូត្រដើម្បីដោះស្រាយទំនាស់នៅក្នុងភូមិទេ។ កាលណាយើងមិនបានរៀនសូត្រ ហើយយើងជាប្រធានភូមិ នោះគ្មានយុត្តិធម៌ទេ។ កាលណាខ្ញុំមិនដឹងថា ត្រូវដោះស្រាយបញ្ហានោះយ៉ាងណានោះ ខ្ញុំប្រាប់ឱ្យគេស្ងាត់ ហើយនៅឱ្យស្ងៀម។ មានយុត្តិធម៌ជាងពីមុន ប៉ុន្តែមិនទាន់មានយុត្តិធម៌១០០%ទេ។ បញ្ហាមួយទៀត គឺពេលណាគេប្រាប់ខ្ញុំឱ្យអនុវត្តច្បាប់។ វាពិបាកនឹងយល់ច្បាស់ណាស់ បើគេមិនចេះអក្សរ។ មនុស្សក្នុងភូមិគ្មានយល់អ្វីទេ។ គេសុខចិត្តព្រោះគេខ្លាចច្បាប់ ប៉ុន្តែគេមិនយល់ថា ហេតុអ្វីបានជាគេធ្វើដូច្នេះ។ គេមានទម្លាប់ស្តាប់មនុស្សនៅខាងលើ ហើយខ្លាច។ កាលសម័យខ្មែរក្រហម គេនិយាយពីសាមគ្គីជាតិ សាមគ្គីអន្តរជាតិ និងរណសិរ្សរួមរួមជាតិ។ គេមិនយល់ច្បាស់ទេ ប៉ុន្តែគេមិននិយាយ។ គេខ្លាច។ ឥឡូវនេះ

ខ្ញុំចូលចិត្តឱ្យគេបង្រៀនខ្ញុំពីអ្វីដែលត្រូវ និងអ្វីដែលមិនត្រូវ។ ខ្ញុំចេះមិនច្បាស់ទេ។ បើពេលក្រោយ ខ្ញុំធ្វើអ្វីភ្លីភ្លើ គេនឹងមកប្រាប់ខ្ញុំថា ខ្ញុំធ្វើអ្វីភ្លីភ្លើ។ ខ្ញុំចង់រៀនច្បាប់ពិត ហើយច្បាប់នោះមានន័យដូចម្ដេច។ គ្មានអ្នកណាអាចមកថាឱ្យខ្ញុំធ្វើអញ្ចឹងមិនត្រូវនោះទេ"។

(លោក ម៉ុន អាយុ៥៤ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម)ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

ការគ្មានអំណាចនឹងដោះស្រាយបញ្ហាពិបាក

"ក្នុងករណីខ្លះ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េចទេ។ កាលណាវាជារឿងស្នេហា គឺពិបាកណាស់។ ប្ដីនិងប្រពន្ធខឹងនឹងគ្នា ហើយបន្ទាប់មកគេស្រឡាញ់គ្នាជាថ្មី។ ខ្ញុំឱ្យដំបូន្មានតាមសំណើរបស់ភាគីម្ខាង ហើយក្រោយមក ពួកគេលែងស្ដាប់ ហើយមិនប្រាប់ខ្ញុំ សូម្បីតែគេមករស់នៅជុំគ្នាជាថ្មីក្ដី។ ខ្ញុំមិនអាចដោះស្រាយរឿងពួកក្មេងៗដែលជាសង្សារនឹងគ្នា ហើយដែលឪពុកម្ដាយមិនចង់ឱ្យរៀបការ ឬដែលពួកគាត់បង្ខំឱ្យលែងលះគ្នា។ ជារឿយៗ គូសង្សាររត់តាមគ្នាដើម្បីទៅរស់នៅរួមគ្នា"។

(លោក វ៉ាយ អាយុ៤៦ឆ្នាំ ប្រធានភូមិ ឃុំពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

ការគ្មានចំណាត់ការនៃការិយាល័យនគរបាលនៃសង្កាត់នៅទីក្រុងដែលសំរេចបញ្ជូលរឿងទៅការិយាល័យដទៃទៀត និងអង្គការ។

"គេកោះហៅមនុស្សចំពោះបណ្ដឹងដែលទាក់ទងនឹងរឿងព្រហ្មទណ្ឌ ដូចជាការធ្វើឱ្យរបួសស្នាមជាដើម។ បើគេមិនឆ្លើយតបនឹងការកោះហៅទេនោះ គេនឹងធ្វើរបាយការណ៍មួយ ហើយគេបញ្ជូនរឿងទៅខ័ណ្ឌ។ គេមិនអាចទៅរកមនុស្សទាំងអស់នោះបានទេបើគេមិនមក ហើយបើរឿងនោះមិនជាធ្ងន់ណាស់ណាទេនោះ។ បើមនុស្សមក គេឱ្យដំបូន្មានដល់អ្នកដែលប្រព្រឹត្តអំពើ។ គេនិយាយទៅអ្នកនោះថា បើគាត់ចង់ឱ្យបញ្ឈប់នីតិវិធី គាត់ត្រូវសងថ្លៃខូចខាតដែលគាត់បានបង្ក។ នៅពេលយប់ នៅពេលដែលការិយាល័យរដ្ឋបាលសង្កាត់បិទ គេទទួលពាក្យបណ្ដឹងដែលគេចាត់ចែងជាទម្លាប់។ មានការឈ្លោះគ្នាច្រើនណាស់ទាក់ទងនឹងសុរា។ ឧទាហរណ៍ ស្ត្រីម្នាក់បានភៀសខ្លួនមកនៅទីនេះច្រើនថ្ងៃមកហើយ ដោយនិយាយថា ប្ដីគាត់ចង់សម្លាប់គាត់នឹងកាំបិត។ យើងបានជួយគាត់ ហើយយើងបានប្រាប់ប្ដីឱ្យនៅស្ងប់ស្ងៀម។ គេឱ្យដំបូន្មានដល់ប្រពន្ធប្ដីវាយដែលមិនចង់ចូលផ្ទះវិញឱ្យទៅរកមជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា។ គេមិនអាចធ្វើអ្វីបានធំដុំទេ។ គេប្រាប់ឱ្យមនុស្សចូលផ្ទះវិញ ហើយរង់ចាំថ្ងៃស្អែក ដើម្បីទៅប្ដឹងសាលាសង្កាត់"។

(លោក គុន នគរបាល អាយុ៤៥ឆ្នាំ សង្កាត់បឹងកេងកង៣ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ)

## ៧. បញ្ជូនបណ្តឹងទៅថ្នាក់លើតាមឋានានុក្រម

កាលណាគេមិនបានដល់ការព្រមព្រៀងគ្នានៅថ្នាក់ភូមិទេនោះ រឿងត្រូវបញ្ជូនទៅថ្នាក់លើ គឺឃុំ(ជាគោលការណ៍តាមចំណាររបស់ប្រធានភូមិ)។ បើការមិនព្រមព្រៀងនៅមានបន្តទៅទៀត រឿងអាចឡើងទៅគ្រប់ជាន់ថ្នាក់រដ្ឋបាល រហូតដល់ស្រុក ឬសាលាខេត្ត។ បើភាគីដែលត្រូវចោទប្រកាន់មិនចង់ព្រមព្រៀងជាមួយភាគីម្ខាងទៀត ហើយបើដើមចោទនៅតែចចេស នៅពេលនោះគឺដល់ពេលត្រូវបោះបង់រឿងចោល ឬក៏ទៅប្តឹងនៅតុលាការ។ ច្បាប់អនុញ្ញាតឱ្យទៅប្តឹងដោយផ្ទាល់នៅតុលាការខេត្ត។ ផ្ទុយទៅវិញ យើងរកឃើញថា នៅតំបន់ជនបទភាគច្រើននៃបញ្ហាត្រូវបានចាត់ការនៅកំរិតភូមិនិងឃុំ។ មានរឿងតិចណាស់ដែលឡើងទៅតុលាការខេត្ត។

មនុស្សនៅភ្នំពេញ មិនញញើតនឹងរំលងអាជ្ញាធរមូលដ្ឋានទេ ហើយយកបណ្តឹងទៅតុលាការ។ ប៉ុន្តែ អ្នកដែលរស់នៅទីកន្លែងដាច់ស្រយាលមិនហ៊ានធ្វើឱ្យអាជ្ញាធរមូលដ្ឋានអន់ចិត្តដោយសារគេមិនទៅពិគ្រោះជាមួយអាជ្ញាធរទាំងនោះទេ។

<u>សេចក្តីប្រាថ្នាចង់ដោះស្រាយជម្លោះនៅត្រឹមថ្នាក់មូលដ្ឋាន</u>

ជាទូទៅ អាជ្ញាធរមូលដ្ឋានមិនចង់ឱ្យបញ្ហារបូតចេញពីមណ្ឌលអំណាចរបស់គាត់ទេ។ ភូមិស្ងប់ស្ងាត់មួយមានកេរ្តិ៍ឈ្មោះល្អ ដែលជាហេតុលើកតិត្តិយសឱ្យប្រធានភូមិ។ ប្រធានដែលចូលចិត្តប្រើអំណាច ហើយដែលដោះស្រាយបញ្ហាដោយមានសមធមិខ្លះៗ មានមនុស្សចូលចិត្តជាងប្រធានស្លូត ដែលមិនត្រួតត្រាលើរាស្ត្រ។

> "នៅពេលប្រជុំប្រធានក្រុម ប្រធានភូមិបាននិយាយថា គេត្រូវដោះស្រាយបញ្ហាឱ្យបានជាអតិបរិមាដោយខ្លួនឯង។ ក្រុមល្អគឺក្រុមដែលមានរឿងតិចឡើងទៅប្រធានភូមិ។ ជួនកាលមនុស្សមិនឆ្លងកាត់ខ្ញុំទេ ហើយគេទៅជួបប្រធានភូមិដោយផ្ទាល់តែម្តង។ អ្នកទាំងអស់នេះអាចសុំឱ្យខ្ញុំមកដើម្បីបានពតិមានអំពីបញ្ហា កាលណាពួកគេមិនយល់ ប៉ុន្តែរឿងនេះមិនមានច្រើនប៉ុន្មានទេ។ កាលណាយើងធ្វើការសំរុះសំរួល វាមិនមានយុត្តិធមិ១០០%ជានិច្ចទេ។ ពេលខ្លះ យើងធ្វើការគាបសង្កត់លើមនុស្សម្នាក់។ បើយើងមិនធ្វើការកៀបសង្កត់ទេ មនុស្សនៅតែបង្កើតរឿង"។
> (លោក វ៉ាយ៉ា អាយុ៤៥ឆ្នាំ ប្រធានក្រុម សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

> "ប្រធានភូមិចង់ដោះស្រាយបញ្ហាដោយខ្លួនឯង។ គាត់មិនចង់ឱ្យរឿងឡើងដល់លើទេ បើពុំដូច្នោះទេ គាត់នឹងខ្មាស់គេថា មានបញ្ហាច្រើននៅក្នុងភូមិ។ ក្រោយពីឆ្នាំ១៩៧៩ ប្រធានភូមិមានអំណាចខ្លាំងណាស់ ហើយគាត់សង្កត់សង្កិនមនុស្ស។ ឥឡូវនេះ មនុស្សមានការអប់រំច្រើនជាងហើយគេលែងស្ងូវខ្លាចហើយ។ លើសពីនេះទៅទៀត គេអាចទៅរកអង្គការខាងក្រៅបាន"។
> (លោក ស៊ីថូ អាយុ៣៣ឆ្នាំ អ្នកស៊ើបអង្កេតនៃអង្គការសិទ្ធិមនុស្សមួយ ក្រុងកំពុងស្ពឺ ខេត្តកំពង់ស្ពឺ)

"បើតាមច្បាប់ គេអាចទៅតុលាការដោយផ្ទាល់តែម្តង ប៉ុន្តែបើតាមប្រពៃណី គេធ្វើមួយដំណាក់ទៅមួយដំណាក់។ គេឡើងទៅគ្រប់ជាន់ថ្នាក់អាជ្ញាធររដ្ឋបាល គឺប្រធានក្រុម ប្រធានភូមិ ប្រធានឃុំ អភិបាលស្រុក និងអភិបាលខេត្ត។ បើមនុស្សផ្លោះរំលងដំណាក់ គេខ្លាចមានការស្តីបន្ទោស។ ឧទាហរណ៍ បើអ្នកណាម្នាក់ដាក់ពាក្យបណ្តឹងទៅរដ្ឋសភា ដោយមិននិយាយជាមួយនិងអាជ្ញាធរមូលដ្ឋាន កាលណាចម្លើយត្រលប់មកវិញតាមខ្សែរយៈអាជ្ញាធរមូលដ្ឋាន អាជ្ញាធរមូលដ្ឋាននឹងស្តីបន្ទោសថាៈ " ហេតុអ្វីបានជាអ្នកឯងប្តឹងទៅសភា? អ្នកឯងជឿថា យើងគ្មានប្រសិទ្ធិភាពឬ? អ្នកឯងមានអារម្មណ៍ថាខ្លួនឯងមានមនុស្សកៀកនឹងថ្នាក់លើឬ?"។ អាជ្ញាធរមូលដ្ឋានមានការខ្មាស់អៀន ពីព្រោះគេអាចចោទគាត់ថាមិនធ្វើការ ដូច្នេះគាត់ត្រូវបន្ទោសមនុស្ស។

ជាងនេះទៅទៀត គេចូលចិត្តដោះស្រាយបញ្ហានៅថ្នាក់ទាបជាមួយនឹងអាជ្ញាធរមូលដ្ឋាន ហើយជៀសវាងមិនទៅថ្នាក់លើដែលបង្កើតបញ្ហាថែមទៀត"។

(លោក សារី អាយុ ៣២ឆ្នាំ ក្រុងតាខ្មៅ ខេត្តកណ្តាល)

ប្រធានភូមិម្នាក់មិនចង់ឱ្យអន្តរាគមពីអាជ្ញាធរខាងក្រៅមកប្រឆាំងនឹងកិច្ចការរបស់គាត់ ជាមួយនឹងបក្ខពួកមូលដ្ឋាន :

" យើងមិនចង់ឱ្យមនុស្សនៅសាលាសង្កាត់ រវល់នឹងរឿងដីនៅទីនេះទេ។ គេមិនដឹងរឿងចែកដីធ្លីនៅទីនេះទេ។ គឺប្រធានភូមិដែលមានក្រដាសស្នាមទាំងអស់ ហើយសមាជិកគណៈកម្មាធិការចែកដីធ្លីនៅរស់ទាំងអស់ គេដឹងអ្នកណាខ្លះដែលបានចែកដីឱ្យ។ នៅទីនេះ មានបញ្ហារវាងមនុស្សអ្នកភូមិ និងយោធា។ តាមពិតគឺមនុស្សអ្នកភូមិដែលយកដីរបស់យោធា គឺមិនមែនយោធាយកដីប្រជាពលរដ្ឋទេ។ យើងចង់ដោះស្រាយរឿងនេះរវាងយើងទាំងអស់គ្នា ប៉ុន្តែអ្នកស្រុកបែរជាទៅរកអង្គការសិទ្ធិមនុស្ស។ អង្គការនេះបានចោទយើងថាលំអៀងទៅយោធា ហើយយកដីប្រជាពលរដ្ឋឱ្យយោធា"។

(លោកទិត អាយុ៥៨ឆ្នាំ អនុប្រធានភូមិ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែបខេត្តកំពត)

## បញ្ជូនរឿងទៅថ្នាក់លើ

កាលណារឿងមិនបានដោះស្រាយនៅថ្នាក់មូលដ្ឋាន ហើយកាលណាភាគីម្នាក់ ឬទាំងពីរនាក់នៃជម្លោះចង់បន្តរឿង គេត្រូវបញ្ជូនរឿងនោះទៅអាជ្ញាធរថ្នាក់លើ។ ដោយសារគាត់នៅកៀកនឹងប្រជាជន ប្រធានឃុំមកសំរុះសំរួលករណីមួយចំនួន។ នៅថ្នាក់ស្រុក អាជ្ញាធរស្ថិតនៅឆ្ងាយពីអ្នកភូមិ ហើយអាជ្ញាធរទាំងនោះមិនស្គាល់អ្នកភូមិដោយផ្ទាល់ទេ។ អត្រានៃជោគជ័យនៅក្នុងការសំរុះសំរួលមានតិចតួច។

បើការមិនព្រមព្រៀងគ្នាចេះតែមានបន្តទៅទៀត ហើយបើភាគីជម្លោះ ជាអ្នកក្រ ហើយមានការអប់រំតិច រឿងនឹងខ្សោះខ្យល់ជារឿយៗនៅក្នុងការប្រជុំសំរុះសំរួលដោយរកទីបញ្ចប់មិនឃើញ។ ជារឿយៗ ភាគីបញ្ចប់ដោយនឿយហត់ខ្លួនឯង ហើយបោះបង់រឿងជម្លោះចោល។ ការគុំគួននឹងចាប់មានឡើង ដើម្បីឱ្យកើតជម្លោះមួយទៀតប្រហែលនៅថ្ងៃណាមួយទៀត។ ក្នុងករណីមនុស្សដែលដាច់ខាតមានទ្រព្យ ឬមានខ្សែទំនាក់ទំនង រឿងអាចបញ្ជូនដល់តុលាការដើម្បីធ្វើការវិនិច្ឆ័យ។

ឧទាហរណ៍ នៃវិវាទរឿងដីធ្លីមួយ ដែលគូជម្លោះបានប្រើប្រាស់អស់លំដាប់ថ្នាក់រដ្ឋបាល មុននឹងដាក់រឿងទៅឱ្យតុលាការ ដែលជាអ្នកសម្រេចឱ្យអ្នកនេះឬអ្នកនោះឈ្នះ។ ប្រធានភូមិទទួលស្គាល់ថា រវាងទំនៀមទំលាប់ និងច្បាប់គេមានការពិបាកសំរុះសំរួលរឿងនៅថ្នាក់មូលដ្ឋាន។

> "ក្នុងសម័យសង្គមរាស្ត្រនិយម ដីទាំងអស់ជាដីរបស់តាហឿន។ នៅឆ្នាំ១៩៧៩ តាប៉ាន់ចាប់បានដីនេះ។ បន្ទាប់មកតាហឿនមក ហើយគាត់បានសុំដីមួយផ្នែក។ តាប៉ាន់បានឱ្យដីទំនាបទៅគាត់។ តាហឿនបានដាំដូង និង ធ្វើស្រែ។ តាប៉ាន់បានជីកដីធ្វើព្រំដែន ហើយតាហឿនបានចោទគាត់ថាចង់យកដីមួយផ្នែករបស់គាត់។ តាហឿន ក៏មកប្តឹង។ ខ្ញុំទៅមើលដល់កន្លែង ហើយសុំឱ្យអ្នកណាដែលរំលោភយកដីគេត្រូវប្រគល់ឱ្យគេវិញ។ តាប៉ាន់ ជាមនុស្សចាស់ចចេស គាត់មិនចង់ស្តាប់បន្តិចសោះ។ តាប៉ាន់ និងតាហឿនជាសត្រូវនឹងគ្នាតាំងពីយូរមកហើយ ហើយនៅបន្តឈ្លោះគ្នារហូតមកទល់សព្វថ្ងៃ។ ឥឡូវនេះ ម្នាក់ៗចង់បានដីទាំងមូល។ តាហឿនថា ដីនោះជារបស់គាត់តាំងពីសម័យសង្គមរាស្ត្រនិយម ហើយតាប៉ាន់ថាដីនោះជារបស់គាត់ ពីព្រោះគាត់បានកាន់កាប់តាំងពីឆ្នាំ១៩៧៩។ គេពិបាកដោះស្រាយរឿងបែបនេះណាស់។ ប្រពៃណីនិយាយថា ដីនោះជាមរតករបស់តាហឿន ហើយច្បាប់និយាយថា ដីជារបស់តាប៉ាន់ ព្រោះគាត់មកនៅលើដីនេះក្នុងឆ្នាំ១៩៧៩។ ប៉ុន្តែគាត់បានអនុញ្ញាតឱ្យតាហឿនមកតាំងនៅលើដីមួយដុំ។ ស្មុគ្រស្មាញណាស់។ យកស្រួល គាត់ត្រូវសំរួលគ្នា ប៉ុន្តែគាត់ស្អប់គ្នា"។

តាប៉ាន់បកស្រាយរឿងរបស់គាត់ឱ្យស្តាប់។ តាមសំដីគាត់ ហេតុការណ៍ពិតសំខាន់ជាងអ្វីដែលសរសេរ និងច្បាប់តុលាការ។

> "តាហឿនចង់ដើរតួជាមនុស្សខ្លាំង ព្រោះកាត់មានខ្នងនៅក្នុងជួរនគរបាល។ គាត់កាច គាត់ជាអតីតខ្មែរក្រហម។ តាហឿនមិនចង់បង្ហាញខ្លួនតាមដីការកោះរបស់ប្រធានភូមិ និងប្រធានឃុំទេ។ ប្រធានភូមិប្រាប់គាត់ថាៈ "ឱ្យដីទៅតាប៉ាន់វិញទៅ"។ ហើយគាត់មិនចង់ឱ្យទេ។ សំរាប់ខ្ញុំការវិនិច្ឆ័យគ្មានអ្វីស្មុគ្រស្មាញទេ។ ខ្ញុំនៅលើដីនេះមុនគាត់ក្នុងឆ្នាំ១៩៧៩ ហើយដីជារបស់ខ្ញុំ

ទាំងមូល។ បញ្ហាបានចាប់ផ្តើម៣ឆ្នាំមកហើយ ខ្ញុំភ្លេចថ្ងៃខែជាក់លាក់។ ព្រឹកថ្ងៃមួយ ខ្ញុំនៅឯស្រែ ហើយតាហឿននិយាយចំអកឱ្យខ្ញុំថា :"អ្ហេ. ឯងធ្វើអីហ្នឹង? ឯងគ្មានសិទ្ធិលើកន្លែងនេះទេ"។ មួយខែក្រោយមក គាត់ប្តឹងទៅភូមិនិងសង្កាត់។ ខ្ញុំត្រូវបានកោះហៅទៅឃុំ។ ខ្ញុំខ្លាច ព្រោះគេចុះលើក្រដាសថា កម្មវត្ថុនៃការកោះហៅគឺ : ជម្លោះដេរប្រមាថ។ ខ្ញុំមិនទៅទេ។ ក្រោយមកតាហឿនប្រាប់ខ្ញុំថា : "កុំជីកឆ្ងាយពេកបានទេ"។ ខ្ញុំមិនបាននិយាយអ្វីទេ ខ្ញុំខ្លាច ខ្ញុំគេចខ្លួន។ គាត់ជាអតីតទាហានប៉ុលពត។ ខ្ញុំបានទៅប៉ុស្តទាហានព្រៃតានិន។ ពីមុនគឺយោធាជាអ្នកដោះស្រាយបញ្ហាប្រជាជន។ ឥឡូវនេះភាគច្រើនគណៈបក្សនយោបាយជាអ្នកដោះស្រាយ។ ពីមុនមនុស្សខ្លាចយោធា។ បើគេនៅខាងយោធា គេអាចជួយ មនុស្សស្តាប់។ មនុស្សខ្លាច។ ឥឡូវនេះទាំងអស់អាស្រ័យលើគណៈបក្ស។ នយោបាយរារាំងប្រធានឃុំ មិនឱ្យគាត់ដោះស្រាយរឿងបានល្អ។ គេខ្លាចមិនហ៊ានធ្វើអន្តរាគមច្រើនពេក ហើយក្រោយមកខ្លាចមនុស្សមិនសប្បាយចិត្ត មិនបោះឆ្នោតឱ្យគាត់។ កាលណាមានវិវាទខ្លាំងពេកគាត់ចូលចិត្តបញ្ជូនរឿងក្តីទៅតុលាការ។ ការសំរុះសំរួលមិនមែនជាវិធី យុត្តិធម៌ត្រឹមត្រូវទេ។ អ្នកខ្លាំងហើយមានប្រាក់ច្រើនជាង អ្នកនោះមានប្រៀប ព្រោះប្រធានឃុំអាចសុំអ្វីម្យ៉ាងពីអ្នកនោះជាថ្នូរនៅថ្ងៃណាមួយ។

បន្ទាប់មក ប្រធានឃុំបានបញ្ជូនរឿងទៅតុលាការ។ តុលាការព្យាយាមធ្វើការសំរុះសំរួល ប៉ុន្តែតាហឿនមិនចង់ស្តាប់ទេ។ គាត់ចង់បានដីទាំងមូល។ ខ្ញុំត្រូវបានកោះហៅទៅតុលាការ។ ចៅក្រមនិយាយថា ខ្ញុំមានលិខិតកាន់កាប់ដីក្លែងក្លាយ។ ខ្ញុំបានធ្វើលិខិតនៅឆ្នាំ១៩៨៩ ប៉ុន្តែគេចុះនៅឆ្នាំ១៩៨២។ គេនិយាយថាខ្ញុំព្យាយាមធ្វើលិខិតក្លែងក្លាយ ប៉ុន្តែនេះមិនមែនជាកំហុសខ្ញុំទេ គឺជាកំហុសរបស់អ្នកសរសេរលិខិតដែលបានធ្វើកំហុស។ ខ្ញុំបានឱ្យដីមួយចំណែកទៅតាហឿននៅឆ្នាំ១៩៨៥។ គាត់បានធ្វើលិខិតមួយនៅពេលនោះ ហើយឥឡូវ គាត់ថា លិខិតគាត់មុនលិខិតខ្ញុំដូច្នេះគាត់ជាម្ចាស់។ ខ្ញុំមិនដឹងថា គាត់បានធ្វើលិខិតមួយទេ។ ខ្ញុំច្បាស់ថាគាត់ទើបតែធ្វើលិខិតនោះ។ គាត់មានខ្នងនៅឃុំ។ ប្រពន្ធទីមួយរបស់គាត់ជាអនុប្រធានទីមួយឃុំ។ តាហឿនពិតជាបានចាយលុយឱ្យតុលាការ ព្រោះខ្ញុំត្រូវបានកោះហៅ។ ឥឡូវនេះ ខ្ញុំត្រូវគេកោះហៅទៅតុលាការទៀតហើយក្នុងពេលឆាប់ៗនេះ។ គេបានទារខ្ញុំ៥០០០រៀលរួចហើយសំរាប់ថ្លៃតែម ប៉ុន្តែគេយល់ព្រមឱ្យខ្ញុំបង់តែ២០០០រៀលទេ ព្រោះខ្ញុំក្រ។ ទៅតុលាការចុះសោហ៊ុយច្រើនណាស់។ យើងត្រូវទៅទីក្រុងជាមួយសាក្សី យើងត្រូវចេញថ្លៃដឹកនាំម្ហូបចំណីបារី។ តុលាការមិនចង់ស្តាប់អ្វីដែលសាក្សីនិយាយទេ។ គេពិចារណាតែលើឯកសារសរសេរ ហើយគេថាខ្ញុំធ្វើឯកសារក្លែងក្លាយ។ ដំណោះស្រាយរបស់តុលាការមិនយុត្តិធម៌ទេ។ គេត្រូវពិចារណាលើការពិតពីអ្វីដែលកើតមាននៅទីកន្លែង គឺមិនត្រូវពិចារណាលើក្រដាសទេ។ ការពិតគឺដីជារបស់ខ្ញុំ ព្រោះខ្ញុំជាអ្នកប្រើប្រាស់ដី

ទីមួយនៅឆ្នាំ១៩៧៩។ តុលាការនិយាយថា បើខ្ញុំទទួលស្គាល់កំហុសរបស់ខ្ញុំ ខ្ញុំត្រូវសងតាហឿន នូវសោហ៊ុយទាំងអស់ដែលគាត់បានចំណាយនៅតុលាការ។ ខ្ញុំមិនចង់ទេ"។

(តាប៉ាន់ អាយុ ៦៩ឆ្នាំ ឃុំអង្គាល់ ក្រុងកែប ខេត្តកំពត)

ប្រធានឃុំបានស្នើដំណោះស្រាយមួយ មុននឹងរឿងត្រូវលើកទៅតុលាការ។

"តាហឿនស្គាល់មនុស្សនៅតុលាការ ហើយធ្វើអោយរឿងស៊ីពេលយូរដើម្បីបានឈ្នះ។ ខ្ញុំបានស្នើឱ្យកំណត់ព្រំដែនជាថ្មីរវាងដីទាំងពីរ ប៉ុន្តែតាប៉ានក្តី តាហឿនក្តី មិនចង់ទេ។ អ្នកទាំងពីរសុទ្ធតែចចេស"។

(លោក ម៉ី អាយុ៥៦ឆ្នាំ ប្រធានឃុំអង្គាល់ ក្រុងកែប ខេត្តកំពត)

នៅក្នុងស្រុកភូមិគេស្គាល់រឿងនេះច្បាស់។ តាលិនបាននិយាយថា ការប្រឆាំងគ្នារវាងមនុស្សទាំងពីរ មានយូរលង់ណាស់មកហើយ ទាំងនេះហើយបានជាគាត់ចចេសរៀង១ខ្លួន ម្នាក់១មិនព្រមប្តូរឥរិយាបថ ហើយនាំឱ្យស្ថានការណ៍នៅតាំងរហូតមកដល់សព្វថ្ងៃនេះ។

"តាបាន់ក្តី តាហឿនក្តី មិនព្រមធ្វើសម្បទានទេ។ អ្នកទាំងពីរបានចំណាយប្រាក់កាសពីរដងច្រើនជាងថ្លៃដីនេះទៅទៀត ដើម្បីបន្តរឿងនៅតុលាការ ប៉ុន្តែគ្មានអ្នកណាសុខចិត្តធ្វើសម្បទានទេ។ មនុស្សច្រើនណាស់ដែលដឹងរឿងនេះ។ គ្មានអ្នកណាសុខចិត្តទន់ទោរ ហើយក៏គ្មានអ្នកណាម្នាក់សុខចិត្តបាក់មុខទេ។ អ្នកទាំងពីរខឹងនឹងគ្នាតាំងពីយូរណាស់មកហើយ។ រឿងនេះជាលេសដើម្បីឱ្យពួកគាត់ប្រឈមមុខដាក់គ្នា។ ម្នាក់១ត្រៀមខ្លួនសុខចិត្តបង់លុយដើម្បីឱ្យឈ្នះម្តងទៀត។ នៅដំណាក់ការនេះនៃជម្លោះ បើមានច្បាប់មួយដែលនិយាយថា រឿងនេះត្រូវនៅត្រឹមនេះមិនទៅណា នោះអ្នកទាំងពីរមុខជាយល់ព្រម។ ប៉ុន្តែឥឡូវនេះ រឿងនេះចេះតែរីកធំទៅ១។ ពួកគាត់លែងដឹងថាត្រូវធ្វើយ៉ាងណាហើយ ហើយតុលាការក៏មិនទៅមុខដែរ។ បើតាមច្បាប់ តាប៉ាន់ជាម្ចាស់ដី ប៉ុន្តែតាហឿនដែលជាម្ចាស់ពីមុនបានយកដីក្រោយឆ្នាំ១៩៧៩។ តាហឿនបានបំភ្លេចដីនោះទៅហើយ។ គាត់បានយកដីមួយផ្នែកឡើងវិញ ហើយឥឡូវនេះគាត់ទាមទារយកដីទាំងមូល ព្រោះគាត់បានធ្វើលិខិតមួយមុនតាប៉ាន់។ តាប៉ាន់មិនអាចលះបង់រឿងនេះបានទេ។ គាត់មិនចង់ខាតទេ។ គាត់រស់នៅក្បែរដីនោះ ចំណែកតាហឿនរស់នៅលើកោះមួយ។ ទាំងតាប៉ាន់ និងតាហឿនមិនចង់ចាញ់ទេ"។

(លោក លិន អាយុ ៧០ឆ្នាំ ឃុំអង្គុល ក្រុងកែប ខេត្តកំពត)

រឿងរីកធំរហូតដល់បញ្ជូនបណ្តឹងដល់ថ្នាក់លើក្នុងករណីស្ថានការណ៍តាំងស្ទះ

យើងបានរកឃើញករណីនានាដែលខ្លាច**បាក់មុខ** នាំឱ្យមានប្រតិកម្មធ្វើឱ្យតាំងស្ទះ ដែលអាចឱ្យមានលទ្ធផលបញ្ច្រាស់ ដូចជាការបំបិទរឿង ឬការមិនព្រមសារភាពកំហុសរបស់ខ្លួន ហើយអាចនឹងបញ្ជូនរឿងទៅថ្នាក់លើៗទៀតបើភាគីម្ខាងទៀតមិនព្រមចុះញ៉ម ។

- ការខូចកិត្តិយស និងការបំបិទរឿង :

ការខ្មាស់ មិនហ៊ាននិយាយពីបញ្ហាប្តីប្រពន្ធ និងសុំលែងលះជារឿយៗនាំឱ្យគេបៀមទុក្ខក្នុងខ្លួនឯង ។

> "នៅទីនេះគេនិយាយថា ប្តីនិងប្រពន្ធមិនត្រូវលែងលះគ្នាទេ ។ ចំណែកខ្ញុំ ខ្ញុំក៏គិតថាជាការល្អដែរ បើប្តីនិងប្រពន្ធនៅរួមគ្នារហូតដល់អស់ជីវិតរៀងៗខ្លួន ។ លែងលះគ្នាមិនល្អទេ ។ សំខាន់គឺកុំឱ្យអ្នកជិតខាងនិយាយចំអកឱ្យប្តីប្រពន្ធ ។ បើមានបញ្ហាគេត្រូវទ្រាំ" ។
>
> (លោក សំអាត អាយុ៤៥ឆ្នាំ ឃុំតាកែន ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

> " គេមិនត្រូវយកការខ្មាស់អៀនមកដាក់ខ្លួនទេ ។ គេត្រូវលាក់បាំងការខ្មាស់អៀន ។ កាលណាអ្នកមានទុក្ខលំបាក អ្នកត្រូវលាក់ទុកនៅក្នុងខ្លួន ។ បើអ្នកប្រាប់អ្នកដ៏ទៃ វានឹងមានបញ្ហាច្រើនទៀត ។ គេនឹងមើលងាយអ្នក" ។
>
> (លោក កឿង អាយុ ៤៥ឆ្នាំ ប្រធានក្រុម សង្កាត់អង្កាល់ ក្រុងកែប ខេត្តកំពត)

- ការបាក់មុខ និងការរីកទៅរកការប្តឹងផ្តល់គ្នា :

ជាប្រពៃណី ប្អូនត្រូវបង្អោនខ្លួនចំពោះមុខបង ទោះបីជាបងមានកំហុសក៏ដោយ ។ នៅទីនេះ ស្ត្រីម្នាក់មិនញញើតនឹងប្តឹងម្តាយក្មេកគាត់ទេ ។ ម្តាយក្មេកទប់ស្កាត់រាល់ការប៉ុនប៉ងសំរុះសំរួលទាំងអស់ដើម្បីកុំឱ្យបាក់មុខនៅចំពោះមុខកូនប្រសារស្រី ។ រឿងដែលមិនអាចដោះស្រាយកើតនៅមូលដ្ឋាន ត្រូវឡើងរហូតដល់តុលាការ ។

> "ថ្ងៃមួយ ខ្ញុំបានវាយកូនខ្ញុំ ។ ម្តាយក្មេកខ្ញុំខឹងនឹងខ្ញុំ ហើយគាត់វាយក្បាលខ្ញុំ ។ ខ្ញុំហូរឈាមយ៉ាងខ្លាំងរហូតដល់សន្លប់ ។ ប្រធានភូមិបានធ្វើសំបុត្រមួយដែលសរសេរថាខ្ញុំត្រូវបានវាយដោយម្តាយក្មេកខ្ញុំ ។ ខ្ញុំទៅដេកពេទ្យ ហើយចេញថ្លៃព្យាបាលអស់ ៨០០,០០០រៀល ។ ខ្ញុំប្តឹងទៅប្រធានភូមិដើម្បីទារអោយម្តាយក្មេកខ្ញុំសងថ្លៃព្យាបាលពេទ្យ ។ ម្តាយក្មេកខ្ញុំបដិសេធហើយគាត់និយាយថា: "ខ្ញុំមិនព្រមសងទេ ។ ទោះបីជាខ្ញុំត្រូវចូលគុកក៏ដោយខ្ញុំមិនខ្វល់ទេ" ។ រឿងនេះបានបញ្ជូនទៅប្រធានសង្កាត់បន្ទាប់មកទៅស្នងការ ប៉ុន្តែគ្មានអ្នកណាអាចដោះស្រាយបានទេ ព្រោះយាយមិនចង់ចុះចាញ់ ។ គឺនគរបាលដែលបានរៀបចំការសំរុះសំរួល ។ នគរបាលធ្វើការល្អ ។ គេបានជួយ ។

មានននគរបាល៥នាក់ ខ្ញុំ ប្ដីខ្ញុំ ម្ដាយក្មេក និងមិត្តភ័ក្រ្តគាត់ម្នាក់នៅក្នុងអង្គប្រជុំ។ គេបានសួរថាខ្ញុំចង់បានប៉ុន្មាន ខ្ញុំថា៨០០,០០០រៀលដើម្បីសងថ្លៃពេទ្យ។ គេសុំឱ្យយាយនិយាយ គាត់និយាយថា: "បើឯងលក់គោនិងស្រែដែលអញបានឱ្យឯងជាមរតក ឯងអាចសងថ្លៃពេទ្យបាន"។ នគរបាលនិយាយទៅគាត់ថា គេមិនអាចយកមរតកវិញបានទេ។ យាយនិយាយថា គាត់មិនចង់ឱ្យអ្វីទាំងអស់។ លោកស្នងការសួរយើងថា តើយើងចង់ឱ្យរឿងនោះបញ្ជូនទៅតុលាការឬយ៉ាងណា។ យើងបានយល់ព្រម។ យូរណាស់នៅតុលាការ យើងចាយប្រាក់អស់ជាច្រើន។ ពីរអាទិត្យក្រោយមកយើងបានត្រូវកោះហៅទៅតុលាការ។ យើងបានបង់ប្រាក់ឱ្យក្រឡាបញ្ជី៥០០០រៀល[១៤៦] ហើយក្រឡាបញ្ជីបានសន្យាថា នឹងធ្វើឱ្យរឿងឿនទៅមុខ។ ដោយសាររឿងនេះមិនទៅមុខសោះ ខ្ញុំបានទៅតុលាការមួយអាទិត្យម្ដងដើម្បីទៅតឿនក្រឡាបញ្ជី។ ក្នុងមួយលើក១ខ្ញុំឱ្យ៥០០០រៀល។ គេមិនបានទារអ្វីទេ ប៉ុន្តែបើឱ្យលុយគេអាចធ្វើឱ្យរឿងទៅមុខ។ ថ្លៃធ្វើដំណើរទៅតុលាការអស់ច្រើនណាស់។ គេត្រូវជិះម៉ូតូឌុប។ យាយត្រូវកោះហៅបីដង តែគាត់មិនទៅ។ បន្ទាប់មកខ្ញុំបានបោះបង់រឿងនោះចោល ព្រោះខ្ញុំគ្មានប្រាក់។ ខ្ញុំបានចេញថ្លៃពេទ្យ តុលាការអស់៥០,០០០រៀល និងថ្លៃធ្វើដំណើរ និងដ៏ទៃទៀត។ ខ្ញុំបានលក់ស្រូវប្រាំផ្លូន[១៤៧] និងគោមួយ (៦២០,០០០រៀល)។ ថែមលើនោះទៀត ខ្ញុំបានខ្ចីប្រាក់គេ១៥០,០០០រៀលដោយដាក់បញ្ចាំដីដែលមានតម្លៃ១លានរៀល។ ទីបញ្ចប់ ខ្ញុំនិយាយទៅយាយថា បើគាត់ព្រមឱ្យខ្ញុំ៣០,០០០ ឬ៤០,០០០រៀល ខ្ញុំព្រមបញ្ចប់រឿងទៅហើយ។ យាយនៅតែមិនចង់ឱ្យប្រាក់ខ្ញុំ។ គឺជារឿងកត្តិយស។

ពីរបីខែក្រោយមក យាយមានជម្លោះជាមួយប្ដីខ្ញុំ(កូនរបស់គាត់)។ កូនយើងកាន់កាំបិតដៃយាយទៅប៉ះកាំបិតហើយរបួស។ គាត់ប្ដឹង ហើយគាត់និយាយថា កូនរបស់គាត់សងសឹកគាត់ដើរទៅក្មេកចៅដើម្បីឱ្យចៅធ្វើឱ្យមុតគាត់។ គាត់ថាដូច្នេះដើម្បីលុបបំបាត់ការខ្មាស់អៀនពីរឿងមុន។ ឥឡូវនេះគាត់ទាមទារចំនួនទឹកប្រាក់ដដែលដូចកាលពីខ្ញុំទារគាត់ក្នុងរឿងពីមុន ប៉ុន្តែខ្ញុំមិនព្រម។

ខ្ញុំគិតថាគ្មានយុត្តិធម៌។ យុត្តិធម៌មានដោយសារលុយ។ ខ្ញុំចង់ឱ្យរឿងដោះស្រាយនៅថ្នាក់ភូមិច្រើនជាង។ គេមិនបាច់ធ្វើដំណើរ មិនបាច់ជួបមនុស្សដ៏ទៃ ហើយមិនបាច់ខាតលុយធ្វើដំណើរនិងតុលាការទេ។ នៅភូមិគ្មានអ្វីទេ។ ប៉ុន្តែប្រធានភូមិគ្មានអំណាចច្រើន។ គាត់ជាមនុស្សល្ងង់។

---

146 ប្រាក់ប្រដាប់ក្តី ដែលចែងក្នុងច្បាប់។

147 មួយផ្លូនស្មើនឹង ៤៨កណ្តាប់ស្រូវ

កាលណារឿងស្មុគ្រស្មាញ គាត់បញ្ជូនទៅប្រធានសង្កាត់។ នៅកន្លែងនេះភាគច្រើននៃការសំរុះសំរួលគេធ្វើនៅសង្កាត់។ ប្រធានភូមិជាមនុស្សគ្មានសមត្ថភាព។

គេគ្មានការគោរពចំពោះប្រធានសង្កាត់ទេ ប៉ុន្តែគេខ្លាចគាត់ ព្រោះគាត់នៅកន្លែងនោះពីយូរមកហើយ"។

(អ្នកស្រី ប៉ុក អាយុ២៨ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ភាគីមួយមិនចង់ចុះញ៉មទេ ហើយបញ្ហាតូចមួយជាមួយអ្នកជិតខាង ក្លាយទៅជាជម្លោះមួយដែលឡើងទៅដល់ស្រុក។

"គោអ្នកជិតខាងបានស៊ីស្រូវនៅក្នុងចំការខ្ញុំកាលពីឆ្នាំទៅ។ ខ្ញុំបាននិយាយទៅម្ចាស់គោ ហើយម្ចាស់គោបានសន្យានឹងខ្ញុំថា នឹងសងថ្លៃខូចខាត។ ខ្ញុំបានសញ្ជឹងគិតពីថ្លៃ ហើយបីអាទិត្យក្រោយមក ខ្ញុំបានប្រាប់ថាថ្លៃ៨០,០០០រៀល។ គាត់បានយល់ព្រម។ មួយអាទិត្យមកទៀតពេលខ្ញុំទៅយកលុយ គាត់ថាគ្មានលុយទេ។ ខ្ញុំនិយាយទៅគាត់ថា បើមិនឱ្យលុយទេនោះ យើងត្រូវទៅផ្ទះប្រធានភូមិ។ គាត់ថា បើខ្ញុំនិយាយរឿងហ្នឹងទៅប្រធានភូមិគាត់មិនឱ្យប្រាក់ទេ។ ខ្ញុំខឹងណាស់ ហើយនៅពេលចាកចេញពីផ្ទះគាត់ ខ្ញុំបានយកកង់គាត់ ហើយទៅផ្ទះប្រធានភូមិ។ ខ្ញុំនិយាយរឿងទាំងអស់ប្រាប់ប្រធានភូមិ។ ប្រធានភូមិបានសរសេរពាក្យបណ្តឹង ហើយខ្ញុំទុកកង់នោះនៅផ្ទះគាត់។ ពីរអាទិត្យក្រោយមក ប្រធានភូមិបានកោះហៅយើងទាំងពីរនាក់។ ប្រធានភូមិនិយាយថា ស្ត្រីនោះត្រូវឱ្យប្រាក់មកខ្ញុំ ហើយគាត់ថាខ្ញុំត្រូវឱ្យស្រូវដែលនៅសល់ក្នុងចំការទាំងអស់ទៅស្ត្រីនោះ។ យើងទាំងអស់គ្នាបានព្រមព្រៀងលើសំណើនេះ។ មួយអាទិត្យតមកទៀត អ្នកជិតខាងបានច្រូតកាត់ស្រូវក្នុងចំការទាំងអស់ ប៉ុន្តែមិនឱ្យប្រាក់មកខ្ញុំ។ គាត់ថាមិនឱ្យទេ។ ប្រធានភូមិបានបញ្ជូនរឿងនេះទៅសាលាសង្កាត់ ហើយប្រធានសង្កាត់ប្រាប់ឱ្យអ្នកជិតខាងសងប្រាក់មកខ្ញុំ។ ប្រធានភូមិបានបញ្ជូនកង់ទៅសង្កាត់។ នៅពេលសំរុះសំរួល អ្នកជិតខាងនោះបានព្យាយាមទារយកកង់មកវិញ ហើយគាត់ថាកង់នោះខូច។ ប្រធានសង្កាត់ប្រាប់កុំឱ្យនិយាយពីរឿងនោះ ហើយថា នៅទីនេះនិយាយពីរឿងគោស៊ីស្រូវ។ អ្នកជិតខាងខ្ញុំនិយាយថា : "ខ្ញុំមានស្មារតីយុត្តិធម៌ បើខ្ញុំនិយាយថាមិនឱ្យ ក្រោយមកខ្ញុំពិតជាមិនអាចឱ្យទេ។ ខ្ញុំកាន់ធម៌ព្រះពុទ្ធ ខ្ញុំមិនអាចកុហកបានទេ។ ខ្ញុំមិនអាចលេបពាក្យសំដីខ្ញុំវិញទេ"។ ប្រធានសង្កាត់នៅតែទទូច ហើយអ្នកជិតខាងខ្ញុំបានសុខចិត្តឱ្យប្រាក់ដើម្បីធ្វើឱ្យមានសាមគ្គីភាព ហើយឈប់ឈ្លោះគ្នា។ គាត់បានចុះហត្ថលេខាលើលិខិតសន្យា។ គាត់បានឱ្យប្រាក់៣០,០០០រៀល ហើយបានយកកង់គាត់ទៅវិញ។ ខ្ញុំបានយុត្តិធម៌ ព្រោះខ្ញុំបានទទួលប្រាក់។ ប្រធានភូមិសួរខ្ញុំថា តើខ្ញុំទទួលយល់ព្រមឬអត់។

ខ្ញុំប្រាប់គាត់ថាទទួល ព្រោះខ្ញុំចង់បានប្រាក់។ បើអ្នកជិតខាងមិនឱ្យប្រាក់ខ្ញុំ ខ្ញុំនឹងយកកង់។ កង់នោះថ្លៃ១៦០,០០០រៀល។ ប៉ុន្តែ ខ្ញុំបានប្រាក់ ខ្ញុំមិនជាសប្បាយចិត្តប៉ុន្មានទេព្រោះបានប្រាក់តិច ប៉ុន្តែខ្ញុំមិនចង់ឱ្យបាក់មុខ។ ដោយសារខ្ញុំបានប្រាក់ ប៉ុណ្ណោះក៏បានហើយ។ ចាប់តាំងពីរឿងនេះមក អ្នកជិតខាងនិងខ្ញុំឈប់និយាយរកគ្នាទៀតហើយ។ គាត់ក្មេង គាត់ល្ងង់"។

(អ្នកស្រី ប៉ាវ អាយុ ៥២ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ចាញ់ក្តី គឺបាក់មុខ និងបាត់ឋានៈចំពោះមុខអ្នកដទៃ។

"បើអ្នកណាម្នាក់មានជម្លោះដីធ្លីជាមួយអ្នកម្នាក់ទៀត គេនឹងត្រៀមខាតបង់ប្រាក់ជាជាងខាតបង់ឈ្នោះ។ អ្នកដែលបាត់បង់ឈ្នោះនឹងបាត់បង់នូវទំនុកចិត្ត និងការគោរពពីអ្នកផងទាំងពួង។ គេលែងចង់ធ្វើទំនាក់ទំនងជាមួយអ្នកណាដែលគ្មានសំណាង គ្មានកិត្តិយស។ គេអាចគិតថាអ្នកដែលចាញ់ ជាអ្នកមានឧបទ្រពចង្រៃនៅជាប់ខ្លួន ហើយគេមិនចង់នៅក្បែរទេ ដើម្បីកុំឱ្យឆ្លងវាសនាអាក្រក់មកលើគេ"។

(លោក សួយ អាយុ ៤៨ឆ្នាំ អ្នកស្រុកភ្នំពេញ)

ប្រធានភូមិម្នាក់នឹកស្រណោះដល់ប្រព័ន្ធចាស់ ដែលគាត់មានអំណាចលើមនុស្ស។ គាត់ស្តាយដែលសព្វថ្ងៃការស្វែងរកការសំរុះសំរួលមានតិចពេក ហើយដែលមនុស្សម្នាក់ៗចង់បញ្ចេញ និងចង់ឈ្នះដើម្បីកុំឱ្យបាក់មុខ។

"ឥឡូវនេះ កាលណាភាគីពីរមានជម្លោះនឹងគ្នា គេពិបាកនឹងស្រាយវិញណាស់។ ចាប់តាំងពីខ្មែរក្រហមចុះចូលមកមានការអប់រំសិទ្ធិមនុស្ស។ មនុស្សលែងស្តាប់ហើយ។ គេចូលចិត្តសិទ្ធិមនុស្សព្រោះគេអាចប្តឹងបាន។ ពីមុន មនុស្សស្តាប់យើង ហើយមិនប្រឆាំងនឹងយើងទេ។ គេមិនហ៊ានប្តឹងទេ។ ឥឡូវនេះគេហ៊ានប្រឆាំង និងឡើងទៅជួបអាជ្ញាធរថ្នាក់លើ។ យើងលែងហ៊ានគំរាម និងបង្ខំឱ្យគេនៅស្ងៀមទៀតហើយ។ សព្វថ្ងៃនេះ បើយើងគំរាមអ្នកណាម្នាក់ យើងខ្លាចមានការសងសឹក បើយើងថាអ្វីមួយដែលធ្វើឱ្យមនុស្សមិនសប្បាយចិត្ត។ យើងរស់នៅក្នុងភូមិជាមួយគ្នា ដូច្នេះវាពិបាកណាស់។ នគរបាល និងប្រធានឃុំរស់នៅឆ្ងាយ ដូច្នេះគាត់មិនសូវខ្លាចទេ។ គាត់អាចគំរាម និងស្តីបន្ទោសបាន។ នៅកន្លែងនេះក្នុងភូមិនេះ យើងស្គាល់គ្នា ហើយយើងមិនអាចគំរាមគេបានទេ។ ទីនេះយើងលែងមានអំណាចទៀតហើយ។ មនុស្សគិតថា គេស្មើភាពគ្នា ហើយគេទាំងអស់គ្នាមានសិទ្ធិដូចគ្នា។ គឺមិនដូចកាលពីសម័យរដ្ឋកម្ពុជាទេ។ កាលនោះយើងមានសិទ្ធិសំរេច ហើយមនុស្សស្តាប់។ កាលណាយើងនិយាយ ថាកុំឱ្យគេយករឿងឡើងទៅលើជាងភូមិ ហើយឱ្យនៅស្ងប់ស្ងៀម គេស្តាប់យើង។ ឥឡូវនេះគេលែងស្តាប់ហើយ។ បើមនុស្ស

មិនទទួលយកសំណើខ្ញុំទេនោះ ខ្ញុំចូលចិត្តធ្វើលិខិតមួយឱ្យគាត់ទៅថ្នាក់លើ ប៉ុន្តែរាល់តែលើក បញ្ហាបកត្រឡប់មកភូមិវិញ ព្រោះនៅថ្នាក់លើគេគ្មានធ្វើអ្វីសោះ។ បច្ចេកទេសធ្វើការសំរុះសំរួល គឺដូចតែគ្នានៅថ្នាក់សង្កាត់។ គេមិនអាចធ្វើលើសនេះទេ។ ជាមួយនគរបាលគឺផ្សេង ពីព្រោះ គេត្រូវបង់ប្រាក់ដើម្បីចុះបញ្ជីបណ្តឹង។ មនុស្សថាខ្ញុំកាន់ជើងអ្នកណាម្នាក់ ប៉ុន្តែមិនអញ្ចឹងទេ ខ្ញុំអព្យាក្រឹត្យ។ គេគ្មានទំនុកចិត្ត។ មនុស្សមិនចង់ធ្វើការសំរុះសំរួលទៀតទេ។ គេចង់ឈ្នះ។ អ្វីដែលសំខាន់បំផុតសំរាប់គេនោះគឺ ស្រោចស្រង់មុខមាត់ជាងបានចំណេញប្រាក់កាសទៅទៀត។ គេចង់រក្សាកិត្តិយស។ គេមិនចង់ទទួលស្គាល់កំហុសរបស់គេ ហើយនិយាយសុំទោសទេ។ ជាទម្លាប់នៅក្នុងការសំរុំសំរួល ខ្ញុំសុំឱ្យអ្នកធ្វើកំហុសទទួលស្គាល់កំហុសរបស់ខ្លួន ហើយនិយាយសុំទោស។ គេមិនចង់បាក់មុខទេ។ អ្នកដែលមានប្រាក់ចូលចិត្តទៅតុលាការ ហើយចាយលុយជាជាងកុំឱ្យបាក់មុខ។ មានករណីជម្លោះដីធ្លីមួយ។ មនុស្សពីរនាក់និយាយថា ម្នាក់ៗសុទ្ធតែជាម្ចាស់លើមួយដុំតូច។ ម្នាក់ៗនៃអ្នកទាំងពីរ គ្មានអ្នកណាព្រមចុះចាញ់ទេ។ គេទៅតុលាការ ហើយគេបានខាតបង់ប្រាក់កាសច្រើនជាងថ្លៃដីនោះទៅទៀត។ គេមិនចង់បាត់បង់កិត្តិយសទេ។
(លោក សម្បត្តិ អាយុ ៦១ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

<u>មិនគោរពដំណាក់ការជាន់ថ្នាក់</u>

តាមនិតិវិធីជាទម្លាប់ គឺអាជ្ញាធររដ្ឋបាលដែលទទួលបន្ទុកបញ្ជូនរឿងទៅថ្នាក់លើ បើការសំរុះសំរួលទទួលបរាជ័យនៅកំរិតគាត់ ហើយបើភាគីណាមួយចង់បន្តរឿង។ ទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញថាមាននិន្នាការ មិនសូវគោរពនិតិវិធីនេះ។ មនុស្សនឹងទៅដាក់ពាក្យបណ្តឹងខ្លួនឯងជាមួយអាជ្ញាធរថ្នាក់លើ ឬជាមួយតុលាការ ដោយមិនខ្វាចអាជ្ញាធរថ្នាក់ក្រោមអន់ចិត្តទេ។

ឧទាហរណ៏នៃការប្រជុំសំរុះសំរួលមួយនៅផ្ទះប្រធានភូមិ ស្រះស្រង់ខាងជើង ឃុំនគរធំ ស្រុកសៀមរៀប ខេត្តសៀមរាប។

ជឿង មកជាមួយប្តីគាត់ដើម្បីប្តឹងប្រធានភូមិ។ គាត់និយាយថា គោរបស់ ចូត ដែលជាអ្នកជិតខាងចូលក្នុងចំការគាត់ ហើយស៊ីត្រសក់អស់ជាច្រើន។ ចូត មកតាមការកោះហៅរបស់ប្រធានភូមិ។ ជឿង ខឹងហើយនិយាយខ្លាំងៗ។ ប្តីរបស់គាត់អង្គុយស្ងៀមក្បែរគាត់។ ជឿង និយាយថា គាត់ស្គាល់គោនោះជាគោរបស់ ចូត។ ចូត ប្រកែកហើយរក្សាទឹកមុខញញឹម។ ប្រធានភូមិនិយាយថា ពិបាកដោះស្រាយរឿងនេះដោយមិនបានឃើញការខូចខាត។ ជឿង និយាយចំអកឱ្យប្រធានភូមិថា៖ "ប្រធានភូមិគ្មានសមត្ថភាពធ្វើសេចក្តីសម្រេចនិងជួយអ្នកស្រុក។ គាត់ស្លូតពេក។ គាត់មិនយកចិត្តទុកដាក់នឹងយើងទេ។ គាត់ត្រូវតែម៉ឹងម៉ាត់ឡើង"។ ប្រធានភូមិតម្លើងសម្លេងបន្តិច ហើយប្រាប់ឱ្យនៅស្ងៀមដោយមុខនៅញញឹម៖

"យើងជាបងប្អូនគ្នា យើងមិនត្រូវឈ្លោះគ្នាទេ។ គេត្រូវនៅស្ងៀម។ ស្អែកយើងនឹងទៅវាស់ការខូចខាតនៅចំការត្រសក់"។ ជឿង និយាយច្រំដែលៗ។ គាត់ថា គាត់ច្បាស់ណាស់ថាវាជាគោអ្នកជិតខាង។ ចូត ប្រកែកដោយស្ងប់ស្ងាត់។ ប្តី ជឿង ព្យាយាមធ្វើឱ្យប្រពន្ធគាត់ស្ងប់ ដោយធ្វើដៃជាកាយវិការ ហើយពួកគេក៏ចេញទៅ។ ក្រោយពីពួកគេចាកចេញទៅ ប្រធានភូមិនិយាយថា មានរឿងចាស់រវាងគ្រួសារទាំងពីរ ហើយថា ជឿង បានសងប្រាក់ទៅចូត។ ថ្ងៃនេះគាត់ព្យាយាមយកលុយមកវិញ ហើយចង់ធ្វើរឿងតូចឱ្យក្លាយជារឿងធំដោយសារតែផ្លែត្រសក់ពីរបីដែលគោស៊ី។

កាលពីពីរខែមុន កូនគ្រួសារពីរនេះវាយតប់គ្នា ហើយជឿងបានជេរគ្រួសារចូត ដោយគ្រួសារចូតបានប្តឹងទារប្រាក់ ២៥០,០០០រៀល។ ក្រោយពីការសំរុះសំរួល ជឿងបានសង ៩០,០០០រៀល។ ថ្ងៃនេះ ជឿងប្តឹងបកវិញ។ គាត់មានគំនុំហើយខឹង ពីព្រោះគាត់ចាស់ឆ្ងាយជាងចូត ហើយនៅតែមិនអាចទប់ចូតមិនឱ្យប្តឹងគាត់ ដូច្នេះគាត់ក៏ជេរចូតទៅ។

ថ្ងៃស្អែក ប្រធានភូមិមកពីចំការត្រសក់វិញ។ "ខ្ញុំបានរកឃើញថាមានការខូចខាតចំការត្រសក់មែន ហើយខ្ញុំព្យាយាមសំរួលការសងទូទាត់ជាប្រាក់ ដែលជាទីពេញចិត្តអ្នកទាំងសងខាង។ ជឿងទារ ៣០,០០០រៀល ហើយចូតយល់ព្រមឱ្យ២០,០០០រៀល។ គ្មានភាគីណាមួយចង់ប្តូរសំណើរបស់ខ្លួនទេ។ ខ្ញុំប្រាប់ឱ្យគេសុខចិត្ត និងប្រាក់ ២៥០០០ រៀលទៅ តែគ្មានអ្នកណាព្រមសោះ"។

ដោយហេតុថា ជឿង មិនសប្បាយចិត្តនឹងលទ្ធផលការនាំសំរុះសំរួលនេះ គាត់ក៏ប្តឹងទៅប្រធានឃុំនៅល្ងាចនោះ ដោយមិនបាននិយាយជាមួយប្រធានភូមិមួយម៉ាត់។ ប្រធានភូមិអន់ចិត្តបន្តិច តែគាត់មិនថាអីទេ។

<u>ការសំរុះសំរួលធ្វើដោយនគរបាល</u>

វិធីធ្វើការសំរុះសំរួលក៏មានអនុវត្តនៅក្នុងប៉ុស្តិ៍នគរបាល ហើយនិងនៅស្នងការដ្ឋានដែរ កាលណាគេបញ្ជូនបណ្តឹងមកឱ្យគាត់។ និតិវិធីនៃការប្រជុំស្រដៀងគ្នានឹងនិតិវិធីនៅមូលដ្ឋាន។ ទោះជាយ៉ាងណាក្តី ភាសារបស់នគរបាលយោងច្រើនទៅច្បាប់ ហើយគាត់ពិចារណាច្រើនទៅលើផលវិបាកនៃបទល្មើស។

> "យើងទទួលករណីលែងលះ កាលណាមានអំពើហិង្សា។ សំណុំរឿងត្រូវបានបញ្ជូនមកដោយសាលាសង្កាត់។ បើជាករណីធ្ងន់ធ្ងរ ខ្ញុំមិនអាចធ្វើអ្វីបានធុំដុំទេ ខ្ញុំបំពេញសំណុំរឿងដោយហៅប្តីប្រពន្ធមក ហើយខ្ញុំធ្វើរបាយការណ៍មួយដើម្បីបញ្ជូនរឿងទៅតុលាការ។ ខ្ញុំកម្រធ្វើការសំរុះសំរួលណាស់ លើកលែងតែខ្ញុំស្គាល់គេ ឬអាណិតគេ។ ក្នុងករណីនេះ ខ្ញុំទូន្មានអ្នករំលោភ។ បើប្តីវាយប្រពន្ធហើយមានស្នាមរបួស គឺជារឿងព្រហ្មទណ្ឌ។ បើគ្មានរបួសស្នាមទេ គឺជារឿង

រដ្ឋប្បវេណី។ យើងទទួលបណ្ដឹងស្ដីពីមរតកដែរ។ ឧទាហរណ៍ មនុស្សម្នាក់រៀបការជាថ្មី ហើយក៏ស្លាប់។ ប្រពន្ធទីមួយនិងទីពីរវាយគ្នាដណ្ដើមកម្មសិទ្ធិដីធ្លី"។

(លោក មាស អាយុ ៤៥ឆ្នាំ ប្រធានការិយាល័យ រដ្ឋបាល ស្នងការដ្ឋានក្រុងកែប ខេត្តកំពត)

នេះជាទស្សនៈរបស់នគរបាលម្នាក់លើការអនុវត្តនីការសំរុះសំរួលនៅថ្នាក់មូលដ្ឋាន។

"ការសំរុះសំរួលនៅថ្នាក់ភូមិ និងឃុំជួយសំរួលការងារខ្ញុំ។ មានរឿងច្រើនណាស់ដែលដោះស្រាយគ្នាបានដោយមិត្តភាព។ ប៉ុន្ដែបញ្ហាគឺថា មានប្រធានភូមិដែលមិនចេះធ្វើការសំរុះសំរួល។ គាត់មិនចេះអាន ហើយគាត់មិនចេះច្បាប់។ ជួនកាលគាត់ចេះខាងខុស។ ជួនកាលគាត់ធ្វើការគាបសង្កត់លើជនរងគ្រោះ ហើយនិយាយថាគឺ អ្នកដែលធ្វើកំហុសដែលមានហេតុផល។ គាត់មានសមត្ថភាពទាបនឹងយល់រឿង គាត់ភ្លឺភ្លើហើយល្ងង់។ ពេលខ្លះទៀត បញ្ហាដោះស្រាយមិនបានដោយសារអាជ្ញាធរខ្លាច។ ពួកប្រធានភូមិខ្លាចមានការសងសឹក បើគាត់លំអៀងទៅភាគីមួយជាងភាគីមួយទៀត។ ជួនកាល នគរបាលក៏ខ្លាចដែរ ប៉ុន្ដែយើងអាចនិយាយជានិច្ចអាងទៅលើច្បាប់ ចំណែកឯប្រធានភូមិវិញគាត់មិនអាចលាក់ខ្លួននៅពីក្រោយមតិផ្ទាល់ខ្លួនរបស់គាត់បានទេ។ ទោះជាយ៉ាងណាក្ដី និយាយរួមស្ថានការណ៍បានប្រសើរហើយ គឺមិនសូវមានអាវុធ ហើយមិនសូវមានមនុស្សសម្លាប់គ្នា"។

(លោក ជ្រុំ អាយុ ៤២ឆ្នាំ ស្នងការដ្ឋានកែប ក្រុងកែប ខេត្តកំពត)

## ៨. រត់រកថ្នាក់លើ : រដ្ឋសភា នាយករដ្ឋមន្ត្រី ព្រះមហាក្សត្រ

កាលណាមធ្យោបាយទាំងអស់ត្រូវបានប្រើប្រាស់អស់ហើយ ដោយគ្មានបានដល់ដំណោះស្រាយសោះ ហើយភាគីជាអ្នកប្ដឹងចចេសទាមទារយុត្តិធម៌ ប្រតិកម្មតាមបែបបូរាណដែលត្រូវលើករឿងទៅអង្គការថ្នាក់លើនៅតែមាននៅឡើយ។ បើព្រះមហាក្សត្រមិនប្រទានយុត្តិធម៌ជាសាធារណៈដូចកាលសម័យសង្គមរាស្ត្រនិយមទេនោះ សព្វថ្ងៃនេះអ្នកស្រុកនៅតែនាំគ្នាមកទីក្រុងដើម្បីលាតត្រដាងការតវ៉ារបស់គេ។ គេបោះជុំរំច្រើនថ្ងៃ ឬថែមទាំងច្រើនអាទិត្យទៀតផងនៅចន្លោះព្រះបរមរាជវាំងនិងរដ្ឋសភា។ ក្នុងករណីភាគច្រើនបំផុត គឺជារឿងអ្នកស្រុកត្រូវគេដណ្ដើមដី។

នេះជាជម្លោះមួយរវាងអ្នកស្រុក និងយោធាត្រូវបានលើកមកតវ៉ានៅមុខរដ្ឋសភា និងក្រសួងការពារជាតិ:

"ដីមួយកន្លែងទំហំ ៨ ហិកតា ជារបស់៩គ្រួសារ។ ដីនោះស្ថិតនៅក្បែរដីយោធា។ នៅឆ្នាំ១៩៩១ យោធាបានយកដីនោះ។ នៅឆ្នាំ១៩៩៣ ការិយាល័យសិទ្ធិមនុស្សរបស់អ៊ុនតាក់បានប្រាប់ឱ្យយោធាប្រគល់ដីនោះឱ្យទៅអ្នកស្រុកវិញ។ គេបានធ្វើតាម។ នៅឆ្នាំ១៩៩៨ យោធាបានយកដីវិញ។ នៅឆ្នាំ១៩៩៩ ទាំង៩គ្រួសារទៅប្ដឹងប្រធានឃុំ។ ប្រធានភូមិចូលដៃជាមួយអ្នកដណ្ដើម

យកដី។ យោធាមិនបានឆ្លើយតបទៅនឹងការកោះហៅរបស់អាជ្ញាធរមូលដ្ឋានទេ។ អាជ្ញាធរមូលដ្ឋានខ្លាចយោធា ហើយមិនអាចធ្វើអ្វីបានធំដំទេ។ អ្នកភូមិមានក្រដាសស្នាមដីធ្លីដែលបញ្ជាក់តឹកតាងថា គេជាអ្នកកាន់កាប់ដីនោះ ពួកយោធាមិនមានក្រដាសស្នាមអ្វីទេ។ យោធាមិនចង់ឆ្លើយនឹងការកោះហៅរបស់ប្រធានឃុំទេ។ គឺជារឿងឋានានុក្រម ពួកយោធាយល់ថាខ្លួនគេខ្ពស់ជាងប្រធានឃុំ។ ពួកគេបានឆ្លើយនឹងការកោះហៅរបស់អភិបាលស្រុក ប៉ុន្តែអភិបាលស្រុកក៏គ្មានបានសំរេចអ្វីដែរ។ ពួកយោធាមិនចាត់ទុកអភិបាលស្រុកជាមនុស្សសំខាន់អ្វីទេ។ ដូច្នេះមនុស្សទៅប្តឹងនៅលីកាដូ ក្រសួងការពារជាតិ ហើយពួកគេ ផ្លាស់ទីកន្លែងទៅនៅមុខរដ្ឋសភានៅភ្នំពេញ។ អធិការក្រសួងការពារជាតិមកជួប ហើយបានធ្វើការអង្កេតដល់ទីកន្លែងនិងសិក្សាឯកសារ។ គេបានសំរេចឱ្យអ្នកភូមិឈ្នះ ហើយឱ្យយោធាប្រគល់ដីទៅឱ្យអ្នកភូមិវិញ"។

(លោក ដារេត អាយុ៣៤ឆ្នាំ ក្រុងកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

ជម្លោះរវាងអ្នកភូមិ និងប្រធានភូមិត្រូវបានលើកមកតវ៉ានៅមុខរដ្ឋសភា :

"មានជម្លោះមួយរវាងអ្នកភូមិនិងប្រធានភូមិ។ គេពិបាកនឹងរកឃើញដំណោះស្រាយមួយ។ ដីឡូតិ៍ក្បាល២០ម៉ែត្រ បណ្តោយ១០០ម៉ែត្រ ត្រូវបានចែកឱ្យប្រជាជនពីដើមទសវត្ស១៩៨០។ ឆ្នាំមុន ប្រធានភូមិបាននិយាយថាដីនោះជារបស់រដ្ឋ ហើយគាត់បានលក់ដីខ្លះទៅឱ្យក្រុមហ៊ុនឯកជន។ គាត់បានឱ្យប្រាក់ពាក់កណ្តាលទៅអភិបាលស្រុក និងអភិបាលខេត្ត។ បើអ្នកភូមិចង់ដាក់ពាក្យបណ្តឹង ស្ថានការណ៍នឹងត្រូវរាំងស្ទះ ពីព្រោះរឿងនោះត្រូវបានសំរួលគ្នាជាមួយអាជ្ញាធរមូលដ្ឋានដែលគេស្គាល់គ្នាអស់ទៅហើយ។ ដូច្នេះ អ្នកភូមិទៅភ្នំពេញនៅមុខរដ្ឋសភាដើម្បីតវ៉ារកយុត្តិធម៌"។

(លោក តាឡោះ អាយុ៥២ឆ្នាំ ក្រុងកំពត ខេត្តកំពត)

ជម្លោះមួយរវាងអ្នកភូមិថ្មីមួយ និងយោធា ត្រូវបានតវ៉ាជាមួយព្រះមហាក្សត្រ។

"តាហ៊ុយ មានដីមួយកន្លែងនៅជើងភ្នំកាលពីជំនាន់សីហនុ។ ក្រោយមកក៏មានសង្គ្រាម។ នៅឆ្នាំ១៩៩៤ ខ្មែរក្រហមបានចុះចូល ហើយគេបានឱ្យដីនៅជើងភ្នំទៅខ្មែរក្រហមទាំងនោះ។ ចៅ៧របស់តាហ៊ុយបានត្រឡប់មករកដីដូនតាវិញ ហើយចាប់ផ្តើមដាំដុះ។ អាជ្ញាធរថ្នាក់លើបានសំរេចថា តំបន់នេះជាតំបន់អភិវឌ្ឍន៍ជាអាទិភាព។ ដោយសារដីបានឡើងថ្លៃ មនុស្សសំខាន់ៗមកពីក្រៅចង់បានដីទាំងនោះ។ យោធាបានយកដីមួយចំណែកធំ រួមមានដីតាហ៊ុយ និងដីគ្រួសារដទៃផងដែរ។ ចៅ៧តាហ៊ុយមានរបងព័ទ្ធជុំវិញដី ហើយពួកយោធាបានដករបងចោល។ គ្រួសារតាហ៊ុយនិង៩គ្រួសារទៀតបានប្តឹងទៅតុលាការខេត្តកំពត ទៅក្រសួងមហាផ្ទៃ និងទៅព្រះ

មហាក្សត្រ។ រឿងនេះមិនបានឆ្លងសង្កាត់ទេ។ នៅត្រឹមក៏រិតយើង យើងខ្លាចយោធា។ គេមានអាវុធ។

រឿងនោះ ត្រូវបានបញ្ជូនទៅព្រះមហាក្សត្រ។ ដោយសារហេតុនោះ អភិបាលខេត្តបានសុំជួប ១០គ្រួសារនោះ និងពួកយោធា។ ក្នុងដី៥០ហិកតាដែលបានយកនោះ យោធាបានយល់ព្រមប្រគល់ដី៥ហិកតាឱ្យវិញ។ គ្រួសារទាំងនោះមិនសុខចិត្តទេ។ អភិបាលខេត្តនិយាយទៅគ្រួសារទាំងនោះថា :"បើអ្នកឯងមិនពេញចិត្តទេ អ្នកឯងអាចយកអាកាដណ្តើមដីនោះទៅវិញទៅ"។ ក្រោយមកទៀតយោធាបានប្រាប់យើងថា គេព្រមឱ្យដី២៥ហិកតាវិញ ប៉ុន្តែគ្រួសារទាំងអស់នៅតែមិនព្រម។ រឿងនេះបានឡើងរហូតដល់អគ្គសេនាធិការកងទ័ព។ នាយអគ្គសេនាធិការបានសុំឱ្យធ្វើការអង្កេតជាក់លាក់។ គេបានសុំលិខិតស្នាមចាស់ លិខិតស្នាមថ្មី។ ក្រោយពីការអង្កេតមក គេថាដីនោះជារបស់១០គ្រួសារមែន"។

(អ្នកស្រី យុន អាយុ៥៣ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ជម្លោះដីធ្លីមួយត្រូវបានតវ៉ានៅចំពោះមុខអង្គការថ្នាក់លើ។

"គេបានឱ្យដីយើង ក្បាល៣០ម៉ែត្រ ជំរៅ៥០០ម៉ែត្រ។ អាជ្ញាធរមូលដ្ឋានបានលក់ដីនោះមួយចំណែកទៅឱ្យវិស្វករម្នាក់មកពីភ្នំពេញដើម្បីធ្វើផ្លូវ។ យើងមិនសប្បាយចិត្តទេ។ ខ្ញុំបានជំទាស់។ ខ្ញុំហៅអ្នកធ្វើការខាងសិទ្ធិមនុស្សមកមើល ហើយខ្ញុំនិយាយថា ខ្ញុំនឹងទៅប្តឹងនៅភ្នំពេញនៅមុខរដ្ឋសភា និងប្តឹងទៅហ៊ុនសែនដែរ។ រឿងនោះក៏ស្ងប់ទៅ។ ពីដំបូង យើងយល់ព្រមឱ្យធ្វើផ្លូវ ប៉ុន្តែនៅពេលដែលគេថា យើងត្រូវឱ្យដីមួយកំណាត់ យើងក៏លែងសុខចិត្តទៅ។ យើងបានធ្វើលិខិតមួយដែលមានឈ្មោះ២១គ្រួសារ ដើម្បីប្តឹងទៅក្រុងកែប។ ប្រធានយោធាកែបបាននិយាយថា យើងត្រូវឱ្យដី។ មកទល់ពេលនេះ គេមិនបានធ្វើអ្វីទេ"។

(អ្នកស្រី សេង អាយុ៤៣ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

អ្នកស្រីបូលីនបានរំលងរបាំងបណ្តាញបក្ខពួកនៅការិយាល័យរដ្ឋបាលដើម្បីជួបអភិបាលក្រុងភ្នំពេញ។

"អ្នកជិតខាងឈ្មោះលោកតាន់ មានម៉ាស៊ីនអារឈើមួយ។ គាត់បានពង្រីករោងអារឈើ និងបានដាក់ម៉ាស៊ីនដែលបញ្ចេញសម្លេងរំខានខ្លាំង។ ដំបូលរោងអារឈើនៅជាប់ជញ្ជាំងផ្ទះខ្ញុំ ហើយចាំងពន្លឺមកខាងក្នុងផ្ទះ។ សម្លេងឮខ្ទរខ្ទារពេញមួយថ្ងៃៗ ហើយធូលីឈើហុយចូលពាសពេញ។ គឺរស់មិនបានទេ។ អ្នកជិតខាងទាំងអស់រអ៊ូ ហើយពិភាក្សាគ្នាអំពីរឿងនេះ។ ៦ខែកន្លងផុតទៅតែគ្មានអ្វីបានផ្លាស់ប្តូរទេ។ ខ្ញុំទៅជួបយាយជុំដែលជាម្តាយម្ចាស់រោងអារឈើ។ ខ្ញុំបាននិយាយប្រាប់គាត់ថា ខ្ញុំដេកមិនបានទេ ហើយថាម្តាយខ្ញុំភ្នែកស្រវាំងនឹងពន្លឺដែលជះពីដំបូលសង្កសីមក។

ខ្ញុំសុំឱ្យយាយរើម៉ាស៊ីនទៅខាងក្រោយផ្ទះគាត់ ដែលជាកន្លែងដែលម៉ាស៊ីននោះនៅពីមុន ហើយសុំឱ្យគាត់ប្តូរសង្កសីជាតង្គវិញ។ យាយថា រោងអារឈើនេះជារបររកស៊ីរបស់គេ ហើយថាបើខ្ញុំមិនពេញចិត្តទេនោះ មានតែទៅប្តឹងទៅ។ បន្ទាប់មក ប្តីខ្ញុំទៅជាក្រុមជាមួយលោកប៉ុនដែលជានគរបាល និងមន្ត្រី៣នាក់ដែលខ្ញុំស្គាល់ដើម្បីនិយាយជាមួយលោកតាន់។ នគរបាលជាមនុស្សម្នាក់មានឈ្មោះល្បីនៅក្នុងសង្កាត់។ គាត់ចូលនិវត្តន៍ហើយ ប៉ុន្តែគាត់មានអំណាច។ គាត់ជាម្ចាស់ដីដើមនៅកន្លែងរោងអារឈើនោះ។ មន្ត្រីទាំងនោះ ជាអតីតកូនចៅរបស់លោកប៉ុន។ នៅម្តុំនេះមានមនុស្សពីរដែលមានឥទ្ធិពលគឺលោកប៉ុន នៅតំបន់ខាងកើត ហើយនិងលោកណើ នៅតំបន់ខាងលិច។ លោកតាន់ បាននិយាយថា យើងជាដៃគូខាងក្រុមលោកប៉ុន។ លោកណើ ដែលរស់នៅខាងក្រោយបានធ្វើញត្តិរួចទៅហើយ ដើម្បីសុំឱ្យរើម៉ាស៊ីននៅខាងមុខផ្ទះគាត់ ពីព្រោះវាឮសម្លេងខ្លាំងពេកនៅខាងក្រោយ។ លោកតាន់ បាននិយាយថា ដោយសារបណ្តឹងនោះ គាត់មិនអាចរើម៉ាស៊ីនសាជាថ្មីទៅខាងក្រោយវិញទេ។ គាត់ថា យើងអាចប្តឹងបាន ហើយទោះជាយ៉ាងណាក្តីគាត់នៅតែឈ្នះ ព្រោះគាត់មានលុយច្រើនជាងយើង។ គាត់ថា ទោះយើងលក់ផ្ទះក៏នៅមិនគ្រប់ថ្លៃសោហ៊ុយប្តឹងផ្តល់ផង។ គាត់ថាទៀតថា សូម្បីតែយើងចាយវាយគ្មានសល់មួយសេន ហើយយើងជិតស្លាប់ទៀត ក៏នៅតែមិនឈ្នះដែរ។ កូនគាត់ជាមនុស្សថ្នាក់ឧកញ៉ាមានបង្អែកថ្នាក់លើនិងមានប្រាក់។

យើងក៏បានសំរេចធ្វើបណ្តឹងទៅអាជ្ញាធរផងដែរ។ រឿងនេះពិបាក ពីព្រោះលោកតាន់បានយកប្រាក់អូសទាញអ្នកទាំងនោះមកខាងគាត់អស់ទៅហើយ។ យើងបានប្តឹងទៅប្រធានក្រុម និងប្រធានសង្កាត់។ ប្រធានក្រុមនិយាយថា គាត់នឹងជួយយើង។ គាត់ទៅជួបលោកតាន់។ ពេលចេញមកវិញ មុខមាត់គាត់ប្រែប្រួល។ លោកតាន់ បានគំរាមសម្លាប់ បើគាត់មិននៅស្ងៀម។ ខ្ញុំបានដាក់ពាក្យបណ្តឹងទៅសង្កាត់។ បីខែក្រោយមក មិនមានចម្លើយ គ្មានការកោះហៅអ្វីទាំងអស់។ ខ្ញុំទៅបីដងតែគ្មានបានលទ្ធផល។ រាល់លើកដែលខ្ញុំចង់ជួបប្រធានសង្កាត់គេប្រាប់ខ្ញុំថាគាត់ជាប់រវល់ជានិច្ច។ តាមពិតលោកតាន់បានឱ្យប្រាក់ទៅគ្រប់មន្ត្រីទាំងអស់។ ខ្ញុំទៅខ័ណ្ឌ។ គេបានកោះហៅខ្ញុំជាប្រញាប់។ គេនិយាយចំអកដាក់ខ្ញុំ ហើយគេប្រាប់ថា យកល្អគួរដកបណ្តឹងទៅ។ គេបានឱ្យយោបល់ខ្ញុំថា ឱ្យទៅការិយាល័យបរិស្ថានខ័ណ្ឌ។ បើគេមិនចំអកឱ្យខ្ញុំទេនោះខ្ញុំគិតថា ខ្ញុំនឹងបោះបង់បណ្តឹងចោល។ ប្រធានការិយាល័យបរិស្ថានខ័ណ្ឌ។ បើគេមិនចំអកឱ្យខ្ញុំទេនោះ ខ្ញុំគិតថាខ្ញុំនឹងបោះបង់បណ្តឹងចោល។ ប្រធានការិយាល័យបរិស្ថានបានស្តាប់ពាក្យបណ្តឹងរបស់ខ្ញុំ។ គាត់ល្អណាស់។ គាត់មិនបានទារប្រាក់ពីខ្ញុំទេ ហើយបានកោះហៅខ្ញុំព្រមទាំងលោក

គាត់។ ការប្រជុំបានឆ្លងកាត់តាមរយៈសាលាសង្កាត់។ ខ្ញុំមក។ លោកគាត់មិនមកទេ។ គេមិនអាចធ្វើអ្វីបានទេ។

ថ្ងៃមួយខ្ញុំឈឺ ហើយខ្ញុំនៅផ្ទះតែឯងជាមួយប្ដីខ្ញុំ។ ប្ដីខ្ញុំបានសុំឱ្យកម្មករបន្ថយសម្លេងម៉ាស៊ីន តែលោកគាត់បែរជាតម្លើងសម្លេងម៉ាស៊ីនដោយចេតនា។ ខ្ញុំឆក់យកកាំភ្លើងខ្លីរបស់ប្ដីខ្ញុំ (ដែលជានគរបាលដែរ) ហើយឡើងទៅលើដំបូល និងយកកាំភ្លើងគោះដំបូល។ លោកគាត់ ថាខ្ញុំឆ្កួត។ ខ្ញុំឆ្លើយទៅវិញថា: "អាឆ្កែឯងជាសត្វអ្វី។ ហេតុម្ដេចបានជាឯងខឹងនឹងសម្លេងបន្តិចនេះ?"។ លោកគាត់ទៅការិយាល័យសង្កាត់ ហើយនគរបាលមកភ្លាម។ ខ្ញុំនិយាយចំអកឱ្យអ្នកទាំងនោះថា: "ពួកឯងធ្វើការឱ្យតែអ្នករងគ្រោះដែលជាអ្នកមានទេ"។ ពួកគេចង់ឱ្យខ្ញុំប្រគល់កាំភ្លើងខ្លី ប៉ុន្តែខ្ញុំនិយាយ: "នៅកន្លែងនេះ អាជ្ញាធរគិតតែប្រាក់ ហើយយកចិត្តទុកដាក់តែបញ្ហាកំប៉ិកកំប៉ុករបស់មនុស្សដែលគ្មានលុយ។ ចំណែកខ្ញុំ ខ្ញុំមានបញ្ហាធំមួយឆ្នាំមកហើយ តែគ្មានអ្នកណាមកទេ។ ផ្លាក"នគរបាល"នោះគ្មានបានការអីទេ។ ត្រូវទម្លាក់ផ្លាកនោះចោលទៅ។ ពួកកុហក ពួកឯងមិនជួយមនុស្សទេ"។

ខ្ញុំមកការិយាយបរិស្ថានម្ដងទៀត។ ប្រធានការិយាល័យបានឱ្យខ្ញុំជួបជាមួយអ្នកកាសែតរស្មីកម្ពុជាដើម្បីឱ្យសរសេរអត្ថបទពីករណីខ្ញុំ។ អ្នកកាសែតធ្វើការអង្កេត ហើយបានថតរូប។ អ្នកកាសែតគ្រាន់តែសុំឱ្យចេញថ្លៃជិះម៉ូតូឌុប។ អត្ថបទមួយចំនួនបានចុះផ្សាយតគ្នា មានទាំងនៅទំព័រមុខផង។ តាមគំនិតរបស់ប្រធានបរិស្ថាន ខ្ញុំបានសំរេចប្ដឹងទៅសាលាក្រុង និង ហ៊ុន សែន។ ខ្ញុំបានដាក់ពាក្យប្ដឹងជាច្រើនដងនៅសាលាក្រុង ប៉ុន្តែលោកគាត់ ស្គាល់មន្ត្រី ហើយបណ្ដឹងរបស់ខ្ញុំត្រូវគេបំភ្លេច។ ខ្ញុំបានសំរេចចិត្តចាំឃ្លាំនៅមុខសាលាក្រុង ហើយរង់ចាំរថយន្តរបស់អភិបាលក្រុងជាមួយប្អូនស្រីជីដូនមួយខ្ញុំ ពីព្រោះគេបានប្រាប់យើងថា យើងមិនអាចជួបអភិបាលក្រុងបានទេ។ យើងបានរង់ចាំអស់ពេលជាយូរ ហើយពេលមួយយើងអាចទៅជិតគាត់ក្នុងខណៈដែលគាត់ចេញឡាន។ យើងបានឱ្យពាក្យបណ្ដឹងទៅគាត់។ គាត់ដឹងរឿងតាមកាសែត រួចគាត់បានប្រាប់សហការីរបស់គាត់ឱ្យរុករកសំណុំរឿងដែលកប់ក្នុងការិយាល័យរបស់គាត់។ ខ្ញុំបានដកពាក្យបណ្ដឹងខ្ញុំពីការិយាល័យ ហ៊ុន សែន ដើម្បីចៀសវាងកុំឱ្យគាត់បន្ទោសអភិបាលក្រុង។ មួយអាទិត្យក្រោយមក ខ្ញុំបានទទួលលិខិតមួយពីអភិបាលក្រុងដែលសរសេរថា ឱ្យខ្ញុំជួបនឹងការិយាល័យបរិស្ថាន ហើយថារោងអារឈើនោះត្រូវបិទ។ ខ្ញុំបានហៅកាសែតដើម្បីបង្ហាញលិខិតនោះ។ លោកគាត់បានដកម៉ាស៊ីនយកទៅតាំងនៅខាងក្រោយ។ ឥឡូវនេះ គាត់មានទំនាស់ជាមួយលោកណើ

ម្តង។ នៅពេលដែលមនុស្សសុំឱ្យគាត់ពន្លត់ម៉ាស៊ីន គាត់រិតតែតម្លើងសម្លេងម៉ាស៊ីន។ គេចង់សម្លាប់គាត់ចោល។

យើងស្គាល់មនុស្សម្នាក់នៅតុលាការដែលអាចជួយយើងបាន ប៉ុន្តែ ដោយសារយើងគ្មានប្រាក់ យើងមិនចាំបាច់ត្រូវចំណាយប្រាក់លើមេធាវីទេ"។

(អ្នកស្រី បូលីន អាយុ៤២ឆ្នាំ សង្កាត់ បឹងកេងកង២ ខ័ណ្ឌចំការមន ភ្នំពេញ)

## ៩. ការធ្វើការសំរុះសំរួលនៅតុលាការ

ការទៅដាក់ពាក្យបណ្តឹងនៅតុលាការ គឺជាដំណើរការមួយដែលមនុស្សចំនួនតិចណាស់នៅស្រុកស្រែហ៊ានធ្វើ។ តុលាការមានឈ្មោះមិនល្អ ដែលអាជ្ញាធរមូលដ្ឋានបាននិយាយហើយនិយាយទៀតមិនឈប់ឈរ។ ហេតុផលសំខាន់ដែលគេមិនចូលចិត្តតុលាការ គឺការត្រូវចំណាយប្រាក់សំរាប់ធ្វើដំណើរ ថ្លៃស្នាក់នៅបើគេមកពីឆ្ងាយ ប្រាក់ក្រោមតុដែលត្រូវឱ្យមន្ត្រីតុលាការដើម្បីជួយជំរុញនីតិវិធីឱ្យលឿន ឬដើម្បីអូសចៅក្រមឱ្យលំអៀងមកខាងខ្លួន។

ហេតុផលទីពីរដែលគួរឱ្យខ្លាចស្ថិតនៅលើប្រការដែលថា នឹងមានសាលក្រម គឺមិនមានការផ្សះផ្សាគ្នាទេ។ មាន"អ្នកចាញ់ និងអ្នកឈ្នះ" ដូចដែលអាជ្ញាធរមូលដ្ឋានចូលចិត្តនិយាយហើយនិយាយទៀត។ នៅក្នុងសង្គមមួយដែលស្វែងរកការស្រុះស្រួលគ្នាជាធ្លុងមួយ ហើយដែលខ្លាចបាក់មុខ ការទៅតុលាការគឺជាការប្រថុយយ៉ាងសម្បើម ការអនុវត្តច្បាប់ និងការសំរេចចិត្តឱ្យអ្នកណាឈ្នះរវាងភាគីទាំងពីរនឹងដឹងបានលុះត្រាអស់ផ្លូវតវ៉ាជាចុងក្រោយ។

"ខ្ញុំបញ្ចុះបញ្ចូលកុំឱ្យមនុស្សទៅតុលាការ។ ខ្ញុំប្រាប់គេថា វានឹងខាតប្រាក់។ អ្នកខ្លះយល់ ហើយសុខចិត្តបោះបង់រឿងចោល អ្នកខ្លះចង់បន្ត។ អ្នកទាំងអស់នោះងាយគេអូសទាញបាន។ គេស្តាប់តែមិត្តមិនល្អដែលពន្យុះឱ្យទៅតុលាការ ព្រោះគេមានបង្អែកហើយគេនឹងបានកំរៃជើងសារពីដំណាក់កាលមួយទៅដំណាក់កាលមួយ។ ពួកគេនិយាយថា : "អ្នកឯងនឹងឈ្នះ ខ្ញុំស្គាល់គេនៅតុលាការ"។ ឥឡូវនេះ ពិបាកណាស់នៅប្រទេសខ្មែរគេមានច្បាប់។ ច្បាប់ល្អ តែអ្នកអនុវត្តអាក្រក់។ គ្មានអ្នកណាត្រួតមើលអ្នកដែលមានភារកិច្ចអនុវត្តច្បាប់ទេ។ គេចង់ធ្វើអ្វីតាមតែចិត្តគេចង់។ ប្រាក់ខែអ្នករាជការទាបណាស់។ ជាមួយនឹងប្រាក់ខែនេះ គេគ្មានប្រាក់ល្មមដើម្បីរស់ទេ។ តើត្រូវធ្វើដូចម្តេច?"។

(លោក មាស អាយុ៤៥ឆ្នាំ ប្រធានការិយាល័យរដ្ឋបាល ស្នងការដ្ឋានកែប ក្រុងកែប ខេត្តកំពត)

"មនុស្សតិចណាស់ដែលទៅតុលាការ។ អ្នកដែលទៅតុលាការ គឺទៅដើម្បីឈ្នះ។ គេមានបង្អែកនៅទីនោះ។ កាលណាគេមានគ្រួសារនៅថ្នាក់លើ គឺស្រួលណាស់។ មនុស្សមិនស្គាល់នីតិវិធីតុលាការទេ។ ពួកគេចាញ់ស្រាបនៅតុលាការ ហើយចង់ដោះស្រាយបញ្ហានៅមូលដ្ឋាន។ នៅតុលាការគេអាចខាតបង់ប្រាក់ច្រើន។ មនុស្សដែលគ្មានបង្អែកចូលចិត្តឱ្យរឿងរបស់គេដោះស្រាយនៅថ្នាក់ក្រោម"។

(លោកសម្បត្តិ អាយុ៥៥ឆ្នាំ ប្រធានសង្កាត់ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ភ្នំពេញ)

"កាលណាមនុស្សទៅតុលាការ គឺដើម្បីឈ្នះ។ គេចចេស។ គេចាយលុយដើម្បីឈ្នះ"។

(អ្នកស្រី សំបូរ អាយុ៥១ឆ្នាំ សង្កាត់ផ្សារថ្មី១ ខ័ណ្ឌដូនពេញ ភ្នំពេញ)

"មនុស្សនៅទីនេះមិនទៅតុលាការទេ ទោះបីមានបញ្ហាសំខាន់ៗ ឧទាហរណ៍ដូចជាពេលគេត្រូវបណ្តេញចេញជាដើម។ គេត្រូវចាយប្រាក់ជាច្រើនឱ្យតុលាការ ហើយមនុស្សនៅទីនេះជាអ្នកក្រីក្រ។ នៅតុលាការទោះឈ្នះក្តី ឬចាញ់ក្តី គេត្រូវខាតបង់ប្រាក់"។

(លោក សាម៉ាត អាយុ៤៥ឆ្នាំ ឃុំតាកែន ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

មនុស្សដែលបានជួបក្នុងពេលសម្ភាសន៍បាននិយាយថា តាមការយល់ដឹងរបស់គេ ច្បាប់គឺល្អ ប៉ុន្តែអ្នកដែលអនុវត្តច្បាប់ទេដែលមិនយុត្តិធម៌។

"ប្រទេសនីយមួយៗមានច្បាប់។ នៅទីនេះ យើងគ្មានទំនុកចិត្តលើច្បាប់ទេ។ អ្វីដែលសំខាន់នៅក្នុងច្បាប់នោះ គឺការអនុវត្ត។ នៅទីនេះ ការអនុវត្តច្បាប់មិនយុត្តិធម៌ទេ"។

(លោក សួយ អាយុ៧១ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

បើតាមច្បាប់ អ្នកដែលដាក់ពាក្យបណ្តឹងនៅតុលាការត្រូវឆ្លងកាត់ការព្យាយាមសំរុះសំរួលម្តង ឬច្រើនដងមុនមានសាលក្រម បើករណីនោះជារឿងរដ្ឋប្បវេណី។

ព្រះរាជអាជ្ញាម្នាក់ពន្យល់ពី<u>របៀបធ្វើការសំរុះសំរួលនៅតុលាការ :</u>

"គេនិយាយថា ផ្សះផ្សា។ នេះមានន័យថា គឺអ្វីដែលបែកបាក់ទៅហើយៗគេព្យាយាមជួសជុលឡើងវិញ។ គេព្យាយាមចងភ្ជាប់ប្តីប្រពន្ធឡើងវិញ។ សំរុះសំរួលមានន័យថា គេនឹងធ្វើអ្វីដែលពិបាកឱ្យទៅជាស្រួល។ ដោះស្រាយជាដំណោះស្រាយ។ នៅទីនេះ គេធ្វើការផ្សះផ្សា។ នៅប្រទេសកម្ពុជាបច្ចុប្បន្នគ្មានច្បាប់និយាយពីការធ្វើការសំរុះសំរួលទេ។ ក៏ប៉ុន្តែ មានសារាចរមួយដែលកំណត់ការសំរុះសំរួល។ មានពាក្យមួយដែលគេនិយាយថា បើគ្មានច្បាប់ទេ សាលក្រម

អាចផ្អែកលើប្រពៃណីបាន[១៤៨]។ លទ្ធផលនៃការផ្សះផ្សា អាស្រ័យលើទេពកោសល្យរបស់ចៅក្រមចេះរើកញែក ដោយរួមផ្សំគោលការណ៍ជាប្រពៃណីនៃសុជីវធម៌និងច្បាប់។ យើងបានរៀនសូត្រ និងយល់ដឹងពីក្រមចរិយាធម៌បូរាណពីឪពុកម្ដាយយើង។ យើងក៏អាស្រ័យលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើងដែរ។ ការផ្សះផ្សាជានីតិវិធីមួយដែលត្រូវតែធ្វើខានមិនបាន មុនមានការវិនិច្ឆ័យចេញសាលក្រម"។

(លោក សុវណ្ណារុំ ព្រះរាជអាជ្ញាតុលាការកំពត ខេត្តកំពត)

ក្រឡាបញ្ជីម្នាក់ពន្យល់ពីនិតិវិធីដែលត្រូវអនុវត្តន៍តាម និងពីតួនាទីជាអាជ្ញាកណ្ដាល ដែលបានប្រគល់ឱ្យចៅក្រម។ យោងតាមក្រឡាបញ្ជីនេះ គេចូលចិត្តការផ្សះផ្សាជាងការចេញសាលក្រម។

"ជាទូទៅ មនុស្សមកចុះបញ្ជីបណ្ដឹងជាមួយក្រឡាបញ្ជីនៅការិយាល័យរដ្ឋបាល។ ក្នុងរឿងរដ្ឋប្បវេណី មុននឹងសំរេចចេញសាលក្រម ចៅក្រមរួមប្រជុំភាគីទាំងពីរហើយធ្វើការផ្សះផ្សា។ ឧទាហរណ៍ ក្នុងករណីបំណុលមួយដែលមិនបានសង ចៅក្រមព្យាយាមស្វែងរកការស្រុះស្រួលគ្នាទៅវិញទៅមកមួយ។ ភាគី ក បានខ្ចីប្រាក់១០,០០០ រៀល ពីភាគី ខ។ ពេលនេះ ភាគី ខ ទាមទារប្រាក់ ១៥ ០០០រៀលដោយគិតទាំងចុងការផង។ ភាគី ក និយាយ ថា គាត់ក្រហើយអាចសងបានតែ ១០,០០០រៀល ប៉ុន្តែយឺតបន្តិច។ ចៅក្រមស្ដាប់សំណើរបស់ភាគី ក និងសំណើរបស់ភាគី ខ។ គាត់ផ្អែកលើភាពពិតជាក់ស្ដែង ហើយស្នើឱ្យភាគី ក ឱ្យប្រាក់ ៥ ០០០រៀលជាបន្ទាន់ រួច៥០០០រៀលទៀតត្រូវសងក្នុងដំណាក់កាលជាក់លាក់។ រួចហើយគាត់ស្នើឱ្យគេចុះថ្លៃចុងការ១០០០រៀល។

នេះគឺប្រសើរជាងសាលក្រម។ សាលក្រមនឹងធ្វើតាមច្បាប់ ហើយសាលក្រមនឹងគាបសង្កត់ភាគី ក ដែលមិនអាចសងគេ។ ចំពោះករណីលែងលះវិញ ចៅក្រមស្ដាប់ទស្សនៈទាំងពីរ បន្ទាប់មកគាត់បង្ហាញពីផលវិបាកនៃការលែងលះ។ ក្នុងករណីលែងលះ ចៅក្រមអាចធ្វើការប្រជុំផ្សះផ្សាជាច្រើនលើក។ ចៅក្រមអូសបន្លាយរឿង ដើម្បីឱ្យប្ដីប្រពន្ធសះជានឹងគ្នា។ ប៉ុន្តែ បើរឿងមិនអាចជួសជុលបានទេនោះ ឧទាហរណ៍ បើប្ដីចុះចោលប្រពន្ធ ការលែងលះនឹងប្រកាសឆាប់។ កាលណារឿងមកដល់បន្ទប់តុលាការ លែងមានផ្លូវជំនួស លែងមានការសំរួលគ្នាទៀតហើយ។ គេអនុវត្តច្បាប់ គេគ្មានជម្រើសទេ"។ (លោក សុវណ្ណរុំ ព្រះរាជអាជ្ញា តុលាការកំពត ខេត្តកំពត)

148 "សាលាជំរះក្ដីគ្រប់ជាន់ថ្នាក់ ត្រូវជំនុំជំរះដោយផ្អែកលើច្បាប់ជាធរមាន និងផ្អែកលើច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បាន អនុម័ត។ ក្នុងរឿងរដ្ឋប្បវេណី បើច្បាប់មិនចែងច្បាស់ ឬច្បាប់មិនបានចែង ត្រូវជំនុំជំរះដោយផ្អែកទៅតាមទំនៀមទម្លាប់ ប្រពៃណី វិចារណៈញ្ញាណ ឬ សមធម៌"។ ច្បាប់ស្ដីពីការចាត់ចែង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា-ជំពូក១ បទបញ្ញត្តិទូទៅមាត្រា៤។

រឿងដែលលើកមកចំពោះមុខតុលាការ និងការប្រជុំសំរុះសំរួល

"ក្នុងចំណោមករណីរដ្ឋប្បវេណី យើងទទួលបានជាពិសេសនូវបណ្តឹងអំពីជម្លោះដីធ្លី បំណុលមិនសងដែលមានកិច្ចសន្យាចុះហត្ថលេខា និងការសុំលែងលះ។ ពាក្យបណ្តឹងត្រូវបានដាក់នៅការិយាល័យក្រឡាបញ្ជី ហើយបញ្ជូនទៅប្រធានតុលាការ។ ប្រធានតុលាការជាអ្នកចាត់តាំងចៅក្រមម្នាក់ទទួលបន្ទុករឿងក្តីនោះ។ មុនពេលចេញសាលក្រម គេធ្វើការប្រជុំសំរុះសំរួលមួយ។ ជាពិសេសក្នុងករណីសុំលែងលះ។ គេឱ្យប្តីប្រពន្ធជួបទល់មុខគ្នា ហើយស្វះស្វែងបញ្ចុះបញ្ចូលឱ្យប្តីប្រពន្ធនោះនៅរួមរស់ជាមួយគ្នា។ បើតាមច្បាប់ ប្តីដែលវាយប្រពន្ធត្រូវចូលគុក។ គេចូលចិត្តដោះស្រាយបញ្ហាដោយមនោសញ្ចេតនាជាជាងអនុវត្តច្បាប់។ គេចង់ឱ្យប្រពន្ធនៅរស់ជាមួយប្តីវាប្រសើរជាង។ គេមិនត្រូវបំបែកបំបាក់គ្រួសារទេ។ គេធ្វើឱ្យប្តីខ្លាច។ ប៉ុន្តែ បើប្តីប្រើហឹង្សាពេកមានតែការលែងលះ ប៉ុណ្ណោះដែលអាចទៅរួច។ ជារួម បើករណីឡើងដល់តុលាការហើយប្តីប្រពន្ធពិតជាបានសំរេចច្បាស់លាស់ថានឹងលែងលះ ហើយគេពិបាកនឹងបញ្ចុះបញ្ចូលឱ្យគេនៅរួមរស់ជាមួយគ្នាណាស់។

គេធ្វើការសំរុះសំរួលដែរ កាលណាវាជាបញ្ហាដីធ្លីតូចតាច។ បញ្ហាធំៗដែលពាក់ព័ន្ធយោធាក្រុមហ៊ុនឬ មនុស្សសំខាន់ៗ អាចឡើងទៅថ្នាក់លើ រហូតដល់តុលាការកំពូល។ គេមិនអាចធ្វើការសំរុះសំរួលជាមួយពួកនេះបានទេ។ ពួកគេជាអ្នកមានអំណាចខ្លាំង ហើយមិនចង់មកពិភាក្សាជាមួយក៏រិតយើងនេះទេ។

ចំពោះបញ្ហាបំណុល គេព្យាយាមធ្វើឱ្យមានការសងជាដំណាក់ៗ។ ធ្វើដូច្នេះ វាប្រសើរជាងសាលក្រម។

ក្នុងករណីទាំងបី គេធ្វើលិខិតមួយដែលបង្ហាញពីលទ្ធផលនៃការសំរុះសំរួល។ បើភាគីពាក់ព័ន្ធមិនគោរការសន្យាក្នុងលិខិតនោះ កាលណារឿងឡើងដល់ដំណាក់ការជំនុំជំរះ លិខិតនោះនឹងត្រូវដាក់បន្ថែមទៅក្នុងសំណុំរឿង។

បើតាមខ្ញុំ ការសំរុះសំរួលនៅថ្នាក់មូលដ្ឋានជាការសំខាន់។ ភាគីស្វែងរកការសំរបសំរួលរួមមួយ។ វាស្រួលជាង។ ក៏រិតជីវភាពរបស់អ្នកស្រុកមិនខ្ពស់ទេ ហើយសោហ៊ុយធ្វើដំណើរមកតុលាការខ្ពស់។ គេថា គេត្រូវបង់ថ្លៃឱ្យតុលាការ តែនេះជាការធម្មតា ព្រោះច្បាប់ចែងដូច្នេះ។ សំរាប់សាលក្រមមួយ គេត្រូវបង់៧០០០រៀលបូកនឹង ១៥០០រៀលជាថ្លៃតែម។

(ក្រឡាបញ្ជីនាយក តុលាការកំពត ខេត្តកំពត)

ដើមចោទ

នៅទីក្រុង ការទៅដាក់ពាក្យប្តឹងនៅតុលាការ មានញឹកញាប់ជាងនៅស្រុកស្រែ។

"មនុស្សមិនសូវមកសាលាសង្កាត់ចំពោះរឿងរំលោភលើទំនុកចិត្ត និងបំណុលមិនសងទេ។ ឥឡូវនេះ មនុស្សមានការអប់រំច្រើន ហើយធ្វើក្រដាសស្នាមទទួលស្គាល់បំណុល។ គេមកទីនេះដើម្បីចុះហត្ថលេខាធ្វើជាសាក្សី។ កាលណាមានបញ្ហាមួយស្តីពីទឹកប្រាក់ចំនួនច្រើន គេទៅតុលាការ។ ករណីបំណុលមិនសងមានតិចទៅៗ ដែលឆ្លងកាត់តាមយើង។ ពីមុន មានមួយរឿងក្នុងរយៈពេលពីរ ឬបីខែ។ ឥឡូវនេះ មានរឿងមួយក្នុង៦ខែ។

ក្នុងករណីការមិនចុះសំរុងប្តីប្រពន្ធ ប្តីប្រពន្ធមកទីនេះធ្វើការសំរុះសំរួល ប៉ុន្តែបើអ្នកណាមួយ ឬទាំងពីរនាក់ចង់លែងលះ គេទៅតុលាការ។ ជួនកាល តុលាការបញ្ជូនរឿងត្រឡប់មកឱ្យយើងវិញ ហើយសុំឱ្យយើងធ្វើការសំរុះសំរួល។

(អ្នកស្រី ប៉ាន់ អាយុ៤៦ ឆ្នាំ ប្រធានសង្កាត់ សង្កាត់ផ្សារកណ្តាល២ ខ័ណ្ឌដូនពេញ ភ្នំពេញ)

"ភាគច្រើន នៃករណីបំណុលមិនសងបានទៅតុលាការ។ ប៉ុន្តែ តុលាការទាមទារក្រដាសស្នាម។ បើគ្មានក្រដាសស្នាមទទួលស្គាល់បំណុលទេនោះ ដើមបណ្តឹងមកសាលាសង្កាត់។ គឺពិបាកដោះស្រាយណាស់ ជាពិសេសកាលណាអ្នកម្ខាងទៀតរស់នៅសង្កាត់ផ្សេង"។

(លោកសារ៉ា អាយុ៤៣ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់ផ្សារកណ្តាល១ ខ័ណ្ឌដូនពេញ ភ្នំពេញ)

ដើម្បីជំនួសតុលាការក្នុងរឿងទំនាស់ដីធ្លី គណៈកម្មាធិការដោះស្រាយជម្លោះត្រូវបានបង្កើតឡើងនៅតាមខេត្ត។ រយៈពេលវេលាចាប់តាំងពីការបង្កើតគណៈកម្មាធិការនេះ មកទល់ពេលនេះមិនទាន់គ្រប់គ្រាន់នៅឡើយ ដើម្បីវាយតម្លៃតួនាទីនៃគណៈកម្មាធិការនេះ។

"មនុស្សមិនចង់ប្តឹងទៅតុលាការទេ។ គេមិនសូវមានប្រាក់កាសប៉ុន្មានដើម្បីចាយវាយនៅតុលាការ។ ចំពោះបញ្ហាដីធ្លី គេអាចទៅរកគណៈកម្មាធិការដោះស្រាយជម្លោះដីធ្លីនៅថ្នាក់ខេត្ត។ តុលាការត្រូវកកស្ទះដោយពាក្យបណ្តឹងអំពីទំនាស់ដីធ្លី ហើយគ្មានពេលច្រើនដើម្បីដោះស្រាយគ្រប់រឿងឱ្យបានត្រឹមត្រូវទេ។ គណៈកម្មាធិការ ស្នើឱ្យមានការដោះស្រាយដោយអាជ្ញាកណ្តាលរវាងភាគី ដើម្បីជួយដោះស្រាយបញ្ហា"។

(លោក ស៊ីថូ អាយុ ៣៣ឆ្នាំ អ្នកស៊ើបអង្កេត អង្គការមនុស្សធម៌មួយ ក្រុងកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

**តួនាទីនៃអភិធម្មជាតិនៅតុលាការ**

ដូចដែលយើងបានពិពណ៌នាខាងមុនមក វប្បធម៌បូរាណជ្រាបចូលយ៉ាងជ្រៅក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា។ ដូច្នេះ តួនាទីនៃអង្គភាពអភិធម្មជាតិ ឬគេហៅថាវត្ថុសក្ដិសិទ្ធិដូចជាអ្នកតាជាដើម ត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌនីតិវិធីតុលាការ។

តុលាការនីមួយៗ មានតាំងយ៉ាងហោចអ្នកតាមួយអង្គ។ ក្នុងពេលមានបណ្ដឹង ភាគីមួយអាចទាមទារឱ្យភាគីម្ខាងទៀតធ្វើសម្បថ នៅចំពោះមុខអ្នកតា។ ពិធីនេះត្រូវបានកត់ត្រាដោយក្រឡាបញ្ជី។

**ធ្វើសម្បថនៅចំពោះរូបអ្នកតា ៖**

> "ក្នុងករណីទំនាស់ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ បើមនុស្សម្នាក់និយាយថាខ្លួនស្លូតត្រង់ ហើយគេមិនជឿ មនុស្សនោះអាចទៅស្បថអំពីសុទ្ធចិត្តរបស់គេនៅមុខអ្នកតាស្ថិតនៅមុខវាំង គឺព្រះអង្គដងកើ។ អ្នកដែលស្បថ និយាយថា បើគេបានយកប្រាក់មែន អពមង្គលនឹងវាយកំទេចខ្លួនគេនិងគ្រួសារ"។
>
> (លោក ផុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

> "សាក្សីទៅធ្វើសម្បថមុខអ្នកតា។ គេភ័យខ្លាចអ្នកតាកាច់បើគេកុហក"
>
> (លោកសុវណ្ណរុំ ព្រះរាជអាជ្ញា តុលាការកំពត)

> "គេអាចសុំឱ្យមនុស្សស្បថនៅមុខយើង ថាគេនិយាយតែការពិត។ គេខ្លាចយើង ដូច្នេះ ជារឿយៗគេចាញ់សម្បថ។ វាដូចជានៅមុខអ្នកតាតុលាការដែរ មនុស្សស្បថថា និយាយតែការពិត បើពុំនោះទេ គ្រោះចង្រៃនឹងធ្លាក់មកលើគេ"។
>
> (លោក មាស អាយុ ៤៥ឆ្នាំ ប្រធានការិយាល័យរដ្ឋបាល ស្នងការដ្ឋានកែប ក្រុងកែប ខេត្តកំពត)

ថ្មីៗនេះទៀត ក្នុងពេលមានការទាស់ទែងគ្នាមួយដែលធ្វើឱ្យបុគ្គលនយោបាយធំៗពីរនាក់ប្រឈមមុខដាក់គ្នា គូទំនាស់ម្នាក់បានសុំឱ្យគូទំនាស់ម្នាក់ទៀតមកស្បថនៅមុខព្រះអង្គដងកើ។

**ធ្វើអំពើដើម្បីសងសឹកនឹងរឿងក្ដីមួយដែលចាញ់។** ទោះបីជាមិនសូវសំខាន់ដូចកាលពីអតីតក្ដី ការខ្លាចគ្រូធ្មប់ធ្វើអំពើនៅតែមាននៅឡើយ។

ជាមធ្យោបាយចុងក្រោយ គេអាចខាបខ្មោចបិសាចដើម្បីមកជួយសង្គ្រោះរឿងពិបាកៗ ឬក៏ដើម្បីមកជួយសងសឹក។

"ប្ដីរបស់សារុនបានខ្ចីមាសពីរតម្លឹង[149] ពីម្ចាស់បំណុលស្រូវម្នាក់ដើម្បីទិញម៉ាស៊ីនភ្លើងថ្មីមួយ (ដើម្បីបញ្ជេះយកឈ្នួលភ្លើងក្នុងភូមិ)។ គំរោងការគាត់មិនដើរ ព្រោះមនុស្សតភ្លើងគាត់មិនបង់ថ្លៃឱ្យគាត់ ហើយគាត់ត្រូវចំណាយលើការជួសជុលលើម៉ាស៊ីននោះទៀតផង។ ប្ដីសារុនលែងមានប្រាក់ទិញប្រេង ហើយគាត់ក៏បញ្ឈប់គំរោងការ។ គាត់គ្មានប្រាក់សងទាំងបំណុលទាំងចុងការ។ ម្ចាស់បំណុលស្រូវទៅប្ដឹងតុលាការ ប៉ុន្តែចៅក្រមនិយាយទៅកាន់ម្ចាស់បំណុលថាគាត់មិនអាចដោះស្រាយរឿងក្ដីនេះបានទេ ព្រោះម្ចាស់បំណុលមិនបានចុះហត្ថលេខាលើក្រដាសស្នាមជាមួយប្ដីសារុន។ ការព្រមព្រៀងត្រូវបានធ្វើដោយមាត់ទទេ។ ម្ចាស់បំណុលខឹងណាស់។ គេបានឃើញថា សារុនធ្លាក់ខ្លួនស្គមស្គាំង។ គាត់មានជម្ងឺមួយ ហើយចាប់តាំងពីពេលនោះមកគាត់ត្រូវស្លាប់មួយចំហៀងខ្លួន។ កូនគាត់ក៏មានបញ្ហាជាមួយនគរបាលដែរ។ មនុស្សនិយាយថាម្ចាស់បំណុលស្រូវបានទៅជួបគ្រូម្នាក់ដែលមានឯកទេសខាងមន្តអាគម ហើយគាត់បានធ្វើការសម្បថ។ តាំងពីពេលនោះមក អពមង្គលបានចូលមកគ្រួសារសារុន"។

(អ្នកស្រី គី ឃុំនគរធំ ស្រុកសៀមរៀប ខេត្តសៀមរៀប)

## ១០. ការនាំបញ្ចូលគោលការណ៍ថ្មី : សិទ្ធិមនុស្ស

ដោយបានការបង្ហាត់បង្រៀនដោយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ឬក្នុងស្រុក គោលទស្សនៈនៃសិទ្ធិមនុស្សចាប់ផ្ដើមរីកសាយក្នុងភូមិ ជាពិសេសដោយសារវិទ្យុ។ ការបណ្ដុះបណ្ដាលក៏ត្រូវបានរៀបចំធ្វើនៅក្នុងបណ្ដាប្រជាជនដែលគួរយកចិត្តទុកដាក់ដែរ (ដូចជាយោធា នគរបាល មន្ត្រីរាជការ)។ គោលការណ៍សិទ្ធិមនុស្សត្រូវបានពិភាក្សា ជួនកាលនៅក្នុងការសន្ទនាប្រចាំថ្ងៃក្នុងកម្លុងពេលមានទំនាស់ និងការស្វែងរកដំណោះស្រាយទំនាស់ទាំងនោះ។ មនុស្សមិនមែនសុទ្ធតែបានយល់ត្រឹមត្រូវជានិច្ចនូវគោលការណ៍ទាំងនោះទេ គឺការអនុវត្តនៅតែស្រពិចស្រពិលច្រើន។ ក្នុងសង្គមបែបបូរាណនេះដែលបានជួបប្រទះនឹងសង្គ្រាមយូរឆ្នាំ គោលការណ៍សិទ្ធិមនុស្សឮខ្ទរខ្ទារហាក់ដូចជាការសន្យាឱ្យសេរីភាព និងសិទ្ធិបុគ្គល។ ការនេះមិនមែនប្រព្រឹត្តទៅដោយមិនបានបង្កើតឱ្យមានការយល់ច្រឡំខ្លះទេ។

<u>ការយល់ដឹងពីសិទ្ធិមនុស្ស</u>

" សិទ្ធិមនុស្សគឺល្អ ប៉ុន្តែអត្ថបទខុសគ្នាឆ្ងាយពីការពិត។ គេនិយាយពីអ្វីដែលល្អ ប៉ុន្តែនៅក្នុងការពិតជាក់ស្ដែង គេមិនដឹងថាត្រូវអនុវត្តអត្ថបទនោះយ៉ាងម៉េច"។

(លោក រឿន អាយុ ៣៨ឆ្នាំ អតីតខ្មែរក្រហម សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

[149] មួយតម្លឹងស្មើនឹងប្រាក់ប្រមាណ ៣៥០ដុល្លាអាមេរិក

" ឥឡូវនេះ គេមានសិទ្ធិ។ គេមានសិទ្ធិនិយាយ មានសិទ្ធិមិនស្តាប់អ្នកដទៃ និងមានសិទ្ធិបង្កើតគំនិតរបស់គេ។ គេមានសិទ្ធិទទួលបានសមភាព។ ស្ត្រីក៏មានសិទ្ធិដែរ។ ស្ត្រីមានសិទ្ធិ និងធ្វើអ្វីៗ។ ខ្ញុំមិនដឹងទេ។ គេមានសិទ្ធិ"។

(លោក តារា អាយុ ៣៥ឆ្នាំ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

"យើងបានចូលវគ្គសិក្សាសិទ្ធិមនុស្ស។ ខ្ញុំយល់មិនច្បាស់ទេ តែខ្ញុំចាំបានថាមនុស្សយើងទាំងអស់គ្នាស្មើភាពគ្នា ទោះបីជាយើងមានរូបកាយខុសគ្នាក៏ដោយ"។

(លោក សុកុល អាយុ ៥៧ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"មានមនុស្សដែលទាមទារសិទ្ធិហួសហេតុពេក។ គេទាមទារសិទ្ធិដោយមិនយល់ថា សិទ្ធិនោះមានន័យដូចម្តេច"។

(លោក មាស អាយុ៤៥ឆ្នាំ ប្រធានការិយាល័យរដ្ឋបាល ស្នងការដ្ឋានកែប ក្រុងកែប ខេត្តកំពត)

"មនុស្សនិយាយតែពីសិទ្ធិខ្លួនឯង។ គេមិននិយាយអ្វីៗផ្សេងៗទៀតទេ។ គឺល្អ ប៉ុន្តែគេយល់ថាគេមានសិទ្ធិ ដើម្បីធ្វើអ្វីបានទាំងអស់។ សិទ្ធិគឺល្អ ប៉ុន្តែត្រូវមានព្រំដែន។ បើគ្មានព្រំដែនគឺអនាធិបតេយ្យទាំងស្រុង"។

(លោក ស្វាយ អាយុ ៥៧ឆ្នាំ ឃុំត្នោត ស្រុកកំពុងរោទិ៍ ខេត្តកំពង់ស្ពឺ)

"កាលណាគេមានសិទ្ធិ ប៉ុន្តែគ្មានច្បាប់ នោះគឺអនាធិបតេយ្យ។ បើគេមានច្បាប់ ប៉ុន្តែមិនគោរពសិទ្ធិ គឺជាអំណាចផ្តាច់ការ។ គេត្រូវការផ្តល់ការអប់រំល្អដល់ប្រជាជនដើម្បីឱ្យគាត់យល់ពីសិទ្ធិ ច្បាប់ និងព្រំដែននៃសិទ្ធិរបស់គាត់។ ច្បាប់ទំនើបគឺល្អ។ ចំពោះសិទ្ធិមនុស្សគេដឹងថា បុរស និងស្ត្រីគឺសត្វលោកដែលស្មើភាពគ្នា។ បើមានបញ្ហាប្តីប្រពន្ធ គឺវាមានទាំងកំហុសរបស់ប្តីទាំងកំហុសប្រពន្ធដូចគ្នា ច្បាប់បូរាណមិនល្អទេ ពីព្រោះច្បាប់នោះនិយាយថា បុរសនិងស្ត្រីត្រូវចាត់ទុកឱ្យខុសពីគ្នា។ ច្បាប់សម័យថ្មីគោរពមនុស្សទាំងអស់"។

(លោក ឡុង អាយុ ៥៣ឆ្នាំ អនុប្រធានឃុំ-អតីតខ្មែរក្រហម ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត)

"ចាស់ៗ ចូលចិត្តការផ្សាយសិទ្ធិមនុស្សតាមវិទ្យុណាស់។ ប៉ុន្តែក្មេងចូលចិត្តការផ្សាយចំរៀង"។

(ក្រុមស្ត្រី ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

នៅក្នុងតំបន់អតីតខ្មែរក្រហម ការបណ្តុះបណ្តាលសិទ្ធិមនុស្សត្រូវបានធ្វើ ក្រោយពីការចុះចាញ់។ មនុស្សនៅក្នុងព្រៃរៀនពីគោលគំនិតថ្មី ហើយព្យាយាមបញ្ចូលគោលគំនិតទាំងនោះទៅតាមការចេះដឹងផ្ទាល់ខ្លួនរបស់គេ។

"ទ្រឹស្ដីសិទ្ធិមនុស្សគឺល្អ ប៉ុន្ដែវាអាស្រ័យលើអ្នកអនុវត្ដ។ ច្បាប់ព្រៃ(របស់ខ្មែរក្រហម) មិនបានពាក់កណ្ដាលច្បាប់បច្ចុប្បន្នផង។ ក្នុងសម័យខ្មែរក្រហម ច្បាប់បើនិយាយឱ្យងាយទៅគឺលើមាត់មនុស្ស ហើយមិនលំអិត ដូចច្បាប់ថ្មីទេ។ វាស្រដៀងគ្នាខ្លះនឹងច្បាប់យើងពីមុន(ខ្មែរក្រហម) កាលណាគេនិយាយថាមនុស្សស្មើភាពគ្នា ហើយស្ដ្រីស្មើនឹងបុរស។ យើងក៏និយាយដូច្នេះដែរ ប៉ុន្ដែប្រើពាក្យផ្សេង។ នៅទីនេះគឺខុសគ្នា គឺគេមានពេញលេញ។ ខ្ញុំបានចូលរួមការបណ្ដុះបណ្ដាលជាច្រើនអំពីរដ្ឋធម្មនុញ្ញ និងសិទ្ធិមនុស្ស។ ខ្ញុំបានសញ្ញាប័ត្រ និងសៀវភៅ។ គឺ សំខាន់ណាស់។ វាជាក់លាក់ជាង។ ខ្ញុំអានហើយខ្ញុំចេះចាំឃ្លារត់មាត់។

(លោក នួន អាយុ ៤២ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្ដិសុខ-អតីតខ្មែរក្រហម-សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

<u>សិទ្ធិស្ដ្រី</u> រំលើងប្រពៃណី និងទម្លាប់របស់របស់បុរស។

"ឥឡូវនេះ ប្រុសៗខ្លាចសិទ្ធិនារី។ ស្ដ្រីនិយាយថា គេមានសិទ្ធិ។ គឺថ្មី។ ស្ដ្រីចង់ធ្វើអ្វីគ្រប់យ៉ាងទោះជាអ្វីក៏ដោយ។ យើងលែងអាចនិយាយអ្វីបានទៀតហើយ ព្រោះស្ដ្រីគេនិយាយថាគេមានសិទ្ធិ គេមានហេតុផលនឹងនិយាយ ព្រោះសិទ្ធិរបស់ស្ដ្រី។ ការនិយាយនោះគឺល្អហើយ ប៉ុន្ដែមិនមែននិយាយដោយមិនគិតពីអ្វីសោះនោះទេ"។

(លោក រិន អាយុ៤៣ឆ្នាំ ឃុំពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

"តាមប្រពៃណី បើគេមានប្រពន្ធមិនល្អ គេមិនមានដំណោះស្រាយផ្សេងក្រៅពីវាយនោះទេ។ ជាមួយនឹងគោលការណ៍សិទ្ធិស្ដ្រី របៀបនេះចាប់ផ្ដើមផ្លាស់ប្ដូរបន្ដិចហើយ។ មនុស្សបានរៀនចេះដឹងថា វាយប្រពន្ធគឺមានទោស"។

(លោក ស៊ីថូ បុគ្គលិកអង្គការសិទ្ធិមនុស្ស កំពង់ស្ពឺ ខេត្តកំពង់ស្ពឺ)

<u>ការអនុវត្តការសំរុះសំរួល និងគោលការណ៍សិទ្ធិមនុស្ស</u>

អាជ្ញាធរមូលដ្ឋានដែលត្រូវបានបណ្ដុះបណ្ដាលអំពីសិទ្ធិមនុស្ស ព្យាយាមអនុវត្តសិទ្ធិមនុស្សនៅពេលធ្វើការសំរុះសំរួល។

"ខ្ញុំអប់រំអ្នកភូមិ។ ខ្ញុំប្រាប់គេថា ស្ដ្រីមានសិទ្ធិដូចបុរសដែរ។ បើស្ដ្រីមានបញ្ហា គាត់អាចប្ដឹងដូចបុរសដែរ។ ខ្ញុំបានរៀនវគ្គបណ្ដុះបណ្ដាលសិទ្ធិមនុស្ស រៀបចំដោយអាដហុក។ ចាប់តាំងពីបានរៀនមក ខ្ញុំដឹងខ្លួនថា ខ្ញុំមានហេតុផលច្រើនជាងពីមុន ដើម្បីធ្វើការសំរុះសំរួល។ យើងគិតដល់មនោសច្ចេតនាមនុស្សច្រើនជាង។ យើងសុំឱ្យមនុស្សនិយាយ ព្រោះគេមានសិទ្ធិបញ្ចេញមតិ។ ដូច្នេះ នៅក្នុងច្បាប់ គេថាកាលណាមានរឿងសស្មាម គឺតុលាការជាអ្នកសំរេច។ ប៉ុន្ដែ ជាមួយនឹង

ការសំរុះសំរួលនិងសិទ្ធិមនុស្ស គឺប្រសើរជាង យើងគិតដល់ចរិតលក្ខណៈរបស់មនុស្ស និងប្រវត្តិរឿងរបស់គាត់។ បើអ្នកណាម្នាក់ចូលគុក គឺវាមិនអាចដោះស្រាយអ្វីបានទេ។ ល្អគឺគេត្រូវសង នេះគឺជាការជាក់ស្តែង។ នៅក្នុងការធ្វើឱ្យរបួសស្នាម គេត្រូវនិយាយសំរួលគ្នាថា តើអ្នករំលោភទទួលស្គាល់កំហុសរបស់ខ្លួន ហើយសុខចិត្តសងដល់ជនរងគ្រោះឬទេ បើជនរងគ្រោះតវ៉ា"។

(លោក ពុធ អាយុ៣០ឆ្នាំ នគរបាល សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

"ដើម្បីបំបាត់អំពើហិង្សា គេត្រូវផ្អែកលើការអនុវត្តសិទ្ធិមនុស្សក្នុងលក្ខខ័ណ្ឌដែលប្តីប្រពន្ធយល់។ ក្រោយពីបានស្តាប់ ប្តីនិងប្រពន្ធត្រូវតែកែខ្លួន។ ក្នុងករណីប្រពន្ធត្រូវវាយបែកក្បាលហូរឈាម ហើយដេកពេទ្យពីរអាទិត្យ នោះគឺរឿងព្រហ្មទណ្ឌ។ ត្រូវមានទោស។ គឺប្រធានប៉ុស្តនគរបាលដែលត្រូវទទួលបបន្ទុករឿងនេះ។ លើកទីមួយ គេអប់រំមនុស្សពីរទៅបីថ្ងៃ។ លើកទីពីរ បើមិនរាងចាលទេនោះ គេដាក់ទណ្ឌកម្ម។ គេឱ្យមនុស្សនោះដាំស្ល រែកទឹក ជួសជុលរបង ជីកដី រំលាយដំបូក។ គេធ្វើដូច្នេះ ដើម្បីឱ្យមនុស្សចៀសវាងផឹកស្រា និងដើម្បីមានការអប់រំ។ គេធ្វើតាមច្បាប់។ គេមិនអាចធ្វើឱ្យមនុស្សខ្លាចទៀតទេ គេធ្វើឱ្យគាត់យល់ពីច្បាប់ និងសិទ្ធិមនុស្ស។ គេនិយាយថា បើតាមច្បាប់មនុស្សដែលធ្វើអាក្រក់នឹងចូលគុក។ គេនិយាយពីច្បាប់ក្នុងលិខិតសន្យា។ គេសរសេរថា "ខ្ញុំធានាចំពោះមុខច្បាប់ថា លែងធ្វើដូច្នេះទៀតហើយ។ បើខ្ញុំនៅតែធ្វើ ខ្ញុំត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន"។

មនុស្សគិតថា វាយប្រពន្ធជាការធម្មតា។ គេទទួលថាអញ្ចឹងនៅក្នុងប្រពៃណី បើប្រពន្ធមិនល្អ។ ចាប់តាំងពីគេទទួលការបណ្តុះបណ្តាលសិទ្ធិមនុស្សមក មនុស្សយល់បន្តិចម្តងៗថា អំពើហិង្សាគឺអាក្រក់។

ពីមុន យើងមានតែច្បាប់ព្រៃ។ ឥឡូវនេះ យើងមានច្បាប់ពិតប្រាកដ។ ពីមុន យើងរៀនតែវាយយួន និងរំដោះប្រទេស"។

(លោក ហួន អាយុ៥៣ឆ្នាំ អនុប្រធានឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត)

<u>អង្គការសិទ្ធិមនុស្ស</u> ធ្វើការនៅតាមមូលដ្ឋាន។ គេបង្ហាញទិសដៅ និងជូនយោបល់ដល់អ្នកមករកគេចំពោះករណីទាក់ទងនឹងសិទ្ធិមនុស្ស។

"កាលណាមនុស្សមកប្តឹងដល់កន្លែងយើង គឺមានន័យថា គេប្រើអស់មធ្យោបាយដោះស្រាយបញ្ហាតាមរបៀបបូរាណ។ ប្រធានភូមិជាមនុស្សប្រកាន់បក្សពួក ហើយជួនកាលគាត់មិនហ៊ានធ្វើអន្តរាគម និងនិយាយថា អ្នកណាឈ្នះអ្នកណាចាញ់ទេ ព្រោះខ្លាចមានសត្រូវ។ វិធីសំរុះសំរួល

អាចមានប្រយោជន៍ក្នុងករណីមានបញ្ហាតូចតាច។ ប្រធានភូមិអាចធ្វើឱ្យមនុស្សស្ងប់កំហឹង ហើយរកឃើញការស្រុះស្រួលគ្នាទៅវិញទៅមករវាងភាគីទាំងពីរ បើមនុស្សមានការអត់អោនគ្នា។ ប៉ុន្តែ បើមនុស្សមិនចង់បន្ទន់ឥរិយាបថទេនោះ អាជ្ញាធរមូលដ្ឋានមិនអាចធ្វើអ្វីបានទេ។ មនុស្សដែលមករកយើង មិនមែនមកពីឆ្ងាយទេ។ អ្នកដែលរស់នៅក្នុងភូមិឆ្ងាយៗ គោរពប្រធានភូមិរបស់គេ"។

(លោក វុទ្ធី អាយុ៣២ឆ្នាំ អ្នកស៊ើបអង្កេត អង្គការសិទ្ធិមនុស្សមួយ ខេត្តកំពត)

"ថ្ងៃណាមួយ បើខ្ញុំមានបញ្ហាធ្ងន់ ខ្ញុំទៅរកសិទ្ធិមនុស្ស។ គេធ្វើការអប់រំនៅក្នុងភូមិ។ ពួកគេនិយាយថា មនុស្សទាំងអស់ស្មើភាពគ្នា។ មនុស្សមានអំណាចមិនអាចទប់ទល់នឹងសិទ្ធិមនុស្សបានទេ។ អ្នកមានប្រាក់ និងអ្នកគ្មានប្រាក់ស្មើគ្នានៅចំពោះមុខច្បាប់។ ប្រធានភូមិមានសមត្ថភាពដោះស្រាយតែរឿងតូចៗទេ។ ចំពោះរឿងធំៗ គាត់មិនចេះទេ ហើយគាត់បញ្ជូនទៅថ្នាក់លើ"។

(អ្នកស្រី បូផានី អាយុ៥០ឆ្នាំ ភូមិស្វាយ ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង)

នៅទីនេះ ប្រពៃណីចាក់គ្រឹះមាំទាំណាស់ ទោះបីមានរូបភាពខាងក្រៅនិងការប្រកាន់ភាសាសិទ្ធិមនុស្សក្តី។

"ខ្ញុំជាប្រធានសមាគមស្ត្រីចាប់តាំងពីឆ្នាំ២០០០។ គោលដៅគឺជួយស្ត្រីក្នុងភូមិ។ ខ្ញុំជួយស្ត្រីឱ្យគេចេះ និយាយអំពីបញ្ហារបស់គេ ហើយខ្ញុំជំរុញឱ្យគេនិយាយទៅកាន់ប្រធានភូមិ កុំឱ្យមានការខ្មាស់អៀន។ បញ្ហាមានញឹកញាប់ជាងគេ គឺកាលណាបុរសវាយប្រពន្ធគាត់ ហើយកាលណាបុរសទៅដេកជាមួយស្រីពេស្យា និងប្រពន្ធផ្សេងទៀត។ វានាំឱ្យប្រពន្ធប្រច័ណ្ឌ។ ប្រពន្ធទាំងអស់ក៏ឈ្លោះគ្នា។

ក្នុងដប់គ្រួសារ មានពីរឬបីគ្រួសារ ដែលមនុស្សប្រុសវាយប្រពន្ធ។ ក្នុងករណីនេះ ខ្ញុំនិយាយទៅប្រពន្ធថា : "គឺជាប្តីឯង ឯងមិនត្រូវស្តីបន្ទោសប្តីពេកទេ។ បើមានបញ្ហា ឯងត្រូវនិយាយឱ្យទន់ភ្លន់"។ ខ្ញុំប្រាប់ឱ្យប្រពន្ធឱ្យអត់ទ្រាំ កុំជេរប្រមាថគ្រួសារប្តីគាត់ ហើយកុំនិយាយពាក្យអាក្រក់ពីប្តីឱ្យអ្នកដទៃស្តាប់។ បើគ្រួសារអ្នកដទៃដឹងរឿង ប្តីអាចខឹង ហើយវាយប្រពន្ធថែមទៀត។ ក្នុងករណីដែលប្រពន្ធត្រូវប្តីវាយខ្លាំងរហូតដល់ហូរឈាម ខ្ញុំសុំឱ្យប្រធានភូមិធ្វើអន្តរាគម ដើម្បីឱ្យគាត់ជួយទូន្មានប្តី។ នោះហើយគឺសិទ្ធិបញ្ចេញគំនិតរបស់ស្ត្រី គឺកាលណាប្រធានភូមិបានដឹងរឿង។ ជួនកាលប្រពន្ធរងរបួស គាត់លាក់មិនហ៊ាននិយាយទេ ព្រោះខ្លាចអ្នកជិតខាងសើចចំអកឱ្យប្តីប្រពន្ធ។ ជួនកាល ប្រពន្ធរបួស គាត់លាក់មិនឱ្យគេដឹង មិនហ៊ាននិយាយដោយខ្លាចអ្នកជិតខាងសើចចំអកឱ្យ។ ខ្ញុំលើកទឹកចិត្តឱ្យស្ត្រីនិយាយ។ បើស្ត្រីត្រូវប្តីវាយតែបន្តិចបន្តួច

ខ្ញុំប្រាប់ឱ្យគាត់អត់ទ្រាំទៅ។ នៅជាមួយប្តី គ្រាន់បើជាងនៅតែឯង។ បើគាត់ត្រូវប្តីវាយបន្តិច គឺអាចទទួលយកបាន គេអាចអត់ទ្រាំបាន។ បើប្តីវាយញឹកញាប់ និងខ្លាំង គេអាចសុំឱ្យប្រធានភូមិជំរុញប្តីនោះចុះហត្ថលេខា លើលិខិតសន្យាមួយ ដើម្បីឱ្យគាត់ប្តេជ្ញាថា ឈប់ធ្វើដូច្នេះទៀតហើយ។ នៅទីនេះ គេមិនអនុញ្ញាតឱ្យលែងលះទេ។ មានតែតុលាការទេ ដែលអាចអនុញ្ញាតឱ្យលែងលះ។ តាមការពិត អ្វីៗវាអាស្រ័យលើចរិតលក្ខណៈរបស់ប្តី។ បើប្តីភ្លីភ្លើហើយអាក្រក់ គាត់មិនប្តូរទេ ហើយប្រពន្ធត្រូវមានទុក្ខចេះតែអត់ទ្រាំទៅ"។

(អ្នកស្រីសែន អាយុ៤៧ឆ្នាំ ប្រធានសមាគមស្ត្រី អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

# III. ការបង្ការ

អ្វីដែលគេហៅថា"ការបង្ការជម្លោះ" នៅក្នុងក្របខ័ណ្ឌសង្គមនៃភូមិខ្មែរមួយនោះ គឺទាក់ទងនឹងចង្កោមអំណាចបង្គាប់របស់សង្គម ដែលតម្រូវឱ្យប្រកាន់យកការប្រព្រឹត្តដែលមិននាំឱ្យខូចរបៀបរបប ដែលគេអនុវត្តនិងមិនលាតត្រដាងបញ្ហា។ យើងមិនបានរកឃើញស្រង់យកការយោងទៅកំរងក្បួនខ្នាត និងក្រមដែលមានគ្រឹះមាំទាំទេ ប៉ុន្តែផ្ទុយទៅវិញ គឺការយោងដល់គោលការណ៍ទូទៅ ដែលគេនិយាយថាជាមរតកនៃ"ប្រពៃណី"។ ក្នុងកម្លុងពេលសន្ទនា យើងបានរកឃើញជាពិសេសនូវអំណាចបង្គាប់បញ្ជាឱ្យនៅស្ងៀម កុំឱ្យបង្កើតបញ្ហានិងកុំធ្វើឱ្យបញ្ហារីកធំ ឱ្យដាក់ខ្លួននៅឆ្ងាយពីអ្នកដទៃ កុំឱ្យគេធ្វើកត់សំគាល់ខ្លួន។ល។ តាមប្រពៃណី ការធ្វើឱ្យខូចរបៀបរបបសង្គមត្រូវរងទណ្ឌកម្មក្នុងរបៀបជាអភិធម្មជាតិ(ខ្មោច អារក្ស អ្នកតា) ឬជាកម្មផល(ជាតិក្រោយអាចកើតជាសត្វមានកម្ម)ឬជាខ្ញុំបរិវារអ្នកដែលខ្លាំងជាង។ ការខ្លាចមិនហ៊ានធ្វើឱ្យខូចរបៀបរបបតែងតែមានជានិច្ច។ មានតែមនុស្សដែលមានអំណាចទេ ដែលមានសិទ្ធិប្តូររបៀបរបប។ ក្នុងករណីនេះ អ្នកតូចជាងយល់តាមសេចក្តីសំរេចរបស់មេ ហើយធ្វើតាមការប្រព្រឹត្តរបស់មេ[១៥០]។ ដូច្នេះ នៅក្នុងវប្បធម៌ដែលផ្អែកលើការស្រុះស្រួលមូលមតិគ្នានេះ ការចាត់ទុកមនុស្សមួយចំនួនជាអ្នកគ្មានសារសំខាន់ ជាអ្នកមិនបានការ ឬជាអ្នកនៅក្រៅសង្គម គឺជាការគ្រោះថ្នាក់ណាស់។ គេរងគ្រោះថ្នាក់នឹងត្រូវបានទាត់ចោលពីសង្គម ឬនៅក្នុងករណីធ្ងន់ធ្ងរទៅទៀត រហូតដល់ត្រូវបានបំបាត់រូបទៀតផង។

នៅក្នុងភូមិដាច់ស្រយ៉ាល ដែលអំណាចរបស់មនុស្សចាស់លើមនុស្សក្មេង ត្រូវបានគេឃើញមានជាទូទៅ មេនៅមូលដ្ឋាន ទុកអ្នកភូមិឱ្យស្ថិតនៅសភាពភ័យខ្លាច ដែលអ្នកក្រៅឃើញថាជាការគោរពទៅវិញ ហើយតាមរយៈនេះ គេបង្ការកុំឱ្យមានជម្លោះនៅមូលដ្ឋាន។ នៅក្នុងតំបន់ទីក្រុង និងជុំវិញទីក្រុង ការគាបសង្កត់របស់អាជ្ញាធរមូលដ្ឋានលើអ្នកភូមិមានស្រាលជាង។

នៅពេលធ្វើការដោះស្រាយទំនាស់ គ្មានអ្វីនៅក្នុងក្បួនច្បាប់ដែលអនុញ្ញាតឱ្យអាជ្ញាធរមូលដ្ឋានធ្វើទណ្ឌកម្មលើអ្នកល្មើសលើរបៀបរបបទេ។ ផ្ទុយទៅវិញ អាជ្ញាធរប្រើមធ្យោបាយគាបសង្កត់ក្រៅផ្លូវការ។

<u>បង្ការការប្រព្រឹត្តមិនរាងចាល : លិខិតសន្យា</u>

ក្រៅពីពាក្យសំដីសុំឱ្យនៅស្ងៀម អាជ្ញាធរមូលដ្ឋានក៏ប្រាប់ឱ្យផ្អែកលើហត្ថលេខាលើលិខិតសន្យាដែលគេសរសេរពាក្យទាំងអស់ដែលបានព្រមព្រៀងគ្នានៅលើលិខិតនោះ ព្រមទាំងគំរាមដាក់ទណ្ឌកម្មដើម្បីឱ្យខ្លាច។

---

[150] រឿងគឺមានភស្តុតាងជាក់ស្តែងនៅពេលខ្មែរក្រហមចុះចូល គេបាននាំកូនចៅរបស់គេទៅជាមួយ ហើយស្លៀកពាក់ឯកសណ្ឋានកងទ័ព រដ្ឋាភិបាល។

លិខិតសន្យាគឺឯកសារមួយដែលសរសេរដោយអ្នកសំរុះសំរួល(អាជ្ញាធររដ្ឋបាល) ហើយដែលកំណត់សេចក្តីផ្សេងៗនៃបញ្ហា នៃការព្រមព្រៀងគ្នារវាងភាគី។ ដូច្នេះ នៅក្នុងករណីទំនាស់ប្តីប្រពន្ធ គេអាចអានថា ភាគី ក សន្យាថាឈប់ផឹកឈប់វាយប្រពន្ធ ហើយភាគីខសន្យាថានឹងឈប់ដើរលេងយូរទៀតហើយ។ ការសន្យាថានឹងឈប់ធ្វើអ្វីមួយតទៅទៀតនោះ គឺជួនកាលកើតចេញពីការគំរាមដាក់ទណ្ឌកម្ម បើសិនជាមិនរាងចាល។

ភាគីម្នាក់ៗ អ្នកសំរុះសំរួល ព្រមទាំងសាក្សីផងទទួលស្គាល់សេចក្តីទាំងអស់នៅក្នុងឯកសារនោះ ដោយម្នាក់ៗផ្តិតមេដៃរបស់ខ្លួនលើលិខិតនោះ។

បើសិនជាឯកសារ គ្មានតម្លៃគតិយុត្តជាផ្លូវការ(តម្លៃតាមផ្លូវច្បាប់)ទេនោះ រឿងដែលគេសរសេរសេចក្តីផ្សេងៗនៃការព្រមព្រៀងគ្នានៅចំពោះមុខអាជ្ញាធររដ្ឋបាលម្នាក់ ក៏ជាវិធីមួយសំរាប់បន្លាច ដែលជំរុញកុំឱ្យអ្នកប្រព្រឹត្តធ្វើអ្វីសាឡើងវិញ។

បើការធ្វើដូច្នេះនៅតែគ្មានប្រសិទ្ធិភាព មានន័យថា មធ្យោបាយចាត់ការនៅក្នុងដៃប្រធានភូមិគឺមានតិចតួចណាស់។ គាត់អាចបញ្ជូនរឿងទៅប្រធានឃុំ ដែលមានមធ្យោបាយគាបសង្កត់ច្រើនជាង។ ការពិតប្រធានឃុំធ្វើការទាក់ទងដោយផ្ទាល់ជាមួយភ្នាក់ងារនគរបាល ដែលអាចចាត់ការចាប់ខ្លួន(ករណីព្រហ្មទណ្ឌ)។

នគរបាលដែលមានទីតាំងនៅការិយាល័យស្រុកទទួលពាក្យបណ្តឹង។ គេធ្វើការសំរុះសំរួល ហើយតាក់តែងលិខិតសន្យា ដើម្បីបង្ការការប្រព្រឹត្តច្រំដែលឡើងវិញ។

> "បុរសម្នាក់បានសុំប្រាក់ពីប្រពន្ធដើម្បីទិញបារីជក់[១៥១]។ ប្រពន្ធប្រកែក។ ប្តីខឹង ហើយយកដំបងវាយប្រពន្ធ។ ប្រពន្ធមកប្តឹងនៅប៉ុស្តិ៍នគរបាល។ គេបានចាប់ប្តី ហើយឃុំទុក៦ម៉ោង។ នៅពេលគាត់ស្វាងពីស្រវឹង ខ្ញុំបានសួរគាត់ថា ហេតុអ្វីបានជាគាត់វាយប្រពន្ធ។ គាត់បានឆ្លើយថា: "គឺដោយសារស្រា ខ្ញុំមិនអាចត្រួតខ្លួនខ្ញុំបាន"។ គេបានឱ្យគាត់ចុះហត្ថលេខាលើលិខិតសន្យាមួយឱ្យឈប់ធ្វើដូច្នេះទៀតដោយសរសេរថា បើគាត់ធ្វើទៀត គាត់នឹងទៅតុលាការ ហើយតុលាការនឹងផ្តន្ទាទោសដាក់គុក។
>
> (លោក សួរ អាយុ៣០ឆ្នាំ នគរបាល សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

[151] ដូចនៅក្នុងប្រទេសអាស៊ីដទៃទៀតដែរ តាមប្រពៃណី ប្រពន្ធជាអ្នកកាន់លុយ។

## ការគំរាមកំហែង និងទណ្ឌកម្មសំរាប់អ្នកមិនរាងចាល

ចំពោះអ្នកដែលមិនរាងចាល អាជ្ញាធរមូលដ្ឋានមានសេរីភាពនឹងអនុវត្ត។ នៅកន្លែងខ្លះ យើងបានរកឃើញថាមានការឃាត់ខ្លួនយូរ ឱ្យនៅអង្គុយលើកៅអីក្នុងការិយាល័យនគរបាល ដែលគេមើលឃើញទាំងអស់គ្នា ឬបង្ខំឱ្យធ្វើការ។

"គេអាចធ្វើការគាបសង្កត់លើមនុស្សដោយធ្វើការស្តីបន្ទោស ដោយប្រាប់ថាអ្នកនោះនឹងចូលគុក បើគេមិនគោរពច្បាប់។ ដូច្នេះ គេអាចទុកឱ្យគាត់នៅអង្គុយលើកៅអីយូរនៅក្នុងការិយាល័យ ឱ្យមនុស្សទាំងអស់ឃើញ ដើម្បីធ្វើឱ្យគាត់ខ្មាស់គេ"។

(លោក ផុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

"កាលណាមនុស្សប្រុសវាយប្រពន្ធញឹកញាប់ពេក គេបញ្ជូនគាត់ទៅការិយាល័យស្រុក ហើយនគរបាលឃុំ គាត់ទុកក្នុងបន្ទប់មួយក្នុងរយៈពេល៤៨ម៉ោង។ គឺដូចជាគាត់ជាប់គុកដែរ"។

(លោក វណ្ណាត អាយុ៥២ឆ្នាំ ប្រធានភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកំពត)

"កាលណាមានញ្ហានៅជិតខ្លួន គេមករកខ្ញុំ។ ប្រធានភូមិរស់នៅឆ្ងាយពេក។ មនុស្សប្តឹងដោយផ្ទាល់តែម្តង កាលណាខ្ញុំធ្វើល្បាតនៅជិតផ្ទះគាត់។ យើងធ្វើការល្បាត ដើម្បីការពារពួកចោរដែលមានចំនួនច្រើននៅទីនេះ។ ជាពិសេស មានបណ្តឹងពីរឿងអំពើហិង្សាក្នុងគ្រួសារ។ ប្រុសៗផឹក បន្ទាប់មកក៏ចូលផ្ទះ ហើយវាយប្រពន្ធ។ ប្រពន្ធទៅជួបនគរបាលតែក្នុងករណីហិង្សាធ្ងន់ធ្ងរដែលប្រើកាំបិត ឬពូថៅប៉ុណ្ណោះ។ ក្នុងករណីទាំងនេះ គេចាប់មនុស្សប្រុស ហើយឃុំ១២ម៉ោងនៅប៉ុស្ត បន្ទាប់មកគេធ្វើការសំរុះសំរួល។ គេសាកសួរទាំងប្តីនិងទាំងប្រពន្ធអំពីអ្វីដែលបានកើតឡើង។ គេសុំឱ្យប្តីនិយាយសុំទោសប្រពន្ធ ហើយគាត់ចុះហត្ថលេខាលើលិខិតដែលនៅក្នុងនោះ គាត់សន្យាថាឈប់ធ្វើដូច្នេះទៀត។ បើវាជាលើកទីមួយដែលប្តីវាយប្រពន្ធ ដូច្នេះគេព្យាយាមបញ្ចុះបញ្ចូលប្រពន្ធឱ្យអត់ទ្រាំទៅវិញ។ បើមានករណីមិនរាងចាលវិញនោះ គេមិនអាចបញ្ចុះបញ្ចូលបានទេ។ គេស្នើឱ្យប្រពន្ធបញ្ជូនរឿងទៅតុលាការ ប៉ុន្តែរឿងដូច្នេះកម្រមានណាស់"។

(លោក សួរ អាយុ៣០ ឆ្នាំ នគរបាល សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

"លី បានវាយប្រពន្ធគាត់ឈ្មោះ ម៉ី។ គាត់ស្រវឹង។ គាត់វាយប្រពន្ធ ព្រោះប្រពន្ធគាត់មិននៅផ្ទះនៅពេលគាត់ចូលផ្ទះវិញ។ ក្នុងឋានៈជាអាជ្ញាធរមូលដ្ឋាន ខ្ញុំនិយាយទៅលីថា : "លើកក្រោយពេលអ្នកឯងស្រវឹង បើប្រពន្ធស្តីឱ្យ អ្នកឯងត្រូវស្តាប់។ អ្នកឯងវាយប្រពន្ធហូរឈាមចេញពីក្បាល គឺគ្មានប្រយោជន៏អ្វីទេ។ គ្មានជួយគ្រួសារទេ។ ក្រោយពីប្រពន្ធមានរបួស

គឺវាខាតការងារ។ គេមិនត្រូវធ្វើឱ្យខាតពេលវេលាធ្វើការទេ"។ ខ្ញុំនិយាយទៅប្រពន្ធថា : "ខ្លួនជាស្រី មិនត្រូវដើរលេងច្រើនពេកទេ។ បើឯងមិននៅផ្ទះ នៅពេលប្តីត្រឡប់មកវិញ ប្តីខឹង ដូច្នេះចូរប្រយ័ត្នលើកក្រោយ"។ លី និង ម៉ី ចុះហត្ថលេខាលើលិខិតសន្យា។ គឺលើកទីបី។ ឪពុកម្តាយ លី និង ម៉ី មានវត្តមាននៅពេលធ្វើការសំរុះសំរួល ព្រមទាំងប្រធានក្រុមផងដែរ។ ខ្ញុំហៅចាស់ទុំឱ្យមក បើប្តីនិងប្រពន្ធមិនព្រមចុះហត្ថលេខាលើលិខិតសន្យា។ ចាស់ទុំឱ្យដំបូន្មានដល់ប្តី។ ខ្ញុំមិនធ្វើលិខិតសន្យាគ្រប់តែពេលទេ ខ្ញុំធ្វើតែពេលមានរឿងធ្ងន់ធ្ងរ។ បើបន្ទាប់ពីលិខិតសន្យាទីបួនទៅប្តីនៅតែវាយប្រពន្ធ គាត់នឹងត្រូវទទួលទណ្ឌកម្ម។ ប្តីនោះត្រូវដកស្មៅនៅជុំវិញប៉ុស្តមួយថ្ងៃ ឬពីរថ្ងៃ។ បើទទួលយកលិខិតសន្យា គឺគោរពច្បាប់។ មនុស្សយល់តម្លៃរបស់វា។ ទណ្ឌកម្មគឺធ្វើឱ្យមនុស្សប្រុសខ្មាស់គេ និងដើម្បីធ្វើឱ្យអ្នកភូមិដទៃទៀតកុំយកតំរាប់តាម"។

(លោក ហំ អាយុ៦២ ឆ្នាំ ប្រធានភូមិ សង្កាត់អង្គាល់ ក្រុងកែប ខេត្តកំពត)

ប្រជាជនគ្រប់ទីកន្លែងមិនព្រមទទួលយកប្រព័ន្ធដាក់ទណ្ឌកម្មទេ។

"ខ្ញុំមិនអាចធ្វើឱ្យមនុស្សជំរះស្មៅ ឬរែកដីទេ ព្រោះគេថា ធ្វើដូចសម័យប៉ុលពត"។

(លោក វ៉ាយ អាយុ ៤៦ឆ្នាំ ប្រធានភូមិ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

ពីដើមឫទ្ធិអំណាចអ្នកតាខ្លាំង ប៉ុន្តែសព្វថ្ងៃចុះថយ ហើយការខ្លាចការដាក់ទណ្ឌកម្មរបស់អភិធម្មជាតិ ចេះតែថយចុះទៅៗ។

"គេធ្វើបុណ្យប្រចាំឆ្នាំឱ្យអ្នកតាពីរ គឺអ្នកតាភូមិដើម្បីបួងសួងសុំសេចក្តីរុងរឿង។ ពីមុន លោកខ្លាំងពូកែ ហើយកាចណាស់។ អ្នកតាកាច់កាលណាអ្នកណាម្នាក់ធ្វើខុស។ ឥឡូវនេះ មនុស្សខ្លះលែងជឿលើលោកទៀតហើយ ហើយពួកគេថ្វាយអាចម៍ឆ្កែ ឬដាំស្មៅដែលអ្នកតាមិនចូលចិត្ត។ អំណាចរបស់អ្នកតាថយកាលណាគេលែងជឿ"។

(ក្រុមស្ត្រី ឃុំពពាក់ ស្រុកស្វាយទាន ខេត្តស្វាយរៀង)

## IV. ការកត់សំគាល់លើស្ថានការណ៍បច្ចុប្បន្ន ៖ ការបារម្ភពីការផ្លាស់ប្តូរ

ការផ្លាស់ប្តូរជាច្រើនបានប្រព្រឹត្តទៅនៅប្រទេសកម្ពុជា ក្នុងរយៈពេល៣០ឆ្នាំកន្លងទៅនេះ។ អាជ្ញាធរមូលដ្ឋាន សព្វថ្ងៃព្យាយាមសំរបសំរួលខ្លួនទៅតាមស្ថានការណ៍ថ្មី ទោះបីពុំមានមធ្យោបាយថ្មីៗច្រើនសំរាប់យកមកប្រើប្រាស់តាមសេចក្តីត្រូវការក៏ដោយ។ អំណាច [១៥២] ដែលគេប្រើលើប្រជាជន ដែលផ្អែកមួយភាគធំលើការបង្ខំត្រូវបាក់បែក ដោយឥតមានប្រព័ន្ធណាមួយទៀតដែលត្រូវចាត់តាំងពិតប្រាកដ។ ការតាំងសន្តិភាព ការចាប់ផ្តើមអភិវឌ្ឍន៍សេដ្ឋកិច្ចនៅទីក្រុង ការភពប្រសព្វជាមួយពិភពលោកខាងក្រៅ និងគោលការណ៍ថ្មីនៃសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ព្រមទាំងការបង្កើតគណបក្សនយោបាយជំទាស បានបើកការសៅហ្មងនៅក្នុងប្រព័ន្ធបូរាណ។ គេកត់សំគាល់ឃើញមានសេរីភាព បញ្ចេញមតិ និងសេរីភាពចលនាកាន់តែធំឡើង។ ការខ្លាចកាន់តែថយចុះ។ ប៉ុន្តែ មរតកវប្បធម៌ចាស់ត្រូវបានចាក់គ្រឹះយ៉ាងមាំក្នុងអសម្បជញ្ញការរួម(ការចេះចាំអ្វីៗមកដោយមិនដឹងថាមានន័យយ៉ាងណា) ប៉ុន្តែ ក្រោមទម្រង់មួយដែលស្រពិចស្រពិល។ គេរកឃើញថា មានការខ្វះខាតចំណុចគោលពិតប្រាកដ សំរាប់ជាគោលអាងក្នុងជីវិតប្រចាំថ្ងៃ។

<u>ការធ្លាក់ចុះនៃអំណាចត្រួតត្រារបស់អាជ្ញាធរមូលដ្ឋានទៅលើប្រជាជន</u>

នៅតំបន់ទីក្រុង និងជុំវិញទីក្រុង ប្រធានភូមិ និងប្រធានសង្កាត់រៀបរាប់អំពីការគ្មានប្រសិទ្ធិភាពរបស់ខ្លួនដើម្បីបំពេញតួនាទីរបស់ខ្លួនឱ្យបានពេញលេញ។ គាត់និយាយថា សេរីភាពបានបោះពួយទៅមុខ ហើយដោយសារសេរីភាពនេះនាំឱ្យធ្លាក់ចុះនូវការគោរពរដ្ឋបាលមូលដ្ឋាន។

> "ឥឡូវនេះ មនុស្សលែងខ្លាចអាជ្ញាធរទៀតហើយ។ កាលណាយើងកោះហៅ ជារឿយៗគេមិនមកទេ។ គេលែងគោរពយើងទៀតហើយ ជាពិសេសក្មេងៗ និងអ្នកដែលមានអាយុតិចជាង៤០ឆ្នាំ"។
>
> (លោកឡែម ប្រធានសង្កាត់ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ភ្នំពេញ)

> "ឥឡូវនេះ អ្វីៗបានប្រែក្រឡាស់អស់ហើយ។ មនុស្សលែងខ្លាចមេ និងនគរបាលហើយ។ គេទះគួថឱ្យ។ បើគេមានលុយ គេអាចចាយវាយឱ្យនគរបាល។ ឥឡូវនេះ គឺមនុស្សចាស់ដែលខ្លាចក្មេងៗ"។
>
> (លោក សម្បត្តិ អាយុ៥៥ឆ្នាំ ប្រធានសង្កាត់ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ភ្នំពេញ)

---

[152] មេបច្ចុប្បន្ន មានមធ្យោបាយគាបសង្កត់តិចជាងកាលពីអតីត។ គេលែងជ្រើសរើសយកទាហ៊ានទៀតហើយ ហើយក៏ គ្មានពលកម្មសំរាប់ ក៥ ទៀតដែរ។ ការរីកដុះដាលគណបក្សនយោបាយធ្វើឱ្យចុះខ្សោយអំណាចរបស់គណបក្សសម្លេងភាគច្រើន។

"ពីមុនមនុស្សខ្លាច ឥឡូវនេះប្រធានភូមិស្លូត គឺគ្មានបញ្ហាទេ។ គេមិនខ្លាចអ្វីដែលប្រធានភូមិថាទេ ព្រោះ ប្រធានភូមិមិនមែននិយាយក្នុងនាមនៃច្បាប់"[១៥៣] ។

(អ្នកស្រី សាវ៉ន អាយុ៤៤ឆ្នាំ ពាណិជ្ជករ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

"មនុស្សដែលធូរធា ឬអ្នកណាម្នាក់ដែលមានបងប្អូនក្នុងគ្រួសារជាអ្នករាជការ ទៅតុលាការងាយជាងអ្នកដទៃទៀត។ ជារឿយៗ គេមិនចង់ដោះស្រាយបញ្ហារបស់គេនៅថ្នាក់ភូមិទេ។ គេគិតថាខ្លួនគេសំខាន់ជាងប្រធានភូមិ។ ចាប់តាំងពីអ៊ុនតាក់មក អ្វីៗបានផ្លាស់ប្តូរ។ មនុស្សលែងសូវខ្លាច និងលែងសូវគោរពអាជ្ញាធរ។ គេបានរៀនសិទ្ធិមនុស្សបន្តិចបន្តួច ហើយថាគេចង់ធ្វើអ្វីដោយសេរី។ គេនិយាយពីប្រជាធិបតេយ្យ។ មនុស្សទាមទារសិទ្ធិបុគ្គលរបស់គេ។ សូម្បីតែកាសែតក៏អាចរិះគន់នាយករដ្ឋមន្ត្រីបានដែរ។ ល្អហើយ ដែលមនុស្សលែងខ្លាច ប៉ុន្តែគេត្រូវមានការអប់រំ។ បើគេចង់បានសេរីភាពទាំងអស់ដោយមិនស្គាល់ពីព្រំដែនរបស់វា គឺពិបាកហើយ"។

(លោកសុវណ្ណរុំ ព្រះរាជអាជ្ញា តុលាការ ខេត្តកំពត)

អំណាចនិងការគោរពដែលផ្តល់ឱ្យប្រធានភូមិកាលពីដើម ហើយដែលរួមផ្សំជាមួយការខ្លាចត្រូវរលាយនៅពេលសព្វថ្ងៃ។ ដូច្នេះ ប្រធានភូមិមានមធ្យោបាយគាបសង្កត់ទៅលើប្រជាជនតិចជាងពីមុន។

"ចាប់តាំងពីឆ្នាំ៩៣ មក មានសេរីភាពកាន់តែច្រើន។ តួនាទីរបស់ប្រធានភូមិចុះថយ។ គេមិនជ្រើសរើស មនុស្សយកទៅច្បាំងទៀតទេ ឬក៏ទៅ ក៥ ឡើយ។ មនុស្សលែងខ្លាចគាត់។ គាត់លែងមានអ្វីចាត់ការលើពួកគេ ទៀតហើយ។ មនុស្សលែងគោរព សូម្បីតែលិខិតសន្យាក្តី។ គេដឹងថា ប្រធានភូមិលែងអាចធ្វើអ្វីគេបានទៀតហើយ។ ដូច្នេះ គេធ្វើអ្វីបានខ្លាំងជាងប្រធានភូមិទៅទៀត។ គេបង្ហាញថា គេអាចប្រឆាំងនឹងប្រធានភូមិបាន។ អំណាចរបស់ប្រធានភូមិចុះថយ។ ប្រធានភូមិលែងខ្លាំងទៀតហើយ គាត់អាចទាក់ទងនគរបាល ហើយមនុស្សនៅខ្លាចនគរបាលបន្តិច ហើយនៅគោរពនគរបាលជាង"។

(លោកដារ៉ាវុធ អាយុ៥២ឆ្នាំ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

"យើងមានអំណាចមានព្រំដែន។ កាលណាយើងទទួលបណ្តឹងពីបញ្ហាអ្វីមួយ ហើយបើយើងកោះហៅអ្នក ណាម្នាក់ច្រើនដង ហើយគាត់មិនមក យើងមិនអាចធ្វើអ្វីបានធំដុំទេ។ នគរបាលខ្លាំងជាងយើង ហើយមនុស្សខ្លាច។ ជួនកាល យើងសហការណ៍ជាមួយនគរបាល បើខ័ណ្ឌសុំឱ្យនគរបាលធ្វើអន្តរាគម។ ប៉ុន្តែ បើយើងសុំខ្លួនឯងឱ្យ នគរបាលធ្វើអន្តរាគម នគរបាលមិនសូវស្តាប់យើងទេ ព្រោះគេចូលចិត្តឆ្លើយតបទៅនឹងបញ្ហាអាជ្ញាធរថ្នាក់លើ គឺខ័ណ្ឌ។

[153] ច្បាប់នៅទីនេះ ចង់សំដៅដល់ការពិន័យ និងការដាក់ទណ្ឌកម្ម។

នីតិវិធីសំរុះសំរួលស៊ីពេលយូរ។ មនុស្សគ្មានការអប់រំ ហើយមិនសូវយល់ពីអ្វីដែលយើងនិយាយប្រាប់គេ។ គេយល់តែវិធីអំណាច ឬវិធីប្រាក់ប៉ុណ្ណោះ។ ពីមុនយើងប្រើអំណាច។ ឥឡូវនេះទៅមិនរួចទេ។ គឺលុយមកជំនួយវិញ។ អ្នកដែលមានលុយដើរជាន់អ្នកដទៃ។ ចំណែកយើងវិញ ឥឡូវនេះយើងមានអំណាចមានព្រំដែននៅចំពោះមុខពួកគេ។ អ្នកដែលមានលុយផ្លោះរំលងយើង"។

(លោក ផុំ អាយុ៥០ឆ្នាំ អនុប្រធានសង្កាត់ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ភ្នំពេញ)

ក្នុងសង្គមនេះ ដែលទំនាក់ទំនងជាមួយអ្នកខ្ពស់សំខាន់ជាងអ្នកតូច តួនាទីនៅក្រោមបង្គាប់នៃប្រធានក្រុម និងប្រធានភូមិ មិនសូវបានគោរពដោយអ្នកភ្នំពេញទេ ព្រោះគេចូលចិត្តទៅរកអាជ្ញាធរថ្នាក់លើ គឺសង្កាត់ ឬខ័ណ្ឌ។

"មនុស្សនៅភ្នំពេញចាត់ទុកថា ប្រធានភូមិមិនសំខាន់ និងមិនសូវមានការរៀនសូត្រទេ។ គេឡើងទៅសាលាសង្កាត់ដោយផ្ទាល់តែម្តង"។

(លោក សារា អនុប្រធានសង្កាត់ផ្សារកណ្តាលមួយ ខ័ណ្ឌដូនពេញ ភ្នំពេញ)

**ការបាត់គោលចារិក :** ករណីខ្មែរក្រហមចុះចូល និងការសំរបសំរួលទៅតាមជីវភាពថ្មី។ ការឆ្លងពីប្រព័ន្ធបែបបង្ខំជាសហគមន៍ ដែលអ្វីៗត្រូវបានចាត់ចែងដោយមេ ទៅកាន់ការបើកចំហរទៅរកប្រព័ន្ធមួយដែលមានសេរីភាពជាង ហើយដែលអនុគ្រោះបែបបទឯកត្តជននិយម មិនមែនប្រព្រឹត្តទៅដោយគ្មានការបង្កើតការញញើតញញើមខ្លះក្នុងបណ្តាអតីតខ្មែរក្រហមដែលបានចុះចូលក្នុងកម្លុងទសវត្ស ៩០នោះទេ។ អតីតមេយោធាខ្មែរក្រហមដែលបានប្រែខ្លួនទៅជាប្រធានភូមិ និងប្រធានឃុំ ជួនកាលមានការយល់មិនច្បាស់អំពីការផ្លាស់ប្តូរ និងការធ្លាក់ចុះឥទ្ធិពលរបស់ខ្លួនទៅលើប្រជាជន។ មនុស្សជាប្រជារាស្ត្រព្យាយាមរកគោលចារឹកថ្មីទាំងត្រដាបត្រដួសសំរាប់ខ្លួនឯង។

"ចាប់តាំងពីយើងចុះមកជីវាបនេះមក គឺតឹងតែងណាស់។ ឥឡូវនេះ មនុស្សលែងស្តាប់យើងហើយ។ គឺអនាធិបតេយ្យ។ សូម្បីតែមនុស្សមកពីព្រៃក៏លែងស្តាប់យើងដែរ។ គេនិយាយពីសេរីភាព ហើយគិតតែពីលែងបៀ បុកប៊ីយ៉ា។ អ្នកដែលស្តាប់យើង គេធ្វើការ និងរស់ដោយសុខក្សេមក្សាន្តនៅពេលនោះ។ គួរតែក្រឡេកមើលផ្ទះ។ ផ្ទះខ្លះធ្វើពីឈើ ហើយមានដើមឈើស៊ីផ្លែ អ្នកខ្លះនៅវេទនា ទោះបីជាយើងបានចែកដីឱ្យទាំងអស់គ្នាក្តី។ ឥឡូវនេះ មានជម្លោះកាន់តែច្រើនឡើង។ ជម្លោះ គឺកើតមកពីការកើនចំនួនប្រជាជន និងអ្នកចេញចូល។ អ្នកខ្លះមក អ្នកខ្លះចេញ។ ពិបាកត្រួតត្រាណាស់។ ល្អហើយដែលឱ្យសេរីភាពទៅមនុស្ស។ ប៉ុន្តែ កាលណាគេឱ្យសេរីភាពខ្លាំងពេក គេលែងស្តាប់យើងហើយ ហើយវានឹងមានបញ្ហា។ លើកឧទាហរណ៍រឿងវិឌីអូ។

ទាំងចាស់ទាំងក្មេងមើល វីឌីអូពេញមួយយប់ៗក្នុងរោងវីឌីអូ។ ខ្ញុំប្រាប់ថា ត្រូវតែកំណត់ម៉ោងដែលត្រូវឈប់បញ្ចាំង ឧទាហរណ៍នៅម៉ោង ១០យប់ជាដើម ប៉ុន្តែគេមិនស្តាប់ខ្ញុំទេ។ មនុស្សអស់កម្លាំងនៅពេលព្រឹក ហើយមិនធ្វើការទេ។ ក្មេងៗងងុយដេក នៅពេលរៀនក្នុងសាលា។ ឥឡូវនេះមានបញ្ហាច្រើនពេកដែលត្រូវដោះស្រាយ។ ខ្ញុំមិនអាចរវល់នឹងគ្រប់បញ្ហាបានទេ។ មនុស្សគេរអ៊ូរទាំថា ខ្ញុំមិនគិតពីគេ។ សូម្បីតែនគរបាលនិយាយក៏គេមិនស្តាប់ដែរ។ បើគេលែងស្តាប់ខ្ញុំ ខ្ញុំចង់ឈប់ធ្វើប្រធានភូមិហើយ"។

(លោក ឈុំ អាយុ៥៤ឆ្នាំ ប្រធានភូមិ-អតីតខ្មែរក្រហម សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

អតីតប្រជាជនខ្មែរក្រហមព្យាយាមទាំងពិបាកនឹងផ្សាភ្ជាប់ឡើងវិញនូវបំណែកជីវិតច្របូកច្របល់។

"ឥឡូវនេះ គឺប្រជាធិបតេយ្យ គេអាចនិយាយ។ ពីមុនខ្ញុំមិនហ៊ាននិយាយទេ។ ពីមុន គឺក្នុងឆ្នាំ១៩៩៦។ គឺច្បាប់ព្រៃ។ គេមិនហ៊ាននិយាយទេ។ បន្ទាប់មក មេត្រូវបានអប់រំដោយចៅហ្វាយស្រុក គឺល្អ។ ពីមុនរហូតមកទល់ឆ្នាំ១៩៩៦ យើងខ្លាចមិនហ៊ាននិយាយ។ គេនិយាយប្រាប់យើងថា: "បើមានបញ្ហា គេសម្លាប់"។ មនុស្សមិន មានការរៀនសូត្រ។ ឥឡូវនេះ គេគោរពសិទ្ធិ។ ការសម្លាប់គឺចប់។ ហើយឥឡូវនេះ យើងជាបងប្អូននឹងគ្នា។ អតីតខ្មែរក្រហមជាច្រើនមានវិប្បដិសារី។ ពួកគេនិយាយថា ពីមុនគេធ្វើអ្វីក៏បាន។ ពួកគេនិយាយថា:"យើងជាខ្មែរទាំងអស់គ្នា ហើយយើងវាយគ្នាសម្លាប់គ្នា។ យើងត្រូវបានបោកប្រាស់ដោយអ្នកដឹកនាំ"។ មនុស្សច្រើនណាស់ដែលស្លាប់។ ក្នុងចំណោមយោធាក្នុងអាយុស្រករខ្ញុំ នៅសល់តែខ្ញុំទេ។ ខ្ញុំបានសំរេចចិត្តថា ឈប់ធ្វើទាហ៊ានទៀតហើយ។ អតីតខ្មែរក្រហមខ្លះរៀបរាប់ថា គេដើរខុសផ្លូវ ប៉ុន្តែអតីតមេខ្មែរក្រហមមិនសារភាពទេ។ ពួកគេនិយាយថា ពីមុនជីវភាពស្រួល ចំណីហូរហៀរដោយគ្រាន់តែធ្វើការបន្តិចបន្តួច។ កាលណាពួកគេចង់សម្លាប់អ្នកណាម្នាក់ គេសុំឱ្យសម្លាប់អ្នកនោះ។ ពួកគេនិយាយថា អ្នកនោះមិនដែលស្គាល់ការលំបាក។ ចំពោះយើងជាកូនចៅ(ទាហាន) គឺតឹងណាស់ យើងគ្មានសេរីភាពទេ។ កន្លែងនេះគឺនៅត្រពាំងក្តី មនុស្សមានការរៀនសូត្រ។ នៅភូមិដទៃទៀតមនុស្សគ្មានការរៀនសូត្រ ហើយគ្មានយល់អ្វីទាំងអស់។ ទោះបីអ្នកណាក៏មិនអាចបញ្ចោបានដែរ។ មេៗធ្វើរំលងច្បាប់ក៏គ្មានអ្នកណាយកចិត្តទុកដាក់ដែរ។ ឧទាហរណ៍ ប្រធានភូមិនិយាយថា: "ទាំងអស់គ្នាត្រូវចូលរួមក្នុងការធ្វើផ្លូវ។ អ្នកណាមិនមក ត្រូវបណ្តេញចេញពីទីនេះ"។ មនុស្សមិនហ៊ាននិយាយទេ។ ពួកគេនិយាយគ្នាថា ប្រធានភូមិធ្វើការគាប់សង្កត់លើពួកគេ។ ពួកគេមិនហ៊ាននិយាយទេ ព្រោះពិបាកនឹងនិយាយជាមួយប្រធានភូមិដែលមិនចេះអក្សរ។ នៅភូមិជ័យតាស្វាយកាលពីបីបួនឆ្នាំមុន ប្រធានភូមិបានបណ្តេញមនុស្សជាង១០គ្រួសារ។ គាត់អនុវត្តច្បាប់ព្រៃ។ គាត់អាចសម្លាប់មនុស្ស។ ប៉ុន្តែ មនុស្សមិនសប្បាយចិត្ត ហើយ

គេបាននិយាយ។ ចាប់ពីពេលនោះមក ប្រធានភូមិមិនហ៊ាននៅផ្ទះគាត់ទេ ព្រោះគាត់ខ្លាចគេសង សឹក។ ឥឡូវនេះលែងដូចមុនទៀតហើយ។ មេៗលែងអាចធ្វើអ្វីបានតាមចិត្តគាត់ចង់ទៀត ហើយ"។

(លោក សាម៉ាត អាយុ៤៥ឆ្នាំ ឃុំតាកែន ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

នេះជាវគ្គនៃសន្ទរកថាឃោសនា ដែលសូត្រដូចម៉ាស៊ីននេះម្តុំនោះម្តុំទៅកាន់កម្មាភិបាលរដ្ឋបាលមួយ ដោយផ្អែកលើអត្ថបទសរសេរ។

"នៅឆ្នាំ៩៤ ពេលយើងចុះមកពីព្រៃ អង្គការមនុស្សបានផ្លាស់ប្តូរ។ ឥឡូវនេះ បើគេចង់ធ្វើការប្រជុំមួយ(ប្រជុំសំរុះសំរួល) គឺត្រូវនៅក្រោមការជ្រោមជ្រែងរបស់មន្ត្រីរាជការ រដ្ឋាភិបាល។ ពីមុន ដំណោះស្រាយបញ្ហាប្រព្រឹត្តទៅដោយសំអាងលើអ្វីដែលគេបានឃើញបានឮ។ យើងនិយាយក្នុងចំណោមគ្នាយើង ជួនកាលយុត្តិធម៌ ឬ ជួនកាលអយុត្តិធម៌។ នេះអាស្រ័យលើអ្នកដែលដោះស្រាយបញ្ហា។ ឥឡូវនេះ ដំណោះស្រាយត្រូវបានធ្វើឡើង ដោយផ្អែកលើឯកសារសរសេរ បទបញ្ជា រដ្ឋធម្មនុញ្ញ ច្បាប់ និងសិទ្ធិមនុស្ស។ ពីមុនក៏មានឯកសារខ្លះដែរ ប៉ុន្តែមេៗ រៀនទន្ទេញចាំមាត់ ហើយយើងសូត្រតាម"។

(លោក សុក អាយុ៥៥ ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

នៅទីនេះ យើងរកឃើញ ការសំរបសំរួលមួយយ៉ាងពិបាកឱ្យស្របតាមប្រព័ន្ធរដ្ឋបាលមួយដែលហួសពីក្របខ័ណ្ឌបិតុនិយមកាលពីអតីត។

"ពីមុន កាលយើងនៅក្នុងព្រៃ តារិនជាឧត្តមសេនីយ។ គេអាចទៅជួបគាត់ដោយស្រួលក្នុងករណីមានបញ្ហា។ គេទៅជួបដោយផ្ទាល់តែម្តង។ គាត់ដោះស្រាយរឿងដោយស្រួល។ ឥឡូវនេះស្មុគ្រស្មាញជាង។ គេត្រូវឆ្លងកាត់អាជ្ញាធរភូមិ សង្កាត់ ទីក្រុង"។

(លោក នួន អាយុ ៤២ ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ (អតីតខ្មែរក្រហម)សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

អតីតខ្មែរក្រហមរ៉ាយរ៉ាប់អំពីការលំបាករបស់គេក្នុងការរស់នៅ ជាមួយអ្វីដែលគេមិនស្គាល់ៈ គឺ សេរីភាព។

"នៅសម័យខ្មែរក្រហម យើងបានផ្ញើវាសនារបស់យើងក្នុងដៃអង្គការ។ យើងគ្មានបារម្ភអ្វីទាំងអស់។ អង្គការគិតគូរសព្វគ្រប់។ ឥឡូវនេះ គឺរឿងអ្នកណាអ្នកនោះគិត។ គឺពិបាក។ សេរីភាពគឺល្អ ប៉ុន្តែបើជ្រុលពេក គឺពិបាករស់។ គេពិបាករស់នៅក្នុងសង្គមសេរីមួយ។ ម្នាក់ៗចង់ធ្វើអ្វីដែលគេចង់ ហើយលែងមានអ្នកណាប្រាប់យើងថា ត្រូវធ្វើអ្វីទៀតហើយ។ យើងពិបាកដែលត្រូវគិតអ្វីដោយខ្លួនឯងដើម្បីបានរស់រហូតដល់ថ្ងៃស្អែក"។

(លោក នាក់ អាយុ៣៨ឆ្នាំ ម្ចាស់រោងរីឌីអូ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

"កាលពីសម័យខ្មែរក្រហម មានវិន័យជាង និងមានយុត្តិធម៌ជាង។ គេត្រង់ហើយស្មោះនឹងគ្នា។ គេនិយាយត្រង់ៗ។ គេមិនកុហកទេ។ ឥឡូវនេះ គេរស់ក្នុងសេរីភាព ប៉ុន្តែគេគ្មានការគោរព គេគ្មានក្បួនច្បាប់មុឹងម៉ាត់។ គឺជាសេរីភាពជ្រុលនិយម។ កាលពីសម័យប៉ុល ពត គឺល្អ មនុស្សត្រង់។ ប៉ុន្តែ គេហូបរួមគ្នា ហើយត្រូវទៅរកសមរភូមិ។ គឺ មុឹងម៉ាត់"។

(អ្នកស្រី សេង អាយុ៤៣ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

ចំពោះស្ត្រីជាអតីតខ្មែរក្រហមវិញ សេរីភាពថ្មី គ្មានអ្វីល្អនាំមកឱ្យប្រុសៗទេ ហើយសេរីភាពប្រហែលជាប្រភពនៃទំនាស់ទៀតផង បើគ្មានកំណត់ព្រំដែន។

"ឥឡូវនេះ មានបញ្ហាប្ដីប្រពន្ធច្រើន។ ប្រុសៗមានប្រពន្ធចុង ហើយវាយប្រពន្ធដើម។ កាលពីប៉ុល ពត បើមានរឿងស្រីញីច្រើន គេត្រូវសម្លាប់ចោល។ ឥឡូវនេះ ប្រុសៗនិយាយថា គេមានសេរីភាព ហើយគេចង់បានប្រពន្ធច្រើន។ គេថាជាសិទ្ធិរបស់គេ ដើម្បីធ្វើអ្វីដែលគេចង់ធ្វើ។ ចំពោះយើងវិញ យើងមិនយល់ស្របទេ យើងចង់កំចាត់ពួកស្រីពេស្យា។ សេរីភាពគឺល្អ ប៉ុន្តែវាក៏បង្កើតបញ្ហាដែរ។ ប្រុសៗធ្វើអ្វីក៏បាន។ ពួកគេមិនសូវស្ដាប់មេទេ។ គឺអនាធិបតេយ្យ។ កាលណាមានមេៗដែលមានការចេះដឹង គេស្ដាប់។ បើមនុស្សទាំងអស់ធ្វើអ្វីស្រេចតែចិត្ត ព្រោះគេថានេះជាសេរីភាពនោះ គឺមិនល្អទេ។ គេលែងមានការគោរព។ គេអាចក្លាយទៅជាសត្វ"។

(អ្នកស្រី សេត អាយុ៤៥ឆ្នាំ អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត-ភូមិថ្មី)

កាលប៉ះទង្គិចគ្នារវាងអតីតខ្មែរក្រហម និងប្រជាជននៅជីរាប ដែលជាប្រជាជនធ្លាប់មានសិទ្ធិបញ្ចេញមតិ មិនមែនប្រព្រឹត្តទៅដោយគ្មានការមិនយល់គ្នាខ្លះនោះទេ។ ចំពោះអតីតខ្មែរក្រហមរូបនេះ ការប្រឹងប្រែងដើម្បីសន្ទនាគ្នា និងការទាមទារថ្មីៗ ត្រូវបានចាត់ទុកដូចជាប្រភពនៃបញ្ហា។

"ពីមុនវាជ្រុលហួស។ គេមានសហករណ៍សំរាប់ហូបរួម។ វាប្រព្រឹត្តទៅល្អ ប៉ុន្តែអ្នកដែលមិនធ្វើតាមបទបញ្ជាត្រូវសម្លាប់ចោល។ ឥឡូវនេះ គេគ្មានសិទ្ធិសម្លាប់មនុស្សទេ។ របបរួមគឺល្អ ប៉ុន្តែវាក៏បង្កើតទំនាស់ដែរ។ មានការច្រណែនគ្នារវាងអ្នកធ្វើការច្រើន និងអ្នកដែលមិនធ្វើការច្រើន។ ដោយហេតុថា មនុស្សទាំងពីរប្រភេទនេះហូបដូចគ្នា ដូច្នេះគេមិនសប្បាយចិត្តទេ។ ឥឡូវនេះក៏អញ្ចឹងដែរ មានមនុស្សនៅទីនេះដែលមិនសប្បាយចិត្ត។ ពួកគេរិះគន់អ្នកដែលធ្វើការល្អ និងដើរតាមការណែនាំរបស់មេ។ ពួកនេះគឺជាអ្នកមិនធ្វើ។ ប្រពន្ធពួកគេជាស្រីពេស្យាដែលដេកជាមួយប្រុសៗម្នាក់២៥០០រៀល ឬដូរអង្ករ។ ពួកនេះច្រណែនជាមួយអ្នកដែលមានបានដោយសារមារយាទល្អរបស់គេ។ ពួកគេតវ៉ាជានិច្ច។ ឧទាហរណ៍ គេថាប្រធានភូមិទារប្រាក់៣០០០០ ឬ

២០០០០រៀល ដើម្បីធ្វើកម្មសិទ្ធិដី ប៉ុន្តែប្រាក់នេះមិនមែនសំរាប់ប្រធាន១ទេ គឺខាងបរិស្ថានខេត្តកំពតទេដែលទាមទារ។ នៅទីនេះ គេព្យាយាមដាក់លាយគ្នារវាងមនុស្សមកពីព្រៃ និងអ្នកមកពីជីវាប។ គេអប់រំអ្នកទាំងនោះ ដោយនិយាយថា បើអ្នកណាលួចទ្រព្យគេ អ្នកនោះនឹងត្រូវសម្លាប់ចោល។ ពួកគេស្តាប់។ យើងគ្មានសិទ្ធិសម្លាប់ទេ ប៉ុន្តែយើងបន្លាច។ ពួកយើងជាអ្នកមកពីព្រៃ យើងមិនចេះឈ្លោះដូចអ្នកនៅក្នុងស្រុកទេ។ អ្នកមកពីស្រុកក្រោមមកទីនេះពីព្រោះគេមានដីតិច ឬគ្មានដីសោះ។ យើងឱ្យដីធំ១ដល់ពួកគាត់ ហើយក្រោយមកយើងសុំដីមួយដុំតូចពីគាត់ដើម្បីធ្វើផ្លូវធំមួយ។ ដូច្នេះ គាត់បង្កើតបញ្ហា។ យើងអ្នកមកពីព្រៃចេះសាមគ្គីគ្នាហើយឱ្យដីមួយផ្នែក។ ពួកគេ(អ្នកមកស្រុកក្រោម)ប្រកែករាល់លើក ហើយបង្កើតបញ្ហា។ ឥឡូវនេះ ពិបាកណាស់។ គេត្រូវនិយាយជានិច្ច"។

(លោក ស្រៃ អាយុ៤៥ឆ្នាំ (អតីតខ្មែរក្រហម)ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត)

## ការរំដោះខ្លួនរបស់ស្ត្រី

ការជឿនទៅមុខនៃសិទ្ធិស្ត្រីមិនមែនប្រព្រឹត្តទៅដោយគ្មានការសង្គ្រោះតធ្មេញខ្លះនោះទេ។

អ្នកស្រី សាង ជាអតីតកម្មាភិបាលខ្មែរក្រហម។ គាត់បានរៀនអក្សរក្នុងក្របខ័ណ្ឌនៃកម្មវិធីអក្ខរកម្មមួយរបស់យូណេស្កូ។ ដោយបានឃើញសមត្ថភាពរបស់គាត់ គាត់ត្រូវបានប្រគល់ភារកិច្ចឱ្យបណ្តុះបណ្តាលស្ត្រីដទៃទៀត និងទទួលបន្ទុកគ្រប់គ្រងរដ្ឋបាលមួយផ្នែកនៃគំរោងការ។ គាត់បានចាប់ផ្តើមធ្វើការយ៉ាងច្រើនដោយចូលផ្ទះវិញនៅពេលប្រលប់។ ប្តីគាត់មិនយល់ព្រមនឹងអវត្តមានរបស់គាត់ទេ (ដោយសារគាត់ចូលផ្ទះយប់ៗ)។ ប្តីគាត់សង្ស័យថា គាត់មានសហាយស្មន់ហើយរួចក៏វាយគាត់។ គាត់ងើបតតាំងនឹងប្តីវិញដោយប្រើហេតុផលសិទ្ធិមនុស្សផ្សំជាមួយទម្លាប់កាលពីនៅជាមួយខ្មែរក្រហម។

"ប្តីខ្ញុំដើរលេងគ្រប់ពេលវេលា ហើយគាត់ចង់ឱ្យខ្ញុំនៅតែផ្ទះ។ ខ្ញុំចង់អប់រំប្តីខ្ញុំអំពីសិទ្ធិស្ត្រី ប៉ុន្តែគាត់មិនចង់ស្តាប់ទេ។ ខ្ញុំបានសុំឱ្យប្រធានភូមិអប់រំប្តីខ្ញុំ ប៉ុន្តែគាត់និយាយថា គាត់គ្មានពេល។ បើតាមគំនិតខ្ញុំ ទោះបីជាប្រធានជាអ្នកបដិវត្តល្អក្តី គាត់ដើរផ្លូវខុស។ គាត់បានមើលឃើញបញ្ហានៅក្នុងទស្សនៈវិស័យនៃច្បាប់ព្រៃ។ ឧទាហរណ៍ នៅពេលមួយ ស្ត្រីម្នាក់ចង់លែងលះព្រោះប្តីគាត់វាយគាត់។ ប្រធានភូមិបាននិយាយថា គាត់មិនអនុញ្ញាតឱ្យលែងលះទេ បើមានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងពីរមិនចង់លែងលះ។ ប្រធានភូមិនិយាយថា បើប្តីវាយប្រពន្ធគឺព្រោះប្រពន្ធជេរប្តី។ ចំណែកខ្ញុំ ខ្ញុំទាមទារឱ្យលែងលះ ព្រោះមកពីហិង្សាក្នុងគ្រួសារ ហើយខ្ញុំមានសិទ្ធិ ទោះបីជាប្តីខ្ញុំមិនចង់លែងលះក៏ដោយ។ គឺសិទ្ធិស្ត្រី។ នៅទីនេះ មេដឹកនាំជាអតីតខ្មែរក្រហមរបស់ប៉ុលពត។ ពួកគាត់គ្មានការអប់រំទេ។ ពួកយើងជាខ្មែរក្រហម ក្រោយឆ្នាំ១៩៧៩

យើងជាយុទ្ធជន។ យើងមិននៅមួយកន្លែងទេ យើងចល័តទៅនេះទៅនោះគ្រប់ទិសទី ហើយយើងដោះស្រាយបញ្ហាយ៉ាងឆាប់ៗ។ ឥឡូវនេះ គេត្រូវទៅច្រើនដងដើម្បីបានជួបប្រធានភូមិដើម្បីឱ្យគាត់ស្តាប់យើងបន្តិច។ អនុប្រធានទទួលបន្ទុកសន្តិសុខ មិនសូវល្អទេ។ គាត់ជាអ្នកប្រើអំណាច។ ខ្ញុំចង់បានសិទ្ធិស្ត្រី។ នៅពេលខ្ញុំចូលផ្ទះ ខ្ញុំចង់ឱ្យអ្វីៗដូចកាលពីសម័យខ្មែរក្រហមគឺបុរសនិងស្ត្រីត្រូវបានប្រព្រឹត្តចំពោះដោយស្មើភាពគ្នា។ នៅសម័យនោះ ក្រោយពីធ្វើការពេញមួយថ្ងៃមក មានអ្នកចំអិនអាហារឱ្យខ្ញុំ និងមើលកូនឱ្យខ្ញុំ។ ប្តីខ្ញុំនៅផ្ទះ។ គាត់និយាយថាគាត់រង់ចាំខ្ញុំ។ គាត់អាចរៀបអាហារ និងមើលកូនក៏បាន។ គាត់មិនធ្វើអ្វីទេ ហើយគាត់និយាយថាគឺប្រពន្ធដែលត្រូវធ្វើ។ ខ្ញុំបដិសេធ។ ខ្ញុំចង់លែងលះ។

ប្រធានភូមិបាននិយាយថា មុខងាររបស់គាត់ មិនអនុញ្ញាតិឱ្យគាត់បំបែកយើងទេ តែខ្ញុំចង់លែងលះ។ ខ្ញុំត្រូវទៅតុលាការ។ ខ្ញុំទៅតុលាការ ហើយគេព្យាយាមធ្វើការសំរុះសំរួលបីដង។ មន្ត្រីតុលាការបានអប់រំប្តីខ្ញុំ ហើយបានលាតត្រដាងពីបញ្ហាកូនគ្មានឪពុក។ ប៉ុន្តែ ខ្ញុំមិនអាចអត់ទ្រាំបានទេ។ ប្តីខ្ញុំកាច គាត់មិនព្រមឱ្យខ្ញុំចិញ្ចឹម កូនជាមួយប្តីមុនរបស់ខ្ញុំទេ។ គាត់ថាថ្លៃចិញ្ចឹមកូនច្រើនណាស់។ គាត់ថា គាត់មិនចង់ធ្វើការដើម្បីចិញ្ចឹមកូនរបស់ប្តី មុនទេ។ ខ្ញុំនិយាយទៅគាត់ថាគឺខ្ញុំទេដែលធ្វើការច្រើន ហើយជាអ្នករកអង្ករច្រកឆ្នាំង។ ខ្ញុំអាចទ្រាំទ្រលំបាកធ្វើការ ប៉ុន្តែមិនទ្រាំនឹងលំបាកចិត្តបានទេ គឺយ៉ាប់ណាស់។

ចាប់តាំងពី២ឆ្នាំមកហើយ ខ្ញុំធ្វើការឱ្យយូណេស្កូលើសពី៨ម៉ោងក្នុងមួយថ្ងៃ។ ប្តីខ្ញុំមិនចង់ឱ្យខ្ញុំចេញក្រៅផ្ទះទេ។ គាត់ប្រច័ណ្ឌ។ គាត់វាយខ្ញុំ ហើយប្រាប់អ្នកជិតខាងថា ខ្ញុំមានសហាយ។ គាត់ស្រឡាញ់ខ្ញុំ តែគាត់មិនស្រឡាញ់កូនខ្ញុំ។ ខ្ញុំអត់ទ្រាំនិងស្ថានការណ៍នេះយូរមកហើយ ប៉ុន្តែគាត់វាយខ្ញុំច្រើនពេក។ គាត់និយាយប្រាប់គេគ្រប់គ្នាថា ខ្ញុំដេកជាមួយមនុស្សប្រុសទាំងអស់នៅកំពត។ ឥឡូវយុត្តិធម៌គឺដើម្បីស្ត្រី។ បើប្រពន្ធធ្វើកំហុស ប្រពន្ធត្រូវទទួលស្គាល់ ហើយសាក្សីអាចនិយាយប្រាប់ពីកំហុស។ គេធ្វើតាមយុត្តិធម៌។ ប្តីខ្ញុំបានរកសាក្សីដែលបានឃើញខ្ញុំដេកជាមួយប្រុស ប៉ុន្តែរកមិនបានទេ។ គឺគាត់ត្រូវអត់ទ្រាំ ព្រោះខ្ញុំជាអ្នកធ្វើការ"។

(អ្នកស្រី សាង អាយុ៤៧ឆ្នាំ (អតីតខ្មែរក្រហម) សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ប្រធានភូមិ ដែលពីដើមជាប្រធានយោធាខ្មែរក្រហម មិនយល់ស្របនឹងគំនិតសម័យថ្មីរបស់សាង។ តាមសំដីរបស់គាត់ អ្នកស្រីសាងដកខ្លួនឱ្យខុសពីគេឯង និងគោលការណ៍សាមគ្គីភាពនិងឯកភាព ដែលអតីតយុទ្ធជនក្នុងព្រៃបានសរសើរ។

"អ្វីដែលគាត់ធ្វើគឺមិនល្អទេ។ គាត់មើលងាយថ្នាក់លើ។ គាត់មិនចង់ពឹងយើងនៅក្នុងភូមិទេ។ គាត់លែងមានទំនុកចិត្តលើពួកយើងហើយ។ យើងជាបងប្អូនគាត់។ យើងនៅព្រៃទាំងអស់គ្នា។ ប៉ុន្តែ គាត់លែងគោរពយើង។ គាត់ទៅតុលាការដោយផ្ទាល់តែម្តង។ យើងមិនចូលចិត្តឥរិយាបថគាត់ទេ។ គាត់និយាយខ្លាំងៗ ហើយមនុស្សទាំងអស់ឮគាត់ស្រែកដាក់ប្តី។ ប្តីគាត់ចង់រស់នៅជាមួយគាត់ ប៉ុន្តែគាត់ខ្មាស់គេដោយសារចរិតលក្ខណៈរបស់ប្រពន្ធគាត់។ គាត់ក៏ចុះចេញ។ គេមិនត្រូវធ្វើដូច្នេះទេ"។

(លោក ឈុំ អាយុ៥៤ឆ្នាំ ប្រធានភូមិ(អតីតខ្មែរក្រហម)សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

ក្នុងភូមិបូរាណមួយ ប្រធានភូមិរៀបរាប់ពីការឈ្លោះប្រកែកប្តីប្រពន្ធមួយ ហើយធ្វើការចាប់អារម្មណ៍លើមារយាទ"ស្រីមិនល្អ" ហើយនិងការជឿនលឿននៃសិទ្ធិស្ត្រី។

"បុរសម្នាក់ចេញពីផ្ទះនៅពេលកំពុងភ្លៀងធ្លាក់។ គាត់ទៅបង្ហូរទឹកចេញពីចំការឪឡឹក រួចមកទៅលេងបាល់ទះ។ គោដើរកាត់ចំការឪឡឹក ហើយស៊ីផ្លែឪឡឹកអស់ខ្លះ។ ដោយមានគេស្រែកប្រាប់ ប្រពន្ធក៏ចេញមកដេញគោចេញពីចំការ រួចហើយក៏ដើររកប្តី។ គាត់មកទីលានបាល់ទះទាំងខឹង ព្រមទាំងបានជេរប្តី។ គាត់ស្រែកជេរថា "អាឆ្កែរអង្កែស៊ី"[១៥៤]។ ប្តី ដោយខ្មាស់គេក៏វាយប្រពន្ធនៅទីលានបាល់ទះ ហើយនាំប្រពន្ធទៅមុខម្តាយនាង។ គាត់បាននិយាយទៅឪពុកម្តាយប្រពន្ធថា គាត់ចង់លែងលះ។ គាត់ថាប្រពន្ធបានជេរគាត់។ បុរសនោះអស់កម្លាំង ក្រោយពីការឈ្លោះប្រកែកនោះ ហើយបានមកផ្ទះខ្ញុំដើម្បីសុំលែងលះ។ ខ្ញុំមិនចង់រវល់នឹងរឿងនោះទេ ក្នុងខណៈដែលមនុស្សប្រុសកំពុងខឹង។ ខ្ញុំបាននិយាថា ខ្ញុំជាប់រវល់ណាស់ ហើយប្រាប់ថា គឺជាភារកិច្ចរបស់ប្រធានភូមិ។ បុរសនោះនិយាយថា គាត់បានសំរេចចិត្តរួចហើយ។ ក្នុងរយៈពេលមួយខែគាត់មិនត្រូវគ្នាជាមួយប្រពន្ធគាត់អស់រយៈពេល៩ថ្ងៃទៅហើយ។ នៅថ្ងៃល្ងាច ប្រធានភូមិមកផ្ទះខ្ញុំ ហើយគាត់ប្រាប់ខ្ញុំថា គេនឹងធ្វើការសំរុះសំរួលនៅល្ងាចស្អែក។ ខ្ញុំបាននិយាយថា ខ្ញុំមិនយល់ស្របទេ ហើយថាគេត្រូវទុករឿងឱ្យនៅ៣ឬ៤ខែសិនមុននឹងធ្វើអន្តរាគម។ បុរសនោះត្រឡប់មកវិញនៅពេលល្ងាច ដើម្បីប្រាប់ថាមានការបន្ទាន់។ ខ្ញុំនិយាយយល់ព្រមសំរាប់ថ្ងៃស្អែក។ បុរសនោះមកម្តងទៀត។ គាត់ចង់ឱ្យខ្ញុំទៅភ្លាមៗ។ ខ្ញុំប្រាប់ថា ខ្ញុំនឹងទៅ ប៉ុន្តែតាមពិតខ្ញុំចង់ទៅថ្ងៃស្អែក។ ប៉ុន្តែបុរសនោះមានះ រួចគាត់មកម្តងទៀត។ ខ្ញុំសំរេចថា យល់ព្រមទៅ។ ខ្ញុំបានប្រាប់ឱ្យប្រធានភូមិមកជាមួយឪពុកម្តាយប្តីប្រពន្ធទាំងពីរ។ ម្តាយខាងប្រុសចាស់ណាស់ គាត់មិនអាចមកបានទេ។ ចំពោះខាងស្រី យើងបានកោះហៅឪពុកម្តាយ និងបងប្អូន

[154] ពាក្យនេះមានន័យថា ពេលប្រុសរៀបការហើយ គេមកតែខ្លួន និងគ្មានយកអ្វីមកជាមួយខ្លួន។

ប្រុសស្រី៤នាក់។ បងប្អូនប្រុសស្រីមិនចង់មកទេ ព្រោះគេមិនចូលចិត្តបង/ប្អូនស្រីរបស់ខ្លួនដែលចេះតែជេរមនុស្សមិនរើសមុខ។ ដោយរង់ចាំការអញ្ជើញមកនៃប្រធានភូមិ ខ្ញុំទៅធ្វើការអង្កេតដល់ទីលានបាល់ទះ។ ខ្ញុំសួរមនុស្សទាំងអស់ថាៈ "អ្នកណាជាអ្នករករឿងមុន? អ្នកណាជាអ្នករងគ្រោះ? ខ្ញុំបានសួរថា តើប្តីនោះមកទីលានបាល់ទះដើម្បីលេងភ្នាល់ឬលេងសប្បាយ។ ពួកគេនិយាយថា គឺដើម្បីសប្បាយទេ ហើយគឺប្រពន្ធទេដែលមករករឿងមុន។ ខ្ញុំក៏បានសួរឪពុកម្តាយខាងស្រីដែរ។ ឪពុកមិនចង់មកទេ គាត់ចង់នៅអាព្យាក្រឹត្យ គាត់ក៏ដើរចេញ។ មានតែម្តាយម្នាក់ឯងដែលនៅ។ ខ្ញុំប្រាប់ឱ្យគាត់ជួយកូនដើម្បីឱ្យគេនៅជាប់គ្នា ហើយកុំឱ្យលែងលះ។ ប្រពន្ធមិនចង់មកទេ គាត់និយាយថាៈ "បើគេចង់លែងលះ គ្រាន់តែហៅខ្ញុំមកបានហើយ ខ្ញុំនឹងផ្តិតមេដៃ"។ ខ្ញុំបានសុំឱ្យប្តីទៅរកប្រពន្ធ។ ប្តីមិនចង់ទៅ។ ម្តាយខាងស្រីក៏មិនចង់ដែរ។ ខ្ញុំបាននិយាយទៅប្រធានភូមិថាៈ "បើប្រពន្ធមិនមក មានន័យថា គាត់មិនចង់លែងលះ។ ប្តីចង់លែងបានជាប្រពន្ធមិនចង់មក"។ ខ្ញុំទៅផ្ទះប្រពន្ធ។ ពេលខ្ញុំមកដល់ផ្ទះ ស្ត្រីជាប្រពន្ធនោះ ធ្វើហាក់ដូចជាគ្មានដឹងរឿងអ្វីទាំងអស់។ គាត់កំពុងបោកគក់ខោអាវ។ គាត់មានការខ្មាស់អៀននឹងអ្វីដែលគាត់បានធ្វើ។ ខ្ញុំព្យាយាមពិភាក្សាជាមួយគាត់ ហើយខ្ញុំបានយល់ថា គាត់មិនចង់លែងលះទេ។ ខ្ញុំមកជួបប្តីម្តង ព្រោះខ្ញុំត្រូវធ្វើការគាបសង្កត់លើគាត់ឱ្យគាត់ស្រុះស្រួលជាមួយប្រពន្ធគាត់។ ខ្ញុំនិយាយទៅគាត់ថា វាជាការធម្មតាទេដែលប្តីប្រពន្ធឈ្លោះគ្នា ដែលត្រូវបោះបង់គំនិតឈ្លោះគ្នា និងដែលថាជម្លោះគ្មានបានចំណេញអ្វី។ ខ្ញុំបាននិយាយទៅស្ត្រីជាប្រពន្ធថា លើកក្រោយបើចង់ជេរប្តីត្រូវជេរនៅក្នុងផ្ទះ ប៉ុន្តែកុំជេរនៅកណ្តាលសាធារណៈ។ ប្តីមិនចង់ធ្វើការសំរុះសំរួលទេ។ គាត់ថា ធ្វើដូច្នេះស៊ីពេលយូរណាស់។ គាត់ចង់លែងលះហើយទាមទារស្រូវ៥បាវ និងកង់។ ផ្ទះ គោ និងសម្បត្តិដទៃទេទៀតគាត់ទុកឱ្យប្រពន្ធ។ ខ្ញុំបានពន្យល់ទៅប្តីអំពីផលវិបាកនៃអំពើរបស់គាត់ទៅលើកូន។ ខ្ញុំបាននិយាយទៅប្រពន្ធឱ្យសុំទោសប្តី។ គាត់យល់ព្រម។ គាត់បាននិយាយថា គាត់ខុសដោយបានជេរប្តី។ គាត់បានសុំទោស ហើយសន្យាថា លើកក្រោយគាត់នឹងលែងជេរប្តីជាសាធារណៈទៀតហើយ។ ប្តីនៅតែមិនព្រម។ ខ្ញុំនិយាយទៅគាត់ថា ខ្ញុំទទួលបន្ទុកបញ្ហានោះ ហើយបើមានរឿងអ្វីកើតឡើង គឺប្រពន្ធនៅតែជេរប្តីនៅមុខសាធារណៈជន ខ្ញុំយល់ព្រមឱ្យលែងលះ។ ដោយហេតុថាខ្ញុំអាចដឹងថា បុរសនោះមិនផឹក និងមិនលេងបៀ ខ្ញុំបានឱ្យយោបល់ដល់ប្រពន្ធឱ្យអត់អោនការខឹងច្រឡោតរបស់ប្តី យល់ព្រមឱ្យគាត់លេងបាល់ទះ និងអាចដើរលេងនៅពេលបុណ្យទានផង។ ខ្ញុំប្រាប់ប្រពន្ធថា បើប្តីផឹកហើយវាយកូន ខ្ញុំអាចជួយឱ្យលែងលះ ប៉ុន្តែក្នុងករណីនេះប្តីជាមនុស្សល្អទេ។ បន្ទាប់មកប្តីបានយល់ព្រមតាម ហើយខ្ញុំសរសេរលិខិតសន្យាដោយសរសេរថា ប្រពន្ធសន្យាថាលេងជេរប្តី។ យើងបានធ្វើសំបុត្រមួយសំរាប់ខ្ញុំ និងសំបុត្រមួយទៀតសំរាប់ប្រធានភូមិ។

ខ្ញុំបានធានារ៉ាប់រងថា ក្នុងករណីមានបញ្ហា អ្នកណាម្នាក់អាចប្រើលិខិតនេះដើម្បីលែងលះ។ ឆ្លងកាត់រឿងនេះ ខ្ញុំអាចយល់រឿងមួយ។ គេប្រាប់យើងថា ប្រុសនិងស្រីមានសិទ្ធិដូចគ្នា។ យើងដឹងច្បាស់ថា ប្រុសនិងស្រីមានសិទ្ធិដូចគ្នា។ ប៉ុន្តែក្នុងករណីនេះ កាលណាស្រីយល់ថាខ្លួនគេមានសិទ្ធិដូចគ្នានិងប្រុស គាត់នឹងឆក់យកចំណេញពីស្ថានភាពនេះ។ ស្រីៗស្គាល់សិទ្ធិរបស់គេ ប៉ុន្តែមិនស្គាល់ពីព្រំដែននៃសិទ្ធិនោះទេ។ នៅទីនេះ ចាប់តាំងពីមានការបណ្ដុះបណ្ដាលផ្នែកសិទ្ធិមនុស្សមក មនុស្សគិតតែនិយាយពីសិទ្ធិរបស់ខ្លួន ហើយមិនគិតពីច្បាប់ទេ"។

(លោក ល័ក្ខ អាយុ៣៨ឆ្នាំ អនុប្រធានភូមិ ទទួលបន្ទុកសន្តិសុខ សង្កាត់អង្កុល ក្រុងកែប ខេត្តកំពត)

## ឥទ្ធិពលនៃសង្គ្រាមដ៏យូរអង្វែង

សង្គ្រាមអស់ពេលជាយូរឆ្នាំបានធ្វើឱ្យសង្គមកម្ពុជាបាត់បង់ស្ថេរភាពយ៉ាងជ្រៅ។ ក្បួនខ្នាតសង្គមត្រូវបានប្រែក្រឡាស់ សាសនាត្រូវបានហាមឃាត់ និងការអប់រំត្រូវបានផ្ដល់បន្តិចបន្តួច ឬគ្មានបានផ្ដល់សោះ។

<u>ការខ្វះខាតការអប់រំ និងមនោសញ្ចេតនានៃការមិនទុកចិត្តគ្នា</u>

មនុស្សដែលមានការអប់រំជាច្រើន ត្រូវបានបាត់ខ្លួននៅក្នុងសម័យជ្រួលច្របល់នៃរបបខ្មែរក្រហម ឬបានចាកចេញទៅរស់នៅក្រៅប្រទេស។ អ្នកដែលសល់ពីរបបនេះ និងអ្នកដែលរស់នៅ ភាគច្រើនមិនបានទទួលការអប់រំមួយមានមូលដ្ឋានមាំទាំទេ។ ស្លាកស្នាមនៃអ្នកដែលបានរៀន និងរស់នៅក្នុងសម័យខ្មែរក្រហមនៅជិតជាប់យ៉ាងជ្រាលជ្រៅថែមទៀតនៅក្នុងទំនាក់ទំនងរវាងមនុស្ស។

"ចាប់តាំងពីសង្គ្រាមមក មនុស្សក្លាយទៅជាសាហាវ។ គេក្លាយទៅជាអ្នកភ្លីភ្លើតិតតែភ្លីភ្លើ។ ម្នាក់ៗចង់ឈ្នះ ម្នាក់ៗចង់បានអ្វីតែម្នាក់ឯង។ គេឃោរឃៅណាស់។ គេគ្មានការអប់រំទេ គេអវិជ្ជា។ គឺមកពីសង្គ្រាម។ នៅពេលសង្គ្រាមគេគ្មានគិតអ្វីទាំងអស់ គេដើរតាមបក្សដោយគ្មានរិះគិតថាមានហេតុផល ឬគ្មានហេតុផលឡើយ។ អ្នកដែលជឿគណបក្សខ្មែរក្រហម បែរទៅជាល្ងង់ហើយភ្លីភ្លើ។ អ្នកដែលរស់នៅក្នុងតំបន់កាន់កាប់ដោយ លន់ ណុល អាចទៅរៀនសាលាបានយូរ។ តមកគេប្រាប់ឱ្យមនុស្សបំភ្លេចអ្វីដែលគេបានចេះពីមុន។ គេថា ជាគំនិតអ្នកមូលធននិយម។ បើគេដឹងថាអ្នកណាម្នាក់បានចូលជាមួយរបប លន់ ណុល គេនឹងសំលាប់អ្នកនោះ។ ហេតុដូច្នេះហើយបានជាមនុស្សដែលមានការរៀនសូត្រជាច្រើន ឬមានការរៀនសូត្រតិចត្រូវស្លាប់។ បន្ទាប់មក វានៅសល់តែអ្នកល្ងង់។

ចំណែកខ្ញុំ មុនដំបូងខ្ញុំដើរតាមពួកខ្មែររំដោះ បន្ទាប់មកក្នុងឆ្នាំ ១៩៧៣ ខ្ញុំត្រឡប់ទៅចូលខាង លុន ណុល ព្រោះគេមានសិទ្ធិច្រើនជាង។ វាមិនសូវតឹងពេក។ បន្ទាប់មកទៀត ខ្មែរក្រហមឈ្នះ។

ខ្ញុំមិនប្រាប់ថា ខ្ញុំនៅខាង លុន ណុល ទេ។ ខ្ញុំអាចរួចជីវិតបាន។ ឥឡូវនេះខ្ញុំល្ងង់។ គេបានបង្រៀនអ្វីខ្លះដល់ខ្ញុំ ប៉ុន្តែអ្វីទាំងអស់គឺខុសនិងអាក្រក់។ តាមខ្ញុំ គេត្រូវរង់ចាំមនុស្សជំនាន់ក្រោយដើម្បីឱ្យសង្គមផ្លាស់ប្តូរ។ យើងវិញ(មនុស្សអាយុស្រករយើង) យើងនៅមានគ្រប់ប្រវត្តិក្បត់នៅក្នុងចិត្ត។ នៅមានគំនុំច្រើន ប៉ុន្តែយើងមិនអាចនិយាយពីរឿងនោះបាន។ ចាប់តាំងពីសម័យ ប៉ុល ពត មកយើងហ៊ាននិយាយពីមនោសញ្ចេតនាដែលយើងមាននៅក្នុងចិត្ត។ ស្មារតីមិនព្រមបើកបង្ហាញពីដួងចិត្ត។ មនុស្សមិនហ៊ាននិយាយឱ្យដឹងពីអារម្មណ៍របស់ខ្លួនទេ សូម្បីតែមានសេរីភាពបញ្ចេញមតិក៏ដោយ។ យើងខ្លាចមិនហ៊ាននិយាយពាក្យខុស យើងខ្លាចមានរឿងធំ ហើយធ្លាក់មករកយើងវិញ។ យើងបានរៀនឱ្យចេះខ្លាច ហើយរៀនមិននិយាយអ្វីដែលយើងមានអារម្មណ៍។ យើងបានរៀនចេះថា អ្នកជិតខាង ឬមនុស្សក្នុងគ្រួសារ អាចជាសត្រូវ"។

(លោក ខាវ អាយុ៤៦ ឆ្នាំ ឃុំចេក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង)

ដូច្នេះ នៅពីក្រោយអាការៈក្រៅនៃបើកចំហ និងសេរីភាពបញ្ចេញមតិ ការខ្លាចនិងការមិនទុកចិត្តនៅតែមាននៅក្នុងចិត្តរបស់អ្នកដែលបានរស់នៅក្នុងរយៈពេលខ្មៅងងឹត និងអ្នកដែលមិនមានការអប់រំ។

"ឥឡូវនេះមានការផ្លាស់ប្តូរ។ អ្នកដែលមិនមានការធ្វើការសិក្សាច្រើន និងអ្នកក្រតែងខ្លាចជានិច្ច ប៉ុន្តែ អ្នកដែលមានការអប់រំលែងមានការខ្លាចហើយ។ ពួកគេដឹងថាគេមានសិទ្ធិ។ គេពិបាកនឹងបំភិតបំភ័យមនុស្សមានការអប់រំ។ គេមានទម្លាប់រស់នៅក្នុងការខ្លាចយូរលង់មកហើយ។ កាលនៅសម័យ ប៉ុល ពត ក្មេងៗគ្មានការអប់រំទេ។ អ្វីដែលគេបានឃើញ បានចេះគឺមិនល្អទេ។ ឥឡូវនេះគេជាមនុស្សធំអស់ហើយ ហើយគេមិនចេះអ្វីសោះ។

អ្នកដែលជាមនុស្សធំ កាលពីសម័យ ប៉ុល ពត តែងតែរស់នៅក្នុងសេចក្តីខ្លាច ដែលគេមាននៅពេលនោះ។ ពួកគេរស់នៅក្នុងសេចក្តីភ័យខ្លាចរហូតដល់ឆ្កួត"។

(លោក ឡៃ អាយុ៥៧ឆ្នាំ សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

" ស្វ័យត្រួតពិនិត្យ គឺលទ្ធផលនៃសម័យខ្មែរក្រហម។ គឺហាក់ដូចជាខ្មោចដែលតែងតែតាមមនុស្សជានិច្ច។ ពួកគេនៅខ្លាចមិនហ៊ាននិយាយ"។

(លោក ព្រុក អាយុ ៥៣ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

ក្បួនច្បាប់ក្នុងសង្គមប្រែក្រឡាស់ : ក្មេងខ្លះមិនគោរពចាស់ទុំទេ។

"នៅសម័យខ្មែរក្រហម គេប្រាប់ឱ្យក្មេងៗឈប់ទទួលស្គាល់ឪពុកម្តាយ។ ឪពុកម្តាយ ត្រូវបានចាត់ទុកដូចជាសត្រូវ។ គ្មានការអប់រំ គ្មានគោរពឪពុកម្តាយ។ នៅមានស្លាកស្នាមនៃការអប់រំ

បែបនេះនៅក្នុងស្មារតីរបស់មនុស្សដែលនៅក្មេងកាលពីសម័យខ្មែរក្រហម។ ពួកគេមិនគោរពឪពុកម្តាយទេ"។

(លោក តុន អាយុ ៥៣ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

## មនុស្សជំនាន់ក្រោយ

ថ្វីបើមានកិច្ចប្រឹងប្រែងយ៉ាងសម្បើមក្នុងការកសាងសាលារៀននៅទូទាំងប្រទេស ក៏រិតសិក្សារបស់យុវជនក្មេងៗនៅខ្សោយណាស់ ជាពិសេសនៅតំបន់ជនបទ។ អនាគតក្មេងជំនាន់ក្រោយ (ប្រហែល៥០ភាគរយនៃប្រជាជនមានអាយុតិចជាង១៦ឆ្នាំ) គឺជាការបារម្ភរបស់ឪពុកម្តាយដែលរស់នៅក្នុងតំបន់ទីក្រុង ឬជុំវិញទីក្រុង។ ក្រោយពីច្រើនឆ្នាំនៃវិបរិតមក យុវជនក្មេងៗគ្មានមូលដ្ឋាននៃការអប់រំជាលក្ខណៈគ្រួសារ និងប្រពៃណីរឹងមាំទេ។

## ការអប់រំ :

"បញ្ហា គឺការអប់រំយុវជនក្មេងៗ។ ពួកគេមានការអប់រំមិនបានល្អ។ ការអប់រំនៅសាលារៀនខ្សោយ។ គេគ្មានសៀវភៅ។ ឥឡូវនេះ មានឥទ្ធិពលមិនល្អពីវីឌីអូតាមភូមិ។ ក្មេងៗមើលភាពយន្តអាសអាភាសដែលមានរូបភាពចាប់រំលោភ។ គឺចង្រៃណាស់។ ខ្ញុំឃើញថា មនុស្សល្ងង់ និងគ្រោះថ្នាក់។ មានវិទ្យុ ប៉ុន្តែមានមនុស្សតិចណាស់ ដែលស្តាប់វិទ្យុហើយយល់ពិតប្រាកដ។ គេត្រូវមានការអប់រំល្អ ដើម្បីយល់ច្បាស់។

(លោក ចាន់ដា អាយុ៦៨ឆ្នាំ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្ត កំពត-ភូមិថ្មី)

## ក្មេងពាល :

"ពីមុន មានប្រពៃណី។ មនុស្សគោរពគ្នា និងគោរពមនុស្សចាស់ជាង។ ចាស់ទុំបង្រៀនក្មេងៗ។ ឥឡូវនេះ ពួកក្មេងៗដើរតាមពួកបងធំ ហើយពួកក្មេងៗទាំងនេះនៅក្រវែលតាមរោងវីឌីអូ និងតុប៊ីយ៉ា។ ពីមុនក្មេងៗគោរពមនុស្សចាស់ ឥឡូវនេះគេស្តាប់ក្មេងៗ។ ពួកគេលែងគោរព និងលែងខ្លាចអ្វីទាំងអស់។ ឆ្នាំមុននគរបាលអាចចាត់ការបាន ហើយចាប់អ្នកខ្លះដាក់គុក។ នៅក្នុងភូមិមានមនុស្សមួយផ្នែកជាអ្នកមាន និងមួយផ្នែកទៀតជាអ្នកក្រ។ អ្នកនៅក្នុងភូមិ ចំណោមអ្នកមានធ្វើការនៅទីក្រុង គេជាពាណិជ្ជករ ឬមន្ត្រីរាជការ។ កូនពួកគេចូលជាមួយបងធំ។ មានតែកូនអ្នកក្រទេដែលត្រូវបានចាប់ខ្លួន។ កូនអ្នកមានមិនដែលមានទោសទេ។ ពួកនេះនៅតែធ្វើដដែល ព្រោះគេគិតថា គ្មានអ្នកណាអាចប៉ះពាល់គេបាន"។

(លោក ខាវ អាយុ ៤៦ឆ្នាំ ឃុំចេក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង)

**ការបាត់ការគោរព រវាងមនុស្សជំនាន់មួយទៅជំនាន់មួយ ៈ**

"ចាប់តាំងពីឆ្នាំ១៩៩៣មក មានបញ្ហាពីរឿងក្មេងៗ។ ពួកគេក្លាយជាមនុស្សអាក្រក់។ គេលែងស្តាប់ហើយ។ គេគិតថាគេមានសិទ្ធិមនុស្សនៅខាងគេ។ គេមិនគិតថា អ្នកដទៃក៏មានសិទ្ធិដែរទេ។ សម្រាប់ពួកគេ មានសិទ្ធិគឺមានអំណាច។ ក្មេងៗនិយាយថា គេមានសិទ្ធិ ហើយគេប្រើសិទ្ធិដូចជាអំណាចមួយ។ គេនិយាយថាៈ "ខ្ញុំមានសិទ្ធិ ខ្ញុំមានសិទ្ធិលើអ្នកដទៃ"។ នៅទីនេះ ក្នុងពេលមួយនោះគេឃើញមានអង្គការសិទ្ធិមនុស្សការពារចោរ ហើយមិនបានជួយសង្គ្រោះអ្នករងគ្រោះទេ។ កាលណាពួកក្មេងៗឃើញដូច្នេះ គេគិតថា ពួកគេមានអ្នកការពារបើគេមានកំហុស"។

(លោក វណ្ណាត អាយុ ៥២ឆ្នាំ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

"នៅឆ្នាំ១៩៧៩ បន្ទាប់ពី ប៉ុល ពត មានទំនាស់រវាងមនុស្ស។ ពេលនោះ មិនមានអាហារច្រើនសម្រាប់ពួកគេទេ គេមិនឈ្លោះគ្នាច្រើនទេ គេគ្មានគិតអ្វីទេ។ ឥឡូវនេះមនុស្សកាន់តែមានហើយគេគិតច្រើន។ ពីមុនមានគំនិតតិច។ ឥឡូវមានសាលារៀន វីដេអូ ម៉ូតូ ម៉ាស៊ីនកិនស្រូវ។ មានមនុស្សដែលយល់ពីគំនិតថ្មីៗ ហើយក៏មានអ្នកផ្សេងទៀតដែលមិនយល់។ អ្នកដែលមិនយល់មិនចង់គោរព។ អ្នកខ្លះសេរីពេក។ ប៉ុន្តែ ច្បាប់គឺច្បាប់។ ឥឡូវនេះ គេអាចទៅណាដោយសេរី។ គ្មានអ្នកណាអាចចាប់យើងទេ។ យើងមានសិទ្ធិ ប៉ុន្តែគេត្រូវគិតគោរពអ្នកនៅក្នុងសង្គមដែរ។ នៅទីនេះមានបញ្ហាពីរឿងក្មេងៗ។ ក្មេងៗមើលវីឌីអូមួយយប់ៗ។ មានវីដេអូអាក្រក់ដែលមានហិង្សានិងការរួមរក្ស និងមានរឿងនៅក្នុងប្រទេសអ្នកមាន។ ពួកក្មេងៗចេះដឹងរឿងទាំងអស់នេះហើយ គេមិនស្តាប់យើងទៀតទេ"។

(លោក ម៉ី អាយុ ៥៦ឆ្នាំ ប្រធានសង្កាត់ សង្កាត់អង្កុល ក្រុងកែប ខេត្តកំពត)

ទំនាក់ទំនងនៃការគោរពគ្នារវាងមនុស្សចាស់ មនុស្សក្មេងនៅក្នុងគ្រួសារលែងមានអនុវត្តទៀតហើយនៅទីនេះ។ ចៅប្តឹងទៅយាយនៅតុលាការ។

"យាយព្រំ ឱ្យដីធ្វើលំនៅដ្ឋានដល់កូនស្រីគាត់។ ចៅស្រីម្នាក់ចង់សង់តូបទំនិញនៅតាមចិញ្ចើមផ្លូវ។ ចៅស្រីម្នាក់ទៀតបាននិយាយថា ដីនោះជារបស់ខ្លួន។ យាយបាននិយាយថាមិនពិតទេ។ ដោយហេតុថាមានរឿងច្រើនពេក យាយក៏ប្រាប់ឱ្យកូនគាត់ទាំងអស់ចេញពីដីនោះ។ ចៅៗស្រីរបស់គាត់ក៏ប្តឹងទៅតុលាការ។ ពីមុនកូនស្តាប់ឪពុកម្តាយ ហើយមិនហ៊ានតមាត់នឹងឪពុកម្តាយទេ។ ពួកក្មេងៗគ្មានការគោរពទេ"។

(លោក ជាល អាយុ៥៦ឆ្នាំ ប្រធានភូមិ ឃុំនគរធំ ស្រុកសៀមរាប ខេត្តសៀមរាប)

## ទម្លាប់ប្រពៃណី

ចាស់ទុំម្នាក់ៗ រិះគន់ប្រព័ន្ធអប់រំកម្ពុជា ដោយផ្អែកលើការសូត្រតាមគ្នា ហើយដែលមិនអនុញ្ញាតឱ្យបណ្តុះគំនិតរិះគន់។

"ចាប់តាំងពីតូចមក គេបង្រៀនក្មេងៗឱ្យនៅស្ងាត់ស្ងៀម។ កាលណាមនុស្សធំនិយាយ ក្មេងៗត្រូវនៅស្ងៀម។ ឪពុកម្តាយមិនពន្យល់កូនទេ។ កូនរៀនដោយខ្លួនឯង។ គេមិនហ៊ាននិយាយ មិនហ៊ានធ្វើចលនាច្រើនពេក ទេដោយខ្លាចគេស្តីឱ្យ។ គេមិនរៀនពីគំនិតរិះគន់ទេ។ នៅពេលគេធំ បើគេមានបញ្ហាជាមួយអ្នកណាម្នាក់ ហើយបើនៅក្នុងពេលប្រជុំសំរុះសំរួលគេសុំឱ្យនៅស្ងៀមស្ងាត់ គេនៅស្ងៀមស្ងាត់តែម្តង។ គឺជាប្រពៃណី។ គេបង្រៀនក្មេងៗ ធ្វើតាមដោយមិនបាច់គិត"។

(លោក តុន អាយុ៥៣ឆ្នាំ ក្រុងស្វាយរៀង ខេត្តស្វាយរៀង)

## សេចក្តីប្រាថ្នា និងសំណូមពរសម្រាប់អនាគត

ទន្ទឹមនឹងប្រធានភូមិមួយចំនួនដែលយើងបានជួបក្នុងពេលសន្ទនាថា ខ្លួនឯងពេញចិត្តនឹងរបៀបខ្លួនដោះស្រាយ និងបង្កាទំនាស់ក្នុងមណ្ឌលរបស់ខ្លួន ប្រធានភូមិដទៃទៀត(ជាពិសេសអ្នកនៅក្នុងតំបន់ទីក្រុង ជុំវិញទីក្រុង ឬទីផ្សារធំៗ)បានសារភាពចំពោះមុខយើងថា គេខ្វះមូលដ្ឋានវិធីសាស្ត្រ និងចំណេះដឹងដើម្បីឆ្លើយតបទៅនឹងតម្រូវការថ្មីៗរបស់ប្រជាជន។

"ខ្ញុំចង់បានអត្ថបទច្បាប់ ដើម្បីដឹងថាត្រូវដោះស្រាយបញ្ហាយ៉ាងណា។ ខ្ញុំចង់ធ្វើទៅតាមច្បាប់។ ឥឡូវនេះ ខ្ញុំធ្វើតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ប៉ុន្តែជួនកាល ពេលណាខ្ញុំមិនដឹងថាធ្វើដូច្នេះតើត្រូវឬខុសនោះ ខ្ញុំចូលចិត្តប្រាប់មនុស្សឱ្យនៅស្ងៀម កុំឱ្យឈ្លោះគ្នាទៀត។ ខ្ញុំមិនចង់លើកឱ្យមានរឿងតទៅទៀត។ លើសនេះទៅទៀត បើខ្ញុំដាក់សំណើទៅអ្នកណាម្នាក់ ហើយខ្ញុំមិនបានដាក់ទៅម្នាក់ទៀត ខ្ញុំអាចត្រូវបានគេរិះគន់។ បើមានច្បាប់ គេអាចនិយាយថា មកពីច្បាប់ គឺចប់។ គេមិនអាចថាជាគំនិតផ្ទាល់ខ្លួន និងថាយើងលំអៀងទៅអ្នកណាម្នាក់ទេ។ យើងថាៈ "គឺច្បាប់មិនមែនយើងទេ"។ លើសពីនេះទៅទៀតច្បាប់ផ្តល់គំនិតដើម្បីដោះស្រាយបញ្ហា។ មានករណីដែលបានពន្យល់រួច គេអាចរកករណីណាមួយដែលស៊ីនឹងបញ្ហា ហើយគេអាចស្នើដំណោះស្រាយមួយយោងតាមច្បាប់។

(លោក សាម៉ុន អាយុ ៤២ឆ្នាំ ប្រធានភូមិ-អតីតខ្មែរក្រហម ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

"គេត្រូវមានការអប់រំ។ ត្រូវមានមេដឹកនាំដែលមានការអប់រំ។ យើងរស់នៅក្នុងព្រៃយូរលង់មកហើយ។ យើងចង់ចេញពីភាពងងឹតអន្ធការទៅរកពន្លឺ។ មេដឹកនាំរបស់យើងត្រូវតែយុត្តិធម៌ ហើយ

មិនត្រូវលំអៀងទៅរកពួកក្រុមរបស់ខ្លួនទេ។ អ្នកក្រុមម្នាក់ៗរស់នៅក្បែរអ្នកដឹកនាំ ពួកគេមានតែខ្លួនឯង ហើយល្ងង់ទៀត"។

(អ្នកស្រី ស៊ីង អាយុ ៤៧ឆ្នាំ-អតីតខ្មែរក្រហម សង្កាត់ពងទឹក ក្រុងកែប ខេត្តកំពត)

"នៅទីនេះ គ្មានបញ្ហាច្រើននៅក្នុងភូមិទេ។ មនុស្សសប្បាយចិត្តនឹងរបៀបខ្ញុំជួយគេ កាលណាមានបញ្ហា។ ខ្ញុំមិនត្រូវការអ្វីទេ។ ទីនេះ យើងដោះស្រាយតែបញ្ហាដែលមិនចូលក្នុងក្របខ័ណ្ឌច្បាប់របស់រដ្ឋាភិបាល។ យើងមានតែរឿងតូចៗ ដែលដោះស្រាយដោយពិភាក្សាគ្នា"។

(លោក មន អាយុ ៥៥ឆ្នាំ ប្រធានភូមិ ឃុំពពាក់ ស្រុកស្វាយទាប ខេត្តស្វាយរៀង)

ប្រធានភូមិម្នាក់ដែលចង់ឱ្យគេគោរព ដឹងថាទម្រង់ថ្មីនៃអំណាចគឺមិនមែនសំអាងលើការបំភិតបំភ័យទៀតទេ ប៉ុន្តែលើចំណេះវិជ្ជា។

"ខ្ញុំអាចធ្វើអ្វីដែលខ្ញុំអាច ហើយខ្ញុំដឹងថាវាមិនសុក្រឹត្យទេ។ ខ្ញុំមិនមែនដោះស្រាយតែគ្រប់បញ្ហាទេ។ ខ្ញុំត្រូវការបណ្តុះបណ្តាល។ ពីមុនខ្ញុំប្រើឃ្លាបូរាណ ប៉ុន្តែខ្ញុំសំរេចថា វាមិនគ្រប់គ្រាន់ទេក្នុងពេលឥឡូវនេះ។ មនុស្សប្តឹងផ្តល់ច្រើនជាងពីដើម។ ខ្ញុំត្រូវការបច្ចេកទេសច្បាស់លាស់ជាង ជាក់លាក់ជាង ដូចជាបទបញ្ជា ច្បាប់ ដែលអាចអនុវត្តនៅមូលដ្ឋាន។ ខ្ញុំល្ងង់ ចំណេះវិជ្ជាខ្ញុំមានតិច ប៉ុន្តែសេចក្តីប្រាថ្នាចង់រៀនរបស់ខ្ញុំធំ។ ល្អត្រូវធ្វើការសំរុះសំរួលនៅភូមិ ប៉ុន្តែយើងមិនសូវប្រាកដថា ត្រូវធ្វើយ៉ាងណាទេ។ ដើម្បីរក្សាអំណាចត្រូវធ្វើឱ្យគេគោរព។ ឥឡូវនេះ គេមិនអាចធ្វើឱ្យគេខ្លាចដើម្បីរក្សាអំណាចទេ។ បើខ្ញុំមានចំណេះដឹង ហើយបើខ្ញុំយុត្តិធម៌ គេនឹងគោរពខ្ញុំ"។

(លោក វណ្ណាត អាយុ ៥២ឆ្នាំ ប្រធានភូមិ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល)

អតីតខ្មែរក្រហមម្នាក់ដែលបានរស់នៅច្រើនឆ្នាំក្នុងជំរុំក្នុងព្រៃ រកឃើញពិភពថ្មី: ពិភពលោកសន្តិភាពដែលធ្វើឱ្យមានក្តីសង្ឃឹមក្នុងជីវិតថ្មី និងការបើកចំហរទៅរកពិភពខាងក្រៅ។

"ឥឡូវនេះ ខ្ញុំឃើញថាអ្វីៗសុទ្ធតែល្អនៅទីនេះ។ ខ្ញុំមិនដែលឃើញមនុស្សច្រើននៅជាមួយគ្នាដូច្នេះទេ។ ខ្ញុំសប្បាយនឹងនិយាយទៅកាន់ជនបរទេសដូចអ្នក។ គឺលើកទីមួយហើយ។ ពីមុននៅក្នុងភ្នំ អ្វីៗងងឹតឈឹង។ ឥឡូវនេះ កាលណាគេនិយាយ គេអាចចូលសន្ទនាជាមួយអ្នកដទៃ គឺច្បាស់។ យើងចេញពីម្លប់ងងឹត ហើយយើងចង់មើលអ្វីៗដោយគ្មានខ្លាច។ ពីមុនកាលខ្ញុំនៅជាទាហ៊ាន ហើយនៅពេលខ្ញុំចុះមកដីរាប ខ្ញុំមានភ្នែកពីរពីមុខនិងភ្នែកពីរពីក្រោយ។ ខ្ញុំខ្លាចគេសម្លាប់។ ឥឡូវនេះ ខ្ញុំចង់ឃើញអ្វីដោយច្បាស់"។

(លោក ក្រឹម អាយុ៥៤ឆ្នាំ ឃុំត្រពាំងភាំង ស្រុកឈូក ខេត្តកំពត-ភូមិថ្មី)

# សំយោគ

*ចាប់តាំងពីរៀបការបោះឆ្នោតដោយសេរីនៅឆ្នាំ១៩៩៣មក ប្រទេសកម្ពុជាបានធ្វើដំណើរឆ្ពោះទៅរកសន្តិភាព និងការបើកទ្វារចំហទៅរកពិភពលោកខាងក្រៅ ។ ក្នុងកម្លុងទសវត្ស១៩៩០ មូលដ្ឋានគ្រឹះចុងក្រោយរបស់ខ្មែរក្រហម បានសុំចុះចាញ់ម្តងមួយៗ ដោយគេនៅចាំតែមើលអនាគតក៏ត្រចះមួយរបស់កម្ពុជា ។*

*នៅក្នុងភូមិនានា លក្ខណៈនៃទំនាស់មិនបានផ្លាស់ប្តូរ បើធៀបទៅនឹងសម័យមុន ៖ ទំនាស់ដីធ្លី និងជម្លោះប្តីប្រពន្ធ និងជម្លោះជាមួយអ្នកជិតខាង ។ ថ្វីបើនីតិវិធីដែលត្រូវអនុវត្តនៅក្នុងពេលដោះស្រាយទំនាស់ដោយអ្នកសំរុះសំរួលខាងក្រៅប្រហាក់ប្រហែលគ្នានៅក្នុងកន្លែងអង្កេតនានា( បណ្តឹងរបស់ភាគីណាមួយ ការប្រជុំសំរុះសំរួល បញ្ហាដែលដំណាលដោយភាគីម្នាក់ៗ ការទូន្មានរបស់អ្នកសំរុះសំរួល និងការតាក់តែងលិខិតសន្យា) យើងបានរកឃើញមានការខុសគ្នាយ៉ាងច្រើន នៅក្នុងឥរិយាបថរបស់អ្នកសំរុះសំរួលទៅតាមទីកន្លែងណាជាកន្លែងដាច់ស្រយាល ឬទីកន្លែងក្នុងក្រុង ឬនៅជិតទីក្រុង ។ ឥរិយាបថរបស់អ្នកសំរុះសំរួលនេះមានចាប់ពីរបៀបអាជ្ញានិយមរហូតដល់ទៅការមិនធ្វើសកម្មភាពអ្វីទាំងអស់ ដោយឆ្លងកាត់តាមការជៀសវាង ការបដិសេធ ការបំបិទ ការព្រមព្រៀងគ្នាជាមិត្តភាព អនុគ្រោះនិយម ការបញ្ជូនរឿងទៅអាជ្ញាធរថ្នាក់លើ ឬការប្តឹងទៅតុលាការ... ។*

*ដោយមានការបើកទ្វារចំហទៅរកពិភពលោកខាងក្រៅ គោលការណ៍សិទ្ធិមនុស្សត្រូវបានផ្សព្វផ្សាយតាមវិទ្យុ ឬតាមការបណ្តុះបណ្តាលនៅកន្លែងខ្លះ ។ គោលគំនិតថ្មីៗទាំងនេះ ជ្រាបចូលក្នុងភាសានិយាយរបស់អ្នកភូមិក៏ដូចជាអ្នកសំរុះសំរួលបន្តិចម្តងៗ ទោះបីពេលខ្លះគេមិនសូវយល់ច្បាស់ពីគោលគំនិតទាំងនេះក្តី ។*

*សង្គមកម្ពុជាសព្វថ្ងៃនេះ ព្យាយាមទាំងលំបាកដើម្បីធ្វើឱ្យមានភាពស្អិតរមួតជាមួយបំណែកខុសៗគ្នានៃប្រវត្តិសាស្ត្រថ្មីដ៏ច្របូកច្របល់មួយ រវាងសំណល់ប្រពៃណីដែលបានវិចវិលយ៉ាងខ្លាំង ស្លាកស្នាមនៃការអនុវត្តន៍កុម្មុយនិស្តជ្រុលនិយម និងគោលគំនិតថ្មីដែលនាំមកដោយពួកបស្ចិមប្រទេស ។*

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

កាលណាគេធ្វើដំណើរក្នុងពេលបច្ចុប្បន្ន កាត់តាមភូមិនានានៅស្រុកស្រែរបស់ខ្មែរ គេហាក់ដូចជាឃើញថា គ្មានអ្វីផ្លាស់ប្តូរច្រើនពីសម័យបុរាណទេ[១៥៥] គឺថា ផ្ទះសង់ដោយមានសរសេរតាមគំរូពីដើម។ អ្នកស្រែដាំដំណាំក្នុងស្រែ ដោយប្រើបច្ចេកទេសកសិកម្មដូចគ្នានឹងដូនតារបស់គេដែរ គេប្រើអង្រុតនិងសំណាញ់ដើម្បីនេសាទដូចដូនតាគេដែរ។

ក៏ប៉ុន្តែ ក្នុងរយៈពេល៤០ឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាចូលក្នុងឆាកសង្គ្រាម ទុរ្ភិក្ស ឬរបបនយោបាយជ្រុលនិយមដែលមានឆន្ទៈនឹងកសាងពិភពលោកថ្មី ក្រោយពីបានព្យាយាមបំបាក់រចនាសម្ព័ន្ធបុរាណ។

ដូច្នេះ ចាប់តាំងពីឆ្នាំ១៩៧០ ប្រទេសបុរាណ និងមិនសូវបើកចំហទៅរកពិភពលោកខាងក្រៅនេះ ត្រូវបានធ្លាក់ចូលយ៉ាងកំរោលទៅក្នុងប្រវត្តិសាស្ត្រមួយ ដែលគ្រោះមហន្តរាយ និងគោលគំនិតបានទៅជ្រុលហួសពីអ្វីដែលប្រទេសនេះអាចទ្រាំទ្របាន ដូចជាផលវិបាកនៃសង្គ្រាមត្រជាក់ បទពិសោធន៍សមូហភាពនៃទ្រឹស្តីម៉ាក្ស។

ក្រោយពីរយៈពេលច្របូកច្របល់នេះ ប្រទេសកម្ពុជាចាប់កសាងឡើងវិញ ដោយផ្អែកលើមូលដ្ឋាននៃគ្រឹះវប្បធម៌ចាស់ ដែលប្រទង់ប្រទាញគ្នារវាងស្នាមរបួសនៃអតីតកាលថ្មីៗដ៏ឈឺចាប់ និងការបើកចំហយ៉ាងលឿនទៅរកពិភពខាងក្រៅ ដោយរូបភាពដែលបញ្ជូនមកដោយអង្គការអន្តរជាតិជាច្រើន និងប្រព័ន្ធផ្សាយពត៌មាន សន្យាថានឹងធ្វើឱ្យកើតជាពិភពមួយដ៏ប្រសើរសំរាប់សតវត្សទី២១។

<u>សង្គមចាស់បុរាណ</u>

នៅក្នុងរយៈកាលដែលហៅថា"បុរាណ"(មុនឆ្នាំ១៩៧០)នេះ យើងមិនបានរកឃើញនូវការអនុវត្តន៍ដែលមានថែងជាក្បួនជាក់លាក់ពីការដោះស្រាយ និងការបង្កាទំនាស់ទេ ប៉ុន្តែ ផ្ទុយទៅវិញ យើងបានរកឃើញនូវការប្រព្រឹត្តទៅតាមកាលៈទេសៈនិងមិននឹងថ្កល់។ ដូច្នេះ យើងហាក់ដូចជាឃើញថា ផ្ទុយពីរបៀបចំជីវភាពក្នុងសង្គម ប្រពៃណីបែរជាអនុគ្រោះឯកត្តនិយមទៅវិញ ដោយអ្វីៗលើកតំកើងការគេចកុំឱ្យមានបញ្ហានិងការស្វែងរកការព្រមព្រៀងជាផ្លូវមួយ។ ការខ្លាចអាជ្ញាធរ និងវត្តុសក្តិសិទ្ធិ ជាចំណែកមួយនៃការបង្កាទំនាស់ រីឯការខ័ណ្ឌក្រុមគ្រួសារឱ្យនៅដាច់ពីអ្នកដទៃ និងការនៅរាយប៉ាយក៏ជាការមួយនាំឱ្យមានបង្ការទំទាស់ដែរ។

---

[155] ការចាប់អារម្មណ៍លើជីវភាពមិនផ្លាស់ប្តូរនេះ គឺឃើញគាប់ជួននឹងកាយវិការបច្ចុប្បន្ននៃអ្នកនេសាទ និងអ្នកស្រែខ្មែរ និងកាយវិការរបស់ បុព្វជនខ្មែរ ដែលគេឆ្លាក់នៅក្នុងរូបចម្លាក់ក្រឡោតនៅអង្គរ។

## ការផ្លាស់ប្តូរយ៉ាងក្រឡាប់ចាក់

ចាប់ពីឆ្នាំ១៩៧០មក និងជាពិសេសទៅទៀត ចាប់ពីឆ្នាំ១៩៧៥ ទៅ ១៩៧៩ ទ្រឹស្តីម៉ាក្ស ជំរុញឱ្យមានរបបសម្ពហភាពនិយម ជាជំរើសតែមួយដែលអាចធ្វើទៅបាន ដើម្បី"ធ្វើឱ្យប្រទេសកម្ពុជាចេញពីរបបសក្តិភូមិ"។ ទ្រឹស្តីនេះ យកមកបំពាក់ឱ្យប្រជាពលរដ្ឋ ដោយក្រុមជ្រុលនិយមខ្មែរមួយ គឺខ្មែរក្រហម។ អ្នកអាជ្ញានិយមម៉ាក្ស ម្នាក់ដាក់បង្គាប់ប្រព័ន្ធសម្ពហភាព និងបង្ខិតបង្ខំមួយទៅលើសង្គមមួយដែលចូលចិត្តការរៀបចំតាមបែបរស់នៅជាក្រុម១ដាច់ពីគ្នា ហើយដែលម្នាក់១គិតតែពីខ្លួនឯង។ ការគោរពចំពោះអ្នកណាម្នាក់ដែលទទួលស្គាល់ថាជាមេ ជារៀមច្បង និងការអនុវត្តរហូតដល់កំរិតរកយល់មិនបាននូវទស្សនៈវិជ្ជាមួយដែលយល់មិនច្បាស់ ជាចំណែកមួយធ្វើឱ្យរលំដួលរបបភេរវកម្មរបស់ខ្មែរក្រហមដែលជាអង្គការអនាមិក និងតាំងខ្លួនជាអស្សារ្យរបស់បក្ស។ នៅចំណុចនេះទៀត គឺការខ្លាចដែលក្លាយទៅជាការភិតភ័យដែលបង្កាទំនាស់ជាយថាហេតុ និងដែលបង្អាក់គំនិតផ្តួចផ្តើមទាំងឡាយណាដែលអាចនាំឱ្យប្រឆាំងនឹងមនោគមវិជ្ជាថ្មី : បដិវត្តន៍ចេញដំណើរហើយ១ប្រកាន់ខ្ជាប់យកមាគ៌ាបដិវត្តន៍ បដិវត្តន៍រំលំតម្លៃប្រពៃណីទាំងអស់ និងជីករំលើងគ្រឹះនៃសង្គម។

## ការកសាងប្រទេសជាថ្មី

នៅឆ្នាំ១៩៧៩ ការរលំដួលនៃរបបខ្មែរក្រហម អ្នកនៅសល់ពីរបបនេះប្រាថ្នាបោះបង់ចោលអ្វី១ដែលជាការអនុវត្តក្នុងរបបនោះ ហើយត្រឡប់មករកគំរូបូរាណវិញ ទោះបីប្រព័ន្ធសម្ពហភាពថ្មីដែលមានតែសំបកក្រៅ ត្រូវបានចាត់តាំងឡើងដោយរដ្ឋាភិបាលថ្មី ហាក់ដូចជាដំណើរការទៅបានក្តី។

គេចាប់អនុវត្តរបៀបសំរុះសំរួលទំនាស់តាមបែបបូរាណឡើងវិញ ប៉ុន្តែគេឃើញមានការផ្លាស់ប្តូរយ៉ាងជ្រៅនៅក្នុងការប្រព្រឹត្តរបស់សង្គម។ បើគ្រឹះចាស់របស់ប្រពៃណីនៅតែមានការរិចរិលនៃសំបកគ្រឹះទាំងនេះ និងការបាត់បង់ខ្លះនូវចំណុចជាគោលចារឹកមួយចំនួននៅតែបង្កើនមនោសច្ចេតនាពិបាកកំណត់និងស្រពិចស្រពិល ជាហេតុធ្វើឱ្យខូចខាតដល់ការរួបរួមរបស់សង្គម។

ដូច្នេះ ជាឧទាហរណ៍ ការខ្វល់ខ្វាយខ្លាចបាត់បង់ឯករាជ្យភាពដែលជារបស់មួយមានតម្លៃបំផុតសំរាប់គ្រួសារកើនឡើងជាទ្វេធ្វើឱ្យគេមានការមិនទុកចិត្តជ្រុលហួសចំពោះអ្នកដទៃ។

## ការចំហទៅកាន់ពិភពខាងក្រៅ

នៅឆ្នាំ១៩៩២ សហប្រជាជាតិ និងអង្គការអន្តរជាតិបានចូលមកប្រទេសកម្ពុជាដោយនាំមកជាមួយនូវគោលគំនិតបស្ចឹមប្រទេស។ ចំណុចជាគោលចារឹកថ្មី១ជាក់ស្តែង ការសន្យានឹងធ្វើឱ្យបានពិភពមួយដ៏ប្រសើរ

ជូនកាលអន្ទងចិត្តនិងធ្វើឱ្យប្រជាជនកម្ពុជាបាត់បង់ស្ថេរភាព ដោយមិនពិចារណាឡើងវិញនូវការអនុវត្តនៃផ្នែកសង្គម វប្បធម៌ ដែលបានចាក់ឫសយ៉ាងជ្រៅដល់ផ្នត់គំនិតរួមរបស់មនុស្ស។

សព្វថ្ងៃនេះ ការត្រឡប់មកវិញនូវសន្តិភាព និងភាពចាំបាច់ជាបន្ទាន់ដើម្បីចូលរួមក្នុងឆាកប្រជាជាតិនានា កំណើនប្រជាសាស្ត្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ការបញ្ចូលនូវគោលគំនិតថ្មីៗ ដូចជាគោលគំនិតសិទ្ធិមនុស្ស ធ្វើឱ្យចុះខ្សោយម្តងទៀតនូវគ្រឹះសង្គមកម្ពុជា។ ថ្វីបើតម្លៃខ្លះដែលនាំមកនូវសេរីភាពបុគ្គលបានទទួលការចូលចិត្តនៅតាមភូមិ តម្លៃនោះមិនមានតុល្យភាពជាមួយនឹងប្រតិកម្មស្វ័យប្រវត្តិផ្នែកវប្បធម៌ទេ។ ដូច្នេះ អំណាចរបស់មេដឹកនាំគណបក្សនយោបាយជាដើម គ្រាន់តែជាការប្រើពាក្យថ្មី ជាការដាក់ជំនួសអំណាចជាប្រពៃណីរបស់ប្រធានភូមិ ហើយក៏ដូចជាសម័យដើមដែរ អំណាចនេះឈរលើមូលដ្ឋាននៃបណ្តាញក្រៅផ្លូវការដែលមានលក្ខណៈជាគ្រួសារ។

ចាប់ពីពេលនេះតទៅដើម្បីដោះស្រាយជម្លោះ និងបង្ការទំនាស់នៅមូលដ្ឋាន អ្នកដែលត្រូវទទួលភារៈធ្វើជាអ្នកសំរុះសំរួល ព្យាយាមប្រមែប្រមូលសំណល់ប្រពៃណី ដែលមានរូបភាពមិនច្បាស់ ទៅរួមជាមួយតម្រូវការថ្មី និងសេចក្តីប្រាថ្នារបស់ប្រជាជន ដែលបើកចំហទទួលគោលការណ៍មកពីក្រៅ(អត្ថបទច្បាប់ គោលការណ៍សិទ្ធិមនុស្ស)។ ដោយភាគច្រើនជាមនុស្សមានការអប់រំតិច អ្នកសំរុះសំរួលមានចង្កោមបច្ចេកទេសស្ទួចស្តើងខាងការសំរុះសំរួល ហើយជារឿយៗអ្នកទាំងនេះលែងមានសារៈសំខាន់នៅចំពោះមុខស្ថានការណ៍ថ្មីៗ ជាពិសេសក្នុងដំណោះស្រាយវិវាទដីធ្លី។ នៅក្នុងតំបន់ទីក្រុង និងជុំវិញទីក្រុង ពួកគេមើលឃើញថាឥទ្ធិពលរបស់ខ្លួនចុះថយ ហើយធម្មានុរូបភាពរបស់ខ្លួនជាបញ្ហាមួយដែលនៅមិនទាន់បានឆ្លើយដាច់ស្រេចនៅឡើយ។ កំណែទំរង់ឃុំសង្កាត់ខាងមុខសំរេចថានឹងឱ្យស្វ័យភាព និងអំណាចដល់ឃុំ-សង្កាត់ច្រើនទៀត។

ជាប្រទេសសម្បូណ៌ទៅដោយទន្លេបឹងបួរ ប្រទេសកម្ពុជាតែងតែបានរកដំណោះស្រាយ ដែលស្របគ្នាជាធ្លុងមួយដើម្បីយល់បញ្ហារបស់គេ គឺបណ្តោយតាមទិសដៅនៃចរន្តដែលខ្លាំងជាង ដើរតាមចរន្តប្រវត្តិសាស្ត្រ ដោយសាកល្បងយកទម្រង់ដែលមកពីក្រៅប៉ុន្តែដោយមិនបដិសេធសភាពប្រែប្រួលដើមរបស់វា ដែលចាំតែរលាយ និងរំលាយភាពខុសគ្នា និងការជំទាស់។ ជាប្រទេសមួយដែលស្មុគ្រស្មាញមិនងាយបានជួបដោយសារសភាពមិនស្ថិតស្ថេររបស់ខ្លួន ធម្មជាតិរបស់ប្រទេសនេះជុំញឱ្យមានការនាំគ្នានៅក្នុងអ្វីដែលហាក់ដូចជាការវិភាគដែលមានហេតុផល។

បើគ្រឹះប្រពៃណីចាស់ជាស្នូលនៅតែមានជានិច្ចនោះ ហើយបើវាអាចជាឧបសគ្គដល់ការអភិវឌ្ឍន៍ បើយោងតាមលក្ខណៈវិនិច្ឆ័យបរទេស គឺគ្រឹះនោះហើយដែលអនុញ្ញាតឱ្យកម្ពុជាដែលខ្សោះឈាមក្នុងកីរតធំនឹង

ក្រោកឡើងវិញៗចាប់តាំងពីឆ្នាំ១៩៧៩។ អ្នកស្រែម្នាក់អាចសាងសង់ផ្ទះរបស់ខ្លួន នង្គ័ល ទ្រូ លប និងរទេះរៀនរស់ដោយខ្លួនឯងជានិច្ច។ ក្នុងយុគសម័យងងឹត ប្រជាជនខ្មែរបានស្តាប់ពាក្យណែនាំដោយពុំបានស្វែងរកពិតប្រាកដឱ្យដឹងថា ពាក្យនោះមានន័យយ៉ាងណា។ ហើយពេលណាដែលដឹងថា អាចធ្វើទៅបាន ប្រជាជនខ្មែរត្រឡប់មករកការអនុវត្តតាមបែបបូរាណរបស់គេវិញ ដែលយើងមិនមែនជាអ្នកវិនិច្ឆ័យថាតើការអនុវត្តនោះល្អ ឬអាក្រក់ទេ។

ដូច្នេះប្រជាជនកម្ពុជាបានបង្ហាញឱ្យឃើញនូវការតតាំង និងការសំរបតាមយ៉ាងចម្លែកទៅនឹងការផ្លាស់ប្តូរដែលគេមិនចង់បាន ហើយនិងភាពពិបាកយល់ពិបាកវាយតម្លៃក្នុងបទពិសោធន៍ដ៏សោកសៅ។

# អនុសាសន៍

សង្គមកម្ពុជានៅពេលនេះត្រូវប្រឈមមុខនឹងស្ថានការណ៍ថ្មីៗ: ការបើកចំហទៅរកតម្លៃអន្តរជាតិ កំណើនប្រជារាស្ត្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ បើគ្រឹះវប្បធម៌ចាស់នៅតែមាននាទី ហើយចូលរួមយ៉ាងជ្រាលជ្រៅនៅក្នុងការបង្កើតតរិយាបទសង្គម គេត្រូវគិតទុកជាមុននូវការផ្លាស់ប្តូរខ្លះក្នុងរយៈពេលមួយមានកំណត់។ គេគួរធ្វើយ៉ាងណាឱ្យការវិវត្តន៍នេះប្រព្រឹត្តទៅបន្តិចម្តងៗ ដោយគោរពដល់ក្បួនច្បាប់ និងតម្លៃនៃសង្គមកម្ពុជា។

ដូច្នេះ គេត្រូវទុកអនុសាសន៍ដែលមានជាបន្តទៅនេះនៅក្នុងក្របខ័ណ្ឌវប្បធម៌ និងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ ការពិត ការស្នើឱ្យមានការផ្លាស់ប្តូរធំៗ ដោយអនុវត្តវិធីបរទេសទៅក្នុងប្រព័ន្ធប្រពៃណី គឺហាក់ដូចជាលាបវានីមួយស្រទាប់ដែលគ្រាន់តែជាការបំភ័ន្តមួយពេល។

អនុសាសន៍របស់យើងលេចចេញពីការស្នើសុំរបស់អ្នកសំរះសំរួលផ្លូវការ និងក្រៅផ្លូវការដែលបានសារភាពប្រាប់យើងអំពីការច្របូកច្របល់របស់គេនៅចំពោះមុខការវិវត្តន៍នៃសង្គម ហើយដែលបានសំដែងសេចក្តីប្រាថ្នារបស់ខ្លួនដើម្បីទាមទារយកវិញនូវទំនុកចិត្ត និងការគោរពរបស់មនុស្សដែលនៅជុំវិញគេ។ សូម្បីតែនៅពេលបច្ចុប្បន្ននេះក៏ដោយ បើសេចក្តីគោរពចំពោះមនុស្សម្នាក់តែងតែទាក់ទងទៅនឹងសេចក្តីភ័យខ្លាចដែលមនុស្សនោះបណ្តាលឡើង តទៅអនាគតសេចក្តីគោរពនោះគួរតែសំដែងចំពោះសមត្ថភាព និងចំណេះដឹងវិញ។

ដូច្នេះ យើងសូមស្នើឱ្យលើកស្ទួយកម្មវិធីអប់រំ និងផ្សាយពតិមាន ដើម្បីផ្តល់ឱ្យជនដែលជាប់ពាក់ព័ន្ធក្នុងដំណោះស្រាយទំនាស់ ឬប្រជាជនសាមញ្ញ នូវចំណេះដឹងព្រមទាំងការចេះគិតពិចារណាពីរបៀបដោះស្រាយ និង បង្កាជម្លោះនៅមូលដ្ឋាន។

### ១. ការបណ្តុះបណ្តាល

ការបណ្តុះបណ្តាល អំពីវិធីធ្វើការសំរុះសំរួល សន្ធានកម្ម និងមជ្ឈត្តកម្មត្រូវរៀបចំឡើង ដោយធ្វើការសំរបសំរួលជាមួយដៃគូផ្សេងៗដូចជា ក្រសួងអប់រំ ក្រសួងយុត្តិធម៌ ក្រសួងវប្បធម៌ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

### ខ្លឹមសារ :

ដើម្បីឱ្យជ្រួតជ្រាបពេញលេញ ជាការសំខាន់ត្រូវរៀបចំការបណ្តុះបណ្តាលដែលឈរលើភាពជាក់ស្តែងនៃជីវភាពបែចាំថ្ងៃនៅកម្ពុជា ហើយដែលគិតដល់ក្រុមសាសនា និងក្រុមសង្គមបូរាណ។

ដូច្នេះ ជាការមានប្រយោជន៍ត្រូវធ្វើការចេញពីករណីពិតៗ ត្រូវបង្ហាញពីរបៀបដែលករណីទាំងនោះត្រូវបានចាត់ការ និងដោះស្រាយ និងត្រូវស្រាវជ្រាវជាមួយមនុស្សដែលចូលរួមក្នុងការបណ្តុះបណ្តាល រក

មធ្យោបាយផ្សេងៗទៀតដើម្បីដោះស្រាយករណីទាំងនោះ ដូចជាការពិភាក្សា ការស្នើវិធីផ្សេងៗទៀត (ឧទាហរណ៍ ដំណោះស្រាយទំនាស់ជំនួសផ្លូវតុលាការ) ការស្រាវជ្រាវរកដំណោះស្រាយដែលមាននៅក្នុងប្រពៃណីហើយរួមបញ្ចូលវិធីទាំងនោះទៅក្នុងទិន្នន័យថ្មី។

ការបណ្តុះបណ្តាលទាំងនេះ ត្រូវរួមបញ្ចូលការបណ្តុះបណ្តាលមូលដ្ឋានអំពីច្បាប់ និងអំពីនិតិវិធីរដ្ឋបាលដែលចាំបាច់សម្រាប់ការដំណើការរឿងទំនាស់ដីធ្លី និងរឿងព្រហ្មទណ្ឌ។

ត្រូវមានការយកចិត្តទុកដាក់ជាពិសេសដល់ការដោះស្រាយទំនាស់ប្តីប្រពន្ធ និងពិសេសទៅទៀតដល់អំពើហិង្សាក្នុងគ្រួសារ។

**ជនគោលដៅ**

អាជ្ញាធរមូលដ្ឋាន**:** ជាប្រពៃណី និងសព្វថ្ងៃនេះផងដែរ គេទទួលស្គាល់ប្រធានភូមិ និងប្រធានឃុំជាអាជ្ញាធរសំរាប់ដោះស្រាយទំនាស់នៅមូលដ្ឋាន។ យើងមើលឃើញថា ជាការសំខាន់ត្រូវពឹងផ្អែកលើអ្នកទាំងនេះ និងមិនត្រូវបង្កើតរចនាសម្ព័ន្ធស្របដែលគ្មានការទទួលស្គាល់នៅថ្នាក់មូលដ្ឋានទេ។

ក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីវិមជ្ឈការ គេនឹងផ្តល់ស្វ័យភាពខ្លាំងថែមទៀត និងអំណាចធំថែមទៀតដល់ប្រធានឃុំ។ ការបណ្តុះបណ្តាលប្រធានឃុំ គួរតែយកចិត្តទុកដាក់ឱ្យបានមែនទែន។ ប្រធានឃុំនឹងទទួលភារកិច្ចបន្ត ទៅទៀតដើម្បីបណ្តុះបណ្តាលប្រធានភូមិ និងត្រូវធ្វើយ៉ាងណាឱ្យមានឯកសារសរសេរដាក់នៅសាលាឃុំសំរាប់អាន។

ជាការសំខាន់ដូចគ្នាដែលការបណ្តុះបណ្តាលត្រូវតំរង់ទៅរក **នគរបាល** និង **មនុស្សទទួលបន្ទុកធ្វើការសំរុះសំរួលនៅតុលាការ**។

ហេតុដូច្នេះ ជាការសំខាន់ដែលត្រូវបង្កើតមុខតំណែងសន្ធានករ ឬមជ្ឈត្តករនៅក្នុងតុលាការ ដែលនឹងមានតួរនាទីគរុកោសល្យផងដែរ(និតិវិធីតុលាការ ច្បាប់) នៅអមប្រជាជនដែលមិនសូវមានការអប់រំ។

**អាចារ្យ** មានតួនាទីសំខាន់ជាពិសេសនៅក្នុងសង្គមខ្មែរ។ ដោយសារគាត់ជាអន្តរការីរវាងគ្រហស្ថ និងព្រះសង្ឃ អាចារ្យទទួលបន្ទុករៀបចំពិធីសាសនានៅវត្ត និងនៅតាមភូមិក្នុងឱកាសពិសេស(ដូចជាពេលសង់ផ្ទះ ពេលអាពាហ៍ពិពាហ៍ ពេលមានជម្ងឺ និងពេលបុណ្យសព)។ ដោយទទួលការគោរព ដោយសារចំណេះដឹងខាងសាសនារបស់គាត់ អាចារ្យជាមនុស្សដែលនៅកៀកនឹងប្រជាជន និងប្រវត្តិជីវិតរបស់ប្រជាជន។ ដូច្នេះអាចារ្យអាច បំពេញនាទីលំដាប់ទីមួយ នៅក្នុងវិស័យទំនាស់សង្គម គឺជម្លោះប្តីប្រពន្ធ ឬជាមួយជម្លោះអ្នកជិតខាង។

**២. ពតិមាន**

**ពតិមានក្នុងមូលដ្ឋាន :**

**ត្រូវមានអត្ថបទច្បាប់សំរាប់សាធារណៈជន :** ជាអត្ថបទច្បាប់ដែលអាចពិគ្រោះបាននៅតុលាការ និងសាលាឃុំ ។

បង្កើត**តំណែងរដ្ឋបាលមួយសំរាប់អ្នកដែលមានចំណេះដឹង**( លោកគ្រូ) :

មនុស្សម្នាក់ អាចទទួលបន្ទុកជួយប្រជាជនដែលពុំសូវមានការអប់រំ ដើម្បីឱ្យគេអាចនឹងយល់ខ្លឹមសារនៃអត្ថបទច្បាប់ ។ មនុស្សនេះអាចជាចាស់ទុំ អាចារ្យ មន្ត្រីចូលនិវត្តន៍ តំណាងសមាគមមូលដ្ឋានដែលជាអ្នកមានសមត្ថភាពទទួលស្គាល់ដោយប្រជាពលរដ្ឋនៅមូលដ្ឋាន ។

មនុស្សនេះគួរតែទទួលការបណ្តុះបណ្តាល និងទទួលប្រាក់កំរៃខ្លះពីសកម្មភាពរបស់គាត់ ។

**ពតិមានថ្នាក់ជាតិ :**

បណ្តាញវិទ្យុ ព្រមទាំងប៉ុស្តិ៍ទូរទស្សន៍ គ្របដណ្តប់ផ្នែកសំខាន់នៃដែនដី ហើយត្រូវបានប្រជាជនមួយភាគធំស្តាប់និងមើល ។ រឿងខ្លីៗតាមវិទ្យុ រឿងភាគចិន និងថៃ ក៏ត្រូវបានប្រជាជនចូលចិត្តស្តាប់ និងមើលដែរ ។

**ទូរទស្សន៍ :** ឧទាហរណ៍ ជាការមួយសំខាន់ដែរបើគេអាចផលិតរឿងភាគក្នុងទូរទស្សន៍ដែលបង្ហាញពីឆាកនៃទំនាស់ និងបញ្ហានៃជីវភាពប្រចាំថ្ងៃនៅប្រទេសកម្ពុជា និងដំណោះស្រាយនៃបញ្ហាទាំងនោះ ។ តួអង្គមានវិរៈភាព( ដូចជាក្នុងរឿងល្បើកចៅក្រមទន្សាយជាដើម) ត្រូវដើរតួជាអ្នកសំរុះសំរួល ជាអ្នកមានគតិបណ្ឌិតនៅតាមភូមិ ខេត្តនៃប្រទេសខ្មែរ ហើយដោយប្រឈមមុខនឹងស្ថានការណ៍ពិបាក តួអង្គនេះនឹងទៅជាអ្នកជាទីអាង និងគំរូនៅក្នុងរបៀបមួយល្អដើម្បីបង្កា ឬដោះស្រាយទំនាស់ ។

**វិទ្យុ :** បង្កើតរឿងខ្លីៗ ដែលបង្ហាញពីឆាកមនុស្សមានទំនាស់នឹងគ្នា ហើយនិងការធ្វើអន្តរាគមនរបស់អ្នកសំរុះសំរួល សន្ធានករ និងមជ្ឈត្តករ ។

**ល្ខោន :** សហការណ៍ជាមួយក្រុមល្ខោនគោចរ ដើម្បីបង្កើតឆាកកំប្លែងដែលបង្ហាញពីរឿងទំនាស់នៅមូលដ្ឋាន និងវិធីដោះស្រាយទំនាស់ដោយអ្នកភូមិខ្លួនឯង ឬដោយសន្ធានករខាងក្រៅ ។

**ល្ខោនខោល :** អង្គការក្រៅរដ្ឋាភិបាលខ្លះបានប្រើដោយជោគជ័យរួចទៅហើយនូវមធ្យោបាយនេះ ដើម្បីផ្សព្វផ្សាយដំណឹងស្តីពីការបង្ការោគអេដស៍ ។

បទពិសោធន៍នេះសំខាន់គួរធ្វើឱ្យបានសំរេចប្រធានបទរបស់យើង ។

### ៣. ការស្រាវជ្រាវ

ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលគ្រប់គ្រាន់ស្តីពីវប្បធម៌ប្រពៃណីរបស់ខ្មែរ ត្រូវលើកស្ទួយឱ្យបានជ្រៅជ្រះការស្រាវជ្រាវលើចំណុចពិសេសៗ ដែលត្រូវបានរុករកតិច ឬច្រើនរួចមកហើយ ។

**ដកស្រង់សំណេរដែលទាក់ទង នឹងទំនាស់ និងការដោះស្រាយទំនាស់នៅកម្ពុជា និងនៅប្រទេសជិតខាង :**

- ពិគ្រោះឯកសារនៅបណ្ណសារដ្ឋានជាតិនៅភ្នំពេញ ឯកសារនៅបណ្ណសារដ្ឋាននៅហាណូយ បណ្ណាល័យសាលាចុងបូព៌ារបស់បារាំងនៅប៉ារីស ឯកសារនៅបណ្ណសារដ្ឋានឯនាយសមុទ្រនៅAix-en-Provence ។

**កំណត់ទិសដៅនៃការស្រាវជ្រាវអំពីស្ថានភាព**

- ការវាយតម្លៃជាស្ថិតិពីស្ថានការណ៍បច្ចុប្បន្នៈ ស្រង់យកចំនួន និងប្រភេទករណីទំនាស់ដែលត្រូវបានដោះស្រាយក្នុងភូមិ ឃុំ ស្រុក និងតុលាការ ។ (សំរាំងយកសំណាកដែលអាចធ្វើតំណាងបានគួរសម) ។
- ការគ្រប់គ្រងដីធ្លី ចាប់តាំងពីមស័យបូរាណរហូតដល់សព្វថ្ងៃៈ ច្បាប់ប្រពៃណី និងការបង្កើតច្បាប់ភូមិបាល ចាប់តាំងពីសម័យអាណាព្យាបាលបារាំង ។
- ឋានៈរបស់បុរស និងស្ត្រីនៅក្នុងសង្គមកម្ពុជា : ប្រពៃណី និងការវិវត្តន៍ ។
- ការសិក្សាអំពីស្ថានភាព ទំនាស់ពិសេសៗ :
    - នេសាទនៅក្នុងបឹងទន្លេសាបចាប់តាំងពីពេលបញ្ចេញឡូតិ៍នេសាទ( ទំនាស់រវាងអាជីវករតូច និងអាជីវករធំ ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន)
    - ការរំសាយទ័ព និងលទ្ធភាពមានដីធ្លី( ទំនាស់ដីធ្លីរវាងយោធា និងអ្នកភូមិ)
- ដំណើរការនៃការផ្សះផ្សាជាតិ : ឋានៈរបស់អតីតខ្មែរក្រហមនៅក្នុងរង្វង់សង្គមខ្មែរ ។
- ឋានៈរបស់សហគមន៍ដើមកំណើតចិន វៀតណាម ចាម និងជនជាតិនៅភ្នំ ក្នុងសង្គមខ្មែរ : ការប៉ះទង្គិចគ្នា និងការប្រឆាំង ។
- ទំនាស់ដីធ្លីនៅទីក្រុង : ករណីភ្នំពេញ ។

### ៤. ពង្រឹងបង្គោលប្រពៃណី និងស្តារទំនុកចិត្តឡើងវិញ

ពឹងផ្អែកលើគ្រឹះវប្បធម៌ខ្មែរ :

- រាវរកក្នុងពុទ្ធសាសនានូវរឿងដែលនាំឱ្យមានគុណធម៌ដើម្បីបង្ហាញឧទាហរណ៍នៃការដោះស្រាយទំនាស់( ដូចជារឿងជាតក : រឿងនិទានជាតិមុនមុនរបស់ព្រះពុទ្ធ)
- យកលំនាំរឿងសុភាទន្សាយមកប្រើក្នុងស្ថានការណ៍សម័យឥឡូវនេះ ។

**ពិចារណាឡើងវិញនូវឋានៈរបស់អាចារ្យ :**

អាចារ្យជួបប្រជុំគ្នាមួយដងក្នុងមួយអាទិត្យ នៅទីវត្តក្នុងឱកាសថ្ងៃសីល។

- បង្កើតកម្មវិធីអប់រំដោយសហការណ៍ជាមួយក្រសួងវប្បធម៌ ស្តីពីការដោះស្រាយទំនាស់ ដែលភ្ជាប់តម្លៃសិទ្ធិមនុស្សជាមួយតម្លៃពុទ្ធសាសនា។ ការបណ្តុះបណ្តាលនេះអាចធ្វើចំពោះអាចារ្យខ្លះនៅក្នុងវត្តនិមួយៗព្រមទាំងដូនជីនៅក្នុងវត្តដែរ។
- ជួយបង្កើតក្រុមប្រឹក្សាចាស់ទុំ ហើយនិងកំណត់ទីកន្លែងជួបជុំគ្នា ដោយមានការយល់ព្រមពីអាជ្ញាធរសាសនា សំរាប់ពិភាក្សា និងនាំគ្នាសំរុះសំរួលក្នុងបរិវេណវត្ត។ ទីកន្លែងនេះដែលគ្រប់គ្រងដោយអាចារ្យ និងដូនជី អាចបើកជំហរសំរាប់មនុស្សដែលបែកបាក់ពីគ្រួសារ ឬពីភូមិផងដែរ ដូចជាស្ត្រីត្រូវប្តីវាយដំ ស្ត្រីមានកូនតែគ្មានប្តី អ្នកជម្ងឺអេដស៍ អ្នកក្រដែលគ្មានបណ្តាញបក្សពួក។ល។ មនុស្សទាំងនេះអាចតំរែតំរង់ឱ្យទៅរកគ្រឹះស្ថានសារធារណៈ ឬអង្គការឯកទេសកម្ម។
- មជ្ឈមណ្ឌលសាកល្បង អាចបង្កើតមុនដំបូងនៅក្នុងវត្ត ដែលអនុវត្តសកម្មភាពរួចហើយទាក់ទងនឹងការអភិវឌ្ឍន៍ជនបទ និងបើកចំហឱ្យគោលការណ៍វប្បធម៌សន្តិភាព មុននឹងពង្រីកទៅកន្លែងផ្សេងទៀត។

**៥. ជួយសមាគមមូលដ្ឋាន :**

- រកសមាគមមូលដ្ឋានណាដែលធ្វើការក្នុងវិស័យដំណោះស្រាយទំនាស់ និងជួយសហគមនោះដោយផ្តល់ពត៌មាន និងឯកសារគរុកោសល្យ។
- ជំរុញឱ្យមានការបង្កើតសមាគមមូលដ្ឋាន ដើម្បីឱ្យសមាគមទាំងនោះសម្របកម្មវិធីរបស់ខ្លួន និងបង្វែរធនធានរបស់ខ្លួន សំដៅបំរើមនុស្សទន់ខ្សោយដែលនៅក្រៅបណ្តាញបក្ខពួក មនុស្សស្រីដែលទទួលរងអំពើហិង្សាក្នុងគ្រួសារ អ្នកក្រ និងមនុស្សមកពីខាងក្រៅ។
- ជួយនាំឱ្យមានសហការណ៍រវាងសមាគមនានា ដោយរៀបចំជាសិក្ខាសាលាឬគណៈកម្មាធិការសំរបសំរួល និងត្រិះរិះ។

**៦. រៀបរយឯកសាររដ្ឋបាលឱ្យមានទម្រង់ត្រឹមត្រូវ :**

ស្នើឱ្យស្ថាប័ននានា រៀបចំឯកសាររដ្ឋបាលឱ្យមានទម្រង់ត្រឹមត្រូវ ដើម្បីងាយឱ្យប្រជាជននៅថ្នាក់ភូមិអាចប្រើប្រាស់និងបំពេញបានដូចជា ឯកសារអំពីកម្មសិទ្ធិ ការកាន់កាប់ ការលក់ ការទិញ ឬការជួលដី ព្រមទាំងឯកសារដែលជួយអ្នកសំរុះសំរួលឱ្យតាក់តែងលិខិតសន្យា។

# ឧបសម្ព័ន្ធ

តំបន់ត្រួតត្រាដោយកងទ័ពរដ្ឋាភិបាលចន្លោះឆ្នាំ១៩៧២ និង១៩៧៥

(តំបន់សស្ថិតក្នុងដៃរបស់ខ្មែរក្រហម)



ខេត្តនៃប្រទេសកម្ពុជា និងទីកន្លែងសាកសួរ

**កំពត** : ស្រុកឈូក ក្រុងកែប

**កណ្តាល** : ស្រុកកៀនស្វាយ

**កំពង់ស្ពឺ** : ស្រុកច្បារមន

**ក្រុងភ្នំពេញ**

**សៀមរាប** : ស្រុកបន្ទាយស្រី ស្រុកនគរធំ

**ស្វាយរៀង** : ស្រុកស្វាយទាប ស្រុកស្វាយជ្រុំ






# មគ្គុទ្ទេសក៏នៃការជួបសន្ទនា

**១. អ្នកសំរបសំរួលផ្លូវការ អាជ្ញាធររដ្ឋបាល**

មេក្រុម មេភូមិ មេឃុំ ចៅសង្កាត់ មេស្រុក

សំណាកៈ ប្រធានភូមិចាស់ ភូមិថ្មី ភូមិនៅព្រំដែន ភូមិនៅតាមដងទន្លេ ភូមិដែលមានបញ្ហាជាមួយមនុស្សមកពីក្រៅសង្កាត់ក្នុងក្រុង ឃុំ ស្រុក ។ល។

ឈ្មោះ អាយុ និងមុខងារ អ្នកដែលត្រូវសម្ភាសន៏ :

**២. ប្រជារាស្ត្រ :**

មានប៉ុន្មានក្រុម ប៉ុន្មានភូមិ? ចំនួនគ្រួសារ? ចំនួនកូន?

**៣. ប្រវត្តិការណ៏នៃការបែងចែករដ្ឋបាល :** ទំនាស់(ការដោះស្រាយ និងការបង្កា) គ្រឹះ

១៩៥៤-១៩៧០ : សម័យសង្គមរាស្ត្រនិយម

១៩៧០-៧៥ : សាធារណរដ្ឋ លន់ ណុល ប្រទេសដែលត្រួតត្រាមួយចំណែកដោយខ្មែរក្រហម

១៩៧៥-៧៩ : របបកម្ពុជាប្រជាធិបតេយ្យ : ការជំលៀស កំរិតជីវភាព

១៩៧៩-៨៩ : សារធារណរដ្ឋប្រជាមានិតកម្ពុជា : បញ្ហាបែងចែកដី

១៩៨៩-៩៣ : រដ្ឋកម្ពុជា

១៩៩៣-២០០១ : អ៊ុនតាក់ រាជរដ្ឋាភិបាល

**ភូមិ និងសង្កាត់ទីក្រុង**

អ្នកស្រុក និងសកម្មភាពចាប់តាំងពីដើមសតវត្សរហូតដល់ឆ្នាំ១៩៧០(ពាណិជ្ជករ មន្ត្រីរាជការ អ្នកមានដើមកំណើតជាតិពន្ធុ)

| | |
|---|---|
| ១៩៧០ | សង្គ្រាម |
| ១៩៧៥ | ជំលៀសទៅទីណា? |
| ១៩៧៩ | អ្នកស្រុកបច្ចុប្បន្ន(ភាគច្រើនជាអតីតអ្នកភ្នំពេញ ឬមនុស្សមកពីខេត្ត?) |

**៤. សកម្មភាពអ្នកស្រុក**

មុខរបរ

កំរិតសង្គម-សេដ្ឋកិច្ច

បញ្ហាដែលជួបប្រទះ( ទឹក ផ្លូវថ្នល់ សាលារៀន ដីធ្លី អសន្តិសុខ....)
វត្តមាន ឬអវត្តមាននៃអង្គការក្រៅរដ្ឋាភិបាល សកម្មភាព

**៥. ទំនាស់**

- **តើបញ្ហាអ្វីខ្លះដែលមានរវាង អ្នកស្រុកក្នុងជីវិតប្រចាំថ្ងៃ?**
- នៅផ្ទៃក្នុង (ដី សំណង់ ជម្លោះគ្រួសារ( មនុស្សស្រី និងមនុស្សប្រុស-មនុស្សស្រី និង មនុស្សស្រី-មនុស្សប្រុស និងមនុស្សប្រុស) បំណុល ការរំលោភទំនុកចិត្ត សត្វ...)
- និងជាមួយខាងក្រៅ ( រវាងភូមិ និងភូមិ រាជការ យោធា)
- **ទំនាស់ញឹកញាប់ជាងគេ** ឧទាហរណ៍ ហេតុអ្វី?
- **ទំនាស់មិនសូវញឹកញាប់** ឧទាហរណ៍ ហេតុអ្វី?
- **កើតឡើងដដែល១ ឬទេ**
- វាយតម្លៃ **ចំនួន និងប្រភេទទំនាស់** នៅក្នុងអតីតកាល និងសព្វថ្ងៃ ការវិវត្តន៍ ការផ្លាស់ប្តូរ មូលហេតុ?

**ជម្លោះគ្រួសារ :**

មូលហេតុ
ការធ្វើឱ្យរបួសស្នាម ហេតុអ្វី សំខាន់ ឬមិនសំខាន់?
គំរូស្ត្រីដែលគួរឱ្យគោរព មិនគួរឱ្យគោរព?
គំរូបុរសដែលគួរឱ្យគោរព

**ទំនាស់ដីធ្លី**

**៦. ការសំរុះសំរួល**

**ដំណាក់កាលផ្តើម :**

- តើអាជ្ញាធរត្រូវបានប្រាប់ឱ្យដឹងពីបញ្ហាយ៉ាងណា? ដោយភាគីទាំងពីរ? ភាគីតែម្ខាង? នគរបាល? អ្នកដទៃទៀត?
- បណ្តឹងផ្ទាល់មាត់ សរសេរ (បែបបទផ្លូវការ? ប្រាក់បង់?)។ ជួបជាមួយដើមបណ្តឹងប៉ុន្មានដង?
- ជួនកាលអាជ្ញាធរធ្វើអន្តរាគមដោយផ្ទាល់? ក្នុងករណីអ្វីខ្លះ? តើគាត់ទៅទីកន្លែងដើម្បីពិនិត្យបញ្ហាដែរឬទេ?

- ការកោះហៅមកការិយាល័យ-តើកោះហៅអ្នកណា? ភាគីម្ខាង? ភាគីទាំងពីរ? តើគាត់ស្ដាប់ភាគីទីពីរដោយឡែកមុននឹងប្រជុំភាគីទាំងពីរ? តើអ្នកណាមិនព្រមមកតាមការកោះហៅ? តើធ្វើយ៉ាងណា បើគ្មានការឆ្លើយតបនឹងការកោះហៅ? តើមានលទ្ធភាពឱ្យនគរបាលធ្វើអន្តរាគមដែរឬទេ? អ្នកដទៃទៀត? តើបញ្ជូនរឿងទៅលើទៀតទេ?
- តើករណីអ្វីខ្លះដែលមិនដោះស្រាយដោយមេភូមិ ហើយបញ្ជូនដោយផ្ទាល់ទៅអាជ្ញាធរថ្នាក់លើ? រឿងព្រហ្មទណ្ឌ(អ្វីដែលចាត់ទុកថាជារឿងប្រហ្មទណ្ឌ ឧទាហរណ៍ ការរំលោភសេពសន្ថវៈ ការរំលោភលើទំនុកចិត្ត បំណុល?)
- តើអាជ្ញាធរថ្នាក់លើមានដាក់រឿងឱ្យមេភូមិពិនិត្យ ហើយឱ្យមេភូមិធ្វើសហការណ៍ដែរឬទេ? ក្នុងករណីណាខ្លះ?

**សន្ធានកម្ម (ការពិពណ៌នា) :**

- តើប្រើពេលប៉ុន្មាន ក្រោយពីការដាក់បណ្ដឹងជាលើកដំបូង?
- តើការសំរុះសំរួលប្រព្រឹត្តទៅនៅទីណា? តើកន្លែងនោះបើកចំហដែរឬទេ? បិទ? តើអ្នកណាខ្លះអនុញ្ញាតឱ្យចូលរួមក្រៅពីគូជម្លោះ?
- តើមេភូមិចាត់ការយ៉ាងណា? សួរសំណួរ ស្ដាប់ ឱ្យដំបូន្មាន ប្រកាសវិធានផ្នែកសីលធម៌ អានច្បាប់?
- តើអ្នកសំរុះសំរួលនិយាយអ្វីខ្លះ?
- ការតាក់តែងលិខិតសន្យា។ តើអ្នកណាជាអ្នកសរសេរ។ តើគេត្រូវធ្វើលិខិតនេះគ្រប់តែរឿងឬ?
- តម្លៃ និងតួនាទីរបស់លិខិត? បង្កា? ខ្លាចការសងសឹកពីសំណាក់រាជការ? បើមាន អ្នកណា?
- ទណ្ឌកម្ម? ការបំភ័យបំភ័យ?
- តើអ្នកសំរុះសំរួលត្រូវការអ្នកដទៃដើម្បីសួរពតិមានពីបញ្ហាសុំយោបល់ដែរឬទេ? បើមានអ្នកណា?
- រយៈពេលនៃការសំរុះសំរួល
- អារម្មណ៍រំជួលរបស់ភាគីទាំងពីរ : ខឹង ទប់ចិត្ត
- តើអ្នកសំរុះសំរួល យកចិត្តទុកដាក់ ឬមិនយកចិត្តទុកដាក់លើអារម្មណ៍រំជួលអ្វីខ្លះ?

**ដំណាក់កាលបន្ត**

- តើជនរងគ្រោះ និងអ្នកបំពានមានប្រតិកម្មអ្វីខ្លះ?

- តើអ្នកសំរុះសំរួលបានដឹងពីការបន្តរឿងទៅទៀតដែរឬទេ? ដោយភាគីប្រាប់ ឬដឹងដោយខ្លួនឯង?
- តើអ្នកសំរុះសំរួលមានដឹងថា តើរឿងនោះដោះស្រាយរួច ឬមិនរួច?
- បើរួច តើលទ្ធផលយ៉ាងណា? (ក្នុង ១០រឿង តើប៉ុន្មានរឿងដែលគ្មានបញ្ហាទៅអនាគត?) តើការអនុវត្តសេចក្ដីសំរេចឬយោបល់របស់អ្នកសំរុះសំរួលមានប្រសិទ្ធិភាពដែរឬទេ? រឿងចាស់ត្រឡប់មកវិញច្រើនឬទេ? តើរឿងនោះដោះស្រាយរួចឬមិន?
- ក្នុង១០ករណី តើប៉ុន្មានរឿងឡើងដល់ថ្នាក់លើទៅតុលាការ? តើរឿងនោះទៅតុលាការដោយផ្ទាល់ឬ?
- កាលណាបញ្ហាមួយដាក់ឱ្យអ្នកសំរុះសំរួលដោះស្រាយជាមធ្យម តើត្រូវស៊ីពេលប៉ុន្មានពីដើមដំបូងរហូតដល់ចប់។

**៧.** ប្រវត្តិអ្នកសំរុះសំរួល : អាយុ ជីវប្រវត្តិ ការជ្រើសរើស? ចាប់បំពេញមុខងារ ចាប់តាំងពីពេលណាមក? អ្នកណាធ្វើមុនគាត់? តើគាត់ចង់ធ្វើទៀតដែរឬទេ? ចុះចេញ? ក៏រឹតអប់រំ?

- **មុខងាររបស់អ្នកសំរុះសំរួល** តើគាត់មានមុខការ សមត្ថកិច្ច និងព្រំដែនត្រឹមណាខ្លះ? ចាប់តាំងពីពេលណា? ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់លើ(គាត់ទាក់ទងគេញឹកញាប់ឬទេ ឬចូលចិត្តដោះស្រាយបញ្ហាផ្ទៃក្នុងជាង?)
- **តើគាត់យល់ពីការសំរុះសំរួលយ៉ាងណាដែរ?**
- តើមាននីតិវិធីប្រពៃណីសំរាប់ដោះស្រាយទំនាស់ដែរឬទេ? ការហ្វឹកហ្វឺនរបស់រាជការ? ការសង្កេតរបៀបធ្វើរបស់ថ្នាក់លើ?
- តើគាត់ឈរលើមូលដ្ឋានអ្វី?
- ច្បាប់ប្រពៃណី ក្រមសីលធម៌? ច្បាប់? ណាមួយ? មានអត្ថបទសរសេរដែរឬទេ? បទពិសោធន៍ផ្ទាល់ខ្លួន(បានមកយ៉ាងដូចម្ដេច?តាមការសង្កេត?) មានយោងទៅសាសនាដែរឬទេ? ពុទ្ធសាសនា? អ្នកតា (ស្បថចំពោះមុខអ្នកតា?)។

**៨.** ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់លើ

**នៅពេលណាដែលអ្នកទាក់ទងជាមួយអាជ្ញាធរថ្នាក់លើ?** ញឹកញាប់ឬទេ? អ្នកណាទៅទាក់ទង? ដោយសារហេតុអ្វី?

**៩.** ការសំរុះសំរួលនៅក្រោមរបបនយោបាយមុនៗ

- តើគេដោះស្រាយទំនាស់យ៉ាងដូចម្ដេច? ទំនាស់អ្វី? ការមិនចុះសម្រុងគ្នា? ដី ជម្លោះគ្រួសារ?

- សង្គមរាស្ត្រនិយម លន់ ណុល កម្ពុជាប្រជាធិបតេយ្យ សាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា?

**១០.** អ្នកសំរុះសំរួលដទៃទៀត

- តើអ្នកមានហៅរកមនុស្សដទៃទៀតដើម្បីជួយអ្នកក្នុងកិច្ចការសំរុះសំរួលដែរឬទេ? តើអ្នកមានប្រគល់ភារកិច្ចនេះឱ្យទៅអ្នកដទៃទៀតដែរឬទេ? (មនុស្សមានឥទ្ធិពល សេនាជន ចាស់ស្រុក ចាស់ទុំ អាចារ្យ លោកសង្ឃ) សហគម? (ស្ត្រីក្មេងៗ)
- តួនាទីរបស់អនុប្រធាន សេនាជន? ប្រធានក្រុម?
- តួនាទី និងសកម្មភាពរបស់ម្នាក់ៗកាលពីអតីត និងសព្វថ្ងៃ។ មានការផ្លាស់ប្តូរឬទេ? ហេតុផល?
- តួនាទីរបស់សាសនា ដើម្បីជៀសវាងទំនាស់ ក្បួនខ្នាត?
- មនុស្សដទៃទៀត ដែលមានឥទ្ធិពលនៅក្នុងភូមិ?

**១១.** បញ្ហាដែលជួបប្រទះ ក្នុងការអនុវត្តប្រចាំថ្ងៃនៃការសំរុះសំរួល?

- ចំណុចខ្លាំង និងចំណុចខ្សោយ

**១២.** សំណើដើម្បីកែលំអរ ការអនុវត្តការសំរុះសំរួល ឬដំណោះស្រាយទំនាស់

**១៣.** ពិពណ៌នាអំពីរឿង(អាចធ្វើបានក្នុងពេលសន្ទនាគ្នា)

## ២. អ្នកសំរុះសំរួលប្រពៃណី

អាចារ្យ ចាស់ទុំ

ឈ្មោះ : អាយុ :

ភូមិបច្ចុប្បន្ន? ភូមិកំណើត?

### ទំនាស់ដែលជួបប្រទះ

ឬទំនាស់ដែលបានសង្កេតឃើញនៅក្នុងជីវិតរបស់អ្នក( សម័យអាណាព្យាបាលបារាំង របបសង្គមរាស្ត្រនិយមរបស់សម្តេច សីហនុ សាធារណរដ្ឋ លន់ ណុល របបខ្មែរក្រហម សាធារណរដ្ឋប្រជាមានិតកម្ពុជា អ៊ុនតាក់ ព្រះរាជាណាចក្រកម្ពុជា)

- នៅសម័យដែលរំលឹកមកនេះ តើអ្នកមានចាំបញ្ហាជម្លោះ ទំនាស់រវាងឪពុកម្តាយ អ្នកជិតខាងក្រុម ឬភូមិដែរឬទេ?
- បើចាំតើអាចរៀបរាប់បានទេ?
- តើគេដោះស្រាយបញ្ហាដោយយ៉ាងណា?
- តើបញ្ហាប្រភេទនោះមានញឹកញាប់ដែរ ឬទេ? ហេតុអ្វី?
- តើគេបង្កាបញ្ហានោះតាមរបៀបណា?
- ក្នុងសម័យនោះ តើមានព្រឹត្តិការណ៍នយោបាយអ្វីខ្លះដែលអ្នកជួបប្រទះ (ខ្មែរឥស្សរៈ ការទម្លាក់សីហនុ ការវាយលុកដំបូងរបស់ពួកវៀតកុង ការឡើងកាន់អំណាចរបស់ខ្មែរក្រហម របៀបវៀតណាម អ៊ុនតាក់ សព្វថ្ងៃ) តើអ្នកបានឃើញ ឬបានធ្វើឬទេ?

### ការដោះស្រាយទំនាស់សព្វថ្ងៃ

- កាលបើមានទំនាស់តើទំនាស់នោះប្រព្រឹត្តទៅយ៉ាងណា? ហេតុអ្វី? ក្នុងករណីមានការសំរុះសំរួលតើអ្នកដែលបានចូលរួមក្នុងនោះដែរឬទេ? ហេតុអ្វីបានជាអ្នកចូលរួម?

  អ្នកណាសុំឱ្យអ្នកចូលរួម?

  អ្នកមានតួនាទីជាអ្វី?

  តើអ្នកអាចពិពណ៌នារឿងខ្លះៗបានឬទេ?

  រឿងអ្វី?

  មានការសំរុះសំរួលដែរឬទេ? (អ្នកណាដែលធ្វើអន្តរាគមមុនគេ? អ្នកសំរុះសំរួលឬគូជម្លោះ? មានការពិភាក្សាក្រៅផ្លូវការ ក្នុងលក្ខណៈបុគ្គល ឬការប្រជុំភាគីទាំងពីរ? ក្បួនខ្នាតប្រពៃណី ឬក្បួនខ្នាតរបស់រាជការ? តើគេយោងទៅក្បួនអ្នកណា ឬដោះស្រាយរបៀបផ្លូវសីលធម៌)

តើអ្នកបានចេះដឹងដោយរបៀបណា? អត្ថបទប្រពៃណីដែលដំណាលដោយផ្ទាល់មាត់ បទពិសោធន៍ផ្ទាល់ខ្លួន?

តើអ្នកសំរុះសំរួលដ៏ទៃទៀត មានតួនាទីដូចម្តេចដែរ?

តើមានវិធីពិសេសអ្វីខ្លះសំរាប់បង្កាទំនាស់និងអំពើហឹង្សា? បើគ្មាន តើគេអាចបង្កាដោយរបៀបណា? (ការគ្រប់គ្រងសង្គម សាសនា រដ្ឋបាល តុលាការ)

ប្រសិទ្ធិភាពនៃវិធីនោះ និងព្រំដែនរបស់វា?

តើមានការខុសគ្នាវគ្នាដូចម្តេចខ្លះដែលអ្នកអាចរកឃើញរវាងសង្គមកម្ពុជាកាលពីមុនសង្គ្រាម និងសង្គមបច្ចុប្បន្ន?

ការវិវត្តន៍នៃតួនាទីរបស់ចាស់ទុំ? តួនាទីរបស់រាជការ?

តើអ្នកអាចពន្យល់ថា ហេតុអ្វីបានជាខុសគ្នា?

តើបញ្ហាអ្វីខ្លះដែលសង្គមកម្ពុជាបច្ចុប្បន្នជួបប្រទះ? សំណើ ចម្លើយដើម្បីបង្កា និងដោះស្រាយទំនាស់ និងអំពើហិង្សាឱ្យបានល្អប្រសើរឡើង?

## ៣. មនុស្សដែលជាប់ពាក់ព័ន្ធនៅក្នុងទំនាស់មួយ ឬអ្នកដែលបានសង្កេតទំនាស់

ឈ្មោះ :

អាយុ :

ភូមិបច្ចុប្បន្ន :

ភូមិកំណើត :

**ប្រវត្តិផ្ទាល់ខ្លួន ?**

**ទំនាស់**

- នៅទីនេះ បញ្ហាជម្លោះ និងទំនាស់អ្វីដែលកើតមានឡើងក្នុងជីវភាពប្រចាំថ្ងៃរវាង មនុស្សក្រុម មនុស្សមកពីខាងក្រៅសហគមន៍?
- កាលណាមានបញ្ហាមួយកើតឡើងនៅផ្ទះអ្នកដទៃ តើអ្នកធ្វើដូចម្តេច?(មិននិយាយអ្វី រង់ចាំនិយាយ ស្វែងរកយោបល់....)
- កាលណាមានបញ្ហាមួយកើតឡើងនៅផ្ទះរបស់អ្នក ឬដែលប៉ះពាល់ដល់សមាជិកម្នាក់ក្នុងគ្រួសាររបស់អ្នកតើអ្នកធ្វើដូចម្តេច? តើអ្នកនិយាយឬទេ? និយាយទៅកាន់អ្នកណា(តាមលំដាប់)?

- តើអ្នកជ្រើសរើសអ្នកណា? ហេតុអ្វី? (ឳពុក ម្ដាយ បងប្អូនបង្កើត ជីដូនមួយ អ្នកជិតខាង មិត្តភ័ក្ដ្រ មនុស្ស មានឥទ្ធិពល ចាស់ទុំ លោកសង្ឃ ប្រធានភូមិ)។
- តើគេនិយាយដូចម្ដេចពីបញ្ហានោះ?
- ក្នុងករណីអ្វីខ្លះដែលអ្នកចង់សុំឱ្យមានការសំរុះសំរួល? តើការសំរុះសំរួលនេះមានន័យដូចម្ដេចចំពោះអ្នក?
- ក្នុងករណីមានអំពើហិង្សា តើមានអន្តរាគមពីអ្នកក្រៅដែរឬទេ?
- រូបអ្នក អ្នកជិតខាង ឬអ្នកណាម្នាក់ដែលអ្នកស្គាល់មានបញ្ហាជាមួយអ្នកដទៃ ឬក្រុមមួយដែរឬទេ?
- តើអ្នកអាចរៀបរាប់ប្រាប់យើងបានឬទេ? (រឿង និងការសំរុះសំរួល)
- តើអ្នកពេញចិត្តនឹងលទ្ធផលដែរឬទេ? តើអ្នកគិតឃើញដូចម្ដេច ពីរបៀបដែលគេចាត់ការនោះ ដំណើការនោះ?
- បើគេមិនរកឃើញដំណោះស្រាយណាមួយទេនោះ តើមានអ្វីកើតឡើង?
- តើអ្នកចាត់ទុកដូចម្ដេចដែរចំពោះសកម្មភាពរបស់អ្នកសំរុះសំរួលដូចជាប្រធានភូមិចាស់ទុំ...?
- តើអ្នកសំរុះសំរួលមានយុត្តិធម៌ឬទេ ឬក៏ជួនកាលគាត់មាននិន្នាការលំអៀងទៅរកមនុស្សខ្លះ? បើមាន គឺទៅរកអ្នកណា? ហេតុអ្វី?
- តើអ្នកគិតឃើញយ៉ាងណាពីយុត្តិធម៌ ដូចជានៅតុលាការខេត្ត? តើអ្នកចង់ទៅកន្លែងនោះដែរឬទេ? បើចង់ក្នុងករណីណាខ្លះ? បើមិនចង់ហេតុអ្វី?
- តើអ្នកចង់ឃើញបញ្ហារបស់អ្នកដោះស្រាយនៅថ្នាក់ភូមិដោយប្រើវិធីសំរុះសំរួល ឬចង់បានវិធីផ្សេង ទៀត? បើចង់បាន តើវិធីអ្វី?
- តើអ្នកដែលឮគេនិយាយពីសិទ្ធិមនុស្សដែរឬទេ? គេនិយាយថាយ៉ាងម៉េច? តើសិទ្ធិមនុស្សនោះមានន័យយ៉ាងដូចម្ដេចចំពោះអ្នក?
- តើអ្វីដែលធ្វើឱ្យអ្នកទៅជាប្រពន្ធល្អ? ប្ដីល្អ? តើមនុស្សប្រុសម្នាក់ និងស្ត្រីម្នាក់អាចរស់នៅតែឯកឯងបានដែរឬទេ?
- កាលណាបុរសម្នាក់វាយប្រពន្ធរបស់ខ្លួន តើនេះត្រូវចាត់ទុកថាជារឿងមួយដែលត្រូវដោះស្រាយក្នុងគ្រួសារ ឬត្រូវដាក់ទោសព្រហ្មទណ្ឌ?

**ទំនាក់ទំនងជាមួយអាជ្ញាធរ**

- បើតាមគំនិតអ្នក តើប្រធានភូមិមានតួនាទីអ្វី?
- ក្នុងហេតុផលអ្វី ដែលអ្នកទៅជួបប្រធានភូមិ? (ទំនាស់ ការសុំអនុញ្ញាតធ្វើអ្វីមួយ....)

- តើគាត់មានកេរ្តិ៍ឈ្មោះដូចម្តេចដែរ? ប្រៀបធៀបជាមួយភូមិដទៃ។
- តើប្រធានឃុំឈ្មោះអ្វី?
- តើអ្នកដែលទៅសាលាឃុំដែរ ឬទេ? ដើម្បីអ្វី? (ធ្វើសំបុត្រអាពាហ៍ពិពាហ៍?)
- តើប្រធានឃុំមានតួនាទីអ្វី? អភិបាលស្រុកមាននាទីអ្វី? តើមានអ្វីខុសគ្នារវាងប្រធានភូមិ និង ប្រធានឃុំ?
- តើអ្នកនឹងទៅពិគ្រោះផ្ទាល់ជាមួយប្រធានឃុំ ដោយមិនឆ្លងកាត់ប្រធានភូមិដែរ ឬទេ?
- តើអាជ្ញាធរណាដែលមកពីខាងក្រៅភូមិ? ដោយហេតុផលអ្វី?

អ្នកណាជាមនុស្សមានឥទ្ធិពលនៅក្នុងភូមិ? ហេតុអ្វីបានជាគាត់មានឥទ្ធិពល? (ញាតិរបស់ប្រធានភូមិ អ្នកមាន មន្ត្រីរាជការ យោធា តំណាងគណបក្សនយោបាយ ចៅអធិការវត្ត...)

តើចាស់ទុំ និងព្រះសង្ឃមានតួនាទីអ្វីនៅក្នុងភូមិ? ចូរប្រៀបធៀបជាមួយសម័យមុន តើអ្វីខ្លះបានផ្លាស់ប្តូរ ហេតុអ្វី?

សំណើដើម្បីកែលំអ វិធីបច្ចុប្បន្ន។

# គន្ថនិទ្ទេស

ANG Chulean-les êtres surnaturels dans la religion polpulaire, Cedoreck, Paris, 1986.

ANG Chulean-La communauté rurale khmère du point de vue du sacré-Journal Asiatique T.CCLXX VIII no 1-2.

AYMONIER Etienne-Le Cambodge-Paris: Ernst Leroux, 3 vol. 1900-1904.

AYMONIER Etienne-Notes sur les coutumes et croyances superstitieuses des cambodgiens-Excursions et reconnaissances, no 16, Saïgon, Paris, 1883, rééd. Cedoreck, Paris. 1994.

AVRUCH Kevin-Conflict resolution: cross-cultural perspectives-Greenwood Press, 1991.

BERNARD S., MARTINI F.- Contes populaires inédits du Cambodge, Paris, G.P. Maisonneuve, coll. "Documentation du folklore de tous les pays. 1946.

BRUGUIER Bruno- Bibliographie du Cambodge ancien, Paris, E.F.E.O, 1999-

BIT Seanglim-The Warrior heritage, Bit Seanglim ed, 1991.

R BERNSTEIN, E-Cambodia: "fermented fish" women stirring up the pot;" in Seeds of peace, vol 10, No. 1, Bangkok, Thailand. 1993.

BOEHNLEIN J-One year follow-up study of PTSD among survivors of Cambodia concentration camps 1985.

Buddhism and conflict resolution: a training seminar for Cambodians-Thai inter religious commission for development, 1992.

CHANDLER, D.P.-The tragedy of Cambodian history; politics, war and revolution since 1945. Yale University, New Heaven and London, UK, 1991.

CHANDLER, D.P. and Ben Kiernan eds-Revolution and its aftermath in Kampuchea: Eight Essays, New Heaven: Yale University Southeast Asia Studies, monograph series, No. 25, 1983.

CHANDLER, D.P.-A Hisotry of Cambodia, Boulder, West View Press, 1983.

COLLINS A Williams-Dynamics of Dispute Resolution and Administration of Justice for Cambodian Villagers-funded by USAID, Phnom Penh.

Commission des moeurs et coutumes du Cambodge-Cérémonies privées des Cambodgiens-Institut bouddhique, Phnom Penh, 1958.

Commission des moeurs et coutumes du Cambodge-Cérémonies des douzes mois. Fêtes annuelles cambodgiennes, rééd., Cedoreck, Paris, 1985.

Commission des moeurs et coutumes du Cambodge-La vie du paysan khmer-Institut bouddhique, Phnom Penh, 1969.

DAVENPORT P-Vulnerable in the village-a study of returnees in Battambang province, Cambodia, with a focus on strategies for the landless. OSB, Australia and World Vision Australia, 1995.

DEBRE François-La Révolution de la forêt-Flammarion, 1976.
DELVERT Jean-Le paysan Cambodgien-L'Harmattan, rééd 1994.

EBIHARA May-Svay, a Khmer Village in Cambodia-Michigan, Ann Arbor, University microfilms international, 2 T. 1971.

EMERSON Bridget-A Legacy of Conflict: Trauma as an obstacle to poverty alleviation in rural Cambodia, a focus on women, empowerment and NGO initiatives-funded by the International Development Research Center (IDRC), Phnom Penh 1997.

FOREST Alain-Le culte des génies protecteurs "neakta" au Cambodge-L'Harmattan, 1992.

FRINGS Viviane-le socialisme et le paysan cambodgien-L'Harmattan, Paris, 1997.

GAILLARD Maurice-La démocratie cambodgienne: la constitution du 24 septembre 1993. L'Harmattan, 1994

General Population Census of Cambodia 1998-National Institute of Statistics, Ministry of Planning, Phnom Penh, Cambodia, July 1999.

GITEAU Madeleine-"Un court traité d'architecture cambodgienne moderne". Arts Asiatiques, no. 24.

GITEAU Madeleine-"Au sujet de la construction des édifices". Arts Asiatiques, no 24, 1971.

HANNE Sophie-Greve-Land Tenure and Property Rights in Cambodia, Phnom Penh,1993.

HASSELSKOG Malin-Local Governance in Transition: Villagers' Perception and SEILA's Impact-UNDP/CARERE, Phnom Penh, 2000.

International Law Development Institute-"Mediation and Conciliation Techniques Alternative Dispute Resolution Methods for International Contracts" February 22-26, 1993, Phnom Penh, Cambodia.

IMBERT J.-Les institutions cambodgiennes-Ecole Royale d'Administration; Annales de la Faculté de Droit et de Sciences Economiques.

JENNAR Raoul Marc-L'action des ONG cambodgiennes dans le domaine de la culture de la paix: un état des lieux-Unesco, UNDP, Phnom Penh, 1997.

JENNAR Raoul Marc-Towards a "Culture of Peace" in Cambodia: 25 National Programme Proposals (phase 1: 1998-2000)-UNESCO, UNDP, Phnom Penh, 1998.

KALAB Milada-Study of a Cambodian Village- in: The Geographical Journal, vol. 134, The Royal Geographical Society, London, 1968.

KALAB Milada-Monastic education, social mobility and village structure in Cambodia- in: The anthropological study of education, Craig J, Calhoun a.j, Ianni eds., The Hauge, 1976.

KHAO Kim Houn-Cambodian Approach to Confict Resolution-Cambodian Institute for Cooperation and Peace, Phnom Penh, 1998.

KIERNAN Ben-Le génocide au Camboidge, Gallimard, 1998.

KING Janet, Rendall Matthew-Alternative Dispute Resolution-Community Legal Education Center, University of San Francisco School of Law: Cambodian Law and Democracy Project, 2000. Cambodian Legal Textbook Series.

KLEINPETER Roger-Le problème foncier au Cambodge-Paris, eds Domat-montchrestien, 1937.
KRISHNAMURTHY Veena-The impact of armed conflict on social capital: a study of two villages in Cambodia-study conducted for the World Bank by "Social Services of Cambodia", Phnom Penh, March 1999.

LECLERE Adémard-Cambodge: contes, légendes et Jatakas-Paris, Cedoreck 1984.

LEGERWOOD Judy-Portrait of a conflict: exploring changing khmer-*Journal of Refugee studies.* Vol 3, No. 2, 1990.

LIPTON M.-The State: Market Dilemma, Civil Society and Structural Adjustment. Any cross-cultural lessons? in Round table, 317, 1991.

LOCARD Henri-Le petit Livre rouge de Pol Pot, L'Harmattan, 1996.

LOPEZ VASQUEZ Carmen Maria-Pre-trial dispute resolution processes-The Cambodian Court Project, Phnom Penh, 96.

LUCIOLLI Esmeralda-le mur de bambou: Le Cambodge après Pol Pot-ed. Régimes Déforges/Medecins Sans Frontières. Coll. Deux milliards d'hommes, 1988.

MC CONNEL-Mindful Mediation: Buddhism Manual for Conflict Resolution, vol 1, CDRI, Phnom Penh

MCGREW Laura-Truth, Justice, Reconciliation and Peace in Cambodia: 20 Years After the Khmer Rouge-Funded by the Canadian Embassy, Dec 99-Feb 00, Phnom Penh.

MARTEL Gabrielle-Lovea, village des environs d'Angkor. Aspects démographiques, économiques et sociologiques du monde rural cambodgien dans la province de Siem Reap-EFEO, 1975.

MEAS Nee-Towards restoring life: Cambodian Villages-Krom Aphivat Phum, Battambang, Cambodia. 1995, JSRC, Phnom Penh.

MEYER Charles-Derrière le sourire khmer, Paris, Plon, 1971.

MIGOZZI Jaques-Cambodge, faits et problèmes de la population-Eds, CNRS, Paris, 1973.

MONOD G.H. - Contes Khmer-Paris, Cedoreck, 1985.

MONOD G.H. – Légendes cambodgiennes que m'a contées le gouveneur Khieu-Paris, Brossard, 1922.

MOORE Christopher – Mediation Process(the) : Practical strategies for resolving conflict-Jossey-bans publisher, 1996

MORIZON René – L'immatriculation foncière de la propriété individuelle au Cambodge-Eds Domart-Montchrestien, 1934.

MOURA J. – Le Royaume du Cambodge – Paris : Ernest Leroux, 1883.

MYSLIWIEC Eva, Morrise Catherine (Edited by) – Dispute Resolution in Cambodia: A Road to Peace and Reconciliation, proceeding of a conference held in Phnom Penh – sponsored by The Cambodian Devlopment Resource Institute, Phnom Penh, 28-30 Nov? 1997.

NEOU Kassie, Gallup Jeffrey C. – Human right, Democracy and Democratization in Cambodia five years after the Paris Agreement- Cambodian Institute of Human Right, Phnom Penh, 1996.

NEPOTE Jacque – Parenté et organisation sociale dans le cambodge moderne et contemporain-Etudes orientales; eds. Olizane, 1992.

OVESEN Jan, TRANKELL Ing-Britt, OJENDAL Joakhim – When every houseland is an island; Social organization and power structure in Rural Cambodia – Uppasala Research Reports in Cultural Anthropology, no.15, 1996.

PELLIOT P. – mémoires sur les coutumes de Cambodge de Tcheou Ta-Kouan – Adrien maison neuve, Paris, 1951,

PAVIE Auguste – Contes du Cambodge-Paris, E. Leroux, 1921.

POREE MASPERO Evelyne – Etude sur les rites agraires des Cambodgiens – 3 vol., Mouton and Cie, La Haye, Paris, t.I : 1952, t.II: 1964; t.III : 1969.

POREE Guy, MASPERO Evelyne – Moeurs et countumes des khmers-Paris, Payot, 1938.

PONCHAUD F. – Le Cambodge, année zéro – Juillard, 1977.

POU Saveros – Guirlande de Cpap, Cedoreck, 1988.

Recueil de contes khmer: histoires de juge Lièvre – Séries culture et civilisation khméres, fasc. 4, ed. de l'Intitute bouddhique, 1970.

ROS Chantrabot – La République khmère : 1970-1975 – L'harmattan, 1993

ROSS Marc Howard – Management of conflict (the) : interpretation and interests in comparative perspective – Yale University, United State of America, 1993.

SHAWCROSS William – Une tragédie sans importance, Balland-france Adel, 1979.

SOKHOM Hean – The portrayal of domestic violence in Cambodian newspapers-Center for Advanced study, Phnom Penh, 1999.

TAMBIAH S.J – World conqueror and world renouncer : a study of buddhism and policy in Thailand against a historical background, Cambridge, Cambridge University Press, 1976.

THIERRY Solange – Les Khmers - Seuil, coll. : le temps qui court, Paris, 1964.

THIERRY Solange – Contribution à une étude de la société cambodgienne – In : L'éthnographie, 58/59, 1964/65, pp. 50-71

UNDP (United Nation Development Programme) – Socio-economic survey of Cambodia (1993/94) – Phnom Penh, 1995.

UNFPA (United Nation Population Fund) – Cambodia: Demographic profile – Phnom Penh, 1995.

VICKERY Mikael – Cambodia 1975-82 – South end press, Boston, Massachusetts, USA, 1984.

VIGHEN John, Sarouen Ly – Customs of Patronage and community development in a Cambodian village – Cambodia Researchers for Development, Phnom Penh, June 1996.

ZIMMERMAN Cathy, "Plates in a basket will Rattle, Demestic Violence in Cambodia," edited by Brad Adams, Phnom Penh, Dec. 1994.

WILDE Vicki L – SEAGA – Socio Economic Gender Analysis – F.A.O. 1998.